♣ ♣ ♣

ចូរកុំភ្លេចខ្លួន រកធម៌អាថ៌

ពឹងត្រៃរតនា ចិត្តសទ្ធា

យកសីល សមាធិ ភាវនា

ទីពឹងនេះជា សុខសាន្តហើយ ៗ

♣ ♣ ♣

ភិក្ខុវិនយធរោ មហាយិន-នឿន

វត្តខ្មែរសាន់តាអាណា

2630 N. Grand Ave.
Santa Ana, CA 92705
(714) 744-2834
U.S.A.

ព.ស.២៥៥២

វិសុទ្ធិមគ្គប្រែ

ភាគទី២

វិសុទ្ធិមគ្គប្រែ

ភាគ ទី២

ប្រែដោយ

សាស្ត្រាចារ្យ រស់-សារទេន

រៀបរៀងដោយ

ភិក្ខុវិនយធរោ មហាយិន-នឿន

* * *

បោះពុម្ពផ្សាយជាធម្មទានចេញពី

វត្តខ្មែរសាន់តាអាណា

សហរដ្ឋអាមេរិក

លើកទី១

ចំនួន ៥,០០០ ក្បាល

រក្សាសិទ្ធិ

ព. ស. ២៥៥២

រូបំ ជីវិត មច្ចានំ នាមគោត្តំ ន ជីវិត

ភិក្ខុវិនយធរោ មហាយិន-នឿន

កើត ថ្ងៃទី១០ ខែកក្កដា ១៩៥២

ភូមិទួលព្រាំ ស្រុកមោងឫស្សី ខេត្តបាត់ដំបង

សាស្ត្រាចារ្យរស-សារេន

កើត ថ្ងៃទី០៧ ខែ០៥ ឆ្នាំ ១៩៣៨

នៅភូមិកោះសូជិន ស្រុកកោះសូជិន ខេត្តកំពង់ចាម

រូបកាយ របស់សត្វទាំងឡាយ តែងចាស់គ្រាំគ្រា

ចំណែកឯនាមនិងគោត្រមិនដែលចាស់ជរាឡើយ។

អារម្ភកថា

(របស់អ្នករៀបរៀង)

សៀវភៅ "បករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គប្រែ" ដែលសាធុជនអ្នកស្រឡាញ់ព្រះធម៌ កំពុងតែអានជាប់នឹងដៃនេះ បានកើតឡើងដោយព្រះរាជយោបល់នៃ សម្ដេចព្រះមហាឃោសានន្ទ (វ៉ា-យ៉ាវ) នៅពេលដែលខ្ញុំ (ភិក្ខុវិនយធរោ មហាឃិន-នឿន) បានយកគម្ពីរមង្គលត្ថទីបនីប្រែទាំងបួនភាគ ទៅថ្វាយសម្ដេច នៅវត្តសំពៅមាស ខែវិសាខ ឆ្នាំ កុរ ឆស័ក ព.ស. ២៥៣៩ គឺឆ្នាំ ១៩៩៥ នោះ ។ សម្ដេចទ្រង់បានមានព្រះរាជបន្ទូលថា "សៀវភៅមង្គលត្ថទីបនីប្រែ ទាំង ៤ ភាគនេះ ជួយជាប្រយោជន៍ ដល់ពុទ្ធបរិស័ទខ្មែរយើងបានច្រើនណាស់... បើអាចប្រែគម្ពីរ វិសុទ្ធិមគ្គ ទាំងបីភាគ [១] ដែលនៅជាភាសាបាលី មកជាភាសាសំរាយខ្មែរយើងបានទៀតនោះ គឺជាការប្រសើរណាស់ ព្រោះខ្មែរយើងសព្វថ្ងៃនេះ មានការខ្វះខាតក្បួនច្បាប់ ខាងផ្នែកព្រះពុទ្ធសាសនា ច្រើនណាស់ សូមប្រែនិងរៀបរៀងសៀវភៅ វិសុទ្ធិមគ្គ ទាំងបីភាគ ឲ្យបានជាបន្តទៅទៀត ដើម្បីជួយខ្មែរយើង..." ។

ហេតុនេះ ខ្ញុំក៏បានទទួលថា នឹងប្រែ ហើយរៀបរៀងធ្វើសៀវភៅវិសុទ្ធិមគ្គ នេះ ឲ្យបានសម្រេច សមតាមព្រះរាជយោបល់នៃសម្ដេចព្រះមហាឃោសានន្ទ ។ នៅក្នុងឆ្នាំកុរ ឆស័ក ព.ស ២៥៣៩ ដដែលនោះ ខ្ញុំក៏បានជួបប្រឹក្សា ជាមួយលោកសាស្ត្រាចារ្យជាច្រើនរូប ដែលកំពុងតែបង្រៀនសមណនិស្សិត នៅពុទ្ធិកវិទ្យាល័យ នាទីក្រុងភ្នំពេញ រួមមាន

១- គម្ពីរ វិសុទ្ធិមគ្គទាំងបីភាគ មានលោកអ្នកប្រែពីមុនមកខ្លះៗ ហើយដែរ ប៉ុន្តែមិនបានប្រែឲ្យចប់សព្វគ្រប់ទាំងអស់ទេ ប្រែកាត់ចោលបាលីភាគច្រើន គឺប្រែជ្រើសរើសយកតែសេចក្តីបែបខ្លីៗ មករៀបរៀងតែប៉ុណ្ណោះឯង ពុំបានចប់សព្វគ្រប់ទេ ។

លោកសាស្ត្រាចារ្យ រស់-សារេន, លោកសាស្ត្រាចារ្យ ឌិត-ឌន ហៅ ឃិន-សូត្រ) និង សាស្ត្រាចារ្យ ទែន-សុខន ជាដើម ដើម្បីរួមដៃគ្នាបកប្រែគម្ពីរ បករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ដែលនៅជាភាសាបាលីមកជាភាសាសម្រាយខ្មែរយើង ឲ្យបានចប់សព្វគ្រប់ទាំងបីភាគ ហើយក៏បានសំរេចគ្នាជាឯកច្ឆន្ទថា ឲ្យលោកសាស្ត្រាចារ្យ ជិត-ជន ទទួលប្រែភាគទី១ លោកសាស្ត្រាចារ្យ រស់-សាវេន ប្រែភាគទី២ [១] និង ឲ្យលោកសាស្ត្រាចារ្យ ទែន-សុខន ទទួលប្រែភាគទី៣ ហើយបានសំរេចឲ្យខ្ញុំជាអ្នកកែសំរួល ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និង រៀបរៀង ព្រមទាំងរកនូវបវិការដើម្បីបោះពុម្ពផង ។ បន្ទាប់ពីបានប្រឹក្សាគ្នារួចស្រេចហើយ យើងទាំងអស់គ្នា មានសេចក្តីរំភើបខ្លាំងណាស់ចំពោះកិច្ចការនេះ ។

នៅពេលដែលលោកសាស្ត្រាចារ្យទាំង ៣ បានបកប្រែមកជាភាសាខ្មែរយើងខ្លះៗ ហើយ ក៏បានបញ្ជូននូវសំណៅ ដែលសរសេរជាអក្សរដៃទៅឲ្យខ្ញុំ ដើម្បីកែសំរួលផ្ទៀងផ្ទាត់ និងរៀបរៀងជាបណ្តើរៗ ពេលដែលខ្ញុំបានទទួលសំណៅនោះហើយ ខ្ញុំបានយកទៅពិនិត្យផ្ទៀងផ្ទាត់ ជាមួយនឹងគម្ពីរវិសុទ្ធិមគ្គ ជាភាសាបាលី ដែលព្រះពុទ្ធឃោសាចារ្យ បានរៀបរៀងជាងមួយពាន់ឆ្នាំ កន្លងមកហើយនោះ ដើម្បីកុំឲ្យមានការខុសភ្លាំងភ្លាត់ពីភាសាបាលីដើមនោះ ដោយបានយកចិត្តទុកដាក់បំផុត... (តែបើមានការភ្លាំងភ្លាត់ដោយអចេតនា សូមលោកអ្នកអានជួយកែតម្រូវផង)។

ដូច្នេះ ការដែលលោកសាស្ត្រាចារ្យទាំងនោះ បកប្រែនេះ ខ្ញុំឃើញថា បានប្រែតាមព្រះត្រៃបិដកខ្លះ ប្រែផ្សេងពីព្រះត្រៃបិដកខ្លះ តែសេចក្តីនឹងអត្ថន័យមិនជាខុសគ្នាទេ ។ លុះខ្ញុំឃើញដូច្នេះ ខ្ញុំក៏បានកែសំរួលឲ្យ

១-សាស្ត្រាចារ្យជិត-ជនប្រែតពីសាស្ត្រាចារ្យរស់-សាវេនពីអនុស្សតិនិទ្ទេសដល់ចប់។

ត្រូវតាមព្រះត្រៃបិដកជាភាសាខ្មែរយើង ហើយខ្ញុំបានដាក់ជាលេខយោង ដើម្បីបញ្ជាក់ប្រាប់គម្ពីរ (ភាគ និង ទំព័រ) ឲ្យបានច្បាស់ និង ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវបន្ថែម សំរាប់សមណនិស្សិតនិងអ្នកបតិបត្តិ ។

ខ្ញុំបានយកសំណៅវិសុទ្ធិមគ្គប្រែ ភាគទី១ ដែលលោកសាស្ត្រាចារ្យ ជិត-ជន បានប្រែហើយនោះ មកកែសំរួល និង រៀបរៀង មុនគេបង្អស់ នៅក្នុងខែមាឃ ព.ស. ២៥៣៩ (១២ មីនា ឆ្នាំ ១៩៩៦) ហើយបាន ចប់សព្វគ្រប់ នៅថ្ងៃច័ន្ទ ៣ កើត ខែផល្គុណ ឆ្នាំជូត អដ្ឋស័ក ព.ស. ២៥៤០ ត្រូវនឹងថ្ងៃទី១០ ខែមីនា ១៩៩៧ ។

បន្ទាប់ពីរៀបរៀងភាគទី១ ចប់ហើយទើបខ្ញុំចាប់ផ្តើមកែសំរួលផ្ទៀងផ្ទាត់ ភាគទី៣ បន្តទៅទៀត ដែលលោកសាស្ត្រា ទែន-សុខន បានប្រែខ្លះៗហើយ ។ ជាអកុសល គួរឲ្យស្តាយខ្លាំងណាស់ លោកសាស្ត្រាចារ្យ ទែន-សុខន ប្រែបានពាក់កណ្តាលតែប៉ុណ្ណោះ លោកក៏បានអនិច្ចកម្មទៅ បន្សល់ទុកនូវភារៈនេះឲ្យទៅលោកសាស្ត្រាចារ្យ នូ-ឌឹម ទទួលប្រែបន្តទៅទៀត តែលោកសាស្ត្រា នូ-ឌឹម ប្រែបានតែបីបួនទំព័រ ក៏ឈប់ទៅវិញ ព្រោះមានការរវល់ខ្លាំងពេក ដូច្នេះភារៈនេះ ត្រូវធ្លាក់មកលើខ្ញុំអ្នករៀបរៀងទៅវិញ ហើយខ្ញុំក៏បានចាប់ផ្តើមប្រែ... និង បានចប់សព្វគ្រប់នៅថ្ងៃ ពុធ ៨ រោច ខែកត្តិក ឆ្នាំខាល សំរឹទ្ធិស័ក ព.ស. ២៥៤២ ត្រូវនឹង ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ។ ហើយបានឲ្យ ភិក្ខុ អឿ-សៅ ជួយវាយចម្លង... តែពុំទាន់បានសំរេចទេ ខ្ញុំត្រូវកែសាជាថ្មីម្តងទៀត ។

ចំណែកឯសំណៅ វិសុទ្ធិមគ្គប្រែ ភាគទី២ វិញនោះ ភិក្ខុ មហាសម-យស វត្តម៉ាក់ស៊ី នៅប្រទេសបារាំង ទទួលយកទៅកែសំរួល និង រៀបរៀង តែលោករវល់ខ្លាំងពេក ក៏បានប្រគល់មកឲ្យខ្ញុំកែសំរួល និង រៀប

រៀង នៅឯប្រទេសសហរដ្ឋអាមេរិកវិញ ខ្ញុំបានទទួលសំណៅវិសុទ្ធិមគ្គ ភាគទី២ ដែលលោកសាស្ត្រា រស់-សារះខេន ប្រែនោះ មកចាប់ផ្តើមកែសំរួល និង រៀបរៀង នៅថ្ងៃច័ន្ទ ៥ កើត ខែភទ្របទ ឆ្នាំច អដ្ឋស័ក ព.ស. ២៥៥០ ត្រូវនឹងថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៦ ហើយបានចប់សព្វគ្រប់ នៅថ្ងៃអង្គារ ៣កើត ខែចេត្រ ឆ្នាំជូត នព្វស័ក ព.ស. ២៥៥១ ត្រូវនឹងថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៨ ។

គម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះ ដែលក្របានបោះពុម្ពផ្សាយនោះ មកពីរង់ចាំភាគ ទី២ ផង និង ព្រោះពុំទាន់មានថវិកាគ្រប់គ្រាន់ផង ។

ក្នុងការប្រែរៀបរៀងនេះ ខ្ញុំសូមខន្តីអភ័យទោសអំពីសំណាក់ព្រះតេជះព្រះគុណ ព្រះថេរានុថេរៈ អស់លោកដែលឆ្លៀវឆ្លាតក្នុងភាសាខ្មែរ និងភាសាបាលី ហើយសូមមេត្តាអនុគ្រោះ ដល់អ្នករៀបរៀងផង ។ ខ្ញុំសូមទទួលនូវការរិះគន់ពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដែលបានឃើញកំហុសត្រង់កន្លែងណាទីមួយនោះ ហើយផ្តល់ជាយោបល ដើម្បីនឹងជួយកែលំអគម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះ ឲ្យបានល្អប្រសើរឡើង និង ដើម្បីជួយទ្រទ្រង់នូវអាយុជីវិត នៃព្រះពុទ្ធសាសនា របស់អង្គព្រះសម្មាសម្ពុទ្ធនៃយើង ឲ្យបានរីកចំរើន រុងរឿង រៀងតទៅមុខទៀត ។ សូមអរព្រះគុណ និង សូមអរគុណទុកជាមុន ។

ភិក្ខុវិនយធរោ មហាយិន-នឿន

វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក

ថ្ងៃច័ន្ទ ១៥ កើត ខែវិសាខ ឆ្នាំជូត សំរឹទ្ធិស័ក ព.ស. ២៥៥២

ត្រូវនឹងថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៨

សេចក្តីថ្លែងអំណរគុណ

ខ្ញុំអ្នករៀបរៀង សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ

-ចំពោះលោកសាស្ត្រាចារ្យទាំងបួនរូប ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ របស់លោក ហើយបានប្រឹងប្រែងប្រែគម្ពីរបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គទាំង ៣ ភាគនេះ ឲ្យបានសម្រេច សមដូចសេចក្តីប៉ងប្រាថ្នា តាំងតែពីដើមរៀងមក រហូតដល់ទីបញ្ចប់ ។

-ចំពោះភិក្ខុ ប្រាជ្ញ-សារាន និង ភិក្ខុ ហួត-ខ៉ែត ព្រមទាំងសហការីដែលបានជួយយកសំណៅវិសុទ្ធិមគ្គប្រែ អំពីលោកសាស្ត្រាចារ្យ ជិត-ជន មកឲ្យខ្ញុំដើម្បីកែសំរួល និង រៀបរៀង ។

-ចំពោះភិក្ខុ អឿ-សៅ ដែលបានយកចិត្តទុកដាក់ជួយវាយចម្លងគម្ពីរវិសុទ្ធិមគ្គប្រែ ភាគទី៣ និង ចំពោះព្រះមហា សម-យស ភាគ ទី២ ។

-ចំពោះសមណនិស្សិត និង សាស្ត្រាចារ្យមួយចំនួនទៀតជាពិសេសគឺលោកសាស្ត្រាចារ្យ នៅពុទ្ធិកវិទ្យាល័យ អ៊ុំខ-ឆួខ វត្តពោធិវាល ទីរួមខេត្តបាត់ដំបង ដែលត្រូវការគម្ពីរវិសុទ្ធិមគ្គប្រែទាំងបីភាគនេះ ជាងគេហើយទទួចចង់បាន និង ជំរុញ... ឲ្យខ្ញុំប្រញាប់រៀបរៀង ដើម្បីទុកជាប្រយោជន៍ដល់ព្រះពុទ្ធសាសនាផង និង ដល់សមណនិស្សិត ព្រមទាំងពុទ្ធបរិស័ទផង...ដែលជាហេតុធ្វើឲ្យខ្ញុំរឹងរឹតតែមានកម្លាំងកាយ-ចិត្តខិតខំកែសំរួល និពិត្យផ្ទៀងផ្ទាត់ និង រៀបរៀង ដើម្បីឲ្យបានសំរេចជាគម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះឡើង ។

-ចំពោះព្រះថេរានុថេរៈ ព្រមទាំងពុទ្ធបរិស័ទ គ្រប់មជ្ឈដ្ឋានទាំងអស់ដែលបានជួយឧបត្ថម្ភ ក្នុងធម្មទាននេះ ទាំងថវិកា ទាំងកម្លាំងប្រាជ្ញា និងស្មារតី តាំងតែពីដើមមក រហូតដល់គម្ពីរវិសុទ្ធិមគ្គប្រែនេះ ចប់បរិបូរ ។

ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសព្រះរាជកុសល ដែលកើតពីធម្មទានដ៏ថ្លៃថ្លានេះ ថ្វាយ

-សម្តេចព្រះមហាឃោសានន្ទ (វ៉ា-យ៉ាវ) សូមទ្រង់សោយនូវព្រះរាជមហាកុសលនេះ សមតាមព្រះរាជហឫទ័យ ។

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ទាំងមហានិកាយ ទាំងធម្មយុត្តដែលទ្រង់សោយនូវព្រះទីវង្គត កន្លងទៅហើយនោះ សូមព្រះអង្គទ្រង់សោយព្រះរាជមហាកុសលនេះ ។

សូមឧទ្ទិសកុសលនៃធម្មទានានិសង្សនេះ ប្រគេន

-ចំពោះព្រះថេរានុថេរៈព្រះសង្ឃសមណនិស្សិតដែលបានបូជាជីវិតដើម្បីព្រះពុទ្ធសាសនា សំរាប់ទុកឲ្យព្រះសង្ឃជំនាន់ក្រោយ បានយកធ្វើជាគំរូដ៏ល្អៗ... សូមបានទទួលបុណ្យកុសលនេះកុំបីខាន ។

-ចំពោះលោកសាស្ត្រាចារ្យ ឌៃន-សុខន ដែលបានកសាងធម្មទានខិតខំប្រែ គម្ពីរវិសុទ្ធិមគ្គ ភាគទី៣ ទោះជាពុំទាន់បានចប់ចុងចប់ដើម ក៏ដោយ នេះជាស្នាដៃមួយដ៏ល្អ សំរាប់ព្រះពុទ្ធសាសនា... សូមលោកសាស្ត្រាចារ្យបានទទួលនូវកុសលនេះ ហើយបានទៅកើត ក្នុងសុគតិភពសមតាមមនោរថទៅហោង ។

-ចំពោះអ្នកដឹកនាំ ពួកបញ្ញវន្ត អ្នកស្នេហាជាតិ យុវជនយុវតី ប្រជាពលរដ្ឋខ្មែរ គ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានបូជាជីវិត ដើម្បីមាតុភូមិដោយទឹកចិត្តដ៏ស្មោះត្រង់ សូមឲ្យវិញ្ញាណក្ខន្ធអ្នកទាំងនោះបានទទួលនូវកុសលនេះ សូមបានទៅកើត ក្នុងទីសុខទីសួគ៌ កុំបីខានឡើយ ។

សូមប្រគេនមគ្គផលដែលកើតអំពីធម្មទាននេះ ចំពោះព្រះតេជះព្រះគុណ ព្រះថេរានុថេរៈ ព្រះសង្ឃគ្រប់អង្គ ដែលបានជួយឧបត្ថម្ភ ក្នុងការ

បោះពុម្ពគម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះ ឲ្យបានសំរេចជាស្ថាពរ សូមព្រះអង្គមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់ និង ជាទីពឹងពាក់ពំនាក់អាស្រ័យដល់ពុទ្ធបរិស័ទទាំងឡាយតរៀងទៅ ។

សូមញាតិញោម ជាពុទ្ធបរិស័ទ អស់លោក លោកស្រី លោកយាយ លោកតា កុមារ កុមារីទាំងអស់ ដែលបានជួយឧបត្ថម្ភផងដែរនោះ បានទទួលនូវកុសលដែលកើតពីធម្មទាននេះស្មើៗ គ្នា ប្រាថ្នាយ៉ាងណាៗ សូមឲ្យបានសំរេច សមដូចសេចក្តីប្រាថ្នា ទៅហោង ។

សូមជូនបុណ្យកុសលនេះផងដែរ ដល់អ្នកដឹកនាំខ្មែរ គ្រប់ជាន់ថ្នាក់ គ្រប់គណៈបក្សទាំងអស់ សូមដឹកនាំប្រទេសជាតិ ប្រកបដោយជោគជ័យ ដើម្បីប្រយោជន៍សុខ ដល់ប្រជាជនដែលសង្ឃឹមទាំងស្រុងទៅលើមាគ៌ានៃការដឹកនាំដ៏ត្រឹមត្រូវ សុចរិត យុត្តិធម៌ និង សាមគ្គីភាព... ។

ខ្មែរសាមគ្គីគ្នា កម្ពុជាបានសុខ !
ខ្មែរបែកបាក់គ្នា កម្ពុជាវិនាស !

ខ្មែរត្រូវស្រឡាញ់ខ្មែរ
ខ្មែរត្រូវថែរក្សាទឹកដីខ្មែរ...កេរពីដូនតាឲ្យបានគង់វង់ល្អ

ភិក្ខុវិនយធរោ មហាយិន-នឿន

វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក

ថ្ងៃច័ន្ទ ១៥ កើត ខែវិសាខ ឆ្នាំជូត សំរិទ្ធិស័ក ព.ស. ២៥៥២
ត្រូវនឹងថ្ងៃទី ១៩ ខែឧសភា ២០០៨

អានិសង្សនៃការផ្សាយមេត្តាចិត្ត

ចូរសាធុជនទាំងប្រុសទាំងស្រី   ប្រញាប់ឃ្នាតខ្មីផ្សាយមេត្តាចិត្ត
ជារៀងរាល់ថ្ងៃប្រពៃពេកពិត   ឲ្យបាននៃបនិត្យនៅក្នុងចិន្តា ។

អានិសង្ស១១ដែលព្រះទ្រង់ញាណ   ទេសនាទូន្មានប្រសើរអស្ចារ្យ
ផ្សាយមេត្តាចិត្តគេងលក់សុខជា   ភ្ញាក់ឡើងដូចគ្នាសប្បាយពេកក្រៃ។

យល់សប្តិចំឡែកអាក្រក់ទាំងឡាយ   វិនាសខ្ចាត់ខ្ចាយទាំងយប់ទាំងថ្ងៃ
ពួកមនុស្សស្រឡាញ់មិនឲ្យមានភ័យ   ចិន្តាថ្លាថ្លៃរាប់អានរកគ្នា ។

ទាំងពួកអមនុស្សមានចិត្តស្រឡាញ់   មិនមានចិត្តខ្នាញ់មកជួយការពារ
ទាំងពួកទេវតារក្សាដូចគ្នា   ឲ្យបានសុខជាប្រសើរថ្លៃថ្លា ។

ភ្លើងនិងថ្នាំពិសទាំងសស្ត្រាវុធ   មិនអាចប៉ះមុតត្រូវដល់កាយា
ចិត្តកើតសមាធិស្ងប់ល្អអស្ចារ្យ   ទឹកមុខថ្លៃថ្លាស្រស់ល្អប្រិមប្រិយ ។

នឹងមិនវង្វេងនៅពេលទៀបស្លាប់   ព្រះពុទ្ធទ្រង់ប្រាប់ថាមានស្មារតី
បើមិនទាន់បានគុណធម៌ប្រពៃ   ជាព្រះអរិយបុគ្គលថ្លៃថ្លា ។

នឹងបានទៅកើតនៅឯព្រហ្មលោក   រំសាយទុក្ខសោកសប្បាយក្រៃណា
ព្រោះមេត្តាចិត្តអាណិតដល់គ្នា   កំចាត់វេរាព្យាបាទចង្រៃ ។

ផ្សាយឲ្យខ្លួនឯងនិងមនុស្សទាំងឡាយ   ឲ្យបានសប្បាយរៀងរាល់យប់ថ្ងៃ
កុំចងកម្មពៀរនឹងគ្នាធ្វើអ្វី   រំលត់ទុក្ខភ័យដោយចិត្តមេត្តា ។

ភិក្ខុ មហាយិន-នឿន

ឯកសារជំនួយ

១- ព្រះត្រៃបិដកខ្មែរ ។

២- វិសុទ្ធិមគ្គបាលី ភាគទី ១-២-៣ ។

៣- វិសុទ្ធិមគ្គសង្ខេប អាចារ្យអ៊ុច-រស់ និង អាចារ្យឈឹម-ទូច

៤- សទ្ទានុក្រមបាលី-ខ្មែរ ចេញថ្មី ឆ្នាំ ២៥៥១

៥- បទានុក្រមធម្មបទ ភាគ ១-២-៣ ។

៦- អភិធានប្បទីបិកា មឹង-សេស

៧- វិធីប្រែបាលី

៨- មង្គលត្ថទីបនីប្រែ ភាគទី ១-២-៣-៤

៩- វចនានុក្រមខ្មែរ ភាគ ១-២ សម្តេចជួន-ណាត

១០- ធាតុប្បទីបិកា

១១- ប្រជុំភាណវារៈបាលី-ប្រែ ពិសេស

១២□ សម្ពន្ធមាលា និង ឯកសារផ្សេងៗ មួយចំនួនទៀត ។

អក្សរសង្ខេប ប្រើក្នុងលេខយោង

អភិ.	ធា.	គឺ	អភិធម្មបិដក	ធាតុកថា
អភិ.	ប	គឺ	អភិធម្មបិដក	បដ្ឋាន
អភិ.	វិ.	គឺ	អភិធម្មបិដក	វិភង្គ
អភិ.	សំ.	គឺ	អភិធម្មបិដក	សង្គណិ
សុ.		គឺ	សុត្តន្តបិដក	
អំ.	អ.	គឺ	អង្គុត្តរនិកាយ	អដ្ឋកនិបាត
អំ.	ឯ.	គឺ	អង្គុត្តរនិកាយ	ឯកនិបាត
អំ.	ឯក.	គឺ	អង្គុត្តរនិកាយ	ឯកាទសកនិបាត
អំ.	ច.	គឺ	អង្គុត្តរនិកាយ	ចតុក្កនិបាត
អំ.	ឆ.	គឺ	អង្គុត្តរនិកាយ	ឆកនិបាត
អំ.	តិ.	គឺ	អង្គុត្តរនិកាយ	តិកនិបាត
អំ.	ទ.	គឺ	អង្គុត្តរនិកាយ	ទសកនិបាត
អំ.	ន.	គឺ	អង្គុត្តរនិកាយ	នវកនិបាត
អំ.	ប.	គឺ	អង្គុត្តរនិកាយ	បញ្ចកនិបាត
អំ.	ស.	គឺ	អង្គុត្តរនិកាយ	សត្តកនិបាត
ខុ.	ឥ.	គឺ	ខុទ្ទកនិកាយ	ឥតិវុត្តកៈ
ខុ.	ឧ.	គឺ	ខុទ្ទកនិកាយ	ឧទាន
ខុ.	ខុ.	គឺ	ខុទ្ទកនិកាយ	ខុទ្ទកបាឋ
ខុ.	ចុ.	គឺ	ខុទ្ទកនិកាយ	ចុឡនិទ្ទេស
ខុ.	ជា. ឯ.	គឺ	ខុទ្ទកនិកាយ	ជាតក ឯកនិបាត
ខុ.	ជា. តិ.	គឺ	ខុទ្ទកនិកាយ	ជាតក តិកនិបាត
ខុ.	ធម្ម.	គឺ	ខុទ្ទកនិកាយ	ធម្មបទ
ខុ.	បដិ.	គឺ	ខុទ្ទកនិកាយ	បដិសម្ភិទាមគ្គ
ខុ.	មហា.	គឺ	ខុទ្ទកនិកាយ	មហានិទ្ទេស
ខុ.	សុ.	គឺ	ខុទ្ទកនិកាយ	សុត្តនិបាត
ទី.	បា.	គឺ	ទីឃនិកាយ	បាដិកវគ្គ
ទី.	ម.	គឺ	ទីឃនិកាយ	មហាវគ្គ
ទី.	សី.	គឺ	ទីឃនិកាយ	សីលក្ខន្ធវគ្គ
ម.	ឧ.	គឺ	មជ្ឈិមនិកាយ	ឧបរិបណ្ណាសក
ម.	ម.	គឺ	មជ្ឈិមនិកាយ	មជ្ឈិមបណ្ណាសក
ម.	មូ.	គឺ	មជ្ឈិមនិកាយ	មូលបណ្ណាសក
វិ.	ម.	គឺ	វិន័យបិដក	មហាវិភង្គ
វិ.	ប.	គឺ	វិន័យបិដក	បរិវារ
វិ.	ម. ម.	គឺ	វិន័យបិដក	មហាវិភង្គ មហាខន្ធក
សំ.	ខ.	គឺ	សំយុត្តនិកាយ	ខន្ធវារវគ្គ
សំ.	និ.	គឺ	សំយុត្តនិកាយ	និទានវគ្គ
សំ.	ម.	គឺ	សំយុត្តនិកាយ	មហាវគ្គ
សំ.	សគ.	គឺ	សំយុត្តនិកាយ	សគាថវគ្គ
សំ.	ស.	គឺ	សំយុត្តនិកាយ	សឡាយតនវគ្គ

ចូរកុំភ្លេចខ្លួនរកធម៌អាថ៌

សង្ខារទាំងឡាយមិនទៀងទាត់ កើតហើយវិបត្តិវិនាសសូន្យ
កើតចាស់ឈឺស្លាប់ធម៌ទាំងបួន មាននៅគ្រប់ខ្លួនគ្រប់អាត្មា ។

គ្មានសត្វណាមួយនឹងចៀសផុត លុះដល់កំណត់ត្រូវមរណា
ព្រាត់ប្រាសគ្មានសល់សព្វសង្ខារ គ្រប់ជនជីវ៉ាទាំងអស់គ្នា ។

ចូរកុំភ្លេចខ្លួនរកធម៌អាថ៌ ពឹងត្រៃរតនាចិត្តសទ្ធា
យកសីល សមាធិ ភាវនា ទីពឹងនេះជាសុខសាន្តអើយ ។

♣ ♣ ♣

ភិក្ខុវិនយធរោ មហាយិន-នឿន

បករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គប្រែ

ភាគទី ២

អនុស្សតិកម្មដ្ឋាននិទ្ទេស

(មរណស្សតិ)

(១៤១) ក្នុងកាលឥឡូវនេះ ការសំដែងចេញនូវកិរិយាចំរើននូវមរណស្សតិ បន្ទាប់អំពីទេវតានុស្សតិនេះ ដល់ហើយតាមលំដាប់ ។ ការចូលទៅផ្តាច់បង់នូវជីវិតិន្ទ្រិយ ដែលលោករាប់បញ្ចូលហើយ ក្នុងភពមួយ ឈ្មោះថាមរណៈ ក្នុងពាក្យថា "មរណស្សតិ" នោះ ។ ចំណែកខាងមរណៈនេះណា ពោលគឺកិរិយាចូលទៅផ្តាច់បង់នូវទុក្ខ ក្នុងវដ្ត នៃព្រះអរហន្តទាំងឡាយ មរណស្សតិនោះ ឈ្មោះថា សមុច្ឆេទមរណៈ, មរណៈណា ពោលគឺកិរិយាបែកធ្លាយក្នុងខណៈ នៃសង្ខារទាំងឡាយ មរណៈនោះ ឈ្មោះថា ខណិកមរណៈ, មរណៈណា ក្នុងប្រយោគទាំងឡាយ មានប្រយោគដូច្នេះជាដើមថា "ឈើងាប់ លោហៈងាប់" មរណៈនោះ ឈ្មោះថា សម្មតិមរណៈ ។ មរណៈ ៣ ប្រការនោះ គឺព្រះមានព្រះភាគ មិនទ្រង់ព្រះបំណងយកហើយ ក្នុងនិទ្ទេសនេះ ។ ចំណែកខាងមរណៈនេះណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ព្រះបំណងយកហើយ មរណៈនោះ មាន ២ ប្រការ គឺ: កាលមរណៈ ១ អកាលមរណៈ ១ ។ បណ្តាមរណៈទាំង ២ ប្រការនោះ កាលមរណៈ រមែងមានព្រោះកិរិយាអស់បុណ្យខ្លះ ព្រោះអស់អាយុខ្លះ ព្រោះអស់បុណ្យ និង អាយុទាំង ២ ខ្លះ, អកាលមរណៈ រមែងមាន ដោយអំណាចនៃកម្មដែលចូលទៅផ្តាច់បង់នូវកម្ម ។ ក៏បណ្តាមរណៈទាំង ២ នោះ មរណៈណា នាកាលកិរិយា

ដល់ព្រម នៃបច្ច័យជាគ្រឿង ត នូវអាយុ ទុកជាកាលមាន រមែងមាន ព្រោះភាវៈនៃកម្មដែលញ៉ាំងបដិសន្ធិឲ្យកើត ជាកម្មមានវិបាកឆ្អិន ដោយវិសេសតែប៉ុណ្ណោះ មរណៈនេះ ឈ្មោះថា មរណៈ ព្រោះអស់បុណ្យ ។ មរណៈណា រមែងមាន ដោយអំណាចនៃកិរិយាអស់ទៅនៃអាយុ មានប្រមាណត្រឹមតែមួយរយឆ្នាំ បីដូចជាអាយុរបស់បុរស ក្នុងពេលសព្វថ្ងៃនេះ ព្រោះកិរិយាមិនមាននៃសម្បត្តិ មានគតិ កាល និង អាហារ ជាដើម មរណៈនេះ ឈ្មោះថា មរណៈព្រោះអស់អាយុ។ ចំណែកមរណៈណា មានដល់បុគ្គលទាំងឡាយ អ្នកមានបច្ច័យជាគ្រឿង ត (នូវអាយុ) ត្រូវកម្មដែលអាចក្នុងកិរិយាញ៉ាំងសត្វឲ្យឃ្លាតចាកទី ក្នុងខណៈនោះឯងចូលទៅផ្តាច់បង់ ដូចជាមនុស្សបាបទាំងឡាយ មានព្រះបាទទុសីមារ និង ព្រះបាទកលាពុជាដើមក្តី ដល់បុគ្គលទាំងឡាយអ្នកមានបច្ច័យជាគ្រឿង ត (នូវអាយុ) ចូលទៅផ្តាច់បង់ ដោយសេចក្តីព្យាយាម មានកិរិយាប្រើនូវគ្រឿងសស្ត្រាជាដើម ដោយអំណាចនៃកម្ម ដែលមានក្នុងកាលមុនក្តី មរណៈនេះ ឈ្មោះថា អកាលមរណៈ ។ មរណៈទាំងអស់នោះ គឺលោកសង្គ្រោះហើយ ដោយកិរិយាចូលទៅផ្តាច់បង់នូវជីវិតិន្ទ្រិយ មានប្រការដូចបានពោលមកហើយ ។ សេចក្តីរលឹកនូវសេចក្តីស្លាប់ ពោលគឺកិរិយាចូលទៅផ្តាច់បង់នូវជីវិតិន្ទ្រិយ ដូចថ្លែងមកនេះ ឈ្មោះថា មរណស្សតិ ។

(វិធីចំរើនមរណស្សតិ)

ព្រះយោគាវចរអ្នកមានបំណងដើម្បីចំរើនមរណស្សតិនោះ គប្បីទៅក្នុងទីស្ងាត់ គេចចេញចាកអារម្មណ៍ សម្ងំនៅ ទោះបីញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅ ដោយឧបាយនៃប្រាជ្ញា ថា "សេចក្តីស្លាប់នឹងមាន ជីវិត-

ន្ទ្រិយ នឹងដាច់សូន្យ” ដូច្នេះក្តី ឬ ថា “មរណៈៗ” ដូច្នេះក្តី ។ ព្រោះថា កាលព្រះយោគាវចរ ញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅ ដោយឧបាយមិនជាប្រាជ្ញា, សេចក្តីសោករមែងកើតឡើង ក្នុងកិរិយារលឹករឿយៗនូវសេចក្តីស្លាប់ នៃជនជាទីស្រឡាញ់ ដូចជាសេចក្តីសោក កើតឡើង ក្នុងកិរិយារលឹករឿយៗ នូវសេចក្តីស្លាប់ នៃកូនជាទីស្រឡាញ់ របស់មាតាបង្កើតយ៉ាងដូច្នោះឯង, សេចក្តីប្រាមោជ្ជ រមែងកើតឡើង ក្នុងការរលឹករឿយៗ នូវសេចក្តីស្លាប់ នៃជនមិនជាទីស្រឡាញ់ ដូចជាសេចក្តីប្រាមោជ្ជ កើតឡើង ដល់ជនអ្នកមានពៀរទាំងឡាយ ក្នុងការរលឹករឿយៗ នូវសេចក្តីស្លាប់ នៃជនអ្នកមានពៀរទាំងឡាយ ដូច្នោះដែរ, សេចក្តីសង្វេគ នឹងមិនកើតឡើង ក្នុងកិរិយារលឹករឿយៗនូវសេចក្តីស្លាប់ នៃជនជាកណ្តាល ដូចជាសេចក្តីសង្វេគ មិនកើតឡើង ដល់ជនអ្នកដុតនូវសាកសព ក្នុងកិរិយាឃើញនូវសាកសពនៃខ្មោច ដូច្នោះ, សេចក្តីតក់ស្លុត រមែងកើតឡើង ក្នុងកិរិយារលឹករឿយៗ នូវសេចក្តីស្លាប់របស់ខ្លួន ដូចជាសេចក្តីតក់ស្លុត កើតឡើងដល់ជនអ្នកប្រកបដោយជាតិជាអ្នកខ្លាច ព្រោះឃើញនូវពេជ្ឈឃាត ដែលមានដាវងារឡើង ។ ការកើតឡើងនៃសេចក្តីសោកជាដើមទាំងអស់នេះនោះ រមែងមាន ដល់បុគ្គលអ្នកដែលនៅប្រាសចាកសតិ សង្វេគៈ និង ញាណ ។ ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីរមិលមើល នូវសត្វដែលត្រូវគេសម្លាប់ នឹងសត្វដែលស្លាប់ហើយ ក្នុងទីនោះៗ ហើយពិចារណា នូវសេចក្តីស្លាប់ របស់ពួកសត្វដែលស្លាប់ហើយ មានសម្បត្តិដែលខ្លួនធ្លាប់ឃើញហើយ ហើយប្រកបនូវសតិ សង្វេគៈ និង ញាណ ហើយញ៉ាំងមនសិការ ឲ្យប្រព្រឹត្តទៅ ដោយន័យជាដើម ថា “សេចក្តីស្លាប់នឹងមាន” ដូច្នេះ ។ ព្រោះថា ព្រះយោគាវចរ

កាលញ៉ាំងមនសិការ ឲ្យប្រព្រឹត្តទៅយ៉ាងនេះ ឈ្មោះថា ឲ្យប្រព្រឹត្តទៅដោយឧបាយនៃប្រាជ្ញា អធិប្បាយថា ឲ្យប្រព្រឹត្តទៅដោយឧបាយ ។ ពិតមែនហើយ កាលព្រះយោគាវចរពួកខ្លះ ញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅយ៉ាងដូច្នេះឯង, នីវរណៈទាំងឡាយ រមែងស្ងប់រម្ងាប់, សតិ ដែលមានមរណៈជាអារម្មណ៍ រមែងតាំងនៅព្រម, កម្មដ្ឋាន រមែងដល់នូវឧបចារៈមែនពិត ។

(ការរលឹកដោយអាការៈ ៨)

តែថា កម្មដ្ឋាន មិនមានដល់ព្រះយោគាវចរណា ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះយោគាវចរនោះ គប្បីរលឹករឿយៗ នូវសេចក្តីស្លាប់ ដោយអាការៈ ៨ នេះ គឺ :

ដោយកិរិយាប្រាកដដូចជាពេជ្ឈឃាត ១,

ដោយវិបត្តិនៃសម្បត្តិ ១,

ដោយសេចក្តីប្រៀបធៀប ១,

ដោយកាយជាសាធារណៈដល់សត្វច្រើន ១,

ដោយអាយុមានកម្លាំងខ្សោយ ១,

ដោយជីវិតមិនមានគ្រឿងសម្គាល់ ១,

ដោយកិរិយាកំណត់នូវកាល ១,

ដោយជីវិតមានខណៈតិច ១ ។

(អធិប្បាយអាការៈ ទី១)

(១៤២) បណ្តាបទទាំងនោះ បទថា “វធកប្បច្ចុបដ្ឋានតោ” មានសេចក្តីថា ដោយកិរិយាប្រាកដដូចជាពេជ្ឈឃាត ។ អធិប្បាយថា ព្រះយោគាវចរ គប្បីរលឹករឿយៗ ថា : ពេជ្ឈឃាត គិតថា “អញនឹងកាត់

នូវក្បាលនៃបុរសនេះ” ដូច្នេះហើយ ចាប់យកដាវមកផ្ទាប់ត្រង់-ក ឈរនៅប្រាកដ យ៉ាងណាមិញ, សូម្បីសេចក្ដីស្លាប់ក៏ប្រាកដយ៉ាងនោះដែរ ។ សួរថា ព្រោះហេតុអ្វី? ។ ឆ្លើយថា ព្រោះសេចក្ដីស្លាប់មកហើយ ជាមួយនឹងជាតិផង ព្រោះវានាំយកនូវជីវិតទៅផង ។ ដូចជាផ្សិតក្បាលពស់នៅក្រពុំ ទូលយកអាចម៍ដី ផុសឡើង យ៉ាងណាមិញ, សត្វទាំងឡាយតែងនាំយកនូវជរា និង មរណៈ ហើយកើតឡើង ក៏យ៉ាងដូច្នោះដែរ ។ ពិតដូច្នោះមែន បដិសន្ធិចិត្ត នៃសត្វទាំងឡាយនោះ ក៏រមែងដល់នូវសេចក្ដីគ្រាំគ្រា ក្នុងលំដាប់នៃកិរិយាកើតឡើងនោះឯង ហើយបែកធ្លាយ មួយអន្លើដោយខន្ធដែលប្រកបព្រមហើយទាំងឡាយ ដូចជាដុំថ្មដែលរមៀលធ្លាក់ចុះមកពីលើកំពូលភ្នំ (បែក) យ៉ាងនោះដែរ ។ ខណិកមរណៈ មកហើយ មួយអន្លើដោយជាតិមុន យ៉ាងនេះឯង ។ តែសូម្បីមរណៈ ដែលលោកបំណងយកហើយ ក្នុងមរណស្សតិនេះ ក៏មកហើយ មួយអន្លើដោយជាតិ ព្រោះសត្វដែលកើតមកហើយត្រូវតែស្លាប់មែនពិត។ ព្រោះហេតុនោះ សត្វនេះ ចាប់ដើមអំពីកាលដែលកើតមកហើយ ក៏មានមុខឆ្ពោះទៅកាន់សេចក្ដីស្លាប់ ទៅមិនត្រឡប់មកវិញឡើយ សូម្បីបន្តិចបន្តួច ប្រៀបបាននឹងព្រះអាទិត្យ ដែលរះឡើងហើយ មានមុខឆ្ពោះទៅកាន់ទីតាំងនៅមិនបាន ចេះតែទៅ មិនត្រឡប់វិញ អំពីទីដែលខ្វួនទៅហើយៗ សូម្បីតែបន្តិចបន្តួច ពុំនោះសោត ប្រៀបដូចជាស្ទឹងតូច ហូរធ្លាក់ចុះអំពីភ្នំ មានខ្សែទឹកលឿន នាំយកនូវវត្ថុដែលគួរនាំយកទៅ ចេះតែហូរទៅ ចេះតែទ្របាញ់ទៅតែម្យ៉ាង មិនត្រឡប់មកវិញឡើយ សូម្បីតែបន្តិចបន្តួច ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ ទើបព្រះអយោឃរកុមារពោធិសត្វពោលថា :

សត្វ នៅក្នុងគភ៌ អស់រាត្រីណាមួយជាដំបូង សត្វនោះ
ប្រព្រឹត្តទៅ ដូចជាពពកដែលតាំងឡើង សត្វនោះចេះ
តែទៅរឿយៗ មិនដែលត្រឡប់វិលវិញទេ [១] ។

មួយទៀត កាលសត្វនោះ ចេះតែទៅ យ៉ាងដូច្នេះ, សេចក្ដីស្លាប់ចេះតែមកជិតបង្កើយ ដូចជាកិរិយារីងស្ងួតនៃស្ទឹងតូចទាំងឡាយ ដែលត្រូវកំដៅថ្ងៃ ក្នុងគិម្ហរដូវផង ដូចជាការធ្លាក់ចុះ នៃផ្លែឈើទាំងឡាយ ដែលមានទងប្រព្រឹត្តទៅតាមរសនៃអាបោ ក្នុងពេលព្រឹកផង ដូចជាការបែកធ្លាយ នៃភាជនៈដីទាំងឡាយ ដែលត្រូវគេវាយបំបែកហើយ ដោយដំបងបួនជ្រុងផង និង ដូចជាការកំចាត់បង់នូវតំណក់ នៃទឹកសន្សើមទាំងឡាយ ដែលត្រូវរស្មីព្រះអាទិត្យពាល់ត្រូវហើយផង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់គាថា ៣ ជាដំបូង និង ព្រះពោធិសត្វពោលគាថា ទី ៤ ថា :

ថ្ងៃនិងយប់ ចេះតែកន្លងទៅ, ជីវិតចេះតែថយចុះ
មក, អាយុរបស់សត្វទាំងឡាយចេះតែអស់ទៅ ដូចជា
ទឹកស្ទឹងតូច ចេះតែរីងស្ងួតទៅ យ៉ាងនោះឯង [២] ។

ផ្លែឈើទាំងឡាយដែលទុំហើយ តែងភ័យអំពីការ
ជ្រុះចុះចាកដើម អំពីព្រលឹម យ៉ាងណាមិញ, សត្វទាំង
ឡាយដែលកើតមកហើយ តែងភ័យអំពីសេចក្ដីស្លាប់
អស់កាលជានិច្ច ក៏យ៉ាងដូច្នោះដែរ ។

ភាជន៍ដីដែលនាយស្មូនឆ្នាំងធ្វើហើយ ទោះតូចក្ដី

១- សុ. ខុ. ភាគទី ៦០ ទំព័រ ១៨២ ។ ២- សំ. សគ. ភាគទី២៩ ទំព័រ ២៩៧ ។

ធំក្តី ភ្និនក្តី ឆៅក្តី សុទ្ធតែមានការបែកធ្លាយទៅជាទីបំផុតទាំងអស់ យ៉ាងណាមិញ, ជីវិត របស់សត្វទាំងឡាយ ក៏យ៉ាងដូច្នោះដែរ (១) ។

ទឹកសន្សើម លើចុងស្មៅ តែងជ្រុះធ្លាក់ ព្រោះកិរិយារះឡើង នៃព្រះអាទិត្យ យ៉ាងណាមិញ, អាយុរបស់មនុស្សទាំងឡាយ ក៏យ៉ាងនោះដែរ, បពិត្រម៉ែ សូមម៉ែកុំហាមឃាត់ខ្ញុំឡើយ ។

មរណៈមកហើយជាមួយនឹងជាតិ ដូចជាពេជ្ឈឃាត មានដាវងាឡើងហើយ យ៉ាងនេះ ។ មួយទៀត មរណៈនេះនោះ ចេះតែនាំយកនូវជីវិតទៅតែម្យ៉ាង លុះនាំយកទៅហើយ ក៏មិននាំយកមកវិញឡើយ ដូចជាពេជ្ឈឃាតនោះ នាំយកដាវ(ដាក់)ត្រង់-ក ដូច្នោះឯង ។ ព្រោះហេតុនោះ សេចក្តីស្លាប់ ឈ្មោះថាជាធម្មជាតប្រាកដមែនពិត ដូចពេជ្ឈឃាតដែលមានដាវងាឡើងហើយ ព្រោះមរណៈមកហើយ ជាមួយនឹងជាតិផងព្រោះនាំយកនូវជីវិតទៅជាមួយផង ដូច្នេះឯង ។ ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់រឿយៗ ដោយកិរិយាប្រាកដដូចជាពេជ្ឈឃាត យ៉ាងដូច្នេះឯង ។

(អធិប្បាយអាការៈ ទី២)

(១៤៣) បទថា “សម្បត្តិវិបត្តិតោ” អធិប្បាយថា : ដរាបណាវិបត្តិ មិនគ្របសង្កត់នូវសម្បត្តិនោះ ដរាបនោះ ឈ្មោះថាសម្បត្តិ ក្នុងលោកនេះ តែងនៅល្អស្អាត ។ តែថា ឈ្មោះថាសម្បត្តិ ដែលកន្លងនូវ

១- សុ. ទី. ម. ភាគទី ១៦ ទំព័រទី ២៥៦ ។

វិបត្តិទៅបាននោះ ពិតជាមិនមានសោះឡើយ ។ ពិតដូច្នោះមែន

សូម្បីព្រះបាទអសោក ទ្រង់មានសេចក្តីសុខ ទ្រង់គ្រប់គ្រងសម្បត្តិលើផែនដីទាំងមូល ទ្រង់ចាយព្រះរាជទ្រព្យ ១០០ កោដិ ទ្រង់ដល់នូវភាពជាធំ ក្នុងទីបំផុត នៃវត្ថុត្រឹមតែផ្លែកន្ទួតព្រៃ ពាក់កណ្តាលប៉ុណ្ណោះ, នាកាលបុណ្យមកដល់កិរិយាអស់ហើយ ដោយចំណងគឺរាងកាយនោះឯង ព្រះអង្គទ្រង់មានព្រះភក្ត្រឆ្ពោះទៅរកសេចក្តីស្លាប់ ទ្រង់ជួបនូវសេចក្តីសោកសៅ ។

មួយទៀត សេចក្តីមិនមានរោគទាំងអស់ មានព្យាធិជាទីបំផុត វ័យទាំងអស់ មានជរាជាទីបំផុត ជីវិតទាំងអស់ មានសេចក្តីស្លាប់ជាទីបំផុត លោកសន្និវាសទាំងអស់ហ្នឹងឯង គឺជាតិទៅតាមហើយ គឺជរាដេញតាមហើយ ត្រូវព្យាធិគ្របសង្កត់ហើយ ត្រូវមរណៈកំចាត់បង់ហើយ ។ ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ ថា :

ភ្នំទាំងឡាយ ដែលជាថ្មតាន់ដ៏ធំ (១) មានកំពូលខ្ពស់ទល់នឹងអាកាស កាលបើរបើកធ្លាក់មក ក៏គប្បីរមៀលសង្កត់ (នូវសត្វទាំងឡាយ) ដោយជុំវិញគ្រប់ទិសទាំងបួន យ៉ាងណាមិញ, ជរា និងមរណៈ តែងគ្របសង្កត់នូវសត្វទាំងឡាយ ទោះជាក្សត្រក្តី ព្រាហ្មណ៍ក្តី អ្នកជំនួញក្តី អ្នកគ្រួក្តី ទោះជាមនុស្សចណ្ឌាល និង អ្នកចោលសំរាមក្តី តែងញាំញីទាំងអស់ មិនមានលើកលែងសត្វណានីមួយសោះឡើយ ក៏យ៉ាងដូច្នោះឯង ។

១- សំ. សគ. ភាគទី ២៩ ទំព័រទី ២៩៧ ។

ក្នុងជរា និង មរណៈនោះ ភូមិនៃពលដំរី មិនមាន ភូមិនៃពលរថមិនមាន ភូមិនៃពលថ្មើរជើង មិនមាន, មួយទៀត ឥតមានអ្នកណាមួយ អាចយកឈ្នះ (នូវជរា និង មរណៈនោះ) ដោយសង្គ្រាម ដោយអាថ៌កំបាំង ឬ ដោយទ្រព្យបានឡើយ ។

វិបត្តិគឺមរណៈ ជាទីបំផុតនៃសម្បត្តិគឺជីវិត ដូចពោលមកនេះ ។ ព្រះយោគាវចរ កាលកំណត់ភាវៈនៃជីវិត មានសេចក្ដីស្លាប់ ជាទីបំផុតនោះ គប្បីរលឹកសេចក្ដីស្លាប់រឿយៗ ដោយវិបត្តិចាកសម្បត្តិ ។

(អធិប្បាយអាការៈ ទី៣)

(១៤៤) បទថា “ឧបសំហរណតោ” *គឺដោយការប្រៀបធៀបខ្លួនជាមួយនឹងពួកជនដទៃ ។ ក្នុងរឿងនោះ ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់រឿយៗ ដោយការប្រៀបធៀប ដោយអាការៈ ៧ គឺ :*

យសមហត្តតោ *ដោយភាពជាអ្នកមានយសធំ,*

បុញ្ញមហត្តតោ *ដោយភាពជាអ្នកមានបុណ្យច្រើន,*

ថាមមហត្តតោ *ដោយភាពជាអ្នកមានកម្លាំងច្រើន,*

ឥទ្ធិមហត្តតោ *ដោយភាពជាអ្នកមានឫទ្ធិច្រើន,*

បញ្ញាមហត្តតោ *ដោយភាពជាអ្នកមានបញ្ញាច្រើន,*

បច្ចេកពុទ្ធតោ *ដោយភាពជាព្រះបច្ចេកពុទ្ធ,*

សម្មាសម្ពុទ្ធមហត្តតោ *ដោយភាពជាព្រះសម្មាសម្ពុទ្ធ,*

(យសមហត្តតោ)

សួរថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាព

ជាអ្នកមានយសធំ) យ៉ាងដូចម្ដេច? ។

ឆ្លើយថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាពជាអ្នកមានយសធំ យ៉ាងនេះជាមុនថា: សេចក្ដីស្លាប់នេះ មិនមានសេចក្ដីសង្ស័យឡើយ ធ្លាក់ចុះលើព្រះរាជាទាំងឡាយ ចាប់ផ្ដើមអំពីស្ដេចទ្រង់ព្រះនាមមហាសម្មតៈ ស្ដេចទ្រង់ព្រះនាមមន្ធាតុ ស្ដេចទ្រង់ព្រះនាមមហាសុទស្សនៈ ស្ដេចទ្រង់ព្រះនាមទឡ្ហនេមិ អ្នកមានយសធំមានបរិវារច្រើន មានទ្រព្យ និង មានពាហនៈច្រើន ចាំបាច់ពោលទៅថ្វី សេចក្ដីស្លាប់នឹងមិនធ្លាក់មកលើខ្លួនអញ ។

អ្នកមានយសធំទាំងឡាយ មានស្ដេចទ្រង់ព្រះនាមមហាសម្មតៈជាដើម ជាស្ដេចប្រសើរ អម្បាលយ៉ាងស្ដេចទាំងនោះ គង់ដល់ហើយនូវអំណាច នៃមច្ចុ ចាំបាច់ពោលទៅថ្វី ក្នុងបុគ្គលទាំងឡាយ ប្រាកដដូចជាអញ *ដូច្នេះ ។*

(បុញ្ញមហត្តតោ)

សួរថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាពជាអ្នកមានបុណ្យច្រើន យ៉ាងដូចម្ដេច? ។

ឆ្លើយថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាពជាអ្នកមានបុណ្យច្រើន យ៉ាងដូច្នេះ ថា :

សេដ្ឋីទាំងឡាយនេះ គឺ សេដ្ឋីឈ្មោះជោតិយៈ ឈ្មោះជដិលៈ ឈ្មោះឧគ្គៈ ឈ្មោះមេណ្ឌកៈ ពុំនោះសោត សេដ្ឋីឈ្មោះបុណ្ណៈ និង ជនទាំងឡាយឯទៀត ដែល

សុទ្ធតែល្បីៗ ថា ជាអ្នកមានបុណ្យដ៏ច្រើន ក្នុងលោក អ្នកទាំងអស់នោះ សុទ្ធតែដល់ហើយ នូវសេចក្ដីស្លាប់ ចាំបាច់ពោលទៅថ្វី ក្នុងបុគ្គលទាំងឡាយ ប្រាកដដូចជាអញ *ដូច្នេះ ។*

(ថាមមហត្តតោ)

សួរថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាពជាអ្នកមានកម្លាំងច្រើន យ៉ាងដូចម្ដេច? ។

ឆ្លើយថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាពជាអ្នកមានកម្លាំងច្រើន យ៉ាងដូច្នេះ ថា :

ព្រះវាសុទេព ព្រះពលទេព ព្រះភីមសេនៈ ព្រះយុធិដ្ឋិលៈ សូម្បីហនុរៈ អ្នកចំបាប់ធំៗ ដល់ហើយ នូវអំណាចនៃសេចក្ដីស្លាប់ អ្នកទាំងនោះឯងដែលសុទ្ធតែជាអ្នកល្បីៗ ដល់ហើយនូវភាពជាអ្នកមានកម្លាំង ក្នុងលោក យ៉ាងនេះ ដល់ហើយនូវសេចក្ដីស្លាប់ ចាំបាច់ពោលទៅថ្វី ក្នុងបុគ្គលប្រាកដដូចអញ *ដូច្នេះ ។*

(ឥទ្ធិមហត្តតោ)

សួរថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាពជាអ្នកមានឫទ្ធិច្រើន យ៉ាងដូចម្ដេច? ។

ឆ្លើយថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាពជាអ្នកមានឫទ្ធិច្រើន យ៉ាងដូច្នេះ ថា :

ព្រះអគ្គសាវ័ក ទី២ ណា ជាអ្នកប្រសើរជាងបុគ្គលអ្នកមានឫទ្ធិទាំងឡាយ កាលញាំងវេជយន្តប្រាសាទមិនឲ្យកម្រើក ដោយត្រឹមតែចុងមេជើង ព្រះអគ្គសាវ័ក ទី ២ នោះ គង់ចូលទៅកាន់មាត់នៃមច្ចុ ដែលគួរឲ្យព្រឺខ្លាចមួយអន្លើដោយអ្នកមានឫទ្ធិទាំងឡាយ ដូចជាម្រឹគចូលទៅកាន់មាត់នៃសីហៈ ចាំបាច់ពោលទៅថ្វី ក្នុងបុគ្គលទាំងឡាយប្រាកដដូចជាអញ *ដូច្នេះ ។*

(បញ្ញាមហត្តតោ)

សួរថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាពជាអ្នកមានប្រាជ្ញាច្រើន យ៉ាងដូចម្ដេច? ។

ឆ្លើយថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាពជាអ្នកមានប្រាជ្ញាច្រើន យ៉ាងដូច្នេះ ថា :

លើកលែងតែព្រះលោកនាថចេញ សត្វទាំងឡាយណាដទៃទៀត ដែលមានសត្វទាំងឡាយនោះ មិនដល់នូវចំណិត ទី១៦ ដែលគេចែកហើយ អស់ឋានៈ ១៦ ដង នៃបញ្ញារបស់ព្រះសារីបុត្រ, ព្រះអគ្គសាវ័ក ទី១ ឈ្មោះថា ជាអ្នកមានបញ្ញាច្រើន យ៉ាងនេះ ដល់ហើយនូវអំណាចនៃសេចក្ដីស្លាប់ ចាំបាច់ពោលទៅថ្វី ក្នុងបុគ្គលទាំងឡាយប្រាកដដូចជាអញ *ដូច្នេះ ។*

(បច្ចេកពុទ្ធតោ)

សួរថា : ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់ ដោយភាព

ជាព្រះបច្ចេកពុទ្ធ យ៉ាងដូចម្តេច? ។

ឆ្លើយថា : ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ ដោយភាពជាព្រះបច្ចេកពុទ្ធ យ៉ាងដូច្នេះ ថា : សូម្បីពុទ្ធបុគ្គលទាំងឡាយនោះណា ធ្វើនូវកិរិយាញ៉ាំញីសត្រូវ គឺកិលេសទាំងពួង ដោយពលៈគឺញាណ និងវីរិយៈ របស់ខ្លួន បានដល់នូវបច្ចេកសម្ពោធិ ជាព្រះសយម្ភូ ដូចជាកុយរមាស, សូម្បីពុទ្ធបុគ្គលទាំងនោះ ក៏មិនរួចផុតហើយអំពីសេចក្តីស្លាប់ ចុះយើងនឹងរួចផុតអំពីទីណាបាន ។

ព្រះមហេសីទាំងឡាយឯណា អាស្រ័យនូវនិមិត្តនោះៗ ពិចារណា ដល់ហើយនូវកិរិយាអស់ទៅ នៃអាសាវៈ ដោយតេជៈនៃញាណជាព្រះសយម្ភូ ប្រៀបដូចជាកុយរមាស ព្រោះកិរិយាត្រាច់ទៅនិងនៅតែម្នាក់ឯង, សូម្បីព្រះមហេសីទាំងឡាយនោះ ក៏កន្លងនូវមច្ចុពុំបានឡើយ ចាំបាច់ពោលទៅថ្វី ក្នុងបុគ្គលទាំងឡាយ ប្រាកដដូចជាអញ *ដូច្នេះ ។*

(សម្មាសម្ពុទ្ធតោ)

សួរថា : ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ ដោយភាពជាព្រះសម្មាសម្ពុទ្ធ យ៉ាងដូចម្តេច? ។

ឆ្លើយថា : ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ ដោយភាពជាព្រះសម្មាសម្ពុទ្ធ យ៉ាងដូច្នេះថា : សូម្បីព្រះមានព្រះភាគនោះណា មានព្រះរូបកាយវិចិត្រ ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ប្រដាប់ហើយដោយអនុព្យញ្ជនៈ ៨០ មានព្រះធម្មកាយសំរេចហើយ ដោយគុណរតនៈ

មានសីលក្ខន្ធដ៏បរិសុទ្ធស្អាត ដោយអាការៈទាំងពួងជាដើម ដល់ហើយនូវត្រើយ នៃភាពជាអ្នកមានយសធំ ភាពជាអ្នកមានបុណ្យច្រើន ភាពជាអ្នកមានកម្លាំងច្រើន ភាពជាអ្នកមានឫទ្ធិច្រើន និង ភាពជាអ្នកមានបញ្ញាច្រើន មិនមានបុគ្គលស្មើ ស្មើដោយបុគ្គលមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀប មានបុគ្គលប្រៀបមិនមាន ជាព្រះអរហន្ត ត្រាស់ដឹងដោយប្រពៃ, សូម្បីព្រះមានព្រះភាគអង្គនោះ ទ្រង់ស្ងប់រម្ងាប់ហើយដោយឋានៈ ដោយកិរិយាធ្លាក់ចុះនៃតំណក់ទឹកភ្លៀង គឺមរណៈ ប្រៀបដូចជាគំនរភ្លើងដ៏ធំ រលត់ដោយកិរិយាធ្លាក់ចុះនៃគ្រាប់ភ្លៀងគឺទឹក ។

ធម្មតាសេចក្តីស្លាប់នោះណា ផ្សាយអំណាចមកដល់ព្រះមហេសី អ្នកមានអានុភាពច្រើន យ៉ាងនេះ ដោយមិនមានសេចក្តីខ្លាច ដោយមិនមានសេចក្តីខ្មាសឡើយ សេចក្តីស្លាប់នេះនោះ ដែលមិនមានសេចក្តីខ្មាស មិនមានកោតញញើត ញាំញីនូវសត្វទាំងអស់ នឹងមិនមកគ្របសង្កត់នូវសត្វ ប្រាកដដូចជាអញ ដូចម្តេចបាន *ដូច្នេះ ។*

កាលព្រះយោគាវចរនោះ ប្រៀបធៀបខ្លួន មួយអន្លើដោយជនទាំងឡាយដទៃ ដែលបរិបូរដោយភាពជាធំ មានភាពជាអ្នកមានយសធំជាដើម ដោយភាពជាអ្នកមានមរណៈស្មើគ្នា ដូច្នេះហើយ រលឹករឿយៗថា “សេចក្តីស្លាប់ នឹងមានដល់អញដែរ ដូចមានដល់ពួកសត្វវិសេសទាំងឡាយនោះ” ដូច្នេះហើយ កម្មដ្ឋាន នឹងដល់ឧបចារៈពិត ។ ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ ដោយការប្រៀបធៀបយ៉ាងនេះ ។

(អធិប្បាយអាការៈ ទី៤)

(១៤៥) បទថា "កាយពហុសាធារណោ" សេចក្តីថា ទូទៅដល់សត្វច្រើន គឺទូទៅដល់ហ្វូវដង្កូវទាំងឡាយ ៨០ ពួក ដោយពិត ។ បណ្តាហ្វូងដង្កូវទាំងនោះ ដង្កូវដែលអាស្រ័យនូវស្បែកសម្បុរថ្ងៃ តែងស៊ីនូវស្បែកសម្បុរថ្ងៃ ដែលអាស្រ័យនូវស្បែក តែងទំពាស៊ីនូវស្បែក ដែលអាស្រ័យនូវសាច់ តែងទំពាស៊ីនូវសាច់ ដែលអាស្រ័យនូវសរសៃ តែងទំពាស៊ីនូវសរសៃ ដែលអាស្រ័យនូវឆ្អឹង តែងទំពាស៊ីនូវឆ្អឹង ដែលអាស្រ័យខួរក្នុងឆ្អឹង តែងទំពាស៊ីនូវខួរក្នុងឆ្អឹង វាកើត ចាស់ ស្លាប់ បន្ទោបង់ឧច្ចារៈ និង បស្សាវៈ ដាក់ក្នុងសរីរប្រទេសនោះឯង ។ ក៏រាងកាយ ជាផ្ទះសំរាប់កើត ជាមន្ទីរពេទ្យ ជាសាកសព ជាព្រៃស្មសាន ជាបង្គន់ និង ជាស្នូកសំរាប់បន្ទោបង់បស្សាវៈ នៃហ្វូងដង្កូវទាំងឡាយនោះ រាងកាយនេះនោះ រមែងដល់នូវសេចក្តីស្លាប់ ដោយកិរិយាកំរើក នៃហ្វូងដង្កូវទាំងឡាយនោះឯង ។

មួយទៀត កាយនេះ ជាទូទៅដល់ហ្វូងដង្កូវទាំងឡាយ ៨០ ហ្វូង យ៉ាងណាមិញ, (កាយនេះ) ក៏ជាទូទៅដល់បច្ច័យទាំងឡាយ នៃសេចក្តីស្លាប់ ដែលប្រព្រឹត្តទៅឰដ៏ខាងក្នុងហ្នឹងឯង បានដល់រោគច្រើនរយជំពូក ដែលមានក្នុងខាងក្រៅ គឺសត្វមានពិសទាំងឡាយ មានពស់ និង ខ្ទួយ ជាដើម ក៏យ៉ាងដូច្នោះដែរ ។ ប្រៀបដូចជាគ្រឿងប្រហារទាំងឡាយ មានកូនសរ លំពែង ផ្គាក់ និង ដុំថ្មជាដើម ដែលមកហើយអំពីទិសទាំងពួង រមែងធ្លាក់ចុះ ក្នុងវង់ជាគ្រឿងកំណត់ដែលគេតម្កល់ទុកហើយ លើផ្លូវធំបែកជាបួន យ៉ាងណា, ឧបទ្រពទាំងពួងទាំងឡាយ ក៏ធ្លាក់ចុះលើកាយក៏យ៉ាងដូច្នោះដែរ ។ កាយនេះនោះ រមែងដល់នូវសេចក្តីស្លាប់ ដោយ

កិរិយាធ្លាក់ចុះ នៃឧបទ្រព្យទាំងឡាយនោះមែនពិត ។

ព្រោះហេតុនោះ បានជាព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ កាលបើថ្ងៃកន្លងទៅហើយ យប់មកដល់វិញ តែងពិចារណាដូច្នេះថា: ហេតុនៃសេចក្តីស្លាប់ របស់អាត្មាអញ មានច្រើនណាស់តើ (ដូចជា) ពស់ចឹកអាត្មាអញក្តី ខ្ទួយទិចអាត្មាអញក្តី ក្អែបខាំអាត្មាអញក្តី អាត្មាអញនឹងស្លាប់ អន្តរាយនោះ នឹងមានដល់អាត្មាអញ ព្រោះហេតុតែពស់ចឹកជាដើមនោះ អាត្មាអញភ្លាត់ជួលក្តី ភត្តដែលអាត្មាអញបរិភោគហើយហាល់ក្តី ប្រមាត់របស់អាត្មាអញកំរើកក្តី ស្លេស្មរបស់អាត្មាអញកម្រើកក្តី កងខ្យល់ដូចសស្ត្រាវុធ របស់អាត្មាអញ កម្រើកក្តី ពួកមនុស្ស ព្យាយាមសម្លាប់អាត្មាអញក្តី ពួកអមនុស្សព្យាយាមសម្លាប់អាត្មាអញក្តី អាត្មាអញនឹងស្លាប់ អន្តរាយនោះ នឹងមានដល់អាត្មាអញ ព្រោះហេតុតែភ្លាត់ជួលជាដើមនោះ [១] " ។

ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់រឿយៗ ដោយកាយជាទូទៅ ដល់សត្វនិងបច្ច័យ នៃសេចក្តីស្លាប់ច្រើនប្រការ យ៉ាងដូច្នេះឯង ។

(អធិប្បាយអាការៈ ទី៥)

(១៤៦) បទថា "អាយុទុព្វលតោ" សេចក្តីថា ធម្មតាអាយុនុ៎ះ មិនមានកំឡាំង មានកំឡាំងខ្សោយ ។ ពិតដូច្នោះមែន ជីវិត របស់សត្វទាំងឡាយ ជាប់ទាក់ទងដោយខ្យល់ដកដង្ហើមចូលចេញ ១ ជាប់ទាក់ទងដោយឥរិយាបថ ១ ជាប់ទាក់ទង ដោយត្រជាក់ក្តៅ ១ ជាប់ទាក់ទងដោយមហាភូតរូប ១ ជាប់ទាក់ទងដោយអាហារ ១ ។

ជីវិតនេះនោះ កាលបាននូវភាពប្រព្រឹត្តិទៅស្មើ នៃខ្យល់ដកដង្ហើម

១– សុ. អំ. អ. ភាគទី ៤៨ ទំព័រទី ៣១៧ ។

ចូល និង ខ្យល់ដកដង្ហើមចេញហ្នឹងឯង ទើបប្រព្រឹត្តទៅបាន ។ ក៏ប៉ុន្តែ កាលបើខ្យល់ក្នុងច្រមុះ ដែលចេញទៅខាងក្រៅហើយ មិនចូលមកខាងក្នុងវិញក្តី កាលបើខ្យល់ដែលចូលទៅហើយ មិនចេញមកវិញក្តី បុគ្គលឈ្មោះថា ស្លាប់ហើយ ។

មួយទៀត ជីវិតនេះ កាលបាននូវភាពនៃកិរិយាប្រព្រឹត្តិទៅស្មើនៃឥរិយាបថទាំងឡាយបួនហ្នឹងឯង ទើបប្រព្រឹត្តទៅបាន ប៉ុន្តែព្រោះភាវៈនៃឥរិយាបថណាមួយៗ (ប្រព្រឹត្តទៅ) ហួសប្រមាណ អាយុសង្ខារ ទើបដាច់សូន្យ ។

មួយទៀត ជីវិតនេះ កាលបាននូវភាពនៃកិរិយាប្រព្រឹត្តិទៅស្មើនៃត្រជាក់ និង ក្តៅទាំងឡាយហ្នឹងឯង ទើបប្រព្រឹត្តទៅបាន ប៉ុន្តែកាលបើបុគ្គលត្រូវត្រជាក់ក្រៃពេកក្តី ក្តៅក្រៃពេកក្តី គ្របសង្កត់ហើយ រមែងវិនាស ។

មួយទៀត ជីវិតនេះ កាលបាននូវភាពនៃកិរិយាប្រព្រឹត្តិទៅស្មើនៃមហាភូតរូបទាំងឡាយហ្នឹងឯង ទើបប្រព្រឹត្តទៅបាន ប៉ុន្តែព្រោះបណ្តាបឋវីធាតុ ឬ បណ្តាធាតុទាំងឡាយ មានអាបោធាតុជាដើម ធាតុណាមួយកម្រើក បុគ្គលសូម្បីបរិបូរហើយដោយកំឡាំង ក៏ជាអ្នកមានកាយរឹងក្រញ៉ង់ខ្លះ មានកាយរលួយស្អុយសៅហ្មង ដោយអំណាចនៃរោគមានរោគធ្លាក់ឈាមជាដើមខ្លះ មានសេចក្តីក្តៅក្រហាយដ៏ធំគ្របសង្កត់ខ្លះ ជាអ្នកមានតំណ និង ចំណងដាច់ខ្លះ រមែងដល់នូវការអស់ទៅនៃជីវិត ។

មួយវិញទៀត កាលបើបុគ្គល បាននូវកវឡិង្ការាហារ ក្នុងកាលដ៏សមគួរប៉ុណ្ណោះ ជីវិត ទើបប្រព្រឹត្តទៅបាន ប៉ុន្តែកាលបើមិនបាននូវអាហារ វាក៏ដល់នូវកិរិយាអស់ទៅតែម្តង យ៉ាងនេះឯង ។

ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់រឿយៗ ដោយអាយុមានកំឡាំងខ្សោយ ដូចបានរៀបរាប់មកនេះឯង ។

(អធិប្បាយអាការៈ ទី៦)

(១៤៧) បទថា “**អនិមិត្តតោ**” គឺ ដោយមិនមានកំណត់ សេចក្តីថា ដោយមិនមាននៃការកំណត់ ។ មែនពិត

> ធម៌ទាំងឡាយ ៥ នេះ គឺ ជីវិត ១ ព្យាធិ ១ កាល ១ កន្លែងសំរាប់ដាក់ចុះនូវរាងកាយ ១ គតិ ១ របស់សត្វទាំងឡាយ ក្នុងជីវលោក មិនមាននិមិត្ត គឺអ្នកណាមួយ ក៏ដឹងមិនបានដែរ ។

បណ្តាធម៌ទាំងឡាយ ៥ នោះ ឈ្មោះថា ជីវិត មិនមាននិមិត្ត ព្រោះមិនមានការកំណត់ថា “សត្វគប្បីរស់នៅ អស់កាលមានប្រមាណប៉ុណ្ណោះឯង មិនគប្បីរស់នៅ ខាងមុខបន្ទាប់អំពីនេះទេ” ដូច្នេះជាដើម ។ ដ្បិតថា សត្វទាំងឡាយ ស្លាប់ក្នុងកាលដែលខ្លួននៅជាកលលៈក៏មាន ក្នុងកាលនៅជាអព្ពុទៈ ជាបេសិ ជាឃនៈ នៅក្នុងគភ៌បាន ១ ខែ បាន ២ ខែ បាន ៣ ខែ បាន ៤ ខែ បាន ៥ ខែ និង បាន ១០ ខែ ក៏មាន ក្នុងសម័យដែលចេញចាកផ្ទៃក៏មាន បន្ទាប់ពីនោះមក ស្លាប់ខាងក្នុង ១០០ ឆ្នាំក៏មាន ខាងក្រៅ (លើសអំពី) ១០០ ឆ្នាំ ក៏មានដូចគ្នាដែរ ។

ឯព្យាធិ ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានកិរិយាកំណត់ថា “សត្វទាំងឡាយ ស្លាប់ដោយព្យាធិនេះតែប៉ុណ្ណោះ មិនស្លាប់ដោយព្យាធិដទៃទៀតទេ” ។ ព្រោះថា សត្វទាំងឡាយ ស្លាប់ដោយរោគក្នុងភ្នែក ក៏មាន ដោយរោគណាមួយ ក្នុងចំណោមរោគទាំងឡាយ មានរោគក្នុងត្រចៀកជាដើមក៏មាន ។

សូម្បីកាល ក៏ឈ្មោះថាមិនមាននិមិត្ត ព្រោះមិនមានការកំណត់ យ៉ាងនេះថា : សត្វគប្បីស្លាប់ ក្នុងកាលនេះឯង មិនស្លាប់ក្នុងកាលដទៃឡើយ ។ ព្រោះថា សត្វទាំងឡាយ ស្លាប់ក្នុងពេលព្រឹកក៏មាន ស្លាប់ក្នុងពេលណាមួយ ក្នុងចំណោមពេលថ្ងៃត្រង់ជាដើមក៏មាន ។

ឯការដាក់ចុះនូវរាងកាយ ក៏ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានការកំណត់ យ៉ាងនេះថា: “កាលសត្វទាំងឡាយស្លាប់ទៅ រាងកាយគប្បីធ្លាក់ចុះ ក្នុងទីនេះតែប៉ុណ្ណោះ មិនធ្លាក់ចុះទៅ ក្នុងទីដទៃឡើយ” ។ ដ្បិតថា អត្តភាព របស់បុគ្គលទាំងឡាយ ដែលកើតហើយ ខាងក្នុងផ្ទះ ធ្លាក់ចុះ ខាងក្រៅផ្ទះក៏មាន អត្តភាព របស់បុគ្គលទាំងឡាយ ដែលកើតហើយ ខាងក្រៅផ្ទះ តែងធ្លាក់ចុះទៅ ខាងក្នុងផ្ទះក៏មាន ។ ដោយន័យដូចគ្នានោះដែរ បណ្ឌិត គប្បី (ពណ៌នា) ឲ្យបានពិស្តារ ដោយប្រការជាច្រើន ដូច្នេះជាដើមថា : អត្តភាព របស់សត្វទាំងឡាយដែលកើតហើយលើគោក ធ្លាក់ចុះក្នុងទឹកក៏មាន ឬថា អត្តភាព របស់សត្វទាំងឡាយដែលកើតហើយក្នុងទឹក ធ្លាក់ចុះ លើគោកក៏មាន ។

ឯគតិ ក៏ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានការកំណត់ យ៉ាងនេះថា : សត្វដែលច្យុតចាកគតិនេះ គប្បីកើតក្នុងគតិនេះ ។ ព្រោះថា សត្វទាំងឡាយ ដែលច្យុតចាកទេវលោក កើតក្នុងមនុស្សលោកក៏មាន ដែលច្យុតចាកមនុស្សលោក កើតក្នុងលោកណាមួយ ក្នុងចំណោមលោកទាំងឡាយមានទេវលោកជាដើមក៏មាន ព្រោះហេតុនេះយ៉ាងដូច្នេះ លោកតែងវិលវល់ទៅ ក្នុងគតិ ៥ ដូចជាគោដែលគេទឹមហើយ ក្នុងយន្ត ដើរវិលវល់ដូច្នោះឯង ។ ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់រឿយៗ ដោយជីវិតមិនមាននិមិត្ត យ៉ាងនេះឯង ។

(១៤៨) បទថា “អទ្ធានបរិច្ឆេទតោ” សេចក្ដីថា ធម្មតាកាល នៃជីវិត របស់មនុស្សទាំងឡាយ ក្នុងពេលឥឡូវនេះ មានប្រមាណតិច, មនុស្សណា រស់នៅអស់កាលដ៏យូរ មនុស្សនោះ រស់នៅត្រឹមតែ ១០០ ឆ្នាំ រស់នៅជាង ១០០ ឆ្នាំនេះ ក៏មានខ្លះដែរ តែតិចទេ ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ អាយុរបស់មនុស្សទាំងឡាយនេះ តិចណាស់ សត្វដែលត្រូវទៅកាន់បរលោក គួរធ្វើកុសល គួរប្រព្រឹត្តព្រហ្មចរិយធម៌ សត្វដែលកើតមកហើយ ឈ្មោះថា មិនស្លាប់មិនមានឡើយ, ម្នាលភិក្ខុទាំងឡាយ មនុស្សណា រស់នៅ អស់កាលដ៏យូរ មនុស្សនោះ រស់នៅ បានត្រឹមតែ ១០០ ឆ្នាំ ឬថយចុះមកក៏មាន លើសជាងបន្តិចក៏មាន [១] ” ព្រោះហេតុដូច្នេះ

(និគមគាថា)

អាយុ របស់មនុស្សទាំងឡាយ មានតិច សប្បុរសគួរ
ខ្ពើមឆ្អើមអាយុនោះ បុគ្គលគួរខំប្រព្រឹត្ត (សុចរិត) ដូច
បុគ្គលដែលភ្លើងកំពុងឆេះក្បាល (ព្រោះ) ដំណើរមិន
មក នៃសេចក្ដីស្លាប់ មិនមានទេ ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ទៀតថា “ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយ មានគ្រូ ឈ្មោះអរកៈ” ដូច្នេះជាដើម ។

ព្រះសូត្រដែលប្រដាប់ដោយឧបមា ៧ ប្រការ ទាំងពួង បណ្ឌិតគប្បី (នាំយកមកពណ៌នា) ឲ្យបានពិស្តារ ។

ព្រះអង្គ ទ្រង់ត្រាស់ព្រះសូត្រដទៃទៀត ថា “ម្នាលភិក្ខុទាំងឡាយ

១- សុ. សំ. សគ. ភាគទី ២៩ ទំព័រទី ២៩៥ ។

ភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្ដីត្រិះរិះ យ៉ាងនេះ ថា : ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅ អស់យប់និងថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន ដូច្នេះក្ដី, ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្ដីត្រិះរិះ យ៉ាងនេះថា : ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅ អស់ ១ ថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅ របស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ដូច្នេះក្ដី, ភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្ដីត្រិះរិះ យ៉ាងនេះ ថា : ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅ ត្រឹមឆាន់ចង្ហាន់បិណ្ឌបាតម្ដង អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ដូច្នេះក្ដី, ភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្ដីត្រិះរិះ យ៉ាងនេះថា : ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅ ត្រឹមខណៈទំពាពំនូតបាយ ៤ ឬ ៥ ពំនូត លេបចូលទៅ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ដូច្នេះក្ដី, ម្នាលភិក្ខុទាំងឡាយ ភិក្ខុអម្បាលនេះ ហៅថា មានសេចក្ដីប្រមាទនៅឡើយ ចំរើនមរណស្សតិ ដើម្បីធ្វើឲ្យអស់ទៅនៃអាសវៈទាំងឡាយ យឺតយូរទេ ដូច្នេះក្ដី, ម្នាលភិក្ខុទាំងឡាយ ចំណែកភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្ដីត្រិះរិះ យ៉ាងនេះថា : ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅ ត្រឹមខណៈទំពាពំនូតបាយ ១ ពំនូត លេបចូលទៅ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅ របស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ដូច្នេះក្ដី, ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា

ចំរើនមរណស្សតិ ដោយសេចក្ដីត្រិះរិះ យ៉ាងនេះ ថា : ធ្វើដូចម្ដេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅ ត្រឹមខណៈដែលដកដង្ហើមចូល ហើយចេញ ឬ ដកដង្ហើមចេញ ហើយចូល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ដូច្នេះក្ដី, ម្នាលភិក្ខុទាំងឡាយ ភិក្ខុអម្បាលនេះ ហៅថា មិនមានសេចក្ដីប្រមាទនៅ ចំរើនមរណស្សតិ ដើម្បីឲ្យអស់ទៅនៃអាសវៈទាំងឡាយ យ៉ាងឆាន់រហ័ស [១] ” ដូច្នេះឯង ។

កាលនៃជីវិត តិចណាស់ គឺបុគ្គលមិនគួរទុកចិត្ត ត្រឹមតែកិរិយាទំពាស៊ីនូវពំនូតបាយ ៤ ឬ ៥ ពំនូត យ៉ាងដូច្នេះឯង ។

ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្លាប់រឿយៗ ដោយជីវិតមានកាលកំណត់ យ៉ាងនេះឯង ។

(អធិប្បាយអាការៈ ទី៨)

(១៤៩) បទថា “ខណបរិត្តតោ” សេចក្ដីថា បើតាមបរមត្ថ ខណៈនៃជីវិត របស់សត្វទាំងឡាយ តិចពេកណាស់ ត្រឹមតែការប្រព្រឹត្តទៅនៃចិត្តតែមួយប៉ុណ្ណោះឯង ។ ប្រៀបដូចជាកង់រថ សូម្បីកំពុងប្រព្រឹត្តទៅ តែងប្រព្រឹត្តទៅ ដោយប្រទេស នៃខ្នងកង់តែម្ខាងប៉ុណ្ណោះ សូម្បីកំពុងឋិតនៅ ក៏រមែងឋិតនៅ ដោយប្រទេសនៃខ្នងកង់ម្ខាងប៉ុណ្ណោះដែរ យ៉ាងណាមិញ, ជីវិត របស់សត្វទាំងឡាយ ប្រកបដោយខណៈ នៃចិត្តតែមួយ ក៏យ៉ាងដូច្នោះដែរ កាលបើចិត្តនោះរលត់ហើយ សត្វ គេសន្មតឲ្យឈ្មោះថា រលត់ហើយ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “ក្នុងខណៈ នៃចិត្តជាអតីតៈ សត្វ ឈ្មោះថា រស់នៅហើយ មិនរស់នៅ

១- សុ. អំ. អ. ភាគទី ៤៨ ទំព័រទី ៣១៤ ។

នឹងមិនរស់នៅ ក្នុងខណៈ នៃចិត្តជាអនាគត សត្វ មិនរស់នៅហើយ មិនកំពុងរស់នៅ (តែ) ឈ្មោះថានឹងរស់នៅ ក្នុងខណៈនៃចិត្តជាបច្ចុប្បន្ន សត្វ មិនរស់នៅហើយ (តែ) ឈ្មោះថា កំពុងរស់នៅ នឹងមិនរស់នៅ

> ជីវិត អត្តភាព សុខ និង ទុក្ខ ទាំងអស់ ប្រកបដោយ ខណៈចិត្តតែមួយ ព្រោះខណៈប្រព្រឹត្តរហ័ស, ខន្ធទាំងឡាយណា របស់បុគ្គលដែលស្លាប់ទៅក្តី រស់នៅក្តី រលត់ហើយ ក្នុងលោកនេះ ខន្ធទាំងអស់នោះ ក៏ដូចគ្នា ទៅបដិសន្ធិទៀតមិនបាន, សត្វលោក មិនមែនកើតហើយ ដោយខន្ធជាអនាគត ដែលមិនទាន់កើតហើយ មិនមែនរស់នៅ ក្នុងបច្ចុប្បន្នទេ សត្វលោកស្លាប់ ដោយការបែកធ្លាយនៃចិត្ត (នេះគឺ) ជាបញ្ញត្តិប្រកបដោយបរមត្ថ [១] " *ដូច្នេះ ។*

ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់រឿយៗ ដោយជីវិតមានខណៈតិចតួច យ៉ាងដូច្នេះឯង ។

(មរណស្សតិជ្ឈាន)

កាលបើព្រះយោគាវចរ សូម្បីរលឹករឿយៗ ដោយអាការៈណាមួយ ក្នុងចំណោមអាការៈទាំង ៨ នេះ យ៉ាងដូច្នេះ ចិត្ត រមែងបាននូវអាសេវនៈ (ការសេព) ដោយអំណាចនៃការធ្វើទុកក្នុងចិត្តរឿយៗ សតិដែលមានសេចក្តីស្លាប់ជាអារម្មណ៍ រមែងតាំងនៅមាំ នីវរណធម៌ទាំងឡាយ រមែងស្ងប់រម្ងាប់ អង្គឈានទាំងឡាយរមែងកើតប្រាកដ ។ ប៉ុន្តែព្រោះអារម្មណ៍ (របស់ឈាននេះ) ជាសភាវធម៌ផង ព្រោះអារម្មណ៍ជា

១- សុ. ខុ. មហា. ភាគទី ៦៤ ទំព័រទី ៧៨ ។

ធម្មជាតគួរសង្វេគផង ឈាននេះ ជាឈានមិនដល់នូវអប្បនា ដល់ត្រឹមតែឧបចារៈប៉ុណ្ណោះ។ ចំណែកលោកុត្តរជ្ឈាន និង អារុប្បជ្ឈាន ទី២ និង ទី៤ ដល់អប្បនា សូម្បីក្នុងសភាវធម៌ព្រោះជាភាវនាពិសេស។ មែនពិត លោកុត្តរជ្ឈាន ដល់នូវអប្បនា ដោយអំណាចលំដាប់នៃវិសុទ្ធិភាវនា ។ អារុប្បជ្ឈាន ដល់អប្បនា ដោយអំណាចភាវនាដែលកន្លងនូវអារម្មណ៍។ ព្រោះថា ក្នុងអារុប្បជ្ឈាននោះ មានត្រឹមតែកិរិយាកន្លងនូវអារម្មណ៍ នៃឈាន ដែលដល់ហើយនូវអប្បនាប៉ុណ្ណោះ ។ ប៉ុន្តែក្នុងមរណស្សតិនេះ (វិសុទ្ធិភាវនានុក្កមៈ និង អារម្មណសមតិក្កមៈ) ទាំងពីរនោះឯង មិនមាន ព្រោះហេតុនោះ ទើបជាឈាន ដល់ត្រឹមតែឧបចារៈប៉ុណ្ណោះ ។ ឈាននេះនោះ ដល់នូវការរាប់ថា មរណស្សតិ មែនពិត ព្រោះភាវៈនៃឈាននោះ ជាធម្មជាតកើតឡើងដោយកំឡាំងនៃការរលឹកដល់សេចក្តីស្លាប់ ។

(អានិសង្សនៃការចំរើនមរណស្សតិ)

ក៏ភិក្ខុដែលប្រកបរឿយៗ នូវមរណស្សតិនេះ ជាអ្នកមិនប្រមាទជាប់ជានិច្ច បាននូវអនភិរតិសញ្ញា ក្នុងភពទាំងពួង លះបង់នូវសេចក្តីអាឡោះអាល័យ ក្នុងជីវិត ជាអ្នកតិះដៀលបាប ជាអ្នកមិនច្រើន ដោយការសន្សំ ជាអ្នកមានមន្ទិល គឺសេចក្តីកំណាញ់ ក្នុងបរិក្ខារទាំងឡាយ ទៅប្រាសហើយ ។ សូម្បីអនិច្ចសញ្ញា ក៏ដល់នូវការស្ទាត់ជំនាញ សំរាប់ភិក្ខុនោះ ។ មួយទៀត ទុក្ខសញ្ញា និង អនត្តសញ្ញា រមែងប្រាកដ (ដល់ភិក្ខុនោះ) តាមលំអាននៃអនិច្ចសញ្ញានោះឯង ។ សត្វទាំងឡាយ ដែលមិនបានអប់រំអំពីសេចក្តីស្លាប់ ក្នុងវេលាជិតស្លាប់ រមែងដល់នូវសេចក្តីខ្លាច សេចក្តីតក់ស្លុត សេចក្តីវង្វេង ដូចមនុស្សដែលត្រូវម្រឹគកាច យក្ខ ពស់ ចោរ និង ពេជ្ឈឃាត គ្របសង្កត់ហើយ ភ្លាមៗ យ៉ាងណាមិញ,

ភិក្ខុនោះ មិនដល់ថ្នាក់យ៉ាងនេះទេ ជាអ្នកមិនភ័យ ជាអ្នកមិនវង្វេង ធ្វើមរណកាល។ ប្រសិនបើភិក្ខុនោះ មិនត្រេកអរនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នហ្នឹងទេ លុះបែកធ្លាយរាងកាយស្លាប់ទៅជាអ្នកមានសុគតិនៅខាងមុខ ។

ព្រោះហេតុនោះឯង បុគ្គលអ្នកមានប្រាជ្ញាល្អ គប្បីធ្វើ
នូវសេចក្តីមិនប្រមាទ ក្នុងមរណស្សតិ ដែលមាន
អានុភាពច្រើន យ៉ាងនេះ សព្វៗ កាល ។

នេះជាកថាមុខ ដោយពិស្តារ ក្នុងមរណស្សតិ ។

(កាយគតាសតិ)

(១៥០) ក្នុងកាលឥឡូវនេះ កាយគតាសតិកម្មដ្ឋាននោះណា មិនធ្លាប់ប្រព្រឹត្តទៅហើយ វៀរចាកពុទ្ធុប្បាទ មិនមែនជាវិស័យនៃពួកតិរ្ថីយ៍ទាំងពួង ដែលព្រះមានព្រះភាគទ្រង់ត្រាស់សរសើរហើយ ក្នុងព្រះសូត្រទាំងឡាយនោះៗ ដោយអាការៈច្រើនជាអនេក យ៉ាងនេះ ថា “ម្នាលភិក្ខុទាំងឡាយ [១] ធម៌មួយយ៉ាង ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្វេគច្រើន តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនច្រើន តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីក្សេមចាកយោគៈច្រើន តែងប្រព្រឹត្តទៅ ដើម្បីសតិ និង សម្បជញ្ញៈច្រើន តែងប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវញាណទស្សនៈ តែងប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវវិជ្ជា (បញ្ញាដ៏សម្បយុត្តដោយមគ្គ) វិមុត្តិ (សម្បយុត្តធម៌ ដែលកើតរលត់ជា

១- សុ. អំ. ឯក. ភាគទី ៤០ ទំព័រទី ៩៥ ។

មួយគ្នាដោយមគ្គបញ្ញានោះ) និង ផល (អរហត្តផល) ។ ធម៌មួយយ៉ាងគឺអ្វី? គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា បរិភោគនូវកាយគតាសតិ ពួកភិក្ខុនោះ ឈ្មោះថា បរិភោគនូវព្រះនិព្វាន, ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា មិនបរិភោគនូវកាយគតាសតិ ពួកភិក្ខុនោះ ឈ្មោះថា មិនបរិភោគនូវព្រះនិព្វាន, ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ ដែលពួកភិក្ខុណាបរិភោគហើយ ព្រះនិព្វាន ក៏ឈ្មោះថា ពួកភិក្ខុទាំងនោះ បរិភោគដែរ, កាយគតាសតិ ដែលពួកភិក្ខុណា មិនបរិភោគហើយ ព្រះនិព្វាន ក៏ឈ្មោះថា ពួកភិក្ខុទាំងនោះ មិនបរិភោគដែរ, កាយគតាសតិ របស់ពួកភិក្ខុណា សាបសូន្យហើយ ព្រះនិព្វាន របស់ពួកភិក្ខុទាំងនោះ ក៏ឈ្មោះថា សាបសូន្យដែរ, កាយគតាសតិ របស់ពួកភិក្ខុណា មិនសាបសូន្យហើយ ព្រះនិព្វាន របស់ពួកភិក្ខុទាំងនោះ ក៏ឈ្មោះថា មិនសាបសូន្យដែរ, កាយគតាសតិ ដែលពួកភិក្ខុណា បោះបង់ហើយ ព្រះនិព្វាន ក៏ឈ្មោះថា ពួកភិក្ខុទាំងនោះ បោះបង់ដែរ, កាយគតាសតិ ដែលពួកភិក្ខុណា ប្រារព្ធហើយ ព្រះនិព្វាន ក៏ឈ្មោះថា ពួកភិក្ខុទាំងនោះ ប្រារព្ធដែរ” ដូច្នេះជាអាទិ៍ ទ្រង់សំដែងចេញហើយ ដោយអំណាចនៃបព្វៈទាំងឡាយ ១៤ យ៉ាងនេះ គឺ អានាបានបព្វៈ១ ឥរិយាបថបព្វៈ១ ចតុសម្បជញ្ញបព្វៈ១ បដិកូលមនសិការបព្វៈ១ ធាតុមនសិការបព្វៈ១ សិវដ្ឋិកបព្វៈ ៩ ដោយន័យជាអាទិ៍ថា “ម្នាលភិក្ខុទាំងឡាយ ក៏កាយគតាសតិ ដែលភិក្ខុចំរើនហើយ តើដូចម្តេច? ធ្វើឲ្យច្រើនហើយ តើដូចម្តេច ទើបមានផលច្រើន ទើបមានអានិសង្សច្រើន, ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅហើយកាន់ព្រៃឬ” ដូច្នេះ ។ និទ្ទេសនៃការចំរើនកាយគតាសតិនោះ ដល់ហើយ ដោយលំដាប់ ។

(កាយគតាសតិដែលលោកបំណានក្នុងទីនេះ)

បណ្ដាបព្វៈ ១៤ នោះ បព្វៈទាំងឡាយ ៣ នេះ គឺឥរិយាបថបព្វៈ ចតុសម្បជញ្ញៈ ធាតុមនសិការបព្វៈ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដោយអំណាចនៃវិបស្សនា សិវថិកបព្វៈ ៩ ព្រះមានព្រះភាគទ្រង់ត្រាស់ ហើយដោយអំណាចអាទីនវានុបស្សនា ក្នុងវិបស្សនាញាណទាំងឡាយ ហ្នឹងឯង មួយទៀត សូម្បីសមាធិភាវនាណា គប្បីសំរេច ក្នុងអសុភ-កម្មដ្ឋានទាំងឡាយ មានឧទ្ធុមាតកកម្មដ្ឋានជាដើម ក្នុងសិវថិកបព្វៈទាំងនោះ សមាធិភាវនានោះ គឺព្រះមានព្រះភាគ ទ្រង់ប្រកាសហើយ ក្នុងអសុភនិទ្ទេសឯណោះ, ចំណែកឯបព្វៈតែ ២ ប៉ុណ្ណោះ គឺអានាបានបព្វៈ និង បដិកូលបព្វៈ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអំណាចនៃសមាធិ (ភាវនា) ក្នុងអនុស្សតិនិទ្ទេសនេះ, បណ្ដាបព្វៈទាំង ២ នោះ អានាបានបព្វៈ ចាត់ជាកម្មដ្ឋានផ្សេង ដោយអំណាចនៃអានាបានស្សតិ (កម្មដ្ឋាន) ហ្នឹងឯង ព្រោះហេតុណា, ព្រោះហេតុនោះ ចំណែក ទ្វត្តិសា-ការកម្មដ្ឋាននោះណា ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយអំណាចនៃបដិកូលមនសិការ សង្គ្រោះយកខួរក្នុងក្បាល ដោយខួរក្នុងឆ្អឹង យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ [១] ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក មានស្បែកបិទបាំងជុំវិញ ពេញទៅដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ គឺ សក់ទាំងឡាយ មាននៅក្នុងកាយនេះ រោមមាននៅក្នុងកាយនេះ ក្រចកមាននៅក្នុងកាយនេះ ធ្មេញ មាននៅក្នុងកាយនេះ ស្បែកមាននៅក្នុងកាយនេះ សរសៃ មាន

១- សុ. ទី. ម. ភាគទី ១៧ ទំព័រទី ២៥២ ។

នៅក្នុងកាយនេះ ឆ្អឹងមាននៅក្នុងកាយនេះ ខួរក្នុងឆ្អឹង មាននៅក្នុងកាយនេះ តំរងនោម មាននៅក្នុងកាយនេះ បេះដូង មាននៅក្នុងកាយនេះ ថ្លើម មាននៅក្នុងកាយនេះ វាវ មាននៅក្នុងកាយនេះ ក្រពះ មាននៅក្នុងកាយនេះ សួត មាននៅក្នុងកាយនេះ ពោះវៀនធំ មាននៅក្នុងកាយនេះ ពោះវៀនតូច មាននៅក្នុងកាយនេះ អាហារថ្មី មាននៅក្នុងកាយនេះ អាហារចាស់ មាននៅក្នុងកាយនេះ ទឹកប្រមាត់ មាននៅក្នុងកាយនេះ ទឹកស្លេស្ម មាននៅក្នុងកាយនេះ ទឹកខ្ទុះ មាននៅក្នុងកាយនេះ ទឹកឈាម មាននៅក្នុងកាយនេះ ទឹកញើស មាននៅក្នុងកាយនេះ ទឹកដំបាខ្លាញ់ខាប់ មាននៅក្នុងកាយនេះ ទឹកភ្នែក មាននៅក្នុងកាយនេះ ទឹកខ្លាញ់រាវមាននៅក្នុងកាយនេះ ទឹកមាត់ មាននៅក្នុងកាយនេះ ទឹកសំបោរ មាននៅក្នុងកាយនេះ ទឹករំអិល មាននៅក្នុងកាយនេះ ទឹកមូត្រ មាននៅក្នុងកាយនេះ" ដូច្នេះ, ទ្វត្តិសាការកម្មដ្ឋាននេះ ព្រះមានព្រះភាគទ្រង់បំណងយកហើយថា កាយគតាសតិ ក្នុងអនុស្សតិនិទ្ទេសនេះ ។

(អធិប្បាយបាលីកាយគតាសតិ)

នេះ គឺជាការសំដែងនូវការចំរើន ក្នុងកាយគតាសតិកម្មដ្ឋាននោះ ដែលមានការពណ៌នាបាលីនាំមុន ដូចតទៅនេះ ។

បាឋៈថា "ឥមមេវ កាយំ" សេចក្ដីថា នូវកាយស្អុយ ដែលជាទីអាស្រ័យនៃមហាភូតរូបនេះ ។ បាឋៈថា "ឧទ្ធំ បាទតលា" សេចក្ដីថា ខាងលើអំពីផ្ទៃនៃជើង ។ បាឋៈថា "អធោ កេសមត្ថកា" សេចក្ដីថា ខាងក្រោមអំពីចុងសក់ ។ បទថា "តចបរិយន្តំ" សេចក្ដីថា មានស្បែករុំព័ទ្ធដោយជុំវិញ ។ បាឋៈថា "បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ" សេចក្ដីថា កាយនេះ ពេញដោយរបស់មិនស្អាត មានសក់ជាដើម មាន

ប្រការផ្សេងៗ ។ មានសំណួរថា គឺដោយប្រការដូចម្ដេច? ឆ្លើយថា: គឺ អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ។បេ។ មុត្តំ ។ បណ្ដាបទទាំងនោះ បទថា "អត្ថិ" គឺ សំវិជ្ជតិ ប្រែថាមាននៅ ។ បទថា "ឥមស្មឹ" គឺក្នុងកាយដែលព្រះអង្គត្រាស់ថា: ខាងលើ អំពីបាតជើងឡើងទៅ ខាងក្រោមអំពីចុងសក់ចុះមក មានស្បែកព័ទ្ធជុំវិញ ពេញដោយរបស់មិនស្អាតមានប្រការផ្សេងៗ ។ បទថា "កាយេ" គឺក្នុងសរីរៈ ។ សេចក្ដីថា សរីរៈ លោកហៅថា កាយ ព្រោះជាទីកើតនៃកោដ្ឋាសៈទាំងឡាយ មានសក់ជាដើម និង នៃរោគរាប់រយ មានរោគក្នុងភ្នែកជាដើម ដែលបណ្ឌិតគួរខ្ពើម ព្រោះកើតមកអំពីរបស់មិនស្អាត ។ បទទាំងឡាយថា "កេសា លោមា" ជាដើមនេះ គឺអាការៈ ៣២ មានសក់ជាដើម ។ បណ្ឌិតគប្បីជ្រាបសម្ពន្ធ ក្នុងបទបាលីនោះ យ៉ាងនេះថា "អត្ថិ ឥមស្មឹ កាយេ កេសា អត្ថិ ឥមស្មឹ កាយេ លោមា សក់ទាំងឡាយ មាននៅក្នុងកាយនេះ រោមទាំងឡាយ មាននៅក្នុងកាយនេះ" ដូច្នេះជាតួយ៉ាង ។

មែនពិត បុគ្គលណាមួយ កាលពិនិត្យមើល ក្នុងកលេវរៈដែលមានប្រវែង ១ ព្យាម មានប្រមាណប៉ុណ្ណោះនេះ គឺ ខាងលើចាប់ដើមតាំងអំពីបាតជើងទៅ ខាងក្រោមចាប់ដើមអំពីចុងសក់ចុះមក ដោយទីបំផុតជុំវិញ ចាប់ដើមអំពីស្បែក សូម្បីដោយអាការៈសព្វយ៉ាង ក៏មិនឃើញនូវភាពជារបស់ស្អាតណាមួយ ទោះជាកែវមុក្ដាក្ដី កែវមណីក្ដី កែវវិទូរ្យក្ដី ខ្លឹមក្រស្នាក្ដី ខ្លឹមចន្ទន៍ក្រហមក្ដី ការបូរក្ដី ទោះជាវត្ថុដទៃ មានលំអិតនៃគ្រឿងអប់ជាដើមក្ដី សូម្បីត្រឹមតែជាអណ្ដូឡើយ, តាមពិត ឃើញសុទ្ធតែជារបស់មិនស្អាត មានប្រការផ្សេងៗ ផ្សេងដោយកោដ្ឋាសៈ

មានសក់ និង រោមជាដើម គន់មើលទៅ មិនមានសេរី ដែលមានក្លិនស្អុយ និង គួរខ្ពើមក្រៃលែង តែប៉ុណ្ណោះឯង ។ ព្រោះហេតុនោះ ទើបព្រះអង្គ ទ្រង់ត្រាស់ថា "អត្ថិ ឥមស្មឹ កាយេ កេសា លោមា ។បេ។ មុត្តំ សក់ទាំងឡាយ មាននៅក្នុងកាយនេះ រោមទាំងឡាយ មាននៅក្នុងកាយនេះ ។ល។ ទឹកមូត្រ មាននៅក្នុងកាយនេះ " ដូច្នេះជាដើម ។

នេះជាការពណ៌នា ដោយបទសម្ពន្ធ ក្នុងបាលីនោះ ។

(ភាវនានិទ្ទេសនៃកាយគតាសតិ)

ក៏ឯអាទិកម្មិកកុលបុត្រ អ្នកប្រាថ្នាដើម្បីចំរើនកម្មដ្ឋាននេះ គប្បីចូលទៅរកកល្យាណមិត្រ មានប្រការដូចពោលមកហើយៗ រៀនយកនូវកម្មដ្ឋាននេះ ។ ចំណែកឯកល្យាណមិត្រនោះ កាលពោលនូវកម្មដ្ឋានដល់កុលបុត្រនោះ គប្បីប្រាប់ឧគ្គហកោសល្ល ដោយចំណែក ៧ និង មនសិការកោសល្ល ដោយចំណែក ១០ ។

(ឧគ្គហកោសល្ល)

ក្នុងកោសល្ល ទាំង ២ នោះ អាចារ្យគប្បីប្រាប់ឧគ្គហកោសល្ល ដោយវិធី ៧ បែប យ៉ាងដូច្នេះ គឺ ដោយវាចា ដោយចិត្ត ដោយពណ៌ ដោយទ្រង់ទ្រាយ ដោយទិស ដោយឱកាស (និង) ដោយបរិច្ឆេទ ។

(ផ្លូវវាចា)

ក៏ក្នុងបដិកូលមនសិការកម្មដ្ឋាននេះ ព្រះយោគាវចរ សូម្បីជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ក៏គប្បីធ្វើការស្វាធ្យាយ ដោយវាចាជាមុនសិន ក្នុងកាលដែលធ្វើទុកក្នុងចិត្ត ។ ព្រោះថា កាលព្រះយោគាវចរពួកខ្លះ ធ្វើការស្វាធ្យាយនោះឯង កម្មដ្ឋាន រមែងប្រាកដ ដូចកម្មដ្ឋាន ប្រាកដ ដល់ព្រះថេរៈពីរព្រះអង្គ ដែលបានរៀនកម្មដ្ឋាន ក្នុងសំណាក់ នៃព្រះមហា-

ទេវត្ថេរ អ្នកអាស្រ័យនៅក្នុងស្រុកឈ្មោះមលយៈ ។ បានឮមកថា ព្រះថេរៈ ត្រូវព្រះថេរៈទាំងពីរអង្គនោះ សូមរៀននូវកម្មដ្ឋានហើយ បានឲ្យនូវបាលី ក្នុងទ្វត្តិសាការកម្មដ្ឋាន ដោយប្រាប់ថា "អ្នកទាំងឡាយ ចូរធ្វើនូវការស្វាធ្យាយនេះឯង រហូត ៤ ខែ" ។ ថ្វីបើព្រះថេរៈទាំង២ រូបនោះស្ទាត់ជំនាញពីរ បី និកាយ ក៏ពិតមែនហើយ ក៏ប៉ុន្តែព្រះថេរៈទាំងពីររូបនោះ (នៅតែខិតខំ) ស្វាធ្យាយ នូវទ្វត្តិសាការៈ អស់ ៤ ខែ ទើបបាន (សំរេច) ជាសោតាបន្នបុគ្គល ព្រោះលោកជាអ្នកទទួលយក (នូវឱវាទ) ដោយគោរពមែនពិត ។ ព្រោះហេតុនោះ អាចារ្យអ្នកពោលនូវកម្មដ្ឋាន គប្បីប្រាប់អន្តេវាសិកថា "គ្រាដំបូង ចូរអ្នកធ្វើការស្វាធ្យាយ ដោយវាចាជាមុន" ។

(វិធីស្វាធ្យាយ)

ក៏កាលអន្តេវាសិកធ្វើ គប្បីកំណត់ នូវតចបញ្ចកកម្មដ្ឋានជាដើម (កម្មដ្ឋានដែលមានស្បែកជាគម្រប់ប្រាំ) ហើយធ្វើការស្វាធ្យាយ ដោយអំណាចអនុលោម និង បដិលោម ។ គឺគប្បីពោលថា "កេសា លោមា នខា ទន្តា ចតោ សក់ រោម ក្រចក ធ្មេញ ស្បែក" ដូច្នេះហើយ ពោល ដោយបដិលោមទៀត ថា "តចោ ទន្តា នខា លោមា កេសា ស្បែក ធ្មេញ ក្រចក រោម សក់" ដូច្នេះ ។

បន្ទាប់អំពីនោះមក អន្តេវាសិក គប្បីពោល ក្នុងវក្កបញ្ចកៈ (មានតំរងនោមជាគម្រប់ប្រាំ) ថា "មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តំរងនោម" ដូច្នេះហើយ ពោលដោយបដិលោមទៀតថា "វក្កំ អដ្ឋិមិញ្ជំ អដ្ឋី នហារូ មំសំ តចោ ទន្តា នខា លោមា កេសា តំរងនោម ខួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ

ក្រចក រោម សក់" ដូច្នេះ ។

បន្ទាប់ពីនោះមក អន្តេវាសិក គប្បីពោល ក្នុងបប្ផាសបញ្ចកៈ (មានសួតជាគម្រប់ប្រាំ) ថា "ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ បេះដូង ថ្លើម វាវ ក្រពះ សួត" ដូច្នេះហើយ ពោលដោយបដិលោមទៀតថា "បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ វក្កំ អដ្ឋិមិញ្ជំ អដ្ឋី នហារូ មំសំ តចោ ទន្តា នខា លោមា កេសា សួត ក្រពះ វាវ ថ្លើម បេះដូង តំរងនោម ខួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់" ដូច្នេះ ។

បន្ទាប់ពីនោះមក អន្តេវាសិក គប្បីពោល ក្នុងមត្ថលុង្គបញ្ចកៈ (មានខួរក្នុងក្បាលជាគម្រប់ប្រាំ) ថា "អន្តំ អន្តគុណំ ឧទរិយំ ករីសំ មត្ថលុង្គំ ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ខួរក្នុងក្បាល" ដូច្នេះហើយ ពោលដោយបដិលោមទៀតថា "មត្ថលុង្គំ ករីសំ ឧទរិយំ អន្តគុណំ អន្តំ បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ វក្កំ អដ្ឋិមិញ្ជំ អដ្ឋី នហារូ មំសំ តចោ ទន្តា នខា លោមា កេសា ខួរក្នុងក្បាល អាហារចាស់ អាហារថ្មី ពោះវៀនតូច ពោះវៀនធំ សួត ក្រពះ វាវ ថ្លើម បេះដូង តំរងនោម ខួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់" ដូច្នេះ ។

បន្ទាប់ពីនោះមក អន្តេវាសិក គប្បីពោល ក្នុងមេទច្ឆក្កៈ (មានទឹកជំបារខ្លាញ់ខាប់ជាគម្រប់ប្រាំមួយ) ថា "បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ ទឹកប្រមាត់ ទឹកស្លេស្ម ទឹកខ្ទុះ ទឹកឈាម ទឹកញើស ទឹកជំបារខ្លាញ់ខាប់" ដូច្នេះហើយពោលដោយបដិលោមទៀតថា "មេទោ

សេទោ លោហិតំ បុព្វោ សេម្ហំ បិត្តំ មត្ថលុង្គំ ករីសំ ឧទរិយំ អន្តគុណំ អន្តំ បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ វក្កំ អដ្ឋិមិញ្ជំ អដ្ឋី នហារូ មំសំ តចោ ទន្តា នខា លោមា កេសា ទឹកដំបារខ្វាញ់ខាប់ ទឹកញើស ទឹកឈាម ទឹកខ្ទុះ ទឹកស្លេស្ម ទឹកប្រមាត់ ខួរក្នុងក្បាល អាហារចាស់ អាហារថ្មី ពោះវៀនតូច ពោះវៀនធំ សួត ក្រពះ វាវ ថ្លើម បេះដូង តំរងនោម ខួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់” ដូច្នេះ ។

បន្ទាប់អំពីនោះមក អន្តេវាសិក គប្បីពោល ក្នុងមុត្តច្ឆក្កៈ (មានទឹកមូត្រជាគម្រប់ប្រាំមួយ) ថា “អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តំ ទឹកភ្នែក ទឹកខ្វាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ” ដូច្នេះហើយ ពោលដោយបដិលោមទៀតថា “មុត្តំ លសិកា សិង្ឃាណិកា ខេឡោ វសា អស្សុ មេទោ សេទោ លោហិតំ បុព្វោ សេម្ហំ បិត្តំ មត្ថលុង្គំ ករីសំ ឧទរិយំ អន្តគុណំ អន្តំ បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ វក្កំ អដ្ឋិមិញ្ជំ អដ្ឋី នហារូ មំសំ តចោ ទន្តា នខា លោមា កេសា ទឹកមូត្រ ទឹករំអិល ទឹកសំបោរ ទឹកប្រមាត់ ទឹកខ្វាញ់រាវ ទឹកភ្នែក ទឹកដំបារខ្វាញ់ខាប់ ទឹកញើស ទឹកឈាម ទឹកខ្ទុះ ទឹកស្លេស្ម ទឹកប្រមាត់ ខួរក្នុងក្បាល អាហារចាស់ អាហារថ្មី ពោះវៀនតូច ពោះវៀនធំ សួត ក្រពះ វាវ ថ្លើម បេះដូង តំរងនោម ខួរក្នុងឆ្អឹង ឆ្អឹង សរសៃ សាច់ ស្បែក ធ្មេញ ក្រចក រោម សក់” ដូច្នេះ ។

អន្តេវាសិក គប្បីធ្វើការស្វាធ្យាយ ដោយវាចា យ៉ាងដូច្នេះ អស់ពេល ១០០ ដងក្តី ១,០០០ ដងក្តី ១០០,០០០ ដងក្តី ។ ព្រោះថា

ដោយការស្វាធ្យាយ ដោយវាចា (យ៉ាងនេះ) របៀបកម្មដ្ឋាន រមែងស្ទាត់ជំនាញ ចិត្ត មិនស្ទុះទៅ ខាងនោះផង ខាងនេះផង កោដ្ឋាសៈទាំងឡាយ រមែងប្រាកដ គឺប្រាកដ ដូចជាជួរនៃម្រាមដៃផង ដូចជាជួរនៃជើងរបងផង យ៉ាងនោះឯង ។

(ចិត្ត-ពណ៌-ទ្រង់ទ្រាយ-ទិស-ឱកាស-បរិច្ឆេទ)

ក៏ព្រះយោគី ធ្វើការស្វាធ្យាយ ដោយវាចា យ៉ាងណា, សូម្បីដោយចិត្ត ក៏គប្បីធ្វើការស្វាធ្យាយ ក៏យ៉ាងដូច្នោះដែរ ។ ព្រោះថា ការស្វាធ្យាយដោយវាចា ក៏ជាបច្ច័យនៃការស្វាធ្យាយ ដោយចិត្តដែរ ។ ការស្វាធ្យាយដោយចិត្ត ក៏ជាបច្ច័យនៃការចាក់ធ្លុះនូវលក្ខណៈ ។

(១៥១) ពាក្យថា “វណ្ណតោ ដោយពណ៌” គឺព្រះយោគី គប្បីកំណត់ពណ៌នៃកោដ្ឋាសៈ (ចំណែក) ទាំងឡាយ មានសក់ជាដើម ។

ពាក្យថា “សណ្ឋានតោ ដោយទ្រង់ទ្រាយ” គឺព្រះយោគី គប្បីកំណត់ទ្រង់ទ្រាយ នៃកោដ្ឋាសទាំងនោះឯង ។

ពាក្យថា “ទិសតោ ដោយទិស” អធិប្បាយថា ក្នុងសរីរៈនេះ ខាងលើផ្ចិតឡើងទៅ ជាទិសខាងលើ ខាងក្រោមផ្ចិតចុះមក ជាទិសខាងក្រោម ព្រោះហេតុនោះ ព្រះយោគីគប្បីកំណត់ទិស ថា “កោដ្ឋាសនេះ (មាន) ក្នុងទិសឈ្មោះនេះ” ។

ពាក្យថា “ឱកាសតោ ដោយឱកាស” សេចក្តីថា ព្រះយោគី គប្បីកំណត់ឱកាស នៃកោដ្ឋាសនោះៗ យ៉ាងនេះថា “កោដ្ឋាសនេះ ឋិតនៅហើយ ក្នុងឱកាសឈ្មោះនេះ” ។

ពាក្យថា “បរិច្ឆេទតោ ដោយបរិច្ឆេទ” អធិប្បាយថា ការកំណត់

ពីរគឺការកំណត់នូវចំណែកស្មើគ្នា១ ការកំណត់នូវចំណែកមិនស្មើគ្នា១ ។ បណ្ដាការកំណត់ទាំង ២ នោះ បណ្ឌិតគប្បីជ្រាបការកំណត់នូវចំណែកស្មើគ្នា យ៉ាងនេះថា "កោដ្ឋាសនេះ គឺលោកបានកំណត់ហើយ ដោយចំណែកឈ្មោះនេះ ទាំងខាងក្រោម ទាំងខាងលើ ទាំងទទឹង" ដូច្នេះ ។ បណ្ឌិត គប្បីជ្រាបការកំណត់នូវចំណែកមិនស្មើគ្នា ដោយអំណាចភាពមិនលាយគ្នា យ៉ាងនេះថា "សក់ទាំងឡាយ គឺមិនមែនជារោម សូម្បីរោមទាំងឡាយ ក៏មិនមែនជាសក់ដែរ" ដូច្នេះជាតួយ៉ាង ។

(កិច្ចដែលគួរដឹងមុននឹងប្រាប់ឧគ្គហកោសល្យ)

(១៥២) ក៏ឯអាចារ្យ កាលប្រាប់ឧគ្គហកោសល្យ ដោយវិធី ៧ យ៉ាង ដូចពោលមកនេះ គប្បីដឹងថា "កម្មដ្ឋាននេះ គឺព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចជារបស់បដិកូលហ្នឹងឯង ក្នុងសូត្រឯនោះ ត្រាស់ដោយអំណាចជាធាតុ ក្នុងសូត្រឯនោះ" ហើយប្រាប់ចុះ ។ មែនពិត កម្មដ្ឋាននេះ ក្នុងមហាសតិបដ្ឋានសូត្រ ទ្រង់ត្រាស់ ដោយអំណាចជារបស់បដិកូលហ្នឹងឯង ក្នុងមហាហត្ថិបទោបមសូត្រ ក្នុងមហារាហុ-លោវាទសូត្រ និង ក្នុងធាតុវិភង្គសូត្រ ទ្រង់ត្រាស់ ដោយអំណាចជាធាតុ ។ ចំណែកក្នុងកាយគតាសតិសូត្រ ព្រះមានព្រះភាគទ្រង់ចំណែកឈាន៤ ព្រោះសំដៅយកបុគ្គលដែលកោដ្ឋាសមានសក់ជាដើម ប្រាកដច្បាស់ (ដល់គេ) ដោយពណ៌ ។ ក្នុងកម្មដ្ឋាន ២ យ៉ាងនោះ កម្មដ្ឋានដែលព្រះអង្គត្រាស់ ដោយអំណាចជាធាតុ ចាត់ជាវិបស្សនាកម្មដ្ឋាន ដែលទ្រង់ត្រាស់ ដោយអំណាចជារបស់បដិកូល ចាត់ជាសមថកម្មដ្ឋាន កម្មដ្ឋានក្នុងបដិកូលមនសិការបព្វៈនេះនុ៎ះ ចាត់ជាសមថកម្មដ្ឋានមែនពិត អាចារ្យគប្បីប្រាប់ឧគ្គហកោសល្យដោយវិធី៧ បែប ដូចពោលមកនេះ ។

(មនសិការកោសល្យ)

អាចារ្យ គប្បីប្រាប់មនសិការកោសល្យ ដោយវធី ១០ យ៉ាង ដូច្នេះ គឺ ដោយលំដាប់ ដោយមិនលឿនពេក ដោយមិនសន្សឹមពេក ដោយកិរិយាការពារនូវសេចក្ដីរាយមាយ ដោយការកន្លងនូវបញ្ញត្តិ ដោយការលះបង់នូវលំដាប់ ដោយអប្បនា និង ដោយសូត្របី ។

(មនសិការដោយលំដាប់)

បទថា "អនុបុព្វតោ ដោយលំដាប់" ក្នុងមនសិការកោសល្យ ១០ នោះ អធិប្បាយថា កម្មដ្ឋាននេះ ព្រះយោគីគប្បីធ្វើទុកក្នុងចិត្ត ដោយលំដាប់លំដោយ ចាប់ដើមអំពីការធ្វើនូវការស្វាធ្យាយ មិនគួរធ្វើទុកក្នុងចិត្ត ដោយការផ្ទោះរំលង ១ ឡើយ ។ ព្រោះថា កាលព្រះយោគីធ្វើទុកក្នុងចិត្ត ដោយការផ្ទោះរំលង ១ នឹងមានចិត្តលំបាក រមែងធ្លាក់ចុះ ព្រោះកិរិយាមិនបាននូវសេចក្ដីរីករាយ ដែលខ្លួនត្រូវបាន ដោយអំណាចនៃការវនាសម្បត្តិ មិនញុំាងការវនាឲ្យសំរេច ប្រៀបដូចជាបុរសដែលមិនឈ្លាសវៃ កាលឡើងកាន់បង្អោង មានកាំ ៣២ ដោយការផ្ទោះរំលង ១ កាំ មានកាយលំបាក រមែងធ្លាក់ចុះ មិនញុំាងការឡើង ឲ្យបានសំរេចឡើយ ក៏ដូច្នោះឯង ។

(មនសិការដោយមិនលឿនពេក)

ក៏សូម្បីព្រះយោគី កាលធ្វើការទុកក្នុងចិត្ត ដោយលំដាប់ គប្បីធ្វើទុកក្នុងចិត្ត ដោយមិនឲ្យលឿនពេកដែរ ។ ព្រោះថា កាលព្រះយោគីធ្វើទុកក្នុងចិត្ត ដោយលឿនហួសពេក កម្មដ្ឋាន រមែងដល់នូវទីបំផុតភ្លាមក៏ពិតមែនហើយ ក៏ប៉ុន្តែ កម្មដ្ឋាន មិនប្រាកដ មិននាំគុណវិសេសមកឲ្យ ប្រៀបដូចជាបុរសកាលដើរផ្លូវ អស់ចម្ងាយ ៣ យោជន៍ មិនបានកំណត់

នូវការឈានចុះទៅ និង ការលះបង់ ហើយធ្វើគមនាគមន៍ សូម្បីអស់វារៈ ៧ ដង ដោយសន្ទុះយ៉ាងលឿន ផ្លូវក៏ដល់នូវទីបញ្ចប់ ក៏ពិតមែនហើយ ក៏ប៉ុន្តែថា បុរសនោះ ត្រូវតែសួរផ្លូវ (គេ) ជាមុនសិន សឹមទៅក៏ដូច្នោះឯង ។ ព្រោះហេតុនោះ ព្រះយោគីគប្បីធ្វើការស្វាធ្យាយ ដោយមិនលឿនហួសពេក ។

(មនសិការដោយមិនសន្សឹមហួសពេក)

មួយទៀត ព្រះយោគីគប្បីធ្វើទុកក្នុងចិត្ត ដោយមិនសន្សឹមហួសពេក ប្រៀបដូចជាធ្វើទុកក្នុងចិត្ត ដោយមិនលឿនហួសពេក ក៏យ៉ាងនោះដែរ ។ ព្រោះថា កាលព្រះយោគីធ្វើទុកក្នុងចិត្ត ដោយសន្សឹមហួសពេក កម្មដ្ឋាន មិនដល់នូវទីបំផុត មិនជាបច្ច័យឲ្យបានសម្រេចនូវគុណវិសេស ដូចជាកាលបុរសប្រាថ្នា ដើម្បីដើរទៅកាន់ផ្លូវប្រវែង ៣ យោជន៍ ក្នុងថ្ងៃនោះឯង នៅបង្អែរបង្អង់ ក្នុងទីទាំងឡាយមានដើមឈើ ភ្នំ និង ស្រះ ជាដើម ក្នុងចន្លោះផ្លូវ, ផ្លូវមិនដល់នូវទីបំផុត ដោយពីរបីថ្ងៃ ទើបដល់ទីបំផុត ដូច្នោះឯង ។

(មនសិការដោយការការពារសេចក្ដីរាយមាយ)

បទថា "វិក្ខេបប្បដិពាហនតោ ដោយការការពារនូវសេចក្ដីរាយមាយ" សេចក្ដីថា ការដែលចិត្តលះបង់នូវកម្មដ្ឋានហើយរាយមាយ ក្នុងអារម្មណ៍ដ៏ក្រាស់ក្រែលដ៏ខាងក្រៅ ព្រះយោគីគប្បីការពារ ។ ព្រោះថា កាលបើមិនការពារទេ កាលបើសេចក្ដីរាយមាយ ទៅដ៏ខាងក្រៅមាន កម្មដ្ឋានរមែងសាបសូន្យ រមែងបាត់បង់ទៅ ប្រៀបដូចជាកាលបុរសដើរទៅកាន់ផ្លូវក្បែរជ្រោះ ជាផ្លូវដើរទៅតែជើងម្ខាង មិនកំណត់ជើងដែលត្រូវឈានទៅ វិលតែបែរមើលទៅខាងនុ៎ះផង ខាងនេះផង វារៈនៃជើង រមែងភ្លាត់

ធ្លាក់, (ជើង) គប្បីភ្លាត់អំពីផ្លូវនោះ ធ្លាក់ចុះទៅក្នុងជ្រោះដែលមានជម្រៅ ១០០ សន្ទូងបុរស ដូច្នោះឯង ។ ព្រោះហេតុនោះ ព្រះយោគី គប្បីធ្វើទុកក្នុងចិត្ត ដោយការការពារសេចក្ដីរាយមាយផង ។

(មនសិការដោយរំលងនូវបញ្ញត្តិ)

បទថា "បណ្ណត្តិសមតិក្កមនតោ ដោយរំលងនូវបញ្ញត្តិ" សេចក្ដីថា បញ្ញត្តិ ថា "កេសា លោមា" ដូច្នេះជាដើម នេះណា ព្រះយោគាវចរគប្បីរំលង នូវបញ្ញត្តិនោះហើយ តម្កល់ចិត្តថា "បដិកូល" ។ ដូចជាក្នុងពេលដែលទឹករកបានដោយកម្រ មនុស្សទាំងឡាយ ឃើញអណ្ដូងទឹកក្នុងព្រៃហើយ ចងនូវវត្ថុណាមួយ មានស្លឹកត្នោតជាដើមហ្នឹងឯង ទុកជាគ្រឿងសំគាល់ ក្នុងទីនោះ ហើយក៏មកតាមគ្រឿងសំគាល់នោះ ងូតផងផឹកផង, តែក្នុងពេលណា ដោយការត្រាច់ទៅជារឿយៗ នៃមនុស្សទាំងឡាយនោះ ស្នាមជើងមនុស្សដែលមកហើយៗ រមែងប្រាកដ, ក្នុងពេលនោះ មិនមានកិច្ចដោយគ្រឿងសំគាល់ទៀតទេ, មនុស្សទាំងឡាយ តែងទៅងូត និង ផឹកទឹក ក្នុងពេលដែលខ្លួនត្រូវការហើយៗ យ៉ាងណាមិញ, កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ដោយអំណាចនៃបញ្ញត្តិថា "កេសា លោមា..." ដូច្នេះ ក្នុងចំណែកខាងដើម, ភាពជាបដិកូល រមែងប្រាកដតមក ព្រះយោគាវចរ គប្បីរំលងចោលនូវបញ្ញត្តិ ថា "កេសា លោមា" ដូច្នេះហើយ តម្កល់ចិត្តទុក ក្នុងភាពជាបដិកូលតែម្យ៉ាង យ៉ាងនោះឯង ។

(មនសិការដោយការលះបង់នូវលំដាប់)

បទថា "អនុបុព្វមុញ្ចនតោ ដោយលះបង់លំដាប់" មានសេចក្ដីថា កោដ្ឋាសៈ (ចំណែក) ណាៗ មិនប្រាកដ ។ ព្រះយោគាវចរ អ្នកលះបង់ចោលនូវកោដ្ឋាសៈនោះៗ ឈ្មោះថា ធ្វើទុកក្នុងចិត្ត ដោយលះ

បង់នូវលំដាប់ ។ ក៏កាលអាទិកម្មិកបុគ្គល ធ្វើទុកក្នុងចិត្តថា “កេសា” មនសិការ ក៏ទៅទល់នឹងកោដ្ឋាសទីបំផុតគឺ “មុត្តំ” នេះតែម្ដង ឋិតនៅនិង កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តថា “មុត្តំ” មនសិការ ក៏ទៅទល់នឹងកោដ្ឋាស ខាងដើម គឺ “កេសា” នេះដូចគ្នា ។ គ្រានេះ កាលព្រះយោគាវចរនោះ ធ្វើទុកក្នុងចិត្តៗ កោដ្ឋាសទាំងឡាយខ្លះ រមែងប្រាកដកោដ្ឋាសទាំងឡាយខ្លះ រមែងមិនប្រាកដ ។ កោដ្ឋាសទាំងឡាយណាៗប្រាកដ, ព្រះយោគាវចរ គប្បីធ្វើការងារ ក្នុងកោដ្ឋាសទាំងឡាយនោះៗរហូតដល់កាលកោដ្ឋាសទាំងឡាយពីរ ប្រាកដ បណ្ដាកោដ្ឋាសទាំងពីរនោះ កោដ្ឋាសណាមួយ ប្រាកដជាក់ច្បាស់ដោយប្រពៃ ។ ក៏កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តជារឿយៗ នូវកោដ្ឋាសនោះឯង ដែលប្រាកដហើយយ៉ាងនេះ គប្បីញ៉ាំងអប្បនា ឲ្យកើតឡើងបាន ។

នេះជាឧបមា ក្នុងការលះបង់នូវលំដាប់នោះ ប្រៀបដូចជានាយព្រាន ប្រាថ្នាដើម្បីនឹងចាប់សត្វស្វា ដែលរស់នៅក្នុងព្រៃត្នោត ដែលមានដើមត្នោត ៣២ ដើម យកសរបាញ់ស្លឹកត្នោត ដែលឋិតនៅ ខាងដើមហើយធ្វើនូវសំឡេងសង្ឃ្រក, កាលបើដូច្នោះ សត្វស្វានោះ ក៏លោតទៅលើដើមត្នោតនោះៗ តាមលំដាប់ រហូតលោតទៅដល់ដើមត្នោត ជាទីបំផុតតែម្ដង, កាលបើដើមត្នោតទាំងនោះ ព្រានទៅធ្វើយ៉ាងនោះដដែលក្នុងទីនោះ, សត្វស្វា ក៏មកកាន់ដើមត្នោតខាងដើម ដោយន័យនោះឯងម្ដងទៀត សត្វស្វានោះ ទៅតាមលំដាប់រឿយៗ យ៉ាងនេះ លោតឡើងក្នុងទីដែលព្រានសង្ឃ្រកៗ ហ្នឹងឯង លបៗ ទៅក្រាបលើដើមត្នោតមួយដើម ហើយចាប់ស្លឹកត្នោតក្រពុំ ត្រង់កណ្ដាលដើមត្នោតនោះ យ៉ាងមាំល្អទោះជាត្រូវព្រានបាញ់ក៏មិនលោតឡើង យ៉ាងណា, ពាក្យឧបមេយ្យ ជា

គ្រឿងញ៉ាំងពាក្យឧបមាឲ្យដល់ព្រមនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះឯង។ នេះជាពាក្យគ្រឿងប្រៀបធៀប ដោយសេចក្ដីឧបមា ក្នុងអធិការនេះ ។

កោដ្ឋាសទាំងឡាយ ៣២ ក្នុងកាយនេះ ដូចជាដើមត្នោត ៣២ ដើម ក្នុងព្រៃត្នោត យ៉ាងដូច្នោះឯង ។ ចិត្តដូចជាសត្វស្វា ។ ព្រះយោ-គាវចរ ដូចជាព្រាន ។ កិរិយាត្រាច់ទៅតាមលំដាប់ ដោយអំណាច នៃអារម្មណ៍ ក្នុងកាយដែលមានចំណែក ៣២ នៃចិត្ត របស់ព្រះយោគី ដូចជាការរស់នៅក្នុងព្រៃត្នោតដែលមានដើមត្នោត ៣២ ដើម នៃសត្វស្វា ។ ការដែល កាលព្រះយោគី ចាប់ផ្ដើមប្រារព្ធធ្វើទុកក្នុងចិត្តថា “កេសា” ហើយ ចិត្ត ត្រាច់ទៅតាមលំដាប់ ឋិតនៅ ក្នុងចំណែកជាទីបំផុតហ្នឹងឯង ដូចជាការដែល កាលព្រានយកសរបាញ់ស្លឹកត្នោត ដែលឋិតនៅ ខាងដើម ហើយធ្វើសំឡេងស្រែកសង្ឃ្រក ស្វាក៏លោត លើដើមត្នោតនោះៗ ហើយទៅកាន់ដើមត្នោតជាទីបំផុត ។ ន័យសូម្បីក្នុងការត្រឡប់វិញទៀតក៏ដូចន័យនេះដែរ ។ ការដែល កាលព្រះយោគី ធ្វើទុកក្នុងចិត្តរឿយៗ នាកាលកោដ្ឋាសៈទាំងឡាយខ្លះៗ ប្រាកដហើយ លះបង់កោដ្ឋាសៈទាំងឡាយដែលមិនទាន់ប្រាកដ ហើយធ្វើនូវបរិកម្ម ក្នុងកោដ្ឋាសៈទាំងឡាយដែលប្រាកដហើយ ដូចជាការដែលសត្វស្វាទៅតាមលំដាប់ (ដើមត្នោត) រឿយៗ លោតឡើងក្នុងទីដែលព្រានស្រែកសង្ឃ្រកហើយៗ ។ ការដែលកាលកោដ្ឋាសៈទាំងឡាយ ២ ប្រាកដហើយ ក្នុងទីបំផុត កោដ្ឋាសៈណាប្រាកដជាក់ច្បាស់ដោយល្អ ព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត នូវកោដ្ឋាសៈនោះឯងរឿយៗ ហើយញ៉ាំងអប្បនា ឲ្យកើតឡើង ដូចជាការដែលសត្វស្វាក្រាប លើដើមត្នោតមួយដើម តាមលំដាប់ហើយ ចាប់នូវស្លឹកត្នោតក្រពុំត្រង់កណ្ដាលដើមត្នោតនោះ យ៉ាងមាំល្អ ទោះជាព្រានបាញ់ ក៏មិន

លោតឡើង ដូច្នោះឯង ។

ឧបមាដទៃទៀត ប្រៀបដូចជាភិក្ខុអ្នកមានការត្រាច់ទៅបិណ្ឌបាតជាប្រក្រតី ចូលទៅអាស្រ័យនូវស្រុកមានត្រកូល ៣២ បានភិក្ខា ២ ក្នុងផ្ទះជាដំបូងហ្នឹងឯង ហើយគប្បីលះបង់នូវភិក្ខា ១ ក្នុងផ្ទះខាងមុខ ស្អែកឡើង បានភិក្ខា ៣ ហើយគប្បីលះបង់នូវភិក្ខា ២ ក្នុងផ្ទះខាងមុខ ក្នុងថ្ងៃទី៣ បានភិក្ខាពេញបាត្រ ក្នុងផ្ទះខាងដើមនោះឯង ទៅកាន់អាសនសាលាហើយឆាន់ យ៉ាងណាមិញ, ពាក្យឧបមេយ្យ ជាគ្រឿងញ៉ាំងឧបមា ឲ្យដល់ព្រមនេះ បណ្ឌិតគប្បីជ្រាប ក៏យ៉ាងនោះឯង ។ ក៏អាការៈ ៣២ ដូចជាស្រុកមានត្រកូល ៣២ ។ ព្រះយោគាវចរ ដូចជាបិណ្ឌបាតិកភិក្ខុ ។ ការដែលព្រះយោគាវចរ ធ្វើការបរិកម្ម នូវអាការៈ ៣២ ដូចជាការចូលទៅនៅអាស្រ័យស្រុកនោះ នៃភិក្ខុនោះ ។ ការដែល កាលព្រះយោ-គាវចរ ធ្វើទុកក្នុងចិត្តៗ លះបង់នូវកោដ្ឋាសៈទាំងឡាយ ដែលមិនប្រាកដហើយ ធ្វើនូវការបរិកម្ម ក្នុងកោដ្ឋាសៈទាំងឡាយ ដែលប្រាកដហើយៗ រហូតដល់កោដ្ឋាសៈ ២ ដូចជាការដែលភិក្ខុ អ្នកមានកិរិយាត្រាច់ទៅបិណ្ឌបាតជាប្រក្រតី បានភិក្ខា ២ ក្នុងផ្ទះជាដំបូងហើយ លះបង់នូវភិក្ខា១ ក្នុងផ្ទះខាងមុខ និង ដូចជាក្នុងថ្ងៃ ទី២ បាននូវភិក្ខា ៣ ហើយលះបង់នូវភិក្ខា ២ ក្នុងផ្ទះខាងមុខ ។ ការដែល បណ្ដាកោដ្ឋាសៈទាំងឡាយ ២ កោដ្ឋាសៈណា ប្រាកដជាក់ច្បាស់ដោយល្អ ព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត នូវកោដ្ឋាសៈនោះឯងរឿយៗ ហើយញ៉ាំងអប្បនា ឲ្យកើតឡើង ដូចជាក្នុងថ្ងៃទី៣ ការដែលភិក្ខុអ្នកមានការត្រាច់ទៅបិណ្ឌបាតជាប្រក្រតី បាននូវភិក្ខាពេញបាត្រ ក្នុងផ្ទះខាងដើមហ្នឹងឯង ហើយគង់ឆាន់ លើអាសន-សាលា យ៉ាងដូច្នោះឯង ។

(មនសិការដោយអប្បនា)

បទថា "អប្បនាតោ ដោយអប្បនា" គឺ ដោយកោដ្ឋាសដែលនាំឲ្យកើតអប្បនា ។ នេះជាអធិប្បាយ ក្នុងបទនោះ ថា "បណ្ឌិតគប្បីជ្រាបថា ក្នុងកោដ្ឋាសទាំងឡាយ មានសក់ជាដើម អប្បនា មាន ក្នុងកោដ្ឋាសមួយៗ" ដូច្នេះ ។

(១៥៣) នេះជាអធិប្បាយ ក្នុងបទថា "ក៏សូត្រ ៣" នោះ សូត្រ ៣ នេះ គឺ : អធិចិត្តសូត្រ សីតិភាវសូត្រ ពោជ្ឈង្គកោសលសូត្រ ព្រះយោគាវចរ គប្បីជ្រាប ដើម្បីប្រកបវិរិយសមាធិ ។

(អធិចិត្តសូត្រ)

បណ្ដាសូត្រទាំង ៣ នោះ សូត្រនេះថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបនូវអធិចិត្តហើយ ត្រូវធ្វើទុកក្នុងចិត្តនូវនិមិត្ត ៣ យ៉ាង ក្នុងកាលដ៏គួរ គឺ ត្រូវធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្ត ក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្ត នូវបគ្គាហនិមិត្ត ក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្ត នូវឧបេក្ខានិមិត្ត ក្នុងកាលដ៏គួរ១ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្ត នូវសមាធិនិមិត្ត តែមួយចំណែក ហេតុនោះ គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្ដីខ្ជិលច្រអូស ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្ត នូវបគ្គាហនិមិត្ត តែមួយចំណែក ហេតុនោះ គប្បីនាំចិត្ត ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្ដីរាយមាយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត តែមួយចំណែក ហេតុនោះ គប្បីនាំចិត្តមិនឲ្យតាំងមាំ ដោយប្រពៃ ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ។ ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុអ្នកប្រកបនូវអធិចិត្ត រមែង

ធ្វើទុកក្នុងចិត្ត នូវសមាធិនិមិត្ត បគ្គាហនិមិត្ត ឧបេក្ខានិមិត្ត ក្នុងកាលដ៏គួរ ទើបចិត្តនោះក៏ទន់ គួរដល់ការនាកម្ម ជាចិត្តភ្លឺផ្លេក មិនរឹង តាំងមាំដោយប្រពៃ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាជាងមាសក្តី សិស្សជាងមាសក្តី ចាត់ចែងបាវ លុះចាត់ចែងបាវរួចហើយ ក៏ដុតមាត់បាវ លុះដុតនូវមាត់បាវរួចហើយ ក៏យកដង្កៀបចៀបមាសដាក់ ក្នុងមាត់បាវ ហើយសប់ ក្នុងកាលដ៏គួរ បំព្រំទឹក ក្នុងកាលដ៏គួរ សំឡឹងមើលក្នុងកាលដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ បើជាងមាសក្តី សិស្សជាងមាសក្តី គប្បីសប់តែមាសនោះ មួយចំណែក ហេតុនោះ ជាហេតុធ្វើឲ្យមាសឆេះរលួយទៅ ។ ម្នាលភិក្ខុទាំងឡាយ បើជាងមាសក្តី សិស្សជាងមាសក្តី បំព្រំតែមាសនោះដោយទឹក មួយចំណែក ហេតុនោះជាហេតុធ្វើឲ្យមាសត្រជាក់។ ម្នាលភិក្ខុទាំងឡាយ បើជាងមាសក្តី សិស្សជាងមាសក្តី សំឡឹងមើលតែមាសនោះ មួយចំណែក ហេតុនោះជាហេតុធ្វើមិនឲ្យមាសផ្ទិនសព្វសាច់បាន ។ ម្នាលភិក្ខុទាំងឡាយ ក៏កាលណាជាងមាសក្តី សិស្សជាងមាសក្តី សប់មាសនោះ ក្នុងកាលដ៏គួរ បំព្រំដោយទឹក ក្នុងកាលដ៏គួរ សំឡឹងមើល ក្នុងកាលដ៏គួរហើយ ទើបមាសនោះទៅជាមាសដ៏ទន់ គួរដល់ការងារ ជាមាសមានសម្បុរភ្លឺផ្លេក មិនស្រួយ គួរបង្អោនទៅ ដើម្បីការងារ ដោយប្រពៃផង, បើគេប្រាថ្នាគ្រឿងប្រដាប់ប្លែកៗ ណាៗ ទោះជាដំបារមាសក្តី កណ្ឋលក្តី គ្រឿងប្រដាប់កក្តី កម្រងមាសក្តី រមែងសម្រេចប្រយោជន៍នោះៗ បាន យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត ត្រូវធ្វើទុកក្នុងចិត្តនូវនិមិត្ត ៣ យ៉ាង ក្នុងកាលដ៏គួរ ។ល។ ចិត្តនោះ រមែងតាំងមាំដោយប្រពៃ ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ, បុគ្គលបង្អោនទៅ

នូវចិត្ត ដើម្បីធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ណាៗ កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុងធម៌នោះៗ ដើម្បីធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម [១] ” ដូច្នេះ បណ្ឌិត គប្បីជ្រាបថា ឈ្មោះអធិចិត្តសូត្រ ។

(សីតិភាវសូត្រ)

សូត្រនេះថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ប្រកបព្រមដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសេចក្តីត្រជាក់ចិត្ត ដ៏ឧត្តម ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចិត្តដែលគួរសង្កត់សង្កិន ក្នុងពេលណា ក៏សង្កត់សង្កិនចិត្ត ក្នុងពេលនោះ១ ចិត្តដែលគួរផ្គងឡើង ក្នុងពេលណា ក៏ផ្គងចិត្តឡើងក្នុងពេលនោះ ១ ចិត្តដែលគួរធ្វើឲ្យរីករាយ ក្នុងពេលណា ក៏ធ្វើឲ្យចិត្តរីករាយក្នុងពេលនោះ ១ ចិត្តដែលគួរធ្វើឲ្យព្រងើយ ក្នុងពេលណា ក៏ធ្វើចិត្តឲ្យព្រងើយ ក្នុងពេលនោះ ១ ជាអ្នកស្ទុះចុះទៅ ក្នុងធម៌ដ៏ថ្លៃថ្លា ១ ត្រេកអរ ក្នុងព្រះនិព្វាន ១, ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសេចក្តីត្រជាក់ចិត្តដ៏ឧត្តម [២] ” ដូច្នេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះសីតិភាវសូត្រ ។

(ពោជ្ឈង្គកោសល្លសូត្រ)

ចំណែកសត្តពោជ្ឈង្គសូត្រ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយហ្នឹងឯង ក្នុងអប្បនាកោសល្លកថា ថា “ម្នាលភិក្ខុទាំងឡាយ ចិត្តជាធម្មជាតិរួញរា ក្នុងសម័យណា កាលនោះ ជាកាលមិនគួរ ដើម្បីចំរើននូវបស្សទ្ធិពោជ្ឈង្គ ក្នុងសម័យនោះ យ៉ាងនេះឯង...” ដូច្នេះជាដើម ។

១– សុ. អំ. តិ. ភាគ ៤១ ទំព័រ ៣៨៥។ ២– អំ. ឆ. ភាគ ៤៦ ទំព័រ ៣០៩ ។

កម្មដ្ឋាន គឺព្រះយោគីនោះ ធ្វើនូវឧគ្គហកោសល្យ ៧ ប្រការនេះ ឲ្យបានយ៉ាងល្អហើយផង កំណត់មនសិការកោសល្យ ១០ ប្រការនេះ ដោយប្រពៃផង តាមន័យដែលពោលមកនេះ ហើយគប្បីរៀន ឲ្យបានល្អប្រសើរ ដោយអំណាចនៃកោសល្យទាំងពីរប្រការ ។

(មុននឹងផ្ដើមកម្មដ្ឋាន)

ក៏ប្រសិនណាបើព្រះយោគាវចរនោះ មានសេចក្ដីសប្បាយ ក្នុងវត្តតែមួយហ្នឹងឯង ជាមួយនឹងអាចារ្យ, ព្រះយោគាចវរនោះ ក៏មិនត្រូវឲ្យអាចារ្យសំដែងប្រាប់ ដោយពិស្ដារ យ៉ាងនេះឡើយ ប្រកបកម្មដ្ឋានរឿយៗ បាននូវគុណវិសេសស្រេចហើយ សឹមឲ្យលោកអាចារ្យសំដែងប្រាប់ ក្នុងថ្នាក់ខ្ពស់ឡើងៗ ។ (ប៉ុន្តែ) ព្រះយោគាវចរ មានប្រាថ្នាចង់នៅក្នុងទីដទៃ ត្រូវឲ្យអាចារ្យដំដែងប្រាប់ ឲ្យបានពិស្ដារ ដោយវិធីដូចដែលយើងពោលមកហើយ ប្រែប្រួលរឿយៗ កាត់ផ្ដាច់នូវទីដែលសង្ស័យទាំងអស់ចេញហើយ លះបង់នូវសេនាសនៈ ដែលមិនសមគួរ តាមន័យដែលបានពោលមកហើយ ក្នុងបឋវីកសិណនិទ្ទេសឯណោះ រួចហើយនៅក្នុងវត្តដែលសមគួរ ធ្វើការផ្ដាច់បង់នូវបលិពោធតូចតាចចោលហើយ ធ្វើបរិកម្ម ដោយកិរិយាធ្វើទុកក្នុងចិត្តជាបដិកូល ។

ក៏ព្រះយោគាវចរ កាលធ្វើ ត្រូវកាន់យកនូវនិមិត្ត ក្នុងសក់ទាំងឡាយជាមុនសិន ។ សួរថា: ត្រូវកាន់យកនូវនិមិត្ត ក្នុងសក់ទាំងឡាយជាមុន យ៉ាងដូចម្ដេច? ។ ឆ្លើយថា: ព្រះយោគាវចរ គប្បីដកសក់មួយសរសៃ ឬ ២ សរសៃ ដាក់លើបាតដៃហើយ កំណត់ពណ៌ជាដំបូង ។ កិរិយាដែលព្រះយោគី រមិលមើលនូវសក់ទាំងឡាយ សូម្បីក្នុងទីនៃសក់ដែលដាច់ហើយក៏គួរ ។ សូម្បីព្រះយោគី រមិលមើលនូវសក់ទាំងឡាយ

ដែលធ្លាក់ហើយ ក្នុង(កែវ)ទឹក ឬ ដែលធ្លាក់ហើយ ក្នុង(ចាន)បបរ រឹតតែគួរណាស់ទៅទៀត។ ព្រះយោគី ឃើញក្នុងពេលដែលសក់ខ្មៅហើយ គប្បីធ្វើទុកក្នុងចិត្ត ថា សក់ទាំងឡាយខ្មៅ, ឃើញ ក្នុងពេលដែលសក់ស ហើយគប្បីធ្វើទុកក្នុងចិត្ត ថា សក់ទាំងឡាយ-ស ។ តែព្រះយោគី (ឃើញ) ក្នុងកាលនៃសក់លាយគ្នា ក៏គប្បីធ្វើទុកក្នុងចិត្ត ដោយអំណាចនៃសក់ក្រាស់ ។ ក៏ព្រះយោគី ឃើញក្នុងសក់ទាំងឡាយហើយកាន់យកនូវនិមិត្ត យ៉ាងណា, សូម្បីក្នុងកោដ្ឋាសៈ ដែលមានក្រចក ជាគម្រប់ ៥ ទាំងមូល គ្រាន់តែឃើញហើយ ក៏គប្បីកាន់យកនិមិត្ត ក៏យ៉ាងនោះដែរ ។ លុះព្រះយោគី កាន់យកនូវនិមិត្តយ៉ាងនេះហើយ គប្បីកំណត់នូវចំណែកទាំងពួងទាំងឡាយ ដោយអំណាចពណ៌ ទ្រង់ទ្រាយ ទិស ឱកាស និងបរិច្ឆេទហើយ កំណត់ភាពនៃអាការៈ ថា ជារបស់បដិកូល ៥ ប្រការ ដោយអំណាចនៃពណ៌ ទ្រង់ទ្រាយ ក្លិន ទីនៅអាស្រ័យ និង ឱកាស ។

អនុបុព្វិកថា ក្នុងការកំណត់នូវលក្ខណៈ និង ភាពបដិកូលនោះ ក្នុងកោដ្ឋាសៈទាំងពួងទាំងឡាយ មានដូចតទៅនេះ ។

(សក់)

(១៥៤) ជាដំបូង សក់ទាំងឡាយ ដោយពណ៌ជាប្រក្រតី ពណ៌ខ្មៅ មានពណ៌ដូចជាផ្លែផ្គាំ ។ ដោយទ្រង់ទ្រាយ វែង មូល មានទ្រង់ទ្រាយដូចជាជង់នៃជញ្ជីង ។ ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាស លោកកំណត់ហើយ ក្នុងខាងទាំងឡាយទាំង ២ តាមគុម្ពត្រចៀកទាំងឡាយ ខាងមុខ តាមទីបំផុតនៃថ្ងាស់ ខាងក្រោយ តាមកញ្ចឹង-ក ។ ស្បែកស្រស់សំរាប់ស្រោបលលាដ៍ក្បាល ជាឱកាសនៃសក់ទាំងឡាយ។ ដោយបរិច្ឆេទ សក់ទាំងឡាយ លោកកំណត់ហើយខាងក្រោម ដោយផ្ទៃ

នៃឫសរបស់ខ្លួនដែលចូលទៅអស់ទីត្រឹមតែចុងស្រូវ ក្នុងស្បែកសំរាប់រុំ
នូវក្បាលហើយតាំងនៅ ខាងលើ កំណត់ ដោយអាកាស ទទឹង កំណត់
ដោយសរសៃសក់ជាមួយគ្នា ។ ការកំណត់ ដោយន័យថា “សក់ទាំង
ឡាយពីរសរសៃ មិនអាចមាន ក្នុងទីជាមួយគ្នាបានទេ” នេះ ឈ្មោះថា
ការកំណត់ដោយចំណែករបស់ខ្លួន (សភាគបរិច្ឆេទ) ។ ធម្មតាសក់ទាំង
ឡាយ ដែលលោកមិនបានធ្វើឲ្យលាយគ្នា ដោយចំណែក ៣១ ដ៏សេស
ទាំងឡាយ យ៉ាងនេះ ថា “សក់ទាំងឡាយមិនមែនរោម រោមទាំងឡាយ
ក៏មិនមែនសក់” ដូច្នេះ ។ ការកំណត់នេះ ថា “ចំណែកនុ៎ះ ជាចំណែក
ដោយឡែកៗ” ឈ្មោះថា វិសភាគបរិច្ឆេទ ។ នេះជាការកំណត់ ដោយ
លក្ខណៈ មានពណ៌ជាដើម នៃសក់ទាំងឡាយ ។ ឯនេះជាការកំណត់
ដោយបដិកូល ៥ ប្រការ ដោយអំណាចនៃលក្ខណៈ មានពណ៌ជាដើម
នៃសក់ទាំងឡាយនោះ ។ ធម្មតាសក់ទាំងឡាយនេះ ជារបស់បដិកូល
ដោយពណ៌ខ្លះ បដិកូល ដោយទ្រង់ទ្រាយខ្លះ បដិកូល ដោយក្លិនខ្លះ
បដិកូល ដោយទីនៅអាស្រ័យខ្លះ បដិកូល ដោយឱកាសខ្លះ ។ ដ្បិតថា
ជនទាំងឡាយ ឃើញវត្ថុអ្វីមួយ ដែលមានពណ៌ដូចជាសក់ ក្នុងភាជន៍
នៃបបរក្តី ក្នុងភាជន៍នៃបាយក្តី សូម្បីជាទីគាប់ចិត្ត ហើយខ្ពើមរអើមថាៈ
វត្ថុនេះ លាយដោយសក់ ចូរអ្នកទាំងឡាយ នាំយកវាចេញទៅ” ។ សក់
ទាំងឡាយ ជារបស់បដិកូល ដោយពណ៌ខ្លះ យ៉ាងនេះឯង ។

ម្យ៉ាងទៀត ជនទាំងឡាយសូម្បីបរិភោគ ក្នុងវេលាយប់ ទុកជា
ពាល់ត្រូវហើយ នូវសរសៃនៃសូត្រ ឬ ឬថា នូវសរសៃនៃក្រចៅ មាន
ទ្រង់ទ្រាយដូចជាសក់ ហើយខ្ពើមរអើម យ៉ាងដូច្នោះដែរ ។ សក់ទាំង
ឡាយ ជារបស់បដិកូល ដោយទ្រង់ទ្រាយ យ៉ាងដូច្នេះឯង ។

ម្យ៉ាងទៀត ក្លិននៃសក់ទាំងឡាយ ដែលប្រាសចាកការតាក់តែង
មានការលាបប្រេង ផ្កា និងធូបជាដើម ជាក្លិនដែលបុគ្គលខ្ពើមក្រៃពេក។
ក្លិននៃសក់ទាំងឡាយ ដែលបុគ្គលដាក់ក្នុងភ្លើង ជាក្លិនគួរខ្ពើមក្រៃលែង
ជាងនោះទៅទៀត ។ មែនពិត សក់ទាំងឡាយ ដោយពណ៌ និង ទ្រង់
ទ្រាយ មិនគួរជារបស់បដិកូលឡើយ ប៉ុន្តែ ដោយក្លិន ជារបស់បដិកូល
ហ្នឹងឯង ។ ដូចជាលាមកនៃកុមារដែលនៅក្មេង ដោយពណ៌ មានពណ៌
ដូចជារមៀត សូម្បីដោយទ្រង់ទ្រាយ ក៏មានទ្រង់ទ្រាយ ដូចជាដុំរមៀត,
មួយទៀត សាកសពឆ្កែខ្មៅដែលហើមប៉ោងឡើង ត្រូវគេបោះចោលលើ
ទីកន្លែងចោលសំរាម ដោយពណ៌ មានពណ៌ដូចជាត្នោតទុំ ដោយទ្រង់
ទ្រាយ មានទ្រង់ទ្រាយបីដូចជាទ្រង់ទ្រាយសំភោរ ដែលគេលះបង់ចោល
ហើយ, សូម្បីចង្កូមទាំងឡយ នៃឆ្កែនោះ ក៏មានទ្រង់ទ្រាយ ដូចជាផ្កាម្លិះ
ក្រពុំ ព្រោះហេតុនោះ លាមកនៃកុមារ និង សាកសពនៃឆ្កែខ្មៅទាំងពីរ
ដោយពណ៌ និង ទ្រង់ទ្រាយ មិនគួរជារបស់បដិកូលទេ ប៉ុន្តែ ដោយក្លិន
ជារបស់បដិកូលហ្នឹងឯង យ៉ាងណាមិញ, សូម្បីសក់ទាំងឡាយ ក៏យ៉ាង
ដូច្នោះដែរ ដោយពណ៌ និង ទ្រង់ទ្រាយ មិនគួរជារបស់បដិកូលទេ ប៉ុន្តែ
ដោយក្លិន ជារបស់បដិកូល ពិតមែនហ្នឹងឯង ។

មួយទៀត បន្លែជាប្រយោជន៍ ដល់សំឡ ដែលដុះហើយ ដោយ
ការហូរចេញ នៃទឹកជ្រាំអំពីស្រុក ក្នុងទីមិនស្អាត ជាវត្ថុគួរខ្ពើម មិនគួរ
នឹងបរិភោគ នៃមនុស្សអ្នកក្រុងទាំងឡាយ យ៉ាងណាមិញ, សូម្បីសក់
ទាំងឡាយ ក៏ឈ្មោះថា ជារបស់គួរខ្ពើម ព្រោះភាពនៃសក់នោះដុះហើយ
ដោយកិរិយាហូរចេញ នៃវត្ថុមិនស្អាត មានខ្ទុះ ឈាម ទឹកមូត្រ អាហារ
ចាស់ ប្រមាត់ និង ស្លេស្ម ជាដើម ក៏យ៉ាងដូច្នោះដែរ ។

នេះ ជាភាពបដិកូល ដោយទីនៅអាស្រ័យ នៃសក់ទាំងឡាយនោះ ។

មួយទៀត ធម្មតាសក់ទាំងឡាយនេះ ដុះហើយ ក្នុងគំនរ នៃចំណែក ៣១ ដូចបន្លែដែលដុះហើយ ក្នុងគំនរនៃលាមក, សក់ទាំងនោះឈ្មោះថា ជារបស់គួរខ្ពើម យ៉ាងក្រៃលែង ព្រោះភាពនៃសក់នោះ ដុះហើយ ក្នុងទីដែលមិនស្អាត ដូចជាបន្លែដែលដុះហើយ ក្នុងទីទាំងឡាយមានព្រៃស្មសាន និង ទីបោលសំរាមជាដើមផង ដូចជាផ្កាឈូក និង ផ្កាលំចង់ជាដើម ដែលដុះហើយ ក្នុងទីទាំងឡាយដែលមិនស្អាត មានស្នាមភ្លោះជាដើមផង ដូច្នេះឯង ។ នេះជាភាពបដិកូល ដោយឱកាស នៃសក់ទាំងឡាយនោះ ។

ព្រះយោគី គប្បីកំណត់ភាពបដិកូល នៃសក់ទាំងឡាយ យ៉ាងណាមិញ, ក៏គប្បីកំណត់ភាពបដិកូល ដោយចំណែក ៥ យ៉ាង ដោយអំណាយនៃពណ៌ ទ្រង់ទ្រាយ ទិស ឱកាស និង បរិច្ឆេទ នៃចំណែកទាំងពួង ក៏យ៉ាងដូច្នោះដែរ ។ តែព្រះយោគី គប្បីកំណត់ចំណែកទាំងឡាយទាំងពួង ផ្សេងៗ គ្នា ដោយអំណាច (លក្ខណៈគឺ) ពណ៌ ទ្រង់ទ្រាយ ទិស ឱកាស និង បរិច្ឆេទ ។

(រោម)

បណ្ដាចំណែកទាំងឡាយនោះ រោមទាំងឡាយ គប្បីកំណត់មុន រោមតាមប្រក្រតី មាន ៩០,០០០ រណ្ដៅ ដោយពណ៌ប្រក្រតី ជារោមមានពណ៌មិនខ្មៅ ដូចជាសក់ទេ តែជារោមមានពណ៌លឿង លាយខ្មៅបន្តិច ។ ដោយទ្រង់ទ្រាយ រោមទាំងឡាយ មានចុងឱនចុះ មានទ្រង់ទ្រាយ ដូចជាឫសត្នោត ។ ដោយទិស រោម កើតក្នុងទិសទាំង ២ ។ ដោយឱកាស រោមទាំងឡាយ លើកលែងនូវឱកាស នៃសក់ទាំងឡាយ

ដែលតាំងនៅហើយផង នូវបាតដៃបាតជើងទាំងឡាយចេញផង ភាគច្រើន ដុះហើយ ក្នុងស្បែកដែលស្រោបសរីរៈដ៏សេស ។ ដោយបរិច្ឆេទ រោមទាំងឡាយ លោកកំណត់ហើយ ខាងក្រោម ដោយឫស របស់ខ្លួន ដែលចូលទៅ អស់ទីត្រឹមតែមួយលិខា ក្នុងស្បែកដែលស្រោបសរីរៈ ហើយតាំងនៅ ខាងលើ ដោយឱកាស ខាងទទឹង កំណត់ ដោយសរសៃរោមគ្នាឯង ។ កិរិយាកំណត់ ដោយន័យ ថា "រោមទាំងឡាយ ២ សរសៃ មិនមាន ក្នុងទីជាមួយគ្នាបានទេ" នេះ ជាការកំណត់នូវចំណែករបស់ខ្លួន នៃរោមទាំងឡាយនោះ ។ កិរិយាកំណត់នូវចំណែកមិនស្មើគ្នាប្រាកដស្មើ ដោយ (ការកំណត់) សក់ដូចគ្នាដែរ ។

(ក្រចក)

ពាក្យថា "ក្រចកទាំងឡាយ" ជាឈ្មោះនៃត្របក នៃក្រចកទាំងឡាយ ២០ ។ ក្រចកទាំងអស់នោះ ដោយពណ៌ ជាពណ៌-ស ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយដូចជាស្រកាត្រី ។ ដោយទិស ក្រចកទាំងឡាយ ដុះហើយ ក្នុងទិសទាំងឡាយពីរ គឺ ក្រចកជើង ដុះក្នុងទិសខាងក្រោម ក្រចកដៃ ដុះក្នុងទិសខាងលើ ។ ដោយឱកាស ក្រចកទាំងឡាយតាំងនៅហើយ លើខ្នងខាងចុង នៃម្រាមដៃទាំងឡាយ ។ ដោយបរិច្ឆេទ ក្នុងទិសទាំង ៣ លោកកំណត់ហើយ ដោយសាច់ខាងចុងនៃម្រាមទាំងឡាយ ខាងក្នុង កំណត់ដោយសាច់ខ្នងនៃម្រាមដៃ ខាងក្រៅ និង ខាងចុង កំណត់ដោយឱកាស ខាងទទឹង កំណត់ដោយក្រចកដូចគ្នា ។ ការកំណត់ ដោយន័យថា "ក្រចកទាំងពីរ មិនមាន ក្នុងទីជាមួយគ្នាបានទេ" នេះ ជាការកំណត់នូវចំណែករបស់ខ្លួននៃក្រចកទាំងឡាយនោះ ។ ឯការកំណត់ នូវចំណែកមិនស្មើ ប្រាកដស្មើ ដោយសក់ដែរ ។

(ធ្មេញ)

(១៥៥) ពាក្យថា "ធ្មេញទាំងឡាយ" គឺឆ្អឹងធ្មេញ ៣២ នៃបុគ្គលអ្នកមានធ្មេញគ្រប់គ្រាន់ ។ ធ្មេញទាំង ៣២ នោះឯង ដោយពណ៌ មានពណ៌-ស ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយច្រើនប្រការ ។ មែនពិតបណ្ដាធ្មេញទាំងនោះ ធ្មេញទាំងឡាយ ៤ ត្រង់កណ្ដាល ធ្មេញជួរក្រោមមុន មានទ្រង់ទ្រាយដូចជាគ្រាប់ឃ្លោក ដែលគេតំរៀប តាមលំដាប់ លើដុំដីស្អិត ។ ទាំងសងខាង នៃធ្មេញកណ្ដាលទាំង ៤ នោះ ធ្មេញមួយៗមានឫសមួយ មានចុងមួយ មានទ្រង់ទ្រាយដូចជាផ្កាម្លិះក្រពុំ ។ បន្ទាប់មក ធ្មេញមួយៗ មានឫស ២ មានចុង ២ មានទ្រង់ទ្រាយ ដូចជាឈើទល់រទេះ ។ បន្ទាប់ពីនោះ ធ្មេញទាំងឡាយពីរៗ មានឫស ៣ មានចុង ៣ ។ បន្ទាប់ពីនោះ ធ្មេញទាំងឡាយពីរៗ មានឫស ៤ មានចុង ៤ ដូច្នេះឯង ។ សូម្បីក្នុងជួរធ្មេញខាងលើ ក៏មានន័យដូច្នេះដែរ ។ ដោយទិស ធ្មេញទាំងនោះ ដុះហើយក្នុងទិសខាងលើ ។ ដោយឱកាស ធ្មេញទាំងនោះ តាំងនៅហើយ ត្រង់ឆ្អឹងចង្កាទាំង ២ ។ ដោយបរិច្ឆេទ ធ្មេញទាំងនោះ លោកកំណត់ហើយ ខាងក្រោម ដោយឫសរបស់ខ្លួន ដែលតាំងនៅហើយ លើឆ្អឹងចង្កា ខាងលើ កំណត់ដោយឱកាស ខាងទទឹងកំណត់ ដោយគ្នា និង គ្នា ។ កិរិយាកំណត់ ដោយន័យ ថា "ធ្មេញទាំងឡាយ ២ មិនមាន ក្នុងទីជាមួយគ្នាបានទេ" នេះជាការកំណត់នូវចំណែករបស់ខ្លួន នៃធ្មេញទាំងនោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នាប្រាកដស្មើ ដោយសក់នោះឯង ។

(ស្បែក)

ពាក្យថា "ស្បែក" គឺ ស្បែកដែលរុំព័ទ្ធសរីរៈទាំងមូលឋិតនៅ ។

ស្បែកសម្បុរថ្ងៃណា ដែលបុគ្គលទាញមកអំពីសរីរៈទាំងមូល ជាស្បែកសម្បុរថ្ងៃ មានទំហំប៉ុនគ្រាប់ពុទ្រា ស្បែកសម្បុរថ្ងៃនោះ មានពណ៌ខ្មៅពណ៌សណ្ដែកបាយ និងពណ៌លឿងជាដើម ខាងលើស្បែកនោះ ។ ប៉ុន្តែស្បែក ដោយពណ៌ មានពណ៌-ស តែម្យ៉ាង ។ ក៏ភាពនៃស្បែកនោះ ជាស្បែកពណ៌-ស នឹងប្រាកដ កាលបើស្បែកសម្បុរថ្ងៃដែលរលាកហើយដោយវត្ថុទាំងឡាយ មានការរលាក ដោយអណ្ដាតភ្លើង និងការប្រហារដោយគ្រឿងប្រហារជាដើម ។ ដោយទ្រង់ទ្រាយ ស្បែក មានទ្រង់ទ្រាយដូចសរីរៈដែរ ។ នេះជាសេចក្ដីសង្ខេប ក្នុងអធិការនៃទ្រង់ទ្រាយនេះ ។

(សណ្ឋានស្បែកផ្សេងៗ)

តែបើពោលដោយពិស្ដារ ស្បែកនៃម្រាមជើង មានទ្រង់ទ្រាយដូចជាសំបុកដង្កូវនាង ។ ស្បែកខ្នងជើង មានទ្រង់ទ្រាយ ដូចជាស្បែកជើងកែងចោទ ។ ស្បែកស្មង មានទ្រង់ទ្រាយ ដូចជាស្លឹកត្នោតខ្ចប់បាយស្បែកភ្លៅ មានទ្រង់ទ្រាយដូចថង់វែង ដែលពេញទៅដោយអង្ករ ស្បែកត្រគាក មានទ្រង់ទ្រាយដូចជាសំពត់តម្រង ដែលពេញដោយទឹក ស្បែកខ្នង មានទ្រង់ទ្រាយដូចជាស្បែកដែលស្រោបបន្ទះក្ដារ ស្បែកពោះ មានទ្រង់ទ្រាយដូចជាស្បែក ដែលគេពាសស្នូកពិណ ស្បែកទ្រូង ភាគច្រើនមានទ្រង់ទ្រាយរាងបួនជ្រុង ស្បែកជើងដៃទាំងពីរ មានទ្រង់ទ្រាយដូចជាស្បែកដែលគេស្រោបនូវស្លាបធ្នូ ស្បែកខ្នងដៃ មានទ្រង់ទ្រាយដូចជាស្រោមកាំបិទកោរខ្វេះ មានទ្រង់ទ្រាយដូចជាខែលខ្វេះ ស្បែកនៃម្រាមដៃ មានទ្រង់ទ្រាយដូចជាស្រោមកូនសោ ស្បែក-ក មានទ្រង់ទ្រាយដូចជាកអាវ ស្បែកមុខមានប្រហោងតូច-ធំ មានទ្រង់ទ្រាយដូចសំបុកកណ្ដូប ស្បែកក្បាល មានទ្រង់ទ្រាយដូចជាស្រោមបាត្រ ដូច្នេះឯង ។

(វិធីកំណត់ស្បែក)

ក៏ឯព្រះយោគាវចរ អ្នកកំណត់ស្បែក គប្បីបញ្ជូនញាណ មានមុខ ទៅខាងលើ ចាប់ដើមអំពីបបូរមាត់ខាងលើទៅ ហើយកំណត់ នូវស្បែកដែលរុំព័ទ្ធមុខហើយតាំងនៅ មុនដំបូងបង្អស់ បន្ទាប់អំពីនោះមក គប្បីកំណត់ស្បែកនៃឆ្អឹងថ្ងាស បន្ទាប់អំពីនោះ ព្រះយោគី កាលបញ្ជូនញាណទៅ តាមចន្លោះឆ្អឹងក្បាល និង ស្បែកក្បាល ដូចជាបុគ្គលលូកដៃទៅ តាមចន្លោះនៃបាត្រ ដែលបុគ្គលប្រកហើយ ក្នុងស្រោក និង តាមចន្លោះនៃស្រោក យ៉ាងដូច្នោះដែរ ហើយញែកនូវភាពនៃស្បែកជាប់គ្នាតែមួយ ជាមួយនឹងឆ្អឹង គប្បីកំណត់ស្បែកក្បាល បន្ទាប់ពីនោះ ព្រះយោគី គប្បីកំណត់ស្បែក-ក តអំពីនោះ គប្បីកំណត់ស្បែកដៃខាងស្តាំ ដោយអនុលោម និង បដិលោម កាលបើមានប្រការដូច្នោះ ព្រះយោគី គប្បីកំណត់ស្បែកដៃខាងឆ្វេង តាមន័យនោះដូចគ្នា តអំពីនោះ គប្បីកំណត់ស្បែកខ្នងនោះហើយ កំណត់ស្បែកជើងខាងស្តាំ ដោយអនុលោម និង បដិលោម កាលបើមានប្រការដូច្នោះ ព្រះយោគី គប្បីកំណត់ស្បែកជើងខាងឆ្វេង តាមន័យនោះដូចគ្នា តអំពីនោះ ព្រះយោគី គប្បីកំណត់ស្បែកក្រពះបស្សាវៈ ស្បែកពោះ ស្បែកបេះដូង និង ស្បែក-ក តាមលំដាប់ហ្នឹងឯង កាលបើមានប្រការដូច្នោះ ព្រះយោគី គប្បីកំណត់ នូវស្បែកចង្កា ដែលមានខាងក្រោម ក្នុងលំដាប់អំពីស្បែក-ក រួចហើយញ៉ាំងទីបំផុតនៃបបូរមាត់ខាងក្រោម ឲ្យដល់ហើយឲ្យសម្រេច ។ កាលព្រះយោគី កំណត់នូវស្បែកដ៏គ្រោតគ្រាតៗ យ៉ាងនេះ សូម្បីស្បែក ដ៏ល្អិត ក៏រមែងប្រាកដ ។ ដោយទិស ស្បែកកើតហើយក្នុងទិសទាំងឡាយពីរ ។ ដោយឱកាស ស្បែករុំព័ទ្ធសរីរៈទាំងមូលហើយតាំងនៅ ។ ដោយ

បរិច្ឆេទ ខាងក្រោម កំណត់ហើយ ដោយផ្ទៃដែលតាំងនៅហើយ ខាងលើ កំណត់ហើយ ដោយអាកាស ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃស្បែកនោះ ។ ឯកិរិយាកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើ ដោយសក់ដែរ ។

(សាច់)

(១៥៦) ពាក្យថា “សាច់” គឺសាច់ ៩០០ ដុំ ។ សាច់ទាំងអស់នោះឯង ដោយពណ៌ ក្រហម ប្រហែលគ្នានឹងផ្កាចារ។ ដោយទ្រង់ទ្រាយ សាច់កំភួនជើង មានទ្រង់ទ្រាយដូចជាបាយ ដែលគេខ្ចប់ហើយ ដោយស្លឹកត្នោត ។ សាច់ទ្រូង មានទ្រង់ទ្រាយ ដូចជាកូនថ្មសំលៀងកាំបិត ។ សាច់ត្រគាក មានទ្រង់ទ្រាយដូចជាឃ្មោះជើងក្រាន ។ សាច់ខ្នងមានទ្រង់ទ្រាយដូចជាផែននៃស្ករត្នោត ។ សាច់ប្រជុំនៃឆ្អឹងជំនីរពីរមានទ្រង់ទ្រាយដូចជាការលាបដោយដីស្អិតដ៏ស្តើង ត្រង់ផ្ទៃនៃជង្រុក ។ សាច់ដោះ មានទ្រង់ទ្រាយ ដូចជាដុំនៃដីស្អិត ដែលបុគ្គលសូន្យហើយព្យួរទុក ។ សាច់ប្រជុំនៃដើមដៃទាំងពីរ មានទ្រង់ទ្រាយដូចជាកណ្តុរដ៏ធំ មិនមានស្បែក ដែលបុគ្គលធ្វើជាពីរជាន់ហើយ តំកល់ទុក ។ កាលព្រះយោគី កំណត់នូវសាច់ដ៏គ្រោតគ្រាតៗ យ៉ាងនេះ សូម្បីសាច់ដ៏ល្អិត ក៏រមែងប្រាកដ ។ ដោយទិស សាច់នោះ កើតហើយ ក្នុងទិសទាំង ២ ។ ដោយឱកាស សាច់ អែបនូវឆ្អឹង ៣០០ កំណាត់ មិនលើស ហើយបិតនៅ ។ ដោយបរិច្ឆេទ ខាងក្រោម លោកកំណត់ហើយ ដោយផ្ទៃដែលតាំងនៅហើយ ក្នុងគ្រោងឆ្អឹង ខាងលើ កំណត់ហើយ ដោយស្បែក ទទឹង កំណត់ហើយ ដោយសាច់ដូចគ្នា ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃសាច់នោះ ។ ឯកិរិយាកំណត់ចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(សរសៃ)

ពាក្យថា “សរសៃ” បានដល់ សរសៃ ៩ រយ ។ ដោយពណ៌ សរសៃទាំងអស់ ជាពណ៌-ស ។ ដោយទ្រង់ទ្រាយ សរសៃទាំងឡាយ មានទ្រង់ទ្រាយផ្សេងៗ ។ មែនពិត បណ្តាសរសៃទាំងនោះ សរសៃធំទាំងឡាយ ដែលរួមរឹតនូវសរីរៈ ចាប់ដើមអំពីផ្នែកខាងលើ នៃ ក ចុះហើយ តាមផ្នែកខាងមុខ (មាន) ៥, សរសៃធំទាំងឡាយ តាមផ្នែកខាងក្រោយ ៥, តាមផ្នែកខាងស្តាំ ក៏ ៥, តាមផ្នែកខាងឆ្វេង ក៏ ៥, សរសៃធំទាំងឡាយ សូម្បីដែលរួមរឹតនូវដៃខាងស្តាំ តាមផ្នែកខាងមុខនៃដៃ ក៏ ៥, តាមផ្នែកខាងក្រោយ នៃដៃ ក៏ ៥, សរសៃធំទាំងឡាយ សូម្បីដែលរួមរឹតនូវដៃខាងឆ្វេង ក៏ដូចគ្នាដែរ, សូម្បីដែលរួមរឹត នូវជើងខាងស្តាំ តាមផ្នែកខាងមុខនៃជើង ក៏ ៥, តាមផ្នែកខាងក្រោយជើង ក៏ ៥, សរសៃធំទាំងឡាយ សូម្បីដែលរួមរឹតនូវជើងខាងឆ្វេង ក៏ដូច្នោះដែរ យ៉ាងដូច្នេះឯង សរសៃធំទាំងឡាយ ៦០ ឈ្មោះថា សរសៃទ្រទ្រង់ នូវសរីរៈ រួមរឹតនូវកាយ ចុះហើយ ។ សរសៃទាំងឡាយណា ដែលលោកហៅថា សរសៃពួរ ដូច្នេះក៏មាន, សូម្បីសរសៃទាំងអស់នោះ មានទ្រង់ទ្រាយដូចជាលំពង់នៃដើមរុន ។ ចំណែកខាងសរសៃទាំងឡាយដទៃ គ្របសង្កត់ នូវប្រទេសនោះៗ ហើយឋិតនៅ ។ សរសៃទាំងឡាយដែលល្អិត ដោយវិសេសជាងសរសៃនោះ មានទ្រង់ទ្រាយដូចជាខ្សែអំបោះ ។ សរសៃទាំងឡាយ ដទៃទៀត ដែលល្អិតដោយវិសេសជាងសរសៃនោះ មានទ្រង់ទ្រាយ ដូចជាវល្លិ៍ផោមហ្នឹងឯង ។ សរសៃទាំងឡាយដទៃ ល្អិតដោយវិសេសជាងសរសៃនោះ មានទ្រង់ទ្រាយ ដូចជាខ្សែពិណដ៏ធំ ។ សរសៃទាំងឡាយដទៃ មានទ្រង់ទ្រាយ ដូចជាអំបោះថ្លោស ។ សរសៃ

ទាំងឡាយ ត្រង់ខ្នងដៃ និង ខ្នងជើងទាំងឡាយ មានទ្រង់ទ្រាយ ដូចជាជើងសត្វស្លាប ។ សរសៃទាំងឡាយ លើក្បាល មានទ្រង់ទ្រាយ ដូចជាសំណាញ់លើក្បាល នៃទារកទាំងឡាយ ។ សរសៃទាំងឡាយ ត្រង់ខ្នង មានទ្រង់ទ្រាយ ដូចជាសំណាញ់ទទឹក ដែលគេត្រដាង ព្ធដ៏កំដៅថ្ងៃ ។ សរសៃទាំងឡាយ ដែលទៅតាមអវយវៈ តូច-ធំ នោះៗ ដ៏សេស មានទ្រង់ទ្រាយ ដូចជាអាវស្រែះ ដែលគេពាក់ហើយ លើសរីរៈ ។ ដោយទិស សរសៃទាំងឡាយ កើតហើយ ក្នុងទិសទាំងពីរ ។ ដោយឱកាស សរសៃទាំងឡាយ ចងនូវឆ្អឹងទាំងឡាយ ក្នុងសរីរៈទាំងមូល ឋិតនៅ ។ ដោយបរិច្ឆេទ ខាងក្រោម លោកកំណត់ហើយ ដោយផ្ទៃដែលវាតាំងនៅហើយ ខាងលើ នៃឆ្អឹង ៣០០ កំណាត់ ខាងលើ កំណត់ហើយ ដោយប្រទេសដែលវាឋិតនៅ ទល់នឹងសាច់ និង ស្បែកទាំងឡាយ ។ ទទឹងកំណត់ ដោយសរសៃដូចគ្នា ។ នេះ ជាកិរិយាកំណត់នូវចំណែក របស់ខ្លួន នៃសរសៃនោះ ។ ឯកិរិយាកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ឆ្អឹង)

ពាក្យថា “ឆ្អឹងទាំងឡាយ” គឺលើកលែងតែឆ្អឹងធ្មេញ ៣២ ចេញ ឆ្អឹងដ៏សេស មានចំនួន ៣០០ យ៉ាងដូច្នេះ គឺ ឆ្អឹងដៃទាំងឡាយ ៦៤ ឆ្អឹងជើងទាំងឡាយ ៦៤ ឆ្អឹងទន់ទាំងឡាយដែលអាស្រ័យនូវសាច់ ៦៤ ឆ្អឹងកែងទាំងឡាយ ២ ត្រង់ជើងនិមួយៗ ឆ្អឹងភ្នែកគោទាំងឡាយពីរ ៗ ឆ្អឹងស្មងទាំងឡាយ ២ ឆ្អឹងជង្គង់ ១ ឆ្អឹងភ្លៅ ១ ឆ្អឹង ចង្កេះ ២ ឆ្អឹងទ្រនុងខ្នងទាំងឡាយ ១៨ ឆ្អឹងជំនីរទាំងឡាយ ២៤ ឆ្អឹងទ្រូងទាំងឡាយ ១៤ ឆ្អឹងបេះដូង ១ ឆ្អឹងដងកាំបិតទាំងឡាយ ២ ឆ្អឹងច្បាក់ទាំងឡាយ ២ ឆ្អឹង

ដើមដៃទាំងឡាយ ២ ឆ្អឹងចុងដើមដៃពីរ ៗ ឆ្អឹង-ក ៧ ឆ្អឹងចង្កា ២ ឆ្អឹងច្រមុះ ១ ឆ្អឹងភ្នែក ២ ឆ្អឹងស្លឹកត្រចៀក ២ ឆ្អឹងថ្ងាស ១ ឆ្អឹងបង្ហើយ ១ ឆ្អឹងអំបែងក្បាល ៩ ។

ឆ្អឹងទាំងអស់នោះ ដោយពណ៌ គឺពណ៌-ស ។ ដោយទ្រង់ទ្រាយ ឆ្អឹងទាំងឡាយ មានទ្រង់ទ្រាយផ្សេងៗ ។ មែនពិត បណ្តាឆ្អឹងទាំងនោះ ឆ្អឹងម្រាមនៃចុងជើងទាំងឡាយ មានទ្រង់ទ្រាយដូចជាគ្រាប់ឈូក ។ ឆ្អឹងថ្នាំងត្រង់កណ្តាល លំដាប់អំពីឆ្អឹងម្រាមជើងនោះ មានទ្រង់ទ្រាយដូចជាគ្រាប់ខ្នុរ ។ ឆ្អឹងថ្នាំងត្រង់គល់ មានទ្រង់ទ្រាយដូចជាខ្ទុយ ។ ឆ្អឹងខ្នងជើងទាំងឡាយ មានទ្រង់ទ្រាយដូចជាគំនរនៃឫសរុនដែលគេដំហើយ ។ ឆ្អឹងកែង មានទ្រង់ទ្រាយដូចជាគ្រាប់ផ្លែត្នោត មានគ្រាប់មួយ ។ ឆ្អឹងភ្នែកគោ មានទ្រង់ទ្រាយដូចជាផ្លែអង្គុញ សំរាប់លេងដែលគេចងហើយ ។ ទីនៃឆ្អឹងស្មងទាំងឡាយ ដែលតាំងនៅហើយ លើឆ្អឹងភ្នែកគោទាំងឡាយ មានទ្រង់ទ្រាយដូចជាលំពង់ផ្តៅ ដែលបុគ្គលសកសំបកចេញហើយ ។ ឆ្អឹងស្មងតូច មានទ្រង់ទ្រាយដូចជាដងធ្នូតូច ។ ឆ្អឹងស្មងធំ មានទ្រង់ទ្រាយដូចជាខ្នងពស់ស្គម ។ ឆ្អឹងជង្គង់ មានទ្រង់ទ្រាយដូចពពុះទឹកដែបម្ខាង ។ ទីនៃឆ្អឹងស្មងដែលតាំងនៅហើយ លើឆ្អឹងជង្គង់ទាំងឡាយនោះ មានទ្រង់ទ្រាយដូចជាស្នែងគោ ដែលមានចុងដាច់ត្និលហើយ ។ ឆ្អឹងភ្លៅ មានទ្រង់ទ្រាយដូចដងកាំបិត និង ប៉ូវថៅ ដែលគេប្រាសហើយមិនបានស្អាត ។ ទីតាំងនៃឆ្អឹងភ្លៅនោះ តាំងនៅហើយ ត្រង់ឆ្អឹងចង្កេះ មានទ្រង់ទ្រាយដូចជាផ្លែអង្គុញសំរាប់លេង ។ ទីនៃឆ្អឹងចង្កេះដែលឆ្អឹងភ្លៅនោះតាំងនៅ មានទ្រង់ទ្រាយដូចជាផ្លែក្រូច ដែលគេចិតហើយត្រង់ក្បាល ។ ឆ្អឹងចង្កេះទាំងឡាយ ២ ជាប់គ្នាតែមួយ មានទ្រង់ទ្រាយដូចជាចង្ក្រានស្មូនឆ្នាំង ផ្សេង

ដោយឡែក មានទ្រង់ទ្រាយដូចជាក្របាប់ដាងមាស ។ ឆ្អឹងត្រគាកដែលតាំងនៅ ត្រង់ខាងចុង មានទ្រង់ទ្រាយដូចជាពពារពស់ ដែលបុគ្គលចាប់ ធ្វើឲ្យមានមុខចុះក្រោមហើយ មានប្រហោងតូច-ធំ ក្នុងទី ៧ ឬ ៨ កន្លែង ។ ឆ្អឹងទ្រនុងខ្នងទាំងឡាយ ព្ធដ៏ខាងក្នុង មានទ្រង់ទ្រាយដូចជាដុំនៃផ្ទាំងសំណាកក់ ដែលបុគ្គលដាក់ខាងលើៗ ខាងក្រៅ មានទ្រង់ទ្រាយដូចជាខ្សែល្ហួសដែលមូល ។ ក្នុងចន្លោះៗ នៃឆ្អឹងទ្រនុងខ្នងទាំងនោះ ឆ្អឹងទ្រនុងខ្នងពីរបីប្រាកដស្មើដោយធ្មេញរណារ ។ បណ្តាឆ្អឹងជំនីរទាំងឡាយ ២៤ ឆ្អឹងជំនីរដែលមិនពេញ មានទ្រង់ទ្រាយដូចជាកណ្តៀវដែប ឆ្អឹងជំនីរទាំងឡាយដែលពេញ មានទ្រង់ទ្រាយដូចកណ្តៀវពេញ, ឆ្អឹងជំនីរទាំងអស់ មានទ្រង់ទ្រាយដូចជាស្លាបកាងនៃមាន់-ស ។ ឆ្អឹងទ្រូងទាំងឡាយ ១៤ មានទ្រង់ទ្រាយដូចជាគ្រែស្នែងស្លាបគ្រុឌចាស់ ។ ឆ្អឹងបេះដូង មានទ្រង់ទ្រាយដូចជាផ្លែវែក ។ ឆ្អឹងដងកាំបិតទាំងឡាយ មានទ្រង់ទ្រាយដូចជាដងកាំបិតតូច ជាវិការៈនៃលោហៈ ។ ឆ្អឹងច្បាក់ទាំងឡាយ មានទ្រង់ទ្រាយ ដូចជាចបកាប់នៃសីហឡៈ ដែលដែបហើយមួយចំហៀង ។ ឆ្អឹងដើមដៃទាំងឡាយ មានទ្រង់ទ្រាយដូចជាក្របនៃកញ្ចក់ ។ ឆ្អឹងចុងនៃដើមដៃទាំងឡាយ មានទ្រង់ទ្រាយដូចជាឫសត្នោតទាំងគូ ។ ឆ្អឹងនៃកដៃទាំងឡាយ មានទ្រង់ទ្រាយដូចជាដុំ នៃបន្ទះសំណាកក់ ដែលបុគ្គលរំលាយក្នុងទីជាមួយគ្នាហើយតំកល់ទុក ។ ឆ្អឹងខ្នងដៃទាំងឡាយ មានទ្រង់ទ្រាយដូចជាគំនរ នៃឫសរុន ដែលគេដំហើយ ។ ឆ្អឹងថ្នាំង នៃគល់ម្រាមដៃទាំងឡាយ មានទ្រង់ទ្រាយដូចជាខ្ទុយ ។ ឆ្អឹងត្រង់ថ្នាំងកណ្តាលទាំងឡាយ មានទ្រង់ទ្រាយ ដូចជាគ្រាប់ខ្នុរដែប ។ ឆ្អឹងត្រង់ថ្នាំងខាងចុងទាំងឡាយ មានទ្រង់ទ្រាយដូចជាគ្រាប់ឈូក ។ ឆ្អឹង-ក ទាំងឡាយ ៧ កង់ មានទ្រង់

ទ្រាយដូចជាកង់នៃទំពាំង ដែលបុគ្គលដោត ដោយកំណាត់ឈើ ហើយតំកល់ទុក តាមលំដាប់ ។ ឆ្អឹងចង្កា ខាងក្រោម មានទ្រង់ទ្រាយដូចជាក្របាប់ដែកនៃពួកជាងមាស ។ ឆ្អឹងចង្កា ខាងលើ មានទ្រង់ទ្រាយ ដូចជាកាំបិតសំរាប់លួសនូវអំពៅ ។ ឆ្អឹងប្រហោងភ្នែក និង ប្រហោងច្រមុះទាំងឡាយ មានទ្រង់ទ្រាយដូចជាគ្រាប់ត្នោតខ្ចី ត្រូវគេយកសាច់ចេញអស់ហើយ ។ ឆ្អឹងថ្ងាស មានទ្រង់ទ្រាយដូចជាអំបែងនៃសំបកខ្យងដែលគេផ្កាប់ហើយ តំកល់ទុក ។ ឆ្អឹងគុម្ពត្រចៀកទាំងឡាយ មានទ្រង់ទ្រាយដូចជាស្រោមកាំបិតកោរ នៃខ្នាន់ព្រះកេស ។ ឆ្អឹង ក្នុងឱកាសដែលជាប់គ្នា ពួដ៏ខាងលើ នៃថ្ងាស និង គុម្ពត្រចៀកទាំងឡាយ មានទ្រង់ទ្រាយដូចជាក្អេងនៃក្អមមានទឹកពេញ ដែលបុគ្គលផ្កាប់ចុះហើយ ។ ឆ្អឹងបង្ហើយមានទ្រង់ទ្រាយ ដូចជាលលាដ៍វែក ដែលមានមាត់ផ្កាប់ហើយ ។ ឆ្អឹងក្បាលទាំងឡាយ មានទ្រង់ទ្រាយដូចជាលលាដ៍ឃ្លោកចាស់ ដែលគេដេរហើយ តំកល់ទុក ។

ដោយទិស ឆ្អឹងទាំងឡាយ កើតហើយក្នុងទិសទាំងពីរ ។ ដោយឱកាស ឆ្អឹងទាំងឡាយ តាំងនៅហើយ ក្នុងសរីរៈទាំងមូល ដោយមិនប្លែកគ្នា ។ ប៉ុន្តែដោយសេចក្តីប្លែកគ្នា បណ្តាឆ្អឹងទាំងឡាយនុ៎ះ ឆ្អឹងក្បាលតាំងនៅហើយ ត្រង់ឆ្អឹង-ក ទាំងឡាយ ។ ឆ្អឹង-ក ទាំងឡាយ តាំងនៅហើយ លើឆ្អឹងទ្រនុងខ្នងទាំងឡាយ ។ ឆ្អឹងទ្រនុងខ្នងទាំងឡាយ តាំងនៅហើយ លើឆ្អឹងចង្កេះទាំងឡាយ ។ ឆ្អឹងចង្កេះទាំងឡាយ តាំងនៅហើយលើឆ្អឹងភ្លៅទាំងឡាយ។ ឆ្អឹងភ្លៅទាំងឡាយ តាំងនៅហើយ លើឆ្អឹងជង្គង់ទាំងឡាយ ។ ឆ្អឹងជង្គង់ទាំងឡាយ តាំងនៅហើយ លើឆ្អឹងស្មងទាំងឡាយ ឆ្អឹងស្មងទាំងឡាយ តាំងនៅហើយ លើឆ្អឹងកែងកោទាំងឡាយ ។

ឆ្អឹងកែងកោទាំងឡាយ តាំងនៅហើយ លើឆ្អឹងខ្នងជើងទាំងឡាយ ។ ដោយបរិច្ឆេទ ខាងក្នុង លោកកំណត់ហើយ ដោយខួរក្នុងឆ្អឹង ខាងលើកំណត់ ដោយសាច់ ត្រង់ចុង និង ត្រង់គល់ កំណត់ ដោយឆ្អឹងដូចគ្នា ។ នេះ ជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃឆ្អឹងទាំងនោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ខួរក្នុងឆ្អឹង)

ពាក្យថា "ខួរក្នុងឆ្អឹង" គឺ ខួរដែលតាំងនៅហើយ ខាងក្នុងនៃឆ្អឹងទាំងឡាយនោះៗ ។ ខួរក្នុងឆ្អឹងនោះ ដោយពណ៌ ជាពណ៌-ស ។ ដោយទ្រង់ទ្រាយ ខួរក្នុងឆ្អឹងនោះ តាំងនៅ ខាងក្នុង នៃឆ្អឹងទាំងឡាយធំៗ មានទ្រង់ទ្រាយដូចជាចុងផ្តៅដ៏ធំ ដែលបុគ្គលរោលហើយដាក់ចូល ក្នុងបំពង់ឫស្សី តាំងនៅហើយ ខាងក្នុង នៃឆ្អឹងទាំងឡាយតូចៗ មានទ្រង់ទ្រាយដូចជាចុងផ្តៅដ៏តូច ដែលគេរោលហើយ ដាក់ចូលទៅ ក្នុងថ្នាំង នៃឫស្សីទាំងឡាយ ។ ដោយទិស ខួរក្នុងឆ្អឹង កើតហើយ ក្នុងទិសទាំងពីរ ។ ដោយឱកាស ខួរក្នុងឆ្អឹង តាំងនៅហើយ ពួដ៏ខាងក្នុងនៃឆ្អឹងទាំងឡាយ ។ ដោយបរិច្ឆេទ លោកកំណត់ហើយ ដោយផ្ទៃខាងក្នុងនៃឆ្អឹងទាំងឡាយ ។ នេះ ជាកិរិយាកំណត់នូវចំណែករបស់ខ្លួន នៃខួរក្នុងឆ្អឹងនោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(តំរងបស្សាវៈ)

(១៥៧) ពាក្យថា "វក្កំ តំរងបស្សាវៈ" គឺ ដុំសាច់ទាំងឡាយ ២ មានទងតែមួយ ។ តំរងបស្សាវៈនោះ ដោយពណ៌ មានពណ៌ក្រហមទន់ដូចពណ៌គ្រាប់រលួសបាយ ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយដូចជាគ្រាប់ផ្លែអង្គុញសំរាប់លេងទាំងគូ នៃក្មេងទាំងឡាយ ឬ ឬថា មានទ្រង់

ទ្រាយដូចជាផ្លែស្វាយព្រៃក ដែលជាប់នៅនឹងទងតែមួយ ។ ដោយទិស កើតហើយ ក្នុងទិសខាងលើ ។ ដោយឱកាស តំរងបស្សាវៈនោះ ជាធម្មជាតជាប់ជាមួយគ្នា ដោយសរសៃដ៏ថ្លោស ដែលលៀនចេញមកអំពីបំពង់-ក ហើយទៅបន្តិច ដោយគល់តែមួយ ហើយបែកទៅជាពីរ រុំព័ទ្ធសាច់នៃបេះដូង ហើយឋិតនៅ ។ ដោយបរិច្ឆេទ តំរងបស្សាវៈ លោកកំណត់ហើយ ដោយចំណែកនៃតំរងបស្សាវៈ ។ នេះ ជាកិរិយាកំណត់នូវចំណែករបស់ខ្លួន នៃតំរងបស្សាវៈនោះ ។ ឯកិរិយាកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើ ដោយសក់ដែរ ។

(បេះដូង)

ពាក្យថា "បេះដូង" គឺសាច់បេះដូង ។ សាច់បេះដូងនោះ ដោយពណ៌ ជាពណ៌ក្រហម មានពណ៌ដូចជាពណ៌ខ្នងត្របកឈូក ។ ដោយទ្រង់ទ្រាយ បេះដូងនោះ មានទ្រង់ទ្រាយដូចជាក្រពុំផ្កាឈូក ដែលគេបកនូវសំបកខាងក្រៅទាំងឡាយ ចេញហើយតំកល់ទុក ឲ្យមានមុខទៅខាងក្រោម មានខាងក្រៅរលីង ខាងក្នុង ដូចជាខាងក្នុងនៃផ្លែននោង សំរាប់បុគ្គលទាំងឡាយដែលមានប្រាជ្ញា រីកបន្តិច សំរាប់បុគ្គលទាំងឡាយ អ្នកមានប្រាជ្ញាទន់ ក្តោបទៅវិញហ្នឹងឯង ។ មួយទៀត ខាងក្នុងបេះដូងនោះ មានរណ្តៅ ទំហំអាចដាក់គ្រាប់បុស្សនាគបាន ជាទីដក់នៅ នៃឈាមប្រមាណកន្លះទូកដៃ ដែលមនោធាតុ និង មនោវិញ្ញាណធាតុ អាស្រ័យហើយប្រព្រឹត្តទៅ, ក៏ឈាមនេះនោះ សំរាប់មនុស្សរាគចរិត ជាឈាមពណ៌ក្រហម សម្រាប់មនុស្សទោសចរិត ជាឈាមពណ៌ខ្មៅ សំរាប់មនុស្សមោហចរិត ជាឈាមពណ៌ដូចជាទឹកសំរាប់លាងសាច់ សម្រាប់មនុស្សវិតក្កចរិត ជាឈាមមានពណ៌ ដូចជាសាច់ពពាយជ្រុង សំរាប់

មនុស្សសទ្ធាចរិត ជាឈាមមានពណ៌ដូចជាផ្កាកណ្ណិការ សំរាប់មនុស្សបញ្ញាចរិត ជាឈាមមិនល្អក់ ស្អាត ថ្លា ស បរិសុទ្ធ ឬ មានពន្លឺប្រាកដដូចជាកែវមណីជាតិ ដែលបុគ្គលច្នៃហើយ ។ ដោយទិស បេះដូងនោះ កើតហើយក្នុងទិសខាងលើ ។ ដោយឱកាស បេះដូងនោះ ឋិតនៅហើយត្រង់កណ្តាល នៃដោះទាំងឡាយពីរ ខាងក្នុងនៃសរីរៈ ។ ដោយបរិច្ឆេទ បេះដូង លោកកំណត់ហើយ ដោយចំណែកនៃបេះដូង ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃបេះដូងនោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើ ដោយសក់ដែរ ។

(ថ្លើម)

ពាក្យថា "ថ្លើម" គឺ ដំបារនៃសាច់ទាំងគូ ។ ដោយពណ៌ ថ្លើមនោះ មានពណ៌ក្រហម ប្រកបដោយធាតុមានពណ៌លឿង ជាពណ៌មិនក្រហមក្រៃពេក មានពណ៌ដូចជាខ្នង នៃត្របកផ្កាឈូកក្រហម ។ ដោយទ្រង់ទ្រាយ ត្រង់គល់ មួយដុំ ត្រង់ចុងជាគូ មានទ្រង់ទ្រាយ ដូចជាស្លឹករលួសផ្អុង ។ មួយទៀត ថ្លើមនោះ សំរាប់មនុស្សល្ងង់ទាំងឡាយ ជាធម្មជាតធំ មានតែមួយគត់ប៉ុណ្ណោះឯង ។ សំរាប់មនុស្ស មានបញ្ញាទាំងឡាយ ជាដុំតូចៗ មានពីរ ឬ បី ក៏មាន ។ ដោយទិស ថ្លើមនោះ កើតហើយ ក្នុងទិសខាងលើ ។ ដោយឱកាស ថ្លើមនោះ តាំងនៅហើយអាស្រ័យនូវផ្នែកខាងស្តាំ ខាងក្នុងនៃដោះទាំងពីរ ។ ដោយបរិច្ឆេទ ថ្លើម លោកកំណត់ហើយ ដោយចំណែកនៃថ្លើម ។ នេះ ជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃថ្លើមនោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(វាវ)

(១៥៨) ពាក្យថា “វាវ” បានដល់ សាច់សម្រាប់រុំព័ទ្ធ មាន ២ យ៉ាង ដោយប្រភេទដែលបិទបាំង និង មិនបិទបាំង ។ វាវទាំងពីរនោះ ឯង ដោយពណ៌ ជាពណ៌-ស មានពណ៌ដូចជាកំណាត់សំពត់ពីរជាន់ ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយដូចជាឱកាសរបស់ខ្លួន ។ ដោយទិស វាវដែលបិទបាំង កើតហើយ ក្នុងទិសខាងលើ វាវក្រៅនេះ កើតហើយ ក្នុងទិសទាំងឡាយពីរ ។ ដោយឱកាស វាវដែលបិទបាំង បិទបាំងនូវបេះដូង និង តំរងបស្សាវៈហើយតាំងនៅ, វាវដែលមិនបិទបាំង រុំព័ទ្ធនូវសាច់ អំពីទីខាងក្រោមនៃស្បែក ក្នុងសរីរៈទាំងមូល ហើយតាំងនៅ ។ ដោយបរិច្ឆេទ ខាងក្រោម លោកកំណត់ហើយ ដោយសាច់ ខាងលើកំណត់ដោយស្បែក ទទឹង កំណត់ ដោយចំណែកនៃវាវ ។ នេះគឺជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃវាវនោះ ។ រីឯកិរិយាកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ក្រពះ)

ពាក្យថា “ក្រពះ” បានដល់ សាច់មានទ្រង់ទ្រាយដូចជាអណ្ដាតក្នុងពោះ ។ ក្រពះនោះ ដោយពណ៌ ជាពណ៌ខៀវ មានពណ៌ដូចជាផ្កាដើមគន្ទីស ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយដូចជាអណ្ដាតកូនគោខ្មៅ មានទងប្រវែង ៧ ធ្នាប់ ។ ដោយទិស ក្រពះនោះ កើតហើយ ក្នុងទិសខាងលើ ។ ដោយឱកាស ក្រពះនោះ បិតនៅអាស្រ័យនូវខាងជាទីបំផុត នៃដំបារពោះ ក្នុងផ្នែកខាងឆ្វេងនៃបេះដូង ។ កាលបើក្រពះលៀនចេញមកខាងក្រៅ ព្រោះការប្រហារដោយគ្រឿងប្រហារហើយ សត្វទាំងឡាយ ក៏នឹងអស់ជីវិត ។ ដោយបរិច្ឆេទ លោកកំណត់ ដោយចំណែកនៃក្រពះ ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃក្រពះនោះ ។

ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(សួត)

ពាក្យថា “សួត” គឺសាច់សួតមានប្រភេទ ៣២ កំណាត់ ។ សួតនោះ ដោយពណ៌ ជាពណ៌ក្រហម មានទ្រង់ទ្រាយដូចជាផ្លែឧទុម្ពរ ដែលនៅស្រគាល ។ ដោយទ្រង់ទ្រាយ សួតនោះ មានទ្រង់ទ្រាយដូចជាដុំនៃនំដ៏ក្រាស់ ដែលគេកាត់ហើយមិនស្មើ វាមិនមានរសជាត មិនមានឱជាដូចជាដុំ នៃស្វឹកឈើដែលបុគ្គលទំពាហើយ ព្រោះភាពនៃសួតនោះ ជាវត្ថុដែលចំហាយនៃតេជោធាតុដែលកើតអំពីកម្ម ផុសឡើងហើយ កំចាត់បង់ចោល ព្រោះពួដ៏ខាងក្នុង វាមិនមានវត្ថុដែលត្រូវស៊ីចូលទៅ និង វត្ថុដែលត្រូវផឹកចូលទៅឡើយ ។ ដោយទិស សួត កើតហើយ ក្នុងទិសខាងលើ ។ ដោយឱកាស សួតនោះ បិទបាំងនូវបេះដូង និង ថ្លើម ខាងលើ ហើយតាំងនៅសំយុងចុះ ត្រង់ចន្លោះ នៃដោះទាំងពីរ ពួដ៏ខាងក្នុងនៃសរីរៈ ។ ដោយបរិច្ឆេទ សួត លោកកំណត់ហើយ ដោយចំណែកនៃសួត ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃសួតនោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ពោះវៀនធំ)

ពាក្យថា “ពោះវៀនធំ” បានដល់ ខ្សែពោះវៀនធំ របស់មនុស្សប្រុសមានប្រវែង ៣២ ហត្ថ របស់ស្ត្រី មានប្រវែង ២៨ ហត្ថ បត់វៀនចុះឡើង ក្នុងទីទាំងឡាយ ២១ ផ្នត់ ។ ពោះវៀនធំនេះនោះ ដោយពណ៌ ជាពណ៌-ស មានពណ៌ដូចជាកំបោរ លាយដោយក្រួស ។ ដោយទ្រង់ទ្រាយ ពោះវៀនធំ មានទ្រង់ទ្រាយដូចជាពស់ ដែលដាច់ក្បាល ត្រូវគេបំពេនហើយ តំកល់ទុក ក្នុងស្នូកនៃឈាម ។ ដោយទិស កើតហើយ

ក្នុងទិសទាំងឡាយពីរ ។ ដោយឱកាស ពោះវៀនធំ តាំងនៅ ខាងក្នុងសរីរៈ ក្នុងទីបំផុតនៃបំពង់-ក និង ផ្លូវនៃករីសៈ ព្រោះខាងលើពោះវៀនធំនោះ ជាប់នៅត្រង់បំពង់-ក ផង ខាងក្រោម ត្រង់ផ្លូវនៃករីសៈផង ។ ដោយបរិច្ឆេទ លោកកំណត់ហើយ ដោយចំណែកនៃពោះវៀនធំ ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃពោះវៀនធំនោះ ។ ឯកិរិយាកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ពោះវៀនតូច)

(១៥៩) ពាក្យថា “ពោះវៀនតូច” គឺពោះវៀនជាគ្រឿងចង ក្នុងទីនៃចង្វាយពោះវៀនធំទាំងឡយ ។ ពោះវៀនតូចនោះ ដោយពណ៌ ជាពណ៌-ស មានពណ៌ដូចជាឫសនៃចង្កុលណី ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយដូចជាឫសនៃចង្កុលណីហ្នឹងឯង ។ ដោយទិស កើតហើយក្នុងទិសទាំងឡាយពីរ ។ ដោយឱកាស ពោះវៀនទូចនោះ ចងហើយ នូវចង្វាយពោះវៀនធំ ឲ្យមានទីបំផុតខាងចុង ក្នុងទីជាមួយគ្នា ដូចជាខ្សែនៃយន្តចងនូវផែនក្តារ នៃយន្តទាំងឡាយ ក្នុងពេលដែលពួកជាង ធ្វើកិច្ចការទាំងឡាយ មានការឆ្ការកាប់ដោយចប និង ប៉ូវថៅជាដើម ទាញនូវយន្ត តាំងនៅហើយ ក្នុងចន្លោះ នៃចង្វាយពោះវៀនធំទាំង ២១ ចង្វាយ ដូចជាខ្សែតូចដែលដេរនូវពោះវៀនធំនោះ ក្នុងចន្លោះនៃមណ្ឌល ទ្រនាប់សំរាប់ជូតជើងយ៉ាងនោះឯង ហើយតាំងនៅ ។ ដោយបរិច្ឆេទ ពោះវៀនទូចនោះ លោកកំណត់ហើយ ដោយចំណែកនៃពោះវៀនទូច ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃពោះវៀនតូចនោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើ ដោយសក់ដែរ ។

(អាហារថ្មី)

វត្ថុដែលបុគ្គលស៊ី ផឹក ទំពាស៊ី និង លិឍ មាននៅ ក្នុងពោះឈ្មោះថា អាហារថ្មី ។ អាហារថ្មីនោះ ដោយពណ៌ មានពណ៌ដូចជាអាហារ ដែលលេបចូលទៅ ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយដូចជាអង្ករ ដែលបុគ្គលវេចហើយយ៉ាងធូរ ក្នុងសំពត់តំរងទឹក ។ ដោយទិសតាំងនៅ ក្នុងទិសខាងលើ ។ ដោយឱកាស ឋិតនៅ ក្នុងពោះ ។

(ពោះ)

ឈ្មោះថា ពោះ គឺអវយវៈដែលរុំព័ទ្ធនូវពោះវៀនធំ ប្រាកដស្មើដោយការប៉ោងដែលកើតព្រម ត្រង់កណ្តាលនៃសំពត់ទទឹក ដែលបុគ្គលរួមខាងទាំងពីរ ខាងក្រៅ រលីង ខាងក្នុង ប្រាកដស្មើដោយសំពត់ដែលខ្ជប់នូវទឹករជូវ ប្រឡាក់ដោយគ្រឿងរុំនូវកាកសាច់ ការពោលថា “ (ខាងក្នុងឧទរនោះ) ប្រាកដស្មើដោយខាងក្នុង នៃសំបកខ្នុរដែលស្អុយ” ដូច្នេះខ្លះ ក៏គួរ ។ ដង្កូវទាំងឡាយ មាន ៣២ ហ្វូង មានជាអាទិ៍ យ៉ាងនេះដូច្នេះគឺ ដង្កូវទាំងឡាយ ឈ្មោះតក្កោជកៈ ១ ឈ្មោះគណ្ឌុប្បាទកៈ ១ ឈ្មោះតាលហីរកៈ ១ ឈ្មោះសូចិមុខកៈ ១ ឈ្មោះបដតន្តូ ១ ឈ្មោះសុត្តកៈ១ ជាសត្វពពាក់ពពូនលើគ្នា ត្រេចទៅជាពួកៗ នៅអាស្រ័យក្នុងពោះ, ពួកដង្កូវ កាលបើវត្ថុមានបាយ និង ទឹកជាដើម មិនមាន ក៏កញ្ជ្រោលឡើងស្រែកជញ្ជក់នូវសាច់បេះដូង និង ក្នុងពេលដែលបុគ្គលលេប នូវអាហារមានទឹក និង ភោជនជាដើមចូលទៅ វាមានមាត់ទៅ ឰដ៏ខាងលើ រវើមរវាម ជញ្ជែងគ្នា នូវពំនូតពីរបីពំនូត ដែលបុគ្គលលេបចូលទៅ ជាដំបូង, ពោះ ដូចជាផ្ទះជាទីកើត ជាវច្ចកុដិ ជាមន្ទីរពេទ្យ និង ជាព្រៃស្មសានរបស់ដង្កូវទាំងឡាយនោះ, ក្នុងពោះ វត្ថុមានទឹក និង ភោជនជាដើមមានប្រការផ្សេងៗ ដែលអង្រែគឺធ្មេញលំអិតហើយ ដែលដៃ គឺអណ្តាតផាត់

ប្រមូលហើយ ព័ន្ធព័ទ្ធហើយដោយជុំទឹកមាត់ ក្នុងខណៈនោះ វាជារបស់ដល់ព្រមដោយវត្ថុមានពណ៌ ក្លិន និង រសជាដើម ទៅប្រាសហើយ ដូចទឹកបាយនៃជាងតម្បាញ និង កំអួតឆ្កែ ធ្លាក់ចុះហើយ ជាវត្ថុរុំព័ទ្ធដោយប្រមាត់ ស្លេស្ម និង ខ្យល់ ជាវត្ថុពុះហើយ ដោយកំឡាំង នៃកំដៅភ្លើងក្នុងពោះ វឹកវរ ដោយហ្វូងដង្កូវ បញ្ចេញនូវពពុះ និង កំពេញទាំងឡាយពួដ៏ខាងលើៗ ដល់នូវភាវៈជាកាកសំណល់ដែលមានក្លិនអាក្រក់ និង គួរខ្ពើមក្រែពេក ឋិតនៅ (ក្នុងពោះ) មានឧបមាដូចជា កាលបើភ្លៀង មានគ្រាប់ដ៏ថ្លោស បង្អុរចុះ ក្នុងនិទាឃសម័យ(រដូវក្តៅ) ជាសាកសពផ្សេងៗចាប់ដើមអំពីមូត្រ ករីសៈ កំណាត់ស្បែក កំណាត់ឆ្អឹង កំណាត់សរសៃទឹកមាត់ ទឹកសំបោរ និង ឈាម គឺទឹកបន្សាត់មក ធ្លាក់ចុះ ក្នុងរណ្តៅជ្រាំ ក្បែរទ្វារស្រុកនៃមនុស្សចណ្ឌាល ប្រឡូកប្រឡាក់ហើយ ដោយភក់និង ទឹក អំណើះពីរបីថ្ងៃមក មានហ្វូងដង្កូវ កើតព្រមឡើង ពុះហើយដោយកំឡាំងនៃកំដៅព្រះអាទិត្យដុតហើយ បញ្ចេញនូវពពុះ និងកំពេញទាំងឡាយ ពួដ៏ខាងលើ មានពណ៌ខៀវក្រែពេក មានក្លិនស្អុយក្រៃលែងគឺបុគ្គលគួរខ្ពើម ដល់នូវភាពជារូប មិនគួរដើរចូលទៅជិត មិនគួរដើម្បីឃើញឡើយ តាំងនៅ នឹងចាំបាច់ពោលទៅថ្វី ដល់ការហិត ឬ ការលិឍដូច្នោះឯង ។ ភាពនៃការមិនគាប់ចិត្ត ក្នុងវត្ថុទាំងឡាយ មានទឹក និងភោជនជាដើម រមែងកើតឡើង ព្រោះឮនូវពោះ ចាំបាច់ពោលទៅថ្វីព្រោះពិចារណាឃើញ ដោយបញ្ញាចក្ខុ ។ មួយទៀត វត្ថុមានទឹក និងភោជនជាដើម ដែលធ្លាក់ចូលហើយ ក្នុងពោះ ដល់នូវការបែងចែកជា៥ ចំណែក គឺពួកសត្វទំពាស៊ីមួយចំណែក ភ្លើងក្នុងពោះដុតមួយចំណែកចំណែកមួយជាទឹកមូត្រ ចំណែកមួយជាករីសៈ ចំណែកមួយដល់នូវភាព

ជារស ហើយចូលទៅ ទំនុកបំរុងនូវវត្ថុមានឈាម និង សាច់ជាដើម ។ ដោយបរិច្ឆេទ ពោះនោះ លោកកំណត់ហើយ ដោយជំបារនៃពោះហ្នឹងឯង និង ដោយចំណែកនៃអាហារថ្មីផងដែរ ។ នេះ ជាកិរិយាកំណត់នូវចំណែករបស់ខ្លួន នៃពោះនោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នាប្រាកដស្មើដោយសក់ដែរ ។

(អាហារចាស់)

ឧច្ចារៈ ឈ្មោះថា អាហារចាស់ ។ អាហារចាស់នោះ ដោយពណ៌មានពណ៌ដូចជាអាហារ ដែលបុគ្គលលេបចូលទៅហើយហ្នឹងឯង ដោយច្រើន ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយដូចជាឱកាស ។ ដោយទិសកើតហើយ ក្នុងទិសខាងក្រោម ។ ដោយឱកាស ឋិតនៅហើយក្នុងក្រពះនៃអាហារចាស់ ។ ឈ្មោះថា ក្រពះនៃអាហារចាស់ ប្រាកដស្មើដោយបំពង់ឫស្សី កំពស់ប្រវែង ៨ អង្គុលី ឋិតនៅ ក្នុងទីបំផុតនៃពោះវៀនធំក្នុងចន្លោះ នៃផ្ចិតខាងក្រោម និង គល់នៃទ្រនុងខ្នងទាំងឡាយ, វត្ថុមានទឹក និង ភោជនជាដើម ឯណាមួយ ដែលធ្លាក់ចុះហើយ ក្នុងក្រពះ នៃអាហារថ្មី ដែលភ្លើងក្នុងពោះ ចំអិនហើយៗ ឲ្យផុសឡើងជាពពុះ ដល់ហើយ នូវភាពជារបស់ល្អិត ដូចជាកិនដោយថ្មកិន ហើយហូរចុះតាមរន្ធនៃពោះវៀនធំ សង្កត់នៅលើគ្នា ដូចជាដីស្អិតពណ៌លឿង ដែលបុគ្គលប្របាច់ដាក់ចូលទៅ ក្នុងថ្នាំងឫស្សី តាំងនៅក្នុងក្រពះ នៃអាហារចាស់ដូចជាទឹកភ្លៀងដែលធ្លាក់ចុះហើយ ក្នុងភូមិភាគពួដ៏ខាងលើ ហូរចុះហើយញ៉ាំងភូមិភាគខាងក្រោម ឲ្យពេញប្រៀបហើយតាំងនៅ យ៉ាងនោះឯង ។

ដោយបរិច្ឆេទ អាហារចាស់នោះ លោកកំណត់ហើយ ដោយជំបារនៃក្រពះ នៃអាហារចាស់ផង ដោយចំណែក នៃករីសៈផងដែរ ។

នេះ ជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃអាហារចាស់នោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើ ដោយសក់ដែរ ។

(ខួរក្នុងក្បាល)

គំនរនៃខួរដែលតាំងនៅ ក្នុងលលាដ៍ក្បាល ឈ្មោះថា ខួរក្នុងក្បាល ។ ខួរក្នុងក្បាលនោះ ដោយពណ៌ ជាពណ៌-ស មានពណ៌ដូចជាដុំនៃផ្សិតក្បាលពស់ ។ ការពោលថា "មានពណ៌ដូចជាទឹកដោះស្រស់ខូច ដែលមិនដល់នូវភាពជាទឹកដោះជូរ" ដូច្នេះខ្ទះក៏គួរដែរ ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយតាមឱកាស ។ ដោយទិស កើត ក្នុងទិសខាងលើ ។ ដោយឱកាស ខួរក្នុងក្បាលនោះ អាស្រ័យសង្រែកទាំងឡាយ ៤ តាំងនៅជុំគ្នាហើយ ខាងក្នុងនៃលលាដ៍ក្បាល បីដូចជាដុំនៃម្សៅ ៤ ដុំ ដែលគេប្រមូលទុកជុំគ្នា យ៉ាងនោះឯង ។ ដោយបរិច្ឆេទ ខួរក្នុងក្បាលលោកកំណត់ ដោយផ្ទៃខាងក្នុង នៃលលាដ៍ក្បាល និង ដោយចំណែកនៃខួរក្នុងក្បាលផង ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃខួរក្នុងក្បាលនោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ប្រមាត់)

(១៦០) ពាក្យថា "ប្រមាត់" គឺ ប្រមាត់មាន ២ គឺ ប្រមាត់មានស្រោម ១ ប្រមាត់មិនមានស្រោម ១ ។ បណ្តាប្រមាត់ទាំងនោះ ប្រមាត់មានស្រោម ដោយពណ៌ មានពណ៌ដូចជាប្រេងស្រគំខាប់ ប្រមាត់មិនមានស្រោម មានពណ៌ដូចជាផ្កាពកុលស្វិត ។ ដោយទ្រង់ទ្រាយ ប្រមាត់ទាំង ២ មានទ្រង់ទ្រាយតាមឱកាស ។ ដោយទិស ប្រមាត់មានស្រោម កើត ក្នុងទិសខាងលើ ប្រមាត់ឥតស្រោម កើតក្នុងទិសទាំងឡាយ ២ ។

ដោយឱកាស ប្រមាត់មិនមានស្រោម លើកលែងនូវទីដែលផុតស្រឡះចាកសាច់ នៃសក់ រោម ធ្មេញ និង ក្រចកទាំងឡាយផង នូវស្បែកទាំងរឹងទាំងស្ងួតផង ជ្រួតជ្រាបទៅកាន់សរីរៈដ៏សេសហើយតាំងនៅ ដូចជាតំណក់ប្រេង ជ្រួតជ្រាបនូវទឹក យ៉ាងនោះឯង កាលបើប្រមាត់មិនមានស្រោមកំរើកហើយ ភ្នែកទាំងឡាយនៃសត្វទាំងឡាយ ជាធម្មជាតលឿងស្រវាំង ខ្លួនញាប់ញ័រ រមាស់ ។ ប្រមាត់មានស្រោម ឋិតនៅហើយក្នុងស្រោមប្រមាត់ ដែលដូចជាសំបកននោងព្រៃដ៏ធំ អាស្រ័យនូវសាច់ថ្លើមហើយតាំងនៅ ក្នុងចន្លោះនៃបេះដូង និង សួត កាលបើប្រមាត់ដែលមានស្រោម កំរើកហើយ សត្វទាំងឡាយ នឹងទៅជាឆ្កួត មានចិត្តវេវវាយ លះបង់ចោលនូវហិរិ និង ឱត្តប្បៈ ធ្វើនូវអំពើដែលគេមិនគួរធ្វើ និយាយពាក្យដែលគេមិនគួរនិយាយ គិតនូវរឿងដែលបុគ្គលមិនគួរគិត។ ដោយបរិច្ឆេទ ប្រមាត់នោះ លោកកំណត់ហើយ ដោយចំណែកនៃប្រមាត់ ។ នេះ ជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃប្រមាត់នោះ ។ ឯកិរិយាកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ស្លេស្ម)

ពាក្យថា "ស្លេស្ម" គឺ ស្លេស្មដែលមានប្រមាណពេញមួយបាត្រខាងក្នុងនៃសរីរៈ ។ ស្លេស្មនោះ ដោយពណ៌ មានពណ៌-ស មានពណ៌បីដូចជាទឹក នៃស្លឹកខ្ទឹមខាប់ ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយតាមឱកាស ។ ដោយទិស កើត ក្នុងទិសខាងលើ ។ ដោយឱកាស តាំងនៅហើយ ក្នុងជំពាវនៃពោះ ស្លេស្ម ក្នុងពេលបុគ្គលលេបនូវអាហារមានទឹក និង ភោជនជាដើម កាលបើទឹក និង ភោជនជាដើម ធ្លាក់ចូលទៅ វាបែកទៅជាពីរចំណែក គ្របជិតជុំវិញ ឋិតនៅតាមដើម មានឧបមាដូចជា

សារាយ និង ចក ក្នុងទឹក កាលបើកំណាត់ឈើ ឬ ក្បឿង ធ្លាក់ចុះទៅ ក៏បែកជាពីរចំណែក គ្រុបជុំជិតហើយតាំងនៅ ដូចដើមវិញ ដូច្នោះឯង ។ មួយទៀត កាលបើស្លេស្ម មានតិចតួច ពោះ ជាធម្មជាត មានក្លិនដូចជាសាកសព ដែលគួរខ្ពើមក្រៃលែង ដូចជាបូសដែលទុំ(ធ្លាយ)ផង ដូចជាពងមាន់ស្អុយផង មានក្លិនស្អុយគួរខ្ពើម ដូច្នោះដែរ ។ មួយទៀត ព្រោះក្លិនដែលកើតឡើងហើយ អំពីពោះនោះ ទាំងការភើរឡើង ទាំងមាត់ ក៏មានក្លិនស្អុយ ដូចជាសាកសពដែលមានក្លិនស្អុយ ។ មួយទៀត បុរសនោះ នឹងដល់នូវភាពជាអ្នកគឺគេពោល (ដេញ) ថា "ចូរអ្នកចៀសចេញទៅ អ្នកផ្សាយនូវក្លិនមិនល្អ" ដូច្នេះ ។ មួយទៀត ស្លេស្ម ចំរើនឡើង ដល់នូវភាពជារបស់ខាប់ បិទក្លិនសាកសពជិត ព្ធដ៏ខាងក្នុង នៃដំបារពោះហ្នឹងឯង ហើយឋិតនៅ ដូចជាក្តារគម្របវច្ចកុដិ ។ ដោយបរិច្ឆេទស្លេស្មនោះ លោកកំណត់ហើយដោយចំណែកនៃស្លេស្ម ។ នេះជាកិរិយាកំណត់នូវចំណែករបស់ខ្លួន នៃស្លេស្មនោះ ។ ឯកិរិយាកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ខ្ទុះ)

ពាក្យថា "ខ្ទុះ" គឺ ខ្ទុះនោះ មានពណ៌ដូចជាស្លឹកឈើលឿង ។ តែក្នុងសរីរៈមនុស្សដែលស្លាប់ហើយ ខ្ទុះមានពណ៌ដូចជាទឹកបាយផ្អូមខាប់ៗ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយតាមឱកាស ។ ដោយទិស មានក្នុងទិសទាំងឡាយពីរ ។ បើពោលតាមឱកាស ធម្មតាឱកាសនៃខ្ទុះ ជាប់ជានិច្ច មិនមាន ខ្ទុះនោះ កកហើយឋិតនៅ ក្នុងឱកាស ។ ក៏កាលបើសរីរ-ប្បទេស ដែលវត្ថុទាំងឡាយមានដង្គត់ បន្លា គ្រឿងប្រហារ និងអណ្តាតភ្លើងជាដើម បះទង្គិចហើយ ឈាមដោរហើយពង ឬក៏ ពកទាំងឡាយ

មានបូស និង ផ្លូចជាដើម កើតឡើង ក្នុងសរីរប្បទេសណាៗ ខ្ទុះ ក៏តាំងនៅក្នុងសរីរប្បទេសនោះៗ ។ ដោយបរិច្ឆេទ ខ្ទុះនោះលោកកំណត់ហើយដោយចំណែកនៃខ្ទុះ ។ នេះជាការកំណត់ នូវចំណែករបស់ខ្លួន នៃខ្ទុះនោះ ។ ឯការកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ឈាម)

ពាក្យថា "ឈាម" គឺ ឈាមមាន ២ យ៉ាង គឺៈ ឈាមខាប់ ១ ឈាមរាវ ១ ។ បណ្តាឈាមទាំងពីរនោះ ឈាមខាប់ ដោយពណ៌ មានពណ៌ដូចជាទឹកល័ក្ខ ដែលបុគ្គលចំអិនខាប់ ឈាមរាវ មានពណ៌ដូចជាទឹកល័ក្ខដ៏ថ្លា ។ ដោយទ្រង់ទ្រាយ ឈាមទាំងពីរ មានទ្រង់ទ្រាយ តាមឱកាស ។ ដោយទិស ឈាមខាប់ កើតហើយ ក្នុងទិសខាងលើ ឈាមក្រៅនេះ កើតក្នុងទិសទាំងឡាយពីរ ។ ដោយឱកាស ឈាមរាវ លើទុកនូវទីបំផុតចាកសាច់ នៃសក់ រោម ធ្មេញ និង ក្រចកទាំងឡាយផង នូវស្បែកទាំងរឹងទាំងស្ងួតផង ផ្សាយទៅកាន់ឧបាទិន្នកសរីរៈទាំងអស់ហើយតាំងនៅ តាមខ្សែបណ្តាញនៃសរសៃ ឈាមខាប់ ញ៉ាំងចំណែកខាងក្រោមនៃទីតាំងនៃថ្លើមឲ្យពេញហើយ មានប្រមាណពេញមួយបាត្រ ហូរចេញបន្តិចៗ ខាងលើ នៃតំរងបស្សាវៈ បេះដូង ថ្លើម និង សួត ញ៉ាំងតំរងបស្សាវៈ បេះដូង ថ្លើម និង សួតទាំងឡាយ ឲ្យសើមឋិតនៅ ព្រោះថា កាលបើឈាមនោះ មិនញ៉ាំងអាការៈទាំងឡាយ មានតំរងបស្សាវៈ បេះដូងជាដើម ឲ្យសើមទេ សត្វទាំងឡាយ ក៏នឹងស្រេកឃ្លាន ។ ដោយបរិច្ឆេទ ឈាមនោះ លោកកំណត់ហើយដោយចំណែកនៃឈាម ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួននៃឈាមនោះ ។ ឯកិរិយាកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ញើស)

ពាក្យថា “ញើស” គឺ ធាតុទឹកដែលហូរចេញ អំពីរន្ធទាំងឡាយ មានរន្ធរោមជាដើម ។ ញើសនោះ ដោយពណ៌ មានពណ៌ដូចជាប្រេងល្វ ដ៏ថ្លា ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយតាមឱកាស។ ដោយទិស កើត ក្នុងទិសទាំងឡាយពីរ ។ ដោយឱកាស ញើសនោះ គប្បីឋិតនៅ សព្វៗ កាល ដូចជាឈាម ក្នុងឱកាសណា ធម្មតាឱកាសនៃញើស ជាប់ជានិច្ច នោះ មិនមាន ។ ក៏ក្នុងកាលណា សរីរៈ ស្អុះស្អាប់អំពីហេតុទាំងឡាយ មានកំដៅភ្លើង កំដៅព្រះអាទិត្យ និង ការប្រែប្រួលរដូវជាដើម ក្នុងកាល នោះ ញើស ក៏ហូរចេញ អំពីចន្លោះ នៃរន្ធសក់ និង រោមទាំងពួង ដូច ជាបាច់នៃទងឈូក គ្រាន់តែបុគ្គលដកហើយ អំពីទឹក មានក្រអៅ និង ឫស ដាច់មិនស្មើគ្នា ព្រោះហេតុនោះ សូម្បីទ្រង់ទ្រាយ នៃញើសនោះ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃចន្លោះនៃរន្ធសក់ និងរោមហ្នឹងឯង ។ ក៏ព្រះយោគី អ្នកកំណត់នូវញើស គប្បីធ្វើទុកក្នុងចិត្តនូវញើស ដោយ អំណាចនៃញើសដែលញាំងចន្លោះ នៃរន្ធសក់ និង រោម ឲ្យពេញហើយ ឋិតនៅហ្នឹងឯង ។ ដោយបរិច្ឆេទ ញើស លោកកំណត់ហើយ ដោយ ចំណែកនៃញើស ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួននៃញើស នោះ ។ ឯការកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ខ្លាញ់ខាប់)

ពាក្យថា “ខ្លាញ់ខាប់” គឺ ជ័រដែលខាប់ ។ ខ្លាញ់ខាប់នោះ ដោយ ពណ៌ មានពណ៌ដូចជារមៀតដែលបុគ្គលចិតហើយ ។ ដោយទ្រង់ទ្រាយ ខ្លាញ់ខាប់ សំរាប់មនុស្សធាត់ មុន មានទ្រង់ទ្រាយដូចជាកំណាត់សំពត់ ពីរជាន់ មានពណ៌ដូចជារមៀត ដែលបុគ្គលតំកល់ទុកហើយ ក្នុងចន្លោះ

នៃស្បែក និង សាច់ សំរាប់មនុស្សស្គម មានទ្រង់ទ្រាយដូចជាកំណាត់ សំពត់ពីរជាន់ មានពណ៌ដូចជារមៀត ដែលបុគ្គលធ្វើឲ្យទៅជាពីរបីជាន់ ហើយតំកល់ទុក ព្រោះអាស្រ័យ នូវសាច់ទាំងឡាយនេះ គឺ: សាច់ស្មង សាច់ភ្លៅ សាច់ខ្នង ដែលអាស្រ័យនូវទ្រនុងខ្នង សាច់កណ្តាប់ពោះ ។ ដោយទិស ខ្លាញ់ខាប់កើតហើយក្នុងទិសទាំងឡាយពីរ ។ ដោយឱកាស ខ្លាញ់ខាប់ ផ្សាយទៅកាន់សរីរៈទាំងមូល របស់មនុស្សធាត់ អាស្រ័យនូវ សាច់ផ្សេងៗ មានសាច់ស្មងមនុស្សស្គមជាដើមឋិតនៅ ជនទាំងឡាយ មិនកាន់យកនូវខ្លាញ់ខាប់ សូម្បីដល់ហើយនូវការរាប់ថា ជាប្រេង ដើម្បី ប្រយោជន៍ធ្វើជាប្រេង (សំរាប់លាបនូវសក់) លើក្បាល មិនកាន់យក ដើម្បីប្រយោជន៍ ដល់វត្ថុទាំងឡាយមានប្រេងសំរាប់ហិត តាមច្រមុះ ជា ដើម ព្រោះខ្លាញ់ខាប់នុ៎ះ ជារបស់ដែលគួរខ្ពើមក្រៃពេក ។ ដោយបរិច្ឆេទ ខាងក្រោម ខ្លាញ់ខាប់នោះ លោកកំណត់ហើយ ដោយសាច់ ខាងលើ កំណត់ដោយស្បែក ទទឹង កំណត់ដោយចំណែក នៃខ្លាញ់ខាប់ ។ នេះ ជាកិរិយាកំណត់ នូវចំណែករបស់ខ្លួន នៃខ្លាញ់ខាប់នោះ ។ ឯកិរិយា កំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ទឹកភ្នែក)

ពាក្យថា “ទឹកភ្នែក” គឺធាតុទឹកដែលហូរចេញពីភ្នែកទាំងឡាយ។ ទឹកភ្នែកនោះ ដោយពណ៌ មានពណ៌ដូចជាប្រេងល្វដ៏ថ្លា ។ ដោយទ្រង់ ទ្រាយ មានទ្រង់ទ្រាយតាមឱកាស ។ ដោយទិស កើតហើយ ក្នុងទិស ខាងលើ ។ ដោយឱកាស ឋិតនៅហើយ ក្នុងរន្ធភ្នែកទាំងឡាយ ។ ប៉ុន្តែ ទឹកភ្នែកនេះ មិនបានដក់នៅ សព្វៗ កាល ក្នុងរន្ធភ្នែកទាំងឡាយ ដូចជា ទឹកប្រមាត់ដក់នៅ ក្នុងស្រោមប្រមាត់ទេ ។ ក៏ក្នុងកាលណា សត្វទាំង

ឡាយ កើតសោមនស្ស សើចយ៉ាងខ្លាំង កើតទោមនស្ស យំខ្សឹកខ្សួល ឬក៏ លេបអាហារមិនស្មើ មានសភាពដូច្នោះ មួយទៀត ក្នុងកាលណា ក្អែកទាំងឡាយ នៃសត្វទាំងឡាយនោះ ខ្ទាំងខ្ទប់ ដោយវត្ថុទាំងឡាយ មានផ្សែងធូលី និង អាចម៍ដីជាដើម ក្នុងកាលនោះ ទឹកក្អែកនោះ ក៏កើតឡើង ព្រោះសោមនស្ស និង ទោមនស្ស អាហារ និង រដូវដែលមិនស្មើ ទាំងឡាយនេះហើយ ឋិតនៅពេញរន្ធក្អែកខ្លះ ហូរចេញមកខ្លះ ។ ក៏ព្រះយោគី អ្នកកំណត់នូវទឹកក្អែក គប្បីកំណត់ ដោយអំណាច នៃទឹកក្អែក ដែលញ៉ាំងរន្ធក្អែកទាំងឡាយ ឲ្យពេញហើយ ឋិតនៅហ្នឹងឯង ។ ដោយបរិច្ឆេទ ទឹកក្អែក លោកកំណត់ហើយ ដោយចំណែកនៃទឹកក្អែក ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួននៃទឹកក្អែកនោះ ។ ឯកិរិយាកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ខ្លាញ់រាវ)

(១៦១) ពាក្យថា "ខ្លាញ់រាវ" ប្រែថា ជ័ររាវ ។ ខ្លាញ់រាវនោះ ដោយពណ៌ មានពណ៌ដូចប្រេងដូង ។ ការពោលថា "មានពណ៌ដូចជាប្រេងដែលគេស្រោចហើយ ក្នុងទឹកបាយ" ដូច្នេះខ្លះ ក៏គួរ ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយដូចជាតំណក់ប្រេងដែលស្រក់ចុះ អណ្តែត ព្ធដ៏ខាងលើ នៃទឹកដែលថ្លា ក្នុងវេលាដែលងូត ។ ដោយទិស កើតក្នុងទិសទាំងឡាយពីរ ។ ដោយឱកាស ភាគច្រើន ខ្លាញ់ខាប់នោះ ឋិតនៅហើយ លើផ្ទៃដៃ ខ្នងដៃ ផ្ទៃជើង ខ្នងជើង ក្តោងច្រមុះ ថ្ងាស និង ចង្កូយស្មាទាំងឡាយ ។ ប៉ុន្តែខ្លាញ់ខាប់នេះ មិនមែនជាធម្មជាតរលាយ ឋិតនៅក្នុងឱកាសទាំងនេះ សព្វៗ កាល បានទេ ក៏ក្នុងពេលណា ប្រទេស (គឺរាងកាយ) ទាំងនោះ ជាសភាវៈមានចំហាយកើតហើយ ព្រោះកំដៅភ្លើង

កំដៅព្រះអាទិត្យ រដូវមិនស្មើ និង ធាតុមិនស្មើទាំងឡាយ ក្នុងពេលនោះ ខ្លាញ់ខាប់នោះ សព្វូរទៅ ខាងនុ៎ះផង ខាងនេះផង ក្នុងសរីរប្បទេសទាំងឡាយនោះ ដូចជាតំណក់ប្រេងដែលស្រក់ចុះទៅ លើទឹកដែលថ្លា ក្នុងពេលដែលងូតដូច្នោះឯង ។ ដោយបរិច្ឆេទ ខ្លាញ់រាវនោះ លោកកំណត់ហើយ ដោយចំណែកនៃខ្លាញ់រាវ ។ នេះជាកិរិយាកំណត់ នូវចំណែករបស់ខ្លួននៃខ្លាញ់រាវនោះ ។ ឯការកំណត់នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ទឹកមាត់)

ធាតុទឹកលាយដោយពពុះ ព្ធដ៏ខាងក្នុងមាត់ ឈ្មោះថាទឹកមាត់ ។ ទឹកមាត់នោះ ដោយពណ៌ គឺពណ៌-ស មានពណ៌ដូចពពុះទឹក ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយតាមឱកាស។ ការពោលថា "មានទ្រង់ទ្រាយដូចជាពពុះទឹក" ដូច្នេះខ្លះ ក៏គួរ ។ ដោយទិស កើតហើយ ក្នុងទិសខាងលើ ។ ដោយឱកាស ទឹកមាត់នោះ ហូរចុះ តាមខាងនៃថ្ពាល់ទាំងពីរ ហើយឋិតនៅ លើអណ្តាត ។ ប៉ុន្តែទឹកមាត់នោះ មិនដែលដក់នៅ ក្នុងទីនុ៎ះ សព្វៗ កាល ទេ ក៏ក្នុងពេលណា សត្វទាំងឡាយឃើញ ឬ រលឹកដល់នូវអាហារ យ៉ាងដូច្នោះ ឬក៏ ដាក់នូវអាហារណាមួយ ក្នុងចំណោមអាហារដែលមានរសក្តៅ ល្វីង ហឹរ ប្រៃ និង ជូរ ទាំងឡាយ ក្នុងមាត់ ឬក៏ ក្នុងពេលណា បេះដូង របស់សត្វទាំងឡាយនោះ រមួល ឬ សេចក្តីខ្ពើម កើតឡើងក្នុងវត្ថុណាមួយហ្នឹងឯង ក្នុងពេលនោះ ទឹកមាត់ កើតឡើងហើយ ហូរចុះ តាមខាងនៃថ្ពាល់ទាំងឡាយពីរ ហើយឋិតនៅ លើអណ្តាត ។ មួយទៀត ទឹកមាត់នោះ លើចុងអណ្តាត មានតិច លើគល់អណ្តាត មានច្រើន ។ មួយទៀត អណ្តាតនុ៎ះ មិនដល់នូវការអស់ទៅ

សោះឡើយ ដូចជាទឹកអណ្តូង ដែលបុគ្គលជីកហើយ លើដីខ្សាច់ ក្បែរស្ទឹង មិនដល់នូវការអស់ទៅ ដូច្នោះឯង ជាទឹកមាត់អាច ដើម្បីនឹងញ៉ាំងអំបុក ឬ អង្ករ ឬក៏ ញ៉ាំងខាទនីយៈ ដទៃណាមួយ ដែលគេដាក់ចូលទៅហើយ ក្នុងមាត់ ឲ្យសើមបាន ។ ដោយបរិច្ឆេទ ទឹកមាត់នោះ លោកកំណត់ហើយ ដោយចំណែកនៃទឹកមាត់ ។ នេះជាការកំណត់នូវចំណែករបស់ខ្លួននៃទឹកមាត់នោះ ។ ឯការកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ទឹកសំបោរ)

ទឹកមិនស្អាត ដែលហូរចេញមក អំពីខួរក្នុងក្បាល ឈ្មោះថាទឹកសំបោរ ។ ទឹកសំបោរនោះ ដោយពណ៌ មានពណ៌បីដូចជាខួរ ក្នុងគ្រាប់ត្នោតខ្ចី ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយតាមឱកាស ។ ដោយទិស កើតហើយ ក្នុងទិសខាងលើ ។ ដោយឱកាស ឋិតនៅពេញក្តោងប្រមុះ ។ ប៉ុន្តែ ទឹកសំបោរនោះ មិនឋិតនៅ ក្នុងក្តោងប្រមុះនុ៎ះ សព្វៗកាលទេ ។ តាមពិត ក្នុងពេលណា សត្វទាំងឡាយ យំ ឬក៏ ជាអ្នកមានការកំរើកនៃធាតុដែលកើតឡើង ដោយអំណាចនៃអាហារ និងរដូវ មានចំណែកមិនស្មើ ក្នុងពេលនោះ ខួរក្នុងក្បាល ដែលដល់ហើយនូវភាពជាស្ទេស្នស្អុយ ហូរចេញ អំពីខាងក្នុងក្បាល ហើយធ្លងចុះ តាមចន្លោះទីបំផុតក្រអូមមាត់ហើយ ញ៉ាំងក្តោងប្រមុះឲ្យពេញ ហើយឋិតនៅខ្លះ ហូរចេញខ្លះ ដូចជាបុរសខ្ចប់នូវទឹកដោះជូរ ក្នុងស្លឹកឈូកហើយ យកបន្លាចាក់ ព្ធដ៏ខាងក្រោម កាលបើដូច្នោះ ទឹកដោះជូររាវ ក៏ហូរចេញមក តាមប្រហោងនោះហើយ គប្បីធ្លាក់ចុះមកខាងក្រៅ យ៉ាងនោះឯង ។ ក៏ព្រះយោគីអ្នកកំណត់នូវទឹកសំបោរ គប្បីកំណត់ ដោយអំណាចទឹកសំបោរ

ដែលដក់នៅពេញក្តោងប្រមុះហ្នឹងឯង ។ ដោយបរិច្ឆេទ ទឹកសំបោរនោះ លោកកំណត់ហើយ ដោយចំណែកនៃទឹកសំបោរ ។ នេះជាការកំណត់នូវចំណែក របស់ខ្លួននៃទឹកសំបោរនោះ ។ ឯការកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ទឹកលំអិល)

សាកសពជាលំអិល ព្ធដ៏ខាងក្នុង នៃតំណក្នុងសរីរៈ ឈ្មោះថាទឹកលំអិល ។ ទឹកលំអិលនោះ ដោយពណ៌ មានពណ៌ដូចជាជ័រ នៃផ្កាកណ្ណិការ ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយតាមឱកាស ។ កើត ក្នុងទិសទាំងឡាយពីរ ។ ដោយឱកាស ទឹកលំអិលនោះ ឋិតនៅ ខាងក្នុងនៃតំណ ១៨០ ញ៉ាំងកិច្ចគឺការបត់នូវតំណនៃឆ្អឹងទាំងឡាយ ឲ្យសំរេច ។ ក៏ទឹកលំអិលនុ៎ះ នៃបុគ្គលណាមានតិច កាលបើបុគ្គលនោះ ក្រោកឡើង អង្គុយចុះ ឈានទៅមុខ ឈានថយក្រោយ បត់ចូល លាចេញ ឆ្អឹងទាំងឡាយ ក៏រមែងលាន់ឮសូរសំឡេងកដៈកដៈ ដូចជាបុគ្គលដើរផ្ទាត់ម្រាមដៃ យ៉ាងដូច្នោះឯង ។ កាលបុគ្គលនោះ ដើរទៅកាន់ផ្លូវឆ្ងាយ អស់ទីត្រឹម ១ យោជន៍ និង ២ យោជន៍ វាយោធាតុ ក៏កំរើក ខ្លួនទាំងឡាយក៏លំបាក ។ តែថា ទឹកលំអិល នៃបុគ្គលណា មានច្រើន ឆ្អឹងទាំងឡាយនៃបុគ្គលនោះ មិនលាន់ឮសូរសំឡេង កដៈកដៈ ក្នុងការកំរើកទាំងឡាយមានការក្រោក និង ការអង្គុយជាដើមទេ កាលបើបុគ្គលនោះ សូម្បីដើរទៅកាន់ផ្លូវឆ្ងាយ វាយោធាតុ ក៏មិនកំរើក ខ្លួនទាំងឡាយ ក៏មិនលំបាក ។ ដោយបរិច្ឆេទ ទឹកលំអិលនោះ លោកកំណត់ហើយ ដោយចំណែកនៃទឹកលំអិល។ នេះជាការកំណត់នូវចំណែករបស់ខ្លួននៃទឹកលំអិលនោះ ។ ឯការកំណត់ នូវចំណែកមិនស្មើគ្នា ប្រាកដស្មើដោយសក់ដែរ ។

(ទឹកមូត្រ)

ពាក្យថា “ទឹកមូត្រ” គឺ ដោយពណ៌ ទឹកមូត្រនោះមានពណ៌ដូចជាទឹកក្បុង នៃសណ្តែករាជមាស ។ ដោយទ្រង់ទ្រាយ មានទ្រង់ទ្រាយដូចជាទឹកដែលឋិតនៅ ខាងក្នុងក្អមទឹក ដែលបុគ្គលដាក់ផ្កាប់មាត់ ទៅខាងក្រោម ។ ដោយទិស កើត ក្នុងទិសខាងក្រោម ។ ដោយឱកាសឋិតនៅខាងក្នុង នៃក្រពះបស្សាវៈ ។ ផ្ទៃនៃក្រពះបស្សាវៈ លោកហៅថា ឈ្មោះថា ក្រពះបស្សាវៈ ។ ទឹកមូត្រ អំពីសរីរៈ ក្នុងក្រពះបស្សាវៈតែងហូរចូល តែថា ផ្លូវជាទីហូរចូលទៅ នៃទឹកមូត្រនោះ មិនប្រាកដទេ ប្រាកដតែផ្លូវជាទីហូរចេញ ដូចជាទឹកជ្រាំ ហូរចូលទៅ ក្នុងក្អមដែលស្រាំមានមាត់ចុះក្រោម ដែលបុគ្គលដាក់ហើយនៅក្បែររណ្តៅទឹកជ្រាំ តែផ្លូវជាទីហូរចូលទៅ នៃទឹកជ្រាំនោះ មិនប្រាកដ យ៉ាងនោះឯង ។ មួយទៀត កាលបើក្រពះបស្សាវៈ ពេញហើយ ដោយទឹកមូត្រ សេចក្តីខ្វល់ខ្វាយថា “យើងទាំងឡាយបន្ទោបង់នូវបស្សាវៈ” តែងមានដល់សត្វទាំងឡាយ ។ ដោយបរិច្ឆេទ ទឹកមូត្រនោះ លោកកំណត់ហើយ ដោយខាងក្នុងនៃក្រពះបស្សាវៈផង ដោយចំណែក នៃទឹកមូត្រផងដែរ ។ នេះជាការកំណត់នូវចំណែករបស់ខ្លួន នៃទឹកមូត្រនោះ ។ ឯការកំណត់នូវចំណែកមិនស្មើគ្នាប្រាកដស្មើដោយសក់ដែរ ។

សរុប

(១៦២) ក៏កាលព្រះយោគី កាលកំណត់នូវចំណែកទាំងឡាយ មានសក់ជាដើម ដោយអំណាចនៃពណ៌ ទ្រង់ទ្រាយ ទិស ឱកាស និង បរិច្ឆេទ យ៉ាងនេះហើយ ធ្វើទុកក្នុងចិត្តថា “បដិកូលៗ” ដោយចំណែក ៥ ដោយអំណាយពណ៌ ទ្រង់ទ្រាយ ក្លិន ទីនៅអាស្រ័យ និង ឱកាស

តាមន័យថា “ដោយលំដាប់ ដោយមិនលឿនពេក” ដូច្នេះជាដើម ក្នុងទីបំផុតនៃការឈានកន្លងនូវបញ្ញត្តិ ពិចារណា នូវកាយនេះថា “សក់ទាំងឡាយ មាន ក្នុងកាយនេះ” ដូច្នេះជាអាទិ៍ ធម៌ទាំងឡាយទាំងពួងនោះ ជាធម៌ប្រាកដ មិនមុនមិនក្រោយ ប្រៀបដូចជាកាលបុរសមានចក្ខុ ក្រឡេកមើលនូវផ្កាកម្រង ដែលគេក្រងផ្កាមានពណ៌ ៣២ ប្រការ ដោយអំបោះមួយសរសៃរួមគ្នា ផ្កាទាំងពួងទាំងឡាយជាផ្កាប្រាកដ មិនមុនមិនក្រោយដូច្នោះឯង ។ ព្រោះហេតុនោះ ទើបលោកពោលទុក ក្នុងមនសិការកោ-សល្លកថា ថា: ក៏អាទិកម្មិកបុគ្គល កាលធ្វើទុកក្នុងចិត្ត ថា “កេសា” ដូច្នេះ មនសិការ ទៅទល់នឹងចំណែកជាទីបំផុតនេះថា “មុត្តំ” ហើយឋិតនៅ ។ ក៏ប្រសិនបើព្រះយោគីនោះ ប្រមូលមកនូវមនសិការ សូម្បីខាងក្រៅ កាលបើដូច្នេះ នាកាលកោដ្ឋាសៈទាំងពួងទាំងឡាយប្រាកដ ដល់ព្រះយោគីនោះ យ៉ាងនេះ សត្វទាំងឡាយ មានមនុស្ស និង តិរច្ឆាន ជាដើម ដែលដើរមក លះបង់នូវអាការៈរបស់សត្វ រមែងប្រាកដ ដោយអំណាចនៃគំនរនៃកោដ្ឋាសៈតែម្យ៉ាង ក៏វត្ថុមានទឹក និង ភោជន ជាដើម ដែលសត្វទាំងឡាយមានមនុស្ស និង តិរច្ឆានជាដើមនោះ លេបចូលទៅ រមែងប្រាកដ បីដូចជាវត្ថុដែលគេដាក់ចូលទៅ ក្នុងគំនរនៃកោដ្ឋាសៈ ។

(និមិត្ត និង អប្បនា)

ក្នុងលំដាប់នោះ កាលព្រះយោគីនោះ ធ្វើទុកក្នុងចិត្តរឿយៗ ថា “បដិកូលៗ” ដោយអំណាចនៃមនសិការកោសល្លវិធី មានការលះបង់នូវលំដាប់ជាដើម អប្បនា រមែងកើតឡើង តាមលំដាប់ ។ ក្នុងកិរិយាកើតឡើងនៃអប្បនានោះ បណ្ឌិតគប្បីជ្រាបថា: កិរិយាប្រាកដ ដោយអំណាចនៃពណ៌ ទ្រង់ទ្រាយ ទិស ឱកាស និង បរិច្ឆេទ នៃចំណែកទាំងឡាយ

មានសក់ជាដើម ឈ្មោះថា ឧគ្គហនិមិត្ត កិរិយាប្រាកដ (នៃកោដ្ឋាសៈទាំងនោះ) ដោយអំណាចនៃបដិកូល ដោយអាការៈគ្រប់យ៉ាង ឈ្មោះថា បដិភាគនិមិត្ត ។ កាលព្រះយោគី សេព ធ្វើឲ្យច្រើន នូវបដិភាគនិមិត្តនោះ អប្បនា រមែងកើតឡើង ដោយអំណាចនៃបឋមជ្ឈាន បីដូចជាអប្បនា ក្នុងអសុភកម្មដ្ឋាន តាមន័យដែលយើងពោលមកហើយ ។ ព្រះយោគាវចរណាមានចំណែកមួយគត់ប្រាកដ ឬព្រះយោគាវចរណា ដល់នូវអប្បនា ក្នុងចំណែកមួយហើយ មិនធ្វើនូវសេចក្ដីព្យាយាម ជាគ្រឿងប្រកប ក្នុងចំណែកដទៃ បន្ថែមទៀត អប្បនា តែមួយគត់ រមែងកើតឡើង ដល់ព្រះយោគាវចរនោះ ។ ចំណែកឯព្រះយោគាវចរណា មានចំណែកដ៏ច្រើន ប្រាកដ ឬថា ព្រះយោគាវចរណា ដល់នូវឈាន ក្នុងចំណែកមួយហើយ ក៏ធ្វើនូវសេចក្ដីព្យាយាមជាគ្រឿងប្រកប សូម្បីក្នុងចំណែកដទៃ បន្តទៅទៀត បឋមជ្ឈានទាំងឡាយ ដោយកិរិយារាប់នូវចំណែក រមែងកើតឡើង ដល់ព្រះយោគាវចរនោះៗ ដូចជាបឋមជ្ឈានទាំងឡាយ កើតឡើង ដល់ព្រះមល្លកត្ថេរ ដូច្នោះឯង ។

បានឮថា លោកអ្នកមានអាយុនោះ ចាប់ដៃព្រះអភយត្ថេរ អ្នកពោលគម្ពីរទីឃនិកាយហើយ ពោលថា “ម្នាលអភ័យដ៏មានអាយុ បន្តិចពីនេះ ចូរអ្នករៀននូវបញ្ហានេះមុន” ហើយពោលថា “ព្រះមល្លកត្ថេរជាអ្នកបាន នូវបឋមជ្ឈាន ៣២ ក្នុងចំណែក ៣២ ប្រសិនបើលោកចូលនូវឈានមួយ ក្នុងវេលាយប់ ឈានមួយ ក្នុងវេលាថ្ងៃ លោកសំរេចនូវឈាននោះ ម្ដងទៀត ដោយកន្លះនៃខែដ៏ក្រៃលែង ប្រសិនបើលោកចូលឈានមួយ រាល់ៗ ថ្ងៃ លោកក៏សំរេច ម្ដងទៀត ដោយខែមួយដ៏ក្រៃលែង” ដូច្នេះឯង ។

(ហេតុដែលហៅថាកាយគតាសតិ)

ក៏កម្មដ្ឋាននេះ សូម្បីសំរេច ដោយអំណាចនៃបឋមជ្ឈាន យ៉ាងដូច្នេះ ក៏លោកហៅថា “កាយគតាសតិ” ព្រោះសំរេច ដោយកំឡាំង នៃសតិ ក្នុងចំណែកទាំងឡាយ មានពណ៌ និង ទ្រង់ទ្រាយជាដើម ។

(អានិសង្សចំរើនកាយគតាសតិ)

ក៏ឯភិក្ខុដែលប្រកបរឿយៗ នូវកាយគតាសតិនេះ ជាអ្នកគ្របសង្កត់សេចក្ដីត្រេកអរ ដោយសេចក្ដីមិនត្រេកអរបាន ទាំងសេចក្ដីមិនត្រេកអរ ក៏មិនគ្របសង្កត់នូវភិក្ខុនោះឡើយ ភិក្ខុនោះ តែងគ្របសង្កត់ហើយៗ នូវសេចក្ដីមិនត្រេកអរដែលកើតហើយ ១, ជាអ្នកគ្របសង្កត់នូវភ័យ និង សេចក្ដីខ្លាចបាន ឯភ័យ និង សេចក្ដីខ្លាច គ្របសង្កត់ នូវភិក្ខុនោះពុំបានឡើយ ភិក្ខុនោះតែងគ្របសង្កត់ហើយនូវភ័យ និង សេចក្ដីខ្លាចដែលកើតហើយ ១, ជាអ្នកអត់ធ្មត់ចំពោះត្រជាក់ កំដៅ (១) ។បេ។ ជាអ្នកអត់ធ្មត់ ចំពោះគន្លងពាក្យ ដែលគេពោលអាក្រក់... ដែលអាចនាំនូវជីវិតចេញបាន ១, ជាអ្នកបានឈាន ៤ ចាក់ធ្លុះនូវអភិញ្ញា ៦ ព្រោះអាស្រ័យនូវពណ៌ផ្សេងៗ នៃកោដ្ឋាសៈទាំងឡាយ មានសក់ជាដើម ។

ព្រោះហេតុដូច្នោះឯង ភិក្ខុអ្នកមានប្រាជ្ញា គប្បីជាអ្នក
មិនប្រមាទ ប្រកបរឿយៗនូវកាយគតាសតិនេះ ដែល
មានអានិសង្សច្រើន ដូចបានពោលមកនេះឯង ។

នេះជាកថាមុខ ដោយពិស្ដារ ក្នុងកាយគតាសតិ ។

---

(១)- សុ. ម. ភាគទី ២៦ ទំព័រទី ៣៩៧ ។

អានាបានសតិ

(១៦៣) ក្នុងកាលឥឡូវនេះ អានាបានស្សតិនោះណា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរ យ៉ាងនេះ ថា "ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះឯង ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ ជាធម៌ល្អិតផង ជាធម៌ដ៏ឧត្តមផង ជាធម៌មិនប្រឡូកប្រឡំដោយ (តណ្ហា និង ឧបាទាន) ផង ជាធម៌ជាគ្រឿងនៅនាំមកនូវសេចក្តីសុខផង តែងញុំាងធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយៗ ឲ្យអន្តរធាន ឲ្យស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ" យ៉ាងដូច្នេះហើយ ទ្រង់សំដែងចេញ ឲ្យជាកម្មដ្ឋានមានវត្ថុ ១៦ យ៉ាងដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ ចុះអានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ ជាធម៌ល្អិតផង ជាធម៌ដ៏ឧត្តមផង ជាធម៌មិនប្រឡូកប្រឡំដោយ (តណ្ហានិងឧបាទាន) ផង ជាធម៌ជាគ្រឿងនៅ នាំមកនូវសេចក្តីសុខផង តែងញុំាងធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយៗ ឲ្យអន្តរធាន ឲ្យស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ ផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះ មានសតិដកដង្ហើយចេញ មានសតិដកដង្ហើមចូល (មានវត្ថុ ១៦ គឺៈ)

(ចតុក្កៈទី១)

១- ភិក្ខុនោះ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬ កាលដកដង្ហើយចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។

២- ភិក្ខុនោះ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬ កាលដកដង្ហើយចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ។

៣- ភិក្ខុសិក្សាថា អាត្មាអញកំណត់ដឹងច្បាស់ នូវកាយ គឺដកដង្ហើមចេញទាំងពួង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវកាយ គឺដកដង្ហើមចូលទាំងពួង នឹងដកដង្ហើមចូល ។

៤- ភិក្ខុសិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ គឺដកដង្ហើមចេញ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់ នូវកាយសង្ខារ គឺដកដង្ហើមចូល នឹងដកដង្ហើមចូល ។

(ចតុក្កៈទី២)

៥- ភិក្ខុសិក្សាថា អាត្មាអញ កំណត់ដឹងច្បាស់នូវបីតិ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងនូវបីតិ នឹងដកដង្ហើមចូល ។

៦- ភិក្ខុសិក្សាថា អាត្មាអញ កំណត់ដឹងច្បាស់ នូវសេចក្តីសុខ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញ កំណត់ដឹងច្បាស់ នូវសេចក្តីសុខ នឹងដកដង្ហើមចូល ។

៧- ភិក្ខុសិក្សាថា អាត្មាអញ កំណត់ដឹងច្បាស់ នូវចិត្តសង្ខារ គឺសញ្ញា និង វេទនា នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញ កំណត់ដឹងច្បាស់នូវចិត្តសង្ខារ នឹងដកដង្ហើមចូល ។

៨- ភិក្ខុសិក្សាថា អាត្មាអញ រម្ងាប់នូវចិត្តសង្ខារ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ នឹងដកដង្ហើមចូល ។

(ចតុក្កៈទី៣)

៩- ភិក្ខុសិក្សាថា អាត្មាអញ កំណត់ដឹងច្បាស់នូវចិត្ត នឹងដក

ដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងនូវចិត្ត នឹងដកដង្ហើមចូល ។

១០- ភិក្ខុសិក្សាថា អាត្មាអញ កាលញ៉ាំងចិត្តឲ្យរីករាយ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលញ៉ាំងចិត្តឲ្យរីករាយ នឹងដកដង្ហើមចូល ។

១១- ភិក្ខុសិក្សាថា អាត្មាអញ កាលញ៉ាំងចិត្ត ឲ្យតាំងនៅ ក្នុងអារម្មណ៍ដ៏ស្មើ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលញ៉ាំងចិត្តឲ្យតាំងនៅ ក្នុងអារម្មណ៍ដ៏ស្មើ នឹងដកដង្ហើមចូល ។

១២- ភិក្ខុសិក្សាថា អាត្មាអញ កាលញ៉ាំងចិត្ត ឲ្យរួចស្រឡះ (ចាកនីវរណធម៌ជាដើម) នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលញ៉ាំងចិត្តឲ្យរួចស្រឡះ នឹងដកដង្ហើមចូល ។

(ចតុក្កៈទី៤)

១៣- ភិក្ខុសិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវបញ្ចក្ខន្ធថា មិនទៀង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវបញ្ចក្ខន្ធ ថា មិនទៀង នឹងដកដង្ហើមចូល ។

១៤- ភិក្ខុសិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញ នូវធម៌ប្រាសចាកតម្រេក នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញ នូវធម៌ប្រាសចាកតម្រេក នឹងដកដង្ហើមចូល ។

១៥- ភិក្ខុសិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញ នូវធម៌សំរាប់រំលត់នូវទុក្ខ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញ នូវធម៌សំរាប់រំលត់នូវទុក្ខ នឹងដកដង្ហើមចូល ។

១៦- ភិក្ខុសិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញ នូវធម៌សំរាប់លះកិលេសចោល នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជា

អ្នកពិចារណាឃើញ នូវធម៌សំរាប់លះកិលេសចោល នឹងដកដង្ហើម (១) ចូល" ដូច្នេះឯង ។

និទ្ទេស នៃការចំរើននូវអានាបានស្សតិកម្មដ្ឋាននោះ ដល់ហើយតាមលំដាប់ ។ តែព្រោះនិទ្ទេសនោះ កាលបើពោលតាមលំអាននៃការពណ៌នានូវបាឡីហ្នឹងឯង នឹងបរិបូរដោយអាការៈទាំងពួង ព្រោះហេតុនោះ ក្នុងអានាបានស្សតិកម្មដ្ឋាននោះ និទ្ទេសនេះ គឺជានិទ្ទេសមានការពណ៌នានូវបាឡី ដល់មុន ។

(ពន្យល់សេចក្តីនៃបាឡីពាក្យសួរ)

បណ្ឌិត គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ត្រង់បទទាំងឡាយនេះ ថា "កថំ ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលចំរើនហើយ ដោយប្រការដូចម្តេច" ដូច្នេះជាដើមមុន ។

ពាក្យថា "កថំ" ជាព្រះបុច្ឆា ដោយភាពនៃព្រះអង្គ ទ្រង់ប្រាថ្នាចង់សំដែង នូវការចំរើននូវអានាបានស្សតិសមាធិ ឲ្យបានពិស្តារ ដោយប្រការផ្សេងៗ ។ ពាក្យថា "ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ" ជាពាក្យជាគ្រឿងសំដែងចេញ នូវធម៌ដែលព្រះអង្គទ្រង់ត្រាស់សួរហើយ ព្រោះភាពនៃព្រះអង្គ ទ្រង់ប្រាថ្នាចង់សំដែង នូវការចំរើននូវអានាបាន-ស្សតិសមាធិ ឲ្យបានពិស្តារ ដោយប្រការផ្សេងៗ ។ ន័យសូម្បីក្នុងពាក្យថា "កថំ ពហុលីកតោ ។បេ។ វូបសមេតិ" នេះ ក៏ដូចន័យនេះដែរ ។

បណ្តាបទទាំងនោះ បទថា "ភាវិតោ" គឺធ្វើឲ្យកើតឡើងផង ឲ្យចំរើនឡើងផង ។ បទថា "អានាបានស្សតិសមាធិ" សេចក្តីថា សមាធិ

១- សុ. សំ. ម. ភាគទី ៣៩ ទំព័រទី ២៧ ។

ដែលប្រកបព្រមហើយ ដោយសតិ ដែលកំណត់នូវខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូល មួយទៀត សមាធិ ក្នុងអានាបានស្សតិ ឈ្មោះថា អនាបានស្សតិសមាធិ ។ បទថា "ពហុលីកតោ" ប្រែថា ធ្វើឲ្យបានរឿយៗ ។

(គែសន្តោ បណីតោ)

បទពីរថា "សន្តោ ចេវ បណីតោ ច" ជាធម៌ល្អិតផង ជាធម៌ដ៏ឧត្តមផង ។ បណ្ឌិតគប្បីជ្រាប កិរិយាកំណត់ ក្នុងបទទាំងពីរ ដោយឯវស័ព្ទ ។ សួរថា: ពាក្យដូចម្ដេចដែលព្រះមានព្រះភាគត្រាស់ហើយ ។ ឆ្លើយថា: ព្រះអង្គទ្រង់ត្រាស់ថា "មែនពិត អានាបានស្សតិសមាធិ នេះ មិនមែនជាធម៌មិនល្អិតផង ជាធម៌មិនឧត្តមផង ដោយបរិយាយឯណាមួយ ដូចជាអសុភកម្មដ្ឋាន ដែលជាធម៌ល្អិតផង ជាធម៌ឧត្តមផង ដោយអំណាច នៃការចាក់ធ្លុះតែម្យ៉ាង ប៉ុន្តែជាធម៌មិនល្អិតផង មិនឧត្តមផង ដោយអំណាចនៃអារម្មណ៍ ព្រោះអសុភកម្មដ្ឋាននោះ មានអារម្មណ៍ដ៏គ្រោតគ្រាតផង មានអារម្មណ៍ជាបដិកូលផង ដូច្នោះទេ ។ បើតាមពិតទៅ អានាបានស្សតិសមាធិ ឈ្មោះថា ជាធម៌ល្អិត គឺជាធម៌ស្ងប់រម្ងាប់ ជាធម៌រំលត់ ព្រោះអានាបានស្សតិសមាធិនោះ ជាធម៌ដ៏ល្អិត ដោយអារម្មណ៍ខ្លះ ព្រោះជាធម៌ល្អិតដោយអង្គ ដែលរាប់បានថា ជាបដិវេធ ខ្លះ ឈ្មោះថា ជាធម៌ដ៏ឧត្តម គឺមិនធ្វើឲ្យឆ្អែត ព្រោះអានាបានស្សតិសមាធិនុ៎ះ ជាធម៌ដ៏ឧត្តម ដោយអារម្មណ៍ខ្លះ ជាធម៌ដ៏ឧត្តម ដោយអង្គខ្លះ" ដូច្នេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា " (អានាបានស្សតិ-សមាធិ) ជាធម៌ល្អិតផង ជាធម៌ដ៏ឧត្តមផង" ។

(គែអសេចនគោ)

ចំណែកក្នុងពាក្យនុ៎ះថា "អសេចនកោ ច សុខោ ច វិហារោ ជាធម៌មិនប្រឡូកប្រឡំផង ជាធម៌ជាគ្រឿងនៅនាំមកនូវសេចក្ដីសុខផង" មានអធិប្បាយថា: កិរិយាស្រោចស្រប់ មិនមាន ដល់អានាបានស្សតិ-សមាធិនោះ ព្រោះហេតុនោះ អានាបានស្សតិសមាធិនោះ ទើបឈ្មោះថា មិនមានការស្រោចស្រប់ គឺមិនបាច់ប្រោះព្រំ មិនប្រឡូកប្រឡំ ញែកដោយឡែក មិនប្របូកប្របល់, សេចក្ដីល្អិត ក្នុងអានាបានស្សតិសមាធិនេះ មិនមានដោយបរិកម្ម ឬ ដោយឧបចារៈទេ អានាបានស្សតិសមាធិនេះ ជាធម៌ដ៏ល្អិតផង ជាធម៌ដ៏ឧត្តមផង ដោយភាវៈរបស់ខ្លួនមែនពិត ចាប់ដើមអំពីការប្រមូលចិត្តធ្វើកម្មដ្ឋានជាដំបូងមក ។ ចំណែកឯអាចារ្យពួកខ្លះ ពោលថា: បទថា "អសេចនកោ" សេចក្ដីថា មិនបាច់ប្រោះព្រំ ជារបស់មានរសឆ្ងាញ់ តាមសភាវៈហ្នឹងឯង ។ បណ្ឌិតគប្បីជ្រាប ថា អានាបានស្សតិសមាធិនេះ ជាធម៌មិនមានការស្រោចស្រប់ហ្នឹងឯង ទើបជាធម៌ជាគ្រឿងនៅនាំមកនូវសេចក្ដីសុខផង ព្រោះប្រព្រឹត្តទៅ ដើម្បីបានចំពោះ នូវសេចក្ដីសុខតាមផ្លូវកាយ និង សេចក្ដីសុខតាមផ្លូវចិត្ត ក្នុងខណៈដែលដល់នូវអប្បនា ។

បទថា "ឧប្បន្នុប្បន្នេ" គឺដែលមិនទាន់បានសង្កត់សង្កិនហើយៗ ។ បទថា "បាបកេ" គឺដ៏អាក្រក់ ។ បទពីរថា "អកុសលេ ធម្មេ" គឺធម៌ដែលកើតអំពីសេចក្ដីមិនឆ្លាត ។ បទពីរថា "ឋានសោ អន្តរធាបេតិ" គឺញុំាងធម៌ដែលជាបាបអកុសលឲ្យអន្តរធានទៅ គឺឲ្យស្ងប់រម្ងាប់ ដោយខណៈហ្នឹងឯង ។ បទថា "វូបសមេតិ" គឺ ឲ្យចូលទៅរម្ងាប់ ដោយល្អមួយទៀត ព្រះយោគាវចរនោះ ដល់នូវសេចក្ដីចំរើន ដោយអរិយមគ្គតាមលំដាប់ រមែងផ្ដាច់បង់ អធិប្បាយថា ធ្វើឲ្យស្ងប់រម្ងាប់ ព្រោះភាវៈនៃ

អានាបានស្សតិសមាធិនោះ ជាធម៌មានចំណែកនៃសេចក្តីទំលុះទំលាយ។

ក៏ក្នុងព្រះបាឡីនៃពាក្យសួរនោះ មានសេចក្តីសង្ខេបដូចតទៅនេះថា "ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានចំរើនហើយ ដោយប្រការៈដូចម្តេច ដោយអាការៈដូចម្តេច ដោយវិធីដូចម្តេច បានធ្វើឲ្យច្រើនហើយ ដោយប្រការៈដូចម្តេច... ទើបជាធម៌ដ៏ល្អិតផង ។បេ។ ឲ្យស្ងប់រម្ងាប់ ដោយហេតុដ៏សមគួរ" ។

(ពន្យល់សេចក្តីនៃបាឡីឆ្លើយ)

(១៦៤) ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ញ៉ាំងសេចក្តីនោះ ឲ្យពិស្តារ ទើបត្រាស់នូវពាក្យថា "ឥធ ភិក្ខវេ" ដូច្នេះជាដើម ។

(កែឥធស័ព្ទ)

ក្នុងពាក្យទាំងនោះ ពាក្យថា "ឥធ ភិក្ខវេ ភិក្ខុ" សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ។ ព្រោះថា ឥធស័ព្ទនេះ ក្នុងបទថា "ឥធ ភិក្ខវេ ភិក្ខុ" នុ៎ះ ជាគ្រឿងបំភ្លឺនូវសាសនាដែលជាទីកកើតនៃបុគ្គលអ្នកញ៉ាំងអានាបានស្សតិសមាធិ មានប្រការទាំងពួងឲ្យកើតផង ជាគ្រឿងបដិសេធនូវភាពយ៉ាងដូច្នោះ នៃសាសនាដទៃផង ។ សមដូចជាព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សមណៈ មានក្នុងសាសនានេះប៉ុណ្ណោះឯង ។បេ។ លទ្ធិដទៃ សូន្យចាកសមណៈទាំងឡាយដទៃ" [១] ដូច្នេះ ។ ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគត្រាស់ថា "ឥមស្មឹ សាសនេ ភិក្ខុ ភិក្ខុ ក្នុងសាសនានេះ" ដូច្នេះ ។

(ហេតុដែលត្រាស់អរញ្ញគតោ ។បេ។ ន័យទី១)

ពាក្យនេះ ថា "នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះ

១- សុ. អំ. ច. ភាគទី ៨៣ ទំព័រទី ២៨៥ ។

ស្ងាត់ក្តី" ជាគ្រឿងបំភ្លឺនូវការកំណត់នូវសេនាសនៈ មានសភាពដ៏សមគួរ ដល់ការចំរើននូវអានាបានស្សតិសមាធិ នៃព្រះយោគីភិក្ខុនោះ ។ ព្រោះថា ចិត្តនៃភិក្ខុនេះ ផ្សាយទៅរឿយៗ ក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម អស់កាលមានរាត្រីដ៏វែង មិនប្រាថ្នា ដើម្បីឡើងកាន់អារម្មណ៍ គឺអានាបានស្សតិសមាធិទេ រមែងស្ទុះទៅកាន់ផ្លូវខុសតែម្យ៉ាង ដូចរថដែលគេទឹម ដោយគោគៀច តែងស្ទុះទៅកាន់ផ្លូវខុសដូច្នោះដែរ ។ ព្រោះហេតុនោះ នាយគោបាល អ្នកប្រាថ្នាដើម្បីបង្ហាត់ នូវកូនគោគៀចដែលផឹកទឹកដោះស្រស់ទាំងអស់ នៃមេគោគៀច បានធំធាត់ឡើងហើយ បំបែកចេញអំពីមេគោ ដាំនូវសសរដ៏ធំ ក្នុងទីដ៏សមគួរមួយហើយ យកខ្សែចង ត្រង់សសរនោះ កាលបើមានប្រការដូច្នោះ កូនគោ នៃនាយគោបាលនោះ ក៏មិនអាចដើម្បីនឹងរើបម្រះ ទៅខាងនេះផង ខាងនុ៎ះផង ហើយរត់គេចទៅបានឡើយ គប្បីឈរជ្រប់ ឬ ដេកជ្រប់នៅត្រង់សសរធំនោះឯង មានឧបមាយ៉ាងណាមិញ សូម្បីភិក្ខុនេះឯង ប្រាថ្នាដើម្បីនឹងទូន្មានចិត្តដ៏កាច ដែលចំរើនដោយការផឹកនូវរសនៃអារម្មណ៍ មានរូបា-រម្មណ៍ជាដើម អស់កាលនៃរាត្រីដ៏វែង ក៏គប្បីនាំចេញអំពីអារម្មណ៍មានរូបារម្មណ៍ជាដើមហើយចូលទៅកាន់ព្រៃក្តី ។បេ។ កាន់ផ្ទះស្ងាត់ក្តីហើយ ចង ត្រង់សសរ គឺខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូលនោះ ដោយខ្សែគឺសតិ កាលបើចងបានដូច្នោះ ចិត្ត នៃភិក្ខុនោះ សូម្បីស្ទុះទៅខាងនេះផង ខាងនុ៎ះផង ក៏មិនបាននូវអារម្មណ៍ដែលខ្លួនសន្សំហើយ ក្នុងកាលមុន មិនអាចដើម្បីនឹងកាត់ផ្តាច់ខ្សែគឺសតិ ហើយរត់គេចបានឡើយ ក៏រមែងអែបនៅជ្រប់ និង ដេកនៅជ្រប់ជាប់នឹងអារម្មណ៍នោះឯង ដោយអំណាចនៃឧបចារៈ និង អប្បនា ក៏មានឧបមេយ្យយ៉ាងនោះឯង ។

ព្រោះហេតុនោះ ទើបបោរាណាចារ្យទាំងឡាយ ពោលថា :

> នរៈ កាលបង្ហាត់នូវកូនគោ គប្បីចង (វា) ត្រង់សសរ
> យ៉ាងណាមិញ ភិក្ខុ ក្នុងសាសនានេះ គប្បីចងនូវចិត្ត
> របស់ខ្លួន ឲ្យបានមាំក្នុងអារម្មណ៍ ដោយសតិ ក៏យ៉ាង
> ដូច្នោះដែរ ។

សេនាសនៈនោះ ជាទីសេនាសនៈដ៏សមគួរ ដល់ភាវនា នៃព្រះយោគីនោះ យ៉ាងនេះឯង ។ ព្រោះហេតុនោះ បានជាខ្ញុំ ពោលហើយថា "ពាក្យនេះ ជាគ្រឿងបំភ្លឺនូវការកំណត់នូវសេនាសនៈដ៏សមគួរ ដល់ការចំរើននូវអានាបានស្សតិសមាធិ នៃព្រះយោគាវចរនោះ" ។

(ហេតុដែលត្រាស់អរញ្ញគតោ *។បេ។* **ន័យទី២)**

ន័យមួយទៀត ព្រោះហេតុថា អានាបានស្សតិកម្មដ្ឋាននេះ ជាកំពូល ក្នុងប្រភេទនៃកម្មដ្ឋាន ជាបទដ្ឋាន នៃកិរិយាបាននូវគុណវិសេស និងកិរិយានៅជាសុខក្នុងបច្ចុប្បន្ន នៃព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង សាវក នៃព្រះពុទ្ធគ្រប់ព្រះអង្គ គឺព្រះយោគាវចរ មិនមែនធ្វើបានដោយងាយ ដើម្បីមិនលះបង់ នូវសេនាសនៈទីបំផុតនៃស្រុក ដែលវឹកវរ ដោយសំឡេង នៃស្ត្រី បុរស ដំរី និង សេះជាដើម ហើយចំរើនបានទេ ព្រោះភាពនៃឈានមានសំឡេងជាបន្លា តែថាក្នុងទីមិនមែនស្រុក គឺក្នុងព្រៃ ព្រះយោគាវចរ ធ្វើបានដោយងាយ ដើម្បីកាន់យកនូវកម្មដ្ឋាននេះ ហើយញ៉ាំងអានាបានចតុត្ថជ្ឈាន ឲ្យកើតឡើង ហើយធ្វើឈាននោះឯង ឲ្យជាជើង ពិចារណានូវសង្ខារទាំងឡាយ ហើយសម្រេច នូវព្រះអរហត្ត ជាផលដ៏កំពូល ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សំដែង

នូវសេនាសនៈដ៏សមគួរ ដល់ព្រះយោគាវចរនោះ ទើបទ្រង់ត្រាស់ថា "អរញ្ញគតោ វា" *ដូច្នេះជាដើម ។*

(ហេតុដែលត្រាស់អរញ្ញគតោ *។បេ។* **ន័យទី៣)**

មែនពិត ព្រះមានព្រះភាគ ប្រៀបដូចជាអាចារ្យ អ្នកចេះនូវភូមិ-សាស្ត្រ ។ អាចារ្យអ្នកចេះនូវភូមិសាស្ត្រនោះ ឃើញនូវទីនៃនគរហើយ ពិចារណា ដោយប្រពៃហើយ ចង្អុលប្រាប់ថា "ចូរអ្នកទាំងឡាយសាងនូវនគរ ក្នុងទីនេះ" ដូច្នេះ លុះដល់នគរបានសម្រេច ដោយសួស្តីហើយ ក៏បាននូវសក្ការៈដ៏ច្រើន អំពីរាជត្រកូល យ៉ាងណាមិញ ព្រះមានព្រះភាគអង្គនោះ ទ្រង់ពិចារណានូវទីសេនាសនៈដ៏សមគួរ ដល់ព្រះយោគា-វចរ ហើយទ្រង់ចង្អុលប្រាប់ថា "ព្រះយោគី គប្បីប្រកបកម្មដ្ឋានរឿយៗ ក្នុងទីសេនាសនៈនេះ" ដូច្នេះ តអំពីនោះទៅ កាលបើព្រះអរហត្តផល ដែលព្រះយោគីអ្នកប្រកបកម្មដ្ឋានរឿយៗ ក្នុងទីនោះ បានសម្រេចហើយ ដោយលំដាប់ រមែងទ្រង់បាននូវសក្ការៈដ៏ច្រើនថា "ព្រះមានព្រះភាគអង្គនោះ ជាព្រះសម្មាសម្ពុទ្ធ ពិតប្រាកដមែន" ក៏យ៉ាងដូច្នោះដែរ ។ ចំណែកភិក្ខុនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ប្រាកដស្មើដោយខ្លាដំបង" ។ បណ្ឌិតគប្បីជ្រាបអធិប្បាយថា "ដូចជាស្ដេចខ្លាដំបងដ៏ធំ ពួនអែបហើយនូវស្បាតស្មៅក្ដី ស្បាតព្រៃក្ដី ស្បាតភ្នំក្ដី ក្នុងព្រៃ ហើយចាប់ម្រឹគទាំងឡាយ មានក្របីព្រៃ រមាំង និង ជ្រូកព្រៃជាដើម យ៉ាងណាមិញ ភិក្ខុអ្នកប្រកបនូវកម្មដ្ឋានរឿយៗ ក្នុងទីសេនាសនៈដ៏សមគួរទាំងឡាយ មានព្រៃជាដើមនេះ រមែងចាប់យកនូវសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ និង អរហត្តមគ្គផង និង នូវអរិយផលផង តាមសមគួរតាមលំដាប់ យ៉ាងដូច្នោះដែរ" ។ ព្រោះហេតុនោះ បោរាណាចារ្យ ពោលថា

ធម្មតាខ្លាដំបង ពួនសម្ងំហើយ ចាប់យកនូវម្រឹគទាំងឡាយ យ៉ាងណាមិញ ភិក្ខុនេះ ជាបុត្រព្រះពុទ្ធ អ្នកមានសេចក្ដីព្យាយាមប្រកបហើយ ជាអ្នកឃើញច្បាស់ ចូលទៅកាន់ព្រៃហើយ តែងចាប់យក នូវផលដ៏ឧត្ដម ក៏យ៉ាងដូច្នោះដែរ ។

(១៦៥) ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សំដែងនូវទីសេនាសនៈក្នុងព្រៃ ដែលជាកន្លែងប្រកបសេចក្ដីព្យាយាម នៃបុគ្គលអ្នកមានព្យាយាម និង អ្នកមានសេចក្ដីស្មុះស្មារ ដល់ព្រះយោគីភិក្ខុនោះ ទើបទ្រង់ត្រាស់ថា “អរញ្ញគតោ វា” *ដូច្នេះជាដើម ។*

(កែអត្ថបទផ្សេងៗនៃបាឡីពាក្យឆ្លើយ)

បណ្ដាបទទាំងនោះ បទថា “អរញ្ញគតោ” *សេចក្ដីថា: ភិក្ខុ ទៅកាន់ព្រៃណាមួយ ដែលមានសេចក្ដីសុខ កើតអំពីវិវេក បណ្ដាព្រៃទាំងឡាយ មានលក្ខណៈដែលលោកពោលមកហើយ យ៉ាងនេះថា “ឈ្មោះថា ព្រៃ បានដល់ព្រៃទាំងអស់នោះ ចេញទៅខាងក្រៅអំពីសសរគោល” ដូច្នេះក្ដី ថា “សេនាសនៈ មានក្នុងទីបំផុត ប្រវែង ៥០០ ធ្នូ ឈ្មោះថា សេនាសនៈ តាំងនៅក្នុងព្រៃ” ដូច្នេះក្ដី ។ បទថា* “រុក្ខមូលគតោ” *គឺភិក្ខុទៅកាន់ទីជិតនៃគល់ឈើ ។ បទថា* “សុញ្ញាគារគតោ” *គឺទៅកាន់ឱកាសដែលសូន្យ គឺឱកាសដែលស្ងាត់ ។ ក៏ក្នុងបាឡីថា* “សុញ្ញាគារគតោ” *នេះ លើកទុកនូវព្រៃ និង គល់ឈើចេញ ភិក្ខុសូម្បីទៅកាន់សេនាសនៈដ៏សេស មាន ៧ ប្រការ ។ ការពោលថា* “សុញ្ញាគារគតោ” *ក៏គួរ ។*

ព្រះមានព្រះភាគ កាលទ្រង់ចង្អុលប្រាប់នូវសេនាសនៈដ៏សមគួរ

ដល់ការចំរើននូវអានាបានស្សតិ ដ៏សមគួរដល់រដូវផង ដ៏សមគួរ ដល់ធាតុ និង ចរិយាផង យ៉ាងនេះហើយ ទ្រង់សំដែងប្រាប់នូវឥរិយាបថ ដ៏ស្ងប់ ដែលប្រព្រឹត្តទៅក្នុងពួក នៃការមិនរួញរា និង ការមិនអណ្ដែតអណ្ដូង ដល់ព្រះយោគីភិក្ខុនោះ ទើបទ្រង់ត្រាស់ថា “និសីទតិ អង្គុយ” *ដូច្នេះ ។ ក្នុងលំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សំដែង នូវភាពនៃការអង្គុយនឹងធឹងផង នូវភាពនៃការប្រព្រឹត្តិទៅស្រួល នៃខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល និង នូវឧបាយគ្រឿងកំណត់ នូវអារម្មណ៍ផង ទើបទ្រង់ត្រាស់ថា* “បល្លង្កំ អាភុជិត្វា ពែនភ្នែន” *ដូច្នេះជាដើម ។*

បណ្ដាបទទាំងនោះ បទថា “បល្លង្កំ” *គឺអង្គុយបត់នូវភ្លៅ ដោយជុំវិញ ។ បទថា* “អាភុជិត្វា” *គឺបត់ចូលហើយ ។ ច្រើនបទថា* “ឧជុំ កាយំ បណិធាយ” *សេចក្ដីថា: តាំងសរីរៈខាងលើឲ្យត្រង់ហើយ ញ៉ាំងចុង ដោយចុង ឲ្យរៀបរយ ត្រង់ទ្រនុងនៃខ្នង ១៨ ។ ព្រោះថា កាលបើព្រះយោគី អង្គុយយ៉ាងនេះ ស្បែក សាច់ និង សរសៃទាំងឡាយ នឹងមិនប្រយឹតចុះ កាលបើមានប្រការដូច្នោះ វេទនាទាំងឡាយណា គប្បីកើតឡើង រាល់ៗ ខណៈ ព្រោះការប្រយឹតចុះ នៃស្បែក សាច់ និង សរសៃទាំងឡាយនោះជាបច្ច័យ វេទនាទាំងឡាយនោះ រមែងមិនកើតឡើង ដល់ព្រះយោគីនោះ កាលបើវេទនាទាំងឡាយនោះ មិនកើតឡើង ចិត្ត ក៏ជាធម្មជាតមានអារម្មណ៍តែមួយ កម្មដ្ឋាន មិនថ្ងោះថ្ងោយ ចូលដល់សេចក្ដីចំរើន សេចក្ដីលូតលាស់ ។ ច្រើនបទថា* “បរិមុខំ សតឹ ឧបដ្ឋបេត្វា” *ប្រែថា តាំងសតិ ឲ្យមានមុខឆ្ពោះទៅកាន់កម្មដ្ឋាន ។ ន័យមួយទៀត ត្រង់បទថា* “បរិមុខំ សតឹ” *នេះ បណ្ឌិត គប្បីជ្រាបសេចក្ដីអធិប្បាយ តាមន័យដែលព្រះសារីបុត្រ ពោលហើយ ក្នុងបដិសម្ភិទា*

យ៉ាងនេះថា: ត្រង់ពាក្យថា "បរិ" មានអត្ថថា កំណត់ ត្រង់ពាក្យថា "មុខំ" មានអត្ថថា ធម៌ជាគ្រឿងនាំចេញ ត្រង់បទថា "សតិ" មានអត្ថថា ប្រុងប្រយ័ត្ន ព្រោះហេតុនោះ ទើបលោកពោលថា "តាំងសតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) [១] " ដូច្នេះ ។ នេះគឺជាសេចក្ដីសង្ខេប ក្នុងបដិសម្ភិទានោះ ថា "ព្រះយោគី ធ្វើសតិ ឲ្យមានការនាំចេញ ចាកធម៌ដែលជាសត្រូវ ដែលខ្លួនកំណត់ហើយ" ដូច្នេះ ។

(សតោវការី)

ពាក្យថា "ភិក្ខុនោះ មានសតិ ដកដង្ហើមចេញ" សេចក្ដីថា ភិក្ខុនោះ អង្គុយយ៉ាងនេះហើយ និង តាំងតម្កល់សតិយ៉ាងនេះហើយ កាលមិនលះបង់នូវសតិនោះ ឈ្មោះថា មានស្មារតី ដកដង្ហើមចេញហ្នឹងឯង មានស្មារតី ដកដង្ហើមចូល ។ អធិប្បាយថា ភិក្ខុអ្នកធ្វើនូវសតិ ។

ឥឡូវនេះ ព្រះយោគីភិក្ខុ ជាអ្នកធ្វើនូវសតិ ដោយអាការៈទាំងឡាយណា ដើម្បីទ្រង់សំដែងនូវអាការៈទាំងឡាយនោះ ទើបទ្រង់ត្រាស់ថា "ទីឃំ វា អស្សសន្តោ" ដូច្នេះជាដើម ។ មែនពិត ក្នុងបដិសម្ភិទា ក្នុងវិភង្គនៃបាឡីនោះឯងថា "ភិក្ខុនោះ មានស្មារតី ដកដង្ហើមចេញ មានស្មារតីដកដង្ហើមចូល" ក៏លោកពោលពាក្យនេះ ថា "ព្រះយោគី ជាអ្នកធ្វើសតិ ដោយអាការៈ ៣២ គឺកាលព្រះយោគី ដឹងច្បាស់នូវភាព នៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាយនៃដង្ហើមចេញវែង សតិក៏តម្កល់នៅមាំ ព្រះយោគីនោះ ធ្វើនូវសតិ ដោយស្មារតីនោះ ដោយញាណនោះ កាលព្រះយោគី ដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាយនៃដង្ហើមចូលវែង សតិ ក៏តម្កល់នៅ

១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ១១៩-១២០ ។

មាំ ព្រះយោគីនោះ ជាអ្នកធ្វើនូវសតិ ដោយស្មារតីនោះ ដោយញាណនោះ ។ល។ កាលព្រះយោគី ដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ សម្រាប់អ្នកពិចារណា ឃើញនូវធម៌ជាគ្រឿងរលាស់ចេញចាកកិលេស ដោយអំណាចនៃដង្ហើមចូល សម្រាប់អ្នកពិចារណាឃើញនូវធម៌ជាគ្រឿងរលាស់ចេញចាកកិលេស សតិ ក៏តម្កល់នៅមាំ ព្រះយោគីនោះ ជាអ្នកធ្វើនូវសតិ ដោយស្មារតីនោះ ដោយញាណនោះ" ដូច្នេះ ។

(កែសំព្វអស្សាសបស្សាសៈ)

បណ្ដាបាឡីទាំងនោះ បាឡីថា "ទីឃំ វា អស្សសន្តោ" គឺញុំាងខ្យល់ដកដង្ហើមចេញវែង ឲ្យប្រព្រឹត្តទៅក្តី ។ ក្នុងអដ្ឋកថាព្រះវិន័យ ក៏លោកពោលថា "ខ្យល់ចេញទៅខាងក្រៅ ឈ្មោះថា អស្សាសៈ ខ្យល់ចូលទៅខាងក្នុង ឈ្មោះថា បស្សាសៈ" ។ តែក្នុងអដ្ឋកថាព្រះសូត្រទាំងឡាយ មកហើយផ្ទុយគ្នា (នឹងអដ្ឋកថាព្រះវិន័យ) ។ បណ្ដាខ្យល់ទាំងពីរនោះ ក្នុងពេលដែលសត្វទាំងឡាយទាំងពួង អ្នកដេកនៅក្នុងគភ៌ ចេញមកអំពីផ្ទៃនៃមាតា ខ្យល់ដ៏ខាងក្នុង ចេញមកខាងក្រៅ មុនគេ ខ្យល់ខាងក្រៅ នាំយកនូវធូលីដ៏ល្អិត ចូលទៅខាងក្នុង ជាខាងក្រោយ លុះដល់ក្រអូមមាត់ ក៏រលត់ទៅ ។ បណ្ឌិតគប្បីជ្រាបខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូល យ៉ាងដូច្នេះ មុន ។

ចំណែកភាពវែង និង ខ្លី នៃខ្យល់ទាំង ២ នោះឯណា ភាពវែង និង ខ្លី នោះ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃអទ្ធានៈ (រយៈពេល) ។ ប្រៀបដូចជា ទឹក ឬ ដីខ្សាច់ ដែលផ្សាយទៅ រហូតអទ្ធានៈ គឺឱកាស (វែង ឬ ខ្លី) ហើយឋិតនៅ លោកហៅថា ទឹកវែង ដីខ្សាច់វែង ទឹកខ្លី

ដីខ្សាច់ខ្ទី យ៉ាងណាមិញ ខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូល សូម្បីដែលល្អិតយ៉ាងក្រៃលែង ញ៉ាំងអទ្ធានៈ (គឺរយៈពេល) វែង ក្នុងរាងកាយនៃដំរី និង ក្នុងរាងកាយនៃពស់ ពោលគឺអត្តភាព នៃដំរី និង ពស់ទាំងពីរនោះ ឲ្យពេញជាសន្សឹមៗ ហើយចេញទៅ ក៏សន្សឹមៗ ដែរ ព្រោះហេតុនោះ ទើបលោកពោលថា ខ្យល់ដកដង្ហើម (នៃដំរី និង ពស់) វែង ។ ខ្យល់នោះ ញ៉ាំងអទ្ធានៈ (គឺរយៈពេល) ខ្លី ពោលគឺអត្តភាព នៃសត្វទាំងឡាយ មានឆ្កែ និង ទន្សាយជាដើម ឲ្យពេញ យ៉ាងឆាប់រហ័ស ហើយចេញមក ក៏ឆាប់រហ័សផងដែរ ព្រោះហេតុនោះ ទើបលោកពោលថា ខ្យល់ដកដង្ហើម (នៃឆ្កែ និង ទន្សាយ) ខ្លី ។ ចំណែកក្នុងពួកមនុស្ស ដោយអំណាចនៃអទ្ធានៈគឺកាល មនុស្សទាំងឡាយខ្លះ ដកដង្ហើមចេញ និង ដកដង្ហើមចូលវែង ដូចជាសត្វទាំងឡាយ មានដំរី និង ពស់ជាដើម មនុស្សពួកខ្លះ ដកដង្ហើមចេញ និង ដកដង្ហើមចូលខ្លី ដូចជាសត្វតូចៗ ទាំងឡាយមានឆ្កែ និង ទន្សាយជាដើម ព្រោះហេតុនោះ ខ្យល់ដកដង្ហើម នៃមនុស្សទាំងឡាយនុ៎ះ កាលចេញក្តី កាលចូលក្តី អស់រយៈពេលវែង ក៏គប្បីជ្រាបថា វែង, កាលចេញក្តី កាលចូលក្តី អស់រយៈពេលខ្លី ក៏គប្បីជ្រាបថា ខ្លី ដោយអំណាចនៃកាល ក៏យ៉ាងនោះដែរ ។

(អានាបានស្សតិជាកាយានុបស្សនាសតិបដ្ឋាន)

ក្នុងកិរិយាដកដង្ហើមចេញ និង ដកដង្ហើមចូល វែង និង ខ្លីនោះ ភិក្ខុនេះ កាលដកដង្ហើមចេញ និង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា “អាត្មាអញ ដកដង្ហើមចេញ ដកដង្ហើមចូលវែង” ដោយអាការៈទាំងឡាយ ៩ ។ ក៏កាលបើភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា “ការចំរើនកាយានុបស្សនាសតិបដ្ឋាន រមែងសម្រេច ដោយអាការៈ

មួយ ។ ដូចជាលោកពោលហើយ ក្នុងបដិសម្ភិទា ថា : សួរថា “ភិក្ខុ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង តើដូចម្តេច” ។

ឆ្លើយថា “ (១) ភិក្ខុ ដកចេញ នូវដង្ហើមចេញវែង ក្នុងចំណែក នៃកាលវែង (២) ដកចូល នូវដង្ហើមចូលវែង ក្នុងចំណែក នៃកាលវែង (៣) ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬ ដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង ។

កាលភិក្ខុ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬ ដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង (ច្រើនដង) ឆន្ទៈ (ចំណង់ក្នុងអ្វីមួយ) រមែងកើតឡើង (៤) ភិក្ខុដកចេញ នូវដង្ហើមចេញវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ (៥) ដកចូល នូវដង្ហើមចូលវែង ដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ (៦) ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬ ដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ ។

កាលភិក្ខុ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬ ដង្ហើមចូល វែងដ៏ក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ (ច្រើនដង) បាមុជ្ជៈ (សេចក្តីរីករាយ) រមែងកើតឡើង (៧) ភិក្ខុ ដកចេញនូវដង្ហើមចេញវែងដ៏ល្អិតជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជៈ (៨) ដកចូល នូវដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជៈ (៩) ដកចេញក្តី

ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែងដ៏ល្អិតជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជៈ (សេចក្តីរីករាយ) ។

កាលភិក្ខុ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬ ដង្ហើមចូលវែង ដ៏ក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាច នៃសេចក្តីរីករាយ (ច្រើនដង) ចិត្ត ក៏ឃ្លាតចេញអំពីដង្ហើមចេញ ឬ ដង្ហើមចូលវែង ឧបេក្ខា ក៏តាំងនៅស៊ប់ ។

នេះ កាយគឺដង្ហើមចេញ និង ដង្ហើមចូលវែង ដោយអាការៈ ៩ យ៉ាង ដែលឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ កាយ ឈ្មោះថា ឧបដ្ឋាន មិនមែនឈ្មោះថា សតិ ទេ សតិ ឈ្មោះថា ឧបដ្ឋានផង ឈ្មោះថាសតិផង ភិក្ខុពិចារណាឃើញនូវកាយនោះ ដោយសតិនោះផង ដោយញាណនោះផង ព្រោះហេតុនោះ ទើបលោកពោលថា "កាយេ កាយានុបស្សនា សតិប្បដ្ឋានភាវនា (ការចំរើនសតិបដ្ឋាន គឺការពិចារណាឃើញ នូវកាយ ក្នុងកាយ) [១] " ដូច្នេះ ។

ន័យសូម្បីក្នុងបទគឺខ្យល់ដង្ហើមខ្លី ក៏ន័យដូចគ្នានេះដែរ ។ ប៉ុន្តែនេះ ជាសេចក្តីប្លែកគ្នា ។ ពាក្យថា "ទីឃំ អស្សាសំ អទ្ធានសង្ខាតេ ខ្យល់ដង្ហើមចេញវែង ក្នុងចំណែកនៃកាលវែង" ដែលលោកបានពោលហើយ ក្នុងបទគឺខ្យល់ដង្ហើមវែងនុ៎ះ យ៉ាងណាមិញ ក្នុងបទគឺខ្យល់ដង្ហើមខ្លីនេះ មកហើយថា "រស្សំ អស្សាសំ ឥត្តរសង្ខាតេ អស្សសតិ ភិក្ខុដកចេញ នូវដង្ហើមចេញខ្លី ក្នុងចំណែកនៃកាលខ្លី" ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ បណ្ឌិតគប្បីប្រកបពាក្យ ដោយអំណាចនៃរស្សសព្ទ រហូតដល់ពាក្យ ថា "តេន វុច្ចតិ កាយេ កាយានុបស្សនា សតិប្បដ្ឋានភាវនា

១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ១២១ ។

ព្រោះហេតុនោះ ទើបលោកពោលថា ការចំរើនសតិបដ្ឋាន គឺការពិចារណាឃើញច្បាស់នូវកាយ ក្នុងកាយ" ដូច្នេះ ។

ភិក្ខុនេះ កាលដឹងច្បាស់ នូវដង្ហើមចេញ និង ដង្ហើមចូល ដោយអាការៈទាំងឡាយ ៩ នេះ ដោយអំណាចនៃកាលវែង និង ដោយអំណាចនៃកាលខ្លី យ៉ាងដូច្នេះ បណ្ឌិតគប្បីជ្រាបថា "ភិក្ខុនោះ ឈ្មោះថា កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ឬ កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី" ដូច្នេះឯង ។ ក៏កាលបើភិក្ខុនោះ ដឹងច្បាស់ យ៉ាងដូច្នេះ

ខ្យល់ ៤ យ៉ាង គឺខ្យល់ដង្ហើមចេញវែង និង ខ្លី សូម្បី
ខ្យល់ដង្ហើមចូល ក៏យ៉ាងដូច្នោះដែរ រមែងប្រព្រឹត្តទៅ
ត្រង់ចុងច្រមុះ នៃភិក្ខុនោះឯង ។

(កែសព្វកាយប្បដិសំវេទី)

(១៦៦) ពាក្យថា "ភិក្ខុនោះ សិក្សាថា អាត្មាអញ កំណត់ដឹងនូវកាយ គឺដង្ហើមចេញទាំងពួង ទើបដកដង្ហើមចេញ... ដកដង្ហើមចូល" នោះ គឺភិក្ខុនោះ សិក្សាថា "អាត្មាអញ កាលធ្វើនូវខាងដើម កណ្តាល និង ចុង នៃកាយ គឺដង្ហើមចេញទាំងអស់ ឲ្យជារបស់ដែលខ្លួនបានដឹង គឺធ្វើ (ដង្ហើមនោះ) ឲ្យបានប្រាកដច្បាស់ ទើបដកដង្ហើមចេញ" ។ សិក្សាថា "អាត្មាអញ កាលធ្វើនូវខាងដើម កណ្តាល និង ចុង នៃកាយ គឺដង្ហើមចូលទាំងអស់ ឲ្យជារបស់ដែលខ្លួនបានដឹង គឺធ្វើ (ដង្ហើមនោះ) ឲ្យបានប្រាកដច្បាស់ ទើបដកដង្ហើមចូល" ។ ភិក្ខុនោះកាលធ្វើ (ដង្ហើមនោះ) ឲ្យជារបស់ដែលខ្លួនបានដឹង គឺធ្វើឲ្យបានប្រាកដច្បាស់ យ៉ាងនេះ

ក៏ឈ្មោះថា ដកដង្ហើមចេញ និង ដកដង្ហើមចូល ដោយចិត្តដែលប្រកបព្រមដោយញាណ ។ ព្រោះហេតុនោះ ទើបលោកពោលថា "ភិក្ខុនោះសិក្សាថា អាត្មាអញ ដកដង្ហើមចេញ ដកដង្ហើមចូល" ដូច្នេះជាដើម ។

មែនពិត សម្រាប់ភិក្ខុអង្គខ្លះ ខាងដើម ក្នុងកាយ គឺដង្ហើមចេញក្តី ក្នុងកាយ គឺដង្ហើមចូលក្តី ដែលស្ទុះទៅយ៉ាងល្អិត រមែងប្រាកដ ត្រង់កណ្តាល និង ខាងចុង មិនប្រាកដទេ ។ ភិក្ខុនោះ អាចកំណត់តែខ្យល់ខាងដើមប៉ុណ្ណោះ តែងលំបាក ត្រង់ខ្យល់កណ្តាលនិងខាងចុង ។ សំរាប់ភិក្ខុអង្គខ្លះ ប្រាកដ ត្រង់កណ្តាល ប៉ុន្តែខាងដើម និង ចុង មិនប្រាកដ ។ សំរាប់ភិក្ខុអង្គខ្លះ ខាងចុង ប្រាកដ ប៉ុន្តែ ខាងដើម និង កណ្តាល មិនប្រាកដទេ ។ ភិក្ខុនោះ អាចកំណត់ នូវខ្យល់ខាងចុងតែប៉ុណ្ណោះ តែងលំបាក ត្រង់ខ្យល់ខាងដើម និង កណ្តាល ។ សំរាប់ភិក្ខុអង្គខ្លះ ប្រាកដគ្រប់ខ្យល់ទាំងអស់ ភិក្ខុនោះ អាចកំណត់បានទាំងអស់ មិនលំបាក ត្រង់ខ្យល់ណាមួយឡើយ ។ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងថា "ព្រះយោគី គប្បីជាអ្នកប្រាកដដូច្នោះ" ទើបទ្រង់ត្រាស់ ថា "ភិក្ខុ សិក្សាថា អាត្មាអញ ជាអ្នកកំណត់ដឹងនូវកាយ គឺដង្ហើមចេញទាំងពួង ទើបដកដង្ហើមចេញ ។ល។ ទើបដកដង្ហើមចូល" ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា "សិក្សា" គឺ ប្រឹងប្រែង ព្យាយាមយ៉ាងនេះ ។ម្យ៉ាងទៀត សេចក្តីអធិប្បាយ ក្នុងបទនេះ បណ្ឌិតគប្បីជ្រាបថា "សេចក្តីសង្រួមឯណា នៃភិក្ខុអ្នកប្រាកដដូច្នោះ សេចក្តីសង្រួមនេះ ជាអធិសីលសិក្ខា ក្នុងបទនេះ សមាធិឯណា នៃភិក្ខុអ្នកប្រាជដូច្នោះ សមាធិនេះ ជាអធិចិត្តសិក្ខា ក្នុងបទនេះ បញ្ញាឯណា នៃភិក្ខុអ្នកប្រាកដដូច្នោះ បញ្ញានេះ ជាអធិបញ្ញាសិក្ខា ក្នុងបទនេះ ភិក្ខុសិក្សា គឺ សេព

ចំរើន ធ្វើឲ្យច្រើន នូវសិក្ខាទាំង ៣ នោះ ដូចពោលមកហើយនេះ ក្នុងអារម្មណ៍នោះ ដោយសតិនោះ ដោយការធ្វើទុកក្នុងចិត្តនោះ" ដូច្នេះ ។

ក្នុងចតុក្កៈទី១ នោះ ក្នុងន័យមុន ព្រះយោគីគប្បីដកដង្ហើមចេញ ដកដង្ហើមចូល តែម្យ៉ាងប៉ុណ្ណោះ និង មិនគួរធ្វើកិច្ចអ្វីៗ ទេ តែថា ចាប់ដើមអំពីនេះទៅ គប្បីធ្វើសេចក្តីព្យាយាម ក្នុងអាការៈទាំងឡាយ មានការញុំាងញាណ ឲ្យកើតឡើងជាដើម ព្រោះហេតុណា ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា "ព្រះមានព្រះភាគ ទ្រង់ត្រាស់បាឡី ដោយអំណាចនៃបច្ចុប្បន្នកាល ថា អស្សសាមីតិ បជានាតិ បស្សសាមីតិ បជានាតិ ភិក្ខុដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញ ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូល ដូច្នេះ ក្នុងន័យមុននោះ ហើយទើបទ្រង់លើកយកបាឡីមក ដោយអំណាចនៃពាក្យជាអនាគតកាល ដោយន័យមានជាដើម ថា សព្វកាយប្បដិសំវេទី អស្សសិស្សាមិ អាត្មាអញ ជាអ្នកកំណត់ដឹងនូវកាយ គឺដង្ហើមចេញទាំងពួង នឹងដកដង្ហើមចេញ ដូច្នេះ ដើម្បីសំដែងនូវអាការៈមានការញុំាងញាណ ឲ្យកើតឡើងជាដើម ដែលគប្បីធ្វើ ចាប់ដើមអំពីន័យមុននេះទៅ" ដូច្នេះឯង ។

(គែបស្សម្ភយំ កាយសង្ខារំ)

ពាក្យថា "ភិក្ខុសិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ ។ល។ ទើបដកដង្ហើមចូល" នោះ គឺភិក្ខុសិក្សាថា "អាត្មាអញ កាលរម្ងាប់ ពន្ធត់ រំលត់ បង្ក្រាបកាយសង្ខារ (ពួកខ្យល់ដង្ហើមវែងខ្លីដែលប្រព្រឹត្តទៅក្នុងកាយ) ដែលគ្រោតគ្រាត ទើបដកដង្ហើមចេញ ដកដង្ហើមចូល" ដូច្នេះ ។

ក្នុងរឿងនេះ ភាពគ្រោតគ្រាត និង ភាពល្អិតក្តី សេចក្តីស្ងប់ក្តី

បណ្ឌិតគប្បីជ្រាប ដូចតទៅនេះ : ក៏កាយ និង ចិត្ត របស់ភិក្ខុនេះ ក្នុងកាលមុន ពេលដែលមិនទាន់បានកំណត់ (នូវអានាបានស្សតិកម្មដ្ឋាននោះ) ជាកាយចិត្ត មានសេចក្ដីក្រវល់ក្រវាយ គ្រោតគ្រាត ។ កាលបើភាពគ្រោតគ្រាត នៃកាយ និង ចិត្ត មិនទាន់ស្ងប់រម្ងាប់ សូម្បីខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូល ក៏គ្រោតគ្រាត ប្រព្រឹត្តទៅ មានកំឡាំងខ្លាំងក្លា ប្រមុះ មិនគ្រប់គ្រាន់ ឈរ ដកដង្ហើមចេញខ្លះ ដកដង្ហើមចូលខ្លះ តាមមាត់ ។ ក៏ក្នុងពេលណា ទាំងកាយ ទាំងចិត្ត របស់ភិក្ខុនោះ គឺខ្លួនបានកំណត់ហើយ ក្នុងពេលនោះ កាយ និង ចិត្តនោះ ក៏ជាធម្មជាតស្ងប់រម្ងាប់ហើយ ។ កាលបើកាយ និង ចិត្តទាំងនោះ ស្ងប់រម្ងាប់ហើយ ខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូល ជាខ្យល់ដ៏ល្អិត រមែងប្រព្រឹត្តទៅ ជាខ្យល់ដល់នូវអាការៈ ដែលគួរពិចារណាថា "មាន ឬ មិនមានហ្ន៎?" ។ ដូចជាខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូល នៃបុគ្គលដែលរត់ចុះមកអំពីភ្នំ ឬ ទម្លាក់ភារៈដ៏ធ្ងន់ចេញអំពីក្បាល ហើយឈរ ជាខ្យល់គ្រោតគ្រាត ប្រមុះ មិនគ្រប់គ្រាន់ ក៏ឈរ ដកដង្ហើមចេញខ្លះ ដកដង្ហើមចូលខ្លះ តាមមាត់ ។ ក៏ក្នុងពេលណា បុគ្គលនោះ បន្ទោបង់ នូវសេចក្ដីនឿយហត់នោះហើយ ងូតទឹក និង ផឹកទឹកហើយ ដាក់សំពត់ទទឹកលើបេះដូង ហើយដេកនៅក្រោមម្លប់ដ៏ត្រជាក់ ក្នុងពេលនោះ ខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូលទាំងនោះ នៃបុគ្គលនោះ ជាខ្យល់ដ៏ល្អិត ដល់នូវអាការៈ គួរពិចារណាថា "មាន ឬ មិនមានហ្ន៎?" ដូច្នេះ យ៉ាងណាមិញ ក្នុងកាលមុន ពេលដែលមិនទាន់បានកំណត់ (នូវអានាបានស្សតិកម្មដ្ឋាននោះ) កាយ និង ចិត្ត នៃភិក្ខុនេះ ។ល។ ជាកាយដល់នូវអាការៈគួរពិចារណាថា "មាន ឬ មិនមានហ្ន៎" ក៏យ៉ាងនោះដែរ ។

សួរថា "ដំណើរនោះ ព្រោះហេតុអ្វី?" ។ ឆ្លើយថា "ព្រោះសេចក្ដីពិតថា ក្នុងកាលមុន ពេលដែលមិនទាន់បានកំណត់ (នូវកម្មដ្ឋាននោះ) ការរំពឹងគិត ការប្រមូលចិត្ត ការធ្វើទុកក្នុងចិត្ត ការពិចារណា ថា "អាត្មាអញរម្ងាប់នូវកាយសង្ខារ ដែលគ្រោតគ្រាតៗ" ដូច្នេះ មិនមាន ដល់ភិក្ខុនោះ តែក្នុងពេលដែលបានកំណត់ (នូវកម្មដ្ឋាននោះ) ហើយ ទើបមាន ព្រោះហេតុនោះ កាយសង្ខារ នៃភិក្ខុនោះ ក្នុងពេលដែលបានកំណត់ (នូវកម្មដ្ឋាន) ហើយ រមែងល្អិតជាងពេលដែលមិនទាន់បានកំណត់ហើយ ។ ព្រោះហេតុនោះ បានជាបោរាណាចារ្យទាំងឡាយ ពោលថា :

> ក៏កាលបើកាយ និង ចិត្ត ក្រវល់ក្រវាយហើយ កាយ-សង្ខារ ក៏រមែងប្រព្រឹត្តទៅគ្រោតគ្រាតដែរ កាលបើកាយ និង ចិត្ត មិនក្រវល់ក្រវាលហើយ កាយសង្ខាររមែងប្រព្រឹត្តទៅ យ៉ាងល្អិត ។

(ន័យផ្លូវសមថៈ)

សូម្បីក្នុងពេលដែលបានកំណត់ (កម្មដ្ឋាន) កាយសង្ខារ ក៏រាប់ថា នៅគ្រោតគ្រាត ក្នុងឧបចារៈ នៃបឋមជ្ឈាន ទើបល្អិត សូម្បីក្នុងឧបចារៈ នៃបឋមជ្ឈាននោះ ក៏រាប់ថា នៅគ្រោតគ្រាត ក្នុងបឋមជ្ឈាន ទើបល្អិត ក្នុងបឋមជ្ឈាន និង ក្នុងឧបចារៈនៃទុតិយជ្ឈាន ក៏រាប់ថា នៅគ្រោតគ្រាត ក្នុងទុតិយជ្ឈាន ទើបល្អិត ក្នុងទុតិយជ្ឈាន និង ក្នុងឧប-ចារៈនៃតតិយជ្ឈាន ក៏រាប់ថា នៅគ្រោតគ្រាត ក្នុងតតិយជ្ឈាន ទើបល្អិត ក្នុងតតិយជ្ឈាន និង ក្នុងឧបចារៈនៃចតុត្ថជ្ឈាន ក៏រាប់ថា នៅគ្រោតគ្រាត ក្នុងចតុត្ថជ្ឈាន ល្អិតក្រៃលែង ដល់នូវការប្រព្រឹត្តិទៅមិនបានមែនពិត" ។

ពាក្យដែលបានពោលមកនេះ ជាមតិ នៃព្រះទីឃភាណកៈ (អ្នកពោលគម្ពីរទីឃនិកាយ) និង ព្រះសំយុត្តភាណកៈ (អ្នកពោលគម្ពីរសំយុត្តនិកាយ) ។ តែព្រះមជ្ឈិមភាណកៈ (អ្នកពោលគម្ពីរមជ្ឈិមនិកាយ) ទាំងឡាយ តែងប្រាថ្នា សូម្បីក្នុងឧបចារៈ នៃឈានថ្នាក់ខ្ពស់ៗ ថា ល្អិតក្រៃលែងជាងឈានថ្នាក់ក្រោមៗ យ៉ាងនេះថា "ក្នុងបឋមជ្ឈាន កាយសង្ខារ រាប់ថា នៅគ្រោតគ្រាត ក្នុងឧបចារៈ នៃទុតិយជ្ឈាន ទើបល្អិត" ដូច្នេះ ។ ប៉ុន្តែបើតាមមតិ នៃអាចារ្យទាំងឡាយទាំងពួងហ្នឹងឯង បានសេចក្តីថា "កាយសង្ខារ ដែលប្រព្រឹត្តទៅ ក្នុងកាលដែលមិនបានកំណត់ (កម្មដ្ឋាន) រមែងស្ងប់រម្ងាប់ ក្នុងកាលដែលបានកំណត់ (នូវកម្មដ្ឋាន) កាយសង្ខារ ដែលប្រព្រឹត្តទៅ ក្នុងកាលដែលបានកំណត់ (នូវកម្មដ្ឋាន) រមែងស្ងប់រម្ងាប់ ក្នុងឧបចារៈ នៃបឋមជ្ឈាន ។ល។ កាយសង្ខារ ដែលប្រព្រឹត្តទៅ ក្នុងឧបចារៈនៃចតុត្ថជ្ឈាន រមែងស្ងប់រម្ងាប់ ក្នុងចតុត្ថជ្ឈាន" ។ នេះ ជាន័យ ក្នុងសមថៈ មុន ។

(ន័យផ្លូវវិបស្សនា)

(១៦៧) ចំណែកក្នុងវិបស្សនា កាយសង្ខារ ដែលប្រព្រឹត្តទៅហើយ ក្នុងកិរិយាកំណត់ ក៏នៅគ្រោតគ្រាត ក្នុងកិរិយាកំណត់នូវមហាភូតរូប ទើបល្អិត សូម្បីកាយសង្ខារ ដែលប្រព្រឹត្តទៅ ក្នុងកិរិយាកំណត់នូវមហាភូតរូបនោះសោត ក៏រាប់ថា នៅគ្រោតគ្រាត ។ កាយសង្ខារ ក្នុងការកំណត់នូវឧបាទាយរូប ទើបល្អិត កាយសង្ខារ ក្នុងកិរិយាកំណត់ នូវឧបាទាយរូបនោះសោត ក៏រាប់ថា នៅគ្រោតគ្រាត ។ កាយសង្ខារ ក្នុងកិរិយាកំណត់ នូវរូបទាំងមូល ទើបល្អិត កាយសង្ខារ ក្នុងកិរិយាកំណត់នូវរូបទាំងមូលនោះសោត ក៏រាប់ថានៅគ្រោតគ្រាត ។ កាយសង្ខារ ក្នុង

កិរិយាកំណត់នូវអរូប ទើបល្អិត កាយសង្ខារ ក្នុងកិរិយាកំណត់ នូវអរូបនោះសោត ក៏រាប់ថា នៅគ្រោតគ្រាត ។ កាយសង្ខារ ក្នុងកិរិយាកំណត់នូវរូប និង អរូប ទើបល្អិត កាយសង្ខារ ក្នុងកិរិយាកំណត់ នូវរូប និង អរូបនោះសោត ក៏រាប់ថា នៅគ្រោតគ្រាត ។ កាយសង្ខារ ក្នុងកិរិយាកំណត់ នូវបច្ច័យ ទើបល្អិត កាយសង្ខារ ក្នុងកិរិយាកំណត់ នូវបច្ច័យនោះសោត ក៏រាប់ថា នៅគ្រោតគ្រាត ។ កាយសង្ខារ ក្នុងកិរិយាឃើញនូវនាមរូប ព្រមទាំងបច្ច័យ ទើបល្អិត កាយសង្ខារ ក្នុងកិរិយាឃើញនូវនាមរូប ព្រមទាំងបច្ច័យនោះសោត ក៏រាប់ថា នៅគ្រោតគ្រារត ។ កាយសង្ខារ ក្នុងវិបស្សនាដែលមាន(ត្រៃ)លក្ខណ៍ជាអារម្មណ៍ទើបល្អិត។ កាយសង្ខារ ក្នុងវិបស្សនា ដែលមានកំឡាំងខ្សោយ ក៏រាប់ថា នៅគ្រោតគ្រាត ក្នុងវិបស្សនា ដែលមានកំឡាំង ទើបល្អិត ។

ក្នុងវិបស្សនានោះ សេចក្តីរម្ងាប់ នៃកាយសង្ខារ ដែលមានក្នុងមុនៗ ដោយកាយសង្ខារ ដែលមានខាងចុងៗ បណ្ឌិតគប្បីជ្រាប តាមន័យដែលលោកពោលហើយ ក្នុងកាលមុនហ្នឹងឯង ។

សេចក្តីគ្រោតគ្រាត និង សេចក្តីល្អិតក្តី និង សេចក្តីស្ងប់រម្ងាប់ក្តី បណ្ឌិតគប្បីជ្រាប ក្នុងបទនោះ ថា "បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមិ បស្សសិស្សាមិ" ដូចបានពោលមកនេះឯង ។

(អត្ថាធិប្បាយក្នុងបដិសម្ភិទាមគ្គ)

ចំណែកក្នុងបដិសម្ភិទា លោកពោលសេចក្តីនេះ នៃពាក្យថា "បស្សម្ភយំ កាយសង្ខារំ" ដូច្នេះនេះ មួយអន្លើដោយការចោទ និង ការឆ្លើយ យ៉ាងដូច្នេះថា "សួរថាៈ កិក្ខុសិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ ។ល។ ទើបដកដង្ហើមចូល តើដូចម្តេច

កាយសង្ខារ តើដូចម្ដេច ? ” ។ ឆ្លើយថា “ធម៌ទាំងឡាយនេះ ដែលប្រព្រឹត្តទៅ ក្នុងកាយ គឺខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលវែង ដែលជាធម៌ជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ ។ ភិក្ខុ កាលញ៉ាំង កាយសង្ខារទាំងឡាយនោះឲ្យរម្ងាប់ គឺថាឲ្យរំលត់ ឲ្យស្ងប់រម្ងាប់ ឈ្មោះថា សិក្សាថា ។ល។ (គឺ) សិក្សាថា ការឱន ការផ្អៀក ការទម្រេត ការឈម ការរញ្ជួយ ការអន្ទះសា ការកម្រើក ការញាប់ញ័រ ណា នៃកាយ ដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់ នូវកាយសង្ខារ ទើបដកដង្ហើមចូល សិក្សាថា ការមិនឱន ការមិនផ្អៀក ការមិនទម្រេត ការមិនឈម ការមិនរញ្ជួយ ការមិនអន្ទះសា ការមិនកម្រើក ការមិនញាប់ញ័រ ណា នៃកាយ ដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ដ៏ល្អិតសុខុម មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ ទើបដកដង្ហើមចូល ។

បានឮថា ភិក្ខុសិក្សាថា អាត្មាអញ កាលរម្ងាប់ នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់ នូវកាយសង្ខារ ទើបដកដង្ហើមចូល ដោយអាការៈយ៉ាងនេះហើយ កាលបើយ៉ាងនេះ ការប្រាកដ នៃការបាននូវខ្យល់ មិនទាន់មាន ការប្រាកដ នៃដង្ហើមចេញ និង ចូល ក៏មិនទាន់មាន ការប្រាកដ នៃអានាបានស្សតិ ក៏មិនទាន់មាន ទាំងការប្រាកដ នៃអានាបានស្សតិសមាធិ ក៏មិនទាន់មានទេ បណ្ឌិតទាំងឡាយ រមែងមិនចូលកាន់សមាបត្តិនោះផង មិនចេញចាកសមាបត្តិនោះផង បានឮថា ភិក្ខុសិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើប

ដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ដោយអាការៈយ៉ាងនេះហើយ កាលបើយ៉ាងនេះ ការប្រាកដនៃការបាននូវខ្យល់ក៏មាន ការប្រាកដ នៃខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលក៏មាន ការប្រាកដ នៃអានាបានស្សតិក៏មាន ទាំងការប្រាកដនៃអានាបានស្សតិសមាធិក៏មាន ពួកបណ្ឌិត ទើបចូលកាន់សមាបត្តិនោះផង ចេញចាកសមាបត្តិនោះផង ដំណើរនោះប្រៀបដូចជាអ្វី ប្រៀបដូចជារគាំងដែលគេគោះ សំឡេងគ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្តនៃសំឡេង ដ៏គ្រោតគ្រាត កាលបើសំឡេងដ៏គ្រោតគ្រាត រលត់ហើយ បន្ទប់មក សំឡេងដ៏ល្អិត រមែងប្រព្រឹត្តទៅ ជាខាងក្រោយ ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្ត នៃសំឡេងដ៏ល្អិត កាលបើសំឡេងដ៏ល្អិត រលត់ហើយ បន្ទាប់មក ចិត្ត ក៏រមែងប្រព្រឹត្តទៅ ជាខាងក្រោយ ព្រោះចិត្តមាននិមិត្ត នៃសំឡេងដ៏ល្អិតជាអារម្មណ៍ មានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចជាខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល ដ៏គ្រោតគ្រាត រមែងប្រព្រឹត្តទៅ ជាដំបូង ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្តនៃខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាត កាលបើខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល ដ៏គ្រោតគ្រាត រលត់ហើយ បន្ទប់មក ខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលដ៏ល្អិត រមែងប្រព្រឹត្តទៅ ជាខាងក្រោយ ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្ត នៃខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលដ៏ល្អិត កាលបើខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលដ៏ល្អិត រលត់ហើយ បន្ទាប់មក

ចិត្ត ក៏មិនដល់នូវសេចក្តីរាយមាយ ក្នុងកាលជាខាងក្រោយ ព្រោះចិត្ត យកនិមិត្ត នៃខ្យល់ដង្ហើមចេញ និង ដង្ហើមចូល ដ៏ល្អិតជាអារម្មណ៍ ក៏យ៉ាងនោះដែរ កាលបើយ៉ាងនេះ ការប្រាកដ នៃការបាននូវខ្យល់ក៏មាន ការប្រាកដ នៃខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលក៏មាន ការប្រាកដ នៃអានាបានស្សតិក៏មាន ទាំងការប្រាកដនៃអានាបានស្សតិសមាធិក៏មាន បណ្ឌិតទាំងឡាយ រមែងចូលកាន់សមាបត្តិនោះផង រមែងចេញចាកសមាបត្តិនោះផង កាយគឺខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល របស់ភិក្ខុកាលរម្ងាប់ នូវកាយសង្ខារ ឈ្មោះថាឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ កាយ ឈ្មោះថាឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថាសតិផង ភិក្ខុ រមែងពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោកពោលថា ការពិចារណាឃើញនូវកាយក្នុងកាយ គឺការចំរើននូវសតិប្បដ្ឋាន [១] ” ។

នេះជាការពណ៌នាបទតាមលំដាប់នៃចតុក្កៈទី១ ដែលទ្រង់ត្រាស់ដោយអំណាចនៃកាយានុបស្សនា ក្នុងអានាបានស្សតិនោះ ជាដំបូង ។

(វិធីហ្វឹកហាត់ធ្វើ)

(១៦៨) ក៏ព្រោះថាក្នុងចតុក្កៈទាំង ៤ នោះ ចតុក្កៈនេះឯង គឺព្រះមានព្រះភាគទ្រង់ត្រាស់ ដោយអំណាចនៃកម្មដ្ឋាន នៃអាទិកម្មិកយោគី ចំណែកចតុក្កៈទាំងឡាយ ៣ ក្រៅនេះ ព្រះអង្គទ្រង់ត្រាស់ហើយ ដោយអំណាច នៃវេទនានុបស្សនា ចិត្តានុបស្សនា និង ធម្មានុបស្សនា នៃព្រះយោគី អ្នកបាននូវឈានហើយ ក្នុងបឋមជ្ឈាននេះ ព្រោះហេតុនោះ

១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ១៩៥ ។

អាទិកម្មិកកុលបុត្រ អ្នកប្រាថ្នាដើម្បីចំរើននូវកម្មដ្ឋាននេះ ហើយសម្រេចនូវព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ដោយវិបស្សនា ដែលមានអានាបានស្សតិចតុត្ថជ្ឈាន ជាបទដ្ឋាន គប្បីធ្វើនូវកិច្ចទាំងពួង ទាំងឡាយ មានការជម្រះនូវសីល តាមន័យដែលលោកពោលហើយ ក្នុងកាលមុនហ្នឹងឯង ហើយរៀនយកនូវកម្មដ្ឋាន ដែលមានសន្ធិ (តំណ) ៥ ក្នុងសំណាក់ នៃអាចារ្យមានប្រការៈដែលយើងពោលហើយ ។

(បញ្ចសន្ធិ)

នេះ ជាតំណ ៥ ក្នុងអានាបានស្សតិនោះ គឺៈ កិរិយារៀនយក កិរិយាសាកសួរ កិរិយាប្រាកដ កិរិយាសំរេច កិរិយាកំណត់ ។ ក្នុងសន្ធិ ៥ យ៉ាងនោះ ការរៀនយកនូវកម្មដ្ឋាន ឈ្មោះថា ឧគ្គហៈ ។ ការសាកសួរនូវកម្មដ្ឋាន ឈ្មោះថា បរិបុច្ឆា ។ ការប្រាកដច្បាស់ នៃកម្មដ្ឋាន ឈ្មោះថា ឧបដ្ឋានៈ ។ ការសំរេចនូវកម្មដ្ឋាន ឈ្មោះថា អប្បនា ។ ការកំណត់នូវកម្មដ្ឋាន អធិប្បាយថា : ការទ្រទ្រង់ទុកនូវសភាវៈ នៃកម្មដ្ឋានថា “កម្មដ្ឋាននេះ មានលក្ខណៈយ៉ាងនេះ” ដូច្នេះ ឈ្មោះថា លក្ខណៈ ។

ព្រះយោគីកាលរៀនយកនូវកម្មដ្ឋានដែលមានសន្ធិ ៥ យ៉ាងនេះ មិនលំបាកដោយខ្លួនឯងផង ទាំងមិនបៀតបៀនអាចារ្យផង ព្រោះហេតុនោះ ព្រះយោគី គប្បីញ៉ាំងអាចារ្យ ឲ្យសំដែងបន្តិចហើយ ស្វាធ្យាយអស់កាលច្រើន រៀនយកនូវកម្មដ្ឋានដែលមានសន្ធិ ៥ យ៉ាងនេះហើយ នៅក្នុងសំណាក់នៃអាចារ្យក៏បាន ក្នុងទីសេនាសនៈដទៃ មានប្រការៈដូចពោលមកហើយ ក្នុងកាលមុនក៏បាន មានបលិពោធតូចៗផ្តាច់បង់ហើយ មានភត្តកិច្ចធ្វើហើយ បន្ទោបង់នូវសេចក្តីស្រវឹងក្នុងភត្ត អង្គុយឲ្យស្រួល ធ្វើចិត្តឲ្យរីករាយ ដោយកិរិយារលឹករឿយៗ នូវគុណព្រះរតនត្រៃហើយ

កុំឲ្យភ្លេចភ្លាំងសូម្បីបទមួយ អំពីការរៀនអំពីអាចារ្យ គប្បីធ្វើទុកក្នុងចិត្ត នូវអានាបានស្សតិកម្មដ្ឋាននេះ ។

(វិធីមនសិការ)

(១៦៩) នេះជាវិធីមនសិការ ក្នុងអានាបានស្សតិកម្មដ្ឋាននោះ គឺ:

១- គណនា ការរាប់,

២- អនុពន្ធនា ការចងក្រៀក,

៣- ផុសនា ការពាល់ត្រូវ,

៤- ឋបនា ការតំកល់នូវចិត្ត,

៥- សល្លក្ខណា ការកំណត់ជាក់,

៦- វិវដ្ដនា ការផ្លាស់ប្តូរ,

៧- បារិសុទ្ធិ សេចក្ដីបរិសុទ្ធិ,

៨- តេសញ្ច បដិបស្សនា និង ប្រាជ្ញាឃើញនូវមគ្គ និង ផលទាំងនោះ។

ក្នុងបទទាំងនោះ ការរាប់ហ្នឹងឯង ឈ្មោះថា គណនា ។ ការនាំមកតាមលំដាប់ ឈ្មោះថា អនុពន្ធនា ។ ទីដែលពាល់ត្រូវ ឈ្មោះថា ផុសនា ។ ការសំរេច ឈ្មោះថា ឋបនា ។ ការឃើញច្បាស់ ឈ្មោះថា សល្លក្ខណា ។ មគ្គ ឈ្មោះថា វិវដ្ដនា ។ ផល ឈ្មោះថា បារិសុទ្ធិ ។ ការពិចារណាឃើញច្បាស់ ឈ្មោះថា ការពិចារណាឃើញច្បាស់នូវមគ្គ និង ផលទាំងឡាយនោះ ។

(គណនា វិធីរាប់)

ក្នុងមនសិការវិធីទាំងនោះ អាទិកម្មិកកុលបុត្រនេះ គប្បីធ្វើទុកក្នុងចិត្ត នូវកម្មដ្ឋាននេះ ដោយការរាប់ ជាមុន ។ ក៏កាលរាប់ មិនគប្បីបញ្ឈប់ ខាងក្រោម ចំនួន ៥ មិនគប្បីនាំទៅ ខាងលើ ចំនួន ១០ មិន

គប្បីសំដែងការរាប់ ដាច់ត្រង់ចន្លោះ ។ ព្រោះថា កាលព្រះយោគីបញ្ឈប់ ខាងក្រោម ចំនួន ៥ ចិត្តុប្បាទ រមែងញាប់ញ័រ ក្នុងឱកាសដ៏ចង្អៀត ដូចជាហ្វូងគោ ដែលនាយគោបាលឃាំងទុកហើយ ក្នុងក្រោលដ៏ចង្អៀត ញាប់ញ័រដូច្នោះ ។ កាលព្រះយោគីនាំទៅ ខាងលើ ចំនួន ១០ ចិត្តុប្បាទ រមែងអាស្រ័យនៅតែនឹងការរាប់ហ្នឹងឯង ។ កាលបើព្រះយោគី សំដែងការរាប់ដាច់ ក្នុងចន្លោះ ចិត្ត រមែងកម្រើកញាប់ញ័រ ថា “កម្មដ្ឋាន របស់អាត្មាអញ ដល់ទីបំផុត ឬហ្ន៎ ឬ មិនទាន់ដល់ទីបំផុត” ព្រោះហេតុនោះ ព្រះយោគី គប្បីវៀរ នូវទោសទាំងឡាយនេះហើយ រាប់ចុះ ។

(ការរាប់យឺតៗ)

ក៏អាទិកម្មិកកុលបុត្រ កាលរាប់ គប្បីរាប់ ដោយវិធីរាប់យឺតៗ គឺរាប់ដូចជាបុគ្គលអ្នកវាល់ស្រូវ ជាដំបូង ។ មែនពិត បុគ្គលអ្នកវាល់ស្រូវ ញ៉ាំងនាឡិ ឲ្យពេញហើយ ពោលថា “មួយ” ហើយក៏ចាក់ធារចុះ កាលបំពេញម្តងទៀត ឃើញនូវសំរាមណាមួយ ក៏ចោលនូវសំរាមនោះ ហើយពោលថា “មួយ មួយ” ដូច្នេះ ។ ក្នុងការរាប់ទាំងឡាយ មានការរាប់ថា “ពីរ ពីរ” ដូច្នេះ ក៏មានន័យដូចគ្នានេះដែ យ៉ាងណាមិញ សូម្បីអាទិកម្មិកកុលបុត្រនេះ ក៏គប្បីកាន់យកនូវខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលដែលប្រាកដ ហើយកំណត់នូវខ្យល់ ដែលប្រព្រឹត្តទៅរឿយៗនោះឯង ហើយរាប់ ចាប់ដើមតាំងពី “មួយ មួយ” រហូតទៅដល់ “ដប់ ដប់” ក៏យ៉ាងនោះដែរ ។

(វិធីរាប់រហ័ស)

កាលអាទិកម្មិកកុលបុត្រនោះ រាប់យ៉ាងនេះ ខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល ដែលកំពុងចេញ និង កំពុងចូល រមែងប្រាកដ ។

បន្ទាប់មក ព្រះយោគីនេះ គប្បីលះបង់ នូវការរាប់យឺត គឺការរាប់ដូចជាបុគ្គលអ្នកវាល់ស្រូវនោះ ហើយរាប់ ដោយការរាប់យ៉ាងលឿន គឺរាប់ដូចជានាយគោបាល ។ មែនពិត នាយគោបាលដែលឆ្លាត ដាក់នូវក្រួសទាំងឡាយ នឹងថ្នក់ មានខ្សែ និង ដំបង ក្នុងដៃ ដើរទៅកាន់ក្រោល តាំងពីព្រលឹមស្រាង គោះគោទាំងឡាយ ត្រង់ខ្នង អង្គុយ លើចុងនៃសសរក្បែរក្រោល ផ្ទាត់ទៅហើយៗ នូវក្រួស ហើយរាប់នូវមេគោ ដែលដល់ហើយៗ នូវទ្វារហ្នឹងឯង ហើយរាប់ថា "មួយ ពីរ" ដូច្នេះ ។ ហ្វូងគោដែលនៅយ៉ាងលំបាក ក្នុងឱកាសដែលចង្អៀត អស់រាត្រី មានយាម ៣ កាលចេញមក ក៏ប្រប្រៀតគ្នានឹងគ្នា មានសភាពជាហ្វូងៗ ចេញទៅដោយរហ័ស ។ នាយគោបាលនោះ ក៏រាប់ ដោយរហ័សៗ ថា "បី បួន ប្រាំ... ដប់" ដូច្នេះ ។ កាលព្រះយោគីនេះ រាប់ តាមន័យមុន យ៉ាងនេះ ខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល ជាសភាវៈប្រាកដ សញ្ចរទៅរឿយៗ យ៉ាងលឿនៗ ។ បន្ទាប់មក ព្រះយោគីនោះគប្បីដឹងថា "ខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល តែងសញ្ចរទៅរឿយៗ" ដូច្នេះហើយ មិនកាន់យក នូវខ្យល់អស្សាសបស្សាសៈ ទាំងខាងក្នុង ទាំងខាងក្រៅ កាន់យកតែខ្យល់ដែលមកដល់នូវទ្វារប៉ុណ្ណោះ ហើយរាប់លឿនៗ ថា :

១ ២ ៣ ៤ ៥,

១ ២ ៣ ៤ ៥ ៦,

១ ២ ៣ ៤ ៥ ៦ ៧,

១ ២ ៣ ៤ ៥ ៦ ៧ ៨,

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩,

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ដូច្នេះឯង ។

ព្រោះថា ក្នុងកម្មដ្ឋាន ដែលជាប់ទាក់ទង ដោយការរាប់ ចិត្ត ជាធម្មជាតមានអារម្មណ៍តែមួយ ដោយកំឡាំង នៃការរាប់ហ្នឹងឯង ដូចជាការចតនូវទូកក្នុងខ្សែទឹកដ៏កំណាច ដោយអំណាចនៃការទប់ដោយថ្នោល យ៉ាងដូច្នោះឯង ។ កាលព្រះយោគីនោះ រាប់លឿនៗ យ៉ាងនេះ កម្មដ្ឋានរមែងប្រាកដ ដូចជាប្រព្រឹត្តទៅហើយ មិនមានចន្លោះ ។ បន្ទាប់មក ព្រះយោគីនោះ គប្បីដឹងថា "កម្មដ្ឋានរមែងប្រព្រឹត្តទៅមិនមានចន្លោះ" ដូច្នេះហើយ កុំកាន់យកនូវខ្យល់ខាងក្នុង និង ខ្យល់ខាងក្រៅ ហើយរាប់ដោយរហ័សក្រៃពេក តាមន័យមុនហ្នឹងឯង ។ ព្រោះថា កាលព្រះយោគីបញ្ជូនចិត្តទៅ ជាមួយនឹងខ្យល់ដែលចូលទៅ ខាងក្នុង ចិត្ត ប្រៀបដូចជាត្រូវខ្យល់បក់បោកហើយ និង ដូចជាពេញហើយ ដោយខ្លាញ់ខាប់ ព្ធដ៏ខាងក្នុង ។ កាលព្រះយោគី នាំចិត្តចេញមក ជាមួយនឹងខ្យល់ ដែលចេញមកខាងក្រៅ ចិត្ត រមែងរាយមាយ ក្នុងអារម្មណ៍ដែលក្រាស់ ព្ធដ៏ខាងក្រៅ ។ លុះដល់ព្រះយោគី តម្កល់នូវសតិ ក្នុងឱកាសដែលខ្យល់ពាល់ត្រូវហើយចំរើនហ្នឹងឯង ទើបភាវនា សម្រេច ។ ព្រោះហេតុនោះ ខ្ញុំម្ចាស់ពោលថា "ព្រះយោគី កុំកាន់យកនូវខ្យល់ ទាំងខាងក្នុង ទាំងខាងក្រៅ ហើយរាប់ ដោយរហ័សក្រៃពេក តាមន័យមុននោះឯង" ។

សួរថា "ក៏ខ្យល់អស្សាសបស្សាសៈនុ៎ះ តើព្រះយោគី គប្បីរាប់យូរប៉ុន្មានទៅ?" ។ ឆ្លើយថា "ព្រះយោគី គប្បីរាប់ រហូតវៀរចាកការរាប់ហើយ សតិ ក៏តាំងនៅព្រម ក្នុងអារម្មណ៍ គឺខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល" ។ ព្រោះថា ការរាប់ ក៏ដើម្បីធ្វើការកាត់ផ្តាច់ នូវវិតក្កៈដែលរាលដាលទៅ ព្ធដ៏ខាងក្រៅហើយ តម្កល់នូវសតិ ក្នុងអារម្មណ៍ គឺអស្សាសបស្សាសៈ ឲ្យបានហ្នឹងឯង ។ ព្រះយោគី លុះធ្វើទុកក្នុងចិត្ត

ដោយវិធីរាប់ យ៉ាងនេះហើយ គប្បីធ្វើទុកក្នុងចិត្ត ដោយការរាប់ តាមលំដាប់ (បន្តទៅទៀត) ។

(អនុពន្ធនា វិធីរាប់តាមខ្យល់)

កិរិយាផ្អាកទុកនូវការរាប់ ហើយបញ្ជូនសតិ ទៅតាមខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល មិនឲ្យមានចន្លោះ ឈ្មោះថា អនុពន្ធនា ។ តែថា ការបញ្ជូននោះ មិនគប្បីធ្វើ ដោយអំណាចនៃការបញ្ជូនទៅកាន់ខាងដើម កណ្តាល និង ខាងចុងទេ ។ ព្រោះថា សំរាប់ខ្យល់ចេញទៅខាងក្រៅ ផ្ចិត គឺខាងដើម បេះដូង គឺកណ្តាល ខាងចុង គឺច្រមុះ ។ សំរាប់ខ្យល់ដែលចូលទៅខាងក្នុង ចុងច្រមុះ ឈ្មោះថាខាងដើម បេះដូង ឈ្មោះថា កណ្តាល ផ្ចិត ឈ្មោះថា ខាងចុង ។ ក៏កាលព្រះយោគីនោះបញ្ជូនទៅ នូវខ្យល់អស្សាសបស្សាសៈនោះ ចិត្ត ដែលដល់នូវសេចក្តីរាយមាយ រមែងមាន ដើម្បីសេចក្តីរាយមាយផង ដើម្បីកិរិយាញាប់ញ័រផង ។ ដូចជាព្រះសារីបុត្រ ពោលថា “កាលភិក្ខុផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចេញ ខាងដើម កណ្តាល និង ខាងចុង កាយ និង ចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្តដែលបោះទៅ ក្នុងខ្យល់ដង្ហើមខាងក្នុង កាលភិក្ខុផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចូល ខាងដើម កណ្តាល និង ខាងចុង កាយ និង ចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្រៅ [១] ” ។ ព្រោះហេតុនោះ ព្រះយោគីកាលធ្វើទុកក្នុងចិត្ត ដោយការជាប់តាម មិនគួរធ្វើទុកក្នុងចិត្ត ដោយអំណាចនៃខ្យល់ខាងដើម កណ្តាល និង ខាងចុងទេ ។ តែថា ព្រះយោគី

១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ៩១ ។

គប្បីធ្វើទុកក្នុងចិត្ត ដោយអំណាច នៃការពាល់ត្រូវផង ដោយអំណាចនៃការតម្កល់ទុកផង ។

មែនពិត ការធ្វើទុកក្នុងចិត្ត ដោយអំណាចនៃការពាល់ត្រូវ និង ការតម្កល់ទុក មិនមានផ្សេង ដូចជាការធ្វើទុកក្នុងចិត្ត ដោយអំណាច នៃការរាប់ និង ការជាប់តាមទេ ។ តែថា ព្រះយោគីកាលរាប់ ក្នុងទីដែលខ្យល់ពាល់ត្រូវហើយៗ ហ្នឹងឯង ធ្វើទុកក្នុងចិត្ត ដោយការរាប់ និង ការពាល់ត្រូវ ផ្អាកការរាប់ ក្នុងទីដែលខ្យល់ពាល់ត្រូវហើយៗ នោះឯង ផ្ចង់សតិទៅតាមខ្យល់អស្សាសបស្សាសៈទាំងនោះ និង តម្កល់ចិត្ត ដោយអំណាចនៃអប្បនា លោកហៅថា “ធ្វើទុកក្នុងចិត្ត ដោយអនុពន្ធនាផង ដោយផុសនាផង ដោយឋបនាផង” ដូច្នេះ ។ សេចក្តីនេះនោះ បណ្ឌិតគប្បីជ្រាប ដោយសេចក្តីឧបមាដោយបុរសខ្វិន និង ឆ្មាំទ្វារ ដែលព្រះអដ្ឋកថាចារ្យ ពោលហើយ ក្នុងអដ្ឋកថាទាំងឡាយ និង ដោយសេចក្តីឧបមាដោយរណារ ដែលលោកពោលហើយ ក្នុងបដិសម្ភិទា ។

បណ្តាឧបមាទាំងនោះ នេះគឺជាសេចក្តីឧបមា ដោយបុរសខ្វិន ។ បុរសខ្វិន យោលទោង ដើម្បីមាតា និង បុត្រទាំងឡាយកំពុងលេងទោងអង្គុយ ទៀបជើងសសរទោង ក្នុងទីនោះឯង រមែងឃើញនូវទីបំផុតទាំងពីរផង នូវពាក់កណ្តាលផង នៃផែនក្តារទោង ដែលមកផងទៅផង តាមលំដាប់ តែថាជាអ្នកមិនខ្វល់ខ្វាយ ដើម្បីឃើញ នូវទីបំផុតទាំងពីរ និង ត្រង់កណ្តាល យ៉ាងណាមិញ ភិក្ខុឈរនៅ ក្បែរសសរដែលចូលទៅចង ដោយអំណាចនៃសតិ យោលនូវទោងគឺខ្យល់អស្សាសបស្សាសៈហើយ អង្គុយ ក្នុងនិមិត្តនោះឯង ដោយសតិ កាលផ្ចង់ ដោយសតិ តម្កល់ចិត្ត ត្រង់ទីដែលខ្យល់ពាល់ត្រូវហើយៗ ហ្នឹងឯង ក៏រមែងឃើញ នូវខាងដើម

ត្រង់កណ្តាល និង ខាងចុង នៃខ្យល់អស្សាសបស្សាសៈ ក្នុងទីដែលខ្យល់ទាំងនោះ មកផងទៅផង ពាល់ត្រូវហើយៗ ដោយលំដាប់ តែថាភិក្ខុនេះ ជាអ្នកមិនខ្វល់ខ្វាយ ដើម្បីឃើញ នូវខ្យល់អស្សាសបស្សាសៈទាំងនោះ ។ នេះជាឧបមាដោយបុរសខ្វិន ។

ចំណែកឧបមាដោយអ្នកឆ្មាំទ្វារ មានដូចតទៅនេះ ។ ឆ្មាំទ្វារ មិនពិចារណា នូវបុរសទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ នៃនគរ ថា "អ្នកជាអ្នកណា ឬ អ្នកមកអំពីទីណា អ្នកទៅទីណា ឬក៏ អ្វីមាននៅ ក្នុងដៃអ្នក" ដូច្នេះ ព្រោះថា បុរសទាំងនោះ មិនមែនជាភារៈនៃឆ្មាំទ្វារនោះទេ តែថា ឆ្មាំទ្វារពិចារណា នូវមនុស្សដែលមកដល់ទ្វារហើយ មកដល់ទ្វារហើយតែប៉ុណ្ណោះឯង យ៉ាងណាមិញ ខ្យល់ចូលទៅខាងក្នុងក្តី ខ្យល់ចេញទៅខាងក្រៅក្តី មិនមែនជាភារៈ នៃភិក្ខុនេះទេ ខ្យល់ដែលមកដល់ទ្វារហើយ មកដល់ទ្វារហើយហ្នឹងឯង គឺជាភារៈ នៃភិក្ខុនេះ ក៏យ៉ាងនោះដែរ ។ នេះ ជាឧបមាដោយអ្នកឆ្មាំទ្វារ ។

ចំណែកឧបមាដោយរណារ បណ្ឌិតគប្បីជ្រាប តាំងតែអំពីដើមដូច្នេះឯង ។ សមដូចជាពាក្យដែលព្រះសារីបុត្រពោលហើយ ថា : [១]

> និមិត្ត ខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល ពុំមែន
> ជាអារម្មណ៍ របស់ចិត្តតែមួយទេ តែថា កាលភិក្ខុមិន
> ដឹងនូវធម៌ទាំងឡាយ ៣ ភាវនា រមែងមិនបានសំរេច,
> និមិត្ត ខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល មិន
> មែនជាអារម្មណ៍ របស់ចិត្តតែមួយទេ តែថា កាលភិក្ខុ
> ដឹងនូវធម៌ទាំងឡាយ ៣ ភាវនា រមែងបានសំរេច ។

១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ១០៨ ។

មានអធិប្បាយដូចម្តេច? ។ មានអធិប្បាយថា : ធម៌ទាំងឡាយ ៣ នេះ មិនមែនជាអារម្មណ៍ របស់ចិត្តតែមួយទេ តែថា ធម៌ទាំងឡាយ ៣ នេះ មិនមែនជាធម៌ គឺភិក្ខុនោះ មិនដឹងទេ ចិត្ត មិនដល់នូវសេចក្តីរាយមាយផង បធាន (សេចក្តីព្យាយាម) រមែងប្រាកដផង ទាំងព្រះយោគី ក៏ញុំាងប្រយោគ ឲ្យសម្រេចផង រមែងបាននូវគុណវិសេស ប្រៀបបីដូចជាដើមឈើដែលគេដាំហើយ ក្នុងភូមិភាគដែលស្មើ បុរសគប្បីកាត់នូវដើមឈើនេះនោះ ដោយរណា សតិ គឺបុរស(នោះ) តាំងទុកហើយ ដោយអំណាច នៃធ្មេញរណារ ដែលពាល់ត្រូវដើមឈើ បុរសនោះ មិនបានធ្វើទុកក្នុងចិត្ត នូវធ្មេញរណារ ដែលមកហើយផង ដែលទៅហើយផងទេ តែថា ធ្មេញរណារ ដែលមកហើយក្តី ដែលទៅហើយក្តី ក៏មិនមែនបុរសនោះ មិនដឹងនោះទេ បធាន (សេចក្តីព្យាយាម) រមែងប្រាកដផង បុរសនោះ រមែងញុំាងប្រយោគ ឲ្យសម្រេចផង រមែងបាន នូវគុណវិសេសយ៉ាងណាមិញ, និមិត្តជាគ្រឿងចូលទៅចងផ្អោប ប្រៀបដូចជាដើមឈើដែលគេដាំហើយ ក្នុងភូមិភាគដែលស្មើ ខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល ប្រៀបដូចជាធ្មេញរណារ, សតិ ជាធម្មជាតិ គឺបុរស តាំងទុកហើយ ដោយអំណាចនៃធ្មេញរណារដែលពាល់ត្រូវដើមឈើ តែថាបុរសនោះ មិនបានធ្វើទុកក្នុងចិត្ត នូវធ្មេញរណារដែលមក ឬ ទៅឡើយទាំងធ្មេញរណារ ដែលមកហើយក្តី ដែលទៅហើយក្តី ក៏មិនមែនជាបុរសនោះ មិនដឹងនោះទេ បធាន (សេចក្តីព្យាយាម) រមែងប្រាកដផងបុរសនោះ រមែងញុំាងប្រយោគ ឲ្យសម្រេចផង រមែងបានគុណវិសេសយ៉ាងណាមិញ, ភិក្ខុ អង្គុយតាំងសតិ ត្រង់ចុងច្រមុះក្តី ត្រង់និមិត្ត នៃមាត់ក្តី មិនធ្វើទុកក្នុងចិត្ត នូវខ្យល់អស្សាសបស្សាសៈដែលមកហើយ ឬ

ដែលទៅហើយ តែថា ខ្យល់អស្សាសបស្សាសៈដែលមកហើយក្តី ដែលទៅហើយក្តី មិនមែនជាសភាវៈគឺភិក្ខុនោះមិនដឹងនោះទេ បធាន (សេចក្តីព្យាយាម) រមែងប្រាកដផង ភិក្ខុនោះ រមែងញុំាងប្រយោគ ឲ្យសម្រេចផង រមែងបាននូវគុណវិសេស ក៏យ៉ាងនោះដែរ ។

ពាក្យថា “បធាន” មានសំណួរថា បធាន តើដូចម្តេច ។ ឆ្លើយថា ទាំងកាយទាំងចិត្ត នៃភិក្ខុអ្នកមានព្យាយាមប្រារព្ធហើយ ជាធម្មជាតគួរដល់ការងារ នេះ ឈ្មោះថា បធាន ។

សួរថា ប្រយោគ តើដូចម្តេច ។ ឆ្លើយថា ឧបក្កិលេសទាំងឡាយ គឺភិក្ខុអ្នកមានព្យាយាមប្រារព្ធហើយ តែងលះបង់បាន វិតក្កៈទាំងឡាយក៏រម្ងាប់បាន នេះ ឈ្មោះថា ប្រយោគ ។

សួរថា គុណវិសេស តើដូចម្តេច ។ ឆ្លើយថា សំយោជនៈទាំងឡាយ គឺភិក្ខុអ្នកមានព្យាយាមប្រារព្ធហើយ តែងលះបង់បាន អនុស័យទាំងឡាយ ក៏ដល់នូវសេចក្តីវិនាស នេះ ឈ្មោះថា គុណវិសេស ។

ធម៌ទាំង ៣ នេះ មិនមែនជាអារម្មណ៍ របស់ចិត្តតែមួយទេ តែថា ធម៌ទាំង ៣ នេះ មិនមែនជាធម៌ គឺព្រះយោគីនោះមិនដឹងនោះទេ ចិត្តក៏មិនដល់នូវសេចក្តីរាយមាយផង បធាន រមែងប្រាកដផង ព្រះយោគីរមែងញុំាងប្រយោគឲ្យសម្រេចផង បាននូវគុណវិសេស ដូច្នេះឯង ។

អានាបានស្សតិ បុគ្គលណាបានបំពេញហើយ ចំរើនហើយ ដោយប្រពៃ សន្សំហើយ ដោយលំដាប់ ឲ្យដូចព្រះពុទ្ធទ្រង់សំដែងទុកហើយ បុគ្គលនោះ រមែងញុំាងលោកនេះ ឲ្យភ្លឺច្បាស់ ដូចជាព្រះច័ន្ទ ដែលផុតស្រឡះចាកពពក ។

នេះ ជាឧបមាដោយរណារ ។

(១៧០) ក៏ហេតុត្រឹមតែព្រះយោគីនោះមិនធ្វើទុកក្នុងចិត្ត ដោយអំណាចនៃខ្យល់អស្សាសបស្សាសៈប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបថា ជាប្រយោជន៍ ក្នុងសេចក្តីឧបមាដោយរណារនេះ ។

ក៏និមិត្ត កើតឡើង និង ឋបនា ពោលគឺអប្បនា ដែលប្រដាប់ដោយអង្គឈានដ៏សេស រមែងសំរេច ដោយកាលមិនយូរប៉ុន្មានឯង ដល់ព្រះយោគីពួកខ្លះ ដែលធ្វើទុកក្នុងចិត្ត នូវកម្មដ្ឋាននេះ ។ តែសម្រាប់ព្រះយោគីពួកខ្លះ នាកាលសេចក្តីក្រវល់ក្រវាយផ្លូវកាយ ស្ងប់រម្ងាប់ហើយ ដោយអំណាចនៃការរំលត់ នូវខ្យល់អស្សាសបស្សាសៈ ដ៏គ្រោតគ្រាតតាមលំដាប់ ចាប់ដើមអំពីកាលជាទីធ្វើទុកក្នុងចិត្ត ដោយអំណាចនៃការរាប់ កាយក្តី ចិត្តក្តី ជាធម្មជាតស្រាល សរីរៈ ប្រៀបបីដូចជាដល់នូវអាការៈអណ្តែតឡើង ព្ធដ៏អាកាស ។ កាលព្រះយោគីមានកាយក្រវល់ក្រវាយ អង្គុយ លើគ្រែក្តី លើតាំងក្តី គ្រែ និង តាំង រមែងទ្រុឌចុះ ព្ធក្រិបក្រៀប កំរាល ចាប់ផ្តើមរួញ, តែថា កាលព្រះយោគីមិនមានកាយក្រវល់ក្រវាយ អង្គុយ លើគ្រែក្តី លើតាំងក្តី គ្រែ និង តាំង រមែងមិនទ្រុឌចុះ មិនព្ធក្រិបក្រៀបទេ គ្រឿងកំរាលមិនចាប់ផ្តើមរួញទេ គ្រែ និង តាំង ប្រៀបដូចជាពូកត្រូវគេញាត់ហើយដោយប៉ុយគរ ។ ព្រោះហេតុអ្វី ព្រោះកាយដែលមិនក្រវល់ក្រវាយ រមែងជាធម្មជាតស្រាល ព្រោះហេតុណា ព្រោះហេតុនោះ កាលសេចក្តីក្រវល់ក្រវាយនៃកាយ ស្ងប់រម្ងាប់ហើយ ដោយអំណាចនៃកិរិយារំលត់នូវខ្យល់អស្សាសបស្សាសៈ ដែលគ្រោតគ្រាត តាមលំដាប់ ចាប់ដើមអំពីកាលជាទីធ្វើទុកក្នុងចិត្ត ដោយអំណាចនៃការរាប់ កាយក្តី ចិត្តក្តី ជាធម្មជាតស្រាល សរីរៈ ជាធម្មជាត

ប្រៀបដូចជាដល់នូវអាការៈអណ្តែតឡើង ក្នុងអាកាស ក៏យ៉ាងនោះដែរ។ កាលខ្យល់អស្សាសបស្សាសៈ ដ៏គ្រោតគ្រាត រលត់ហើយ ចិត្ត របស់ព្រះយោគីនោះ មាននិមិត្តគឺខ្យល់អស្សាសបស្សាសៈដ៏ល្អិត ជាអារម្មណ៍ រមែងប្រព្រឹត្តទៅ ។ សូម្បីនិមិត្តនោះ រលត់ហើយ ចិត្ត ដទៃៗ ទៀត ជាធម្មជាតមាននិមិត្ត គឺខ្យល់អស្សាសបស្សាសៈ ដ៏ល្អិតក្រៃលែងជាងនោះ ជាអារម្មណ៍ រមែងប្រព្រឹត្តទៅហ្នឹងឯង។ សួរថា ដោយប្រការដូចម្តេច ។ ឆ្លើយថា “បណ្ឌិតគប្បីជ្រាបថា ប្រៀបដូចបុរសគោះរគាំងសំរិទ្ធិ ដោយបន្ទះលោហៈដ៏ធំ សំឡេងដ៏ខ្លាំង គប្បីកើតឡើង ដោយការវាយតែម្តងប៉ុណ្ណោះ ចិត្តរបស់បុរសនោះជាចិត្តមានសំឡេងគ្រោតគ្រាតជាអារម្មណ៍ ប្រព្រឹត្តទៅ ។ កាលសំឡេងដែលគ្រោតគ្រាត រលត់ហើយ គ្រានោះក្រោយមក ចិត្តរបស់បុរសនោះក៏មាននិមិត្តនៃសំឡេងដ៏ល្អិតជាអារម្មណ៍ សូម្បីកាលនិមិត្តនោះ រលត់ហើយ ចិត្ត ដទៃៗ ទៀត ជាធម្មជាតមាននិមត្តនៃសំឡេង ដ៏ល្អិតក្រៃលែងជាងនោះជាអារម្មណ៍ រមែងប្រព្រឹត្តទៅយ៉ាងដូច្នោះឯង” ។ មែនពិត សូម្បីព្រះសារីបុត្រ ក៏បានពោលពាក្យនេះ (ក្នុងបដិសម្ភិទាមគ្គ) ថា “ប្រៀបដូចជា នាកាលរគាំង ត្រូវគេវាយហើយ...” ដូច្នេះជាដើម ។ សេចក្តីពិស្តារ បណ្ឌិតគប្បីជ្រាប (តាមន័យក្នុងបដិសម្ភិទានោះចុះ) ។

(លក្ខណៈដែលផ្សេងចាកកម្មដ្ឋានដទៃ)

ដូចជាកម្មដ្ឋានទាំងឡាយដទៃ រមែងប្រាកដច្បាស់ ក្នុងដ៏ខាងលើៗ យ៉ាងណាមិញ កម្មដ្ឋាននេះ មិនដូច្នោះទេ ។ តែថាកម្មដ្ឋាននេះ កាលព្រះយោគីចំរើន ខ្ពស់ឡើងទៅៗ រមែងដល់នូវភាពដ៏ល្អិត មិនចូលទៅដល់ការប្រាកដឡើយ ។ តែថាកាលកម្មដ្ឋាននោះ មិនទាន់ប្រាកដ យ៉ាងនេះ

ភិក្ខុនោះ មិនត្រូវក្រោកចាកអាសនៈ ហើយរលាស់ នូវកំណាត់ស្បែក ដើរទៅឡើយ ។ សួរថា តើគប្បីធ្វើយ៉ាងដូចម្តេច ។ ឆ្លើយថា ភិក្ខុ មិនគួរក្រោក ដោយគិតថា “អាត្មាអញ នឹងសួរនូវអាចារ្យ” ដូច្នេះ ឬ ឬថា “ឥឡូវនេះ កម្មដ្ឋានរបស់អាត្មាអញ វិនាសហើយ” ដូច្នេះឡើយ ព្រោះថា ព្រះយោគីកាលញ៉ាំងឥរិយាបថ ឲ្យកំរើកហើយទៅ កម្មដ្ឋាន ជាកម្មដ្ឋាននៅតែថ្មីៗ ដដែល ព្រោះហេតុនោះ ព្រះយោគីអង្គុយយ៉ាងណាហ្នឹងឯង គប្បីនាំមកចាកទីកន្លែង ។

(ឧបាយនាំខ្យល់)

នេះជាឧបាយនាំមក ក្នុងពាក្យនោះ ។ ភិក្ខុនោះ ដឹងភាវៈគឺកិរិយាមិនប្រាកដ នៃកម្មដ្ឋានហើយ គប្បីពិចារណា ដូច្នេះថា “ឈ្មោះថា ខ្យល់អស្សាសបស្សាសៈទាំងនេះ រមែងមាន ក្នុងទីណា មិនមានក្នុងទីណា មានដល់បុគ្គលណា ឬ មិនមានដល់បុគ្គលណា” ដូច្នេះ ។ តមក កាលព្រះយោគី ពិចារណាយ៉ាងនេះ ក៏ដឹងថា “ខ្យល់អស្សាសបស្សាសៈទាំងនេះ មិនមានដល់សត្វទាំងឡាយ ក្នុងដ៏ខាងក្នុង ផ្ទៃនៃមាតា មិនមានដល់បុគ្គលទាំងឡាយដែលមុជចុះក្នុងទឹក មួយវិញទៀត មិនមានដល់បុគ្គលទាំងឡាយ ដែលជាអសញ្ញីសត្វ មិនមាន ដល់បុគ្គលទាំងឡាយដែលស្លាប់ហើយ មិនមានដល់អរិយបុគ្គលទាំងឡាយ ដែលចូលចតុត្ថជ្ឈាន មិនមានដល់អរិយបុគ្គលទាំងឡាយ អ្នកប្រកបដោយរូបភពនិងអរូបភព មិនមានដល់អរិយបុគ្គលទាំងឡាយដែលចូលនិរោធ” ដូច្នេះហើយ គប្បីពិចារណាខ្លួន ដោយខ្លួនឯង យ៉ាងនេះថា “នៃបណ្ឌិត ក្រែងអ្នកមិនមែនឋិតនៅ ក្នុងផ្ទៃនៃមាតា មិនមែនមុជចុះ ក្នុងទឹក មិនមែនជាអសញ្ញីសត្វ មិនមែនជាអ្នកស្លាប់ មិនមែនជាអ្នកចូល នូវចតុត្ថជ្ឈាន មិនមែនជាអ្នក

ប្រកបព្រមដោយរូបកព និង អរូបកព មិនមែនជាអ្នកចូលនិរោធ ខ្យល់អស្សាសបស្សាសៈទាំងនោះ នៅតែមានដដែលហ្នឹងឯង តែអ្នកមិនអាចដើម្បីកំណត់បានទេ ព្រោះភាពនៃខ្លួនជាអ្នកមានប្រាជ្ញាដ៏ទន់ខ្សោយ” ។ បន្ទាប់មក ព្រះយោគីនោះ គប្បីតាំងចិត្ត ដោយអំណាចនៃខ្យល់ដែលពាល់ត្រូវហើយតាមប្រក្រតី ហើយញ៉ាំងមនសិការ ឲ្យប្រព្រឹត្តទៅ ។ ក៏ខ្យល់អស្សាសបស្សាសៈទាំងនេះ សំរាប់បុគ្គលមានច្រមុះវែង ខ្ទប់នូវក្ដោងច្រមុះប្រព្រឹត្តទៅ ។ ខ្យល់អស្សាសបស្សាសៈទាំងនេះ សំរាប់អ្នកមានច្រមុះខ្លី ខ្ទប់នូវបបូរមាត់ពួដ៏ខាងលើ ប្រព្រឹត្តទៅ ។ ព្រោះហេតុនោះ ព្រះយោគីនោះ គប្បីតម្កល់នូវនិមិត្តថា “ខ្យល់អស្សាសបស្សាសៈ ខ្ទប់នូវទីឈ្មោះនេះ” ។ មែនពិត ព្រះមានព្រះភាគ ទ្រង់អាស្រ័យនូវអំណាចនៃប្រយោជន៍នេះ ទើបទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ តថាគត មិនពោលនូវការចំរើនអានាបានស្សតិ ដល់បុគ្គលអ្នកភ្លេចភ្លាំងសតិ អ្នកមិនដឹងខ្លួន” ដូច្នេះជាដើម ។

មែនពិត កម្មដ្ឋានណានិមួយ រមែងសំរេច ដល់បុគ្គលអ្នកមានសតិ អ្នកដឹងខ្លួនតែប៉ុណ្ណោះ ក៏ពិតមែនហើយ ក៏ប៉ុន្តែថាកម្មដ្ឋានដទៃក្រៅអំពីកម្មដ្ឋាននេះ រមែងប្រាកដច្បាស់ ដល់អ្នកដែលធ្វើទុកក្នុងចិត្តៗ ។ ឯអានាបានស្សតិកម្មដ្ឋាននេះ ធ្ងន់ ការភាវនាក៏ធ្ងន់ ជាភូមិនៃមនសិការ នៃព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង បុត្ររបស់ព្រះពុទ្ធទាំងឡាយដែលជាមហាបុរសប៉ុណ្ណោះ មិនមែនជាកម្មដ្ឋានថយថោកទេ និង មិនមែនជាកម្មដ្ឋានដែលសត្វថ្នាក់ល្មមសេពបានទេ គឺធ្វើទុកក្នុងចិត្ត ដោយប្រការណាៗ ក៏រមែងស្ងប់រម្ងាប់ និង ល្អិត ដោយប្រការនោះៗ ព្រោះហេតុនោះ ក្នុងកម្មដ្ឋាននេះ សតិ និង បញ្ញា ដ៏មានកំឡាំងគឺព្រះយោគីគប្បីប្រាថ្នា ។

ដូចជា ក្នុងពេលដែលបុគ្គលធ្វើការជុល នូវសាដកសាច់ម៉ត់ សូម្បីម្ជុលដ៏ឆ្មារ គឺបុគ្គលគប្បីប្រាថ្នា សូម្បីចេសសំរាប់ដោត នូវប្រហោងនៃម្ជុល ដ៏ឆ្មារក្រៃលែងជាងនោះ ក៏បុគ្គលគប្បីប្រាថ្នាដែរ យ៉ាងណាមិញ ក្នុងពេលចំរើននូវកម្មដ្ឋាននេះ ដែលប្រាកដស្មើដោយសាដកសាច់ម៉ត់ សតិ ដែលប្រៀបដូចជាម្ជុលផង បញ្ញាដ៏សម្បយុត្តដោយសតិនោះផង ដែលប្រៀបដូចជាចេសសំរាប់ដោត នូវប្រហោងនៃម្ជុលផង ដែលមានកំឡាំង គឺព្រះយោគីគប្បីប្រាថ្នា ក៏យ៉ាងនោះដែរ ។

ក៏ភិក្ខុអ្នកប្រកបដោយសតិ និង បញ្ញាទាំងនោះ មិនគួរស្វែងរកខ្យល់អស្សាសបស្សាសៈទាំងនោះ ក្នុងទីដទៃអំពីឱកាសដែលខ្យល់ពាល់ត្រូវ តាមប្រក្រតីទេ ។ ប្រៀបដូចជា អ្នកស្រែភ្ជួរស្រែហើយលែងគោចំរើនទាំងឡាយ ដេញឲ្យមានមុខឆ្ពោះទៅកាន់ទីគោចរ អង្គុយសំរាកនៅក្រោមម្លប់ កាលបើដូច្នោះ គោចំរើនទាំងនោះ របស់អ្នកស្រែនោះ គប្បីចូលទៅកាន់ដងព្រៃ ដោយលឿន អ្នកស្រែដែលជាអ្នកឆ្លាត ប្រាថ្នាចង់ចាប់គោទាំងនុ៎ះ យកមកទឹមម្ដងទៀត មិនបាច់ទៅតាមស្នាមជើងគោទាំងនោះទេ ដើរទៅកាន់ដងព្រៃ គ្រាន់តែកាន់យកខ្សែ និង ជន្លួញ ហើយដើរតម្រង់ត្រង់ ទៅកាន់កំពង់ទឹកដែលគោទាំងនោះ នៅផ្ដុំគ្នាតែម្ដង ហើយអង្គុយឬក៏ដេក ។ ក្រោយមក អ្នកស្រែនោះ ឃើញគោទាំងនោះត្រាច់ទៅ អស់ចំណែកនៃថ្ងៃហើយ ចុះកំពង់ទឹកជាទីប្រជុំគ្នា ត្រាំផង ផឹកផង ហើយឡើងមកឈរនៅ ក៏យកខ្សែចង ចាក់នឹងជន្លួញ នាំយកទៅទឹមធ្វើការងារ ម្ដងទៀត យ៉ាងណាមិញ ភិក្ខុនោះ មិនគប្បីស្វែងរកខ្យល់អស្សាសបស្សាសៈទាំងនោះ ក្នុងទីដទៃអំពីឱកាសដែលខ្យល់នោះពាល់ត្រូវហើយតាមប្រក្រតី គ្រាន់តែកាន់យកនូវខ្សែគឺសតិ និង ជន្លួញគឺបញ្ញា

តម្កល់ចិត្ត ក្នុងឱកាសដែលខ្យល់ពាល់ត្រូវហើយ តាមប្រក្រតី ហើយញ៉ាំងមនសិការ ឲ្យប្រព្រឹត្តទៅ ដ្បិតថា កាលភិក្ខុនោះ ធ្វើទុកក្នុងចិត្តយ៉ាងនេះ មិនយូរប៉ុន្មានឡើយ ខ្យល់អស្សាសបស្សាសៈទាំងនោះ រមែងប្រាកដ ដូចគោទាំងឡាយដែលប្រាកដ ត្រង់កំពង់ទឹកដែលជាទីប្រជុំចុះតអំពីនោះមក ភិក្ខុនោះគប្បីយកខ្សែគឺសតិចង ទឹមក្នុងទីនោះឯង ស្រេចហើយចាក់ដោយជន្លួញគឺបញ្ញា ប្រកបនូវកម្មដ្ឋានរឿយៗ ក៏យ៉ាងនោះដែរ ។ កាលភិក្ខុនោះ ប្រកបយ៉ាងនេះ មិនយូរប៉ុន្មាន និមិត្ត ក៏ប្រាកដ ។

(និមិត្តប្រាកដផ្សេងគ្នា)

ក៏អាចារ្យទាំងឡាយពួកខ្លះ ពោលថា "និមិត្តនេះនោះ មិនមែនជានិមិត្តប្រាកដស្មើតែមួយ ដល់ព្រះយោគីទាំងពួងឡើយ ប៉ុន្តែថា និមិត្តនោះ រមែងប្រាកដ ដល់ព្រះយោគីពួកខ្លះ ដូចជាប៉ុយគរក៏មាន ដូចជាប៉ុយកប្បាសក៏មាន ដូចជាផ្សារនៃខ្យល់ក៏មាន ដែលញ៉ាំងសុខសម្ផស្សឲ្យកើតឡើង" ។

ចំណែកសេចក្តីវិនិច្ឆ័យ ក្នុងអដ្ឋកថាទាំងឡាយ ដូចតទៅនេះ ។ ក៏និមិត្តនេះ រមែងប្រាកដ ដល់ព្រះយោគីពួកខ្លះ ដូចជារូបផ្កាយក៏មាន ដូចជាដុំកែវមណីក៏មាន ដូចជាដុំកែវមុក្តាក៏មាន សំរាប់ព្រះយោគីពួកខ្លះ ជានិមិត្តមានសម្ផស្សរឹង រមែងប្រាកដ ដូចជាគ្រាប់កប្បាសក៏មាន ដូចជាវនុកឈើដែលមានខ្លឹមក៏មាន សំរាប់ព្រះយោគីពួកខ្លះ រមែងប្រាកដ ដូចជាខ្សែសង្វាដ៏វែងក៏មាន ដូចជាកម្រងផ្កាក៏មាន ដូចជាអណ្តាតផ្សែងក៏មាន សំរាប់ព្រះយោគីពួកខ្លះ រមែងប្រាកដ ដូចជាសរសៃពីងពាងដែលលាតហើយក៏មាន ដូចជាដំបារពពកក៏មាន ដូចជាផ្កាឈូកក៏មាន ដូចជាកង់រថក៏មាន ដូចជាមណ្ឌល នៃព្រះច័ន្ទក៏មាន និង ដូចជាមណ្ឌលនៃព្រះ

អាទិត្យក៏មាន ។ ក៏ឯកម្មដ្ឋាននេះនោះ តែមួយគត់ រមែងប្រាកដ ដោយសេចក្តីផ្សេងគ្នា ក៏ព្រោះភាពនៃព្រះយោគីមានសញ្ញាផ្សេងគ្នា ប្រៀបដូចជា កាលភិក្ខុទាំងឡាយច្រើនរូប អង្គុយស្វាធ្យាយនូវព្រះសូត្រ កាលភិក្ខុមួយរូប ពោលថា "ព្រះសូត្រនេះ ប្រាកដដល់លោកទាំងឡាយ ដូចជាអ្វី" ដូច្នេះ, ភិក្ខុមួយរូប ក៏ឆ្លើយតបថា "ប្រាកដដល់ខ្ញុំ ដូចជាស្ទឹងដ៏ធំដែលហូរចេញអំពីភ្នំ" ដូច្នេះ, ភិក្ខុដទៃទៀត ឆ្លើយថា "(និមិត្តនេះ) រមែងប្រាកដដល់ខ្ញុំ ដូចជាជួរព្រៃមួយ" ដូច្នេះ, ភិក្ខុមួយរូបទៀត ឆ្លើយថា "(និមិត្តនេះ) ប្រាកដដល់ខ្ញុំ ដូចជាដើមឈើ ដែលពេញហើយ ដោយទម្ងន់នៃផ្លែ ដែលបរិបូរទៅដោយមែក មានម្លប់ដ៏ត្រជាក់" ដូច្នេះ ។ មែនពិត ព្រះសូត្រនោះ តែមួយគត់ រមែងប្រាកដ ដល់ភិក្ខុទាំងឡាយនោះផ្សេងគ្នា ព្រោះភិក្ខុទាំងនោះមានសញ្ញាផ្សេងគ្នា យ៉ាងដូច្នោះ ។ ព្រោះថា កម្មដ្ឋាននេះ កើតអំពីសញ្ញា មានសញ្ញាជាហេតុ មានសញ្ញាជាដែនកើត ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា "រមែងប្រាកដ ដោយសេចក្តីផ្សេងគ្នា ព្រោះភាវៈនៃព្រះយោគីទាំងនោះ មានសញ្ញាផ្សេងគ្នា" ដូច្នេះឯង ។

(រឿងធម៌ ៣ ប្រការ)

ក៏ក្នុងកម្មដ្ឋាននេះ ចិត្ត ដែលមានខ្យល់ដង្ហើមចេញជាអារម្មណ៍ ជាចិត្តមួយ ចិត្ត ដែលមានខ្យល់ដង្ហើមចូលជាអារម្មណ៍ ជាចិត្តមួយ ចិត្ត ដែលមាននិមិត្តជាអារម្មណ៍ ក៏ជាចិត្តមួយដែរ ។ មែនពិត ធម៌ទាំងឡាយបីនេះ មិនមានដល់បុគ្គលណា កម្មដ្ឋាន នៃបុគ្គលនោះ រមែងមិនដល់នូវអប្បនាផង នូវឧបចារៈផង ។ ប៉ុន្តែធម៌ទាំងបីនេះ មានដល់បុគ្គលណា កម្មដ្ឋាន នៃបុគ្គលនោះឯង រមែងដល់នូវអប្បនាផង នូវឧបចារៈផង ។

សមដូចពាក្យដែលព្រះសារីបុត្រពោល (ក្នុងបដិសម្ភិទាមគ្គ) ថា

និមិត្ត ខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល ពុំមែន
ជាអារម្មណ៍ របស់ចិត្តតែមួយទេ តែថា កាលភិក្ខុមិន
ដឹងនូវធម៌ទាំងឡាយ ៣ ភាវនា រមែងមិនបានសំរេច,
និមិត្ត ខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល មិន
មែនជាអារម្មណ៍ របស់ចិត្តតែមួយទេ តែថា កាលភិក្ខុ
ដឹងនូវធម៌ទាំងឡាយបី ភាវនា រមែងបានសំរេច [១] ។

(និមិត្តប្រាកដហើយដោយធ្វើយ៉ាងណា)

(១៧១) ព្រះទីឃភាណាចារ្យទាំងឡាយ ពោលហើយ យ៉ាងនេះថា : ក៏កាលនិមិត្ត ប្រាកដហើយ យ៉ាងដូច្នេះ ភិក្ខុនោះ គប្បីទៅកាន់សំណាក់នៃអាចារ្យ ហើយប្រាប់ថា "បពិត្រលោកដ៏ចំរើន អារម្មណ៍មានសភាពបែបនេះ រមែងប្រាកដ ដល់ខ្ញុំ" ។ ចំណែកអាចារ្យ គប្បីប្រាប់ថា "នុ៎ះគឺជានិមិត្ត" ឬថា "នុ៎ះមិនមែនជានិមិត្ត" ដូច្នេះទេ ភិក្ខុនោះត្រូវអាចារ្យប្រាប់ថា "ម្នាលអាវុសោ ហេតុនោះ មានយ៉ាងនេះឯង" ហើយពោលថា "អ្នកចូរធ្វើទុកក្នុងចិត្ត យ៉ាងនេះរឿយៗ ចុះ" ។ ព្រោះថា កាលអាចារ្យពោលថា "ជានិមិត្ត" ដូច្នេះ ភិក្ខុនោះ រមែងដល់នូវទីបញ្ចប់ ។ កាលអាចារ្យ ពោលថា "មិនមែនជានិមិត្តទេ" ដូច្នេះ ភិក្ខុនោះ ក៏អស់សេចក្ដីសង្ឃឹម គប្បីសោះអង្គើយ ព្រោះហេតុនោះ ភិក្ខុនោះ គឺអាចារ្យមិនត្រូវប្រាប់ទាំងពីរយ៉ាងឡើយ គ្រាន់តែប្រកបក្នុងមនសិការប៉ុណ្ណោះ ។

ចំណែកព្រះមជ្ឈិមភាណកាចារ្យទាំងឡាយ ពោលថា "ភិក្ខុនោះគឺអាចារ្យគប្បីពោលថា : ម្នាលអាវុសោ នេះជានិមិត្ត នៃសប្បុរស អ្នក

១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ១០៤ ។

ចូរធ្វើទុកក្នុងចិត្ត នូវកម្មដ្ឋានរឿយៗ" ។

លំដាប់នោះ ព្រះយោគីនេះ គប្បីតំកល់ចិត្ត ក្នុងនិមិត្តហ្នឹងឯង ។ ភាវនា រមែងសំរេច ដល់ព្រះយោគីនោះ ដោយអំណាចនៃឋបនា ចាប់ដើមអំពីបដិភាគនិមិត្តនេះទៅ យ៉ាងនេះឯង ។ សមដូចព្រះបុរាណាចារ្យទាំងឡាយ ពោលថា :

អ្នកមានប្រាជ្ញា កាលបញ្ឈប់នូវចិត្ត ក្នុងនិមិត្ត ធ្វើឲ្យ
ជាក់ច្បាស់ នូវអាការៈផ្សេងៗ ឈ្មោះថា ចងក្រៀកទុក
នូវចិត្ត របស់ខ្លួន ក្នុងខ្យល់អស្សាសបស្សាសៈ ។

ចាប់ដើមអំពីការប្រាកដនៃនិមិត្តយ៉ាងនេះ នីវរណធម៌ទាំងឡាយជាធម្មជាត គឺភិក្ខុនោះ គ្របសង្កត់ហើយមែនពិត កិលេសទាំងឡាយស្ងប់ស្ងៀមហើយ សតិជាធម្មជាតប្រាកដពិត ចិត្តក៏តំកល់នៅមាំ ដោយឧបចារសមាធិពិតមែន ។

លំដាប់នោះ និមិត្តនោះ ព្រះយោគីនេះ មិនគប្បីធ្វើទុកក្នុងចិត្តដោយពណ៌ មិនគប្បីពិចារណា ដោយលក្ខណៈទេ ។ ក៏ប៉ុន្តែព្រះយោគីគប្បីវៀរ នូវអសប្បាយទាំង ៧ មានអាវាសជាដើម ហើយសេពនូវសប្បាយទាំង ៧ នោះឯង គប្បីរក្សាឲ្យបានល្អ ដូចជាព្រះខត្តិយមហេសីថែរក្សានូវគភ៌នៃស្ដេចចក្រពត្តិ និង ដូចជាអ្នកស្រែថែរក្សាកំផើមនៃស្រូវសាលី និង ស្រូវដំណើប ដូច្នោះឯង ។ បន្ទាប់មក លុះព្រះយោគីរក្សានូវនិមិត្តនោះ យ៉ាងនេះហើយ គប្បីធ្វើឲ្យដល់ នូវសេចក្ដីចំរើនទូលំទូលាយ ដោយអំណាចនៃកិរិយាធ្វើទុកក្នុងចិត្ត ជារឿយៗ ហើយញុំាងអប្បនាកោសល្ល ១០ យ៉ាង ឲ្យដល់ព្រម ហើយប្រកបសេចក្ដីព្យាយាម

ឲ្យបានប្រពៃ ។ កាលព្រះយោគីនោះព្យាយាមយ៉ាងនេះ ចតុក្កជ្ឈាន និង បញ្ចកជ្ឈាន រមែងកើតឡើង ក្នុងនិមិត្តនោះ តាមលំដាប់នៃពាក្យដែលយើងពោលហើយ ក្នុងបឋវីកសិណាហ្នឹងឯង ។

(វិធីចំរើនវិបស្សនា គ)

(កំណត់នាមរូប)

(១៧២) ក៏ភិក្ខុ អ្នកមានចតុក្កជ្ឈាន និង បញ្ចកជ្ឈាន កើតហើយយ៉ាងនេះ ជាអ្នកប្រាថ្នាដើម្បីចំរើនកម្មដ្ឋាន ដោយអំណាចនៃសល្លក្ខណា និង វិវដ្ដនា ហើយដល់នូវសេចក្ដីបរិសុទ្ធិ ក្នុងអានាបានស្សតិភាវនានេះ រមែងធ្វើឈាននោះឯង ឲ្យដល់នូវភាពស្ទាត់ ដោយអាការៈទាំងឡាយ ៥ យ៉ាងស្ទាត់ជំនាញ កំណត់នូវនាមរូបហើយ តាំងផ្ដើមនូវវិបស្សនា ។ សួរថា : តើតាំងផ្ដើមដូចម្ដេច ។ ឆ្លើយថា: ដ្បិតថា ព្រះយោគាវចរភិក្ខុនោះ ចេញចាកពីសមាបត្តិហើយ រមែងឃើញថា ករជកាយ និង ចិត្ត ជាដែនកើតឡើង នៃខ្យល់អស្សាសបស្សាសៈទាំងឡាយ ។ ដូចជាកាលស្នប់នៃជាងមាស គឺបុគ្គលសប់ ខ្យល់ដែលអាស្រ័យនូវស្នប់ផង នូវសេចក្ដីព្យាយាម ដ៏សមគួរដល់ស្នប់នោះ នៃបុរសផង រមែងសញ្ចរទៅយ៉ាងណាមិញ ខ្យល់អស្សាសបស្សាសៈទាំងឡាយ អាស្រ័យនូវកាយ និង ចិត្ត ក៏យ៉ាងនោះដែរ ។ តអំពីនោះមក ព្រះយោគី កំណត់នូវខ្យល់អស្សាសបស្សាសៈទាំងឡាយ នូវកាយផង ថា ជារូប នូវចិត្តផង នូវធម៌ដែលសម្បយុត្ត ដោយចិត្តនោះផង ថា ជាអរូប ។ នេះជាសេចក្ដីសង្ខេប ក្នុងការកំណត់នាមរូបទុំះ ។ ចំណែកឯការកំណត់នាមនិងរូបនឹងមានប្រាកដ ខាងមុខ ដោយសេចក្ដីពិស្ដារ ។

ព្រះយោគីលុះកំណត់នាមនិងរូបយ៉ាងនេះហើយ ស្វែងរកបច្ច័យ

នៃនាមនិងរូបនោះ ។ ក៏ព្រះយោគី កាលស្វែងរក ឃើញនាមនិងរូបនោះហើយប្រារព្ធ នូវកិរិយាប្រព្រឹត្តិទៅ នៃនាមនិងរូប ក្នុងកាលទាំងឡាយបីហើយ ឆ្លងនូវសេចក្ដីសង្ស័យ ជាអ្នកមានសេចក្ដីសង្ស័យឆ្លងផុតហើយ លើកឡើង(នូវនាមរូប) កាន់ត្រៃលក្ខណ៍ ដោយអំណាចនៃការពិចារណានូវកលាប(បាច់) ហើយលះបង់ នូវវិបស្សនូបក្កិលេសទាំង ១០ មានឱភាសជាដើម ដែលកើតឡើង ក្នុងបុព្វភាគ នៃឧទយព្វយានុបស្សនា (កិរិយាពិចារណាឃើញនូវការកើត និង ការរលត់) ហើយកំណត់ នូវបដិបទាញាណ ដែលផុតហើយ ចាកឧបក្កិលេសទាំងឡាយ ថា ជាមគ្គហើយ លះបង់នូវការកើតឡើង សម្រេចដល់ភង្គានុបស្សនា (កិរិយាពិចារណាឃើញនូវការបែកធ្លាយ) ហើយក៏នឿយណាយ ធុញទ្រាន់ ក្នុងសង្ខារទាំងពួង ដែលប្រាកដឡើងដោយភាពគួរភ័យខ្លាច ដោយអំណាចនៃភង្គានុបស្សនា មិនមានចន្លោះ រួចស្រឡះ ដល់នូវអរិយមគ្គ ៤ តាមលំដាប់យ៉ាងណា តាំងនៅស៊ប់ ក្នុងអរហត្តផល ដល់ហើយនូវទីបំផុតនៃបច្ចវេក្ខណញ្ញាណ ១៩ ប្រភេទ ជាអគ្គទក្ខិណេយ្យ នៃលោក ព្រមទាំងទេវលោក ។

ក៏ការចំរើនអានាបានស្សតិសមាធិ នៃព្រះយោគីនោះ ដែលធ្វើការរាប់ជាខាងដើម មានបដិបស្សនាជាទីបំផុត ជាធម្មជាតចប់ស្រេចហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ នេះជាការពណ៌នា នូវចតុក្កៈ ទី១ ដោយអាការៈទាំងពួង ។

(១៧៣) ចំណែកក្នុងចតុក្កៈទាំងបីក្រៅនេះ ឈ្មោះថាន័យ នៃការចំរើនកម្មដ្ឋានផ្សេងមិនមាន ព្រោះហេតុណា ព្រោះហេតុនោះ គប្បីជ្រាបសេចក្ដីនៃចតុក្កៈទាំងនោះឯង តាមន័យនៃការពណ៌នាអនុបទហ្នឹងឯង ។

(ការពណ៌នាចតុក្កៈទី២)

បទថា “បីតិប្បដិសំវេទី” សេចក្ដីថា ភិក្ខុសិក្សាថា អាត្មាអញកាលធ្វើនូវបីតិឲ្យជាបីតិគឺខ្លួនដឹងច្បាស់ហើយ គឺធ្វើឲ្យប្រាកដ ដកដង្ហើមចេញ ដកដង្ហើមចូល ។ ត្រង់បទថា “បីតិប្បដិសំវេទី” នោះមានសេចក្ដីថា បីតិ ជាធម្មជាតគឺភិក្ខុដឹងច្បាស់ហើយ ដោយអាការៈទាំងឡាយ ២ គឺដោយអារម្មណ៍ ១ ដោយអសម្មោហៈ ១ ។ សួរថា បីតិ ជាធម្មជាតគឺភិក្ខុដឹងច្បាស់ហើយ ដោយអារម្មណ៍ តើដូចម្ដេច ។ ឆ្លើយថា ភិក្ខុចូលឈាន ២ ដែលមានបីតិ ព្រោះកិរិយាបាននូវឈាន បីតិ ជាធម្មជាតគឺភិក្ខុនោះដឹងច្បាស់ហើយ ដោយអារម្មណ៍ ព្រោះភាវៈនៃអារម្មណ៍ ជាធម្មជាត គឺភិក្ខុនោះ ដឹងច្បាស់ហើយ ក្នុងខណៈដែលចូលសមាបត្តិ ។ សួរថា បីតិ ជាធម្មជាត គឺភិក្ខុនោះដឹងច្បាស់ហើយ ដោយអសម្មោហៈ តើដូចម្ដេច ។ ឆ្លើយថា ភិក្ខុចូលឈាន ២ ដែលមានបីតិ ចេញហើយពិចារណានូវបីតិ ដែលសម្បយុត្តដោយឈាន ដោយសេចក្ដីអស់ទៅ ដោយសេចក្ដីសូន្យទៅ បីតិ ជាបីតិ គឺភិក្ខុនោះ ដឹងច្បាស់ហើយ ដោយអសម្មោហៈ ព្រោះកិរិយាចាក់ធ្លុះនូវលក្ខណៈ ក្នុងខណៈនៃវិបស្សនា ។ សមដូចជាព្រះសារីបុត្រពោលហើយ ក្នុងបដិសម្ភិទាមគ្គ ថា : កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សតិ ក៏តម្កល់មាំ បីតិនោះ ឈ្មោះថា ភិក្ខុដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង...ដោយអំណាចនៃដង្ហើមចេញខ្លី...ដោយអំណាចនៃដង្ហើមចូលខ្លី... ដោយអំណាចនៃដង្ហើមចេញ និង ដង្ហើមចូល

របស់អ្នកកំណត់ដឹង នូវកាយទាំងពួង... ដោយអំណាចនៃភាពជាអ្នករម្ងាប់នូវកាយសង្ខារ ដកដង្ហើមចេញ និង ដកដង្ហើមចូល សតិក៏តម្កល់មាំ បីតិនោះ ឈ្មោះថា ភិក្ខុ ដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលភិក្ខុរំពឹង បីតិនោះ ឈ្មោះថា គឺភិក្ខុនោះ ដឹងច្បាស់ហើយ កាលភិក្ខុនោះដឹង... កាលឃើញ... កាលពិចារណា... កាលអធិដ្ឋាននូវចិត្ត...កាលជឿស៊ប់ដោយសទ្ធា...កាលផ្គងសេចក្ដីព្យាយាម... កាលប្រុងទុកនូវសតិ... កាលតម្កល់នូវចិត្ត... កាលដឹងច្បាស់ ដោយបញ្ញា... កាលត្រាស់ដឹង នូវធម៌ដែលគួរត្រាស់ដឹង... កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង... កាលលះនូវធម៌ដែលគួរលះ... កាលចំរើននូវធម៌ដែលគួរចំរើន... កាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់, បីតិនោះ ឈ្មោះថា ភិក្ខុនោះ ដឹងច្បាស់ហើយ, បីតិនោះ ឈ្មោះថា គឺភិក្ខុនោះ ដឹងច្បាស់ហើយ យ៉ាងដូច្នេះឯង [១] ។

សូម្បីបទដ៏សេសទាំងឡាយ ក៏បណ្ឌិតគប្បីជ្រាប ដោយសេចក្ដីតាមន័យនេះឯង ។ តែនេះគ្រាន់តែជាសេចក្ដីប្លែកគ្នាត្រង់បទនេះ ។ ភាពនៃព្រះយោគីជាអ្នកដឹងច្បាស់នូវសុខ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃឈានទាំងឡាយ ៣ ភាពនៃព្រះយោគីជាអ្នកដឹងច្បាស់ នូវចិត្តសង្ខារ បណ្ឌិតគប្បីជ្រាប ដោយអំណាចឈានទាំងឡាយ ៤ ។ ខន្ធទាំងឡាយ ២ មានវេទនាជាដើម ឈ្មោះថា ចិត្តសង្ខារ ។ ក៏ក្នុងបទថា សុខប្បដិសំវេទី នេះ ព្រះសារីបុត្រពោលហើយ ក្នុងបដិសម្ភិទាថា : ពាក្យថា “សុខ” បានដល់ សុខ ២ យ៉ាង គឺកាយិកសុខ ១ ចេតសិកសុខ ១ ដើម្បីសំដែងនូវវិបស្សនាភូមិ ។

១- សុ. ខុ. បដិ. ភាគទី ៧០ ទំព័រទី ១៥១ ។

បទថា “បស្សម្ភយំ ចិត្តសង្ខារំ” សេចក្តីថា កាលរម្ងាប់ គឺកាលរំលត់នូវចិត្តសង្ខារ ដែលគ្រោតគ្រាត ៗ ។ បណ្ឌិតគប្បីជ្រាបសេចក្តីរលត់នូវចិត្តសង្ខារនោះ ដោយសេចក្តីពិស្តារ តាមន័យដែលលោកបានពោលហើយ ក្នុងកាយសង្ខារហ្នឹងឯង ។ មួយទៀត បណ្តាបទទាំងនោះ ក្នុងបទថា បីតិ លោកពោលវេទនា ដោយប្រធានគឺបីតិ ត្រង់បទថា សុខ លោកពោលវេទនា ដោយរូបរបស់ខ្លួនហ្នឹងឯង ក្នុងបទថា ចិត្តសង្ខារទាំង ២ លោកពោលវេទនា ដែលប្រកបព្រមហើយ ដោយសញ្ញា ព្រោះបាឡីថា “សញ្ញា និង វេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះជាប់ចំពោះដោយចិត្ត ឈ្មោះថា ចិត្តសង្ខារ” ដូច្នេះឯង ។

បណ្ឌិតគប្បីជ្រាបថា ចតុក្កៈនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ តាមន័យនៃវេទនានុបស្សនា យ៉ាងនេះឯង ។

(ចតុក្កៈទី៣)

(១៧៤) សូម្បីក្នុងចតុក្កៈ ទី៣ បណ្ឌិត គប្បីជ្រាបភាព នៃព្រះយោគីជាអ្នកដឹងច្បាស់នូវចិត្ត ដោយអំណាចនៃឈានទាំងឡាយ ៤ ។ ពីរបទថា “អភិប្បមោទយំ ចិត្តំ” សេចក្តីថា ភិក្ខុសិក្សាថា អាត្មាអញកាលញ៉ាំងចិត្តឲ្យរីករាយ ឲ្យរីករាយទូទៅ ឲ្យស្រស់ស្រាយ ឲ្យស្រស់ស្រាយទូទៅនឹងដកដង្ហើមចេញ នឹងដកដង្ហើមចូល ។ ត្រង់បទថា “អភិប្បមោទយំ ចិត្តំ” នោះ សេចក្តីត្រេកអរដ៏ក្រៃលែង តែងមាន ដោយអាការៈ ២ យ៉ាង គឺ ដោយអំណាចនៃសមាធិ ១ ដោយអំណាច នៃវិបស្សនា ១ ។ សួរថា សេចក្តីត្រេកអរដ៏ក្រៃលែង ដោយអំណាចនៃសមាធិ តើយ៉ាងដូចម្តេច ។ ឆ្លើយថា ភិក្ខុចូលឈាន ២ ដែលមានបីតិ ភិក្ខុនោះ ញ៉ាំងចិត្តឲ្យរីករាយ ឲ្យរីករាយទូទៅ ដោយបីតិ ដែលជា

សម្បយុត្តធម៌ ក្នុងខណៈដែលចូលសមាបត្តិ ។ សួរថា : សេចក្តីត្រេកអរដ៏ក្រៃលែង ដោយអំណាចនៃវិបស្សនា តើដូចម្តេច ។ ឆ្លើយថា ភិក្ខុ ចូលឈាន ២ ដែលមានបីតិ ចេញហើយ ពិចារណាបីតិ ដែលសម្បយុត្តដោយឈាន ដោយសេចក្តីអស់ទៅ ដោយសេចក្តីសូន្យទៅ ភិក្ខុនោះ ធ្វើបីតិដែលសម្បយុត្តហើយដោយឈានឲ្យជាអារម្មណ៍ ញ៉ាំងចិត្តឲ្យរីករាយ ឲ្យរីករាយទូទៅ ក្នុងខណៈនៃវិបស្សនា យ៉ាងនេះឯង ។

ព្រះយោគីអ្នកប្រតិបត្តិយ៉ាងនេះ លោកហៅថា សិក្សាថា អាត្មាអញ នឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ដកដង្ហើមចេញ ដកដង្ហើមចូល។

បទពីរថា “សមាទហំ ចិត្តំ” សេចក្តីថា ព្រះយោគី កាលតំកល់នូវចិត្តឲ្យស្មើ គឺ តាំងចិត្តឲ្យស្មើ ក្នុងអារម្មណ៍ ដោយអំណាចនៃឈានមានបឋមជ្ឈានជាដើម ឬពុំនោះសោត ចូលឈានទាំងនោះហើយ ក៏ចេញ ហើយពិចារណានូវចិត្តដែលសម្បយុត្តហើយដោយឈាន ដោយសេចក្តីអស់ទៅ ដោយសេចក្តីសូន្យទៅ ភាពនៃចិត្តប្រព្រឹត្តទៅ ក្នុងខណៈជាចិត្តមានអារម្មណ៍តែមួយ រមែងកើតឡើង ដោយការចាក់ធ្លុះនូវលក្ខណៈ ក្នុងខណៈនៃវិបស្សនា ភិក្ខុតំកល់ចិត្តឲ្យស្មើ គឺតាំងចិត្តឲ្យស្មើក្នុងអារម្មណ៍ ដោយអំណាចនៃខណិកចិត្តេកគ្គតា ដែលកើតឡើងហើយយ៉ាងនេះ លោកហៅថា សិក្សាថា អាត្មាអញ នឹងតំកល់ចិត្ត ឲ្យនឹងដកដង្ហើមចេញ ដកដង្ហើមចូល ។

បទពីរថា “វិមោចយំ ចិត្តំ” សេចក្តីថា ព្រះយោគី កាលញ៉ាំងចិត្តឲ្យរួច ឲ្យរួចស្រឡះ ចាកនីវរណៈទាំងឡាយ ដោយបឋមជ្ឈាន កាលញ៉ាំងចិត្តឲ្យរួច ឲ្យរួចស្រឡះ ចាកវិតក្កៈ និង វិចារៈទាំងឡាយ ដោយទុតិយជ្ឈាន កាលញ៉ាំងចិត្តឲ្យរួច ឲ្យរួចស្រឡះ ចាកបីតិ ដោយ

តតិយជ្ឈាន កាលញ៉ាំងចិត្តឲ្យរួច ឲ្យរួចស្រឡះ ចាកសុខ និង ទុក្ខទាំងឡាយ ដោយចតុត្ថជ្ឈាន ម្យ៉ាងទៀត ព្រះយោគី ចូលឈានទាំងឡាយនោះ ចេញហើយ ក៏ពិចារណានូវចិត្តដែលសម្បយុត្តហើយដោយឈាន ដោយសេចក្ដីអស់ទៅ ដោយសេចក្ដីសូន្យទៅ ព្រះយោគីនោះ ធ្វើចិត្តឲ្យរួច ឲ្យរួចស្រឡះ ចាកនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ក្នុងខណៈនៃវិបស្សនា ធ្វើចិត្តឲ្យរួច ឲ្យរួចស្រឡះ ចាកសុខសញ្ញា ដោយទុក្ខានុបស្សនា... ចាកអត្តសញ្ញា ដោយអនត្តានុបស្សនា... ចាកសេចក្ដីត្រេកត្រអាល ដោយនិព្វិទានុបស្សនា... ចាករាគៈ ដោយវិរាគានុបស្សនា... ចាកសមុទយៈ ដោយនិរោធានុបស្សនា... ចាកអាទានៈ(សេចក្ដីប្រកាន់) ដោយបដិនិស្សគ្គានុបស្សនា ដកដង្ហើមចេញ និង ដកដង្ហើមចូល ។ ព្រោះហេតុនោះ ទើបលោកពោលថា សិក្ខាថា អាត្មាអញ នឹងធ្វើចិត្តឲ្យរួច ដកដង្ហើមចេញ ដកដង្ហើមចូល ។

បណ្ឌិតគប្បីជ្រាបចតុក្កៈនេះ ថា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអំណាចនៃចិត្តានុបស្សនា យ៉ាងដូច្នេះឯង ។

(ចតុក្កៈទី៤)

(អនិច្ចានុបស្សី)

(១៧៥) ចំណែកក្នុងចតុក្កៈ ទី៤ មានសេចក្ដីវិនិច្ឆ័យថា ក្នុងបទថា "អនិច្ចានុបស្សី" នោះ បណ្ឌិតគប្បីជ្រាប អនិច្ចំ (របស់មិនទៀង) គប្បីជ្រាបអនិច្ចតា (ភាពជារបស់មិនទៀង) គប្បីជ្រាបអនិច្ចានុបស្សនា (ការពិចារណាឃើញថាមិនទៀង) គប្បីជ្រាបអនិច្ចានុបស្សី (អ្នកដែលពិចារណាឃើញថាជារបស់មិនទៀង) ជាមុន ។

ក្នុង ៤ បទ នោះ បទថា "អនិច្ចំ" បានដល់ ខន្ធប្រាំ ។ សួរថា

ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះភាវៈនៃខន្ធប្រាំនោះ មានការកើតឡើង អស់សូន្យទៅ និង ជារបស់ដទៃ ។ បទថា "អនិច្ចតា" បានដល់ភាពនៃបញ្ចក្ខន្ធទាំងនោះឯងមានការកើតឡើង អស់សូន្យទៅ និង ជារបស់ដទៃ ឬថា ភាពនៃបញ្ចក្ខន្ធទាំងនោះ មានហើយ បែរទៅជាមិនមានទៅវិញ ។ អធិប្បាយថា អនិច្ចតា ក៏គឺភាពនៃបញ្ចក្ខន្ធទាំងឡាយនោះ ដែលកើតឡើងហើយ មិនតាំងនៅ ដោយអាការៈនោះឯង ហើយបែកធ្លាយ ដោយការបែកធ្លាយគ្រប់ខណៈ ។ បទថា "អនិច្ចានុបស្សនា" គឺការពិចារណាឃើញថា មិនទៀង ក្នុងខន្ធទាំងឡាយ មានរូបជាដើម ដោយអំណាចនៃអនិច្ចតានោះ ។ បទថា "អនិច្ចានុបស្សី" បានដល់ព្រះយោគីអ្នកប្រកបព្រម ដោយការពិចារណាឃើញនោះ ។ ព្រោះហេតុនោះ ភិក្ខុជាអ្នកយ៉ាងដូច្នេះហើយ កាលដកដង្ហើមចេញ ដកដង្ហើមចូល បណ្ឌិតគប្បីជ្រាប ថា ឈ្មោះថា សិក្ខាថា អាត្មាអញ ជាអ្នកពិចារណាឃើញថាមិនទៀង នឹងដកដង្ហើមចេញ នឹងដកដង្ហើមចូល ក្នុងទីនេះ ។

(វិរាគានុបស្សី និរោធានុបស្សី)

ចំណែកក្នុងបទថា "វិរាគានុបស្សី" នេះ វិរាគៈ (ការប្រាសចាកតម្រេក) មាន ២ យ៉ាង គឺខយវិរាគៈ ១ អច្ចន្តវិរាគៈ ១ ។ បណ្ដាវិរាគៈទាំង ២ នោះ ការបែកធ្លាយគ្រប់ខណៈ នៃសង្ខារទាំងឡាយ ឈ្មោះថា ខណវិរាគៈ ។ ព្រះនិព្វាន ឈ្មោះថា អច្ចន្តវិរាគៈ ។ វិបស្សនា និង មគ្គដែលប្រព្រឹត្តទៅ ដោយអំណាចនៃវិរាគៈទាំង ២ នោះ ឈ្មោះថា វិរាគានុបស្សនា ។ ព្រះយោគីជាអ្នកប្រកបព្រម ដោយអនុបស្សនាទាំង ២ នោះឯង កាលដកដង្ហើមចេញ ដកដង្ហើមចូល បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា សិក្ខាថា អាត្មាអញ នឹងជាអ្នកពិចារណាឃើញការប្រាស

ចាកតម្រេក ដកដង្ហើមចេញ ដកដង្ហើមចូល ។ ន័យ សូម្បីក្នុងបទថា “និរោធានុបស្សី” ក៏ន័យដូចគ្នានេះដែរ ។

(បដិនិស្សគ្គានុបស្សី)

សូម្បីក្នុងបទថា “បដិនិស្សគ្គានុបស្សី” នេះ បដិនិស្សគ្គៈ (ការលះបង់) មាន ២ គឺ បរិច្ចាគប្បដិនិស្សគ្គៈ (បដិនិស្សគ្គៈ គឺការលះបង់)១ បក្ខន្ទនប្បដិនិស្សគ្គៈ(បដិនិស្សគ្គៈគឺការស្ទុះទៅ)១ ។ អនុបស្សនា គឺបដិនិស្សគ្គៈ ឈ្មោះថាបដិនិស្សគ្គានុបស្សនា ។ ពាក្យថា បដិនិស្សគ្គានុបស្សនា នេះ ជាឈ្មោះ នៃវិបស្សនា និង មគ្គ ទាំងឡាយ ។ មែនពិត វិបស្សនា រមែងលះបង់ នូវកិលេសទាំងឡាយ ព្រមទាំងខន្ធ និង អភិសង្ខារទាំងឡាយ ដោយអំណាចនៃតទង្គប្បហានៈ ថែមទាំង រមែងស្ទុះទៅ ក្នុងព្រះនិព្វាន ដែលផ្ទុយគ្នានឹងកិលេសនោះ ព្រោះភាវៈនៃវិបស្សនាឱនទៅ ក្នុងផ្លូវនោះ ដោយកិរិយាឃើញនូវទោស ក្នុងសង្ខតធម៌ ព្រោះហេតុដូច្នោះ ទើបលោកហៅថា (បដិនិស្សគ្គៈ មាន ២ គឺ) បរិច្ចាគប្បដិនិស្សគ្គៈ ១ បក្ខន្ទនប្បដិនិស្សគ្គៈ ១ ។ ចំណែកមគ្គ រមែងលះបង់ នូវកិលេសទាំងឡាយ ព្រមទាំងខន្ធ និង អភិសង្ខារទាំងឡាយ ដោយអំណាចនៃសមុច្ឆេទប្បហានៈ ថែមទាំង រមែងស្ទុះទៅ ក្នុងព្រះនិព្វាន ដោយកិរិយាធ្វើ (នូវព្រះនិព្វាន) ឲ្យជាអារម្មណ៍ ព្រោះហេតុដូច្នោះ ទើបលោកហៅថា (បដិនិស្សគ្គៈ មាន ២ គឺ) បរិច្ចាគប្បដិនិស្សគ្គៈ ១ បក្ខន្ទនប្បដិនិស្សគ្គៈ ១ ។ ក៏វិបស្សនាញាណ និង មគ្គញ្ញាណទាំង ២ នេះ លោកហៅថា អនុបស្សនា ព្រោះកិរិយាឃើញរឿយៗ នូវញាណ មានក្នុងខាងមុនៗ ទាំងឡាយ ។ ព្រះយោគីជាអ្នកប្រកបព្រម ដោយបដិនិស្សគ្គានុបស្សនា ទាំង ២ យ៉ាងនោះ កាលដកដង្ហើមចេញ និង កាល

ដកដង្ហើមចូល បណ្ឌិតគប្បីជ្រាបថា សិក្សាថា អាត្មាអញ នឹងជាអ្នកពិចារណាឃើញរឿយៗ នូវកិរិយារលាស់ចោល ដកដង្ហើមចេញ ដកដង្ហើមចូល ។

ចតុក្កៈ ទី ៤ នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអំណាចនៃវិបស្សនាសុទ្ធ ហ្នឹងឯង ។ ចំណែក ចតុក្កៈទាំង ៣ មានក្នុងខាងមុន ព្រះមានព្រះភាគទ្រង់ត្រាស់ហើយដោយអំណាចនៃសមថៈ និង វិបស្សនា ។

(១៧៦) ការចំរើននូវអានាបានស្សតិ មានវត្ថុ ១៦ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃចតុក្កៈទាំង ៤ ដូចបានពណ៌នាមកនេះឯង ។ ក៏អានាបានស្សតិនេះ (ដែលភិក្ខុបានចំរើនហើយ) ដោយអំណាចនៃវត្ថុ ១៦ យ៉ាងនេះ ទើបមានផលច្រើន មានអានិសង្សច្រើន ។

(អានិសង្សអានាបានស្សតិ)

ក្នុងអានិសង្សនៃអានាបានស្សតិនោះ មានពណ៌នាថា បណ្ឌិតគប្បីជ្រាបភាវៈនៃអានាបានស្សតិនោះ ជាធម្មជាតិ មានអានិសង្សច្រើន សូម្បីដោយអំណាចនៃធម៌ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរ មានភាពជាធម៌ដ៏ល្អិតជាដើម ព្រោះព្រះបាឡីថា “ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះឯង ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ ជាធម៌ដ៏ល្អិតផង ជាធម៌ដ៏ប្រណីតផង” ព្រោះភាវៈជាធម៌អាចក្នុងការកាត់ផ្តាច់នូវវិតក្កៈ ។ មែនពិត អានាបានស្សតិសមាធិនេះ ព្រោះជាធម៌ដ៏ល្អិត ប្រណីត ជាធម៌ជាគ្រឿងនៅមិនប្រឡូកប្រឡំ និង ជាសុខ ទើបកាត់ផ្តាច់នូវការស្ទុះទៅនៃចិត្ត ខាងនេះផង ខាងនោះផង ដោយអំណាចនៃវិតក្កៈទាំងឡាយ ដែលធ្វើសេចក្តីអន្តរាយ ដល់សមាធិ

ហើយធ្វើចិត្តឲ្យមានមុខឆ្ពោះទៅរកអារម្មណ៍ គឺខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូល តែប៉ុណ្ណោះ ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា “អានាបានស្សតិ គឺភិក្ខុគប្បីចំរើន ដើម្បីចូលទៅកាត់ផ្តាច់នូវវិតក្កៈ” ដូច្នេះ ។

មួយទៀត បណ្ឌិតគប្បីជ្រាបភាពនៃអានាបានស្សតិនោះ មានអានិសង្សច្រើន សូម្បីដោយភាពជាមូលនៃការបំពេញនូវវិជ្ជា និង វិមុត្តិឲ្យបរិបូរ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា “ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យរឿយៗ ហើយ រមែងញ៉ាំងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌បាន ។ សតិប្បដ្ឋាន ៤ ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យរឿយៗ ហើយ រមែងញ៉ាំងសម្ពោជ្ឈង្គៈទាំង ៧ ឲ្យពេញបរិបូណ៌បាន ។ សម្ពោជ្ឈង្គៈទាំងឡាយ ៧ ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យរឿយៗ ហើយ រមែងញ៉ាំងវិជ្ជា និង វិមុត្តិ ឲ្យពេញបរិបូណ៌បាន [១] ” ដូច្នេះ ។

ម្យ៉ាងវិញទៀត ភាវៈនៃអានាបានស្សតិនោះ ជាធម្មជាតិ មានអានិសង្សដ៏ច្រើន បណ្ឌិតគប្បីជ្រាប សូម្បីព្រោះការធ្វើនូវភាវៈ នៃខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូលទាំងឡាយ ដែលមាន ក្នុងទីបំផុត ជាសភាវៈគឺខ្លួនដឹងបាន ។ សមដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា “ម្នាលរាហុល កាលបើអានាបានស្សតិ ដែលបុគ្គលបានចម្រើនហើយយ៉ាងនេះ បានធ្វើឲ្យរឿយៗ ហើយយ៉ាងនេះ ខ្យល់ដង្ហើមចេញ និង ដង្ហើមចូលទាំងឡាយនោះណា ដែលមានក្នុងកាលជាខាងក្រោយ ដង្ហើមចេញ និង ដង្ហើមចូលទាំងនោះឯង នឹងរលត់ទៅវិញជា

១- សុ. ម. ឧ. ភាគទី ២៦ ទំព័រទី ៣៥៩ ។

ប្រាកដ មិនមែនមិនរលត់ទៅវិញទេ [១] ” ដូច្នេះ ។

ក្នុងអានាបានស្សតិនោះ ខ្យល់អស្សាសបស្សាសៈទាំងឡាយ បី គឺ ខ្យល់អស្សាសបស្សាសៈ មានក្នុងទីបំផុតនៃភព ខ្យល់អស្សាស-បស្សាសៈ មានក្នុងទីបំផុតនៃឈាន ខ្យល់អស្សាសបស្សាសៈ មានក្នុងទីបំផុតនៃចុតិ ដោយអំណាចនៃកិរិយារលត់ ។ មែនពិត ខ្យល់អស្សាសបស្សាសៈទាំងឡាយ រមែងប្រព្រឹត្តទៅ ក្នុងកាមភព បណ្តាភពទាំងឡាយ រមែងមិនប្រព្រឹត្តទៅ ក្នុងរូបភព និង អរូបភពទាំងឡាយទេ ព្រោះហេតុនោះ ខ្យល់អស្សាសបស្សាសៈទាំងឡាយនោះ ទើបឈ្មោះថា មានក្នុងទីបំផុតនៃភព ។ ខ្យល់អស្សាសបស្សាសៈទាំងឡាយ រមែងប្រព្រឹត្តទៅ ក្នុងឈាន ៣ មានក្នុងទីបំផុត បណ្តាឈានទាំងឡាយ រមែងមិនប្រព្រឹត្តទៅក្នុងឈានទី៤ ព្រោះហេតុនោះ ខ្យល់អស្សាសបស្សាសៈទាំងឡាយនោះ ទើបឈ្មោះថា មានក្នុងទីបំផុតនៃឈាន ។ ចំណែកខ្យល់អស្សាសបស្សាសៈទាំងឡាយណា កើតឡើងហើយ ជាមួយនឹងចិត្ត ទី១៦ ក្នុងខាងមុន នៃចុតិចិត្ត រមែងរលត់ ជាមួយនឹងចុតិចិត្ត ខ្យល់អស្សាសបស្សាសៈទាំងឡាយនេះ ឈ្មោះថា មានក្នុងទីបំផុតនៃចុតិ ។ ខ្យល់ចុតិចរិមៈទាំងឡាយនេះ ព្រះមានព្រះភាគ ទ្រង់បំណងហើយ ថា “មានក្នុងទីបំផុត” ក្នុងព្រះសូត្រនេះ ។

បានឮថា កាលភិក្ខុអ្នកប្រកបរឿយៗ នូវកម្មដ្ឋាននេះ ពិចារណានូវការកើតឡើង ក្នុងខណៈនៃការកើតឡើងនៃចិត្ត ទី១៦ ក្នុងខាងមុខនៃចុតិចិត្ត ព្រោះភាវៈនៃខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល ដែលភិក្ខុកំណត់ជាអារម្មណ៍ បានល្អប្រពៃហើយ សូម្បីកិរិយាកើតឡើង នៃខ្យល់

១- សុ. ម. ម. ភាគទី ២៣ ទំព័រទី ២៨៤ ។

ទាំងនោះ រមែងប្រាកដ កាលពិចារណានូវកិរិយាតាំងនៅ សូម្បីកិរិយាតាំងនៅនៃខ្យល់ទាំងនោះ រមែងប្រាកដ កាលពិចារណានូវការបែកធ្លាយ សូម្បីការបែកធ្លាយ នៃខ្យល់ទាំងនោះ ក៏រមែងប្រាកដ ។

មែនពិត ភិក្ខុអ្នកចំរើននូវកម្មដ្ឋានដទៃ ក្រៅអំពីអានាបានស្សតិ-កម្មដ្ឋាននេះហើយ សម្រេចនូវព្រះអរហត្ត តែងកំណត់ចន្លោះកាល នៃអាយុបានខ្លះ កំណត់មិនបានខ្លះ ។ ប៉ុន្តែភិក្ខុអ្នកចំរើននូវអានាបានស្សតិមានវត្ថុ ១៦ នេះ ហើយសម្រេចព្រះអរហត្ត តែងកំណត់ចន្លោះកាលនៃអាយុបានទាំងអស់ ។ ភិក្ខុអ្នកចំរើនអានាបានស្សតិ ហើយបានសំរេចនូវព្រះអរហត្តនោះ ដឹងថា "ក្នុងកាលឥឡូវនេះ អាយុសង្ខារ របស់អាត្មាអញ នឹងប្រព្រឹត្តទៅ អស់កាលមានប្រមាណប៉ុណ្ណេះ នឹងមិនប្រព្រឹត្តទៅក្នុងខាងនាយអំពីកាលនេះទេ" ដូច្នេះហើយ ធ្វើនូវកិច្ចទាំងពួងទាំងឡាយមានការជំរះនូវសរីរៈ និង ការស្លៀកពាក់ជាដើម តាមធម្មតារបស់ខ្លួនហ្នឹងឯង ហើយផ្ចង់ភ្នែកទាំងឡាយ ដូចជាព្រះតិស្សត្ថេរ អ្នកអាស្រ័យនៅក្នុងកោដិបព្វតវិហារ ដូចជាព្រះមហាតិស្សត្ថេរ អ្នកអាស្រ័យនៅក្នុងមហាករញ្ជនិយវិហារ ដូចជាព្រះបិណ្ឌបាតិកតិស្សត្ថេរ ក្នុងទេវបុត្តរដ្ឋ និង ដូចជាព្រះភាតិយត្ថេរទាំងពីរព្រះអង្គ អ្នកអាស្រ័យនៅ ក្នុងចិត្តល-បព្វតវិហារ យ៉ាងដូច្នោះឯង ។

នេះជាការសំដែងនូវរឿងមួយ ក្នុងចំណោមរឿងនៃព្រះថេរៈទាំងឡាយនោះ ។ បានឮថា ក្នុងចំណោមព្រះភាតិយត្ថេរទាំងពីរអង្គ ព្រះថេរៈមួយអង្គ សូត្រនូវបាតិមោក្ខ ក្នុងថ្ងៃឧបោសថ មានព្រះច័ន្ទពេញវង់ មានភិក្ខុសង្ឃហែហមហើយ និមន្តទៅកាន់ទីជាទីនៅ របស់ខ្លួន បានឋិតនៅត្រង់ទីចង្ក្រម រមិលមើលនូវពន្លឺនៃព្រះច័ន្ទ ពិចារណានូវអាយុសង្ខារ

របស់ខ្លួន ហើយប្រាប់ភិក្ខុសង្ឃ ថា "តើអ្នកទាំងឡាយ ធ្លាប់ឃើញភិក្ខុដែលបរិនិព្វាន ដោយអាការៈដូចម្ដេចខ្លះដែរ? " ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយពួកខ្លះ បានពោលថា "ពួកខ្ញុំធ្លាប់បានឃើញភិក្ខុទាំងឡាយដែលអង្គុយលើអាសនៈហ្នឹងឯង បរិនិព្វាន" ។ ភិក្ខុពួកខ្លះ បានពោលថា "ពួកខ្ញុំធ្លាប់បានឃើញភិក្ខុទាំងឡាយ ដែលអង្គុយពែនភ្នែន លើអាកាសបរិនិព្វាន" ។ ព្រះថេរៈ ពោលថា "ក្នុងកាលឥឡូវនេះ ខ្ញុំនឹងសំដែងនូវភិក្ខុដែលកំពុងតែចង្ក្រមហ្នឹងឯង បរិនិព្វាន ដល់អ្នកទាំងឡាយ" ។ ក្នុងលំដាប់នោះ ព្រះថេរៈ ធ្វើនូវគំនូស ត្រង់ទីចង្ក្រម ហើយពោលថា "ខ្ញុំនឹងដើរទៅកាន់ទីបំផុតនៃខាងមុខ អំពីទីបំផុតនៃទីចង្ក្រមនេះហើយ កាលត្រឡប់មកវិញ គ្រាន់តែដល់នូវគំនូសនេះភ្លាម នឹងបរិនិព្វាន" យ៉ាងនេះហើយ ក៏ចុះកាន់ទីចង្ក្រម ដើរទៅកាន់ចំណែកខាងនាយ កាលត្រឡប់មកវិញ ក៏បរិនិព្វានហើយ ក្នុងខណៈដែលលោកជាន់នូវគំនូស ដោយជើងម្ខាងភ្លាមហ្នឹងឯង ។

ព្រោះហេតុនោះឯង បណ្ឌិតគប្បីជាអ្នកមិនប្រមាទ
ប្រកបរឿយៗ នូវអានាបានស្សតិ ដែលមានអានិសង្ស
ច្រើន យ៉ាងនេះ សព្វៗកាល យ៉ាងនេះឯង ។

នេះជាកថាមុខ ដោយពិស្ដារ ក្នុងអានាបានស្សតិ ។

(ឧបសមានុស្សតិ)

(១៧៧) ក៏ព្រះយោគីអ្នកប្រាថ្នា ដើម្បីចំរើននូវឧបសមានុស្សតិ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ បន្ទាប់អំពីអានាបានស្សតិ ទៅកាន់ទីស្ងាត់ ចៀសចេញចាកអារម្មណ៍សម្ងំនៅ ត្រូវរលឹករឿយៗ នូវគុណទាំងឡាយ នៃព្រះនិព្វាន ពោលគឺកិរិយាចូលទៅរម្ងាប់ នូវសេចក្តីទុក្ខគ្រប់យ៉ាង យ៉ាងដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ជាសង្ខតធម៌ក្តី ជាអសង្ខតធម៌ក្តី វិរាគធម៌ ប្រាកដជាប្រសើរជាងធម៌ទាំងឡាយនោះ ព្រោះថា វិរាគធម៌នេះ ជាធម៌សម្រាប់បន្ទោបង់នូវសេចក្តីស្រវឹង ជាធម៌កំចាត់បង់នូវសេចក្តីស្រេកឃ្លាន ជាធម៌អាចដកឡើងនូវអាល័យ ជាធម៌ផ្តាច់បង់នូវវដ្តៈ ជាធម៌អស់ទៅនៃតណ្ហា ជាធម៌ប្រាសចាកតម្រេក ជាធម៌រលត់ ជាធម៌មិនមានគ្រឿងចាក់ស្រែះ [១]" ដូច្នេះ ។

(កែអត្ថបាឡី)

ក្នុងបាឋៈទាំងឡាយនោះ ពាក្យថា "មានប្រមាណត្រឹមណា" គឺមានប្រមាណប៉ុណ្ណា ។ ពាក្យថា "ធម៌ទាំងឡាយ" បានដល់សភាវធម៌ទាំងឡាយ ។ ពាក្យថា "ជាសង្ខតៈក្តី ជាអសង្ខតៈក្តី" គឺ ដែលបច្ច័យទាំងឡាយផ្សំប្រជុំគ្នាធ្វើក្តី មិនបានផ្សំប្រជុំគ្នាធ្វើក្តី ។ ពាក្យថា "វិរាគធម៌តថាគតពោលថាជាកំពូលនៃធម៌ទាំងឡាយនោះ" គឺវិរាគធម៌ តថាគតពោលថា ជាកំពូល គឺពោលថា ប្រសើរ ឧត្តម នៃសង្ខតធម៌ និងអសង្ខតធម៌ទាំងឡាយនោះ ។ មិនមែនត្រឹមតែកិរិយាមិនមាននៃសេចក្តីតម្រេកប៉ុណ្ណោះទេ ឈ្មោះថា វិរាគៈ ក្នុងបាឡីនោះ បើតាមពិតទៅអសង្ខតធម៌នោះណា បាននូវឈ្មោះទាំងឡាយ មានជាអាទិ៍ថា "ធម៌ជា

១- សុ. អំ. ច. ភាគទី ៤២ ទំព័រទី ៨៤ ។

គ្រឿងញាំញីនូវសេចក្តីស្រវឹង" ព្រោះព្រះបាឡីថា "វិរាគធម៌នេះ គឺអ្វី? វិរាគធម៌នេះ គឺធម៌ជាគ្រឿងញាំញីនូវសេចក្តីស្រវឹង ។ល។ គឺព្រះនិព្វាន" ដូច្នេះ អសង្ខតធម៌នោះ ក៏គប្បីបានឈ្មោះថា វិរាគធម៌ដែរ ។ មែនពិត វិរាគធម៌នោះ លោកហៅថា មទនិម្មទនៈ ព្រោះសេចក្តីស្រវឹងទាំងឡាយទាំងពួង មានសេចក្តីស្រវឹង ដោយអំណាចនៃមានះ និង សេចក្តីស្រវឹងក្នុងភាពជាបុរសជាដើម អាស្រ័យនូវវិរាគធម៌ហើយ ក៏អស់ស្រវឹង គឺលែងស្រវឹង គឺថាបាត់ទៅ ។ មួយទៀត វិរាគធម៌នោះ លោកហៅថា បិបាសវិនយៈ ព្រោះសេចក្តីស្រេកឃ្លាន ក្នុងកាមទាំងឡាយទាំងពួង ព្រោះអាស្រ័យនូវវិរាគធម៌នោះ រមែងដល់នូវកិរិយាកំចាត់បង់ គឺថា នូវកិរិយាអស់បាត់ទៅ ។ មួយទៀត វិរាគធម៌ លោកហៅថា អាលយសមុគ្ឃាតៈ ព្រោះអាល័យ គឺបញ្ចកាមគុណទាំងឡាយ រមែងដល់នូវកិរិយាដកឡើង ព្រោះអាស្រ័យនូវវិរាគធម៌នោះ ។ មួយទៀត វិរាគធម៌នោះ លោកហៅថា វដ្តុបច្ឆេទៈ ព្រោះវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ រមែងដាច់សូន្យ ព្រោះអាស្រ័យនូវវិរាគធម៌នោះ ។ មួយទៀត វិរាគធម៌នោះ លោកហៅថា តណ្ហក្ខយៈ វិរាគៈ និរោធៈ ព្រោះតណ្ហា អាស្រ័យនូវវិរាគធម៌នោះ រមែងដល់នូវការអស់ទៅផង ប្រាសចាកតំរេកផង រលត់ទៅផង ដោយប្រការទាំងពួង ។ មួយទៀត វិរាគធម៌នោះ លោកហៅថា និព្វានៈ ព្រោះវិរាគធម៌នោះ ចេញហើយ គឺរលាស់ចេញហើយ ប្រាសចេញហើយ ចាកតណ្ហា ដែលបានឈ្មោះថា "វានៈ" ព្រោះរួបរឹត គឺចងស្រែះ ចាក់ស្រែះ នូវកំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ និង សត្តាវាស ៩ ព្រោះភាពនៃកិរិយាញុំាងសត្វឲ្យទៅៗ មកៗ ដូច្នេះឯង ។ ធម៌ដែលចូលទៅរម្ងាប់ ពោលគឺព្រះនិព្វាន ព្រះយោគីគប្បីរលឹករឿយៗ ដោយ

អំណាចនៃគុណទាំងឡាយ មានធម៌ជាគ្រឿងរម្ងាប់នូវសេចក្ដីស្រវឹង ជាដើមនោះៗ ដូចពណ៌នាមកនេះ ឬក៏ គុណនៃឧបសមៈទាំងឡាយដទៃណា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងព្រះសូត្រទាំងឡាយ មានជាដើមថា “ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងនូវអសង្ខតធម៌ ដល់អ្នកទាំងឡាយផង តថាគត នឹងសំដែងនូវសច្ចធម៌ផង តថាគត នឹងសំដែងនូវត្រើយគឺព្រះនិព្វានផង តថាគត នឹងសំដែងនូវធម៌ដែលសត្វឃើញបានដោយកម្រពន់ពេកផង តថាគត នឹងសំដែងនូវធម៌ដែលគ្មានសេចក្ដីចាស់គ្រាំគ្រាផង តថាគត នឹងសំដែងនូវធម៌ដែលទៀងទាត់ផង តថាគត នឹងសំដែងនូវធម៌ដែលគ្មានដំណើរឃើតយូរផង តថាគត នឹងសំដែងធម៌ដែលមិនស្លាប់ផង តថាគត នឹងសំដែងធម៌ជាទីសម្រាន្តផង តថាគត នឹងសំដែងនូវធម៌ដ៏ក្សេមផង តថាគត នឹងសំដែងនូវធម៌ដែលមិនធ្លាប់មានផង តថាគត នឹងសំដែងនូវធម៌មិនមានសេចក្ដីអន្តរាយផង តថាគត នឹងសំដែងនូវធម៌មិនព្យាបាទផង តថាគត នឹងសំដែងនូវធម៌ដ៏បរិសុទ្ធផង តថាគត នឹងសំដែងនូវធម៌ជាទីពឹងផង តថាគត នឹងសំដែងនូវធម៌ជាទីការពារផង ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងនូវធម៌ជាទីពួន ដល់អ្នកទាំងឡាយផង [១] ” ដូច្នេះ ក៏ព្រះយោគី គប្បីរលឹករឿយៗ ដោយអំណាចនៃគុណទាំងឡាយនោះឯង ដូចគ្នាបានដែរ ។

(អានិសង្សឧបសមានុស្សតិ)

កាលព្រះយោគាវចរនោះ រលឹករឿយៗ នូវសេចក្ដីស្ងប់រម្ងាប់ ដោយអំណាចនៃគុណ មានធម៌សំរាប់បន្ទោបង់ នូវសេចក្ដីស្រវឹងជាដើម យ៉ាងនេះ ក្នុងសម័យនោះ ចិត្ត មិនត្រូវរាគៈចាំស្កាត់ហើយ មិនត្រូវ

១- សុ. សំ. ស. ភាគទី ៣៦ ទំព័រទី ៣៦៦-៣៧៣ ។

ទោសៈចាំស្កាត់ហើយ មិនត្រូវមោហៈចាំស្កាត់ហើយ ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគាវចរនោះ ជាចិត្តទៅត្រង់ បាញ់ឆ្ពោះទៅរកសេចក្ដីស្ងប់រម្ងាប់មែនពិត ព្រោះហេតុនោះ អង្គឈានទាំងឡាយ រមែងកើតឡើង ដល់ព្រះយោគាវចរ អ្នកគ្របសង្កត់នូវនីវរណធម៌បានហើយ ក្នុងខណៈជាមួយគ្នា ដោយអំណាចនៃន័យដែលបានពោលមកហើយ ក្នុងអនុស្សតិមុន ៗ មានពុទ្ធានុស្សតិ ជាដើមហ្នឹងឯង ។ តែព្រោះភាវៈនៃឧបសមគុណទាំងឡាយជាគុណដ៏ជ្រាលជ្រៅ ឬថា ព្រោះភាវៈនៃចិត្តបង្អោនទៅក្នុងកិរិយារលឹករឿយៗ នូវគុណមានប្រការផ្សេងៗគ្នា ឈាននេះ ទើបជាឈានមិនដល់នូវអប្បនា ដល់ត្រឹមតែឧបចារៈប៉ុណ្ណោះឯង ។ ឈាននេះនោះ រមែងដល់នូវការរាប់ថា “ឧបសមានុស្សតិ” ហ្នឹងឯង ព្រោះកើតឡើង ដោយអំណាចនៃកិរិយារលឹករឿយៗនូវឧបសមគុណ ។ ឯឧបសមានុស្សតិនេះ រមែងសម្រេច ដល់ព្រះអរិយសាវកតែប៉ុណ្ណោះ ដូចជាធអនុស្សតិដែរ ។ កាលបើមានហេតុដូច្នោះ សូម្បីបុថុជ្ជន អ្នកធ្ងន់ក្នុងឧបសមៈ ក៏គួរធ្វើទុកក្នុងចិត្ត នូវឧបសមានុស្សតិដែរ ។ ព្រោះថា សូម្បីដោយអំណាចនៃការស្ដាប់ ចិត្ត ក៏រមែងជ្រះថ្លាក្នុងឧបសមៈបាន ។

ក៏ភិក្ខុអ្នកប្រកបរឿយៗ នូវឧបសមានុស្សតិនេះ រមែងដេកលក់ជាសុខ ភ្ញាក់ឡើងក៏ជាសុខ ជាអ្នកមានឥន្ទ្រិយ៍ស្ងប់រម្ងាប់ ជាអ្នកមានចិត្តស្ងប់ស្ងៀម ជាអ្នកប្រកបព្រមដោយហិរិ និង ឱត្តប្បៈ ជាអ្នកនាំមកនូវសេចក្ដីជ្រះថ្លា ជាអ្នកមានចិត្តបង្អោនទៅ ក្នុងធម៌ដ៏ប្រណីត ជាអ្នកគួរគោរព និង ជាអ្នកគួរសរសើរ នៃសព្រហ្មចារីទាំងឡាយ មួយទៀត បើមិនទាន់បានចាក់ធ្លុះនូវធម៌ដ៏ក្រៃលែងទេ ជាអ្នកមានសុគតិប្រព្រឹត្តទៅក្នុងខាងមុខ ។

ព្រោះហេតុនោះឯង បណ្ឌិត អ្នកមានប្រាជ្ញាជាគ្រឿងពិចារណា គប្បីជាអ្នកមិនប្រមាទ ចំរើននូវសតិ ក្នុងឧបសមៈដ៏ប្រសើរ ដែលមានអានិសង្សច្រើន យ៉ាងនេះ ដូចបានពណ៌នាមកនេះឯង ។

នេះជាកថាមុខ ដោយពិស្តារ ក្នុងឧបសមានុស្សតិ ។

បរិច្ឆេទ ទី៨

ឈ្មោះ អនុស្សតិកម្មដ្ឋាននិទ្ទេស ក្នុងអធិការនៃសមាធិភាវនា
ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ដែលខ្ញុំធ្វើហើយ
ដើម្បីប្រយោជន៍ដល់កិរិយារីករាយនៃសាធុជន
ដូចពណ៌នាមកនេះឯង ។

❈ ❈ ❈

មេត្តាព្រហ្មវិហារ

(១៧៨) ក៏ក្នុងព្រហ្មវិហារទាំងឡាយ ៤ នេះ គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ក្នុងលំដាប់នៃអនុស្សតិកម្មដ្ឋាន ព្រះយោគាវចរ ដែលជាអាទិកម្មិកៈ អ្នកប្រាថ្នាដើម្បីចំរើននូវមេត្តា គប្បីចូលទៅផ្តាច់បង់នូវបលិពោធ រៀននូវកម្មដ្ឋាន ធ្វើភត្តកិច្ចហើយ បន្ទោបង់នូវសេចក្តីស្រវឹងក្នុងភត្ត អង្គុយឲ្យបានស្រួលលើអាសនៈដែលបុគ្គលក្រាលល្អហើយ ក្នុងប្រទេសដ៏ស្ងាត់ ពិចារណានូវទោស ក្នុងទោសៈ និង អានិសង្ស ក្នុងសេចក្តីអត់ធន់ ជាមុន ។

សួរថា ព្រោះហេតុអ្វី ? ។ ឆ្លើយថា ព្រោះព្រះយោគីគប្បីលះបង់ទោសៈបាន និង គប្បីបានខន្តី ដោយភាវនានេះ ។ ឯព្រះយោគី មិនអាចដើម្បីលះបង់ នូវទោសដែលខ្លួនមិនបានឃើញហើយណាមួយ ឬក៏ដើម្បីបាននូវអានិសង្ស ដែលខ្លួនមិនដឹងច្បាស់ហើយណាមួយបានទេ ។ ព្រោះហេតុនោះ ព្រះយោគីគប្បីឃើញទោស ក្នុងទោសៈ ដោយអំណាចនៃព្រះសូត្រទាំងឡាយមានជាអាទិ៍ថា “ម្នាលអាវុសោ បុគ្គលត្រូវទោសៈប្រទូស្តហើយ ត្រូវទោសៈគ្របសង្កត់ហើយ ជាអ្នកមានចិត្តក្រហល់ក្រហាយហើយដោយទោសៈ រមែងសម្លាប់សត្វមានជីវិតបាន” ដូច្នេះ ។

ព្រះយោគាវចរ គប្បីជ្រាបអានិសង្ស ក្នុងខន្តី ដោយអំណាចនៃព្រះបាឡីទាំងឡាយ មានជាដើម ថា :

“ខន្តីគឺសេចក្តីអត់ធន់ ជាតបៈ ដ៏ក្រៃលែង ព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់នូវព្រះនិព្វានថា ជាធម្មជាតដ៏ឧត្តម តថាគត ហៅនូវបុគ្គលអ្នកមានខន្តីជាកំឡាំង អ្នកមាន

កំឡាំង គឺខន្តី ជាកងព័ទ ថា ជាព្រាហ្មណ៍ ប្រយោជន៍
ដ៏ក្រៃលែងជាងខន្តី មិនមានឡើយ" ។

បន្ទាប់មក ព្រះយោគាវចរ គប្បីប្រារព្ធការចំរើនមេត្តា ដើម្បីជាប្រយោជន៍ដល់ការធ្វើចិត្ត ឲ្យបានស្ងាត់ចាកទោសៈ ដែលមានទោស គឺខ្លួនឃើញហើយ និង ដើម្បីប្រយោជន៍ដល់ការចងនូវចិត្ត ក្នុងខន្តីដែលមានអានិសង្ស គឺខ្លួនបានដឹងច្បាស់ហើយ យ៉ាងនេះឯង ។

(បុគ្គលដែលជាទោសដល់ភាវនា)

ក៏ឯព្រះយោគី កាលចាប់ផ្តើម គប្បីដឹងបុគ្គលជាទោស អំពីខាងដើមសិន ថា "ព្រះយោគី មិនត្រូវចំរើនមេត្តា ជាមុន ក្នុងបុគ្គលទាំងឡាយនេះទេ មិនត្រូវចំរើនមេត្តា ក្នុងបុគ្គលទាំងឡាយនេះមែនពិត" ។ ពិតមែនហើយ មេត្តានេះ ព្រះយោគីមិនត្រូវចំរើន ជាដំបូង ក្នុងបុគ្គលទាំងឡាយ ៤ នេះ គឺ បុគ្គលដែលមិនជាទីស្រឡាញ់ ១ បុគ្គលដែលជាសំឡាញ់ដែលស្រឡាញ់ក្រៃពេក ១ បុគ្គលជាកណ្តាល ១ បុគ្គលដែលមានពៀរ ១ មិនត្រូវចំរើនមេត្តា ដោយចំពោះបុគ្គលដែលមានភេទជាសត្រូវនឹងគ្នា មិនត្រូវចំរើនសោះក្នុងបុគ្គលដែលធ្វើកាលកិរិយាហើយ ។

សួរថា ព្រោះហេតុអ្វី បានជាព្រះយោគីមិនត្រូវចំរើនមេត្តា ជាដំបូង ក្នុងបុគ្គលទាំងឡាយ មានបុគ្គលដែលមិនជាទីស្រឡាញ់ជាដើម ។

ឆ្លើយថា ព្រោះថា ព្រះយោគី កាលតំកល់នូវបុគ្គលដែលមិនជាទីស្រឡាញ់ ក្នុងកន្លែងជាទីស្រឡាញ់រមែងលំបាក កាលតំកល់សំឡាញ់ដែលជាទីស្រឡាញ់ក្រៃពេក ក្នុងកន្លែងនៃបុគ្គលដែលជាកណ្តាល រមែងលំបាក ក៏កាលបើសេចក្តីទុក្ខ សូម្បីមានប្រមាណតិច កើតឡើងហើយ

ដល់ព្រះយោគីនោះ ក៏ជាអ្នកដល់ហើយនូវអាការៈគឺការស្រែកយំក៏បាន កាលតំកល់នូវបុគ្គលជាកណ្តាលៗ ក្នុងកន្លែងនៃបុគ្គលជាគ្រូ និង ក្នុងកន្លែងនៃបុគ្គលដែលស្រឡាញ់ រមែងលំបាក កាលព្រះយោគី រំលឹកដល់បុគ្គលដែលមានពៀរ សេចក្តីក្រោធ ក៏រមែងកើតឡើង ព្រោះហេតុនោះ ព្រះយោគីមិនត្រូវចំរើនមេត្តា ជាដំបូង ក្នុងបុគ្គលទាំងឡាយ មានបុគ្គលដែលមិនជាទីស្រឡាញ់ជាដើមឡើយ ។

ចំណែកឯ ក្នុងបុគ្គលអ្នកមានភេទជាសត្រូវនឹងគ្នា កាលព្រះយោគី ចំរើនដោយចំពោះ ប្រារព្ធនូវបុគ្គលអ្នកមានភេទជាសត្រូវនឹងគ្នានោះឯង រាគៈ រមែងកើតឡើង ។ បានឮថា បុត្ររបស់អាមាត្យម្នាក់សួរព្រះថេរៈ ដែលជាជីតុនថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន តើបុគ្គលគួរចំរើនមេត្តា ក្នុងបុគ្គលបែបណា?" ។ ព្រះថេរៈ ឆ្លើយថា "ក្នុងបុគ្គលដែលជាទីស្រឡាញ់" ។ ក៏ភរិយារបស់ខ្លួន ជាទីស្រឡាញ់ នៃអាមាត្យនោះ ។ អាមាត្យនោះ ក៏ចំរើនមេត្តាចំពោះភរិយានោះ ធ្វើការប្រយុទ្ធជាមួយនឹងជញ្ជាំង រហូតរាត្រីទាំងមូល ។ ព្រោះហេតុនោះ ព្រះយោគី មិនត្រូវចំរើនមេត្តា ក្នុងបុគ្គលដែលមានភេទជាសត្រូវនឹងគ្នាទេ ។

ចំណែកក្នុងបុគ្គលដែលធ្វើកាលកិរិយាហើយ កាលព្រះយោគីចំរើន (មេត្តា) ក៏រមែងមិនដល់នូវអប្បនា មិនដល់នូវឧបចារៈឡើយ ។ បានឮមកថា ភិក្ខុកំឡោះមួយរូប ប្រារព្ធនូវអាចារ្យ ទើបផ្តើមនូវមេត្តា ។ មេត្តា របស់ភិក្ខុនោះ ប្រព្រឹត្តទៅមិនបានឡើយ ។ ភិក្ខុនោះ ទៅកាន់សំណាក់ព្រះមហាថេរៈហើយសួរថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ការចូលមេត្តាឈាន របស់ខ្ញុំម្ចាស់ ជាធម្មជាតស្ទាត់ពិតមែន ប៉ុន្តែខ្ញុំម្ចាស់មិនអាចដើម្បីចូលមេត្តាឈានសមាបត្តិនោះបានទេ តើព្រោះហេតុអ្វី" ។

ព្រះថេរៈ ឆ្លើយថា “ម្នាលអាវុសោ ចូរលោកស្វែងរកនូវនិមិត្ត” ។ ភិក្ខុនោះ កាលស្វែងរក (នូវនិមិត្ត) ដឹងថាអាចារ្យធ្វើកាលកិរិយាហើយ ក៏ចំរើនមេត្តា ប្រារព្ធអ្នកដទៃ ហើយក៏បានសំរេចសមាបត្តិ ។ ព្រោះហេតុនោះ ព្រះយោគី មិនត្រូវចំរើនមេត្តា ក្នុងបុគ្គលធ្វើកាលកិរិយាឡើយ ។

(ចំរើនមេត្តា ក្នុងខ្លួនឯងជាមុន)

តែថា មុនជាងជនទាំងអស់ ព្រះយោគី គប្បីចំរើនមេត្តា ក្នុងខ្លួនឯង ជារឿយៗ យ៉ាងនេះ ថា “សូមឲ្យអាត្មាអញ ជាអ្នកដល់ហើយនូវសេចក្តីសុខ កុំបីមានទុក្ខឡើយ” ឬថា “អាត្មាអញ ចូរជាអ្នកមិនមានពៀរ មិនមានព្យាបាទ មិនមានសេចក្តីទុក្ខ មានសេចក្តីសុខ រក្សានូវខ្លួន” ដូច្នេះក៏បាន ។

បើមានពាក្យសួរថា : កាលបើមានហេតុយ៉ាងនេះ ពាក្យឯណា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងវិភង្គ ថា “ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គលឃើញបុគ្គលម្នាក់ ដែលជាទីស្រឡាញ់ ជាទីពេញចិត្ត គប្បីផ្សាយមេត្តា យ៉ាងណាមិញ ភិក្ខុ រមែងផ្សាយមេត្តាចិត្ត ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង[១] ” ដូច្នេះក្តី ពាក្យណាដែលព្រះសារីបុត្រពោលហើយ ក្នុងបដិសម្ភិទាថា “មេត្តាចេតោវិមុត្តិ ផ្សាយដោយមិនមានចំណែក ដោយអាការ ៥ តើដូចម្តេច ? គឺ ផ្សាយដោយមេត្តាចិត្តថា សូមសត្វទាំងអស់ កុំឲ្យមានពៀរ កុំឲ្យមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ, សូមសត្វមានជីវិតទាំងអស់... សូមសត្វកើតហើយទាំងអស់... សូមបុគ្គលទាំងអស់... សូមសត្វទាំងអស់ ដែលរាប់ថាមាន

១- អភិ. វិ. ភាគទី ៨១ ទំព័រទី ៣១៣ ។

អត្តភាព កុំឲ្យមានពៀរ កុំឲ្យមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ [១] ” ដូច្នេះជាដើមក្តី ពាក្យណា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ក្នុងមេត្តសូត្រ ថា “សូមសត្វទាំងអស់ មានសេចក្តីសុខ ឬ មានសេចក្តីក្សេម សូមមានខ្លួនដល់នូវសេចក្តីសុខ [២] ” ដូច្នេះជាដើមក្តី, ពាក្យក្នុងគម្ពីរវិភង្គជាដើមនោះ រមែងខុស ព្រោះក្នុងពាក្យនោះ ព្រះមានព្រះភាគ មិនទ្រង់ត្រាស់នូវការចំរើន (មេត្តា) ក្នុងខ្លួន” ដូច្នេះ ។

គប្បីឆ្លើយថា : ពាក្យក្នុងគម្ពីរវិភង្គជាដើមនោះ មិនខុសអ្វីទេ ។ ព្រោះហេតុអ្វី ? ព្រោះពាក្យនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអំណាចនៃអប្បនា ពាក្យផ្សាយមេត្តា ក្នុងខ្លួនមានជាអាទិ៍ថា “សូមឲ្យអាត្មាអញបានសេចក្តីសុខ” ដូច្នេះនេះ គឺខ្ញុំបានពោលហើយ ដោយអំណាចភាវៈនៃខ្លួនជាបន្ទាល់ ។ មែនពិតប្រសិនបើព្រះយោគី ចំរើននូវមេត្តា ក្នុងខ្លួន តាមន័យថា “សូមឲ្យអាត្មាអញ ជាអ្នកមានសេចក្តីសុខ” ដូច្នេះជាដើមក្តី អស់កាល ១០០ ឆ្នាំ ឬ ១,០០០ ឆ្នាំ អប្បនា ក៏មិនកើតឡើង ដល់ព្រះយោគីនោះបានទេ ។ ប៉ុន្តែកាលព្រះយោគីនោះចំរើន (មេត្តា ក្នុងខ្លួន) ថា “សូមឲ្យអាត្មាអញ មានសេចក្តីសុខ” ដូច្នេះជាដើម ភាពនៃខ្លួនជាអ្នកប្រាថ្នានូវសេចក្តីសុខ ក្នុងពួកសត្វដទៃ រមែងកើតឡើង ព្រោះធ្វើខ្លួន ឲ្យជាបន្ទាល់ថា អាត្មាអញ ចង់បាននូវសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខ ចង់មានជីវិតរស់នៅ និង មិនចង់បាននូវសេចក្តីស្លាប់ទេ យ៉ាងណា ឯពពួកសត្វដទៃ ក៏ចង់បានសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខ ចង់មានជីវិតរស់នៅ និង មិនចង់បានសេចក្តីស្លាប់ ក៏យ៉ាងដូច្នោះដែរ ។

មួយទៀត ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា :

១- សុ. បដិ. ភាគទី ៧១ ទំព័រទី ៩៧ ។ ២- សុ. ខុ. ខុទ្ទកបាឋ. ។

> បុគ្គល មានចិត្តរំពឹងគិត សព្វទិស រមែងរកមិនឃើញ នូវបុគ្គលជាទីស្រឡាញ់ជាងខ្លួន ក្នុងទីណាមួយទេ ខ្លួនទើបជាទីស្រឡាញ់ច្រើនជាងបុគ្គលដទៃ យ៉ាងនោះឯង ព្រោះហេតុនោះ បុគ្គលដែលស្រឡាញ់ខ្លួន មិនគប្បីបៀតបៀនបុគ្គលដទៃឡើយ [1] ដូច្នេះ

ទ្រង់សំដែងហើយនូវន័យនេះឯង ។

ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីផ្សាយមេត្តាចំពោះខ្លួន ជាដំបូង ដើម្បីភាពជាបន្ទាល់ ក្នុងលំដាប់នោះ ដើម្បីញ៉ាំងមេត្តាភាវនា ឲ្យប្រព្រឹត្តទៅដោយស្រួល បុគ្គលណាដែលជាទីស្រឡាញ់ ជាទីគាប់ចិត្ត ជាទីគោរព និង ជាទីសរសើរ ជាអាចារ្យ ឬ ឬថា ប្រហែលអាចារ្យ ជាឧបជ្ឈាយ៍ ឬ ឬថា ប្រហែលឧបជ្ឈាយ៍ នៃព្រះយោគីនោះ គប្បីរឭក នូវហេតុគឺភាពនៃខ្លួនជាទីស្រឡាញ់ មានការឲ្យ និង ការពោលនូវពាក្យជាទីស្រឡាញ់ជាដើម និង នូវហេតុគឺភាពនៃខ្លួនជាទីគោរព និង ជាទីសរសើរ មានសីល និង សុតៈជាដើម នៃបុគ្គលជាទីស្រឡាញ់ មានអាចារ្យជាដើមនោះ ហើយចំរើនមេត្តា តាមន័យជាដើមថា “សប្បុរសនុ៎ះ ចូរជាអ្នកដល់ហើយនូវសេចក្តីសុខ ចូរជាអ្នកមិនមានទុក្ខ” ។ ក៏ (កាលចំរើនទៅ) ចំពោះបុគ្គលបែបនេះ អប្បនា រមែងសម្រេច ដោយពិត ។

(ចំរើនមេត្តា រួមខេត្តដែន)

បើព្រះយោគាវចរភិក្ខុនេះ មិនដល់នូវសេចក្តីត្រេកអរ ដោយហេតុមានប្រមាណប៉ុណ្ណេះទេ ហើយចង់ ដើម្បីធ្វើនូវសីមសម្ភេទ (ការ

---

[1] ១- សុ. សំ. សគ. ភាគទី ២៩ ទំព័រទី ២០៧ ។

រួមដែនចូលគ្នា) ក្នុងលំដាប់អំពីបុគ្គល មានអាចារ្យជាដើមនោះមក គប្បីចំរើនមេត្តា ចំពោះបុគ្គលជាសំឡាញ់ដែលជាទីស្រឡាញ់ក្រៃពេក អំពីបុគ្គលជាសំឡាញ់ ដែលជាទីស្រឡាញ់ក្រៃពេក ចំពោះបុគ្គលជាកណ្តាល អំពីបុគ្គលជាកណ្តាល ចំពោះបុគ្គលអ្នកមានពៀរ ។ ក៏កាលព្រះយោគាវចរចំរើន គប្បីធ្វើនូវចិត្តទន់ឲ្យគួរដល់ភាវនាកម្ម ក្នុងចំណែកមួយៗ ហើយគប្បីប្រមូលមក ក្នុងបុគ្គលជាលំដាប់គ្នានោះ ៗ ។

ចំណែកព្រះយោគាវចរភិក្ខុណា មិនមានបុគ្គលអ្នកមានពៀរក្តី សូម្បីកាលបើបុគ្គលដទៃធ្វើនូវសេចក្តីវិនាសឲ្យ សេចក្តីសំគាល់ថា ជាអ្នកមានពៀរហ្នឹងឯង ក៏មិនកើតឡើង ព្រោះភាពនៃខ្លួនជាអ្នកប្រកបដោយជាតិជាមហាបុរសក្តី ព្រះយោគាវចរភិក្ខុនោះ មិនគប្បីធ្វើសូម្បីនូវសេចក្តីខ្វល់ខ្វាយ ថា “មេត្តាចិត្ត របស់អញ ក្នុងបុគ្គលជាកណ្តាលជាចិត្តគួរដល់ភាវនាកម្ម ឥឡូវនេះ អាត្មាអញ ប្រមូលមក នូវមេត្តាចិត្តនោះ ចំពោះបុគ្គលអ្នកមានពៀរ” ដូច្នេះឡើយ ។ ចំណែកខាងបុគ្គលអ្នកមានពៀរ មានដល់ព្រះយោគីណា ពាក្យថា “ព្រះយោគីគប្បីចំរើនមេត្តាចំពោះបុគ្គលអ្នកមានពៀរ អំពីបុគ្គលជាកណ្តាល” ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដៅយកព្រះយោគីនោះ ។

(ទូន្មានខ្លួនពេលកើតបដិឃៈ)

(ន័យទី១ រលឹកដល់ទោសនៃសេចក្តីក្រោធ)

ក៏ប្រសិនបើកាលព្រះយោគីនោះ ប្រមូលចិត្តមក ចំពោះបុគ្គលអ្នកមានពៀរ បដិឃៈ (សេចក្តីថ្នាំងថ្នាក់ចិត្ត) រមែងកើតឡើង ព្រោះការរលឹករឿយៗ នូវកំហុសដែលបុគ្គលអ្នកមានពៀរនោះធ្វើហើយ កាលបើមានប្រការដូច្នោះ ព្រះយោគីនោះ កាលជួបនូវមេត្តា ចំពោះបុគ្គល

ណាមួយ ក្នុងចំណោមបុគ្គលមានក្នុងកាលមុនទាំងឡាយរឿយៗ ចេញហើយផ្សាយមេត្តា ចំពោះបុគ្គលនោះរឿយៗ គប្បីបន្ទោបង់នូវបដិឃៈ ។

ប្រសិនបើ កាលព្រះយោគី ព្យាយាម សូម្បីយ៉ាងនេះ បដិឃៈនៅតែមិនរលត់ បើមានប្រការដូច្នេះ ព្រះយោគី គប្បីព្យាយាម ដើម្បីលះបង់នូវបដិឃៈ ដោយការរលឹករឿយៗ នូវព្រះឱវាទទាំងឡាយ មានព្រះឱវាទដែលប្រៀបធៀបដោយរណារជាដើមចុះ ។

ក៏ព្រះយោគីនោះកាលទូន្មាននូវខ្លួននោះ គប្បីទូន្មានដោយអាការនេះរឿយៗ ថា ម្នាលបុរសអ្នកក្រោធចង្រៃ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ថា : “ម្នាលភិក្ខុទាំងឡាយ បើពួកចោរ ដែលប្រព្រឹត្តអាក្រក់ នាំគ្នាអារអវយវៈតូចធំ របស់អ្នកទាំងឡាយ ដោយរណារដែលមានដងទាំងសងខាង ភិក្ខុណាមួយ ញុំាងចិត្តឲ្យប្រទូស្ត ចំពោះចោរទាំងអម្បាលនោះ ភិក្ខុនោះ មិនឈ្មោះថា ជាអ្នកធ្វើតាមសាសនា របស់តថាគត ដោយការមិនអត់សង្កត់នោះឡើយ [១] ” ដូច្នេះ និង ថា :

“អ្នកណា ក្រោធតប នឹងបុគ្គលដែលក្រោធហើយ
អ្នកនោះឯងនឹងមានសេចក្តីអាក្រក់ ព្រោះសេចក្តីក្រោធ
នោះឯង ឯបុគ្គលមិនក្រោធតប នឹងបុគ្គលដែលក្រោធ
ហើយ រមែងឈ្នះនូវសង្គ្រាម ដែលគេឈ្នះបានដោយ
កម្រ អ្នកណាដឹងថាអ្នកដទៃក្រោធនឹងខ្លួន ជាអ្នកមាន
ស្មារតី រម្ងាប់សេចក្តីក្រោធបាន អ្នកនោះ ឈ្មោះថា
ជាអ្នកប្រព្រឹត្តនូវប្រយោជន៍ ដល់ជនទាំង ២ នាក់ គឺ
ខ្លួន និង អ្នកដទៃ [២] ” ដូច្នេះ និង ថា :

១- សុ. ម. មូ. ភាគទី២១ ទំព័រទី២៨ ។ ២- សុ. ភាគទី៣០ ទំព័រទី៨៩ ។

(១៧៩) “ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្រ្តីភាព ឬ បុរិសភាពដែលមានសេចក្តីក្រោធ ។ ធម៌ ៧ យ៉ាងនេះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សត្រូវក្នុងលោកនេះ រមែងប្រាថ្នានូវហេតុ យ៉ាងនេះ ដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ មានវណ្ណៈអាក្រក់ ។ រឿងនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ សត្រូវ រមែងមិនត្រេកអរ ដល់សត្រូវ ព្រោះវណ្ណៈទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ (កាលបើ) មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ហើយ មានសេចក្តីក្រោធ រួបរឹតហើយ បុរសបុគ្គលនោះ ទុកជាលាបស្រឡាបល្អ បានកោរសក់ នឹង ពុកមាត់ហើយស្លៀកសំពត់មានពណ៌-ស ក៏ពិតមែនហើយ ប៉ុន្តែបុរសបុគ្គលនោះ ឈ្មោះថា មានវណ្ណៈអាក្រក់ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ទី១ ជាទីត្រេកអរ នៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្រ្តីភាព ឬ បុរិសភាពដែលមានសេចក្តីក្រោធ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវ រមែងប្រាថ្នានូវហេតុយ៉ាងនេះ ដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ ដេកជាទុក្ខ ។ល។ ឱហ្ន៎ សូមឲ្យបុគ្គលនេះកុំមានប្រយោជន៍ច្រើនឡើយ ។ល។ ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានភោគៈឡើយ ។ល។ ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានយសឡើយ ។ល។ ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានមិត្រឡើយ ។ល។ លុះបែកធ្លាយរាងកាយស្លាប់ទៅ សូមកុំឲ្យបុគ្គលនេះ ចូលទៅកាន់សុគតិ សួគ៌ ទេវលោកឡើយ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះសត្រូវ រមែងមិនត្រេកអរ ដល់សត្រូវ ដោយដំណើរទៅកាន់សុគតិទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែបុរស-

បុគ្គលនេះ មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្របសង្កត់ហើយ មានសេចក្តីក្រោធរួបរឹតហើយ ក៏ប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិត ដោយចិត្ត ។ លុះបុគ្គលដែលមានសេចក្តីក្រោធគ្របសង្កត់នោះ ប្រព្រឹត្តទុច្ចរិតដោយកាយ វាចា ដោយចិត្តហើយ បែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើត ក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក [១] ” ដូច្នេះ និង ថា :

“ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអង្កត់ឧសសំរាប់ដុតខ្មោច ដែលភ្លើងឆេះរន្ទាលទាំងសងខាង មានលាមកប្រឡាក់ត្រង់កណ្តាល រមែងមិនសម្រេចជាឧស ក្នុងស្រុកបាន ទាំងមិនសម្រេចជាឧស ក្នុងព្រៃបាន មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ (បុគ្គលណា ជាអ្នកមិនប្រព្រឹត្ត ដើម្បីប្រយោជន៍ខ្លួន ទាំងមិនប្រព្រឹត្ត ដើម្បីប្រយោជន៍អ្នកដទៃ) តថាគតពោលថា បុរសបុគ្គលនេះ មានឧបមេយ្យយ៉ាងនោះដែរ [២]” ។

ក្នុងកាលឥឡូវនេះ អ្នកនោះ កាលក្រោធយ៉ាងនេះ នឹងមិនបានឈ្មោះថា ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគផង មែនពិត កាលក្រោធតប (នឹងអ្នកដែលក្រោធ) ក៏ជាអ្នកអាក្រក់ជាងបុរសដែលក្រោធហើយ នឹងមិនបានឈ្មោះថា ជាអ្នកឈ្នះនូវសង្គ្រាមដែលគេឈ្នះបានដោយលំបាកផង នឹងបានឈ្មោះថា ជាអ្នកធ្វើនូវធម៌ដែលសត្រូវធ្វើឲ្យដល់សត្រូវ ដល់ខ្លួន ដោយខ្លួនឯងផង នឹងឈ្មោះថា ជាអ្នកប្រៀបដូចជាអង្កត់ឧស សំរាប់ដុតខ្មោចផង” ដូច្នេះ ។

(ទូន្មានខ្លួន ន័យទី២ នឹកដល់សេចក្តីល្អរបស់គេ)

កាលព្រះយោគីនោះ ប្រឹងប្រែងព្យាយាម យ៉ាងនេះ បើបដិឃៈ

១- អំ. ស. ភាគទី ៤៧ ទំព័រទី ១៧២ ។ ២- ភាគទី ៤២ ទំព័រទី ២៣៥ ។

នោះ ស្ងប់រម្ងាប់ ការស្ងប់រម្ងាប់បានយ៉ាងនេះ ជាការប្រពៃ បើបដិឃៈនោះ មិនស្ងប់រម្ងាប់ទេ តអំពីនោះទៅ ធម៌ណាៗ របស់បុគ្គលនោះ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏បរិសុទ្ធល្អ កាលរលឹករឿយៗទៅ ក៏រមែងនាំមកនូវសេចក្តីជ្រះថ្លា ព្រះយោគី គប្បីរំលឹកនូវធម៌នោះៗ រឿយៗ ហើយបន្ទោបង់នូវបដិឃៈបាន ។

មែនពិត កាយសមាចារហ្នឹងឯង នៃព្រះយោគីពួកខ្លះ ជាសភាវៈស្ងប់រម្ងាប់ហើយ ។ ឯភាពនៃកាយសមាចារ របស់ព្រះយោគីនោះ ស្ងប់រម្ងាប់ហើយ កាលព្រះយោគីនោះ ធ្វើនូវវត្ត និង សេចក្តីប្រតិបត្តិច្រើន គឺជនទាំងអស់ តែងដឹងបាន ។ ចំណែកវចីសមាចារ និង មនោសមាចារ ជាសភាវៈមិនស្ងប់រម្ងាប់ទេ ព្រះយោគី មិនគប្បីគិតនូវវចីសមាចារ និង មនោសមាចារទាំងនោះ របស់បុគ្គលនោះទេ គប្បីរលឹករឿយៗ នូវការស្ងប់រម្ងាប់នៃកាយសមាចារ តែប៉ុណ្ណោះ ។

វចីសមាចារតែម្យ៉ាង នៃព្រះយោគីពួកខ្លះ ជាសភាវៈស្ងប់រម្ងាប់ហើយ ។ ឯភាពនៃវចីសមាចារ នៃបុគ្គលពួកខ្លះនោះស្ងប់រម្ងាប់ គឺជនទាំងអស់ តែងដឹងបាន ។ ព្រោះថាតាមប្រក្រតី បុគ្គលនោះជាអ្នកឆ្លាតវៃក្នុងបដិសណ្ឋារៈផង ជាអ្នកគួរស្រឡាញ់ផង ជាអ្នកពោលស្រួលស្តាប់ផង ជាអ្នករួសរាយផង ជាអ្នកមានមុខស្រស់បស់ផង ជាអ្នកពោលមុនផង សូត្រនូវធម៌ ដោយសំឡេងដ៏ពិរោះ សំដែងនូវធម្មកថា ដោយបទ និង ព្យញ្ជនៈទាំងឡាយដ៏ត្រឹមត្រូវ ។ ចំណែកកាយសមាចារ និង មនោសមាចារ មិនស្ងប់រម្ងាប់ទេ ។ ព្រះយោគី មិនគប្បីគិតនូវកាយសមាចារ និង មនោសមាចារ របស់បុគ្គលនោះទេ គប្បីរលឹករឿយៗ នូវការស្ងប់រម្ងាប់ នៃវចីសមាចារតែប៉ុណ្ណោះបានហើយ ។

សំរាប់បុគ្គលពួកខ្លះ មានមនោសមាចារតែម្យ៉ាងគត់ ស្ងប់រម្ងាប់ហើយ ។ ឯភាពនៃមនោសមាចារ នៃបុគ្គលពួកខ្លះនោះ ស្ងប់រម្ងាប់ហើយ រមែងប្រាកដ ដល់ជនទាំងអស់ ក្នុងទីទាំងឡាយ មានការចូលទៅថ្វាយបង្គំព្រះចេតិយជាដើម ។ មែនពិត បុគ្គលណា ជាអ្នកមានចិត្តមិនស្ងប់រម្ងាប់ហើយ បុគ្គលនោះ កាលថ្វាយបង្គំនូវព្រះចេតិយក្តី នូវដើមពោធិព្រឹក្សក្តី នូវព្រះថេរៈទាំងឡាយក្តី មិនថ្វាយបង្គំដោយគោរពទេ ជាអ្នកអង្គុយមានចិត្តរវើរវាយខ្លះ អង្គុយងោកងក់ខ្លះ ក្នុងមណ្ឌលជាទីស្តាប់នូវធម៌ ។ ចំណែកបុគ្គលអ្នកមានចិត្តស្ងប់រម្ងាប់ហើយ ជឿជាក់ហើយ ថ្វាយបង្គំដោយគោរព ជាអ្នកមានត្រចៀកផ្ទៀងស្តាប់ហើយ ធ្វើឲ្យជាប្រយោជន៍ កាលធ្វើឲ្យជាក់ច្បាស់ នូវសេចក្តីជ្រះថ្លានៃចិត្ត ដោយកាយខ្លះ ដោយវាចាខ្លះ ទើបស្តាប់ធម៌ ។

សំរាប់បុគ្គលពួកខ្លះ មនោសមាចារតែម្យ៉ាងគត់ ជាសភាវៈស្ងប់រម្ងាប់ហើយ ដូចថ្លែងមកនេះឯង, កាយសមាចារ និង វចីសមាចារទាំងឡាយ ជាសភាវៈមិនស្ងប់រម្ងាប់ទេ ព្រះយោគី មិនគប្បីគិតនូវកាយ-សមាចារ និង វចីសមាចារទាំងនោះ នៃបុគ្គលនោះទេ គប្បីរលឹករឿយៗ នូវការស្ងប់រម្ងាប់ នៃមនោសមាចារតែម្យ៉ាងប៉ុណ្ណោះបានហើយ ។

សំរាប់បុគ្គលពួកខ្លះ បណ្តាធម៌ទាំង ៣ នេះ សូម្បីធម៌មួយ ក៏មិនស្ងប់រម្ងាប់ដែរ ព្រះយោគី គប្បីតំកល់សេចក្តីអាណិត ក្នុងបុគ្គលនោះថា "ក្នុងកាលឥឡូវនេះ បុគ្គលនេះ ត្រាច់ទៅ ក្នុងមនុស្សលោក ក៏ពិតមែនហើយ ក៏ប៉ុន្តែថា ដោយអំណើះពីរបីថ្ងៃទៅ បុគ្គលនេះ នឹងជាអ្នកបំពេញ នូវមហានរក ៨ រណ្តៅផង និង ឧស្សទនរក ១៦ ផង" ។ ដ្បិតថា សេចក្តីគំនុំ រមែងស្ងប់រម្ងាប់ ព្រោះអាស្រ័យនូវករុណា ។

សំរាប់បុគ្គលពួកខ្លះ មានធម៌ទាំង ៣ នេះ ស្ងប់រម្ងាប់ហើយ ព្រះយោគីប្រាថ្នានូវធម៌ណាៗ របស់បុគ្គលនោះ គប្បីរលឹករឿយៗ នូវធម៌នោះៗ ចុះ ។

មួយទៀត ដើម្បីសំដែងឲ្យច្បាស់នូវសេចក្តីនេះថា "មេត្តាភាវនាជាធម្មជាតិ មិនមែនដែលបុគ្គលទាំងឡាយ ប្រាកដដូច្នេះ ធ្វើបាន ដោយកម្រទេ" ដូច្នេះ អាឃាតប្បដិវិនយសូត្រ ក្នុងបញ្ចកនិបាតនេះថា "ម្នាលអាវុសោ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកំចាត់បង់ ដោយប្រការទាំងពួងព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះមាន ៥ យ៉ាង [១] " ដូច្នេះ បណ្ឌិតគប្បីធ្វើឲ្យពិស្តារផងចុះ ។

(ទូន្មានខ្លួន ន័យទី៣ សេចក្តីក្រោធធ្វើទុក្ខឱ្យខ្លួនឯង)

ក៏ប្រសិនណាបើ កាលព្រះយោគីនោះ ព្យាយាម សូម្បីយ៉ាងនេះ សេចក្តីគំនុំ នៅតែកើតឡើងដដែល កាលបើមានប្រការដូច្នេះ ព្រះយោគីគប្បីទូន្មានខ្លួន យ៉ាងនេះ ថា :

> *(១)* ថាបើបុគ្គលមានពៀរ ធ្វើសេចក្តីទុក្ខដល់អ្នក ក្នុងរាងកាយរបស់ខ្លួន ចុះហេតុអ្វី ក៏អ្នកប្រាថ្នាដើម្បីធ្វើនូវសេចក្តីទុក្ខ ក្នុងចិត្តរបស់ខ្លួន ដែលមិនមែនជាកាយរបស់គេទៅវិញ,
>
> *(២)* អ្នកលះបង់ហើយនូវមាតាបិតា អ្នកមានឧបការៈច្រើន និង ពួកញាតិ មានមុខកំពុងតែស្រែកយំ ហេតុអ្វី មិនលះបង់នូវសេចក្តីក្រោធ ដែលជាសត្រូវ អ្នកធ្វើនូវអំពើដែលមិនមែនជាប្រយោជន៍ដ៏ធំ,

---

១- សុ. អំ. ប. ភាគទី ៤៥ ទំព័រទី ១១៤ ។

(៣) អ្នកមិនសមបើ នៅតែឱបក្រសោបសេចក្តីក្រោធ ដែលជាគ្រឿងកាត់បង់ នូវឫសនៃសីលទាំងឡាយដែលអ្នករក្សានោះ សូមសួរបន្តិច អ្នកណាល្ងីល្ងើ ប្រាកដស្មើដោយអ្នក,

(៤) អ្នកក្រោធថា កម្មមិនប្រសើរ ដែលបុគ្គលដទៃបានធ្វើហើយ យ៉ាងណាហ្ន៎ អ្នកប្រាថ្នាដើម្បីធ្វើនូវកម្មប្រាកដដូច្នោះ ដោយខ្លួនឯងទៅវិញ,

(៥) បើបុគ្គលដទៃមានបំណងចង់ធ្វើឲ្យអ្នកខឹង បានធ្វើនូវសេចក្តីមិនគាប់ចិត្តឲ្យ ម្តេចក៏អ្នកញុំាងមនោរថរបស់គេឲ្យពេញ ដោយការញុំាងកំហឹងឲ្យកើតឡើងនោះ,

(៦) ក៏ធម្មតាអ្នកក្រោធហើយ នឹងធ្វើនូវសេចក្តីទុក្ខដល់គេ ឬ មិនធ្វើ តែឥឡូវនេះឯង អ្នកបៀតបៀន នូវខ្លួនឯង ដោយកោធទុក្ខ (ទុក្ខព្រោះសេចក្តីក្រោធ),

(៧) ម្យ៉ាងទៀត បើពួកអ្នកមានពៀរ ឡើងហើយកាន់ផ្លូវមិនជាប្រយោជន៍ គឺសេចក្តីក្រោធ ហេតុម្តេចទាំងអ្នកក៏ខឹង យកតំរាប់តាមបុគ្គលពួកនោះទៅវិញ,

(៨) សត្រូវអាស្រ័យនូវការខឹងណារបស់អ្នក ធ្វើនូវអំពើមិនជាទីស្រឡាញ់ ចូរអ្នកកាត់ចោល នូវសេចក្តីខឹងនោះទៅ ដូចម្តេចក៏អ្នកនៅតែក្តៅក្រហាយ ក្នុងអំពើដែលមិនសមគួរធ្វើអ្វីទៀត,

(៩) សត្រូវបានធ្វើអំពើមិនជាទីគាប់ចិត្តដល់អ្នក ដោយខន្ធទាំងឡាយណា ខន្ធទាំងឡាយនោះ ក៏រលត់បាត់ទៅ

ហើយ ព្រោះភាវៈនៃធម៌ទាំងឡាយជាសភាវៈប្រព្រឹត្តទៅក្នុងខណៈ ក្នុងកាលឥឡូវនេះ តើអ្នកនៅក្រោធខឹងនឹងអ្នកណាទៀត ក្នុងទីនេះ,

(១០) បុគ្គលណាធ្វើនូវសេចក្តីទុក្ខដល់បុគ្គលណា វៀរនូវបុគ្គលនោះចេញ បុគ្គលនោះ គប្បីធ្វើនូវសេចក្តីទុក្ខដល់បុគ្គលណា ខ្លួនអ្នកជាហេតុ នៃសេចក្តីទុក្ខ ដោយខ្លួនឯងមែនពិត ព្រោះហេតុដូចម្តេច ក៏អ្នកនៅតែក្រោធខឹងនឹងគេទៀត ។

(ទូន្មានខ្លួន ន័យទី៤ ពិចារណាកម្មរបស់ខ្លួន)

(១៨០) ក៏ប្រសិនបើ កាលព្រះយោគីនោះសូម្បីទូន្មានខ្លួន យ៉ាងនេះ បដិឃៈ នៅតែមិនស្ងប់រម្ងាប់ហ្នឹងឯង, កាលបើយ៉ាងនេះ ព្រះយោគីនេះ គប្បីពិចារណានូវភាពនៃខ្លួនផង នៃបុគ្គលដទៃផង ថា ជាអ្នកមានកម្មជារបស់ខ្លួន ។ បណ្តាខ្លួន និង បុគ្គលដទៃទាំងនោះ ព្រះយោគីគប្បីពិចារណា (កម្ម) របស់ខ្លួនឯង ជាមុន យ៉ាងនេះ ថា “ម្នាលអ្នកដ៏ចំរើន អ្នកក្រោធខឹងហើយចំពោះបុគ្គលនោះ អ្នកនឹងធ្វើនូវអ្វី ក្រែងកម្មនោះមានទោសជាហេតុ នឹងប្រព្រឹត្តទៅ ដើម្បីមិនមែនជាប្រយោជន៍ ដល់អ្នកទេឬ ព្រោះថា អ្នក ជាអ្នកមានកម្មជារបស់ខ្លួន ជាអ្នកមានកម្មជាមត៌ក ជាអ្នកមានកម្មជាកំណើត ជាអ្នកមានកម្មជាផៅពង្ស ជាអ្នកមានកម្មជាទីពឹងអាស្រ័យ អ្នកនឹងធ្វើនូវកម្មណា នឹងជាអ្នកទទួលយកនូវរង្វាន់ នៃកម្មនោះ មួយវិញទៀត កម្មនេះ មិនអាចញុំាងសម្មាសម្ពោធិញ្ញាណ ឲ្យសំរេច ដល់អ្នកបានទេ មិនអាចញុំាងបច្ចេកពោធិ(ញ្ញាណ) ឲ្យសំម្រេចទេ មិនអាចញុំាងសាវកភូមិឲ្យសំរេចបានទេ មិនអាចញុំាងសម្បត្តិណា-

មួយ ក្នុងចំណោមសម្បត្តិទាំងឡាយ មានភាពនៃខ្លួនជាព្រហ្ម ជាព្រះឥន្ទ្រ ជាស្តេចចក្រពត្តិ និង ជាស្តេចក្នុងប្រទេសជាដើម ឲ្យសម្រេច ដល់អ្នកបានទេ, បើតាមពិតទៅ កម្មនេះ មានតែញ៉ាំងអ្នកឲ្យឃ្លាតចាកព្រះសាសនាហើយ ញ៉ាំងភាពនៃបុគ្គល មានបុគ្គលអ្នកស៊ីដែលជាដើម និង ញ៉ាំងទុក្ខវិសេសទាំងឡាយ មានទុក្ខក្នុងនរកជាដើម ឲ្យប្រព្រឹត្តទៅ ដល់អ្នក, អ្នកនោះ កាលធ្វើនូវកម្មនេះ ឈ្មោះថា ដុតនូវខ្លួនឯង ជាមុន និង ឈ្មោះថា ធ្វើខ្លួនឯង ឲ្យមានក្លិនស្អុយ ដូចជាបុរសអ្នកប្រាថ្នា ដើម្បីចាប់នូវរងើកភ្លើងទាំងឡាយ ដែលប្រាសចាកអណ្តាតភ្លើង នូវលាមកក្តី ដោយដៃទាំង ២ ហើយប្រហារនូវបុគ្គលដទៃ ឈ្មោះថា ដុតនូវខ្លួនឯង ជាមុន និង ឈ្មោះថា ធ្វើខ្លួនឯងឲ្យមានក្លិនស្អុយ យ៉ាងនោះដែរ ។

ព្រះយោគី លុះពិចារណា នូវភាពនៃខ្លួនជាអ្នកមានកម្មជារបស់ខ្លួន យ៉ាងនេះហើយ គប្បីពិចារណា នូវភាពនៃបុគ្គលដទៃជាអ្នកមានកម្មជារបស់ខ្លួន យ៉ាងនេះ ថា “សូម្បីបុគ្គលនោះ ខឹងចំពោះអ្នកហើយ នឹងធ្វើនូវអ្វី ក្រែងកម្មនោះ នឹងប្រព្រឹត្តទៅ ដើម្បីមិនមែនជាប្រយោជន៍ ដល់បុគ្គលនុ៎ះឯង ព្រោះថា លោកអ្នកដ៏មានអាយុនេះ ជាអ្នកមានកម្មជារបស់ខ្លួន ជាអ្នកមានកម្មជាមត៌ក ។ល។ នឹងធ្វើនូវកម្មណា នឹងជាអ្នកទទួលយកនូវផ្លែនៃកម្មនោះ មួយវិញទៀត កម្មនេះ មិនអាចញ៉ាំងសម្មាសម្ពោធិញ្ញាណ ឲ្យសំរេចដល់គេបានទេ មិនអាចញ៉ាំងបច្ចេកពោធិ(ញ្ញាណ) ឲ្យសម្រេចបានទេ មិនអាចញ៉ាំងសាវកភូមិ ឲ្យសំរេចបានទេ មិនអាចញ៉ាំងសម្បត្តិណាមួយ ក្នុងចំណោមសម្បត្តិទាំងឡាយ មានភាពនៃខ្លួនជាព្រហ្ម ជាព្រះឥន្ទ្រ ជាស្តេចចក្រពត្តិ និង ជាស្តេចក្នុងប្រទេសជាដើម ឲ្យសម្រេចដល់គេបានទេ, បើតាមពិតទៅ កម្មនេះ មានតែញ៉ាំង

បុគ្គលនោះ ឲ្យឃ្លាតចាកព្រះសាសនាហើយ ញ៉ាំងភាពនៃបុគ្គល មានបុគ្គលអ្នកស៊ីដែលជាដើម និង ញ៉ាំងទុក្ខវិសេសទាំងឡាយ មានទុក្ខក្នុងនរកជាដើម ឲ្យប្រព្រឹត្តទៅ ដល់បុគ្គលនោះ, បុគ្គនោះឯង កាលធ្វើនូវកម្មនេះ ឈ្មោះថា រោយរាយនូវ (ទោស) ដល់ខ្លួនឯង ប្រៀបដូចជាបុរស អ្នកឈរនៅ ក្នុងទីប្រាសខ្យល់ ហើយប្រាថ្នារោយរាយ នូវបុគ្គលដទៃ ដោយធូលី ដូច្នោះឯង ។ សមដូចជាព្រះមានព្រះភាគត្រាស់ ថា :

> បុគ្គលពាលណា ប្រទូស្តចំពោះជន ដែលមិនប្រទូស្ត
> ជាបុរសបរិសុទ្ធ មិនមានកិលេសដូចជាទីទួល បាប
> រមែងត្រឡប់មកត្រូវបុគ្គលពាលនោះវិញ ដូចជាធូលីដ៏
> ល្អិត ដែលបុគ្គលបាចប្រាសខ្យល់ៗ ក៏ត្រឡប់មកត្រូវ
> អ្នកបាចនោះវិញ [១] ។

(ទូន្មានខ្លួន ន័យទី៥ ពិចារណាដល់បុព្វចរិយារបស់ព្រះពុទ្ធ)

(១៨១) ក៏ប្រសិនបើ ព្រះយោគីនោះ ពិចារណា នូវកម្មស្សកតាយ៉ាងនេះហើយ បដិឃៈ ក៏នៅតែមិនស្ងប់រម្ងាប់ដដែល កាលបើយ៉ាងនេះ ព្រះយោគីនោះ គប្បីពិចារណា នូវគុណជាចំណែក នៃបុព្វចរិយារបស់ព្រះសាស្តាវិញម្តង ។ នេះជាន័យនៃការពិចារណា ក្នុងបុព្វចរិយាគុណរបស់ព្រះសាស្តានោះ ថា “នៃបព្វជិតដ៏ចំរើន ព្រះសាស្តារបស់អ្នកមិនទាន់បានត្រាស់ដឹង ក្នុងកាលមុនអំពីសម្ពោធិសម័យ សូម្បីនៅជាព្រះពោធិសត្វនៅឡើយ កាលបំពេញព្រះបារមី អស់ ៤ អសង្ខេយកំរៃមួយសែនកប្ប ក៏មិនញ៉ាំងចិត្តប្រទូស្តចំពោះបុគ្គលទាំងឡាយជាសត្រូវសូម្បី

១- សុ. សំ. ស. ភាគទី ៣០ ទំព័រទី ៩២ ។

ជាអ្នកសម្លាប់ ក្នុងជាតិទាំងឡាយនោះៗក៏ដោយ រឿងនេះដូចម្ដេចខ្លះ? ។

(សីលវជាតក)

បណ្ឌិតគប្បីជ្រាបរឿង ក្នុងសីលវជាតក មុនសិន ព្រះសីលវ-ពោធិសត្វ កាលព្រះរាជាដែលជាសត្រូវ គឺអាមាត្យបាប ដែលប្រទូស្ត ហើយ ចំពោះព្រះទេវីរបស់ព្រះអង្គ នាំយកមកហើយ ដណ្ដើមយកនូវ អាណាខេត្ត អស់ទី៣០០ យោជន៍ ក៏មិនបានឲ្យពួកអាមាត្យដែលក្រោក ឡើង ដើម្បីប្រយោជន៍ ដល់ការការពារ ចាប់ពាល់សូម្បីនូវអាវុធឡើយ ត្រូវព្រះរាជាជាសត្រូវ មួយអន្លើដោយអាមាត្យមួយពាន់ ជីកនូវផែនដី ប្រមាណត្រឹម-ក ហើយកប់ចោល ក្នុងព្រៃស្មសាន ជាទីចោលនូវខ្មោច ស្រស់ទៀត ក៏មិនធ្វើសូម្បីត្រឹមតែការញ៉ាំងចិត្តឲ្យប្រទូស្ត ទ្រង់ធ្វើការ ព្យាយាមរបស់បុរសហើយ ក៏បានមានជីវិតមកវិញ ព្រោះអាស្រ័យនូវ ឆ្កែចចកទាំងឡាយដែលមកកកាយអាចម៍ដីស៊ីនូវសាសព ទ្រង់ចុះហើយ ក្នុងបន្ទប់ដ៏មានសិរីរបស់ខ្លួន ដោយអានុភាពនៃយក្ស ឃើញនូវសត្រូវ ដែលដេកហើយលើដំណេកដ៏មានសិរី មិនធ្វើនូវសេចក្ដីក្រោធខឹងសោះ ធ្វើនូវការស្បថស្បែគ្នាទៅវិញទៅមក ក៏បានតែងតាំងនូវសត្រូវនោះ ក្នុង តំណែងដូចជាមិត្រ ហើយត្រាស់ថា :

បុរសជាបណ្ឌិត ត្រូវតែប៉ុនប៉ងឲ្យមុតមាំ មិនត្រូវនឿយ
ណាយឡើយ យើងឃើញនូវខ្លួនយើងស្រាប់ហើយ
យើងប្រាថ្នា យ៉ាងណា ក៏បានយ៉ាងនោះ [១] ។

(ខន្តិវាទិជាតក)

១- សុ. ខុ. ជា. ភាគទី ៥៨ ទំព័រទី ២៣ ។

រឿងក្នុងខន្តិវាទីជាតក ខន្តិវាទីតាបសពោធិសត្វ កាលបើព្រះ រាជា (កលាពុ) ដែនកាសី ទ្រង់មានប្រាជ្ញាទន់ខ្សោយ ទ្រង់ត្រាស់សួរថា "នែសមណៈ តើអ្នកមានវាទីដូចម្ដេច" ដូច្នេះ ក៏ឆ្លើយថា "អាត្មា ឈ្មោះ ថា ខន្តិវាទី" ដូច្នេះ ត្រូវវាយដោយផ្ដៅទាំងបន្លាហើយ កាត់ដៃ និង ជើង ចោលក៏ដោយ ក៏មិនបានធ្វើសូម្បីនូវហេតុត្រឹមតែការក្រោធខឹងឡើយ ។

ការដែលខន្តិវាទីតាបស ដែលជាធំ ចូលកាន់ផ្នួសហើយ គប្បី ធ្វើបានយ៉ាងនេះ នុ៎ះ មិនជាការអស្ចារ្យណាស់ណាទេ ។

(ចូឡធម្មបាលជាតក)

អម្បាលយ៉ាងក្នុងចូឡធម្មបាលជាតក ធម្មបាលកុមារពោធិសត្វ សូម្បីជាអ្នកនៅដេកផ្ងារ កាលព្រះមាតាទ្រង់ព្រះពិលាប យ៉ាងនេះថា :

បពិត្រព្រះសម្មតិទេព ដើមដៃទាំងឡាយ ដែលលាប
លន់ហើយ ដោយរសនៃខ្លឹមចន្ទន៍ នៃធម្មបាល អ្នកជា
ទាយាទ ផែនដីដាច់ ជីវិត របស់ខ្ញុំម្ចាស់ក៏នឹងរលត់ទៅ

ដូច្នេះ ត្រូវព្រះរាជាព្រះនាមមហាបតាបៈជាបិតា ត្រាស់បញ្ជា ឲ្យគេកាត់ ដៃ និង ជើងទាំង ៤ ដូចជាកង់នៃឫស្សីប៉ុណ្ណឹងហើយ ក៏នៅតែមិនល្មម ព្រះទ័យ ទ្រង់ត្រាស់បង្គាប់ (ទៀត) ថា "ចូរអ្នកទាំងឡាយកាត់នូវក្បាល របស់វា" ដូច្នេះ ទើបទ្រង់ជាស់តឿនខ្លួនថា "ក្នុងកាលឥឡូវនេះ នេះគឺជា កាលជាទីផ្ចញ់ផ្ចាល់នូវចិត្តរបស់អ្នកឲ្យល្អហើយ ម្នាលធម្មបាលដ៏ចំរើន ឥឡូវនេះ អ្នកចូរជាអ្នកមានចិត្តស្មើ ចំពោះបុគ្គលទាំង ៤ នាក់នេះ គឺ ចំពោះព្រះបិតាអ្នកបង្គាប់ឲ្យកាត់ក្បាល ១ ចំពោះបុរសអ្នកកាត់ក្បាល១ ចំពោះព្រះមាតា ដែលកំពុងតែទ្រង់ខ្សឹកខ្សួល ១ ចំពោះខ្លួន ១ " ដូច្នេះ

ហើយ ទ្រង់អធិដ្ឋាននូវទឡ្ហសមាទាន(គឺការធ្វើចិត្តស្មើឲ្យរឹងមាំ) មិនបាន ទ្រង់ធ្វើសូម្បីត្រឹមតែអាការដែលប្រទូសរ៉ាយឡើយ ។

ធម្មបាលកុមារជាមនុស្សត្រឡាំង បានធ្វើហើយយ៉ាងនេះ ដោយហេតុណា ហេតុនុ៎ះ ពុំទាន់អស្ចារ្យនៅឡើយទេ ។

(ឆទ្ទន្តជាតក)

ប៉ុនអម្បាលយ៉ាង (ក្នុងឆទ្ទន្តជាតក) ព្រះពោធិសត្វសូម្បីជាសត្វតិរច្ឆាន គឺជាដំរីឈ្មោះឆទ្ទន្ត សូម្បីត្រូវកូនសរដែលត្រាំហើយ ដោយថ្នាំពិស មុតហើយ ត្រង់ផ្ចិត ក៏មិនញុំាងចិត្តឲ្យប្រទូស្ត ចំពោះព្រានអ្នកធ្វើនូវសេចក្តីវិនាស សមដូចជាព្រះអដ្ឋកថាចារ្យ ពោលទុកហើយ ថា :

ដំរីដ៏ប្រសើរ ត្រូវព្រានព្រៃបាញ់ហើយ ដោយសរដ៏
ថ្លោស មិនមានចិត្តប្រទូស្តបាននិយាយនឹងព្រានព្រៃថា
នៃសំឡាញ់ អ្នកត្រូវការអ្វី តើព្រោះហេតុអ្វីបានជាអ្នក
សម្លាប់យើង ម្យ៉ាងទៀត ការប្រកបនេះរបស់អ្នកណា

ដូច្នេះ លុះពោលយ៉ាងនេះរួចហើយ ព្រានប្រាប់ថា “ខ្ញុំ ជាអ្នកដែលព្រះមហេសី នៃស្តេចក្នុងដែនកាសី ទ្រង់ត្រាស់បញ្ជូនមក ដើម្បីប្រយោជន៍ដល់ភ្លុកទាំងឡាយរបស់អ្នក” ដូច្នេះ កាលញុំាងមនោរថ នៃព្រាននោះឲ្យពេញ បានឲ្យព្រានកាត់ភ្លុកទាំងឡាយ របស់ខ្លួន ដ៏ភ្លឺផ្លេកដូចជាមាសដែលរុងរឿងព្រមហើយឆ្លុះរស្មីមានពណ៌ ៦ ។

(មហាកបិជាតក)

(ក្នុងមហាកបិជាតក) ព្រះពោធិសត្វ ជាស្វាដ៏ធំ ត្រូវបុរសដែលលើកឡើងហើយ អំពីជ្រោះភ្នំ ដោយខ្លួនឯង គិតយ៉ាងនេះ ថា :

ស្វានេះ ជាអាហារ របស់ពួកមនុស្ស ដូចជាពួកម្រឹគ
ដទៃ ក្នុងព្រៃដែរ បើដូច្នោះ អាត្មាអញ ឃ្លានហើយ
គប្បីសម្លាប់នូវស្វានេះស៊ី អញស៊ីឆ្អែតហើយ នឹងយក
នូវសាច់ជាស្បៀង ហើយនឹងដើរទៅ នឹងឆ្លងនូវផ្លូវ
ឆ្ងាយ ស្បៀងរបស់អញក៏មានស្រាប់

ដូច្នេះហើយ ក៏លើកដុំថ្មហើយទំលាយក្បាល កាលក្រឡេកមើល នូវបុរសនោះ មានភ្នែកទាំងឡាយ ពេញហើយដោយទឹកភ្នែក ពោលថា :

បពិត្រលោកដ៏ចំរើន លោកជាលោកម្ចាស់នៃខ្ញុំ ឈ្មោះ
ថា លោកកុំធ្វើឡើយនូវអំពើប្រាកដដូចនេះ គួរជាអ្នក
មានអាយុវែងគួរដើម្បីហាមឃាត់នូវជនទាំងឡាយដទៃ

ដូច្នេះហើយ មិនញុំាងចិត្តឲ្យប្រទូស្ត ក្នុងបុរសនោះ មិនគិតនូវសេចក្តីទុក្ខរបស់ខ្លួនសោះ ហើយញុំាងបុរសនោះឯង ឲ្យបានដល់ហើយ នូវភូមិដែលមានសេចក្តីក្សេមក្សាន្ត ។

(ភូរិទត្តជាតក)

(ក្នុងភូរិទត្តជាតក) ព្រះពោធិសត្វ ជានាគរាជ ឈ្មោះថា ភូរិទត្ត កាលអធិដ្ឋាន នូវអង្គនៃឧបោសថសីលហើយ ក៏ដេកនៅលើក្បាលដំបូក កាលបើសរីរៈទាំងមូល ទុកជាត្រូវព្រានព្រួសដោយឱសថ ប្រាកដស្មើដោយភ្លើងដែលតាំងនៅអស់កប្ប ដាក់ចុះក្នុងកំប្រោងហើយ ឲ្យលេងក្នុងសកលជម្ពូទ្វីប ក៏មិនបានធ្វើហើយសូម្បីត្រឹមតែកិរិយាញុំាងចិត្ត ឲ្យប្រទូស្ត ក្នុងព្រានព្រៃនោះឡើយ សមដូចជាលោកពោលទុក ថា :

ខ្ញុំកាលអាលម្តាយ ច្រកក្នុងកំប្រោងក្តី កាលញាំញី ដោយកែងជើងក្តី ក៏មិនក្រោធខឹងដែរ ព្រោះភ័យខ្លាច អំពីកិរិយាដាច់នៃសីល របស់យើង ។

(ចម្បេយ្យជាតក)

សូម្បីគ្រាកាលព្រះពោធិសត្វ ជានាគរាជឈ្មោះថា ចម្បេយ្យៈ ត្រូវហ្មពស់បៀតបៀន ក៏មិនបានញុំាងសូម្បីត្រឹមតែសេចក្តីប្រទូស្តនៃចិត្ត ឲ្យកើតឡើងដែរ សមដូចជាលោកពោលហើយ ថា :

ហ្មពស់ ចាប់នូវអញជាអ្នកប្រព្រឹត្តនូវធម៌ ចាំឧបោសថ (នាំទៅឲ្យ)លេង ទ្បេបទ្វារព្រះរាជវាំង ក៏ក្នុងកាលនោះ ហ្មពស់នោះ គិតនូវពណ៌ណា គឺ ពណ៌ខៀវក្តី ព៌ណលឿងក្តី ពណ៌ក្រហមក្តី ខ្ញុំកាលប្រព្រឹត្តតាមចិត្ត នៃហ្មពស់នោះ ជាអ្នកឈ្វេងយល់នូវហេតុដែលហ្មពស់នោះគិតហើយ ខ្ញុំគប្បីធ្វើទីគោកឲ្យទៅជាទីទឹកក៏បាន គប្បីធ្វើទីទឹកឲ្យទៅជាទីគោកក៏បាន ប្រសិនបើខ្ញុំគប្បីក្រោធខឹង ចំពោះហ្មពស់នោះ ក៏ខ្ញុំគប្បីធ្វើហ្មពស់នោះ ឲ្យទៅជាផេះ ភ្លាមៗក៏បាន ប្រសិនបើខ្ញុំនឹងជាអ្នកប្រព្រឹត្តទៅក្នុងអំណាចនៃចិត្ត ខ្ញុំនឹងសាបសូន្យហើយ ចាកសីល កាលបើខ្ញុំសាបសូន្យចាកសីលហើយ ប្រយោជន៍ ដ៏ឧត្តម នឹងមិនសម្រេចឡើយ ។

(សង្ខបាលជាតក)

សូម្បីក្នុងគ្រាដែលព្រះពោធិសត្វ កើតជាសង្ខបាលនាគរាជ ត្រូវកូនព្រានព្រៃ ១៦ នាក់ ចោះស្រេកីទាំងឡាយ ៨ កន្លែង ដោយលំពែងទាំងឡាយដ៏មុត ហើយរុញវល្លិដែលមានបន្លាចូលទៅតាមមុខរបួសទាំងឡាយ ប្រកខ្សែដែលមាំ តាមច្រមុះ ហើយសែងអូស ដោយសង្រែកមានខ្លួនប៉ះទង្គិចត្រង់ផ្ទៃនៃធរណី ទទួលនូវសេចក្តីទុក្ខដ៏ធំធេង វីងហើយ សូម្បីជាអ្នកអាច ដើម្បីធ្វើនូវកូនព្រានព្រៃទាំងអស់ឲ្យទៅជាផេះ ដោយគ្រាន់តែក្រឡេកមើលប៉ុណ្ណោះ ផ្ចង់ភ្នែកហើយ មិនបានធ្វើហើយសូម្បីត្រឹមតែអាការដែលប្រទូស្ត ។ សមដូចជាលោកពោលហើយ ថា :

បពិត្រអឡារៈ ខ្ញុំរក្សាឧបោសថ ក្នុងថ្ងៃទី១៤ និង ថ្ងៃទី ១៥ ជានិច្ច គ្រានោះ ពួកភោជបុត្រ ១៦ នាក់ កាន់នូវខ្សែ និង អន្ទាក់ដ៏មាំ ដើរមក ព្រានទាំងឡាយទំលាយ (សរីរៈ) យកខ្សែខ្លួសច្រមុះហើយ សែងនាំយកខ្ញុំទៅ ខ្ញុំញុំាងឧបោសថ មិនឲ្យកម្រើក ខំអត់ទ្រាំនូវសេចក្តីទុក្ខទាំងនោះ ។

ក៏ព្រះមានព្រះភាគទ្រង់បានធ្វើនូវគុណគួរអស្ចារ្យ មានប្រការដូចពោលមកប៉ុណ្ណោះ នៅពុំទាន់អស់ជើងទេ ទ្រង់បានធ្វើនូវគុណទាំងឡាយដទៃទៀត ដែលគួរឲ្យអស្ចារ្យជាច្រើន ក្នុងជាតិទាំងឡាយ មានមាតុ-បោសកជាតកជាដើម, អំពើឈ្មោះថា ការញុំាងបដិឃចិត្ត ឲ្យកើតឡើងជាការមិនគួរ គឺ មានសភាពមិនសមគួរក្រៃពេក ដល់អ្នកនោះ ដែលពោលអាងនូវព្រះដ៏មានព្រះភាគអង្គនោះ ដែលក្នុងកាលឥឡូវនេះ ទ្រង់សម្រេចហើយ នូវសព្វញ្ញុតញ្ញាណ មានខន្តីជាគុណ ជាព្រះសាស្តា មិន

មានបុគ្គលណាមួយ ក្នុងលោកព្រមទាំងទេវលោកប្រៀបស្មើបានឡើយ យ៉ាងដូច្នេះឯង ។

(ឧបាយទី៦ ពិចារណាភាពជាញាតិក្នុងវដ្ដសង្សារ)

(១៨២) ក៏ប្រសិនបើ កាលព្រះយោគីនោះ សូម្បីពិចារណា នូវព្រះគុណ គឺកិរិយាប្រព្រឹត្តិក្នុងខាងដើម របស់ព្រះសាស្ដា ដូចដែលបានពោលមកយ៉ាងនេះ, សេចក្ដីថ្នាំងថ្នាក់ចិត្ត របស់ព្រះយោគីអ្នកដល់នូវភាពជាខ្ញុំនៃកិលេសទាំងឡាយ អស់រាត្រីកាលដ៏វែងនោះ នៅតែមិនទាន់ស្ងប់រម្ងាប់ទៀត បន្ទាប់មក ព្រះយោគីនោះ គប្បីពិចារណា នូវភាពនៃសង្សារ មិនមានទីបំផុត ។ មែនពិត ក្នុងអនមតគ្គសូត្រនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ព្រះតម្រាស់នេះ ថា "ម្នាលភិក្ខុទាំងឡាយ សត្វណាមិនធ្លាប់កើតជាមាតា សត្វណា មិនធ្លាប់កើតជាបិតា សត្វណា មិនធ្លាប់កើតជាបងប្អូនប្រុស សត្វណា មិនធ្លាប់កើតជាបងប្អូនស្រី សត្វណា មិនធ្លាប់កើតជាកូនប្រុស សត្វណាមិនធ្លាប់កើតជាកូនស្រី សត្វនោះ គេមិនងាយរកបាន [(១)] " ។ ព្រោះហេតុនោះ ព្រះយោគីគប្បីញ៉ាំងចិត្ត ឲ្យកើតឡើង ក្នុងបុគ្គលនោះ ថា "បានឮថា ក្នុងកាលដែលកន្លងមកហើយ ស្ត្រីនេះ ជាមាតារបស់អញ កាលរក្សានូវផ្ទៃ អស់ ១០ ខែ ក៏មិនខ្ពើមឆ្អើមនាំចេញមកនូវវត្ថុមិនស្អាតទាំងឡាយមានមូត្រ ករីស ទឹកមាត់ និង ទឹកសម្បោរជាដើម ដូចជាគេនាំចេញនូវខ្លឹមចន្ទន៍ក្រហម ផ្ដេកនៅលើទ្រូងពដោយចង្កេះ ចិញ្ចឹមហើយ, (បុរសនេះ) ជាបិតា របស់អញ កាលទៅកាន់ផ្លូវលំបាកទាំងឡាយ មានផ្លូវពពៃ និង ផ្លូវកន្ទេរជាដើម ប្រកបនូវការជួញ លះបង់ទាំងជីវិត ដើម្បីប្រយោជន៍ដល់អញ ហើយចូលទៅក្នុង

១- សុ. សំ. និ. ភាគទី ៣២ ទំព័រទី ១០១ ។

សង្គ្រាមប្រកៀកគ្នាទាំងពីរខាង ស្ទុះទៅក្នុងសមុទ្រ តាមនាវា និង ធ្វើនូវការងារដទៃទៀត ដែលធ្វើបានដោយលំបាក ប្រមូលនូវទ្រព្យ ដោយឧបាយទាំងឡាយនោះៗ ដោយគិតថា "អញនឹងចិញ្ចឹមនូវកូនតូច" ដូច្នេះ ហើយចិញ្ចឹមនូវអាត្មាអញ, បុរសនេះ ជាបងប្អូនប្រុស ស្រីនេះ ជាបងប្អូនស្រី បុរសនេះជាកូនប្រុស និង ស្រីនេះជាកូនស្រី (របស់អាត្មាអញ) ក៏ថាបាន ទាំងបានធ្វើហើយ នូវឧបការៈនេះផងនោះផង ដល់អាត្មាអញ ព្រោះហេតុនោះ ការដែលអាត្មាអញ ញ៉ាំងចិត្តឲ្យប្រទូស្ត ចំពោះបុគ្គលទាំងឡាយនោះ មិនសមគួរសោះឡើយ" ដូច្នេះ ។

(ឧបាយទី៧ ពិចារណាអានិសង្សនៃមេត្តា)

(១៨៣) ក៏ប្រសិនបើព្រះយោគីនោះ នៅតែមិនអាច ដើម្បីរំលត់នូវចិត្ត យ៉ាងដូច្នេះបានទេ បន្ទាប់មក ព្រះយោគីនេះ គប្បីពិចារណាអានិសង្សនៃមេត្តា យ៉ាងនេះថា "ម្នាលបព្វជិតដ៏ចំរើន ក្រែងព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា: ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលបានសេព អប់រំ ធ្វើឲ្យច្រើន ធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាទីតាំងតម្កល់មាំ សន្សំដោយម៉ត់ចត់ ប្រារព្ធល្អហើយ នឹងមានអានិសង្ស ១១ ជាប្រាកដ អានិសង្ស ១១ តើដូចម្ដេចខ្លះ គឺ មេត្តាវិហារិបុគ្គល រមែងដេកលក់ស្រួល ១ ភ្ញាក់ឡើងក៏ស្រួល ១ មិនយល់សប្តអាក្រក់ ១ ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ១ ជាទីស្រឡាញ់នៃអមនុស្សទាំងឡាយ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្ដីថ្នាំពិសក្ដីសស្ត្រាវុធក្ដី រមែងមិនប៉ះពាល់១ បុគ្គលនោះតម្កល់ចិត្តនៅនឹងដ៏ឆាប់រហ័ស១ មានសម្បុរមុខស្រស់បស់១ មិនវង្វេងធ្វើមរណកាល ១ កាលបើមិនទាន់បានត្រាស់ដឹងនូវមគ្គផលទេ គង់បានទៅកើតនៅឯព្រហ្មលោក ១ " ដូច្នេះ ថាបើអ្នកមិនរំលត់នូវចិត្ត

នេះទេ អ្នកនឹងនៅខាងក្រៅអំពីអានិសង្សទាំងនេះ ។

(ទូន្មានខ្លួន ន័យទី៨ ប្រើវិធីបំបែកធាតុ)

(១៨៤) តែបើព្រះយោគី មិនអាចដើម្បីធ្វើចិត្តឲ្យរំលត់ យ៉ាងនេះបានទេ គប្បីធ្វើការវែកញែកធាតុ, តើត្រូវធ្វើដូចម្ដេច? គឺត្រូវទូន្មានខ្លួន ដោយវិធីយ៉ាងនេះថា “នែបព្វជិតដ៏ចំរើន ចុះអ្នកកាលខឹងចំពោះបុគ្គលនេះ អ្នកខឹងដល់អ្នកណា អ្នកខឹងដល់សក់ទាំងឡាយឬ ឬថាដល់រោមទាំងឡាយ ក្រចកទាំងឡាយ ។ល។ អ្នកខឹងដល់ទឹកមូត្រឬ ឬពុំនោះសោត អ្នកខឹងដល់បឋវីធាតុ ក្នុងអាការទាំងឡាយមានសក់ជាដើម ឬ អ្នកខឹងដល់អាបោធាតុ តេជោធាតុ វាយោធាតុឬ? ម្យ៉ាងវិញទៀត លោកដ៏មានអាយុនេះ គេហៅថា មានឈ្មោះយ៉ាងនេះ ព្រោះអាស្រ័យនូវខន្ធ ៥ ទាំងឡាយណា ព្រោះអាស្រ័យនូវអាយតនៈ ១២ ទាំងឡាយណា ព្រោះអាស្រ័យនូវធាតុ ១៦ ទាំងឡាយណា, ក្នុងបញ្ចក្ខន្ធទាំងនោះ តើអ្នកខឹងដល់រូបក្ខន្ធឬ ឬថា អ្នកខឹងដល់វេទនាខន្ធ...សញ្ញាខន្ធ...សង្ខារក្ខន្ធ...និង វិញ្ញាណក្ខន្ធ, ម្យ៉ាងទៀត អ្នកខឹងដល់ចក្ខាយតនៈឬ ឬថា អ្នកខឹងដល់រូបាយតនៈ? ។ល។ អ្នកខឹងដល់មនាយតនៈ ឬ អ្នកខឹងដល់ធម្មាយតនៈ?, ម្យ៉ាងទៀត អ្នកខឹងដល់ចក្ខុធាតុ ឬ អ្នកខឹងដល់រូបធាតុ អ្នកខឹងដល់ចក្ខុវិញ្ញាណធាតុ ។ល។ អ្នកខឹងដល់មនោធាតុ ឬ ខឹងដល់ធម្មធាតុ ឬក៏អ្នកខឹងដល់មនោវិញ្ញាណធាតុ?” ដូច្នេះ ។ មែនពិតហើយ កាលព្រះយោគីនោះ ធ្វើនូវការបំបែកធាតុ ដូចបានពោលមកនេះ ទីជាទីតាំងនៅស៊ប់នៃសេចក្ដីក្រោធ ក៏មិនមាន ដូចជាទីតាំងនៃគ្រាប់ស្ពៃ លើដែកដែលស្រួច មិនមាន និង ដូចជាទីតាំងនៃរូបគំនូរព្លដ៏អាកាស មិនមាន យ៉ាងដូច្នោះឯង ។

(ទូន្មានខ្លួនចុងក្រោយ ធ្វើការវែកញែកនូវទាន)

(១៨៥) តែបើព្រះយោគីនេះ មិនអាច ដើម្បីធ្វើការបំបែកធាតុ (យ៉ាងនេះ) បានទេ គប្បីធ្វើការវែកញែកនូវទាន ។ ព្រះយោគី គប្បីឲ្យវត្ថុដែលជារបស់ខ្លួន ដល់អ្នកដទៃ ។ គប្បីទទួលយក នូវវត្ថុរបស់អ្នកដទៃមក ដើម្បីខ្លួន ។ ក៏ប្រសិនបើអ្នកដទៃ ជាអ្នកមានអាជីពផ្សេងគ្នា មានបរិក្ខារមិនល្មមប្រើប្រាស់ ព្រះយោគីត្រូវឲ្យតែវត្ថុជារបស់ខ្លួនវិញ ។ កាលព្រះយោគីនោះ ធ្វើយ៉ាងនេះ សេចក្ដីគំនុំ ចំពោះបុគ្គលនោះ រមែងស្ងប់រម្ងាប់ ដោយចំណែកមួយមែនពិត ។ ចំណែកសេចក្ដីក្រោធ របស់ព្រះយោគីក្រៅនេះ ស្ទូម្បីជាប់តាមហើយ ចាប់តាំងអំពីអតីតជាតិមក ក៏រមែងស្ងប់រម្ងាប់បាន ក្នុងខណៈនោះភ្លាមដែរ ដូចជាសេចក្ដីក្រោធរបស់ព្រះមហាថេរៈអ្នកបានបាត្រហើយ ដែលព្រះថេរៈ អ្នកប្រព្រឹត្តបិណ្ឌបាតជាវត្ត អ្នកមានសេនាសនៈនៅរួចហើយ អស់វារៈ៣ ដង ក្នុងវត្តឈ្មោះចិត្តលបពិត ពោលថា “បពិត្រព្រះតេជះព្រះគុណ បាត្រនេះ ប្រកបដោយតម្លៃ ៨ កហាបណៈ ដែលឧបាសិកាជាមាតារបស់ខ្ញុំប្រគេនហើយ ជាលាភប្រកបដោយធម៌ សូមព្រះតេជះព្រះគុណធ្វើនូវបុញ្ញលាភ ដល់មហាឧបាសិកាផងចុះ” ដូច្នេះ ប្រគេនហើយ ស្ងប់រម្ងាប់យ៉ាងនោះឯង ។ ពិតមែនហើយ ធម្មតាទាននេះ មានអានុភាពច្រើនយ៉ាងនេះឯង សមដូចលោកពោលហើយ ថា :

> ទានជាគ្រឿងទូន្មានចិត្តដែលមិនទាន់ទូន្មានហើយ ទាន
> ជាគ្រឿងញ៉ាំងប្រយោជន៍ទាំងពួង ឲ្យសំរេចបាន ជន
> ទាំងឡាយ ត្រេកត្រអាលផង ថ្មមចិត្តផង ព្រោះការឲ្យ
> ជាមួយនឹងការពោលពាក្យជាទីស្រឡាញ់ ។

(១៨៦) កាលព្រះយោគីនោះ មានសេចក្ដីថ្នាំងថ្នាក់ចិត្ត ចំពោះបុគ្គលដែលជាសត្រូវ ស្ងប់រម្ងាប់ ដោយវិធីទូន្មានខ្លួន មានប្រការផ្សេងៗ ដូចបានពណ៌នាមកនេះហើយ (មេត្តាចិត្ត ដែលព្រះយោគីឲ្យប្រព្រឹត្តទៅ) ក្នុងបុគ្គលជាទីស្រឡាញ់ ជាទីស្រឡាញ់ក្រៃពេក បុគ្គលជាសំឡាញ់ និងបុគ្គលជាកណ្ដាលទាំងឡាយ យ៉ាងណា ចិត្ត (របស់ព្រះយោគី) រមែងប្រព្រឹត្តទៅដោយអំណាចមេត្តា ក្នុងបុគ្គលមានពៀរនោះ យ៉ាងនុ៎ះដែរ ។

បន្ទាប់មក ព្រះយោគីនេះ កាលញុំាងមេត្តាឲ្យប្រព្រឹត្តទៅរឿយៗ ញុំាងភាពនៃចិត្តដ៏ស្មើ ក្នុងជនទាំង ៤ ពួក គឺ ក្នុងខ្លួនឯង ១ ក្នុងបុគ្គលជាទីស្រឡាញ់ ១ ក្នុងបុគ្គលជាកណ្ដាល ១ ក្នុងបុគ្គលដែលជាសត្រូវ ១ ឲ្យដល់ព្រម គប្បីធ្វើជាសីមសម្ភេទ (ការរួមដែនចូលគ្នា) ។ នេះគឺជាលក្ខណៈ នៃសីមសម្ភេទ [១] នោះ ។

ថាបើ កាលបើបុគ្គលនេះ ជាមួយនឹងបុគ្គលដែលជាទីស្រឡាញ់ បុគ្គលជាកណ្ដាល និង បុគ្គលជាសត្រូវទាំងឡាយ ត្រូវជា ៤ នឹងរូបខ្លួនឯង អង្គុយហើយ ក្នុងប្រទេសមួយ ពួកចោរ បានមកហើយ ពោលថា "បពិត្រព្រះគុណម្ចាស់ សូមព្រះគុណម្ចាស់ ឲ្យនូវភិក្ខុមួយរូប ដល់ពួកយើងខ្ញុំ" ដូច្នេះ, កាលបើបុគ្គលនោះ សួរថា "ព្រោះហេតុអ្វី?" ដូច្នេះ ក៏គប្បីពោលថា "ដើម្បីប្រយោជន៍ ដល់ការសម្លាប់ភិក្ខុនោះ យកឈាមក្នុងបំពង់-ក ហើយធ្វើនូវពលិកម្ម" ។ ក៏ក្នុងរឿងនោះ ភិក្ខុនុ៎ះ គប្បីគិតថា "ពួកចោរ ចូរចាប់យក នូវភិក្ខុឯណោះៗ" ដូច្នេះ, សីមសម្ភេទ ឈ្មោះថា ជាដែនគឺភិក្ខុនោះ មិនបានធ្វើហើយមែនពិត ។ ប្រសិនបើព្រះយោគី គិតថា "ពួកចោរ ចូរចាប់យកនូវអាត្មាអញ ចូរកុំចាប់យក

១- ការផ្សាយមេត្តាចិត្តទៅស្មើ ក្នុងដែនទាំង ៤ នេះ ហៅថា សីមសម្ភេទ ។

នូវភិក្ខុទាំង ៣ រូបឡើយ" ដូច្នេះ, សីមសម្ភេទ ឈ្មោះថា ជាដែនគឺភិក្ខុនោះ មិនបានធ្វើហើយមែនពិត ។ ព្រោះហេតុអ្វី? ។ ព្រោះថា ព្រះយោគី ប្រាថ្នា (ឲ្យពួកចោរ) ចាប់ភិក្ខុណាៗ ក៏ឈ្មោះថា ជាអ្នកមិនស្វែងរកនូវប្រយោជន៍ ឲ្យដល់ភិក្ខុនោះៗ ឈ្មោះថា ជាអ្នកស្វែងរកតែប្រយោជន៍ ឲ្យដល់ភិក្ខុដទៃទៅវិញ ។ ប៉ុន្តែ ក្នុងកាលណា ព្រះយោគីមិនឃើញសូម្បីនូវភិក្ខុមួយរូប ក្នុងចន្លោះ នៃជនទាំង ៤ នាក់ ដែលខ្លួនគប្បីឲ្យដល់ពួករចោរ, ចិត្តដ៏ស្មើតែម្យ៉ាង រមែងប្រព្រឹត្តទៅក្នុងខ្លួនឯងផង ក្នុងជនទាំង ៣ នាក់នោះផង, ក្នុងកាលនោះ សីមសម្ភេទ ឈ្មោះថា ជាដែនគឺព្រះយោគីនោះធ្វើហើយ ដូច្នេះឯង ។ ព្រោះហេតុនោះ បានជាបុរាណាចារ្យទាំងឡាយ ពោលថា :

> ព្រះយោគីណា ជាអ្នកមានចិត្តជាប្រយោជន៍មែនពិតដល់សត្វទាំងឡាយ រមែងឃើញ នូវភាពផ្សេងៗ ក្នុងបុគ្គល ៤ ពួក គឺ ក្នុងខ្លួនឯង ១ ក្នុងបុគ្គលអ្នកប្រាថ្នាប្រយោជន៍ ១ ក្នុងបុគ្គលជាកណ្ដាល ១ ក្នុងបុគ្គលជាអ្នកមិនប្រាថ្នាប្រយោជន៍ ១ ក្នុងកាលណា, ក្នុងកាលនោះ ព្រះយោគីនោះ គឺបណ្ឌិតក៏មិនហៅថា ជាអ្នកឆ្លាត បានមេត្តាតាមដែលខ្លួនប្រាថ្នាទេ, ក្នុងកាលណា សីមាទាំង ៤ គឺភិក្ខុរួមចូលជាមួយគ្នាហើយ ព្រះយោគីផ្សាយមេត្តាស្មើគ្នា ទៅកាន់សត្វលោកទាំងពួង ព្រមទាំងទេវលោកផង ក្នុងកាលនោះ ព្រះយោគីអ្នកមានសីមាមិនប្រាកដ ទើបបានឈ្មោះថា ជាអ្នកវិសេសធំជាងព្រះយោគាវចរមុន ។

(មេត្តាឈាន)

(១៨៧) ចំណែកឯ និមិត្តក្តី ឧបចារក្តី ឈ្មោះថា គឺភិក្ខុនេះបានហើយ អស់កាលដ៏ស្មើ នៃសីមសម្ភេទ យ៉ាងដូច្នេះឯង ។ ក៏កាលបើភិក្ខុនេះ ធ្វើសីមសម្ភេទហើយ ភិក្ខុនោះ កាលសេព ចំរើន ធ្វើឲ្យច្រើន នូវនិមិត្តនោះឯង ឈ្មោះថាបានសម្រេចនូវអប្បនា តាមន័យដែលលោកពោលហើយ ក្នុងបឋវីកសិណឯណោះ ដោយមិនលំបាកឡើយ ។

បឋមជ្ឈាន ប្រកបព្រមដោយមេត្តា ដែលលះនូវអង្គ ៥ ប្រកបដោយអង្គ ៥ មានលំអ ៣ យ៉ាង បរិបូរដោយលក្ខណៈ ១០ ជាឈានដែលព្រះយោគីនោះ បានសម្រេចហើយ ដោយការនៃនានុយោគ មានប្រមាណប៉ុណ្ណោះ ។ ក៏កាលបើបឋមជ្ឈាននោះ គឺព្រះយោគី បានសំរេចហើយ ព្រះយោគីនោះ កាលសេព ចំរើន ធ្វើឲ្យច្រើន នូវនិមិត្តនោះឯងឈ្មោះថា សំរេចនូវទុតិយជ្ឈាន និង តតិយជ្ឈាន ក្នុងចតុក្កន័យផង និងសំរេចនូវទុតិយជ្ឈាន តតិយជ្ឈាន និង ចតុត្ថជ្ឈាន ក្នុងបញ្ចកន័យផងតាមលំដាប់ ។ មែនពិត ព្រះយោគីនោះ ឈ្មោះថា មានចិត្តប្រកបដោយមេត្តា ដោយអំណាចនៃឈានឯណាមួយ បណ្តាឈានទាំងឡាយ មានបឋមជ្ឈានជាដើម ផ្សាយទៅកាន់ទិស ១ ហើយនៅ, ផ្សាយទៅកាន់ទិសទី២ ដូចគ្នា ទិសទី៣ ដូចគ្នា ទិសទី៤ ក៏ដូចគ្នា ទិសខាងលើ ទិសខាងក្រោម ទទឹង ក៏ន័យដូចគ្នានេះដែរ, ព្រះយោគីនោះ មានចិត្តប្រកបដោយមេត្តា ដ៏ទូលាយ ដ៏ធំខ្ពស់ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វគ្រប់អន្លើ ក្នុងទិសទាំងពួង ព្រោះភាពនៃចិត្តទាំងអស់ ហើយនៅ ។ ក៏អប្បនាជាគ្រឿងធ្វើឲ្យប្លែកនេះ រមែងសំរេច ដល់ព្រះយោគីអ្នកមានចិត្តបានដល់ នូវអប្បនា

ដោយអំណាចនៃឈាន មានបឋមជ្ឈានជាដើមតែប៉ុណ្ណោះ ។

(កែបាឡីអប្បមញ្ញា)

ក៏ក្នុងបាឡីនុ៎ះ បទថា “មេត្តាសហគតេន” *សេចក្តីថា ប្រកបព្រមហើយដោយមេត្តា ។ បទថា* “ចេតសា” *គឺមានចិត្ត ។ បទថា* “ឯកំ ទិសំ” *ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដោយអំណាចនៃការផ្សាយទៅកាន់សត្វដែលលោកកាប់បញ្ចូលហើយ ក្នុងទិសមួយ ព្រោះអាស្រ័យនូវសត្វដែលលោកកំណត់ហើយជាដំបូង ក្នុងទិសមួយ ។ បទថា* “ផរិត្វា” *គឺប៉ះពាល់ហើយ បានដល់ធ្វើឲ្យជាអារម្មណ៍ ។ បទថា* “វិហរតិ” *មានសេចក្តីថា ញ៉ាំងកិរិយានៅដោយឥរិយាបថ ដែលខ្លួនបានតាំងទុកហើយ ក្នុងធម៌ជាគ្រឿងនៅដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅ ។ បទថា* “តថា ទុតិយំ” *សេចក្តីថា ព្រះយោគីនោះ ផ្សាយទៅកាន់ទិសណាៗ មួយ ក្នុងទិសទាំងឡាយ មានទិសខាងកើតជាដើម ហើយនៅ យ៉ាងណា, ក៏ផ្សាយទៅកាន់ទិសទី២ ទិសទី៣ និង ទិសទី៤ ក្នុងលំដាប់នៃទិសទី ១ នោះ ក៏យ៉ាងនោះដែរ ។ ពាក្យថា* “ឥតិ ឧទ្ធំ” *ខែសេចក្តីថា និង ដោយន័យដូចគ្នានុ៎ះឯង ក្នុងទិសខាងលើ ។ ពីរបទថា* “អធោ តិរិយំ” *គឺសូម្បីក្នុងទិសខាងក្រោម សូម្បីក្នុងទិសទទឹង ក៏យ៉ាងដូច្នោះដែរ ។ ក៏ក្នុងបទទាំង ២ នោះ បទថា* “អធោ” *គឺទិសខាងក្រោម, បទថា* “តិរិយំ” *បានដល់ទិសតូចទាំងឡាយ ។*

ដោយន័យនេះឯង ព្រះយោគី ឈ្មោះថាញ៉ាំងចិត្ត ដែលប្រកបដោយមេត្តា ឲ្យស្ទុះលឿនទៅផង ឲ្យស្ទុះលឿនត្រឡប់មកវិញផង ក្នុងទិសទាំងពួងទាំងឡាយ ដូចនាយសារថី ញ៉ាំងសេះឲ្យស្ទុះលឿនទៅមកក្នុងមណ្ឌលជាទីលេងសេះ យ៉ាងនោះឯង ។

ព្រះមានព្រះភាគ ទ្រង់សំដែងនូវការផ្សាយមេត្តា ដោយចំពោះព្រោះកំណត់នូវទិសមួយ និង ទិសមួយ ដោយបទបាឡី មានប្រមាណប៉ុណ្ណោះ ។ ចំណែកបទបាឡីជាដើមថា "សព្វធិ" ព្រះអង្គទ្រង់ត្រាស់ហើយ ដើម្បីសំដែង ដោយមិនចំពោះ ។

ក្នុងបទទាំងនោះ បទថា "សព្វធិ" គឺក្នុងទិសទាំងពួង ។ បទថា "សព្វត្តតាយ" សេចក្ដីថា ព្រោះភាពនៃព្រះយោគីជាអ្នកមានខ្លួន ក្នុងសត្វទាំងពួងទាំងឡាយ មានប្រភេទផ្សេងៗ អំពីគ្នា ដូចជាសត្វថ្នាក់ទាបថ្នាក់កណ្ដាល ថ្នាក់ខ្ពង់ខ្ពស់ ដែលជាមិត្រ ជាសត្រូវ និង ជាកណ្ដាលជាដើម ។ អធិប្បាយថា បទថា "អយំ បរសត្តោ" គឺ ព្រោះភាវៈ នៃព្រះយោគីនោះ ជាអ្នកមានខ្លួនស្មើ ព្រោះមិនធ្វើនូវការវែកញែក ។ ន័យមួយទៀត បទថា "សព្វត្តតាយ" សេចក្ដីថាដោយភាពនៃចិត្តទាំងអស់។ អធិប្បាយថា "មិនបានបញ្ជូនចិត្តទៅឰដ៏ខាងក្រៅសូម្បីតែបន្តិចបន្តួច" ។ បទថា "សព្វាវន្តំ" សេចក្ដីថា ដែលមានសត្វសព្វគ្រប់ គឺដែលប្រកបដោយសត្វគ្រប់អន្លើ ។ បទថា "លោកំ" គឺសត្វលោកទាំងអស់ ។

ចំណែកពាក្យថា "ប្រកបដោយមេត្តា" បានជាព្រះមានព្រះភាគទ្រង់ត្រាស់ ម្ដងទៀត ក្នុងការផ្សាយដោយមិនចំពោះនុ៎ះ ព្រោះសំដែងនូវបរិយាយមានពាក្យថា "វិបុលេន ដ៏ទូលាយ" យ៉ាងនេះជាដើម ។ មា្យ៉ាងវិញទៀត ពថា សត្តុក្ដី ឥតិ សត្តុក្ដី ព្រះមានព្រះភាគ មិនទ្រង់ត្រាស់ហើយ ម្ដងទៀត ក្នុងការផ្សាយមិនចំពោះនុ៎ះ ដូចជាក្នុងការផ្សាយចំពោះព្រោះហេតុណា ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ត្រាស់ ម្ដងទៀត ថា "មានចិត្តប្រកបដោយមេត្តា" ។ មួយទៀត ព្រះអង្គទ្រង់ត្រាស់ពាក្យនេះដោយអំណាចនៃពាក្យជាគ្រឿងត្រាស់ថែម ។

(អត្ថនៃវិកុព្វនា)

ក៏ក្នុងបទថា "វិបុលេន" នេះ បណ្ឌិតគប្បីឃើញភាព នៃមេត្តាសហគតចិត្តជាចិត្តទូលាយ ដោយអំណាចនៃការផ្សាយ ។ ក៏មួយទៀតចិត្តនោះ ជាចិត្តដ៏ធំ ដោយអំណាចនៃភូមិ ។ ជាចិត្តមិនមានប្រមាណដោយអំណាចនៃសេចក្ដីស្ទាត់ផង ដោយអំណាចនៃព្រះយោគី មានសត្វជាអារម្មណ៍មានប្រមាណមិនបានផង ។ ឈ្មោះថា ជាចិត្តមិនមានពៀរព្រោះលះបង់នូវសត្រូវ គឺព្យាបាទបាន ។ ឈ្មោះថា ជាចិត្តមិនព្យាបាទព្រោះលះបង់នូវទោមនស្ស ។ មានអធិប្បាយថា "មិនមានទុក្ខ" ។

នេះជាសេចក្ដីនៃវិកុព្វនា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយដោយន័យថា "មានចិត្តប្រកបដោយមេត្តា" ដូច្នេះជាដើម ។ ក៏ឯវិកុព្វនា (ការធ្វើឲ្យជាក់ច្បាស់) នេះ រមែងសំរេច ដល់ព្រះយោគីអ្នកមានចិត្តដល់ហើយនូវអប្បនាតែប៉ុណ្ណោះ យ៉ាងណាមិញ ព្រះសារីបុត្តត្ថេរ ពោលនូវគុណជាតជាគ្រឿងធ្វើឲ្យប្លែកឯណា ក្នុងបដិសម្ភិទាហ្នឹងឯង ថា "មេត្តា-ចេតោវិមុត្តិ (គុណជាតជាគ្រឿងរួចចាកបដិឃៈដោយចិត្តគឺមេត្តា) ផ្សាយដោយមិនមានចំណែក ដោយអាការ ៥ មេត្តាចេតោវិមុត្តិ ផ្សាយដោយមានចំណែក ដោយអាការ ៧ មេត្តាចេតោវិមុត្តិ ផ្សាយទៅកាន់ទិសដោយអាការ ១០ [១] " ដូច្នេះ, បណ្ឌិតគប្បីជ្រាបគុណជាតជាគ្រឿងធ្វើឲ្យប្លែកនោះថា "រមែងសំរេច ដល់ព្រះយោគី អ្នកមានចិត្តដល់ហើយនូវអប្បនា តែប៉ុណ្ណោះឯង" ក៏យ៉ាងនោះដែរ ។

(អនោធិសោផរណា ៥)

ក៏បណ្ដាវិមុត្តិទាំងពីរនោះ បណ្ឌិត គប្បីជ្រាបមេត្តាចេតោវិមុត្តិ

១- សុ. ខុ. បដិ. ភាគទី ៧១ ទំព័រទី ៩៧ ។

មានការផ្សាយដោយមិនចំពោះ ដោយអាការៈទាំងឡាយ ៥ នេះ គឺ

(១) សត្វទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(២) សត្វមានជីវិតទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៣) ភូតទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៤) បុគ្គលទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៥) បុគ្គលទាំងឡាយទាំងពួង ដែលលោករាប់បញ្ចូលហើយក្នុងអត្តភាព ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(ឱធិសោធរណា ៧)

បណ្ឌិតគប្បីជ្រាបមេត្តាចេតោវិមុត្តិ មានផ្សាយដោយចំពោះ ដោយអាការៈទាំងឡាយ ៧ នេះ គឺ

(១) ស្ត្រីទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(២) បុរសទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៣) ព្រះអរិយៈទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៤) បុគ្គលមិនមែនជាព្រះអរិយៈទាំងឡាយទាំងពួងចូរកុំឲ្យមាន

ពៀរ កុំមានព្យាបាទកុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ។

(៥) ទេវតាទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៦) មនុស្សទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៧) សត្វធ្លាក់ក្នុងអបាយទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(ទិសាផរណា ១០)

បណ្ឌិតគប្បីជ្រាបមេត្តាចេតោវិមុត្តិ មានផ្សាយទៅកាន់ទិស ដោយអាការៈទាំងឡាយ ១០ នេះ គឺ

(១) សត្វទាំងឡាយទាំងពួង ក្នុងទិសខាងកើត ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(២) សត្វទាំងឡាយទាំងពួង ក្នុងទិសខាងលិច ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៣) សត្វទាំងឡាយទាំងពួង ក្នុងទិសខាងជើង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៤) សត្វទាំងឡាយទាំងពួង ក្នុងទិសខាងត្បូង ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៥) សត្វទាំងឡាយទាំងពួង ក្នុងទិសអាគ្នេយ៍ ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៦) សត្វទាំងឡាយទាំងពួង ក្នុងទិសពាយ័ព្យ ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្តីសុខ ចូររក្សានូវខ្លួនចុះ ។

(៧) សត្វទាំងឡាយទាំងពួង ក្នុងទិសព្យាសាន ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្ដីសុខ ចូររក្សានូវខ្លួនចុះ ។

(៨) សត្វទាំងឡាយទាំងពួង ក្នុងទិសនិរតី ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្ដីសុខ ចូររក្សានូវខ្លួនចុះ ។

(៩) សត្វទាំងឡាយទាំងពួង ក្នុងទិសខាងក្រោម ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្ដីសុខ ចូររក្សាខ្លួនចុះ ។

(១០) សត្វទាំងឡាយទាំងពួង ក្នុងទិសខាងលើ ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្ដីសុខ ចូររក្សានូវខ្លួនចុះ ។

សត្វមានជីវិតទាំងឡាយទាំងពួង... ភូតទាំងឡាយទាំងពួង... បុគ្គលទាំងឡាយទាំងពួង...ពួកសត្វដែលលោករាប់បញ្ចូលអត្តភាពទាំងឡាយទាំងពួង... ក្នុងទិសខាងកើត... ពួកស្ត្រីទាំងឡាយទាំងពួង...បុរសទាំងឡាយទាំងពួង... ព្រះអរិយៈទាំងឡាយទាំងពួង... ពួកមិនមែនព្រះអរិយៈទាំងឡាយទាំងពួង... ទេវតាទាំងឡាយទាំងពួង... មនុស្សទាំងឡាយទាំងពួង... ពួកវិនិបាតិកៈទាំងពួង ក្នុងទិសខាងកើត ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្ដីសុខ ចូររក្សាខ្លួនចុះ ។

សត្វមានជីវិតទាំងឡាយទាំងពួង ។ល។ ស្ត្រីទាំងឡាយទាំងពួង ។ល។ វិនិបាតិកៈទាំងឡាយទាំងពួង ក្នុងទិសខាងលិច.. ក្នុងទិសខាងជើង...ក្នុងទិសខាងត្បូង..ក្នុងទិសអាគ្នេយ៍...ក្នុងទិសខាងលិច...ក្នុងទិសខាងជើង... ក្នុងទិសនិរតី... ក្នុងទិសខាងក្រោម... ក្នុងទិសខាងលើ ចូរកុំឲ្យមានពៀរ កុំមានព្យាបាទ កុំឲ្យមានទុក្ខ មានតែសេចក្ដីសុខ ចូររក្សានូវខ្លួនចុះ ” ។

ក្នុងបទទាំងនោះ បទថា “សព្វេ” នោះ ជាពាក្យសំរាប់ប្រមូល

មកនូវស័ព្ទមិនឲ្យសេសសល់ ។ បុគ្គលអ្នកជាប់ហើយ គឺ ជំពាក់ហើយដោយឆ័ន្ទរាគៈ ក្នុងខន្ធទាំងឡាយមានរូបជាដើម ឈ្មោះថា សត្វ ។ សមដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ ថា “ម្នាលរាធៈ សេចក្ដីពេញចិត្តណា សេចក្ដីត្រេកអរណា សេចក្ដីរីករាយណា សេចក្ដីប្រាថ្នាណា ក្នុងរូប បុគ្គលដែលជាប់នៅ ក្នុងសេចក្ដីពេញចិត្តជាដើមនោះ ជំពាក់នៅ ក្នុងសេចក្ដីពេញចិត្តជាដើមនោះ ហេតុនោះ លោកហៅថា សត្វ, សេចក្ដីពេញចិត្តណា សេចក្ដីត្រេកអរណា សេចក្ដីរីករាយណា សេចក្ដីប្រាថ្នាណា ក្នុងវេទនា...ក្នុងសញ្ញា...ក្នុងសង្ខារ...ក្នុងវិញ្ញាណ បុគ្គលដែលជាប់នៅក្នុងសេចក្ដីពេញចិត្តជាដើមនោះ ជំពាក់នៅក្នុងសេចក្ដីពេញចិត្តជាដើមនោះ ព្រោះហេតុនោះ លោកហៅថា សត្វ [១] ” ដូច្នេះ ។ តែដោយស័ព្ទដែលប្រើដោយជេរជាស វោហារថា (សត្វ) នេះ ប្រព្រឹត្តទៅ ក្នុងបុគ្គលទាំងឡាយដែលមានរាគៈទៅប្រាសហើយផងដែរ ។ ដូចវោហារថា ផ្ចិតស្ទឹកត្នោត ប្រព្រឹត្តទៅក្នុងផ្ចិតដ៏វិសេស ដែលសំរេចអំពីបន្ទោះនៃឫស្សី ដូច្នោះ ។ ចំណែកខាង អ្នកគិតគូរអំពីអក្ខរៈទាំងឡាយ មិនពិចារណានូវសេចក្ដី ក៏ត្រូវការ ថា “ពាក្យថាសត្វនេះ គ្រាន់តែជាឈ្មោះប៉ុណ្ណោះ” ។ ចំណែកឯអាចារ្យពួកណាប្រាថ្នានូវសេចក្ដី អាចារ្យពួកនោះប្រាថ្នាសេចក្ដីថា “ឈ្មោះថា សត្វ ព្រោះប្រកបដោយការជាប់ជំពាក់” ។

សត្វទាំងឡាយ ឈ្មោះថាមានជីវិត ព្រោះភាវៈនៃសត្វមានខ្យល់ដង្ហើម អធិប្បាយថា ព្រោះកិរិយាប្រព្រឹត្តិទៅជាប់មិនដាច់ក្នុងខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល ។

ឈ្មោះថា ពួកភូត ព្រោះភាវៈនៃសត្វទាំងនោះជាសត្វកើតហើយ

១- សុ. សំ. ខ. ភាគទី ៣៨ ទំព័រទី ៧៣ ។

អធិប្បាយថា ព្រោះភាវៈនៃសត្វនោះ កើតព្រមហើយ គឺកើតធំធាត់ឡើងហើយ ។

និរយៈ លោកហៅថា ប៉ុំ ពួកសត្វណា លេបចូលទៅ ក្នុងនិរយៈដែលហៅថា ប៉ុំ នោះ ព្រោះហេតុនោះ ពួកសត្វនោះ ឈ្មោះថា បុគ្គល, អធិប្បាយថា ពួកសត្វនោះ តែងទៅ ។

រាងកាយ លោកហៅថា អត្តភាព ឬថា ខន្ធទាំង ៥ ហ្នឹងឯង លោកហៅថាអត្តភាព, ពាក្យថា អត្តភាពនេះ គឺគ្រាន់តែជាពាក្យបញ្ញត្តិ ព្រោះសំដៅយកខន្ធប្រាំនោះ តាមសភាវៈ, សត្វទាំងឡាយដែលលោករាប់បញ្ចូលហើយ ក្នុងអត្តភាពនោះ ព្រោះហេតុនោះ សត្វទាំងឡាយនោះ ទើបឈ្មោះថា អត្តភាវបរិយាបន្នា, អធិប្បាយថា "សភាវៈទាំងឡាយដែលលោកកំណត់ហើយ ឈ្មោះថា គឺលោករាប់បញ្ចូលហើយ គឺជាប់ចូលហើយ ឲ្យជំពាក់ក្នុង" ដូច្នេះ ។

ក៏ពាក្យថា "ពួកសត្វ" ដូច្នេះ យ៉ាងណា សូម្បីពាក្យដ៏សេសទាំងឡាយ ក៏យ៉ាងដូច្នោះដែរ, ពាក្យទាំងអស់នេះហ្នឹងឯង បណ្ឌិតគប្បីជ្រាបថា "ជាពាក្យផ្លាស់ប្ដូរ នៃសត្វទាំងអស់ ព្រោះលើកឡើង ដោយអំណាចនៃស័ព្ទដែលប្រើញឹកញយ" ។

សូម្បីពាក្យទាំងឡាយដទៃថា "សព្វេ ជន្តូ សព្វេ ជីវា" ដូច្នេះជាដើម ជាពាក្យផ្លាស់ប្ដូរនៃសត្វទាំងអស់តែងមានទៀតក៏ពិតមែនហើយ បើទុកជាដូច្នោះក៏ដោយ ព្រះមានព្រះភាគត្រាស់ថា "មេត្តា ចេតោវិមុត្តិ មានកិរិយាផ្សាយទៅ ដោយមិនចំពោះ ដោយអាការៈទាំងឡាយ ៥" ព្រោះកាន់យកនូវអាការៈទាំង ៥ នេះឯង ដោយអំណាចនៃ(អាការៈទាំង ៥ នោះ) ជាពាក្យប្រាកដ ។ បើពួកអាចារ្យណា មិនត្រូវការដល់ពាក្យ

ទាំងឡាយមានពាក្យថា "សត្តា បាណា" ដូច្នេះជាដើម ព្រោះត្រឹមតែពាក្យផ្លាស់ប្ដូរតែប៉ុណ្ណោះ, បើតាមពិតទៅ ចង់បាននូវពាក្យផ្សេងៗ តែម្យ៉ាង តាមសេចក្ដីអធិប្បាយផងដែរ, មតិរបស់អាចារ្យទាំងនោះ បណ្ឌិតពោលថា "ផ្សាយទៅ ដោយមិនចំពោះ" ។ ព្រោះហេតុនោះ ព្រះយោគីមិនគួរកាន់យកនូវសេចក្ដី ដោយប្រការដូច្នោះ គប្បីផ្សាយមេត្តា ដោយមិនចំពោះ ដោយអំណាចនៃអាការៈណាមួយ ក្នុងអាការៈទាំង ៥ នេះ ។

(អប្បនា ៥២៨)

ក៏ក្នុងបទមាតិកាទាំងនុ៎ះ មាតិកានេះ ថា "សព្វេ សត្តា អវេរា ហោន្តុ" ដូច្នេះ ឈ្មោះថា ជាអប្បនា ១ ។ មាតិកានេះ ថា "អព្យាបជ្ឈា ហោន្តុ" ដូច្នេះ ឈ្មោះថា ជាអប្បនា ១ ។ ពាក្យថា "អព្យាបជ្ឈា" សេចក្ដីថា ដែលប្រាសចាកសេចក្ដីព្យាបាទ ។ មាតិកានេះថា "អនីឃា ហោន្តុ" ដូច្នេះ ឈ្មោះថា ជាអប្បនា ១ ។ បទថា "អនីឃា" គឺ មិនមានទុក្ខ ។ មាតិកាថា "សុខី អត្តានំ បរិហរន្តុ" ដូច្នេះ ឈ្មោះថា ជាអប្បនា ១ ។ ព្រោះហេតុនោះ បណ្ដាបទទាំងនេះ បទណាៗ ជាបទប្រាកដ ព្រះយោគីគប្បីផ្សាយមេត្តា ដោយអំណាចនៃបទនោះៗ ចុះ ។

ដោយន័យដូចរៀបរាប់មកនេះ អប្បនា ក្នុងការផ្សាយ ដោយមិនចំពោះ មាន ២០ ដោយអំណាចនៃអប្បនាទាំងឡាយ ៤ ក្នុងអាការៈទាំងឡាយ ៥ ។ ចំណែក ក្នុងការផ្សាយដោយចំពោះ មានអប្បនា ២៨ ដោយអំណាចនៃអប្បនាទាំងឡាយ ៤ ក្នុងអាការៈទាំងឡាយ ៧ ។

ក៏ក្នុងអាការៈទាំង ៧ នោះ បទថា "ពួកស្ត្រី ពួកបុរស" ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដោយអំណាចនៃលិង្គ, បទថា "ពួកព្រះអរិយៈ ពួកមិនមែនព្រះអរិយៈ" ទ្រង់ត្រាស់ដោយអំណាចនៃព្រះអរិយៈ

និង បុថុជ្ជន, បទថា “ពួកទេវតា ពួកមនុស្ស ពួកវិនិបាតិកៈ” ទ្រង់ត្រាស់ហើយ ដោយអំណាចនៃកំណើតកើតឯង ។

ចំណែកក្នុងការផ្សាយទៅកាន់ទិស អប្បនា មានដល់ទៅ ៤៨០ គឺ ២០០ ព្រោះធ្វើនូវអប្បនាទាំងឡាយ ២០ ៗ ក្នុងទិសមួយនិងមួយ ដោយអំណាចនៃន័យមានន័យថា “សព្វេ បុរត្ថិមាយ ទិសាយ សត្តា” ដូច្នេះជាដើម គឺ ២៨០ ព្រោះធ្វើនូវអប្បនាទាំងឡាយ ២៨ ៗ ក្នុងទិសមួយ និង មួយ ដោយន័យមានន័យថា “សព្វា បុរត្ថិមាយ ទិសាយ ឥត្ថិយោ” ដូច្នេះជាដើម ។

បើរួបរួមទៅ អប្បនាទាំងអស់ហ្នឹងឯង ត្រូវជាអប្បនា ៥២៨ ដែលព្រះធម្មសេនាបតី ពោលហើយ ក្នុងបដិសម្ភិទា ដូច្នេះឯង ។

(កែអត្ថមេត្តានិសង្ស)

ព្រះយោគាវចរនេះ លុះចំរើនមេត្តាចេតោវិមុត្តិ ដោយអំណាចនៃអប្បនាណាមួយ ក្នុងចំណោមអប្បនាទាំងនេះ ដូចបានពណ៌នាមកហើយនេះ រមែងបាននូវអានិសង្ស ១១ យ៉ាង ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដោយន័យថា “អ្នកចំរើនមេត្តាចេតោវិមុត្តិ រមែងដេកលក់ស្រួល” ដូច្នេះជាដើម ។

ក្នុងអានិសង្ស ១១ យ៉ាងនោះ បទថា “រមែងដេកលក់ស្រួល” មានសេចក្តីថា ជនទាំងឡាយដ៏សេស រមែងដេកលក់ បម្រះននៀលស្រមុក ជាទុក្ខ យ៉ាងណាមិញ, បុគ្គលអ្នកបានមេត្តាចេតោវិមុត្តិ មិនដេកលក់ យ៉ាងនោះទេ រមែងដេកលក់ស្រួល សូម្បីចូលដល់ការលង់លក់ហើយ ក៏ហាក់បីដូចជាចូលសមាបត្តិអីចឹង ។

បទថា “ភ្ញាក់ឡើងជាសុខ” សេចក្តីថា ពួកជនដទៃ ភ្ញាក់ឡើង

ថ្ងូរ ពត់ (ខ្លួន) បម្រះននៀលទៅមកជាទុក្ខ យ៉ាងណាមិញ, បុគ្គលអ្នកចំរើនមេត្តាចេតោវិមុត្តិ មិនភ្ញាក់ឡើង យ៉ាងដូច្នោះទេ រមែងភ្ញាក់ឡើង ជាសុខ គឺមិនមានអាការៈខុសប្លែក ដូចផ្កាឈូកដែលកំពុងតែរីក ដូច្នោះ ។

បទថា “មិនសុបិនអាក្រក់” សេចក្តីថា បុគ្គលអ្នកចំរើនមេត្តា-ចេតោវិមុត្តិនោះ សូម្បីយល់សុបិន ក៏រមែងយល់ឃើញសុបិនដែលល្អតែម្យ៉ាងប៉ុណ្ណោះ ហាក់ដូចជាកំពុងថ្វាយបង្គំព្រះចេតិយ ដូចជាកំពុងធ្វើការបូជា និង ដូចជាកំពុងស្តាប់ព្រះធម៌ ។ ចំណែកខាង ពួកបុគ្គលដទៃឃើញនូវខ្លួន ហាក់បីដូចជាត្រូវពួកចោរព័ទ្ធចាប់ផង ហាក់បីដូចជាត្រូវពួកម្រឹគសាហាវចូលទៅប្រទូស្តផង និង ហាក់បីដូចជាកំពុងធ្លាក់ចុះទៅក្នុងជ្រោះផង យ៉ាងណាមិញ, បុគ្គលអ្នកចំរើននូវមេត្តាចេតោវិមុត្តិ មិនសុបិនអាក្រក់ យ៉ាងដូច្នោះទេ ។

បទថា “ជាទីស្រឡាញ់នៃពួកមនុស្ស” សេចក្តីថា បុគ្គលអ្នកចំរើនមេត្តាចេតោវិមុត្តិនោះ រមែងជាទីស្រឡាញ់ គឺជាទីពេញចិត្ត នៃមនុស្សទាំងឡាយ ហាក់បីដូចជាកែវមុក្តាសំរាប់ពាក់ត្រង់ទ្រូង និង ហាក់បីដូចជាផ្កាកម្រងសំរាប់ប្រដាប់ព្ធដ៏ក្បាល យ៉ាងដូច្នោះ ។

បទថា “ជាទីស្រឡាញ់នៃពួកអមនុស្ស” សេចក្តីថា បុគ្គលអ្នកចំរើនមេត្តាចេតោវិមុត្តិនោះ រមែងជាទីស្រឡាញ់ នៃមនុស្សទាំងឡាយ យ៉ាងណាមិញ, ក៏រមែងជាទីស្រឡាញ់ នៃអមនុស្សទាំងឡាយ ក៏យ៉ាងដូច្នោះដែរ ប្រៀបដូចជាព្រះថេរៈ ឈ្មោះ វិសាខៈ ។

(រឿងព្រះវិសាខត្ថេរ)

បានឮមកថា ព្រះថេរៈ ឈ្មោះវិសាខៈនោះ បានជាកុដុម្ពិក៍ នៅក្នុងទីក្រុងបាដលីបុត្រ ។ កុដុម្ពិក៍នោះ កាលនៅ ក្នុងទីក្រុងបាដលីបុត្រ

នោះឯង បានដឹងពត៌មានថា "ឮមកថា តម្ពបណ្ណិទ្វីប ត្រូវគេតាក់តែងហើយ ដោយកម្រងផ្កាក្នុងចេតិយ ដ៏រុងរឿង ដោយសំពត់កាសាវៈ អ្នកណាក៏ដោយ អាចដើម្បីអង្គុយក្តី ដេកក្តី ក្នុងទីនោះ ជាទីដែលខ្លួនត្រូវការហើយៗ ហ្នឹងឯង សេចក្តីសប្បាយគ្រប់យ៉ាង គឺ ឧតុសប្បាយ សេនាសនសប្បាយ បុគ្គលសប្បាយ ធម្មស្សវនសប្បាយ គឺគេរកបានដោយស្រួល ក្នុងទីនោះ ។ កុដុម្ពីក៏នោះ ប្រគល់គំនរភោគៈរបស់ខ្លួន ឲ្យដល់បុត្រ និង ភរិយា មានតែមួយកហាបណៈប៉ុណ្ណោះឯង ដែលខ្លួនវេចត្រង់ជាយសំពត់ ចាកចេញអំពីផ្ទះ រង់ចាំនាវា ត្រង់ច្រាំងនៃសមុទ្រ នៅហើយអស់មួយខែ ។ គួរឲ្យស្ងើចមែន ព្រោះគាត់ជាអ្នកឆ្លាតក្នុងវោហារ គាត់ទិញកណ្ឌៈ ក្បែរទ្វារនេះ យកទៅលក់ក្បែរទ្វារឯនោះ ទើបសន្សំនូវទ្រព្យបានមួយពាន់កហាបណៈ ដោយរវាងមួយខែ ដែលរង់ចាំនាវានោះឯង ដោយការជួញប្រែដែលប្រកបដោយធម៌ ។ គាត់ក៏បានមកដល់មហាវិហារ ដោយលំដាប់ហើយក៏បានសូមផ្នួស ។ គាត់ត្រូវពួកភិក្ខុនាំយកទៅកាន់សីមា ដើម្បីប្រយោជន៍ដល់ការសាងផ្នួស បានទម្លាក់នូវថង់ប្រាក់មួយពាន់កហាបណៈនោះ ត្រង់ទីកន្លែងតាមចន្លោះក្រវិលឡេវ, លុះដល់ពួកភិក្ខុសួរថា "មួយនេះគឺជាអ្វី?" ក៏ឆ្លើយទូលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន គឺកហាបណៈមួយពាន់" ត្រូវពួកភិក្ខុប្រាប់ថា "នែឧបាសក ចាប់ដើមអំពីកាលដែលអ្នកបួសហើយ អ្នកមិនអាច ដើម្បីចាយវាយវាបានទេ ឥឡូវនេះឯង ចូរអ្នកចាយវាយវាចុះ" ដូច្នេះហើយ ក៏ប្រកាសថា "មនុស្សទាំងឡាយដែលមកកាន់ទីកន្លែងសាងផ្នួស របស់ឧបាសកឈ្មោះវិសាខៈហើយ កុំមានដៃទទេ ទៅវិញឡើយ" ដូច្នេះហើយ ក៏បានស្រាយរោយរាយ ទៀបរោងសីមា បួសហើយបានឧបសម្បទាហើយ ។

វិសាខភិក្ខុនោះ មានវស្សាគ្រប់ ៥ ហើយ ធ្វើមាតិកា ២ ឲ្យស្ទាត់ លុះបវារណាហើយ ក៏រៀននូវកម្មដ្ឋានជាទីសប្បាយដល់ខ្លួន ធ្វើខែទាំងឡាយបួន ក្នុងវត្តមួយៗ ឲ្យជាបួនៗ ខែ នៅបំពេញវត្តប្រតិបត្តិ យ៉ាងស្មើ ។

លុះដល់ព្រះថេរៈឈ្មោះវិសាខៈ កាលប្រព្រឹត្តយ៉ាងនេះ
ឋិតនៅ ត្រង់ចន្លោះនៃព្រៃ ស្វែងរកនូវគុណ របស់ខ្លួន
កាលបន្លឺ ក៏បានពោលសេចក្តីនេះថា "ដរាបតាំងតែ
អាត្មាអញឧបសម្បន្នហើយ ដរាបតាំងតែអាត្មាអញ
មកហើយក្នុងទីនេះ សេចក្តីភ្លាំងភ្លាត់ ក្នុងចន្លោះ ក្នុង
ព្រៃនេះ មិនមានទេ ម្នាលអ្នកនិទ្ទុក្ខទាំងឡាយ មាន
លាភទាំងឡាយអ្វីម្ល៉េះទេ" ។

ព្រះថេរៈនោះ កាលទៅកាន់វត្តឈ្មោះចិត្តលបព៌ត បានទៅដល់ផ្លូវបែកជា ២ ហើយ ឈរគិតថា "ផ្លូវនេះឬហ្ន៎ ឬក៏ផ្លូវនេះ" ។ គ្រានោះ ទេវតាដែលអាស្រ័យនៅលើភ្នំរបស់លោក ក៏លាដៃចង្អុលប្រាប់ថា "ផ្លូវនុ៎ះ" ។ ព្រះថេរៈនោះ នៅលើចិត្តលបព៌ត អស់ ៤ ខែ គិតថា "អាត្មាអញនឹងទៅ ក្នុងពេលទៀបភ្លឺ" ហើយក៏សិងលក់ទៅ ។ ទេវតាដែលអាស្រ័យនៅលើដើមច័ន្ទន៍ទេស លើក្បាលនៃទីចង្រ្កម អង្គុយខ្សឹកខ្សួលហើយលើកាំជណ្តើរ ។ ព្រះថេរៈសួរថា "អ្នកណានុ៎ះ?" ។ ទេវតាឆ្លើយថា "បពិត្រព្រះគុណម្ចាស់ ខ្ញុំឈ្មោះមណិលយៈ" ។ ព្រះថេរៈសួរថា "អ្នកយំដើម្បីអ្នកណា?" ។ ទេវតាឆ្លើយថា "ព្រោះអាស្រ័យការនិមន្តទៅនៃព្រះគុណម្ចាស់" ។ ព្រះថេរៈសួរថា "កាលអាត្មានៅក្នុងទីនេះ តើមានគុណដូចម្តេច ដល់អ្នក?" ។ ទេវតាឆ្លើយថា "បពិត្រព្រះគុណម្ចាស់ កាលបើព្រះ

គុណម្ចាស់នៅក្នុងទីនេះ ពួកមនុស្ស តែងបាននូវមេត្តាដល់គ្នានឹងគ្នា, ក្នុងកាលឥឡូវនេះ ពួកមនុស្សទាំងនោះ កាលបើព្រះគុណម្ចាស់ និមន្តទៅហើយ នឹងធ្វើនូវជំលោះ នឹងពោលនូវពាក្យដែលអាក្រក់” ។ ព្រះថេរៈពោលថា “ប្រសិនបើ កាលអាត្មា នៅក្នុងទីនេះ ការនៅជាសុខសប្បាយតែងមាន ដល់អ្នកទាំងឡាយ, នុ៎ះជាការដែលល្អ” ហើយក៏នៅ ក្នុងចិត្តលបព៌តនោះឯង អស់ ៤ ខែ ទៀត ហើយញ៉ាំងចិត្តគិតនឹងទៅ ឲ្យកើតឡើង យ៉ាងដូច្នោះឯង ម្តងទៀត ។ ឯទេវតា ក៏យំហើយ ដោយប្រការដូច្នោះម្តងទៀតដែរ ។ ព្រះថេរៈ នៅហើយ ក្នុងចិត្តលបព៌តនោះដដែល ដោយឧបាយនេះ បរិនិព្វានហើយ ក្នុងចិត្តលបព៌តនោះឯង ។ ភិក្ខុអ្នកមានកិរិយានៅដោយមេត្តា រមែងជាទីស្រឡាញ់ នៃអមនុស្សទាំងឡាយ យ៉ាងនេះឯង ។

បទថា “ទេវតា តែងរក្សា” សេចក្តីថា ពួកទេវតា តែងថែរក្សាដូចជាមាតា និង បិតាទាំងឡាយ រក្សានូវបុត្រ យ៉ាងនោះឯង ។

បទថា “ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី មិនប៉ះពាល់ដល់អ្នកដែលនៅដោយមេត្តានោះ” សេចក្តីថា ភ្លើងក្តី មិនរលាក គឺមិនប៉ះពាល់ ក្នុងកាយ របស់អ្នកមានកិរិយានៅដោយមេត្តា ដូចជាភ្លើង មិនរលាកដល់ឧបាសិកាឈ្មោះឧត្តរាដូច្នោះ, ថ្នាំពិសក្តី មិនរលាក គឺមិនចូលទៅ ក្នុងកាយ របស់អ្នកមានកិរិយានៅដោយមេត្តា ដូចជាថ្នាំពិស មិនចូលទៅ ក្នុងកាយ របស់ព្រះចូឡសិវត្ថេរ អ្នកពោលគម្ពីរសំយុត្តនិកាយដូច្នោះ, គ្រឿងសស្ត្រាវុធក្តី មិនប៉ះពាល់ គឺមិនចូលទៅ ក្នុងកាយ របស់អ្នកដែលមានកិរិយានៅដោយមេត្តានោះ ដូចជាគ្រឿងសស្ត្រាវុធ មិនប៉ះពាល់ ក្នុងកាយ របស់សំកិច្ចសាមណេរ យ៉ាងដូច្នោះឯង ។ មានពាក្យ

អធិប្បាយថា “ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី ញុំាងកាយ របស់អ្នកមានកិរិយានៅដោយមេត្តានោះ ឲ្យកម្រើកមិនបានទេ” ។ តួយ៉ាងក្នុងរឿងនៃអ្នកមានកិរិយានៅដោយមេត្តានេះ បណ្ឌិតគប្បីសំដែងនូវរឿងមេគោផងក៏បាន ។

បានឮមកថា មេគោមួយក្បាលកំពុងតែឈរបង្ហូរនូវទនៃទឹកដោះស្រស់ដល់កូនគោ ។ ព្រានម្នាក់ គិតថា “អញនឹងសម្លាប់មេគោនោះ” តំរង់ដោយដៃហើយ ក៏ពួយលំពែងដែលមានដងវែងទៅ ។ លំពែងនោះទៅប៉ះនូវសរីរៈមេគោនោះហើយ ក៏របូតទៅហើយ ដូចជាស្លឹកត្នោត ។ លំពែងនោះ ទៅផុតហើយ ព្រោះភាវៈនៃមេគោនោះ ជាសត្វមានសេចក្តីស្រឡាញ់ដ៏មានកំឡាំង ក្នុងកូនគោតែប៉ុណ្ណោះ មិនមែនដោយកំឡាំង នៃឧបចារៈ មិនមែនដោយកំឡាំងនៃអប្បនាទេ, មេត្តា មានអានុភាពច្រើនយ៉ាងនេះឯង ។

បទថា “បុគ្គលនោះ តំកល់ចិត្តនៅនឹងដ៏ឆាប់រហ័ស” សេចក្តីថា ចិត្ត របស់បុគ្គលអ្នកនៅដោយមេត្តា រមែងតាំងនៅមាំឆាប់ភ្លាម, ភាពយឺតយូរ នៃចិត្តជាសមាធិនោះ មិនមាន ។

បទថា “មានសម្បុរមុខស្រស់បស់” សេចក្តីថា ក៏មុខ របស់បុគ្គលអ្នកនៅដោយមេត្តានោះ ជាមុខមានសម្បុរដ៏ថ្លា ដូចជាផ្លែត្នោតទុំដែលរលេះចាកទង ។

បទថា “មិនវង្វេងធ្វើមរណកាល”សេចក្តីថា ធម្មតាសេចក្តីស្លាប់ដោយការវង្វេងវង្វន់ មិនមាន ដល់បុគ្គលអ្នកនៅដោយមេត្តាទេ, បុគ្គលអ្នកនៅដោយមេត្តា មិនវង្វេងវង្វន់ឡើយ ធ្វើមរណកាល ដូចជាបុគ្គលកំពុងដេកលក់ យ៉ាងនោះឯង ។

បទថា "កាលបើមិនទាន់បានត្រាស់ដឹងនូវមគ្គផលទេ" សេចក្តីថា បុគ្គលអ្នកនៅដោយមេត្តានោះ កាលមិនអាច ដើម្បីត្រាស់ដឹងនូវព្រះអរហត្ត ដ៏ខ្ពង់ខ្ពស់ ជាងមេត្តាសមាបត្តិបានទេ លុះច្យុតចាកអត្តភាពនេះ រមែងចូលទៅកាន់ព្រហ្មលោក ដូចជាលក់ហើយភ្ញាក់ឡើងយ៉ាងដូច្នោះ ។ នេះជាកថា យ៉ាងពិស្តារ ក្នុងមេត្តាភាវនា ។

(ករុណាព្រហ្មវិហារ)

(១៨៨) ចំណែកខាង ព្រះយោគីអ្នកប្រាថ្នាដើម្បីចំរើននូវករុណា គប្បីពិចារណានូវទោស នៃការមិនមានករុណាផង និង នូវអានិសង្ស នៃករុណាផងហើយ ចាប់ផ្តើមចំរើនករុណាព្រហ្មវិហារ ។ ក៏ព្រះយោគី កាលចាប់ផ្តើមចំរើន នូវករុណានោះ មិនត្រូវចាប់ផ្តើម ក្នុងបុគ្គលដែលមានទោសដល់ភាវនា មានបុគ្គលដែលជាទីស្រឡាញ់ជាដើម មុនទេ ។ ព្រោះថា សេចក្តីស្រឡាញ់ តែងឋិតនៅក្នុងឋានៈជាទីស្រឡាញ់ហ្នឹងឯង, បុគ្គលជាសំឡាញ់ជាទីស្រឡាញ់ក្រៃពេក តែងឋិតនៅក្នុងឋានៈនៃបុគ្គលជាសំឡាញ់ជាទីស្រឡាញ់ក្រៃពេកមែនពិត, បុគ្គលជាកណ្តាល តែងឋិតនៅក្នុងឋានៈជាកណ្តាលហ្នឹងឯង, បុគ្គលមិនជាទីស្រឡាញ់ តែងឋិតនៅក្នុងឋានៈមិនជាទីស្រឡាញ់មែនពិត, បុគ្គលជាសត្រូវ តែងឋិតនៅ ក្នុងឋានៈជាសត្រូវមែនពិត។ ភាពនៃបុគ្គលអ្នកមានភេទខុសគ្នា និង បុគ្គលដែលស្លាប់ហើយ មិនមែនជាខេត្តដែន (ដែលត្រូវផ្សាយករុណា) ទេ ។ ប៉ុន្តែបើព្រះយោគី ឃើញនូវបុរសណាមួយហ្នឹងឯង ជាអ្នកដែលគួរឲ្យអាណិតអាសូរ មានរូបរាងប្លែក ដល់នូវសេចក្តីលំបាកក្រៃលែង ជាអ្នកទុគ៌ត មានរូបអាក្រក់ ជាមនុស្សកំព្រា កំបុតដៃជើង ដាក់អំបែងពីមុខដេកលើសាលាគ្មានទីពឹង មានហ្វូងដង្កូវកំពុងវារចេញ តាមដៃជើងទាំង

ឡាយ កំពុងធ្វើសំឡេងថ្ងូរ គប្បីញុំាងករុណា ឲ្យប្រព្រឹត្តទៅ មុនគេទាំងអស់ ថា "ឱហ្ន៎ សត្វនេះ ដល់ហើយនូវសេចក្តីលំបាក ធ្វើដូចម្តេចទៅហ្ន៎ សត្វនេះ គប្បីរួចចាកសេចក្តីទុក្ខនេះបាន" ដូច្នេះ ព្រោះលោកបានពោលហើយ ក្នុងវិភង្គ ថា "ចុះភិក្ខុ មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិស ១ សម្រាន្តនៅ តើដូចម្តេច ។ បុគ្គល ឃើញនូវបុគ្គលម្នាក់ ជាអ្នកក្រីក្រ ដល់នូវសេចក្តីលំបាក ហើយផ្សាយករុណា យ៉ាងណាមិញ, ភិក្ខុ ផ្សាយករុណា ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង [១] " ។

ព្រះយោគី កាលមិនបាន នូវបុគ្គលដែលដល់ហើយ នូវសេចក្តីលំបាកនោះទេ សូម្បីបុគ្គលដែលដល់ហើយនូវសេចក្តីសុខ តែជាអ្នកធ្វើនូវអំពើអាក្រក់ ក៏គប្បីផ្សាយករុណាបានដែរ ព្រោះប្រៀបផ្ទឹមនឹងចោរដែលគេនឹងសម្លាប់ ជាមុន ។ សួរថា "ប្រៀបដូចម្តេច? " ។ ឆ្លើយថា ប្រៀបដូចជាពួករាជបុរស ចងនូវចោរដែលខ្លួនចាប់បានហើយ ព្រមទាំងទ្រព្យ តាមព្រះអាជ្ញានៃស្តេចថា "អ្នកទាំងឡាយចូរសម្លាប់នូវចោរនោះ" ដូច្នេះហើយ ឲ្យនូវការប្រហារទាំងឡាយ និមិត្តរំពាត់ ៤ ៗ នាំទៅកាន់ទីសំរាប់សម្លាប់, ពួកមនុស្ស ឲ្យនូវខាទនីយៈខ្លះ ភោជនីយៈខ្លះ កម្រងផ្កាខ្លះ គ្រឿងក្រអូបខ្លះ គ្រឿងលាបខ្លះ និង ស្លាម្លូខ្លះ ដល់ចោរនោះ, ចោរនោះកាលទំពាស៊ី និង ប្រើប្រាស់នូវវត្ថុទាំងនោះ ហាក់ដូចជាដល់ហើយនូវសេចក្តីសុខ ឆ្អែតស្កប់ស្កល់ហើយដោយភោគៈ ដើរទៅ ក៏ពិតមែនហើយ តែបើទុកជាដូច្នោះ អ្នកណាមួយ ក៏មិនសម្គាល់សោះនូវចោរនោះ ថា "ឱហ្ន៎ ចោរនេះ ដល់ហើយនូវសេចក្តីសុខ មានភោគៈច្រើន" ដូច្នេះទេ, ដោយពិតទៅ ជនតែងអាណិត នូវចោរនោះ ថា "ចោរនេះជា

១- អភិ. វិ. ភាគទី ៨២ ទំព័រទី ៣១៥ ។

មនុស្សគួរឲ្យស្រណោះអាណិត នឹងស្លាប់ ក្នុងកាលឥឡូវនេះ ព្រោះថា ចោរនេះ ឈានទូវជំហានណាក៏ដោយ រមែងមានដល់សេចក្ដីស្លាប់ ក្នុងទីជិតបង្កើយដោយជំហាននោះ ៗ ” ដូច្នេះ យ៉ាងណាមិញ, សូម្បីបុគ្គលអ្នកដល់ហើយនូវសេចក្ដីសុខ ក៏ភិក្ខុអ្នកប្រកបនូវករុណាកម្មដ្ឋាន គប្បីផ្សាយករុណាបាន យ៉ាងនេះ ថា “បុគ្គលនេះ ជាអ្នករហេមរហាម ក្នុងកាលឥឡូវនេះ ជាអ្នកមានសេចក្ដីសុខ ចាត់ចែងល្អហើយ ប្រើប្រាស់នូវភោគៈទាំងឡាយ ក៏ពិតមែនហើយ តែបើទុកជាដូច្នោះក៏ដោយ គេ នឹងទទួលទុក្ខទោមនស្ស មានប្រមាណមិនតិច ក្នុងអបាយទាំងឡាយ ក្នុងកាលឥឡូវនេះ ព្រោះការមិនមានកល្យាណកម្ម ដែលខ្លួនបានធ្វើហើយ សូម្បីដោយទ្វារមួយ ក្នុងចំណោមទ្វារទាំងបី” ដូច្នេះ ក៏យ៉ាងដូច្នោះដែរ, លុះករុណាកម្មដ្ឋានិកភិក្ខុនោះ បានផ្សាយករុណាចំពោះបុគ្គលនោះ យ៉ាងដូច្នេះហើយ បន្ទាប់មក គប្បីញ៉ាំងករុណា ឲ្យប្រព្រឹត្តទៅ តាមលំដាប់ ដូច្នេះ គឺ ក្នុងបុគ្គលដែលជាទីស្រឡាញ់ តមក ក្នុងបុគ្គលជាកណ្ដាល តមក ក្នុងបុគ្គលអ្នកមានពៀរ ដោយឧបាយនេះឯង ។ ក៏ប្រសិនបើ សេចក្ដីថ្នាំងថ្នាក់ ក្នុងបុគ្គលមានពៀរ កើតឡើង ដល់ករុណាកម្មដ្ឋានិក-ភិក្ខុនោះ តាមន័យដែលលោកបានពោលហើយ ក្នុងកាលមុនក៏ដោយ ករុណាកម្មដ្ឋានិកភិក្ខុនោះ ត្រូវញ៉ាំងសេចក្ដីថ្នាំងថ្នាក់នោះ ឲ្យស្ងប់រម្ងាប់ តាមន័យដែលលោកពោលហើយ ក្នុងមេត្តាភាវនាហ្នឹងឯង ។ មួយទៀត ក្នុងការផ្សាយករុណានេះ ព្រះយោគី ឃើញក្ដី ឮក្ដី សូម្បីនូវបុគ្គលដែលធ្វើសេចក្ដីល្អហើយ មកជួបប្រទះ ដោយសេចក្ដីវិនាសណាមួយ បណ្ដាសេចក្ដីវិនាសទាំងឡាយមានវិនាសចាកញាតិ វិនាសព្រោះរោគ វិនាសចាកទ្រព្យជាដើម ហើយផ្សាយករុណា ដោយប្រការទាំងពួង យ៉ាងនេះ

ថា “បុគ្គលនេះ សូម្បីមិនមានសេចក្ដីវិនាសចាកញាតិជាដើមទាំងនោះ ក៏ប៉ុន្តែ ឈ្មោះថាជាអ្នកដល់ហើយ នូវសេចក្ដីទុក្ខដោយពិត ព្រោះជាអ្នកមិនកន្លងនូវវដ្ដទុក្ខបាន” ដូច្នេះហើយ គប្បីធ្វើសីមសម្ភេទ ក្នុងជនទាំងឡាយ ៤ គឺ ក្នុងខ្លួនឯង ១ ក្នុងបុគ្គលជាទីស្រឡាញ់ ១ ក្នុងបុគ្គលជាកណ្ដាល ១ ក្នុងបុគ្គលមានពៀរ ១ តាមន័យដែលលោកពោលហើយនោះឯង ហើយសេព ចំរើន ធ្វើឲ្យច្រើននូវនិមិត្តនោះ គប្បីចំរើនអប្បនា ដោយអំណាចនៃតិកជ្ឈាន និង ចតុក្កជ្ឈាន តាមន័យដែលលោកពោលហើយ ក្នុងមេត្តាភាវនា កុំខាន ។

តែក្នុងអដ្ឋកថានៃអង្គុត្តរនិកាយ ព្រះអដ្ឋកថាចារ្យ ពោលលំដាប់នេះថា “បុគ្គលមានពៀរ ព្រះយោគីគប្បីផ្សាយករុណា មុនគេ ត្រូវធ្វើចិត្តឲ្យទន់ ក្នុងបុគ្គលមានពៀរនោះហើយ គប្បីផ្សាយករុណា ឲ្យដល់បុគ្គលទុគ៌ត តមក ឲ្យបុគ្គលជាទីស្រឡាញ់ តមក ផ្សាយឲ្យខ្លួនឯង” ដូច្នេះ ។ លំដាប់នោះ មិនសមតាមបាឡី ថា “ទុគ្គតំ ទុរូបេតំ” ដូច្នេះជាដើមទេ ។ ព្រោះហេតុនោះ ព្រះយោគី គប្បីប្រារព្ធនូវភាវនា ក្នុងករុណាកម្មដ្ឋាននោះ តាមន័យដែលលោកពោលហើយនោះឯង ហើយធ្វើនូវសីមសម្ភេទ ហើយចំរើនអប្បនា ។ បន្ទាប់អំពីនោះមក ព្រះយោគីគប្បីជ្រាបអប្បនា ឈ្មោះវិកុព្វនានេះ ថា “ការផ្សាយ ដោយមិនចំពោះ ដោយអាការៈទាំងឡាយ ៥ ការផ្សាយដោយចំពោះ ដោយអាការៈទាំងឡាយ ៧ ការផ្សាយទៅកាន់ទិស ដោយអាការៈទាំងឡាយ ១០” និងអានិសង្សទាំងឡាយ មានអានិសង្ស ថា “ដេកលក់ស្រួល” ដូច្នេះជាដើម តាមន័យដែលលោកពោលហើយ ក្នុងមេត្តាភាវនានោះឯង ។

នេះជាកថាពិស្ដារ ក្នុងករុណាភាវនា ។

(មុទិតាព្រហ្មវិហារ)

(១៨៩) ព្រះយោគី សូម្បីកាលប្រារព្ធមុទិតាភាវនា ក៏មិនគប្បីប្រារព្ធ ក្នុងបុគ្គលដែលមានទោសដល់ភាវនាទាំងឡាយ មានបុគ្គលជាទីស្រឡាញ់ជាដើមមុនទេ ។ ព្រោះថា បុគ្គលជាទីស្រឡាញ់ មិនមែនជាហេតុជាទីតាំង នៃភាពជាចិត្តទន់ ដោយត្រឹមតែភាពជាទីស្រឡាញ់ប៉ុណ្ណោះទេ ពុំចាំបាច់និយាយថ្វី ដល់បុគ្គលជាកណ្តាល និង បុគ្គលមានពៀរ ។ ភាពនៃបុគ្គលខុសភេទគ្នា និង បុគ្គលធ្វើមរណកាល មិនមែនជាខេត្តដែន (ដែលចំរើនមុទិតា) ដូចគ្នាដែរ ។ ឯបុគ្គលជាសំឡាញ់ជាទីស្រឡាញ់ក្រៃពេក គប្បីជាហេតុជាទីតាំងបាន ។ ព្រោះថា បុគ្គលនោះដែលព្រះអដ្ឋកថាចារ្យ ពោលហើយក្នុងអដ្ឋកថា ថា “បុគ្គលជាសំឡាញ់ជាអ្នកលេង” ដូច្នេះ ជាអ្នករីករាយសប្បាយមែនពិត សើចមុនហើយទើបនិយាយ ជាខាងក្រោយ ព្រោះហេតុនោះ ម្យ៉ាងទៀត បុគ្គលជាសំឡាញ់ជាអ្នកលេងនោះ ព្រះយោគី គប្បីផ្សាយមុទិតាមុនគេ ។ ព្រះយោគី ឃើញក្តី ឮក្តី នូវបុគ្គលជាទីស្រឡាញ់ក្តី នូវបុគ្គលដែលដល់នូវសេចក្តីសុខក្តី នូវបុគ្គលស្ទុកស្តម្ភក្តី ដែលកំពុងតែរីករាយ គប្បីញុំាងមុទិតា ឲ្យកើតឡើង ថា “ឱហ្ន៎ សត្វនេះរីករាយណាស់តើ ឱហ្ន៎ ល្អមែន ឱហ្ន៎ ប្រពៃពិតមែន” ដូច្នេះ ។ មែនពិត ព្រះធម្មសេនាបតី អាស្រ័យនូវអំណាចនៃប្រយោជន៍នេះឯង ទើបពោលហើយក្នុងវិភង្គថា “ចុះភិក្ខុមានចិត្តប្រកបដោយមុទិតា ផ្សាយទៅកាន់ទិស ១ សម្រាន្តនៅ តើដូចម្តេច គឺបុគ្គលឃើញបុគ្គលម្នាក់ ជាទីស្រឡាញ់ជាទីពេញចិត្ត ហើយជាអ្នករីករាយ យ៉ាងណា ភិក្ខុផ្សាយមុទិតាចំពោះសត្វទាំងពួង ក៏យ៉ាងនោះដែរ ។ ប្រសិនបើបុគ្គលជាសំឡាញ់ជាអ្នកលេង ឬ បុគ្គលជាទីស្រឡាញ់ របស់

ព្រះយោគីនោះ ជាអ្នកមានសេចក្តីសុខ ក្នុងអតីតកាល ប៉ុន្តែឥឡូវនេះ ជាអ្នកទុគ៌ត ជាអ្នកលំបាកក្រៃពេក, ព្រះយោគី គប្បីរំលឹករឿយៗ នូវភាពនៃបុគ្គលនោះជាអ្នកដល់ហើយ នូវសេចក្តីសុខដែលកន្លងទៅហើយនោះឯង ហើយកាន់យក នូវអាការៈគឺការរីករាយចិត្ត របស់បុគ្គលនោះឯង ថា “ក្នុងកាលកន្លងទៅហើយ បុគ្គលនេះជាអ្នកមានភោគៈច្រើន ជាអ្នកមានបរិវារច្រើន ជាអ្នកមានចិត្តរីករាយជានិច្ច” ដូច្នេះហើយ គប្បីញុំាងមុទិតា ឲ្យកើតឡើង ។ ម្យ៉ាងទៀត ព្រះយោគីគប្បីកាន់យក នូវអាការៈគឺការរីករាយចិត្ត របស់បុគ្គលនោះ ដែលជាអនាគតហើយ ញុំាងមុទិតា ឲ្យកើតឡើង ថា “ក្នុងអនាគត បុគ្គលនេះ បាននូវសម្បត្តិនោះម្តងទៀត នឹងត្រាច់ទៅ ដោយយានវិសេសទាំងឡាយ មានលើ-ក ដំរី លើខ្នងសេះ និង លើអង្រឹងជាវិការនៃមាសជាដើម” ដូច្នេះ ។ លុះព្រះយោគីនោះ ញុំាងមុទិតាចិត្តឲ្យកើតឡើង ក្នុងបុគ្គលជាទីស្រឡាញ់ យ៉ាងនេះហើយ បន្ទាប់មក ត្រូវញុំាងមុទិតាឲ្យប្រព្រឹត្តទៅ តាមលំដាប់ យ៉ាងនេះ គឺក្នុងបុគ្គលជាកណ្តាល តមក ក្នុងបុគ្គលមានពៀរ ។ តែប្រសិនបើបដិឃៈ ក្នុងបុគ្គលមានពៀរ កើតឡើង ដល់ព្រះយោគីនោះ តាមន័យដែលលោកពោលហើយ ក្នុងកាលមុននោះឯង, ព្រះយោគី គប្បីញុំាងបដិឃៈនោះឲ្យស្ងប់រម្ងាប់ តាមន័យដែលលោកពោលហើយ ក្នុងមេត្តាភាវនានោះឯង ហើយធ្វើនូវសីមសម្ភេទ ដោយភាពជាអ្នកមានចិត្តស្មើ ក្នុងជនទាំងឡាយ ៤ គឺ ក្នុងបុគ្គលទាំងបីនេះផង និង ក្នុងខ្លួនឯងផង ហើយសេព ចំរើន ធ្វើឲ្យច្រើន នូវនិមិត្តនោះ គប្បីចំរើនអប្បនា ដោយអំណាចនៃតិក្កជ្ឈាន (ក្នុងចតុក្កន័យ) និង ចតុក្កជ្ឈាន (ក្នុងបញ្ចក្កន័យ) តាមន័យដែលពោលហើយ ក្នុងមេត្តាភាវនានោះឯង ។ បន្ទាប់អំពីនោះ

ព្រះយោគី គប្បីជ្រាបអប្បនា ឈ្មោះវិកុព្វនានេះ ថា "ការផ្សាយ ដោយមិនចំពោះ ដោយអាការៈទាំងឡាយ ៥ ការផ្សាយដោយចំពោះ ដោយអាការៈទាំងឡាយ ៧ ការផ្សាយទៅកាន់ទិស ដោយអាការៈទាំងឡាយ ១០ " និង អានិសង្សទាំងឡាយ មានអានិសង្ស ថា "ដេកលក់ស្រួល" ដូច្នេះជាដើម តាមន័យដែលពោលហើយ ក្នុងមេត្តាភាវនានោះឯង ។

នេះជាកថាពិស្តារ ក្នុងមុទិតាភាវនា ។

(ឧបេក្ខាព្រហ្មវិហារ)

(១៩០) ចំណែកខាងព្រះយោគី អ្នកមានប្រាថ្នាដើម្បីប្រារព្ធ នូវឧបេក្ខាភាវនា ជាអ្នកបានឈានទី ៣ និង ទី ៤ ក្នុងភាវនាទាំងឡាយមានមេត្តាភាវនាជាដើម ចេញចាកតតិយជ្ឈានដែលស្ទាត់ហើយ ឃើញនូវទោស ក្នុងភាវនាទាំងឡាយខាងដើម ព្រោះភាវៈនៃភាវនានោះប្រកបដោយការធ្វើទុកក្នុងចិត្ត ដែលប្រព្រឹត្តទៅ ដោយសេចក្តីស្រឡាញ់ ក្នុងសត្វ ដោយអំណាចនៃការផ្សាយថា "សូមសត្វទាំងពួងបានដល់សេចក្តីសុខចុះ" ដូច្នេះជាដើមផង ព្រោះជាភាវនាដែលត្រាច់ទៅជិតសេចក្តីថ្នាំងថ្នាក់ និង សេចក្តីត្រេកអរផង ព្រោះជាភាវនាដែលគ្រោតគ្រាត ព្រោះប្រកបដោយសោមនស្សផង និង (ឃើញ) នូវអានិសង្ស ក្នុងឧបេក្ខាដោយភាពជាធម៌ដ៏ល្អិតផង, បុគ្គលណាតាំងនៅជាកណ្តាល តាមប្រក្រតីនៃបុគ្គលនោះ, គប្បីព្រងើយចំពោះបុគ្គលនោះ ហើយញ៉ាំងឧបេក្ខា ឲ្យកើតឡើង តអំពីនោះមក គប្បីញ៉ាំងឧបេក្ខាឲ្យកើតឡើង ក្នុងបុគ្គលទាំងឡាយដទៃទៀត មានបុគ្គលជាទីស្រឡាញ់ជាដើម ។ សមដូចជាលោកពោលហើយ ថា "ចុះភិក្ខុមានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសមួយ សម្រាន្តនៅ តើដូចម្តេច ? ។ គឺបុគ្គលឃើញ នូវបុគ្គលម្នាក់

ជាទីគាប់ចិត្តក៏មិនមែន មិនជាទីគាប់ចិត្តក៏មិនមែន គប្បីជាអ្នកព្រងើយកន្តើយ យ៉ាងណា ភិក្ខុផ្សាយឧបេក្ខា ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះដែរ" ។ ព្រោះហេតុនោះ ព្រះយោគី លុះញ៉ាំងឧបេក្ខាឲ្យកើតឡើងក្នុងបុគ្គលជាកណ្តាល តាមន័យដែលលោកបានពោលហើយ បន្ទាប់មកគប្បីញ៉ាំងឧបេក្ខាឲ្យកើតឡើងក្នុងបុគ្គលជាទីស្រឡាញ់ បន្ទាប់មក ក្នុងបុគ្គលជាសំឡាញ់ជាអ្នកលេង បន្ទាប់មក ក្នុងបុគ្គលមានពៀរ យ៉ាងនេះហើយ គប្បីធ្វើនូវសីមសម្ភេទ ដោយអំណាចនៃ(ការធ្វើចិត្ត)ជាកណ្តាលក្នុងបុគ្គលទាំងពួង គឺ ក្នុងបុគ្គលទាំងឡាយបីនេះ ដែលពោលមកហើយផង ក្នុងខ្លួនឯងផង ហើយគប្បីសេព ចំរើន ធ្វើឲ្យច្រើន នូវនិមិត្តនោះ ។ កាលព្រះយោគីនោះ ធ្វើយ៉ាងនេះ ចតុត្ថជ្ឈាន រមែងកើតឡើង តាមន័យដែលលោកពោលហើយ ក្នុងបឋវីកសិណនោះឯង ។

សួរថា "ចុះចតុត្ថជ្ឈាននេះ រមែងកើតឡើង ដល់ព្រះយោគាវចរដែលបាននូវតតិយជ្ឈាន ដែលកើតឡើងហើយ ក្នុងកម្មដ្ឋានទាំងឡាយមានបឋវីកសិណជាដើមផងឬ ? " ។ ឆ្លើយថា "មិនកើតឡើងទេ" ។ សួរថា "ព្រោះហេតុអ្វី?" ។ ឆ្លើយថា "ព្រោះភាវៈនៃចតុត្ថជ្ឈានជាឈានមានអារម្មណ៍ខុសគ្នា" ។ ក៏ប៉ុន្តែចតុត្ថជ្ឈាននេះ រមែងកើតឡើង ដល់ព្រះយោគីដែលបាននូវតតិយជ្ឈាន ដែលកើតឡើងក្នុងព្រហ្មវិហារភាវនាមានមេត្តាជាដើមប៉ុណ្ណោះ ព្រោះភាវៈនៃចតុត្ថជ្ឈាននោះ ជាឈានមានអារម្មណ៍ស្មើគ្នា" ។

បន្ទាប់អំពីនោះ បណ្ឌិតគប្បីជ្រាបអប្បនា ឈ្មោះថាវិកុព្វនា និងការបានអានិសង្ស តាមន័យដែលពោលហើយក្នុងមេត្តាភាវនានោះឯង។

នេះជាកថាពិស្តារ ក្នុងឧបេក្ខាភាវនា ។

បកិណ្ណកកថា

(១៩១) បណ្ឌិត ជ្រាបនូវព្រហ្មវិហារទាំងឡាយនេះ ដែលព្រះព្រហ្មគ្គមាចារ្យ ទ្រង់សំដែងហើយ យ៉ាងនេះ គប្បីជ្រាបបកិណ្ណកកថានេះ ក្នុងព្រហ្មវិហារទាំងឡាយនុ៎ះ ដោយក្រៃលែងថែមទៀត ។

(វិនិច្ឆ័យដោយសេចក្ដី)

ក៏បណ្ឌិតគប្បីជ្រាប ដោយសេចក្ដី ក្នុងមេត្តា ករុណា មុទិតា និង ឧបេក្ខាទាំងឡាយនេះ ជាមុនសិន ។

ធម្មជាតិណា ស្រឡាញ់ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា មេត្តា, អធិប្បាយថា ស្និទ្ធស្នំ ។ មួយទៀត ការជិតដិតនុ៎ះ មានក្នុងមិត្ត ឬ ឬថា ប្រព្រឹត្តទៅចំពោះមិត្ត ព្រោះហេតុនោះ ការជិតដិតនុ៎ះ ឈ្មោះថា មេត្តា ។

គុណជាតិណា កាលបើសេចក្ដីទុក្ខរបស់ជនដទៃមាន ធ្វើនូវការឈឺផ្សាល ដល់សប្បុរសទាំងឡាយ គុណជាតិនោះ ឈ្មោះថាករុណា ។ មួយទៀត គុណជាតិណា ផ្ទេរ គឺថា បៀតបៀន នូវសេចក្ដីទុក្ខរបស់ជនដទៃ សេចក្ដីថា ញុំាងសេចក្ដីទុក្ខរបស់ជនដទៃឲ្យវិនាសទៅ ព្រោះហេតុនោះ គុណជាតិនោះ ឈ្មោះថាករុណា ។ម្យ៉ាងវិញទៀត គុណជាតិណា ដែលសាធុជនទាំងឡាយតែងធ្វើ គឺថា លាតចេញ ដោយអំណាចនៃការផ្សាយទៅ ក្នុងជនទាំងឡាយដែលដល់ហើយនូវសេចក្ដីទុក្ខ ព្រោះហេតុនោះ គុណជាតិនោះ ទើបឈ្មោះថា ករុណា ។

សាធុជនទាំងឡាយ តែងរីករាយ ចំពោះជនអ្នកព្រមព្រៀងគ្នា ដោយសម្បត្តិនោះ ដោយគុណជាតិនោះ ព្រោះហេតុនោះ គុណជាតិនោះ

ឈ្មោះថា មុទិតា, មួយទៀត គុណជាតិនោះ រីករាយ ចំពោះខ្លួនឯង ព្រោះហេតុនោះ គុណជាតិនោះ ឈ្មោះថា មុទិតា, ម្យ៉ាងវិញទៀត ពាក្យថា “មុទិតា” នោះ គឺគ្រាន់តែជាកិរិយារីករាយប៉ុណ្ណោះ ព្រោះហេតុនោះ គុណជាតិនោះ ទើបឈ្មោះថា មុទិតា ។

គុណជាតិណា តែងព្រងើយកន្តើយ ដោយកិរិយាលះបង់ នូវសេចក្ដីខ្វល់ខ្វាយជាដើម ថា “សត្វទាំងឡាយ ចូរកុំឲ្យមានពៀរនឹងគ្នា” ដូច្នេះ និង ដោយកិរិយាចូលទៅដល់ នូវភាពព្រងើយកន្តើយ ព្រោះហេតុនោះ គុណជាតិនោះ ទើបឈ្មោះថា ឧបេក្ខា ។

(វិនិច្ឆ័យដោយលក្ខណៈជាដើម)

បណ្ឌិតគប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ដោយប្រការដទៃមានលក្ខណៈជាដើម ក្នុងព្រហ្មវិហារទាំង ៤ នោះ (ដូចតទៅនេះ) ។

មេត្តា មានកិរិយាប្រព្រឹត្តិទៅ ដោយអាការៈជាប្រយោជន៍ (ដល់សត្វទាំងឡាយ) ជាលក្ខណៈ, មានកិរិយារួបរួមមកនូវប្រយោជន៍ជាកិច្ច, មានការកំចាត់បង់នូវគំនុំជាផល, មានកិរិយាបង្ហាញ នូវភាពនៃសត្វទាំងឡាយជាទីគាប់ចិត្តជាហេតុជិត, កិរិយាចូលទៅរម្ងាប់ព្យាបាទ ជាសម្បត្តិនៃមេត្តានោះ, កិរិយាកើតព្រមនៃសេចក្ដីស្នេហា ជាវិបត្តិ នៃមេត្តានោះ ។

ករុណា មានកិរិយាប្រព្រឹត្តិទៅដោយអាការៈជាគ្រឿងកំចាត់បង់នូវសេចក្ដីទុក្ខ (របស់សត្វទាំងឡាយ) ជាលក្ខណៈ, មានកិរិយាអត់ទ្រាំមិនបាននូវសេចក្ដីទុក្ខ របស់សត្វដទៃ ជាកិច្ច, មានកិរិយាមិនបៀតបៀនជាផល, មានកិរិយាសំដែងនូវភាពមិនមានទីពឹង នៃសត្វទាំងឡាយដែលមានសេចក្ដីទុក្ខគ្របសង្កត់ហើយ ជាហេតុជិត, កិរិយារម្ងាប់នូវការបៀតបៀន ជាសម្បត្តិនៃករុណានោះ, ការកើតព្រម នៃសេចក្ដីសោក ជាវិបត្តិ

នៃករុណានោះ ។

មុទិតា មានកិរិយារីករាយទូទៅ ជាលក្ខណៈ, មានកិរិយាមិនឫស្យាជាកិច្ច, មានកិរិយាកំចាត់បង់នូវអរតិ ជាផល, មានកិរិយាបង្ហាញនូវសម្បត្តិនៃសត្វទាំងឡាយជាហេតុ, កិរិយាចូលទៅរម្ងាប់នូវអរតិ ជាសម្បត្តិនៃមុទិតានោះ, ការកើតព្រម នៃសំណើចជាវិបត្តិនៃមុទិតានោះ ។

ឧបេក្ខា មានកិរិយាប្រព្រឹត្តិទៅដោយអាការៈជាកណ្តាលក្នុងសត្វទាំងឡាយជាលក្ខណៈ, មានកិរិយាសំដែងនូវភាពស្មើគ្នា ក្នុងសត្វទាំងឡាយជាកិច្ច, មានការចូលទៅរម្ងាប់នូវសេចក្តីស្អប់និងសេចក្តីស្រឡាញ់ជាផល, មានការសំដែងនូវភាពនៃសត្វជាអ្នកមានកម្មជារបស់ខ្លួន ដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា "សត្វទាំងឡាយមានកម្មជារបស់ខ្លួន សត្វទាំងឡាយនោះ នឹងជាអ្នកដល់ហើយនូវសេចក្តីសុខក្តី នឹងរួចចាកទុក្ខក្តី នឹងមិនវិនាស ចាកសម្បត្តិដែលខ្លួនបានហើយក្តី ដោយសេចក្តីគាប់ចិត្តនៃកម្ម" ដូច្នេះ ជាហេតុ, ការចូលទៅរម្ងាប់នូវសេចក្តីស្អប់ និង សេចក្តីស្រឡាញ់ ជាសម្បត្តិនៃឧបេក្ខានោះ, ការកើតព្រមនៃការព្រងើយកន្តើយដែលគ្មានញាណដែលអាស្រ័យនូវផ្ទះគឺតណ្ហា ជាវិបត្តិ នៃឧបេក្ខានោះ ។

(ប្រយោជន៍នៃព្រហ្មវិហារ)

ក៏ឯសេចក្តីសុខ ដែលកើតអំពីវិបស្សនាក្តី ការដល់ព្រម ដោយភពក្តី ជាប្រយោជន៍ទូទៅ នៃព្រហ្មវិហារទាំងឡាយ ៤ នោះឯង ។ ការផ្តាច់ផ្តិលនូវសត្រូវមានព្យាបាទជាដើម ជាប្រយោជន៍ដោយឡែក ។ ពិតមែន បណ្តាព្រហ្មវិហារទាំងនោះ មេត្តា មានការផ្តាច់ផ្តិលនូវព្យាបាទជាប្រយោជន៍, ព្រហ្មវិហារទាំងឡាយក្រៅនេះមានការផ្តាច់ផ្តិលនូវការបៀតបៀន ការមិនត្រេកអរ និង រាគៈជាប្រយោជន៍ ។ សមដូចព្រះសារីបុត្រ

ពោលហើយ ថា "ម្នាលអាវុសោទាំងឡាយ ព្រោះមេត្តាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវព្យាបាទ, ម្នាលអាវុសោទាំងឡាយ ព្រោះករុណាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវការបៀតបៀន, ម្នាលអាវុសោទាំងឡាយ ព្រោះមុទិតាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវអរតិ (គឺសេចក្តីមិនត្រេកអរ), ម្នាលអាវុសោទាំងឡាយ ព្រោះឧបេក្ខាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវរាគៈ [១] " ដូច្នេះ ។

(សត្រូវជិតនិងឆ្ងាយរបស់ព្រហ្មវិហារ)

ក៏ក្នុងព្រហ្មវិហារទាំងនោះ សំរាប់ព្រហ្មវិហារមួយៗ មានសត្រូវពីរ ៗ ដោយអំណាចនៃសត្រូវជិត និង ឆ្ងាយ ។ អធិប្បាយថា រាគៈ ជាសត្រូវជិត របស់មេត្តាព្រហ្មវិហារ ព្រោះភាវៈនៃមេត្តា និង រាគៈ មានចំណែកស្មើគ្នា ក្នុងកិរិយាបង្ហាញនូវគុណ ដូចជាសត្រូវរបស់បុរសត្រាច់ទៅក្នុងទីជិត រាគៈនោះតែងបាននូវទោសជាគ្រឿងឆ្លងចុះ យ៉ាងស្រួល ។ ព្រោះហេតុនោះ មេត្តា ព្រះយោគាវចរត្រូវរក្សាឲ្យបានល្អ អំពីរាគៈនោះ ព្យាបាទ ជាសត្រូវក្នុងទីឆ្ងាយ (របស់មេត្តា) ព្រោះភាវៈនៃមេត្តា និង ព្យាបាទមានចំណែកស្មើគ្នា និងមិនស្មើគ្នា ដូចជាសត្រូវរបស់បុរសដែលអាស្រ័យនូវញាតស្បាតនៃព្រៃមានភ្នំជាដើម ព្រោះហេតុនោះ ព្រះយោគីមិនត្រូវភ័យខ្លាចអំពីព្យាបាទនោះទេ ត្រូវចំរើនមេត្តាចុះ ។ តាមធម្មតា បុគ្គលនឹងចំរើនមេត្តាផង នឹងធ្វើនូវសេចក្តីក្រោធទឹងផង ព្រោះហេតុដូច្នោះ ហេតុនេះ មិនមែនជាហេតុជាទីតាំងទេ ។

ទោមនស្ស ដែលអាស្រ័យនូវផ្ទះគឺកាមគុណ មកហើយ ដោយន័យមានន័យ ថា "បុគ្គល កាលមិនបាន កាលឃើញច្បាស់ នូវការមិន

១- សុ. ទី. បាដ. ភាគទី ១៩ ទំព័រទី ២០៣ ។

បាននូវរូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោកាមិសក្តី កាលរលឹកឃើញនូវរូបដែលខ្លួនមិនធ្លាប់បានក្នុងកាលមុនក្តី ដែលកន្លងទៅហើយ ដែលរលត់ហើយ ដែលប្រែប្រួលក្តី ហើយក៏កើតទោមនស្សឡើង, ទោមនស្សណាមានសភាពដូច្នេះ ទោមនស្សនោះ តថាគតហៅថា គេហសិតទោមនស្ស (ទោមនស្ស ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ) " ដូច្នេះជាដើម ជាសត្រូវក្នុងទីជិត របស់ករុណាព្រហ្មវិហារ ព្រោះករុណានិងគេហសិត-ទោមនស្សមានចំណែកស្មើគ្នាក្នុងកិរិយាបង្ហាញនូវវិបត្តិ, ការបៀតបៀនជាសត្រូវក្នុងទីឆ្ងាយ (របស់ករុណា) ព្រោះភាវៈនៃវិហឹសាមានចំណែកស្មើគ្នា និង មិនស្មើគ្នា ព្រោះហេតុនោះ ព្រះយោគីមិនត្រូវកោតញញើតអំពីការបៀតបៀននោះទេ គប្បីចំរើនករុណាចុះ ។ តាមធម្មតា បុគ្គលនឹងធ្វើនូវករុណាក្តី នឹងបៀតបៀន (នូវសត្វ) ដោយគ្រឿងប្រហារទាំងឡាយមានបាតដៃជាដើម ព្រោះហេតុដូច្នោះ ហេតុនុ៎ះ មិនមែនជាហេតុជាទីតាំងទេ ។

សោមនស្ស ដែលអាស្រ័យនូវផ្ទះគឺកាមគុណ មកហើយដោយន័យមានន័យជាដើម ថា "បុគ្គលកាលមិនបាន កាលឃើញច្បាស់ នូវការមិនបាននូវរូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោកាមិសក្តី កាលរលឹកឃើញនូវរូបដែលខ្លួនមិនធ្លាប់បាន ក្នុងកាលមុនក្តី ដែលកន្លងទៅហើយ ដែលរលត់ហើយ ដែលប្រែប្រួលក្តី ហើយក៏កើតសោមនស្សឡើង, សោមនស្សណា មានសភាពដូច្នេះ សោមនស្សនោះ តថាគតហៅថា គេហសិតសោមនស្ស" ដូច្នេះ ជាសត្រូវក្នុងទីជិតរបស់មុទិតាព្រហ្មវិហារ

ព្រោះភាវៈនៃមុទិតា និង គេហសិតសោមនស្ស មានចំណែកស្មើគ្នា ក្នុងការបង្ហាញនូវសម្បត្តិ ចំណែកសេចក្តីមិនត្រេកអរ(អរតិ)ជាសត្រូវឆ្ងាយ (របស់មុទិតា) ព្រោះភាវៈនៃអរតិ មានចំណែកស្មើគ្នា និង មិនស្មើគ្នា ព្រោះហេតុនោះ ព្រះយោគីមិនត្រូវកោតញញើត អំពីអរតិនោះទេ គប្បីចំរើនមុទិតាចុះ ។ តាមធម្មតា ព្រះយោគី នឹងជាអ្នករីករាយទូទៅផង នឹងអផ្សុក ក្នុងសេនាសនៈដ៏ស្ងាត់ ឬ ក្នុងសមថៈ និង វិបស្សនាផង ព្រោះហេតុដូច្នោះ ហេតុនុ៎ះ មិនមែនជាហេតុជាទីតាំងទេ ។

ចំណែកខាង គេហសិតអញ្ញាណឧបេក្ខា (ឧបេក្ខាមិនមានញាណដែលអាស្រ័យនូវផ្ទះគឺកាមគុណ) ដែលមកហើយ ដោយន័យមានន័យថា "ព្រោះឃើញនូវរូប ដោយចក្ខុ ឧបេក្ខា (ភាពព្រងើយកន្តើយ) រមែងកើតឡើង ដល់បុថុជ្ជន អ្នកល្ងង់ខ្លៅ វង្វេងវង្វន់ អ្នកមានកិលេសក្រាស់ អ្នកមិនឈ្នះនូវដែនគឺលោកៈ អ្នកមិនឈ្នះនូវវិបាក អ្នកមិនឃើញទោស អ្នកមិនបានស្តាប់, ឧបេក្ខា ណា មានសភាពបែបនេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្លងនូវរូប ព្រោះហេតុនោះ ឧបេក្ខានោះ តថាគតត្រាស់ហៅថា គេហសិតា (អាស្រ័យនូវផ្ទះគឺកាមគុណ)" ដូច្នេះជាដើម ជាសត្រូវដ៏ជិត របស់ឧបេក្ខាព្រហ្មវិហារ ព្រោះភាវៈនៃឧបេក្ខាព្រហ្មវិហារ និង គេហ-សិតអញ្ញាណឧបេក្ខា មានចំណែកស្មើគ្នា ដោយអំណាចនៃកិរិយាមិនពិចារណានូវទោស និង គុណ, សេចក្តីថ្នាំងថ្នាក់ដោយរាគៈ ជាសត្រូវឆ្ងាយ (របស់ឧបេក្ខា) ព្រោះរាគប្បដិឃៈនោះ មានចំណែកស្មើគ្នា និង មិនស្មើគ្នា ព្រោះហេតុនោះ ព្រះយោគីមិនត្រូវកោតញញើតឡើយ អំពីរាគប្បដិឃៈនោះ គប្បីចំរើនឧបេក្ខាចុះ ។ តាមធម្មតា ព្រះយោគី នឹងព្រងើយកន្តើយផង នឹងរីករាយផង នឹងប៉ះទង្គិចផង ព្រោះហេតុដូច្នោះ

ហេតុនុ៎ះ មិនមែនជាហេតុជាទីតាំងទេ [១] ។

(ខាងដើម...និង ការចំរើនអារម្មណ៍នៃព្រហ្មវិហារ)

(១៩២) ក៏ព្រហ្មវិហារទាំងអស់នុ៎ះ មានកត្តុកាមតាឆន្ទៈ (សេចក្តីពេញចិត្តក្នុងភាពអ្នកចង់ដើម្បីធ្វើ) ជាខាងដើម មានកិរិយាសង្កត់សង្កិននូវនីវរណៈជាដើម ជាកណ្តាល មានអប្បនា ជាទីបំផុត ដោយអំណាចនៃបញ្ញត្តិធម៌ រប់ថា មានសត្វមួយ ជាអារម្មណ៍ ឬ មានសត្វដ៏ច្រើន ជាអារម្មណ៍ ។ កាលបើដល់ឧបចារៈ និង អប្បនាហើយ ការចំរើន ដោយអាម្មណ៍ ទើបកើតបាន ។

ក្នុងការចំរើនដោយអារម្មណ៍នោះ នេះគឺជាលំដាប់ នៃការចំរើនអារម្មណ៍(ដូចតទៅ) ។ ដូចជាអ្នកភ្ជួរដែលឆ្វាតកំណត់នូវទីដែលខ្លួនគប្បីភ្ជួរហើយទើបភ្ជួរ យ៉ាងណា, ព្រះយោគីគប្បីកំណត់ នូវអាវាសមួយ ជាដំបូងបង្អស់ ហើយគប្បីចំរើនមេត្តា ក្នុងសត្វទាំងឡាយក្នុងអាវាសនោះ ដោយន័យមានន័យថា “សត្វទាំងឡាយក្នុងអាវាសនេះចូរកុំឲ្យមានពៀរ” ដូច្នេះជាដើម ។ ព្រះយោគីគប្បីធ្វើចិត្តឲ្យទន់ ឲ្យគួរដល់ការនាកម្ម ក្នុងអាវាសនោះហើយ កំណត់អាវាសពីរ ។ បន្ទាប់អំពីអាវាសនោះ ព្រះយោគីគប្បីកំណត់អាវាសពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់ ថ្នល់មួយ ពាក់កណ្តាលស្រុក ស្រុកមួយ ជនបទមួយ អាណាចក្រមួយ ទិសមួយ ដោយលំដាប់ ដោយន័យនេះហើយ គប្បីកំណត់រហូតដល់ចក្រវាឡមួយ ។ មួយទៀត ព្រះយោគីគប្បីចំរើនមេត្តាចំពោះសត្វទាំងឡាយ ក្នុងទីទាំងឡាយនោះៗ ដោយក្រៃលែង អំពីចក្រវាឡនោះក៏បាន ។ ព្រហ្មវិហារទាំងឡាយ មានករុណាជាដើម ក៏ព្រះ

១- សុ. ម. ឧ. ភាគទី ២៨ ទំព័រទី ៣០៦ ។

យោគីគប្បីចំរើន ដូចគ្នានោះដែរ ។ នេះជាលំដាប់នៃការចំរើនអារម្មណ៍ក្នុងព្រហ្មវិហារភាវនានោះ ។

(ឧបេក្ខាព្រហ្មវិហារជាផលនៃព្រហ្មវិហារបីខាងដើម)

មួយទៀត អារូបសមាបត្តិទាំងឡាយ ជាទីហូរចេញ នៃកសិណទាំងឡាយ, នេវសញ្ញានាសញ្ញាយតនៈ ជាទីហូរចេញ នៃសមាធិទាំងឡាយ, ផលសមាបត្តិ ជាទីហូរចេញនៃវិបស្សនា, និរោធសមាបត្តិ ជាទីហូរចេញ នៃសមថៈ និង វិបស្សនា យ៉ាងណាមិញ, ឧបេក្ខាព្រហ្មវិហារក្នុងព្រហ្មវិហារភាវនានេះ ជាទីហូរចេញនៃព្រហ្មវិហារបីខាងដើម ក៏យ៉ាងដូច្នោះដែរ ។ ព្រោះដូចជា ជាងមិនទាន់បានដាំនូវសសរទាំងឡាយ មិនទាន់បានលើកនូវធ្នឹម និង ផ្តងហើយ ក៏មិនអាចដើម្បីដាក់នូវមេដំបូល និង បង្កង់ ឰដ៏អាកាសបានឡើយ យ៉ាងណាមិញ, វៀរចាកតតិយជ្ឈានក្នុងព្រហ្មវិហារបីខាងដើមចេញហើយ ព្រះយោគី ក៏មិនអាចដើម្បីចំរើនចតុត្ថជ្ឈានបាន ក៏យ៉ាងនោះដែរ ។

(ហេតុអ្វីបានជាហៅថាព្រហ្មវិហារ)

(សេចក្តីត្រិះរិះ របស់អាចារ្យពួកខ្លះ) គប្បីមានក្នុងអធិការនេះថា “ក៏ព្រោះហេតុអ្វី បានជាព្រះមានព្រះភាគទ្រង់ត្រាស់ហៅ មេត្តា ករុណា មុទិតា ឧបេក្ខានោះ ថា ព្រហ្មវិហារ ?, ព្រោះហេតុអ្វីបានជាទ្រង់ត្រាស់គុណជាតិ មានមេត្តាជាដើមនោះ ថា មានបួន ?, ចុះអ្វីជាលំដាប់ នៃព្រហ្មវិហារទាំងឡាយនុ៎ះ?, ចំណែកក្នុងព្រះអភិធម្ម ព្រោះហេតុអ្វីបានជាទ្រង់ត្រាស់ព្រហ្មវិហារទាំង៤ នោះ ថា អប្បមញ្ញា ដូច្នេះទៅវិញ? ” ។ ខ្ញុំនឹងពោលដោះស្រាយ (ដូចតទៅនេះ) ។

ដំបូង បណ្ឌិតគប្បីជ្រាបភាពនៃព្រហ្មវិហារ ក្នុងគុណជាតិមាន

មេត្តាជាដើមនុ៎ះ ដោយសេចក្តីថាជាធម៌ដ៏ប្រសើរ និង ព្រោះភាវៈជាធម៌មិនមានទោស ។ មែនពិត ព្រហ្មវិហារធម៌ទាំងឡាយនុ៎ះ ឈ្មោះថាជាធម៌ជាគ្រឿងនៅដ៏ប្រសើរបំផុត ព្រោះភាវៈនៃសេចក្តីប្រតិបត្តិដ៏ប្រពៃ ចំពោះសត្វទាំងឡាយ, មួយទៀត ព្រហ្មវិហារទាំងឡាយ មិនមានចិត្តជាទោសនៅ យ៉ាងណា, ព្រះយោគីទាំងឡាយ អ្នកប្រកបព្រមដោយព្រហ្មវិហារទាំងឡាយនុ៎ះ ជាអ្នកនៅស្មើ ដោយព្រហ្ម មែនពិត ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ ធម៌ទាំងឡាយ មានមេត្តាជាដើមនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ព្រហ្មវិហារ ដោយសេចក្តីថា ជាធម៌ដ៏ប្រសើរបំផុតផង ព្រោះភាវៈជាធម៌ មិនមានទោសផង ។

ចំណែកពាក្យនេះ ជាសេចក្តីដោះស្រាយ នូវបញ្ហាដែលថា “ក៏ព្រោះហេតុអ្វី ទើបត្រាស់ថា មាន ៤ ” ដូច្នេះជាដើម ។

(១៩៣) បណ្ឌិតគប្បីជ្រាបគុណជាតិ ៤ មានមេត្តា ជាដើម ដោយអំណាចនៃអាការៈមានផ្លូវដ៏បរិសុទ្ធជាដើម តែថា គប្បីជ្រាបលំដាប់ នៃគុណជាតិមានមេត្តាជាដើមនោះ ដោយអំណាចនៃអាការៈ មានការគិតប្រយោជន៍ជាដើម, មួយទៀត គុណជាតិទាំងឡាយ មានមេត្តាជាដើមនោះ រមែងប្រព្រឹត្តទៅ ក្នុងអារម្មណ៍ មានប្រមាណមិនបាន ព្រោះហេតុណា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អប្បមញ្ញា ។

អធិប្បាយថា ក្នុងភាវនាទាំង ៤ នុ៎ះ មេត្តា ជាផ្លូវដ៏បរិសុទ្ធ នៃបុគ្គលអ្នកច្រើន ដោយព្យាបាទ, ករុណា ជាផ្លូវដ៏បរិសុទ្ធ នៃបុគ្គលអ្នក

ច្រើនដោយសេចក្តីបៀតបៀន, មុទិតា ជាផ្លូវដ៏បរិសុទ្ធនៃបុគ្គលអ្នកច្រើនដោយសេចក្តីមិនត្រេកអរ, ឧបេក្ខា ជាផ្លូវដ៏បរិសុទ្ធ នៃបុគ្គលអ្នកច្រើនដោយតម្រេក ព្រោះហេតុណា, មួយទៀត ការធ្វើទុកក្នុងចិត្ត ចំពោះសត្វទាំងឡាយ ក៏មាន ៤ ប្រការហ្នឹងឯង ដោយអំណាចនៃការប្រមូលមកនូវប្រយោជន៍ ការកំចាត់ចោលនូវអំពើដែលមិនជាប្រយោជន៍ ការត្រេកអរនូវសម្បត្តិ និង ការមិនបាច់តាំងចិត្តខ្វល់ខ្វាយ ព្រោះហេតុណា, ពុំនោះសោតទេ ប្រៀបដូចជាមាតា ជាអ្នកមានសេចក្តីប្រាថ្នា នូវការចំរុងចំរើន ដល់កូនតូច ក្នុងចំណោមកូនទាំង ៤ ពួក គឺ កូនតូច កូនដែលឈឺ កូនដែលពេញកំឡោះ និង កូនដែលខ្វល់ខ្វាយ ក្នុងកិច្ចការរបស់ខ្លួន ជាអ្នកមានសេចក្តីប្រាថ្នាដើម្បីកំចាត់បង់នូវជម្ងឺ ដល់កូនដែលឈឺ ជាអ្នកមានសេចក្តីប្រាថ្នា ដើម្បីការតាំងនៅអស់កាលដ៏យូរ នៃការដល់ព្រមដោយវ័យ ដល់កូនដែលពេញកំឡោះហើយ ជាអ្នកអស់សេចក្តីខ្វល់ខ្វាយ ក្នុងហេតុឯណានីមួយ ដល់កូនដែលខ្វល់ខ្វាយ ក្នុងកិច្ចការរបស់ខ្លួន យ៉ាងណាមិញ, ព្រះយោគី ក៏គប្បីជាអ្នកនៅ ដោយអប្ប-មញ្ញាធម៌ ដោយអំណាចនៃការចំរើនព្រហ្មវិហារ ៤ មានមេត្តាជាដើម ចំពោះសព្វសត្វទាំងឡាយ ក៏យ៉ាងនោះដែរ ព្រោះហេតុណា, ព្រោះហេតុនោះ អប្បមញ្ញា ទើបមាន ៤ ដោយអំណាចនៃកិច្ច មានផ្លូវដ៏បរិសុទ្ធជាដើម ជាងព្រហ្មវិហារ ៤ នេះ ។

ក៏ឯព្រះយោគីអ្នកមានសេចក្តីប្រាថ្នាដើម្បីចំរើនអប្បមញ្ញាទាំង ៤ នេះឯង គប្បីប្រតិបត្តិ ចំពោះសត្វទាំងឡាយ ដោយអំណាចនៃកិរិយាប្រព្រឹត្តិទៅ ដោយអាការៈជាប្រយោជន៍ ជាមុនសិន, ភាវនាដែលមានការប្រព្រឹត្តិទៅដោយអាការៈជាប្រយោជន៍ជាលក្ខណៈហ្នឹងឯង ជាមេត្តា,

បន្ទាប់អំពីនោះទៅ ព្រះយោគីបានឃើញក្តី បានស្តាប់ក្តី បានសរសើរក្តី (បានត្រិះរិះក្តី) នូវភាវៈនៃសត្វទាំងឡាយ ដែលប្រាថ្នាប្រយោជន៍ យ៉ាងនេះហើយ ត្រូវសេចក្តីទុក្ខគ្របសង្កត់ គប្បីប្រតិបត្តិ ដោយអំណាច នៃកិរិយាប្រព្រឹត្តិទៅ ដោយអាការៈនៃការកំចាត់បង់ នូវសេចក្តីទុក្ខ, ភាវនាដែលមានការប្រព្រឹត្តិទៅ ដើម្បីការកំចាត់បង់ នូវសេចក្តីទុក្ខជាលក្ខណៈហ្នឹងឯង ជាករុណា, បន្ទាប់មក ព្រះយោគី បានឃើញនូវសម្បត្តិនៃសត្វទាំងឡាយនោះដែលជាអ្នកប្រាថ្នានូវប្រយោជន៍ និង ជាអ្នកប្រាថ្នានូវការប្រាសចាកសេចក្តីទុក្ខ យ៉ាងនេះហើយ គប្បីប្រតិបត្តិ ដោយអំណាចនៃការរីករាយក្នុងសម្បត្តិ (របស់សត្វទាំងនោះ), ភាវនា (ការចំរើន) ដែលមានការរីករាយទូទៅជាលក្ខណៈហ្នឹងឯង ជាមុទិតា, ចំណែកបន្ទាប់អំពីមុទិតានោះមក ព្រះយោគាវចរ គប្បីប្រតិបត្តិ ដោយអាការៈជាកណ្តាលពោលគឺភាពនៃខ្លួនជាអ្នកមានចិត្តព្រងើយកន្តើយព្រោះមិនមានកិច្ចដែលខ្លួនគប្បីធ្វើ, ភាវនាដែលមានការប្រព្រឹត្តិទៅ ដោយអាការៈជាកណ្តាលជាលក្ខណៈហ្នឹងឯង ជាឧបេក្ខា, ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបលំដាប់នេះ នៃអប្បមញ្ញាទាំងឡាយនុ៎ះ យ៉ាងនេះ ថា "ព្រះមានព្រះភាគទ្រង់ត្រាស់មេត្តា ជាមុន បន្ទាប់មក ទ្រង់ត្រាស់ករុណា មុទិតា ឧបេក្ខា" ដោយអំណាចនៃអាការៈមានប្រយោជន៍ជាដើម អំពី អប្បមញ្ញា នេះ ។

ក៏ព្រោះថា អប្បមញ្ញាទាំងឡាយទាំងអស់នេះ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ មានប្រមាណមិនបាន, មែនពិត សត្វទាំងឡាយ មានប្រមាណមិនបាន ជាអារម្មណ៍ នៃអប្បមញ្ញាទាំងនុ៎ះ, ភាវនាទាំងនោះប្រព្រឹត្តទៅ ដោយអំណាចនៃការផ្សាយទៅទាំងមូលតែម្តង មិនប្រកាន់យកនូវប្រមាណ យ៉ាងនេះ ថា "ក៏ព្រះយោគីគប្បីចំរើនអប្បមញ្ញា មាន

មេត្តាជាដើម ក្នុងទីដែលមានប្រមាណប៉ុណ្ណោះ សូម្បីដល់សត្វ ១" យ៉ាងដូច្នេះឯង ។ ព្រោះហេតុនោះ ទើបលោកពោលហើយ ថា :

បណ្ឌិត គប្បីជ្រាបគុណជាតិ ៤ មានមេត្តាជាដើម
ដោយអំណាចនៃអាការៈមានផ្លូវដ៏បរិសុទ្ធជាដើម តែថា
គប្បីជ្រាបលំដាប់ នៃគុណជាតិ មានមេត្តាជាដើមនោះ
ដោយអំណាចនៃអាការៈ មានការគិតប្រយោជន៍ ជា
ដើម, មួយទៀត គុណជាតិទាំងឡាយ មានមេត្តា ជា
ដើមនោះ រមែងប្រព្រឹត្តទៅ ក្នុងអារម្មណ៍មានប្រមាណ
មិនបាន ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះ
មានព្រះភាគ ទ្រង់ត្រាស់ថា អប្បមញ្ញា ។

(ព្រហ្មវិហារបីខាងដើមសំរេចបានត្រឹមតែតតិយជ្ឈាន)

(១៩៤) អប្បមញ្ញា ៣ ខាងដើម ក្នុងចំណោមអប្បមញ្ញាទាំង៤នោះ ដែលមានលក្ខណៈតែមួយ ព្រោះភាវៈនៃអប្បមញ្ញាទាំងនោះ មានប្រមាណមិនបាន យ៉ាងនេះ ទើបជាអប្បមញ្ញាប្រព្រឹត្តទៅ ក្នុងឈាន ៣ ក្នុងចតុក្កន័យ និងប្រព្រឹត្តទៅក្នុងឈាន៤ ក្នុងបញ្ចកន័យ ប៉ុណ្ណោះឯង ។ ព្រោះហេតុអ្វី? ។ ព្រោះមិនបានប្រាសចាកសោមនស្ស ។ ក៏ការប្រាសចាកសោមនស្សមិនបានតែងមានដល់អប្បមញ្ញាទាំងនុ៎ះ ព្រោះហេតុអ្វី ។ ព្រោះអប្បមញ្ញាទាំងនោះ ជាគ្រឿងរលាស់ចេញ នូវអកុសលធម៌ទាំងឡាយ មានព្យាបាទជាដើម ដែលកើតអំពីទោមនស្ស ។ ចំណែកខាងអប្បមញ្ញាខាងចុង ជាអវសេសឯកជ្ឈានិកៈ (ប្រព្រឹត្តទៅ ក្នុងឈានតែមួយ ដែលសេសសល់ គឺចតុត្ថជ្ឈាន ក្នុងចតុក្កន័យ ឬ បញ្ចកជ្ឈាន ក្នុង

បញ្ចកនយ) ។ ព្រោះហេតុអ្វី? ។ ព្រោះប្រកបដោយឧបេក្ខាវេទនា ។ មែនពិត ឧបេក្ខាព្រហ្មវិហារ ដែលប្រព្រឹត្តទៅ ក្នុងអាការៈជាកណ្តាល ក្នុងសត្វទាំងឡាយ វៀរចាកឧបេក្ខាវេទនា ប្រព្រឹត្តទៅមិនបានឡើយ ។

ចំណែកបុគ្គលណា គប្បីពោលយ៉ាងនេះថាៈ ព្រោះព្រះមានព្រះភាគទ្រង់ត្រាស់ ដោយមិនប្លែកគ្នា ក្នុងអប្បមញ្ញាទាំង ៤ ក្នុងអដ្ឋកនិបាត ថា “ម្នាលភិក្ខុ ក្នុងកាលនោះ អ្នកគួរចំរើននូវសមាធិនេះ ដែលប្រកបដោយវិតក្កៈ និង វិចារៈផង គួរចំរើននូវសមាធិ ដែលមិនមានវិតក្កៈផង មានតែវិចារៈប៉ុណ្ណោះ គួរចំរើននូវសមាធិ ដែលមិនមានវិតក្កៈ មិនមានវិចារៈផង គួរចំរើននូវសមាធិ ដែលប្រកបដោយបីតិផង គួរចំរើននូវសមាធិ ដែលមិនមានបីតិផង គួរចំរើននូវសមាធិ ដែលប្រកបដោយសេចក្តីសប្បាយផង គួរចំរើននូវសមាធិ ដែលប្រកបដោយឧបេក្ខា [១] ផង” ដូច្នេះ ព្រោះហេតុនោះ អប្បមញ្ញាទាំង ៤ នោះឯង ជាអប្បមញ្ញា ប្រព្រឹត្តទៅក្នុងចតុក្កជ្ឈាន ក្នុងចតុក្កនយ ឬ ប្រព្រឹត្តទៅ ក្នុងបញ្ចកជ្ឈាន ក្នុងបញ្ចកនយ ។

បុគ្គលនោះជាបុគ្គលគឺគេគប្បីពោលថា “អ្នកកុំគប្បីពោលពាក្យយ៉ាងនេះ ដល់បុគ្គលនោះឡើយ ព្រោះថា កាលបើយ៉ាងដូច្នេះ សូម្បីវិបស្សនាទាំងឡាយ មានកាយានុបស្សនាជាដើម ក៏គប្បីជាវិបស្សនា ដែលប្រកបដោយចតុក្កជ្ឈាន និង បញ្ចកជ្ឈាន, ក៏សូម្បីក្នុងវិបស្សនាទាំងឡាយ មានវេទនានុបស្សនាជាដើម សូម្បីបឋមជ្ឈាន ក៏មិនមានដែរ, មិនចាំបាច់ពោលថ្វីដល់ឈានទាំងឡាយ មានទុតិយជ្ឈានជាដើម, ព្រោះហេតុនោះ អ្នកកុំបានប្រកាន់ នូវត្រឹមតែស្រមោលនៃព្យញ្ជនៈ ហើយ

១- សុ. អំ. អ. ភាគទី ៤៨ ទំព័រទី ២៧៧ ។

មួលបង្កាច់នូវព្រះមានព្រះភាគឡើយ, ព្រោះថា ព្រះពុទ្ធវចនៈ ជាធម៌ដ៏ជ្រាលជ្រៅ អ្នកគប្បីចូលទៅអង្គុយជិតអាចារ្យទាំងឡាយហើយ គប្បីរៀននូវព្រះពុទ្ធវចនៈនោះ ដោយសេចក្តីអធិប្បាយ ។ ក៏នេះជាសេចក្តីអធិប្បាយ ក្នុងព្រះពុទ្ធវចនៈនោះ ។ បានឮមកថា ព្រះមានព្រះភាគទ្រង់ត្រាស់តិះដៀលភិក្ខុនោះដែលអារាធនា ឲ្យព្រះអង្គសំដែងព្រះធម៌ទេសនា ថា “សាធុប្រពៃហើយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានស្តាប់នូវធម៌ឯណារបស់ព្រះដ៏មានព្រះភាគហើយ ជាបុគ្គលម្នាក់ឯង ចៀសចេញទៅ មិនប្រមាទ មានព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សូមព្រះដ៏មានព្រះភាគសំដែងនូវធម៌នោះ ឲ្យទានដល់ខ្ញុំព្រះអង្គ ដោយសង្ខេប [១] ” ដូច្នេះ ថា “យ៉ាងនេះឯង មោឃបុរសពួកខ្លះក្នុងលោកនេះ គ្រាន់តែអារាធនាតថាគតតែប៉ុណ្ណោះ កាលបើធម៌ដែលតថាគតសំដែងហើយ ក៏គ្រាន់តែសំគាល់តថាគតថាជាបុគ្គលគួរប្រព្រឹត្តតាមប៉ុណ្ណោះ” ដូច្នេះ ព្រោះហេតុដែលភិក្ខុនោះស្តាប់នូវធម៌របស់តថាគតសូម្បីក្នុងកាលមុនហើយ ក៏នៅតែនៅក្នុងទីនោះដដែល មិនប្រាថ្នាដើម្បីធ្វើនូវសមណធម៌ឡើយ ព្រោះភិក្ខុនោះ ដល់ព្រមដោយឧបនិស្ស័យ នៃព្រះអរហត្ត ព្រោះហេតុនោះ កាលទ្រង់ទូន្មាននូវភិក្ខុនោះ ទើបទ្រង់ត្រាស់នឹងភិក្ខុនោះម្តងទៀត ថា “ម្នាលភិក្ខុ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញ នឹងតាំងនៅក្នុងសន្តាន តាំងនៅដោយល្អ ទាំងពួកអកុសលធម៌ដ៏លាមក ក៏មិនកើតឡើង គ្របសង្កត់ចិត្តបានឡើយ ដូច្នេះ, ម្នាលភិក្ខុ អ្នកគប្បីសិក្សា យ៉ាងដូច្នេះឯង” ។ ក៏មូលសមាធិ ត្រឹមតែភាពនៃចិត្ត មានអារម្មណ៍តែមួយ ដោយអំណាចនៃ

១- សុ. អំ. អ. ភាគទី ៤៨ ទំព័រទី ២៧៦ ។

ចិត្តដែលឋិតនៅខាងក្នុង គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដល់ភិក្ខុនោះ ដោយព្រះឱវាទនេះ ។ បន្ទាប់អំពីនោះ ដើម្បីសំដែងនូវព្រះបំណង ថា "ភិក្ខុនោះ មិនដល់នូវសេចក្ដីពេញចិត្ត ដោយសមាធិមានប្រមាណប៉ុណ្ណោះ គប្បីញ៉ាំងសមាធិនោះឲ្យចំរើនយ៉ាងនេះ" ដូច្នេះហើយ ទើបទ្រង់ត្រាស់នូវការចំរើន(សមាធិ) ដោយអំណាចនៃមេត្តា ដល់ភិក្ខុនោះ យ៉ាងនេះ ថា "ម្នាលភិក្ខុ កាលណា ចិត្តរបស់អ្នក តាំងនៅក្នុងសន្ដាន តាំងនៅល្អហើយ ទាំងពួកអកុសលធម៌ ដ៏លាមក ក៏មិនកើតឡើង គ្របសង្កត់ចិត្តបាន, ម្នាលភិក្ខុ កាលនោះ អ្នកគប្បីសិក្សា យ៉ាងនេះ ថា "ចេតោវិមុត្តិ ប្រកបដោយមេត្តា នឹងជាគុណជាតិ គឺអាត្មាអញបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានតាំកល់ស៊ប់ហើយ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ" ដូច្នេះ, ម្នាលភិក្ខុ អ្នកគប្បីសិក្សា យ៉ាងនេះចុះ " ដូច្នេះហើយ ទើបទ្រង់ត្រាស់បន្តទៀត ថា "ម្នាលភិក្ខុ កាលណា សមាធិនេះ គឺអ្នកបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ យ៉ាងនេះ, ម្នាលភិក្ខុ កាលនោះ អ្នកគួរចំរើននូវសមាធិនេះដែលប្រកបដោយវិតក្កៈ និង វិចារៈផង ។ល។ អ្នកគួរចំរើននូវសមាធិនេះ ដែលប្រកបដោយឧបេក្ខាផង" ដូច្នេះ ។

បណ្ឌិតគប្បីជ្រាបសេចក្ដីនៃព្រះឱវាទនោះថា : ព្រះមានព្រះភាគលុះទ្រង់ត្រាស់ថា "ម្នាលភិក្ខុ ក្នុងកាលណា មូលសមាធិនេះ ជាគុណជាតិ គឺអ្នកបានចំរើនហើយ ដោយអំណាចនៃមេត្តា យ៉ាងនេះ, ក្នុងកាលនោះ អ្នកកុំដល់នូវសេចក្ដីត្រេកអរ ដោយសមាធិមានប្រមាណប៉ុណ្ណោះ កាលញ៉ាំងមូលសមាធិនេះ ឲ្យដល់នូវចតុក្កជ្ឈាន និង បញ្ចកជ្ឈាន ក្នុងអារម្មណ៍ទាំងឡាយដទៃ (បន្តទៅទៀត) គប្បីចំរើន ដោយន័យមានន័យ

ថា នូវសមាធិប្រកបដោយវិតក្កៈ និង វិចារៈផង ដូច្នេះជាដើម" ដូច្នេះហើយ កាលទ្រង់សំដែងនូវព្រហ្មវិហារដ៏សេសមានករុណាជាដើម ដែលជាប្រធាន ដល់ភិក្ខុនោះម្ដងទៀត ថា "ភិក្ខុគប្បីធ្វើ នូវការចំរើនសមាធិ ដោយអំណាចនៃចតុក្កជ្ឈាន និង បញ្ចកជ្ឈាន ក្នុងអារម្មណ៍ទាំងឡាយដទៃ" ដូច្នេះ ទើបទ្រង់ត្រាស់ព្រះតម្រាស់ថា "ម្នាលភិក្ខុ ក្នុងកាលណា សមាធិនេះ ជាគុណជាតិ គឺអ្នកបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ យ៉ាងនេះ, ម្នាលភិក្ខុ ក្នុងកាលនោះ អ្នកគប្បីសិក្សា យ៉ាងនេះ ថា "ចេតោវិមុត្តិ ប្រកបដោយករុណា ជាគុណជាតិ គឺអាត្មាអញបានចំរើនហើយ បានធ្វើឲ្យច្រើនហើយ..." ដូច្នេះជាដើម, លុះព្រះមានព្រះភាគទ្រង់សំដែងនូវការចំរើននូវចតុក្កជ្ឈាន និង បញ្ចកជ្ឈាន ដែលមានមេត្តាជាដើម ជាប្រធាន យ៉ាងនេះរួចហើយ ដើម្បីទ្រង់សំដែងនូវសមាធិដែលមានអនុបស្សនា ៤ មានកាយានុបស្សនាជាដើម ជាប្រធាន ទើបទ្រង់ត្រាស់នូវព្រះតម្រាស់ថា "ម្នាលភិក្ខុ ក្នុងកាលណា សមាធិនេះ ជាគុណជាតិគឺអ្នកបានចំរើនហើយ បានធ្វើឲ្យច្រើនហើយយ៉ាងនេះ, ម្នាលភិក្ខុ ក្នុងកាលនោះ អ្នកគប្បីសិក្សា យ៉ាងនេះ ថា "អាត្មាអញ នឹងជាអ្នកមានកិរិយាពិចារណានូវកាយក្នុងកាយនៅ" ដូច្នេះជាដើម ទើបទ្រង់ញ៉ាំងភិក្ខុនោះ ឲ្យសមាទាននូវព្រះធម៌ទេសនា ដោយជាកំពូលគឺព្រះអរហត្ត ថា "ម្នាលភិក្ខុ ក្នុងកាលណា សមាធិនេះ នឹងជាគុណជាតិ គឺអ្នកបានចំរើនហើយ នឹងបានចំរើនល្អហើយយ៉ាងនេះ ម្នាលភិក្ខុ ក្នុងកាលនោះ អ្នកនឹងទៅ ក្នុងទីណាៗ អ្នកនឹងនៅសប្បាយ ក្នុងទីនោះៗ អ្នកនឹងឈរនៅក្នុងទីណាៗ អ្នកនឹងឈរនៅសប្បាយ ក្នុងទីនោះៗ អ្នកនឹងអង្គុយ ក្នុងទីណាៗ អ្នកនឹងអង្គុយសប្បាយ ក្នុងទីនោះៗ អ្នកនឹងសម្រេចការដេក

ក្នុងទីណាៗ អ្នកនឹងសម្រេចការដេកសប្បាយ ក្នុងទីនោះៗ” ដូច្នេះ ។

ព្រោះហេតុនោះ អប្បមញ្ញា ៣ មានមេត្តាជាដើម បណ្ឌិតគប្បីជ្រាបថា “ជាតិកជ្ឈានិកា និង ចតុក្កជ្ឈានិកា (គឺប្រព្រឹត្តទៅក្នុងឈាន ៣ ក្នុងចតុក្កន័យ និងប្រព្រឹត្តទៅក្នុងឈាន ៤ ក្នុងបញ្ចកន័យ) តែប៉ុណ្ណោះ”, ចំណែកឧបេក្ខាបណ្ឌិតគប្បីជ្រាបថា “ជាអវសេសឯកជ្ឈានិកា(គឺប្រព្រឹត្តទៅ ក្នុងឈានតែមួយដ៏សេស) តែប៉ុណ្ណោះ” ។ ក៏អប្បមញ្ញាទាំងឡាយមានមេត្តាជាដើម គឺព្រះដ៏មានព្រះភាគទ្រង់ចំណែកហើយ ក្នុងអភិធម្មឯណោះដូចគ្នាដែរ ។

(អប្បមញ្ញាមានអានុភាពផ្សេងគ្នា)

(១៩៥) បណ្ឌិតគប្បីជ្រាបថា អប្បមញ្ញាទាំង ៤ នោះ សូម្បីបិតនៅហើយ ដោយ ២ ផ្នែក ដោយអំណាចនៃតិកជ្ឈាន ឬ ចតុក្កជ្ឈាន ១ ដោយអំណាចនៃអវសេសឯកជ្ឈាន១ ដូចបានពោលមកហើយនេះ មានអានុភាពដ៏វិសេស មិនដូចគ្នា ដោយអំណាចនៃវិមោក្ខ មានសុភវិមោក្ខដ៏ក្រៃលែងជាដើម ។ មែនពិត អប្បមញ្ញាទាំងនុ៎ះ ព្រះមានព្រះភាគទ្រង់សំដែង ឲ្យវិសេស ក្នុងហលិទ្ទវសនសូត្រ ដោយអំណាចវិមោក្ខ មានសុភវិមោក្ខ ដ៏ក្រៃលែងជាដើម ។ ដូចជាព្រះអង្គទ្រង់ត្រាស់ ថា “ម្នាលភិក្ខុទាំងឡាយ តថាគត ហៅមេត្តាចេតោវិមុត្តិ ថា មានសុភវិមោក្ខដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ តថាគត ហៅករុណាចេតោវិមុត្តិ ថា មានអាកាសានញ្ចាយតនៈ ជាយ៉ាងក្រៃលែង ម្នាលភិក្ខុទាំងឡាយ តថាគតហៅមុទិតាចេតោវិមុត្តិ ថា មានវិញ្ញាណញ្ចាយតនៈ ជាយ៉ាងក្រៃលែង ម្នាលភិក្ខុទាំងឡាយ តថាគតហៅឧបេក្ខាចេតោវិមុត្តិ ថា មានអាកិញ្ចញ្ញាយតនៈ ជាយ៉ាងក្រៃលែង” ។ សួរថា “ចុះព្រោះហេតុអ្វី បានជាព្រះ

មានព្រះភាគ ទ្រង់ត្រាស់អប្បមញ្ញាទាំងនោះ យ៉ាងនេះ ? ” ។ ឆ្លើយថា “ព្រោះអប្បមញ្ញាទាំងនោះ ជាឧបនិស្ស័យនៃវិមោក្ខនោះៗ” ។ មែនពិត សត្វទាំងឡាយ រមែងជារបស់មិនបដិកូល សំរាប់ព្រះយោគី អ្នកមានកិរិយានៅដោយមេត្តា ។ លំដាប់នោះ កាលព្រះយោគី អ្នកមានកិរិយានៅដោយមេត្តានោះ ប្រមូលនូវចិត្ត ក្នុងពណ៌ទាំងឡាយមានពណ៌ខៀវជាដើម ដែលជាពណ៌ដ៏បរិសុទ្ធ មិនបដិកូល ព្រោះកិរិយាថ្នឹកដោយវត្ថុដែលមិនបដិកូល ចិត្ត តែងស្ទុះទៅក្នុងវណ្ណកសិណនោះ ដោយមិនបាច់ព្រួយឡើយ ។ មេត្តាជាឧបនិស្ស័យនៃសុភវិមោក្ខ ដោយន័យដែលបានពោលមកនេះឯង បន្ទាប់អំពីមេត្តានោះមក មិនមែនជាឧបនិស្ស័យទេ ព្រោះហេតុនោះ ទើបបានជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់មេត្តានោះថា “មានសុភវិមោក្ខ យ៉ាងក្រៃលែង” ។

សំរាប់ព្រះយោគីអ្នកមានកិរិយានៅដោយករុណា អ្នកពិចារណាឃើញច្បាស់ នូវសេចក្តីទុក្ខរបស់សត្វ មានរូបស្វាកស្នាមដែលបុគ្គលវាយហើយដោយដំបងជាដើម ទោស ក្នុងរូប គឺជាទោសដែលដឹងច្បាស់ហើយ ព្រោះកើតមានកិរិយាប្រព្រឹត្តិទៅនៃករុណា ។ តមក ព្រោះភាវៈនៃរូបដែលខ្លួនដឹងប្រាកដហើយថាជាទោស កាលព្រះយោគីនុ៎ះ បើកនូវកសិណណាមួយ ក្នុងចំណោមកសិណ មានបឋវីកសិណជាដើមហើយប្រមូលមកនូវចិត្ត ក្នុងអាកាសជាគ្រឿងរលាស់ចោលនូវរូប, ចិត្ត តែងស្ទុះទៅ ក្នុងអាកាសនោះ ដោយមិនបាច់ព្រួយឡើយ ។ ករុណា ជាឧបនិស្ស័យ នៃអាកាសានញ្ចាយតនវិមោក្ខ ដោយន័យដែលបានពោលមកនេះ បន្ទាប់អំពីករុណានោះទៅ មិនមែនជាឧបនិស្ស័យទេ ព្រោះហេតុនោះ ករុណានោះ បានជាព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា “មាន

អាកាសានញ្ចាយតនវិមោក្ខ ជាយ៉ាងក្រៃលែង” ។

ចំណែកឯ ចិត្ត របស់ព្រះយោគី អ្នកមានកិរិយានៅដោយមុទិតា អ្នកពិចារណាឃើញច្បាស់ នូវវិញ្ញាណ របស់ពួកសត្វដែលមានសេចក្តីរីករាយកើតឡើងហើយ ដោយហេតុនៃសេចក្តីរីករាយនោះៗ រមែងជាចិត្តប្រាកដច្បាស់ហើយ ក្នុងការកាន់យកនូវវិញ្ញាណ ព្រោះកើតមានកិរិយាប្រព្រឹត្តិទៅនៃមុទិតា ។ បន្ទាប់មក កាលព្រះយោគីនោះ ប្រព្រឹត្តកន្លងនូវអាកាសានញ្ចាយតនៈ ដែលខ្លួនបានសំរេចហើយ ដោយលំដាប់ ហើយប្រមូលមកនូវចិត្ត ក្នុងវិញ្ញាណ ដែលមាននិមិត្ត គឺអាកាសជាអារម្មណ៍, ចិត្ត (របស់ព្រះយោគីនោះ) តែងស្ទុះទៅ ក្នុងវិញ្ញាណនោះ ដោយមិនបាច់ព្រួយឡើយ។ មុទិតា ជាឧបនិស្ស័យនៃវិញ្ញាណញ្ចាយតនវិមោក្ខ ដោយន័យដែលបានពោលមកនេះ, បន្ទាប់អំពីមុទិតានោះទៅ មិនមែនជាឧបនិស្ស័យទេ ព្រោះហេតុនោះ មុទិតានោះ បានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា “មានវិញ្ញាណញ្ចាយតនវិមោក្ខយ៉ាងក្រៃលែង” ។

ចំណែក ចិត្ត របស់ព្រះយោគី អ្នកមានកិរិយានៅដោយឧបេក្ខា រមែងជាចិត្តដ៏លំបាក ក្នុងកិរិយាកាន់យកនូវធម្មជាតដែលមិនមាន ព្រោះភាវៈជាអ្នកព្រងើយកន្តើយ ក្នុងកិរិយាកាន់យកនូវប្រយោជន៍ របស់អ្នកដទៃ មានសុខ និង ទុក្ខជាដើម ព្រោះមិនមានសេចក្តីកង្វល់ ថា “សត្វទាំងឡាយចូរជាសត្វដល់ហើយនូវសេចក្តីសុខ ឬ ឬថា សត្វទាំងឡាយចូររួចចាកទុក្ខ មួយវិញទៀត សត្វទាំងឡាយចូរកុំប្រាសចាកសេចក្តីសុខដែលដល់ព្រមហើយ” ដូច្នេះ ។ បន្ទាប់មក កាលព្រះយោគីនោះ មានចិត្តថ្មឹក ក្នុងកិរិយាព្រងើយកន្តើយ ចំពោះការកាន់យកនូវប្រយោជន៍ នៃបុគ្គលដទៃ និង ជាអ្នកមានចិត្តលំបាក ក្នុងការកាន់យកនូវធម្មជាតដែល

មិនមាន តាមបរមត្ថ ប្រព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនៈ ដែលខ្លួនបានសំរេចហើយដោយលំដាប់ ហើយប្រមូលមកនូវចិត្ត ក្នុងការមិនមាន នៃវិញ្ញាណដែលជាបរមត្ថ ក្នុងធម្មជាតដែលគ្មាន ដោយសភាវៈ, ចិត្ត តែងស្ទុះទៅ ក្នុងការមិនមាននៃវិញ្ញាណនោះ ដោយមិនបាច់ព្រួយឡើយ ។ ឧបេក្ខា ជាឧបនិស្ស័យ នៃអាកិញ្ចញ្ញាយតនវិមោក្ខ ដោយន័យដែលបានពោលមកហើយនេះ បន្ទាប់អំពីឧបេក្ខានោះ មិនមែនជាឧបនិស្ស័យទេ, ព្រោះហេតុនោះ ឧបេក្ខា ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា “មានអាកិញ្ចញ្ញាយតនវិមោក្ខ ជាយ៉ាងក្រៃលែង” ដោយប្រការដូច្នេះ ។

(អប្បមញ្ញាធ្វើកល្យាណធម៌ឱ្យបរិបូរ)

បណ្ឌិតជ្រាប នូវអានុភាពនៃអប្បមញ្ញាទាំងនុ៎ះ ដោយអំណាចនៃវិមោក្ខមានសុភវិមោក្ខដ៏ក្រៃលែងជាដើម យ៉ាងនេះហើយ គប្បីជ្រាបនូវអប្បមញ្ញាទាំងអស់នោះ ម្តងទៀត ថា “ជាគុណជាតិ បំពេញនូវពួកកល្យាណធម៌គ្រប់យ៉ាង មានទានជាដើម ឲ្យបរិបូរ” ដូច្នេះ ។ មែនពិត ព្រះមហាសត្វទាំងឡាយ ជាអ្នកមានចិត្តប្រព្រឹត្តទៅស្មើ ព្រោះភាវៈជាអ្នកមានអជ្ឈាស្រ័យជាប្រយោជន៍ ចំពោះសត្វទាំងឡាយផង ព្រោះភាពជាអ្នកអត់ទ្រាំមិនបាននូវសេចក្តីទុក្ខរបស់សត្វទាំងឡាយផង ព្រោះភាវៈជាអ្នកមានសេចក្តីប្រាថ្នា ដើម្បីការបិតនៅ អស់កាលយូរ ចំពោះសម្បត្តិវិសេសរបស់សត្វទាំងឡាយផង និង ព្រោះភាពមិនមានការធ្លាក់ចុះទៅក្នុងបក្សពួក ក្នុងសព្វសត្វទាំងឡាយផង ទ្រង់បំពេញនូវបារមីទាំងឡាយ យ៉ាងនេះ គឺ : (១) ទ្រង់ឲ្យទាន ដែលជាហេតុនៃសេចក្តីសុខ ចំពោះសព្វសត្វទាំងឡាយ មិនទ្រង់ធ្វើនូវការបែងចែក ថា “គឺអាត្មាអញ គួរឲ្យដល់ជននេះ មិនគួរឲ្យដល់ជននេះទេ” ដូច្នេះ, (២) ទ្រង់លះបង់ នូវគំនុំ

គុំក្កួន ចំពោះតួទាំងឡាយនោះ សមាទាននូវសីល, (៣) ទ្រង់គប់រកនូវនេក្ខម្ម ដើម្បីញុំាងសីលឲ្យពេញបរិបូរ, (៤) ទ្រង់ជម្រះនូវបញ្ញា ឲ្យផូរផង់ ដើម្បីប្រយោជន៍ដល់សេចក្តីមិនវង្វេង ក្នុងប្រយោជន៍ និង មិនមែនជាប្រយោជន៍របស់សត្វទាំងឡាយ, (៥) ទ្រង់ប្រារព្ធនូវសេចក្តីព្យាយាមជានិច្ច ដើម្បីប្រយោជន៍ និង សេចក្តីសុខ ដល់សត្វទាំងឡាយ, (៦) មួយទៀត បើទុកជាដល់ហើយនូវសេចក្តីក្លៀវក្លា ដោយអំណាចសេចក្តីព្យាយាមដ៏ខ្ពង់ខ្ពស់ ក៏ទ្រង់អត់នូវទោសកំហុសមានប្រការផ្សេងៗ ដល់សត្វទាំងឡាយដែរ, (៧) មិនទ្រង់ញុំាងសេចក្តីប្តេជ្ញា ដែលខ្លួនធ្វើហើយ ថា "យើងនឹងឲ្យទាននេះ ដល់អ្នកទាំងឡាយ នឹងធ្វើនូវរបស់នេះ ដល់អ្នកទាំងឡាយ" ដូច្នេះ ឲ្យឃ្លៀងឃ្លាតឡើយ, (៨) ទ្រង់ជាអ្នកមានសេចក្តីអធិដ្ឋានមិនកម្រើក ដើម្បីប្រយោជន៍ និង សេចក្តីសុខ ដល់សត្វទាំងឡាយនោះ, (៩) ទ្រង់ជាអ្នកមានកិរិយាធ្វើមុន ដោយមេត្តា មិនឲ្យឃ្លៀងឃ្លាតចំពោះសត្វទាំងនោះ, (១០) តែមិនទ្រង់នឹកប្រាថ្នានូវឧបការៈតបវិញ ដោយឧបេក្ខា ដូច្នេះ រហូតដល់ទ្រង់បំពេញនូវកល្យាណធម៌ទាំងឡាយគ្រប់យ៉ាង ផ្សេងដោយពលញ្ញាណ ១០ វេសារជ្ជញ្ញាណ ៤ អសាធារណញ្ញាណ ៦ និង ពុទ្ធធម៌ ១៨ ឲ្យពេញបរិបូរ ។ អប្បមញ្ញាទាំងឡាយនុ៎ះឯង ជាគុណជាតិបំពេញ នូវកល្យាណធម៌ទាំងអស់ មានទានជាដើមឲ្យបរិបូរ យ៉ាងនេះឯង ។

បរិច្ឆេទ ទី៩ ឈ្មោះ ព្រហ្មវិហារនិទ្ទេស ក្នុងអធិការនៃសមាធិកាវនា
ក្នុងបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គដែលខ្ញុំរៀបរៀងហើយ
ដើម្បីប្រយោជន៍ដល់កិរិយាញុំាងសាធុជនឲ្យរីករាយ (ចប់ហើយ)
ដោយប្រការដូច្នេះឯង ។

អារុប្បនិទ្ទេស

(អាកាសានញ្ចាយតនៈ)

(១៩៦) ចំណែកឯ ក្នុងអរូបកម្មដ្ឋានទាំងឡាយ ៤ ដែលព្រះមានព្រះភាគទ្រង់សំដែងចេញហើយ បន្ទាប់ពីព្រហ្មវិហារ ព្រះយោគីអ្នកប្រាថ្នាដើម្បីចំរើននូវអាកាសានញ្ចាយតនៈ ជាដំបូង ឃើញនូវទោសក្នុងករជរូប ដោយអំណាចនៃទោស មានការកាន់យកនូវដំបងជាដើមផងនៃអាពាធទាំង ១,០០០ មានរោគក្នុងភ្នែក និង ត្រចៀក ជាដើមនេះផង ព្រោះបាឡីថា "ក៏ការកាន់យកដំបង កាន់យកនូវគ្រឿងសស្ត្រា ជំលោះការប្រកាន់ខុស និងការទាស់ទែងគ្នាទាំងឡាយ ជាជំលោះដល់រូប រមែងប្រាកដមែនពិត ប៉ុន្តែទោសមានការកាន់យកនូវដំបងជាដើមនុ៎ះ មិនមានឡើយ ដោយប្រការទាំងពួង ក្នុងអារូប្បឈាន ព្រះយោគីនោះពិចារណាឃើញ យ៉ាងនេះហើយ ជាអ្នកប្រតិបត្តិដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវរូបទាំងឡាយមែនពិត" ដូច្នេះហើយញុំាងចតុត្ថជ្ឈានឲ្យកើតឡើងក្នុងកសិណណាមួយ ក្នុងចំណោមកសិណ ៩ មានបឋវីកសិណជាដើម លើកលែងតែអាកាសកសិណដែលកំណត់ហើយ ដើម្បីកន្លងនូវករជរូបនោះ ។ មែនពិត ករជរូប ជាអារម្មណ៍ដែលព្រះយោគីនោះកន្លងហើយ ដោយអំណាចនៃចតុត្ថជ្ឈានជារូបាវចរក៏ពិតមែនហើយ តែបើទុកជាដូច្នោះ សូម្បីកសិណរូបក៏មានករជរូបនោះជាគ្រឿងប្រៀបធៀបដែរ ព្រោះហេតុណា ព្រោះហេតុនោះ ព្រះយោគីនោះ ជាអ្នកប្រាថ្នាដើម្បីកន្លង នូវកសិណរូបនោះឯង ។ សួរថា "កន្លងដោយប្រការដូច្នេះ ? " ។ ឆ្លើយថា "ដូចជាបុរសខ្លាចពស់ ត្រូវពស់ក្នុងព្រៃដេញតាម រត់ទៅយ៉ាងលឿន ឃើញនូវស្លឹកត្នោតដែលវិចិត្រដោយគំនូរក្តី នូវវល្លិក្តី នូវខ្សែក្តី ពុំនោះសោត នូវក្រហែងនៃផែនដីដែលបែក

ក្រហែងហើយក្តី ក្នុងទីដែលខ្លួនរត់ហើយ រឹងរឹតតែខ្លាចរឹងរឹតតែតក់ស្លុត ជាអ្នកមិនប្រាថ្នាដើម្បីឃើញវត្ថុនោះឡើយ យ៉ាងណាមិញ ។ មួយទៀត ប្រៀបដូចជាបុរស នៅក្នុងស្រុកមួយ ជាមួយនឹងបុរសមានពៀរ អ្នកធ្វើនូវសេចក្តីវិនាស ត្រូវបុរសមានពៀរនោះ ចូលទៅប្រទូស្តហើយ ដោយការសម្លាប់ ការចាប់ចង និង ការដុតផ្ទះជាដើម ទៅកាន់ស្រុកដទៃ ដើម្បីប្រយោជន៍ដល់ការរស់នៅ ក៏ឃើញនូវបុរស ដែលមានរូប សំឡេង និងការហៅរកប្រហែលគ្នានឹងបុរសមានពៀរ ក្នុងស្រុកនោះទៀត ហើយក៏រឹងរឹតតែខ្លាច រឹងរឹតតែតក់ស្លុត ជាអ្នកមិនប្រាថ្នាចង់ឃើញនូវបុរសនោះសោះឡើយ យ៉ាងណាមិញ ។ នេះជាសេចក្តីប្រៀបធៀប នូវភាពនៃសេចក្តីប្រៀបផ្ទឹម ក្នុងករជរូបនោះ ។

មែនពិត កាលជាទីព្រមព្រៀងដោយករជរូប ដោយអំណាចនៃអារម្មណ៍ របស់ភិក្ខុ ដូចជាកាលដែលបុរសទាំងឡាយនោះ ត្រូវពស់ ឬ ត្រូវបុរសមានពៀរ ចូលទៅប្រទូស្តហើយ ។ កាលដែលភិក្ខុ ប្រព្រឹត្តកន្លងនូវករជរូបបាន ដោយអំណាចនៃចតុត្ថជ្ឈានជារូបាវចរ ដូចជាការដែលបុរសទាំងនោះ រត់ទៅយ៉ាងលឿន និង ទៅកាន់ស្រុកដទៃទៀត ។ ភាវៈនៃភិក្ខុកំណត់នូវកសិណរូបហ្នឹងឯងថា "កសិណរូបនេះមានចំណែកប្រៀបដោយករជរូបមែនពិត" ដូច្នេះហើយ ប្រាថ្នាដើម្បីប្រព្រឹត្តកន្លង នូវកសិណរូបនោះឯង ដូចជាភាវៈនៃបុរសទាំងឡាយនោះ ឃើញនូវវត្ថុដែលស្រដៀងពស់ មានស្លឹកត្នោតដែលវិចិត្រហើយ ដោយគំនូរជាដើម និង នូវបុរសជាអ្នកប្រាកដស្មើដោយបុគ្គលមានពៀរ ក្នុងទីដែលខ្លួនរត់ទៅហើយ និង ក្នុងស្រុកមួយ ហើយភ័យខ្លាច និង មិនប្រាថ្នាដើម្បីជួបប្រទះឡើយ ។

មួយទៀត បណ្ឌិតគប្បីពណ៌នាសេចក្តីប្រៀបធៀប មានឆ្កែដែលត្រូវជ្រូកព្រៃខ្វេះ និង បុរសដែលខ្លាចខ្មោចជាដើម ក្នុងករជរូបនុ៎ះចុះ ។

ព្រះយោគីនោះ នឿយណាយ ចាកកសិណរូបដែលជាអារម្មណ៍របស់ចតុត្ថជ្ឈាននោះ យ៉ាងនេះហើយ ជាអ្នកប្រាថ្នាដើម្បីចៀសចេញទៅ ជាអ្នកស្ទាត់ជំនាញ ដោយអាការៈទាំងឡាយ ៥ ហើយចេញចាកចតុត្ថជ្ឈាន ជារូបាវចរ ដែលស្ទាត់ជំនាញហើយ ឃើញនូវទោស ក្នុងឈាននោះ ថា "ចតុត្ថជ្ឈាននេះ ធ្វើនូវរូប ដែលអាត្មាអញនឿយណាយហើយ ឲ្យជាអារម្មណ៍" ដូច្នេះផង ថា "ចតុត្ថជ្ឈាននេះ ជាសត្រូវ ដល់សោមនស្សដ៏ជិត" ដូច្នេះផង ថា "ចតុត្ថជ្ឈាននេះ ជាឈានគ្រោតគ្រាតជាងវិមោក្ខដ៏ល្អិត" ដូច្នេះផង ។

ក៏ក្នុងអារូប្បជ្ឈាននុ៎ះ មិនមានអង្គដែលគ្រោតគ្រាតទេ ។ មែនពិត ចតុត្ថជ្ឈាន ជារូបាវចរនេះ ប្រកបដោយអង្គ ២ ហ្នឹងឯង យ៉ាងណា, សូម្បីអារូបជ្ឈានទាំងឡាយ ក៏ប្រកបដោយអង្គ ២ ក៏យ៉ាងនោះដែរ ។

(បើកកសិណ)

ព្រះយោគីនោះ លុះឃើញនូវទោស ក្នុងរូបាវចរចតុត្ថជ្ឈាននោះយ៉ាងនេះហើយ គ្របសង្កត់នូវសេចក្តីស្រឡាញ់ ធ្វើទុកក្នុងចិត្តនូវអាកា-សានញ្ចាយតនៈ ដោយថាជាធម៌ដ៏ល្អិត ហើយផ្សាយកសិណទៅ រហូតដល់ទីបំផុតនៃចក្រវាឡ ឬ រហូតដល់ទីដែលខ្លួនប្រាថ្នា ហើយធ្វើទុកក្នុងចិត្តនូវឱកាសដែលកសិណរូបនោះផ្សាយទៅដល់ថា "អាកាស" ដូច្នេះក្តី ថា "អាកាស គ្មានទីបំផុត" ដូច្នេះក្តី ទើបបើកនូវកសិណបាន ។ ក៏ព្រះយោគី កាលបើកនូវកសិណ មិនមូរ ដូចជាបុគ្គលមូរកន្ទេលផែងទេ មិនរើឡើង ដូចជាបុគ្គលលើកឡើង នូវនំអំពីអំបែងទេ គ្រាន់តែលែងនឹកនា

លែងធ្វើទុកក្នុងចិត្ត លែងពិចារណានូវកសិណនោះប៉ុណ្ណោះ, ព្រះយោគី កាលមិននឹកនា មិនធ្វើទុកក្នុងចិត្ត មិនពិចារណា តែថា ធ្វើទុកក្នុងចិត្តនូវឱកាសដែលកសិណរូបនោះ ពាល់ត្រូវហើយ ដោយពិត ថា “អាកាស អាកាស” ដូច្នេះ ឈ្មោះថាបើកនូវកសិណ ។ សូម្បីកសិណ កាលត្រូវព្រះយោគីបើក ក៏មិនមែនរបូតឡើង មិនមែនខ្ទាត់ខ្ចាយឡើយ ជាធម្មជាតដែលអាស្រ័យនូវការធ្វើទុកក្នុងចិត្ត ដល់កសិណរូបនេះ និង ធ្វើទុកក្នុងចិត្ត ថា “អាកាស អាកាស” ដូច្នេះ ទើបឈ្មោះថា ត្រូវបានបើកហើយតែប៉ុណ្ណោះ ។ ការបើកកសិណថាអាកាសប៉ុណ្ណោះ តែងប្រាកដ ។

ពាក្យទាំងអស់នេះ ថា “ការបើកនូវកសិណថាអាកាស” ដូច្នេះក្តី ថា “អាកាសត្រូវកសិណពាល់ត្រូវហើយ” ដូច្នេះក្តី ថា “អាកាសដែលស្វាត់ចាកកសិណ” ដូច្នេះក្តី ជាពាក្យតែមួយមែនពិត ។

(ឧបចារៈ និង អប្បនា)

ព្រះយោគីនោះ ពិចារណារឿយៗ នូវកសិណុគ្ឃាដិកាសនិមិត្តនោះ ថា “អាកាស អាកាស” ដូច្នេះ ឈ្មោះថា ធ្វើឲ្យទៅជានិមិត្តដែលសេចក្តីត្រិះរិះស្ទួយឡើងហើយ ឲ្យទៅជានិមិត្តដែលសេចក្តីនឹកត្រិះរិះស្ទួយឡើងហើយ ។ កាលព្រះយោគីនោះ ពិចារណារឿយៗ យ៉ាងនេះ កាលធ្វើឲ្យទៅជានិមិត្តដែលសេចក្តីត្រិះរិះស្ទួយឡើងហើយ ឲ្យជានិមិត្តដែលសេចក្តីនឹកត្រិះរិះស្ទួយឡើងហើយ, នីវរណធម៌ទាំងឡាយ រមែងស្ងប់រម្ងាប់បាន សតិ រមែងតាំងនៅស៊ប់ ចិត្ត ក៏រមែងតាំងនៅមាំ ដោយឧបចារៈ។ ព្រះយោគីនោះសេព ចំរើន ធ្វើឲ្យច្រើននូវនិមិត្តនោះរឿយៗ។ កាលព្រះយោគាវចរនោះ ពិចារណា ធ្វើទុកក្នុងចិត្ត រឿយៗ យ៉ាងនេះ, អាកាសានញ្ចាយតនចិត្ត រមែងអែបស៊ប់ ឮដ៏អាកាស ដូចជារូបាវចរចិត្ត

អែបស៊ប់ ក្នុងកសិណទាំងឡាយមានបឋវីកសិណជាដើម ។ មែនពិត សូម្បីក្នុងអាកាសានញ្ចាយតនឈាននេះ ជវនទាំងឡាយបី ឬ បួន ក្នុងចំណែកខាងដើម ជាកាមាវចរ សម្បយុត្តដោយឧបេក្ខាវេទនាហ្នឹងឯង ។ ជវន ទី ៤ ឬ ជវន ទី ៥ ជាអរូបាវចរ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយ ក្នុងបឋវីកសិណហ្នឹងឯង ។

(សេចក្តីផ្សេងគ្នាក្នុងអាកាសានញ្ចាយតនៈ)

ចំណែកសេចក្តីផ្សេងគ្នា ដូចតទៅនេះ ។ កាលបើអរូបាវចរចិត្តកើតឡើងហើយ យ៉ាងនេះ, ភិក្ខុនោះ កាលសំឡឹងមើលនូវមណ្ឌល នៃកសិណ ដោយឈានចក្ខុ ក្នុងកាលមុន នៅហើយ, កាលបើនិមិត្តនោះត្រូវការធ្វើទុកក្នុងចិត្តនូវបរិកម្ម ថា “អាកាស អាកាស” នេះ នាំចេញហើយ ដោយរហ័ស, ក៏នៅសំឡឹងមើលនូវអាកាសហ្នឹងឯង ប្រៀបដូចជាបុរសអ្នកចងនូវមាត់ណាមួយ ក្នុងចំណោមមាត់ទាំងឡាយ មានមាត់យាន មាត់ពាងតូច និង មាត់ឆ្នាំងជាដើម ដោយកំណាត់សំពត់ពណ៌ខៀវ ឬ ដោយកំណាត់សំពត់ពណ៌ឯណាមួយ បណ្តាពណ៌ទាំងឡាយ មានពណ៌លឿង ពណ៌ក្រហម និង ពណ៌-ស ជាដើម ហើយសំឡឹងមើល, កាលបើកំណាត់សំពត់ ត្រូវកំឡាំងខ្យល់ ឬ ត្រូវវត្ថុណានីមួយនាំយកទៅហើយ ឈ្មោះថា ឈរសំឡឹងមើលនូវអាកាសហ្នឹងឯង យ៉ាងដូច្នោះឯង ។

ក៏ភិក្ខុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា “ចូលទៅសំរេចដល់អាកាសានញ្ចាយតនៈ ហើយនៅ ដោយធ្វើទុកក្នុងចិត្តថា : អាកាស អាកាស ដូច្នេះ ព្រោះកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះដល់នូវការតាំងនៅមិនបាន នៃបដិឃសញ្ញា ដោយប្រការទាំងពួង ព្រោះ

មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង " ដូច្នេះ ។

(គែសព្វសោ)

ក្នុងបាឋៈទាំងនោះ បទថា "សព្វសោ" គឺដោយអាការទាំងពួង។ សេចក្តីថា "ទាំងអស់ ឬ មិនមានសេសសល់" ។

(គែរូបសញ្ញានំ)

បទថា "រូបសញ្ញានំ" បានដល់នូវរូបាវចរឈានដែលបានពោលហើយ ដោយប្រធានគឺសញ្ញាផង និង នូវអារម្មណ៍របស់រូបាវចរឈាននោះផង ។ មែនពិតសូម្បីរូបាវចរឈាន ក៏ព្រះមានព្រះភាគទ្រង់ត្រាស់ថា រូប (ដូច) ក្នុងបាឡីទាំងឡាយមានជាអាទិ៍ថា "បុគ្គលបាននូវរូបជ្ឈានរមែងឃើញនូវរូបទាំងឡាយ [១] (មាននីលកសិណជាដើម)" ដូច្នេះ, សូម្បីអារម្មណ៍ របស់រូបាវចរឈាននោះ ក៏ព្រះមានព្រះភាគទ្រង់ត្រាស់ថា រូប (ដូច) ក្នុងបាឡីទាំងឡាយថា "បុគ្គលពួកខ្លះ ឃើញនូវពួករូបខាងក្រៅ ដែលមានពណ៌ល្អ និង ពណ៌អាក្រក់ [២] " ដូច្នេះជាដើម ។

ព្រោះហេតុនោះ ក្នុងទីនេះ ពាក្យនេះថា "សេចក្តីសំគាល់ក្នុងរូប ឈ្មោះថា រូបសញ្ញា" ដូច្នេះ គប្បីជ្រាបថា ជាឈ្មោះ នៃរូបាវចរឈាន ដែលលោកបានពោលហើយដោយយកសញ្ញាជាប្រធាន យ៉ាងនេះឯង។ រូប ជាសញ្ញានៃអារម្មណ៍នោះ ព្រោះហេតុនោះ អារម្មណ៍នោះ ឈ្មោះថា រូបសញ្ញា ។ អធិប្បាយថា "រូប ជាឈ្មោះ នៃឈាននោះ" ។ ក៏បណ្ឌិតគប្បីជ្រាបថា ពាក្យនោះ ជាឈ្មោះ នៃអារម្មណ៍ នៃរូបាវចរឈាននោះផ្សេងដោយកសិណ មានបឋវីកសិណជាដើម យ៉ាងនេះឯង ។

(គែសមតិក្កមា)

១- ២- សុ. ម. ម. ភាគទី ២៨ ទំព័រទី ១៦៣-១៦៤ ។

បទថា "សមតិក្កមា" សេចក្តីថា ព្រោះប្រាសចាកតម្រេក និង ព្រោះរលត់ ។ សួរថា "មានអធិប្បាយដូចម្តេច ? " ។ ឆ្លើយថា "ព្រោះប្រាសចាកតម្រេក និង ព្រោះរលត់ គឺព្រោះហេតុនៃការប្រាសចាករាគៈ និង ព្រោះហេតុនៃការរលត់ នូវរូបសញ្ញា ពោលគឺឈាន ១៥ ដោយអំណាចនៃកុសល វិបាក និង កិរិយាទាំងនោះ និង នូវរូបសញ្ញា ពោលគឺអារម្មណ៍ ៩ ទាំងនោះ ដោយអំណាចនៃកសិណ មានបឋវីកសិណជាដើម ដោយអាការៈទាំងពួង ឬ មិនមានសេសសល់ ទើបចូលទៅសំរេចដល់អាកាសានញ្ចាយតនៈហើយនៅ ។ ព្រោះថា ព្រះយោគីដែលមានរូបសញ្ញាមិនទាន់បានកន្លងហើយ ដោយប្រការទាំងពួង ក៏មិនអាចដើម្បីចូលទៅសំរេចដល់អាកាសានញ្ចាយតនៈនោះហើយនៅបានទេ" ។ ការប្រព្រឹត្តិកន្លងនូវសញ្ញា មិនមានដល់ព្រះយោគីអ្នកមិនទាន់ប្រាសចាករាគៈហើយក្នុងអារម្មណ៍ ក្នុងអាកាសានញ្ចាយតនៈនោះ ប៉ុន្តែ កាលបើសញ្ញាទាំងឡាយប្រព្រឹត្តកន្លងទៅហើយ, អារម្មណ៍ ក៏ជាធម្មជាតប្រព្រឹត្តកន្លងទៅហើយដូចគ្នាដែរ ព្រោះហេតុណា, ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគ មិនទ្រង់ត្រាស់ហើយ នូវការប្រព្រឹត្តិកន្លង នូវអារម្មណ៍ក្នុងអាកាសានញ្ចាយតនៈនោះទេ ទ្រង់ត្រាស់តែការប្រព្រឹត្តិកន្លង នូវសញ្ញាប៉ុណ្ណោះ ក្នុងវិភង្គ យ៉ាងនេះថា "បណ្តាសញ្ញាទាំងនោះ រូបសញ្ញាតើដូចម្តេច? ការសំគាល់ អាការសំគាល់ ភាពនៃការសំគាល់ ណា របស់បុគ្គលអ្នកចូលកាន់រូបាវចរសមាបត្តិក្តី របស់បុគ្គលអ្នកប្រកប (ដោយរូបាវចរសមាបត្តិ) ក្តី របស់បុគ្គលអ្នកនៅជាសុខ ក្នុងបច្ចុប្បន្ន (ដោយរូបាវចរសមាបត្តិ)ក្តី, នេះ ហៅថា រូបសញ្ញា, បុគ្គលជាអ្នកកន្លងប្រព្រឹត្តកន្លង ឈានកន្លង នូវរូបសញ្ញាទាំងនេះ ព្រោះហេតុនោះ ទើប

ពោលថា "ព្រោះកន្លងនូវរូបសញ្ញា ដោយសព្វគ្រប់ [១] " ។

ប៉ុន្តែ (អរូបាវចរ) សមាបត្តិទាំងឡាយនុ៎ះ គឺព្រះយោគីគប្បីបាន សំរេច ដោយការប្រព្រឹត្តិកន្លងនូវអារម្មណ៍ មិនដូចជារូបាវចរឈានទាំង ឡាយមានបឋមជ្ឈានជាដើម គឺព្រះយោគីគប្បីបានសំរេច ក្នុងអារម្មណ៍ តែមួយប៉ុណ្ណោះ ព្រោះហេតុណា, ព្រោះហេតុនោះ សេចក្តីពណ៌នានេះ បណ្ឌិតគប្បីជ្រាបថា "គឺលោកធ្វើហើយ ដោយអំណាចនៃការប្រព្រឹត្តិ កន្លងនូវអារម្មណ៍ហ្នឹងឯង" ។

(កែបដិឃសញ្ញានំ អត្ថង្គមា)

ពីរបទថា "បដិឃសញ្ញានំ អត្ថង្គមា" សេចក្តីថា ការសំគាល់ ដែលកើតឡើងព្រមហើយ ព្រោះកិរិយាប៉ះនូវវត្ថុទាំងឡាយ មានចក្ខុ ជា ដើម និងនូវអារម្មណ៍ទាំងឡាយមានរូបជាដើម ឈ្មោះថាបដិឃសញ្ញា ។ ពាក្យថា បដិឃសញ្ញានុ៎ះ ជាឈ្មោះ នៃសញ្ញាទាំងឡាយ មានរូបសញ្ញា ជាដើម ។ សមដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ថា "បណ្តាសញ្ញាទាំង នោះ បដិឃសញ្ញា តើដូចម្តេច? គឺ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា សញ្ញាទាំងនេះ ហៅថា បដិឃសញ្ញា [២] " ។

(ព្រះយោគីចូលដល់អាកាសានញ្ចាយតនជ្ឈាន) ព្រោះដល់នូវ ការតាំងនៅមិនបាន គឺព្រោះលះបង់ ព្រោះមិនកើតឡើងព្រម អធិប្បាយ ថា ព្រោះធ្វើមិនឲ្យប្រព្រឹត្តទៅ នៃបដិឃសញ្ញាទាំង ១០ នោះ ដោយ ប្រការទាំងពួង ដូច្នេះគឺ បដិឃសញ្ញាទាំងឡាយ ៥ ជាកុសលវិបាក បដិឃសញ្ញាទាំងឡាយ ៥ ជាអកុសលវិបាក ។

បដិឃសញ្ញាទាំងឡាយនោះ មិនមាន សូម្បីដល់ព្រះយោគាវចរ

១- ២- អភិ. វិ. ភាគទី ៨១ ទំព័រទី ២៨៦ ។

អ្នកចូលរូបាវចរជ្ឈាន មានបឋមជ្ឈានជាដើម ព្រោះថា ក្នុងសម័យនោះ ចិត្ត រមែងមិនប្រព្រឹត្តទៅ ដោយអំណាចនៃបញ្ចទ្វារ ក៏ពិតមែន, កាល បើមានប្រការដូច្នេះ ការពោលនូវបដិឃសញ្ញាទាំងឡាយនុ៎ះ ក្នុងអាកា- សានញ្ចាយតនកថានេះ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃការពោល សរសើរនូវឈាននេះ ដើម្បីញ៉ាំងសេចក្តីឧស្សាហ៍ឲ្យកើតឡើង ក្នុងឈាន នេះ ដូចជាការពោលនូវសុខ និង ទុក្ខ ទាំងឡាយ ដែលព្រះយោគីលះ បង់បានហើយ ក្នុងឈានដទៃ ក្នុងចតុត្ថជ្ឈាន និង ដូចជាការពោល នូវ ទិដ្ឋិទាំងឡាយមានសក្កាយទិដ្ឋិជាដើម ដែលព្រះយោគីលះបង់បានហើយ ក្នុងមគ្គដទៃ ក្នុងតតិយមគ្គ ។ មួយទៀត សញ្ញាទាំងឡាយនោះ មិនមាន សូម្បីដល់ព្រះយោគីអ្នកចូលកាន់រូបាវចរជ្ឈានហើយ ក៏ពិតមែន តែបើ ទុកជាដូច្នោះ សញ្ញាទាំងឡាយនោះ រមែងមិនមាន ព្រោះភាវៈនៃសញ្ញា ទាំងនោះ គឺព្រះយោគីលះបង់បានហើយ ក៏ទេដែរ ។ ព្រោះថា ការចំរើន រូបាវចរជ្ឈាន មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេកក្នុងរូប ។ ចំណែក ការប្រព្រឹត្តិទៅ នៃរូបាវចរភាវនាទាំងឡាយនុ៎ះ ជាធម្មជាតិជិតតាមរូប ។ ចំណែក ភាវនានេះ ប្រព្រឹត្តទៅ ដើម្បីប្រាសចាករាគៈក្នុងរូប ។ ព្រោះ ហេតុនោះ ទីងពោលថា "បដិឃសញ្ញាទាំងឡាយនោះ គឺព្រះយោគីលះ បង់បានហើយ ក្នុងអារូបទី១ នេះ" ដូច្នេះ ក៏គួរ និង មិនមែនត្រឹមតែ ពោលប៉ុណ្ណោះឡើយ សូម្បីទ្រទ្រង់សេចក្តីទុក យ៉ាងនេះ ដោយចំណែក មួយហ្នឹងឯង ក៏គួរដែរ ។ ក៏ព្រោះបដិឃសញ្ញាទាំងឡាយនោះ គឺព្រះ យោគីលះមិនទាន់បាន ក្នុងឈានមុន អំពីឈាននេះនោះឯង ព្រះមាន ព្រះភាគត្រាស់ថា "សំឡេង ជាបន្លា របស់អ្នកចូលបឋមជ្ឈាន [១] " ។

១- សុ. អំ. ទ. ភាទី ៥០ ទំព័រទី ២៩៥ ។

ចំណែកក្នុងអារូប្បជ្ឈាននេះ អារូបសមាបត្តិទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថាជាគុណជាតមិនញាប់ញ័រ និង ជាគុណជាតរូបស្រឡះហើយដោយសេចក្ដីស្ងប់ ព្រោះភាវៈនៃបដិឃសញ្ញាទាំងនោះ គឺព្រះយោគីលះបង់បានហើយ មែនពិត ។ ដូចអាឡារតាបសកាលាមគោត្រចូលអារូបសមាបត្តិ មិនបានឃើញរទេះចំនួន ៥០០ ដែលឆ្លងកាត់ទៅហើយនៅក្បែរ ៗ និង មិនឮទាំងសំឡេងរទេះនោះទៀតផង ដូច្នេះឯង ។

(នានត្តសញ្ញានំ អមនសិការា)

ពីរបទថា "នានត្តសញ្ញានំ អមនសិការា" សេចក្ដីថា ព្រោះមិនធ្វើទុកក្នុងចិត្តនូវសញ្ញាទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍មានភាពផ្សេងៗ ឬ នូវសញ្ញាទាំងឡាយដែលមានសភាពផ្សេងៗ ។ មែនពិតសញ្ញាទាំងនោះ គឺព្រះមានព្រះភាគទ្រង់ត្រាស់វែកញែកហើយ ក្នុងវិភង្គយ៉ាងនេះថា "បណ្ដាសញ្ញាទាំងនោះ នានត្តសញ្ញា តើដូចម្ដេច? សេចក្ដីសំគាល់ អាការសំគាល់ ភាពនៃការសំគាល់ ណា របស់បុគ្គលអ្នកមិនបានចូលកាន់ (រូបសមាបត្តិ) ជាអ្នកព្រមព្រៀង ដោយមនោធាតុក្ដីជាអ្នកព្រមព្រៀងដោយមនោវិញ្ញាណធាតុក្ដី នេះហៅថា នានត្តសញ្ញា [1] " ដូច្នេះ, សញ្ញា ដែលព្រះមានព្រះភាគ ទ្រង់បំណងយកហើយ ក្នុងទីនេះ ជាសញ្ញាសង្គ្រោះចូលក្នុងមនោធាតុ ឬ មនោវិញ្ញាណធាតុ នៃព្រះយោគីអ្នកមិនបានចូលសមាបត្តិ រមែងប្រព្រឹត្តទៅ ក្នុងអារម្មណ៍ដែលមានភាពផ្សេងៗ គឺមានសភាពផ្សេងៗ ដែលផ្សេងគ្នា ដោយរូប និងសំឡេងជាដើម ព្រោះហេតុណា, មួយទៀត សូម្បីសញ្ញាទាំង ៤៤ នេះយ៉ាងនេះ គឺ៖ សញ្ញា ជាកាមាវចរកុសល ៨ សញ្ញា ជាអកុសល ១២

១- អភិ. វិ. ភាគទី ៨១ ទំព័រទី ២៨៧ ។

សញ្ញា ជាកាមាវចរកុសល ១១ សញ្ញា ជាអកុសលវិបាក ២ សញ្ញា ជាកាមាវចរកិរិយា ១១ ជាសញ្ញាមានភាពផ្សេងៗ គឺមានសភាពផ្សេងៗ មិនស្មើគ្នានឹងគ្នាទេ ព្រោះហេតុណា, ព្រោះហេតុនោះ សញ្ញាទាំងនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា "នានត្តសញ្ញា" ។ ព្រោះមិនធ្វើទុកក្នុងចិត្ត គឺព្រោះមិននឹកនា ព្រោះមិនទទួចនឹក ព្រោះមិនពិចារណា នូវនានត្តសញ្ញាទាំងឡាយនោះ ដោយប្រការទាំងពួង ។ អធិប្បាយថា "ព្រះយោគី មិននឹកនា មិនធ្វើទុកក្នុងចិត្ត មិនពិចារណា នូវសញ្ញាទាំងនោះ ព្រោះហេតុណា, ព្រោះហេតុនោះ (ព្រះយោគីនោះ ចូលទៅសំរេចឈាននេះ ហើយនៅ)" ។

(សេចក្ដីផ្សេងនៃបាឋៈ)

មួយទៀត បណ្ឌិតគប្បីជ្រាបថា : ក្នុងសញ្ញាទាំងនោះ រូបសញ្ញា និង បដិឃសញ្ញា មានក្នុងកាលមុន រមែងមិនមាន សូម្បីក្នុងភព ដែលកើតហើយ ដោយឈាននេះមែនពិត ចាំបាច់និយាយថ្វី ក្នុងកាលជាទីចូលទៅសំរេចនូវឈាននេះ ហើយនៅ ក្នុងភពនោះ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ការមិនមានមែនពិតនៃរូបសញ្ញា និង បដិឃសញ្ញាទាំងនោះ ជា ២ ផ្នែក ថា "ព្រោះប្រព្រឹត្តកន្លង ព្រោះដល់នូវការតាំងនៅមិនបាន" ដូច្នេះ ។ ប៉ុន្តែក្នុងនានត្តសញ្ញាទាំងឡាយ សញ្ញាទាំងឡាយ ២៧ នេះ គឺ៖ សញ្ញា ជាកាមាវចរកុសល ៨ សញ្ញា ជាកិរិយា ៩ សញ្ញា ជាអកុសល ១០ រមែងមាន ក្នុងភពដែលកើតហើយ ដោយឈាននេះ ព្រោះហេតុណា, ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាទាំងនោះ" ដូច្នេះឯង ។ មែនពិតសូម្បីក្នុងភពនោះ

ព្រះយោគី កាលចូលទៅសំរេចនូវឈាននេះ ឈ្មោះថា ចូលទៅសំរេចហើយនៅ ព្រោះមិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញាទាំងនោះហ្នឹងឯង ។ តែព្រះយោគី កាលធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាទាំងនោះ ឈ្មោះថា ជាអ្នកមិនបានចូលឈានទេ ។

(សេចក្តីដោយសង្ខេប)

ប៉ុន្តែបណ្ឌិតគប្បីជ្រាប សេចក្តីអធិប្បាយ ដោយសង្ខេប ក្នុងបទទាំងនោះ ថា : ព្រះមានព្រះភាគ ទ្រង់ត្រាស់ នូវការលះនូវកាមាវចរធម៌ទាំងពួងទាំងឡាយ ដោយបទនេះថា "ព្រោះប្រព្រឹត្តកន្លង នូវរូបសញ្ញាទាំងឡាយ" ដូច្នេះ, ទ្រង់ត្រាស់ការលះ និង ការមិនធ្វើទុកក្នុងចិត្តនូវចិត្ត និង ចេតសិក ដែលជាកាមាវចរទាំងឡាយទាំងពួង ដោយបទនេះ ថា "ព្រោះដល់នូវការតាំងនៅមិនបាន នៃបដិឃសញ្ញាទាំងឡាយ ព្រោះមិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញាទាំងឡាយ" ដូច្នេះ ។

(អនន្តោ អាកាសោ)

ក្នុងបាឋៈថា "អាកាសមិនមានទីបំផុត" នេះ មានវិនិច្ឆ័យដូចតទៅនេះ ។ ទីបំផុតនៃការកើតឡើងក្តី ទីបំផុតនៃការសាបសូន្យទៅក្តី មិនមានប្រាកដ ដល់អាកាសនោះ ព្រោះហេតុនោះ អាកាសនោះ ឈ្មោះថា មិនមានទីបំផុត ។ អាកាសជាទីបើកនូវកសិណលោកហៅថាអាកាស ។ មួយទៀត បណ្ឌិតគប្បីជ្រាបភាវៈនៃទីមិនមានទីបំផុត ក្នុងអាកាសនោះ ដោយអំណាចនៃការធ្វើទុកក្នុងចិត្តក៏បាន ។ ព្រោះហេតុដូច្នេះឯង បានជាព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងវិភង្គ ថា "ភិក្ខុតំកល់ តាំងទុកនូវចិត្ត ក្នុងអាកាសនោះ ផ្សាយទៅកាន់ទីដែលមិនមានទីបំផុត ព្រោះហេតុនោះ ទើបពោលថា អាកាសមិនមានទីបំផុត" ដូច្នេះ ។

(អាកាសានញ្ចាយតនំ)

ចំណែកក្នុងបាឋៈនេះថា "ចូលកាន់អាកាសានញ្ចាយតនៈសំរេចឥរិយាបថ" មានអត្ថវិគ្រោះថា ទីបំផុតនៃអាកាសនោះ មិនមាន ព្រោះហេតុនោះ អាកាសនោះ ឈ្មោះថា មិនមានទីបំផុត ។ អាកាស មិនមានទីបំផុត ឈ្មោះថាអាកាសមិនមានទីបំផុត ។ អាកាសមិនមានទីបំផុតហ្នឹងឯង ឈ្មោះថាអាកាសានញ្ចៈ(អាកាសមិនមានទីបំផុត) ។ អាកាសានញ្ចនោះ (អាកាសមិនមានទីបំផុតនោះ) ឈ្មោះថា អាយតនៈ (ជាទីនៅអាស្រ័យ) ដោយអត្ថថា ជាទីនៅអាស្រ័យនៃឈាននេះ ដែលប្រកបដោយសម្បយុត្តធម៌ ដូចពាក្យថា "ទីជាទីនៅនៃទេវតាទាំងឡាយ" ដូច្នេះ ព្រោះហេតុនោះ ឈាននោះ ទើបបានឈ្មោះថា អាកាសានញ្ចាយតនៈ (ឈានមានអាកាសមិនមានទីបំផុតជាទីនៅអាស្រ័យ) ។ ពាក្យថា "ចូលកាន់...នៅ" សេចក្តីថា ព្រះយោគីនោះ ដល់នូវអាកាសានញ្ចាយតនៈនោះហើយ គឺញ៉ាំងអាកាសានញ្ចាយតនៈនោះឲ្យសំរេចហើយនៅ ដោយធម៌ជាគ្រឿងនៅ ដោយឥរិយាបថដ៏សមគួរ ដល់ឈាននោះ ។

នេះជាកថាដោយពិស្តារ ក្នុងអាកាសានញ្ចាយតនកម្មដ្ឋាន ។

(វិញ្ញាណញ្ចាយតនៈ)

(១៩៧) ចំណែកឯព្រះយោគី អ្នកប្រាថ្នាដើម្បីចំរើននូវវិញ្ញាណញ្ចាយតនៈ គប្បីជាអ្នកមានការស្ទាត់ប្រព្រឹត្តហើយ ក្នុងអាកាសានញ្ចាយតនសមាបត្តិ ដោយអាការៈទាំងឡាយ ៥ ឃើញនូវទោស ក្នុងអាកាសានញ្ចាយតនៈថា "សមាបត្តិនេះ ជាសត្រូវដល់រូបាវចរជ្ឈាន ដ៏ជិត និង ជាគុណជាតដ៏ល្អិត ដូចជាវិញ្ញាណញ្ចាយតនៈ ក៏ទេដែរ" ដូច្នេះហើយ គ្របសង្កត់នូវសេចក្តីពេញចិត្ត ក្នុងអាកាសានញ្ចាយតនៈនោះ

ហើយ ធ្វើទុកក្នុងចិត្តនូវវិញ្ញាណញ្ចាយតនៈ ដោយថាជាគុណជាតដ៏ល្អិត គប្បីរំពឹងមើលនូវវិញ្ញាណដែលប្រព្រឹត្តទៅ ផ្សាយទៅកាន់អាកាសនោះ ហើយ គប្បីធ្វើទុកក្នុងចិត្ត ពិចារណាជារឿយៗ ថា "វិញ្ញាណ វិញ្ញាណ" ដូច្នេះហើយ គប្បីធ្វើឲ្យជាធម្មជាតគឺសេចក្តីត្រិះរិះស្ទួយឡើងហើយ ឲ្យជាធម្មជាត គឺសេចក្តីគិតរិះរក ស្ទួយឡើងហើយ ។

ប៉ុន្តែ មិនត្រូវធ្វើទុកក្នុងចិត្តថា "មិនមានទីបំផុត មិនមានទីបំផុត" ដូច្នេះទេ ។ កាលព្រះយោគីនោះញុំាងចិត្តឲ្យប្រព្រឹត្តទៅរឿយៗ ក្នុងនិមិត្តនោះ យ៉ាងនេះ, នីវរណៈទាំងឡាយ ក៏រមែងស្ងប់រម្ងាប់ សតិ តែងតាំងនៅស៊ប់ ចិត្ត រមែងតាំងនៅមាំ ដោយឧបចារៈ ។ ព្រះយោគីនោះ សេព ចំរើន ធ្វើឲ្យច្រើនរឿយៗ នូវនិមិត្តនោះ ។ កាលព្រះយោគីនោះ ធ្វើយ៉ាងនេះ វិញ្ញាណញ្ចាយតនចិត្ត រមែងអែបជិត (ជាអប្បនា) ក្នុងវិញ្ញាណដែលផ្សាយទៅកាន់អាកាស ដូចជាអាកាសានញ្ចាយតនចិត្ត អែបជិតក្នុងអាកាស ដូច្នោះឯង ។

ចំណែកន័យនៃអប្បនា ក្នុងវិញ្ញាណញ្ចាយតនៈនេះ បណ្ឌិតគប្បីជ្រាប តាមន័យដែលពោលហើយ (ក្នុងអាកាសានញ្ចាយតនៈនុ៎ះ) ចុះ ។

ក៏ដោយភាវនានុក្រម មានប្រមាណប៉ុណ្ណេះ ព្រះយោគីនោះ គឺព្រះមានព្រះភាគ ត្រាស់ហៅថា "ប្រព្រឹត្តកន្លងនូវអាកាសានញ្ចាយតនៈ ដោយប្រការទាំងពួង ហើយធ្វើទុកក្នុងចិត្ត ថា "វិញ្ញាណមិនមានទីបំផុត" ដូច្នេះហើយចូលកាន់វិញ្ញាណញ្ចាយតនៈ សំរេចឥរិយាបថ" ដូច្នេះឯង ។

(កែអត្ថក្នុងវិញ្ញាណញ្ចាយតនៈ)

ក្នុងបទទាំងនោះ បទថា "ដោយប្រការទាំងពួង" នេះមានន័យដូចយើងបានពោលមកហើយហ្នឹងឯង ។ ចំណែកក្នុងពាក្យថា "ប្រព្រឹត្ត

កន្លងនូវអាកាសានញ្ចាយតនៈ" នេះ មានអធិប្បាយថា សូម្បីឈាន ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ សូម្បីអារម្មណ៍ ក៏ឈ្មោះថា អាកាសា-នញ្ចាយតនៈ តាមន័យដែលពោលហើយក្នុងកាលមុន ។ ពិតមែនហើយ សូម្បីអារម្មណ៍ ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ ព្រោះអត្ថវិគ្រោះថា "អាកាសមិនមានទីបំផុតផង អាកាសានញ្ចៈនោះ ឈ្មោះថា អាយតនៈ (ទីនៅអាស្រ័យ) ព្រោះអត្ថថាជាទីនៅអាស្រ័យ ដូចជា ទេវាយតនៈ (ទីនៅអាស្រ័យ) របស់ពួកទេវតា ព្រោះអាកាសានញ្ចាយតនៈនោះ ជាអារម្មណ៍របស់អារូបជ្ឈាន ទី១ ផង" ដូច្នេះ តាមន័យមុននុ៎ះឯង ។ ន័យមួយទៀត អារម្មណ៍ ឈ្មោះថា អាកាសានញ្ចាយតនៈ ព្រោះអត្ថវិគ្រោះថា "អាកាសានញ្ចៈផង អាកាសានញ្ចៈនោះ ឈ្មោះថា អាយតនៈ(ជាទីកើត) ដោយសេចក្តីថា ជាទីកំណើត ដូចពាក្យថា "វជ្ជ កម្ពោជា ជាអាយតនៈ(ជាទីកំណើត) នៃសេះទាំងឡាយ" ដូច្នេះជាដើម ព្រោះអាកា-សានញ្ចាយតនៈនោះ ជាទីដើមកំណើត របស់ឈាននោះផង" ដូច្នេះខ្លះក៏បានដែរ ។ ព្រោះវិញ្ញាណញ្ចាយតនៈនេះ ព្រះយោគី ត្រូវប្រព្រឹត្តកន្លងទាំង ២ យ៉ាងនោះ គឺទាំងឈាន ទាំងអារម្មណ៍ យ៉ាងនេះឯង ដោយធ្វើមិនឲ្យប្រព្រឹត្តទៅ និង ដោយមិនធ្វើទុកក្នុងចិត្ត ប៉ុណ្ណោះ ទើបចូលកាន់វិញ្ញាណញ្ចាយតនៈនេះហើយសម្រេចឥរិយាបថ ព្រោះហេតុណា, ព្រោះហេតុនោះ ពាក្យថា "កន្លងនូវអាកាសានញ្ចាយតនៈ" នេះ បណ្ឌិតគប្បីជ្រាបថា "លោកពោលហើយ ធ្វើនូវឈាន និង អារម្មណ៍ទាំង ២ យ៉ាងនោះ ចូលជាមួយគ្នា" ដូច្នេះ ។

ត្រង់ពាក្យថា "**អនន្តំ វិញ្ញាណំ**" អធិប្បាយថា ព្រះយោគីធ្វើទុកក្នុងចិត្តនូវវិញ្ញាណដែលប្រព្រឹត្តផ្សាយទៅ យ៉ាងនេះថា អាកាសមិនមាន

ទីបំផុត ដូច្នេះនោះឯង ថា “វិញ្ញាណ មិនមានទីបំផុត” ដូច្នេះ ។ ន័យមួយទៀត វិញ្ញាណនោះ មិនមានទីបំផុត ដោយអំណាចនៃការធ្វើទុកក្នុងចិត្ត ។ មែនពិត ព្រះយោគីនោះ កាលធ្វើទុកក្នុងចិត្តនូវវិញ្ញាណដែលមានអាកាសជាអារម្មណ៍នោះ ដោយមិនមានសេសសល់ ឈ្មោះថា ធ្វើទុកក្នុងចិត្តថា “វិញ្ញាណមិនមានទីបំផុត” ដូច្នេះ ។ សូម្បីពាក្យណាដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ក្នុងវិភង្គថា: ត្រង់ពាក្យថា “វិញ្ញាណ មិនមានទីបំផុត” គឺ ភិក្ខុ ធ្វើទុកក្នុងចិត្ត ចំពោះអាកាសនោះផង ដែលពាល់ត្រូវហើយ ដោយវិញ្ញាណ ផ្សាយទៅកាន់ទីមិនមានទីបំផុត ព្រោះហេតុនោះ ទើបពោលថា “វិញ្ញាណ មិនមានទីបំផុត [១]” ដូច្នេះ, បទថា **“វិញ្ញាណេន”** *ក្នុងពាក្យនោះ បណ្ឌិតគប្បីជ្រាបថាជា តតិយាវិភត្តិ (ប្រើ) ក្នុងអត្ថ នៃទុតិយាវិភត្តិ ។ ព្រោះព្រះអដ្ឋកថាចារ្យទាំងឡាយ ពណ៌នានូវសេចក្តីនៃបទនោះ យ៉ាងនេះឯង ។ មានអធិប្បាយថា “ព្រះយោគីនោះ ផ្សាយទៅ គឺធ្វើទុកក្នុងចិត្ត នូវវិញ្ញាណដែលពាល់ត្រូវនូវអាកាសនោះឯង ដែលមិនមានទីបំផុត” ។*

ចំណែកក្នុងបទមាតិកាថា “ចូលដល់វិញ្ញាណញ្ចាយតនៈ សំរេចឥរិយាបថ” នេះ មានអត្ថវិគ្រោះថា “ទីបំផុត នៃវិញ្ញាណនោះ មិនមាន ព្រោះហេតុនោះ វិញ្ញាណនោះ ឈ្មោះថា មិនមានទីបំផុត ។ វិញ្ញាណមិនមានទីបំផុតនោះឯង ឈ្មោះថា អានញ្ចៈ ។ លោកមិនបានពោល ថា “វិញ្ញាណ ជាអានញ្ចៈ ឈ្មោះថា វិញ្ញាណានញ្ចៈ” ដូច្នេះ (តែ) ពោលថា “វិញ្ញាណញ្ចៈ” ដូច្នេះវិញ ។ នេះឯង ជាស័ព្ទផុសឡើង ក្នុងអត្ថនេះ ។ វិញ្ញាណញ្ចៈនោះ ឈ្មោះថាអាយតនៈ ដោយសេចក្តីថាជាទីនៅអាស្រ័យ

១- អភិ. វិ. ភាគទី ៨១ ទំព័រទី ២៨៨ ។

នៃឈាននោះ ដែលប្រកបព្រមហើយដោយសម្បយុត្តធម៌ ដូចពាក្យថា ទេវស្ថាន របស់ទេវតាទាំងឡាយ ព្រោះហេតុនោះ ឈាននោះ ទើបឈ្មោះថា វិញ្ញាណញ្ចាយតនៈ (ឈាន មានវិញ្ញាណ មិនមានទីបំផុត ជាទីនៅអាស្រ័យ) ។ ពាក្យដ៏សេស មានន័យដូចពណ៌នា មុនហ្នឹងឯង ។

នេះជាកថាដោយពិស្តារ ក្នុងវិញ្ញាណញ្ចាយតនកម្មដ្ឋាន ។

(អាកិញ្ចញ្ញាយតនៈ)

(១៩៨) ឯព្រះយោគីអ្នកប្រាថ្នាដើម្បីចំរើននូវអាកិញ្ចញ្ញាយតនៈ គប្បីជាអ្នកមានការប្រព្រឹត្តិស្ទាត់ ក្នុងវិញ្ញាណញ្ចាយតនសមាបត្តិ ដោយអាការៈទាំងឡាយ ៥ ហើយឃើញនូវទោស ក្នុងវិញ្ញាណញ្ចាយតនៈ ថា “សមាបត្តិនេះ មានសត្រូវគឺអាកាសានញ្ចាយតនៈដ៏ជិត និង មិនល្អិតដូចជាអាកិញ្ចញ្ញាយតនៈទេ”ដូច្នេះហើយ គ្របសង្កត់នូវសេចក្តីពេញចិត្តក្នុងវិញ្ញាណញ្ចាយតនៈនោះ ធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនៈ ដោយថា ជាធម្មជាតដ៏ល្អិត ហើយធ្វើទុកក្នុងចិត្ត នូវការមិនមាន នូវភាពសោះសូន្យ នូវអាការៈដែលទទេ នៃការដឹងក្នុងអាកាសានញ្ចាយតនៈ ដែលជាអារម្មណ៍នៃវិញ្ញាណញ្ចាយតនៈនោះឯង ។ សួរថា គប្បីធ្វើទុកក្នុងចិត្តយ៉ាងដូចម្តេច ? ។ ឆ្លើយថា មិនត្រូវធ្វើទុកក្នុងចិត្ត នូវវិញ្ញាណនោះទេ គប្បីនឹករំពឹង ធ្វើទុកក្នុងចិត្ត ពិចារណា ថា “មិនមាន មិនមាន” ឬ ថា “សោះសូន្យ សោះសូន្យ” ឬ ថា “ស្ងាត់ ស្ងាត់” ដូច្នេះ រឿយៗ គប្បីធ្វើទុកក្នុងចិត្ត ឲ្យជាធម្មជាតគឺសេចក្តីត្រិះរិះស្ទួយឡើងហើយ ឲ្យជាធម្មជាតគឺសេចក្តីរិះគិតស្ទួយឡើងហើយ ។ កាលព្រះយោគីនោះ ញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅរឿយៗ ក្នុងនិមិត្តនោះ យ៉ាងនេះ, នីវរណៈទាំងឡាយក៏រមែងស្ងប់រម្ងាប់ សតិ ក៏តាំងនៅស៊ប់ ចិត្ត រមែងតាំងនៅមាំ ដោយឧបចារៈ ។

ព្រះយោគីនោះ សេព ចំរើន ធ្វើឲ្យច្រើនរឿយៗ នូវនិមិត្តនោះ ។ កាលព្រះយោគីនោះ ធ្វើយ៉ាងនេះ, អាកិញ្ចញ្ញាយតនចិត្ត រមែងអែបជិត ក្នុងភាពសោះសូន្យ ភាពស្ងាត់ ឬ ភាពមិនមាន នៃមហគ្គតវិញ្ញាណ ដែលប្រព្រឹត្តផ្សាយទៅកាន់អាកាសនោះឯង ដូចជាវិញ្ញាណញ្ចាយតនៈ (ចិត្ត) អែបនែប ក្នុងមហគ្គតវិញ្ញាណ ដែលផ្សាយទៅកាន់អាកាស ។

ចំណែកន័យនៃអប្បនា សូម្បីក្នុងអាកិញ្ចញ្ញាយតនៈនេះ បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។ តែនេះជាន័យវិសេស ។ មែនពិត កាលបើអប្បនាចិត្តនោះ កើតឡើងហើយ, ភិក្ខុនោះ ឃើញនូវវិញ្ញាណ (សេចក្ដីដឹងច្បាស់) ដែលប្រព្រឹត្តទៅ ឰដ៏អាកាស ដោយចក្ខុគឺវិញ្ញាណញ្ចាយតនជ្ឈាន ក្នុងកាលមុន, កាលបើសេចក្ដីដឹងច្បាស់នោះ រលត់បាត់ទៅហើយ, ដោយការធ្វើទុកក្នុងចិត្តនូវបរិកម្មថា “មិនមាន មិនមាន” ដូច្នេះជាដើម ក៏ឃើញតែភាពមិនមាន ពោលគឺកិរិយាទៅប្រាសនៃសេចក្ដីដឹងច្បាស់នោះតែប៉ុណ្ណោះ សម្រេចឥរិយាបថ ប្រៀបដូចបុរសឃើញនូវភិក្ខុសង្ឃដែលប្រជុំគ្នា ដោយករណីយកិច្ចណាមួយ ក្នុងទីទាំងឡាយ មានទីមណ្ឌលជាដើម ហើយក៏ទៅក្នុងទីឯណាមួយ, ក្នុងពេលដែលចប់កិច្ចប្រជុំហ្នឹងឯង កាលបើភិក្ខុទាំងឡាយ ក្រោកឡើងហើយចៀសចេញទៅ, ក៏មកវិញ ឈរត្រង់ទ្វារ មើលនូវទីនោះទៀត ក៏ឃើញតែភាពសូន្យ ឃើញតែភាពស្ងាត់ឈឹងប៉ុណ្ណោះ, សេចក្ដីនឹកគិត បែបនេះ មិនមាន ដល់បុរសនោះ ថា “ស្លាប់ហើយ! ពួកភិក្ខុ មានប្រមាណប៉ុណ្ណោះ ធ្វើកាលកិរិយាហើយ ឬ ចៀសចេញទៅបាត់អស់ហើយ” ដូច្នេះ បើតាមពិតទៅ បុរសនោះ ឃើញនូវភាពមិនមាន ថា “ទីនេះសូន្យ ទីនេះស្ងាត់ឈឹង” តែប៉ុណ្ណោះ យ៉ាងដូច្នោះឯង ។

ក៏ដោយការនានុក្រមមានប្រមាណប៉ុណ្ណោះ ព្រះយោគីនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា “ប្រព្រឹត្តកន្លង នូវវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង ធ្វើទុកក្នុងចិត្តថា “មិនមានអ្វីតិចតួចឡើយ” ចូលកាន់អាកិញ្ចញ្ញាយតនៈ សម្រេចឥរិយាបថ” ដូច្នេះ ។

(កែអត្ថក្នុងអាកិញ្ចញ្ញាយតនៈ)

សូម្បីក្នុងទីនេះ ពាក្យថា “សព្វសោ” ក៏មានន័យដូចពណ៌នាមកហើយនោះដែរ ។ ក៏ក្នុងបទថា “វិញ្ញាណញ្ចាយតនំ” នេះឯង បានដល់ទាំងឈាន ទាំងអារម្មណ៍ ដែលជាវិញ្ញាណញ្ចាយតនៈ មានន័យដែលពោលមកហើយ ក្នុងកាលមុនដូចគ្នាដែរ ។ មែនពិត សូម្បីអារម្មណ៍ ក៏ឈ្មោះថា វិញ្ញាណញ្ចាយតនៈ ព្រោះអត្ថវិគ្រោះថា “វិញ្ញាណ មិនមានទីបំផុតផង វិញ្ញាណញ្ចៈនោះ ឈ្មោះថា អាយតនៈ ដោយសេចក្ដីថា ជាទីនៅអាស្រ័យ ដូចពាក្យថា ទេវស្ថាន (ទីនៅអាស្រ័យ) របស់ទេវតាទាំងឡាយ ព្រោះវិញ្ញាណញ្ចៈនោះ ជាអារម្មណ៍ របស់អារុប្បជ្ឈាន ទីពីរផង” ដូច្នេះ តាមន័យមុននោះឯង ។ ន័យមួយបែបទៀត អារម្មណ៍ក៏ឈ្មោះថា វិញ្ញាណញ្ចាយតនៈ ព្រោះអត្ថវិគ្រោះថា “វិញ្ញាណញ្ចៈផង វិញ្ញាណញ្ចៈនោះ ឈ្មោះថា ជាអាយតនៈដោយសេចក្ដីថាជាទីកំណើត ដូចពាក្យថា ដែនកម្ពោជា ជាអាយតនៈ (គឺទីកំណើត) របស់សេះទាំងឡាយ ដូច្នេះជាដើម ព្រោះវិញ្ញាណញ្ចៈនោះ ជាហេតុជាទីកំណើត របស់ឈាននោះដូចគ្នាដែរ” ដូច្នេះក៏បាន ។ អាកិញ្ចញ្ញាយតនៈនេះ គឺព្រះយោគីត្រូវកន្លងទាំង ២ យ៉ាងនោះ គឺទាំងឈាន ទាំងអារម្មណ៍ យ៉ាងនេះ ដោយការមិនធ្វើ (នូវវិញ្ញាណញ្ចាយតនៈនោះ) ឲ្យប្រព្រឹត្តទៅផង ដោយការមិនធ្វើទុកក្នុងចិត្ត (នូវវិញ្ញាណញ្ចាយតនៈនោះ) ផង ប៉ុណ្ណោះ ទើបចូលទៅសំរេច

សម្រាន្តនៅបាន ព្រោះហេតុណា, ព្រោះហេតុនោះ ពាក្យថា "ប្រព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនៈ" នេះ បណ្ឌិតគប្បីជ្រាបថា "លោកពោលរួមយកឈាន និង អារម្មណ៍ ទាំង ២ យ៉ាងនោះ ចូលជាមួយគ្នា" ។

ពាក្យថា "នត្ថិ កិញ្ចិ" នុ៎ះ មានអធិប្បាយថា ធ្វើទុកក្នុងចិត្តយ៉ាងនេះ ថា "មិនមាន មិនមាន" ថា "សោះសូន្យ សោះសន្យ" ថា "ស្ងាត់ ស្ងាត់" ដូច្នេះ ។ សូម្បីពាក្យណា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ក្នុងវិភង្គ ថា : ត្រង់បទថា "វត្ថុតិចតួច មិនមាន" គឺ ភិក្ខុធ្វើវិញ្ញាណនោះឯងមិនឲ្យមាន ធ្វើឲ្យប្រាសចាកទៅ ធ្វើឲ្យបាត់វិញ្ញាណនោះទៅ រមែងឃើញ ថា "វត្ថុតិចតួច មិនមាន" ព្រោះហេតុនោះ ទើបពោលថា "វត្ថុតិចតួច មិនមាន [1]" ដូច្នេះ ។ ពាក្យនោះ ហាក់ដូចជាលោកពោលហើយ នូវការពិចារណា ដោយកិរិយាអស់ទៅ ក៏ពិតមែនបើទុកជាដូច្នោះ សេចក្តីនៃពាក្យនោះ បណ្ឌិតគប្បីយល់ ដូចបានពោលមកហើយ យ៉ាងនេះឯង ។ ព្រោះថា កាលព្រះយោគី មិននឹករំពឹង មិនធ្វើទុកក្នុងចិត្ត មិនពិចារណា នូវវិញ្ញាណនោះ ធ្វើទុកក្នុងចិត្តតែភាពមិនមាន ភាពសោះសូន្យ ភាពស្ងាត់ឈឹង នៃវិញ្ញាណនោះតែម្យ៉ាងប៉ុណ្ណោះ ទើបលោកហៅថា ធ្វើមិនឲ្យមាន ធ្វើឲ្យប្រាសចាកទៅ ធ្វើឲ្យបាត់អស់ទៅ, មិនមែន ដោយប្រការដទៃឡើយ" ដូច្នេះ ។

ឯក្នុងពាក្យថា "ចូលកាន់អាកិញ្ចញ្ញាយតនៈ សម្រេចឥរិយាបថ" នេះ មានវិគ្រោះថា "អ្វីតិចតួច នៃវិញ្ញាណនោះ មិនមាន ព្រោះហេតុនោះ វិញ្ញាណនោះ ឈ្មោះថា មិនមានអ្វីតិចតួច" ។ អធិប្បាយថា "អ្វីដែលសេសសល់ នៃវិញ្ញាណនោះ ដោយទីបំផុតទៅ សូម្បីត្រឹមតែការ

១- អភិ. វិ. ភាគទី ៨១ ទំព័រទី ២៨៩ ។

រលត់ ក៏មិនមានដែរ" ។ ភាវៈ នៃអាកិញ្ចនៈ ឈ្មោះថា អាកិញ្ចញ្ញៈ ។ ពាក្យនេះ ជាឈ្មោះ នៃការប្រាសចាកនៃវិញ្ញាណ ក្នុងអាកាសានញ្ចាយតនៈ ។ អាកិញ្ចញ្ញៈនោះ ឈ្មោះថា អាយតនៈ ដោយសេចក្តីថា ជាទីនៅអាស្រ័យ នៃឈាននោះ ដូចជាពាក្យថា ទេវស្ថាន របស់ទេវតាទាំងឡាយ ព្រោះហេតុនោះ ឈាននោះ ទើបឈ្មោះថា អាកិញ្ចញ្ញាយតនៈ (ឈានមានភាពមិនមាននៃវិញ្ញាណអ្វីតិចតួចជាទីនៅអាស្រ័យ) ។ ពាក្យដ៏សេស ក៏មានសេចក្តីដូចពាក្យមុននោះដែរ ។

នេះជាកថាដោយពិស្តារ ក្នុងអាកិញ្ចញ្ញាយតនកម្មដ្ឋាន ។

(នេវសញ្ញានាសញ្ញាយតនៈ)

(១៩៩) ចំណែកព្រះយោគាវចរ អ្នកប្រាថ្នាដើម្បីចំរើន នូវនេវសញ្ញានាសញ្ញាយតនៈ គប្បីជាអ្នកមានការស្ទាត់ប្រព្រឹត្តទៅហើយ ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ដោយអាការទាំងឡាយ ៥ ឃើញនូវទោសក្នុងអាកិញ្ចញ្ញាយតនៈ យ៉ាងដូច្នេះ ថា "សមាបត្តិនេះ មានសត្រូវ គឺវិញ្ញាណញ្ចាយតនៈដ៏ជិត និង មិនល្អិត ដូចជានេវសញ្ញានាសញ្ញាយតនៈទេ" ដូច្នេះ ឬ (ឃើញ) ថា "សញ្ញា ដូចជារោគ, សញ្ញា ដូចជាបូស, សញ្ញា ដូចជាកូនសរ, ធម្មជាតនុ៎ះ ល្អិត, ធម្មជាតនុ៎ះ ប្រណីត, ធម្មជាតនុ៎ះគឺអ្វី? ធម្មជាតនុ៎ះ គឺនេវសញ្ញានាសញ្ញាយតនៈ" ដូច្នេះ និង (ឃើញ) នូវអានិសង្ស ក្នុងគុណដែលខ្ពង់ខ្ពស់ (ក្នុងអារូបជ្ឈានទី៤) ហើយគ្រប់សង្កត់នូវសេចក្តីពេញចិត្ត ក្នុងអាកិញ្ចញ្ញាយតនៈ ស្រេចហើយ ធ្វើទុកក្នុងចិត្ត នូវនេវសញ្ញានាសញ្ញាយតនៈ ដោយថាជាធម៌ដ៏ល្អិត គប្បីនឹករំពឹងនូវអាកិញ្ចញ្ញាយតនសមាបត្តិដែលធ្វើភាពមិនមានឲ្យជាអារម្មណ៍ប្រព្រឹត្តទៅនោះឯង គប្បីធ្វើទុកក្នុងចិត្ត គប្បីពិចារណា ជារឿយៗ ថា

“ល្អិត ល្អិត” ដូច្នេះ គប្បីធ្វើឲ្យជាធម្មជាត គឺសេចក្ដីត្រិះរិះសួយឡើងហើយ ឲ្យជាធម្មជាត គឺសេចក្ដីរិះគិតសួយឡើងហើយ ។ កាលព្រះយោគីនោះញុំាងចិត្តឲ្យប្រព្រឹត្តទៅ ក្នុងនិមិត្តនោះ ជារឿយៗ យ៉ាងនេះ, នីវរណៈទាំងឡាយ រមែងស្ងប់រម្ងាប់ សតិ ក៏តាំងនៅស៊ប់ ចិត្ត ក៏រមែងតាំងនៅមាំ ដោយឧបចារៈ ។ ព្រះយោគីនោះ សេព ចំរើន ធ្វើឲ្យច្រើននូវនិមិត្តនោះ រឿយៗ ។ កាលព្រះយោគីនោះ ធ្វើយ៉ាងនេះ, នេវសញ្ញា-នាសញ្ញាយតនចិត្ត រមែងអែបជិត (ជាអប្បនា) ក្នុងខន្ធទាំងឡាយ ៤ ពោលគឺអាកិញ្ចញ្ញាយតនសមាបត្តិ ដូចជាអាកិញ្ចញ្ញាយតនៈ(ចិត្ត) អែបជិត ក្នុងការទៅប្រាសនៃវិញ្ញាណ ដូច្នោះឯង ។ ចំណែកន័យនៃអប្បនា ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាប តាមន័យដែលពោលហើយនោះចុះ ។

ក៏ដោយភាវនានុក្រមមានប្រមាណប៉ុណ្ណេះ ព្រះយោគីនោះ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា “ប្រព្រឹត្តកន្លង នូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនៈ ហើយសម្រេចឥរិយាបថ” ដូច្នេះ ។

(កថាអត្ថក្នុងនេវសញ្ញានាសញ្ញាយតនៈ)

សូម្បីក្នុងទីនេះ បទថា “សព្វសោ” នេះ ក៏មានន័យដូចពោលមកហើយហ្នឹងឯង ។ សូម្បីក្នុងពាក្យថា “អាកិញ្ចញ្ញាយតនំ សមតិក្កមា” នេះ ក៏សំដៅយកទាំងឈាន ទាំងអារម្មណ៍ ដែលជាអាកិញ្ចញ្ញាយតនៈ តាមន័យដែលបានពោលមកហើយ ក្នុងកាលមុននោះឯង ។ ពិតមែនហើយ សូម្បីអារម្មណ៍ ក៏ឈ្មោះថា អាកិញ្ចញ្ញាយតនៈ ព្រោះអត្ថវិគ្រោះថា “អាកិញ្ចៈ (វិញ្ញាណ មិនមានអ្វីតិចតួច) ផង អាកិញ្ចៈនោះ ឈ្មោះថា អាយតនៈ (ទីនៅអាស្រ័យ) ដោយសេចក្ដីថា ជាទីនៅអាស្រ័យ ដូចជា

ពាក្យថា ទេវាយតនៈ របស់ទេវតាទាំងឡាយ ព្រោះអាកិញ្ចៈនោះ ជាអារម្មណ៍ របស់អារូប្បជ្ឈាន ទី ៣ ផង” ដូច្នេះ តាមន័យមុននោះឯង ។ មួយទៀត អារម្មណ៍ ឈ្មោះថា អាកិញ្ចញ្ញាយតនៈ ព្រោះអត្ថវិគ្រោះថា “អាកិញ្ចៈ ផង អាកិញ្ចៈ នោះ ឈ្មោះថា អាយតនៈ (ទីកំណើត) ដោយសេចក្ដីថា ជាទីកំណើត ដូចជាពាក្យថា “រដ្ឋ កម្ពោជា ជាអាយតនៈ (គឺទីកំណើត) របស់សេះទាំងឡាយ” ដូច្នេះជាដើម ព្រោះអាកិញ្ចៈនោះជាហេតុដើមកំណើត នៃឈាននោះឯង ផង” ដូច្នេះ ក៏បាន ។ នេវសញ្ញា-នាសញ្ញាយតនៈនេះ គឺព្រះយោគី គប្បីកន្លងទាំង ២ យ៉ាងនោះ គឺទាំងឈានទាំងអារម្មណ៍យ៉ាងនេះ ដោយធ្វើមិនឲ្យ (អាកិញ្ចញ្ញាយតនៈនោះ) ប្រព្រឹត្តទៅ និង ដោយការមិនធ្វើទុកក្នុងចិត្ត (នូវអាកិញ្ចញ្ញាយតនៈ) តែប៉ុណ្ណោះ ហើយគប្បីចូលទៅ សម្រេចឥរិយាបថបាន ព្រោះហេតុណា, ព្រោះហេតុនោះ ពាក្យថា “ប្រព្រឹត្តកន្លង នូវអាកិញ្ចញ្ញាយតនៈ” នេះ បណ្ឌិតគប្បីជ្រាបថា លោកពោលហើយ ព្រោះរួមយកទាំងឈាន និង អារម្មណ៍ ទាំង ២ យ៉ាងនុ៎ះ ចូលជាមួយគ្នា ” ដូច្នេះ ។

ចំណែកក្នុងបទថា “នេវសញ្ញានាសញ្ញាយតនំ” នេះ អធិប្បាយថា “ឈាននេះ ឈ្មោះថា នេវសញ្ញានាសញ្ញាយតនៈ ព្រោះមាន នៃសញ្ញាណា សញ្ញានោះ រមែងមាន ដល់ព្រះយោគី អ្នកប្រតិបត្តិយ៉ាងណា ក្នុងវិភង្គ ដើម្បីសំដែងនូវសេចក្ដីប្រតិបត្តិរបស់ព្រះយោគីនោះ មុនទើបលោកលើកឡើង ថា “នេវសញ្ញីនាសញ្ញី” ដូច្នេះហើយ ពោលថា “ព្រះយោគីនោះ ធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនៈនោះឯង ដោយថាជាធម៌ល្អិត ចំរើនសមាបត្តិមានសង្ខារសេសនៅ ព្រោះហេតុនោះ ទើបលោកពោលថា “នេវសញ្ញីនាសញ្ញី” ។ ក្នុងពាក្យទាំងនោះ ពាក្យថា

“ធ្វើទុកក្នុងចិត្ត ដោយថាជាធម៌ល្អិត” នោះ សេចក្តីថា ធ្វើទុកក្នុងចិត្ត នូវអាកិញ្ចាយតនៈនោះ ថា “ជាសមាបត្តិដ៏ល្អិត” ព្រោះមានអារម្មណ៍ដ៏ល្អិតយ៉ាងនេះថា “សមាបត្តិនេះ ល្អិតអ្វីម្ល៉េះទេហ្ន៎! មើលចុះ សមាបត្តិណាទៅនឹងធ្វើសូម្បីនូវភាពមិនមានឲ្យជាអារម្មណ៍ ហើយតាំងនៅបាន” ដូច្នេះ ។

បើមានពាក្យសួរថា “ព្រះយោគី ធ្វើទុកក្នុងចិត្ត ដោយថាជាធម៌ដ៏ល្អិត សេចក្តីប្រព្រឹត្តិកន្លង តែងមាន យ៉ាងដូចម្តេច?” ។ គប្បីឆ្លើយថា “សេចក្តីប្រព្រឹត្តិកន្លង តែងមាន ព្រោះភាវៈនៃព្រះយោគីនោះ ជាអ្នកមិនប្រាថ្នាដើម្បីនឹងចូល (អាកិញ្ចញ្ញាយតនៈនោះ)” ។ មែនពិត ព្រះយោគីនោះ ធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនៈនោះ ដោយថាជាធម៌ល្អិត ក៏ពិតមែនហើយ បើទុកជាដូច្នោះ ការនឹកគិត ការរួបរួមចិត្ត ការធ្វើទុកក្នុងចិត្ត ថា “អាត្មាអញ នឹងរំពឹងគិត អាត្មាអញ នឹងចូល អាត្មាអញ នឹងអធិដ្ឋាន អាត្មាអញនឹងចេញ អាត្មាអញនឹងពិចារណា នូវសមាបត្តិនុ៎ះ” ដូច្នេះនេះ មិនមានដល់ព្រះយោគីនោះទេ ។ សួរថា “ព្រោះហេតុអ្វី?” ។ ឆ្លើយថា “ព្រោះភាវៈនៃនេវសញ្ញានាសញ្ញាយតនៈ ល្អិតជាង ប្រណីតជាងអាកិញ្ចញ្ញាយតនៈ” ។ ប្រៀបឧបមាដូចជាព្រះរាជា ទ្រង់គង់លើ-កដំរីដ៏ប្រសើរ ស្តេចយាងទៅលើថ្នល់ ក្នុងព្រះនគរ ដោយព្រះរាជានុភាពដ៏ច្រើន ទ្រង់ទតព្រះនេត្រឃើញ នូវជាងអ្នកមានសិល្បៈទាំងឡាយ មានជាងធ្វាក់ភ្លុកជាដើម កំពុងតែស្លៀកសំពត់មួយ យ៉ាងណែនហើយ យកសំពត់មួយជូតក្បាល មានខ្លួនប្រឡាក់ប្រឡូស ដោយកំទេចទាំងឡាយមានកំទេចភ្លុកជាដើម ហើយធ្វើនូវសិល្បៈទាំងឡាយជាច្រើន មានរចនាភ្លុកធ្វើជារូបផ្សេងៗ ជាដើម ហើយទ្រង់ពេញព្រះទ័យ ក្នុងសេចក្តីឆ្លៀវឆ្លាតរបស់ជាងទាំងនោះ ដោយត្រាស់បញ្ជាយ៉ាងនេះថា “នែវើយ! ឱហ្ន៎!

អាចារ្យទាំងឡាយ ជាអ្នកឆ្លាតមែនទែន ធ្វើនូវសិល្បៈយ៉ាងនេះ ឥតមានទាស់ឡើយ” ដូច្នេះ តែព្រះរាជតម្រិះ យ៉ាងដូច្នេះ ថា “ឱហ្ន៎ អាត្មាអញលះបង់រាជសម្បត្តិ ហើយធ្វើជាជាងសិល្បៈបែបនេះ” ដូច្នេះ មិនមានដល់ព្រះរាជានោះទេ ។ នោះព្រោះហេតុអ្វី? ។ ព្រោះសិរីរាជសម្បត្តិមានគុណច្រើនជាង ។ ព្រះអង្គទ្រង់កន្លង នូវជាងសិល្បៈទាំងឡាយហើយ ក៏ស្តេចយាងទៅប៉ុណ្ណោះឯង យ៉ាងណាមិញ, ឯខាងព្រះយោគីនេះ ក៏យ៉ាងដូច្នោះដែរ ធ្វើទុកក្នុងចិត្តនូវសមាបត្តិនោះ ដោយថាជាធម៌ដ៏ល្អិត ក៏ពិតមែនហើយ បើទុកជាដូច្នោះ ការនឹកគិត ការរួបរួមចិត្ត ការធ្វើទុកក្នុងចិត្ត ថា “អាត្មាអញនឹងរំពឹងគិត អាត្មាអញនឹងចូល អាត្មាអញនឹងអធិដ្ឋាន អាត្មាអញនឹងចេញ អាត្មាអញនឹងពិចារណា នូវសមាបត្តិនុ៎ះ” ដូច្នេះនេះ មិនមានឡើយដល់ព្រះយោគីនោះ ។ ព្រះយោគីនោះ កាលធ្វើទុកក្នុងចិត្ត នូវសមាបត្តិនោះ ដោយថាជាធម៌ដ៏ល្អិត តាមន័យដូចបានពោលហើយ ក្នុងកាលមុនហ្នឹងឯង ទើបបានដល់នូវសញ្ញា ដែលដល់នូវអប្បនាដ៏ល្អិតសុខុមក្រៃលែងនោះ ជាសញ្ញាដែលជាហេតុឲ្យបានឈ្មោះថា នេវសញ្ញី-នាសញ្ញី លោកហៅថា “ចំរើននូវសមាបត្តិ មានសង្ខារសេសនៅ ” ។

ពាក្យថា “សង្ខារាវសេសសមាបត្តិ” គឺ អារូប្បសមាបត្តិ ៤ ដែលមានសង្ខារដល់នូវភាពសុខុមក្រៃលែង ។

(២០០) ក្នុងកាលឥឡូវនេះ ឈាននេះឯណា ដែលលោកហៅថា “នេវសញ្ញានាសញ្ញាយតនៈ” ដូច្នេះ ដោយអំណាចនៃសញ្ញា ដែលព្រះយោគីបានសម្រេចយ៉ាងនេះ ដើម្បីសំដែងនូវឈាននោះ ដោយសេចក្តីទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា : ត្រង់បទថា “នេវសញ្ញានាសញ្ញា-យតនំ” បានដល់ ពួកធម៌ គឺ ចិត្ត និង ចេតសិក របស់បុគ្គលអ្នកចូល

កាន់នេវសញ្ញានាសញ្ញាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប (ដោយនេវសញ្ញានាសញ្ញាយតនជ្ឈាន) ក្តី របស់បុគ្គលអ្នកនៅជាសុខ ក្នុងបច្ចុប្បន្ន (ដោយនេវសញ្ញានាសញ្ញាយតនជ្ឈាន)ក្តី [១] ” ដូច្នេះ ។ ក្នុងបុគ្គលទាំង ៣ ពួកនោះ ពួកធម៌ គឺចិត្ត និង ចេតសិក របស់បុគ្គលអ្នកចូលកាន់ (នេវសញ្ញានាសញ្ញាយតនជ្ឈាន) លោកអធិប្បាយហើយក្នុងអធិការនេះ ។

ឯសេចក្តីនៃពាក្យ ក្នុងពាក្យថា “នេវសញ្ញានាសញ្ញាយតនំ” នុ៎ះ បណ្ឌិតគប្បីជ្រាបថា “ឈាននោះ ដែលប្រកបព្រមដោយសម្បយុត្តធម៌ ឈ្មោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ដោយពិត ព្រោះមិនមានសញ្ញាដ៏គ្រោតគ្រាត និង ព្រោះមានតែសញ្ញាដ៏ល្អិត ព្រោះហេតុនោះ ឈាននោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញៈ (ឈានមិនមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន) ។ នេវសញ្ញានាសញ្ញៈ (ឈាន) ផង នេវសញ្ញានាសញ្ញៈ (ឈាន) នោះ ឈ្មោះថា អាយតនៈ ព្រោះរាប់បញ្ចូលក្នុងមនាយតនៈ និង ធម្មាយតនៈ ផង ព្រោះហេតុនោះ ឈាននោះ ទើបឈ្មោះថានេវសញ្ញានាសញ្ញាយតនៈ(អាយតនៈគឺឈានមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន)” ដូច្នេះ ។ មួយទៀត ក្នុងអារូប្បជ្ឈាន ទី ៤ នោះ សញ្ញានេះ ឯណា សញ្ញានោះ ឈ្មោះថា ជាសញ្ញា ក៏មិនមែនពិត ព្រោះសញ្ញានោះ មិនមានសមត្ថភាព ដើម្បីធ្វើនូវសញ្ញាកិច្ច (មុខនាទីនៃសញ្ញា) ដ៏ជាក់ស្តែងបាន ឈ្មោះថា មិនមែនជាសញ្ញា ក៏មិនមែន ព្រោះជាធម្មជាតដែលមាន ដោយភាវៈនៃសង្ខារដែលសល់នៅដ៏សុខុម ព្រោះហេតុនោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញា ។

១- អភិ. វិ. ភាគទី ៨១ ទំព័រទី ២៩១ ។

នេវសញ្ញានាសញ្ញាផង នេវសញ្ញានាសញ្ញានោះ ឈ្មោះថា អាយតនៈ ព្រោះសេចក្តីថា ជាទីនៅអាស្រ័យ របស់ធម៌ ដ៏សេសទាំងឡាយផង ព្រោះហេតុនោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញាយតនៈ ។

ក៏ក្នុងអារូប្បជ្ឈាន ទី៤ នេះ សញ្ញា ប្រាកដដូច្នេះ តែម្យ៉ាង ក៏មិនមែនដែរ ។ តាមពិតទៅ សូម្បីវេទនា ជាវេទនាក៏មិនមែន មិនមែនជាវេទនាក៏មិនមែន, សូម្បីចិត្ត ជាចិត្តក៏មិនមែន មិនមែនជាចិត្តក៏មិនមែន, សូម្បីផស្សៈ ជាផស្សៈ ក៏មិនមែន មិនមែនជាផស្សៈ ក៏មិនមែន ។ ក្នុងសម្បយុត្តធម៌ ដ៏សេសទាំងឡាយ ក៏ន័យនេះដែរ ។ ក៏ព្រះធម៌ទេសនានេះ បណ្ឌិតគប្បីជ្រាបថា “ព្រះមានព្រះភាគ ទ្រង់ធ្វើហើយ ដោយលើកយកសញ្ញាជាប្រធាន” ។ មួយទៀត សេចក្តីនេះ បណ្ឌិតគប្បីពង្រីក ឲ្យវិសេស ដោយឧបមាទាំងឡាយ តាំងអំពីរឿងប្រេងលាបបាត្រ ដូច្នេះ ។

បានឮមកថា សាមណេរ យកប្រេងលាបបាត្រហើយ ក៏តំកល់ទុក ។ ក្នុងពេលឆាន់បបរ ព្រះថេរៈ ក៏ប្រាប់ឲ្យសាមណេរនោះយកបាត្រមកប្រគេន ។ សាមណេរនោះ ទូលថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន! ក្នុងបាត្រ មានប្រេង” ។ ក្នុងពេលនោះ កាលបើព្រះថេរៈ ពោលថា “នៃសាមណេរ អ្នកចូរនាំយកមក, ខ្ញុំនឹងដាក់ត្រឡោកប្រេង ឲ្យពេញ” ដូច្នេះហើយ, សាមណេរ ក៏ទូលថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ប្រេងមិនមានទេ” ។

ក្នុងពាក្យ របស់សាមណេរនោះ ពាក្យថា “ប្រេងមាន” ដូច្នេះ ក៏ត្រូវ ដោយសេចក្តីថា (ប្រេងនោះ) មិនគួរ ជាមួយនឹងបបរទេ ព្រោះ(ប្រេង)មាននៅខាងក្នុង(បាត្រ), ពាក្យថា“មិនមាន”ក៏ត្រូវ ដោយអំណាចនៃកិច្ចការផ្សេងៗ មានការថែមត្រឡោកប្រេងជាដើម យ៉ាងណាមិញ,

សូម្បីសញ្ញានេះ ក៏យ៉ាងដូច្នោះដែរ ឈ្មោះថាសញ្ញា ក៏មិនមែនពិត ព្រោះមិនអាចដើម្បីធ្វើ នូវសញ្ញាកិច្ច ដ៏ជាក់ស្តែងបាន ឈ្មោះថា មិនមែនជាសញ្ញា ក៏មិនមែន ព្រោះជាធម្មជាតដែលមាន ដោយភាវៈនៃសង្ខារដែលសល់នៅ ដ៏សុខុម ។

សួរថា "ក៏សញ្ញាកិច្ចក្នុងពាក្យនេះគឺអ្វី?" ។ ឆ្លើយថា "សញ្ញាកិច្ចនោះ គឺការចាំបាននូវអារម្មណ៍ ១ ការចូលដល់ភាពជាវិស័យ(អារម្មណ៍) នៃវិបស្សនា ហើយញ៉ាំងសេចក្តីនឿយណាយ ឲ្យកើតឡើង ១ ។ ក៏សញ្ញានោះ សូម្បីកិច្ចគឺការចាំបាន (នូវអារម្មណ៍) ក៏មិនអាចដើម្បីធ្វើ ឲ្យជាក់ច្បាស់បាន ប្រៀបដូចជាធាតុភ្លើង ក្នុងទឹកក្តៅ មិនអាចធ្វើកិច្ចគឺការដុតឆេះបានឡើយ យ៉ាងនោះឯង ។ សូម្បីការចូលដល់ភាពជាវិស័យនៃវិបស្សនាហើយ ញ៉ាំងនិព្វិទាឲ្យកើតឡើង ដូចជាសញ្ញា ក្នុងសមាបត្តិដ៏សេសទាំងឡាយ ក៏មិនអាចដើម្បីធ្វើបានដែរ ។ ព្រោះថា ភិក្ខុជាអ្នកមិនបានធ្វើអភិនិវេស (គឺវិបស្សនា) ក្នុងខន្ធទាំងឡាយឯទៀត ហើយឈ្មោះថា ជាអ្នកអាចដើម្បីពិចារណា នូវនេវសញ្ញានាសញ្ញាយតនក្ខន្ធទាំងឡាយហើយ បានសម្រេចដល់និព្វិទា រមែងមិនមាន ។ អើមែន! ក៏មានតែព្រះសារីបុត្រដ៏មានអាយុ ឬ លោកអ្នកមានបញ្ញាច្រើន ជាអ្នកដែលពិចារណាឃើញច្បាស់តាមប្រក្រតី ដូចជាព្រះសារីបុត្រហ្នឹងឯងទើបអាច (ពិចារណានូវនេវសញ្ញានាសញ្ញាយតនខន្ធហើយធ្វើឲ្យសំរេចដល់និព្វិទាបាន) ។ សូម្បីព្រះសារីបុត្រនោះ ក៏អាច (ធ្វើបាន) ដោយអំណាចនៃការពិចារណាជាកលាប (គឺក្រុម) តែប៉ុណ្ណោះ មិនអាច (ធ្វើ) ដោយអំណាចនៃការពិចារណាឃើញធម៌ តាមលំដាប់បទបានទេ ព្រោះលោកយល់ឃើញថា "បានឮថា ធម៌ទាំងឡាយនេះ យ៉ាងដូច្នេះឯង គឺ

មិនមានក៏រមែងមាន មានហើយក៏ប្រាកដច្បាស់" ដូច្នេះ ។ សមាបត្តិនេះដល់ហើយ នូវសេចក្តីល្អិតសុខុម ដោយប្រការដូច្នេះឯង ។ មួយទៀតសេចក្តីនេះ បណ្ឌិតគប្បីធ្វើឲ្យវិសេស សូម្បីដោយឧបមាដោយទឹកលើផ្លូវ ដូចជាឧបមាដោយប្រេងលាបបាត្រ យ៉ាងនោះក៏បានដែរ ។

បានឮមកថា សាមណេរ និមន្តទៅខាងមុខព្រះថេរៈ ដែលនិមន្តលើផ្លូវ ឃើញនូវទឹកបន្តិច ក៏ទូលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ទឹកសូមព្រះគុណម្ចាស់ដោះនូវស្បែកជើងចេញ" ។ លំដាប់នោះ កាលបើព្រះថេរៈពោល ថា "នែសាមណេរ បើទឹកមាន, ចូរអ្នកនាំយកសំពត់សំរាប់ស្រង់ទឹកមក ខ្ញុំនឹងស្រង់ទឹក" ដូច្នេះ, សាមណេរ ទូលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ទឹកមិនមានទេ" ។

ក្នុងពាក្យសាមណេរនោះ ពាក្យថា "ទឹកមាន" ក៏ត្រូវ ព្រោះសេចក្តីថាត្រឹមតែទទឹកស្បែកជើង ពាក្យថា "ទឹកមិនមាន" ក៏ត្រូវ ព្រោះសេចក្តីថា(ទឹកមិនមានល្មមនឹង) ងូតបាន យ៉ាងណាមិញ, សូម្បីសញ្ញានោះ ក៏យ៉ាងដូច្នោះដែរ ឈ្មោះថា ជាសញ្ញា ក៏មិនមែន ព្រោះមិនអាចដើម្បីធ្វើនូវសញ្ញាកិច្ច ដ៏ជាក់ច្បាស់បាន ឈ្មោះថា មិនមែនជាសញ្ញា ក៏មិនមែន ព្រោះជាធម្មជាតមាន ដោយភាវៈនៃសង្ខារដែលសល់នៅ ដ៏ល្អិតសុខុម ។ ក៏សេចក្តីនេះ បណ្ឌិតគប្បីធ្វើឲ្យវិសេស ដោយឧបមាទាំងឡាយនេះឯង តែម្យ៉ាង មិនបានឡើយ គប្បីធ្វើឲ្យវិសេស ដោយឧបមាទាំងឡាយដទៃទៀត ដែលសមគួរ ក៏បានដែរ ។

ពាក្យថា "ចូលទៅកាន់...សម្រេចឥរិយាបថ" នេះ មានន័យដូចពោលមកហើយហ្នឹងឯង ។

នេះជាកថា ដោយពិស្តារ ក្នុងនេវសញ្ញានាសញ្ញាយតនកម្មដ្ឋាន ។

បកិណ្ណកកថា

(២០១) ព្រះនាថៈទ្រង់មានព្រះរូបមិនមានបុគ្គលប្រៀបផ្ទឹមស្មើបាន ទ្រង់ត្រាស់នូវអារុប្បៈ ៤ ប្រការ ឯណា, បណ្ឌិតបានជ្រាបនូវអារុប្បៈ ៤ នោះ យ៉ាងនេះហើយ ត្រូវដឹងច្បាស់បកិណ្ណកកថា ក្នុងអារុប្បៈនោះទៀតផង។

មែនពិត អារុប្បសមាបត្តិទាំងឡាយ

នេះ សូម្បីមាន ៤ ដោយការប្រព្រឹត្តិកន្លងនូវអារម្មណ៍ (តែ) អ្នកប្រាជ្ញទាំងឡាយមិនប្រាថ្នានូវការប្រព្រឹត្តិកន្លងនូវអង្គ នៃសមាបត្តិទាំងឡាយនោះទេ ។

មែនពិត អារុប្បសមាបត្តិទាំងឡាយនេះ បណ្ឌិតគប្បីជ្រាបថា សូម្បីមាន ៤ ដោយការប្រព្រឹត្តិកន្លងនូវអារម្មណ៍ ដោយប្រការទាំងពួង គឺ ក្នុងសមាបត្តិទាំង ៤ នោះ សមាបត្តិ ទី១ មាន ដោយការប្រព្រឹត្តិកន្លងនូវរូបនិមិត្ត ទី ២ ដោយការប្រព្រឹត្តិកន្លងនូវអាកាស ទី៣ ដោយការប្រព្រឹត្តិកន្លងនូវវិញ្ញាណដែលប្រព្រឹត្តទៅ ក្នុងអាកាស ទី ៤ ដោយការប្រព្រឹត្តិកន្លងនូវការទៅប្រាសនៃវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាស តែបណ្ឌិតទាំងឡាយ មិនប្រាថ្នា នូវការប្រព្រឹត្តិកន្លងនូវអង្គ នៃសមាបត្តិទាំងឡាយនោះទេ ។ ព្រោះថា ការប្រព្រឹត្តិកន្លងនូវអង្គ ក្នុងសមាបត្តិទាំងឡាយនោះ តែងមាន ដូចជាក្នុងរូបាវចរសមាបត្តិទាំងឡាយ ក៏ទេដែរ ។ ពិតមែនហើយ ក្នុងសមាបត្តិទាំងឡាយនោះ សូម្បីគ្រប់យ៉ាង មានតែអង្គឈាន ២ យ៉ាងប៉ុណ្ណោះ គឺ ឧបេក្ខា ១ ចិត្តេកគ្គតា ១ ។

សូម្បីកាលបើហេតុដូច្នោះ មានពិតមែន ។

ក្នុងអារុប្បសមាបត្តិនេះ សមាបត្តិទាំងឡាយ ខាងក្រោយៗ រមែងប្រណីតល្អជាង (សមាបត្តិដើមៗ) បណ្ឌិតគប្បីជ្រាប(រឿង) ផ្ទៃប្រាសាទ និង សំពត់ ជាឧបមា ក្នុងសេចក្តីប្រណីតល្អជាងគ្នានោះ ។

ដូចជា ពួដ៏ផ្ទៃក្រោមនៃប្រាសាទ ដែលមាន ៤ ជាន់ កាមគុណទាំងឡាយ ៥ ដែលប្រណីត ដោយអំណាចនៃការបម្រើ មានកិរិយារាំច្រៀង, ការប្រគុំដូរតន្ត្រី, គ្រឿងក្រអូប, ផ្កាកម្រង, ភោជន, ទីដេក និងគ្រឿងស្លៀកពាក់ដែលជាទិព្វជាដើម គប្បីជារបស់ដែលតាំងទុកហើយ, ក្នុងជាន់ទី ២ បញ្ចកាមគុណ ប្រណីតជាងជាន់ក្រោមនោះ, ក្នុងជាន់ទី ៣ ប្រណីតជាងជាន់ទី ២ នោះ, ក្នុងជាន់ទី ៤ ប្រណីតជាងគេទាំងអស់, ក្នុងសេចក្តីឧបមានោះ ជាន់ទាំងឡាយ ៤ នោះ គឺជាផ្ទៃប្រាសាទហ្នឹងឯង, សេចក្តីប្លែកគ្នា ដោយភាពជាផ្ទៃប្រាសាទ នៃជាន់ទាំង ៤ នោះ មិនមាន ក៏ពិតមែនហើយ ទុកជាយ៉ាងដូច្នោះ ជាន់ខាងលើៗ ជាជាន់ប្រណីតជាងជាន់ខាងក្រោម ៗ ដោយមានសេចក្តីបរិបូណ៌ នៃបញ្ចកាមគុណប្លែកគ្នាយ៉ាងណាមិញ, មួយទៀត សំពត់ ទម្ងន់៤ បលៈ, ទម្ងន់៣ បលៈ, ទម្ងន់ ២ បលៈ ទម្ងន់១ បលៈ នៃអំបោះដែលគ្រើម ម៉ត់ ម៉ត់ជាង ម៉ត់ជាងគេទាំងអស់ ដែលស្ត្រីម្នាក់រវៃហើយ គប្បីជាសំពត់ដែលមានខ្នាតស្មើគ្នាទាំងបណ្តោយទាំងទទឹង, ក្នុងសេចក្តីឧបមានោះ សំពត់ទាំងឡាយ ៤ នោះ មានខ្នាតស្មើគ្នា ទាំងបណ្តោយទាំងទទឹង, សេចក្តីប្លែកគ្នា ដោយខ្នាត នៃសំពត់ទាំង ៤ នោះ មិនមាន ក៏ពិតមែនហើយ តែបើទុកជាដូច្នោះ សំពត់ក្រោយៗ ជាសំពត់ប្រណីតជាងសំពត់មុនៗ ដោយមាន

សម្ពស្សទន់ល្មៃ មានសាច់ម៉ត់ និង មានតម្លៃច្រើន យ៉ាងណា, សូម្បីក្នុងអារូប្បសមាបត្តិទាំង ៤ ក៏មានអង្គ ២ នេះ ដូចគ្នាដែរ គឺឧបេក្ខា ១ ចិត្តេកគ្គតា ១ ក៏ពិតមែន បើទុកជាដូច្នោះ បណ្ឌិតគប្បីជ្រាបថា "ក្នុងសមាបត្តិនេះ សមាបត្តិខាងក្រោយៗ ជាសមាបត្តិប្រណីតល្អជាង ព្រោះភាវៈនៃសមាបត្តិនោះប្រណីត និងប្រណីតជាងអង្គទាំងឡាយនោះដោយសេចក្តីវិសេសនៃភាវនា ក៏យ៉ាងដូច្នោះដែរ" ។ ក៏អារូប្បសមាបត្តិទាំងនុ៎ះ ជាសមាបត្តិប្រណីត និង ប្រណីតជាង ដោយលំដាប់ ដូច្នេះឯង ។

(អារូប្បៈ ៤ ឧបមាដោយបុរស ៤ នាក់)

បុរសម្នាក់ជាប់ទើរ ត្រង់ទីមណ្ឌបដែលមិនស្អាត បុរសម្នាក់ទៀតអាស្រ័យនូវបុរសម្នាក់នោះ, បុរសដទៃទៀតមិនអាស្រ័យបុរសនោះទេ (ឈរនៅ) ខាងក្រៅ, និងបុរសម្នាក់ទៀត បានឈរអាស្រ័យ នូវបុរសដែលឈរនៅខាងក្រៅនោះហើយ, អារូប្បសមាបត្តិទាំង ៤ អ្នកប្រាជ្ញគប្បីជ្រាប ដោយភាពជាធម្មជាតស្មើគ្នា ដោយបុរសទាំងឡាយ ៤ នេះ ដោយលំដាប់ចុះ ។

នេះ ជាពាក្យប្រកបសេចក្តី ក្នុងឧបមានោះ ។ មានរឿងមកថា មានមណ្ឌបមួយ នៅត្រង់ទីដែលមិនស្អាត ។ គ្រានោះ បុរសម្នាក់ មកហើយ ក៏ខ្ពើមនូវទីមិនស្អាតនោះ ទើបយកដៃតោងនូវមណ្ឌបនោះហើយក៏ជាប់នៅក្នុងមណ្ឌបនោះ ដូចជាគេព្យួរទុកហើយ ។ បន្ទាប់មក បុរសមួយទៀត មកហើយ ក៏អាស្រ័យនូវបុរសដែលជាប់ក្នុងមណ្ឌបនោះ ។ បុរសផ្សេងទៀត មកដល់ហើយ គិតថា "បុរសអ្នកដែលជាប់ក្នុងមណ្ឌប

និង បុរសដែលអាស្រ័យនូវបុរសជាប់មណ្ឌបនោះ, បុរសទាំង ២ នាក់នោះ លំបាកហើយ, ឯការធ្លាក់ចុះទៅ ក្នុងជ្រោះនៃមណ្ឌប នឹងមាន ដល់បុរសទាំង ២ នាក់នោះ ទៀងទាត់ណាស់, ណ្ហើយចុះ អាត្មាអញ ឈរនៅខាងក្រៅនេះបានហើយ" ដូច្នេះ ។ បុរសនោះ មិនអាស្រ័យនូវបុរសដែលអាស្រ័យនូវបុរសខាងដើមនោះទេ ក៏បានឈរនៅហើយ ឰដ៏ខាងក្រៅហ្នឹងឯង ។ គ្រានោះ ស្រាប់តែបុរសម្នាក់ទៀតមក សំគាល់នូវបុរសដែលគិតនូវសេចក្តីមិនក្សេមក្សាន្ត នៃបុរសដែលជាប់ ក្នុងមណ្ឌល និងបុរសដែលអាស្រ័យ នូវបុរសអ្នកជាប់មណ្ឌបនោះផង ហើយឈរនៅខាងក្រៅហ្នឹងឯងឈរនៅយ៉ាងល្អ ទើបអាស្រ័យ នូវបុរសដែលឈរនៅខាងក្រៅនោះ បានឈរនៅហើយ ។

អាកាសត្រង់ទីដែលកសិណបើក បណ្ឌិតគប្បីឃើញ ឲ្យដូចជាមណ្ឌប ក្នុងទីដែលមិនស្អាត ក្នុងឧបមានោះ ។ អាកាសានញ្ចាយតនៈដែលមានអាកាសជាអារម្មណ៍ ព្រោះខ្ពើមរអើមនូវរូបនិមិត្ត បណ្ឌិតគប្បីឃើញថា ដូចជាបុរសដែលជាប់មណ្ឌប ព្រោះខ្ពើមទីដែលមិនស្អាត ។ វិញ្ញាណញ្ចាយតនៈ ដែលប្រារព្ធ នូវអាកាសានញ្ចាយតនៈ ដែលមានអាកាសជាអារម្មណ៍ ហើយប្រព្រឹត្តទៅ បណ្ឌិតគប្បីឃើញថា ដូចជាបុរសដែលអាស្រ័យ នូវបុរសដែលជាប់មណ្ឌប ។ អាកិញ្ចញ្ញាយតនៈដែលមិនធ្វើ នូវអាកាសានញ្ចាយតនៈ ឲ្យជាអារម្មណ៍ មានភាពមិនមានវិញ្ញាណនោះជាអារម្មណ៍ បណ្ឌិតគប្បីឃើញថា ដូចជាបុរសដែលគិតនូវសេចក្តីមិនក្សេមក្សាន្ត នៃបុរសទាំង ២ នាក់នោះ ទើបមិនអាស្រ័យនូវបុរសដែលជាប់មណ្ឌបនោះ ហើយក៏បានមកឈរនៅខាងក្រៅ ។ នេវ-សញ្ញានាសញ្ញាយតនៈ ដែលប្រារព្ធ នូវអាកិញ្ចញ្ញាយតនៈ ដែលឋិតនៅ

ត្រង់ទីខាងក្រៅ ពោលគឺភាពមិនមានវិញ្ញាណ ហើយប្រព្រឹត្តទៅ បណ្ឌិតគប្បីឃើញថា ដូចជាបុរសដែលសំគាល់ នូវបុគ្គលដែលគិត នូវសេចក្តីមិនក្សេមក្សាន្ត នៃបុរសដែលជាប់មណ្ឌប និង អ្នកដែលអាស្រ័យបុរសអ្នកជាប់មណ្ឌបនោះផង ហើយបានឈរនៅខាងក្រៅនោះឯងថា "ជាអ្នកឈរបានល្អហើយ" ដូច្នេះ ទើបអាស្រ័យនូវបុរសនោះ ឋិតនៅហើយ ។

ក៏នេវសញ្ញានាសញ្ញាយតនៈនេះ កាលប្រព្រឹត្តទៅ យ៉ាងដូច្នេះ

រមែងធ្វើនូវអាកិញ្ចញ្ញាយតនៈនោះឲ្យជាអារម្មណ៍ ព្រោះ
មិនមានអារម្មណ៍ដទៃទៀត ប្រៀបដូចជា (ប្រជា)ជន
អាស្រ័យ នូវព្រះរាជា សូម្បីជាអ្នកមានទោស ប្រាកដ
ប្រព្រឹត្តទៅ ព្រោះការចិញ្ចឹមជីវិតជាហេតុ ដូច្នោះ ។

អធិប្បាយថា នេវសញ្ញានាសញ្ញាយតនៈនេះ ត្រូវធ្វើនូវអាកិញ្ចញ្ញាយតនៈនោះ សូម្បីជាមានទោសដែលឃើញហើយ យ៉ាងដូច្នេះ ថា "សមាបត្តិនេះ មានសត្រូវគឺវិញ្ញាណញ្ចាយតនៈនៅជិត" ដូច្នេះ ឲ្យជាអារម្មណ៍ ព្រោះមិនមានអារម្មណ៍ដទៃទៀត ។ ប្រៀបដូចអ្វី? ។ ប្រៀបដូចជា (ប្រជា) ជន ត្រូវអាស្រ័យព្រះរាជា សូម្បីមានទោសដែលឃើញហើយប្រព្រឹត្តទៅ ព្រោះការចិញ្ចឹមជីវិតជាហេតុ ដូច្នោះ ។ អធិប្បាយថា (ប្រជា)ជន កាលមិនបាននូវការចិញ្ចឹមជីវិត ក្នុងប្រទេសដទៃ ចាំបាច់ត្រូវអាស្រ័យព្រះរាជាមួយអង្គ ជាធំក្នុងទ្វីបទាំងមូល ជាអ្នកមិនសង្រួម មានសេចក្តីប្រព្រឹត្តិតាមផ្លូវកាយ វាចា និង ចិត្ត ថោកទាប សូម្បីជាអ្នកមានទោសដែលបុគ្គលឃើញហើយថា "ព្រះរាជានេះ ជាអ្នកមានការប្រព្រឹត្តិថោកទាប" ដូច្នេះ រមែងប្រព្រឹត្តទៅ ព្រោះកិរិយាចិញ្ចឹមជីវិតជាហេតុ

យ៉ាងណាមិញ, នេវសញ្ញានាសញ្ញាយតនៈនេះ កាលមិនបានអារម្មណ៍ដទៃ ក៏ត្រូវធ្វើនូវអាកិញ្ចញ្ញាយតនៈនោះ សូម្បីមានទោសដែលឃើញហើយឲ្យជាអារម្មណ៍ ក៏យ៉ាងដូច្នោះដែរ ។ ក៏នេវសញ្ញានាសញ្ញាយតនៈនេះ កាលធ្វើយ៉ាងដូច្នេះ

ក៏តែងតែតោងជាប់ (នូវអាកិញ្ចញ្ញាយតនៈ)ឈាននោះ
ហើយ ប្រព្រឹត្តទៅ (ព្រោះមិនមានអ្វីតោង) ប្រៀប
ដូចជាបុគ្គលឡើងជណ្តើរវែង (ដល់កាំខាងលើហើយ)
ក៏ប្រតោង (នូវមេ)ជណ្តើរ (ព្រោះមិនមានអ្វីនឹងតោង)
និង ប្រៀបដូចជាបុគ្គលឡើងកំពូលភ្នំ ហើយប្រតោង
នូវកំពូលភ្នំ (ព្រោះមិនមានអ្វីនឹងប្រតោង) ឬ ប្រៀប
ដូចជាបុគ្គលឡើងភ្នំ ហើយទប់ទល់ជង្គង់ របស់ខ្លួន
ហ្នឹងឯង (ព្រោះមិនមានអ្វីនឹងទប់ទល់) ដូច្នោះឯង ។

បរិច្ឆេទ ទី១០ ឈ្មោះអារុប្បនិទ្ទេស ក្នុងអធិការនៃសមាធិភាវនា
ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ
គឺខ្ញុំរចនាហើយ ដើម្បីប្រយោជន៍
ដល់សេចក្តីរីករាយរបស់សាធុជន យ៉ាងដូច្នេះឯង ។

❈ ❀ ❈

បានរៀបរៀងចប់ ថ្ងៃព្រហស្បតិ៍ ២ កើត ខែបុស្ស ព.ស.២៥៥០
ថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០០៦

(អាហារេបដិក្កូលសញ្ញា)

(២០២) ក្នុងកាលឥឡូវនេះ ការសំដែងចេញនូវការចំរើន នៃការសំគាល់ថា បដិកូល ក្នុងអាហារ ដែលលោកលើកយកមកសំដែងយ៉ាងនេះ ថា “សញ្ញា មួយ” ដូច្នេះ បន្ទាប់អំពីអារូប្បនិទ្ទេស មកដល់ហើយតាមលំដាប់ ។

ក្នុងការសំគាល់ថា បដិកូល ក្នុងអាហារនោះ បណ្ឌិតគប្បីជ្រាបសេចក្ដីវិនិច្ឆ័យ តូចតទៅ : សភាពណា តែងនាំមក ព្រោះហេតុនោះ សភាពនោះ ឈ្មោះថា អាហារ (សភាពអ្នកនាំមក) ។ អាហារនោះមាន ៤ យ៉ាង គឺ កពឡិង្ការាហារ, ផស្សាហារ, មនោសញ្ចេតនាហារ, វិញ្ញាណាហារ ។

សួរថា “ក៏ក្នុងអាហារទាំង ៤ យ៉ាងនុ៎ះ អាហារយ៉ាងណា តែងនាំអ្វីមក? ” ។

ឆ្លើយថា “កពឡិង្ការាហារ តែងនាំមក នូវរូប ដែលមានឱជា ជាគម្រប់៨ ។ ផស្សាហារ តែងនាំមកនូវវេទនា ៣ ។ មនោសញ្ចេតនាហារ តែងនាំមកនូវបដិសន្ធិ ក្នុងភពទាំង ៣ ។ វិញ្ញាណាហារ តែងនាំមក នូវនាមរូប ក្នុងខណៈ នៃបដិសន្ធិ ។

(ភ័យកើតព្រោះអាហារជាហេតុ)

ក្នុងអាហារទាំង ៤ នោះ ភ័យគឺការមិនត្រេកអរ តែងមាន ក្នុងកពឡិង្ការាហារ, ភ័យគឺការចូលទៅរក តែងមាន ក្នុងផស្សាហារ, ភ័យគឺការកើតឯង តែងមាន ក្នុងមនោសញ្ចេតនាហារ, ភ័យគឺបដិសន្ធិ តែងមាន ក្នុងវិញ្ញាណាហារ ។ ក៏ក្នុងអាហារទាំងឡាយនេះ ដែលមានភ័យចំពោះ យ៉ាងនេះ កពឡិង្ការាហារ បណ្ឌិតគប្បីសំដែង ដោយព្រះឱវាទ

ដែលប្រៀបដោយសាច់របស់កូន, ផស្សាហារ បណ្ឌិតគប្បីសំដែងដោយព្រះឱវាទ ដែលប្រៀបដោយមេគោមិនមានស្បែក, មនោសញ្ចេតនាហារ បណ្ឌិតគប្បីសំដែង ដោយព្រះឱវាទ ដែលប្រៀបដោយរណ្ដៅរងើកភ្លើង, វិញ្ញាណាហារ បណ្ឌិតគប្បីសំដែង ដោយព្រះឱវាទ ដែលប្រៀបដោយមុខនៃលំពែង ។

(អាហារដែលប្រាថ្នាក្នុងកម្មដ្ឋាននេះ)

តែក្នុងអាហារទាំង ៤ នេះ កពឡិង្ការាហារ ដែលចែកជារបស់ស៊ី ផឹក ទំពា និង ភ្លក្ស ប៉ុណ្ណោះ គឺលោកប៉ងយកហើយថា “អាហារ” ក្នុងសេចក្ដីនេះ ។ សេចក្ដីសំគាល់ ដែលកើតឡើង ដោយអំណាចនៃការកាន់យកនូវអាការៈដែលគួរខ្ពើម ក្នុងអាហារនោះ ឈ្មោះថា សេចក្ដីសំគាល់ថា គួរខ្ពើម ក្នុងអាហារ ។ ព្រះយោគីអ្នកប្រាថ្នាដើម្បីចំរើននូវអាហារេបដិកូលសញ្ញានោះ គប្បីរៀននូវកម្មដ្ឋាន មិនឲ្យភ្លាំងភ្លាត់អំពីការដែលរៀនមកសូម្បីតែមួយបទ ទៅក្នុងទីស្ងាត់តែម្នាក់ឯងសម្ងំនៅ ហើយត្រូវពិចារណា នូវភាពបដិកូល ក្នុងកពឡិង្ការាហារ ដែលចែកជារបស់ស៊ី ផឹក ទំពា និង លិទ្ធភ្លក្ស ដោយអាការៈទាំងឡាយ ១០ ។ អាការៈទាំង ១០ នេះ គឺអ្វីខ្លះ ? ។ គឺ :

១- គមនតោ បដិកូលដោយដំណើរដើរ,

២- បរិយេសនតោ បដិកូលដោយការស្វែងរក,

៣- បរិភោគតោ បដិកូលដោយការបរិភោគ,

៤- អាសយតោ បដិកូលដោយទីអាស្រ័យ,

៥- និធានតោ បដិកូលដោយកន្លែងតំកល់នៅក្នុងផ្ទៃ,

៦- អបរិបក្កតោ បដិកូលដោយភាពដែលមិនទាន់រលួយ,

៧- បរិបក្កតោ បដិកូលដោយភាពដែលរលួយហើយ,

៨- ផលតោ បដិកូលដោយផល,

៩- និស្សន្ទតោ បដិកូលដោយហូរចេញ,

១០- សម្មក្ខនតោ បដិកូលដោយប្រឡាក់ប្រឡូស ។

(បដិកូលដោយដំណើរដើរ)

(២០៣) ក្នុងបទទាំង១០ នោះ បទថា "គមនតោ" នោះ សេចក្តីថា សេចក្តីបដិកូលដោយដំណើរដើរ គឺព្រះយោគីគប្បីពិចារណា ដោយន័យយ៉ាងនេះ ថា "អ្នកបួស ក្នុងសាសនា ដែលឈ្មោះថាមានអានុភាពច្រើន យ៉ាងនេះ ធ្វើការស្វាធ្យាយនូវព្រះពុទ្ធវចនៈក្តី នូវសមណធម៌ក្តី រហូតទាំងរាត្រី ក្រោកឡើងហើយអំពីព្រឹកព្រលឹម ធ្វើវត្តត្រង់លានព្រះចេតិយ និង វត្តត្រង់លានពោធិព្រឹក្ស តំកល់ទឹកសំរាប់ឆាន់ ទឹកសំរាប់ប្រើប្រាស់ បោសសំអាតទីបរិវេណ ជម្រះនូវសរីរៈហើយ ឡើងកាន់ទីអាសនៈ ធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន អស់ ២០-៣០ ដង ហើយ ក្រោកឡើង ចាប់យកបាត្រ និង ចីវរ លះបង់នូវតបោវន (គឺព្រៃជាទីធ្វើនូវតបោកម្ម) ដែលជាទីប្រាសចាកជនបៀតសៀត សុខសប្បាយដល់វិវេក ដល់ព្រមដោយម្លប់ និង ទឹក ស្អាតល្អ ត្រជាក់ ជាទីឋានដែលជាទីរីករាយហើយ មិនសម្លឹងនូវសេចក្តីត្រេកអរក្នុងវិវេក ដែលជាអរិយគុណ គប្បីមានមុខឆ្ពោះទៅកាន់ស្រុក និមន្តទៅ ដើម្បីប្រយោជន៍ដល់អាហារ ដូចជាឆ្កែចចក មានមុខឆ្ពោះទៅកាន់ទីស្មសានដូច្នោះ កាលនិមន្តទៅយ៉ាងនេះ ចាប់តាំងពីចុះចេញអំពីគ្រែ ឬ តាំងទៅហើយ ក៏ត្រូវជាន់ទឹកម្រាល ដែលពោរពេញទៅដោយគ្រឿងមិនស្អាត មានកំទេចធូលីជាប់ជើង និង លាមកសត្វជីងចក់ជាដើម, បន្ទាប់ពីនោះ ត្រូវមើលមុខជាប្រធាន ដែល

បដិកូលជាងខាងក្នុងបន្ទប់ ព្រោះពេលខ្លះ ត្រូវវត្ថុបដិកូល មានអាចម៍កណ្តុរ និង អាចម៍ប្រចៀវជាដើម ធ្វើឲ្យខូចខាតហើយ, បន្ទាប់មក ត្រូវមើលជាន់ខាងក្រោម(កុដិ)ដែលបដិកូលជាងជាន់ខាងលើ ព្រោះពេលខ្លះត្រូវប្រឡាក់ដោយអាចម៍មៀម និង អាចម៍ព្រាបជាដើម, បន្ទាប់មក ត្រូវមើលបរិវេណ ដែលបដិកូលជាងជាន់ខាងក្រោម(នៃកុដិ) ព្រោះពេលខ្លះគគ្រិចហើយដោយស្មៅ និង ស្លឹកឈើចាស់ៗ ដែលត្រូវខ្យល់បក់មកដោយបស្សាវៈ ឧច្ចារៈ ទឹកមាត់ និង ទឹកសំបោរ នៃពួកសាមណេរដែលមានជម្ងឺ និង ដោយទឹកនិងភក់ជាដើម ក្នុងរដូវភ្លៀង, ត្រូវមើលផ្លូវទៅវិហារដែលបដិកូលជាងបរិវេណទៅទៀត, មួយទៀត អ្នកបួសនោះថ្វាយបង្គំនូវពោធិព្រឹក្ស និង ព្រះចេតិយ ដោយលំដាប់ហើយ ត្រូវឈរនៅ ត្រង់កន្លែងដែលឈរត្រិះរិះ ហើយត្រិះរិះ ថា "អាត្មាអញ នឹងមិនត្រូវក្រឡេកមើលព្រះចេតិយដែលដូចជាកងនៃកែវមុក្តា និង ដើមពោធិ-ព្រឹក្សដ៏ជាទីគាប់ចិត្តដូចជាស្វាបកន្ទុយនៃសត្វក្ងោក និង នូវសេនាសនៈដែលមានសិរី ដូចជាសម្បត្តិនៃទេព្វវិមានហើយ បែរខ្នងទៅកាន់ទីដែលជាទីរីករាយ ឈ្មោះយ៉ាងនេះ ហើយទៅ ព្រោះអាហារជាហេតុ" ដូច្នេះហើយ ចៀសចេញទៅ ក៏ដើរទៅកាន់ផ្លូវទៅកាន់ស្រុកហើយ ត្រូវមើលផ្លូវដែលមានដង្គត់ និង បន្លាផង ផ្លូវដែលត្រូវកំឡាំងទឹកច្រោះហើយ និង ផ្លូវមិនរាបស្មើផង, បន្ទាប់មក អ្នកបួសត្រូវស្លៀកស្បង់ (ដោយការនឹកគិត) ដូចសំពត់បិទនូវបូស ចងនូវវត្ថពន្ធ ដូចចងសំពត់រុំដំបៅ គ្រងចីវរ (ដោយការនឹកគិត) ដូចជាគ្របនូវគ្រោងឆ្អឹង នាំយកបាត្រចេញ (ដោយការនឹកគិត) ដូចជានាំយកនូវភាជនៈសំរាប់ប្រេកថ្នាំ មកដល់ទីជិតនៃទ្វារស្រុក ក៏នឹងឃើញនូវសាកសពផ្សេងៗ ដូចសាកសពដំរីខ្លះ សាកសព

សេះខ្លះ សាកសពគោខ្លះ សាកសពក្របីខ្លះ សាកសពមនុស្សខ្លះ សាកសពពស់ខ្លះ សាកសពឆ្កែជាដើមខ្លះ នឹងត្រូវតែមើលតែប៉ុណ្ណោះ ក៏មិនមែនដែរ សូម្បីក្លិននៃសាកសពទាំងនោះដែលមកប៉ះនូវច្រមុះ ក៏ជារឿងដែលត្រូវអត់ទ្រាំផងដែរ, បន្ទាប់មក អ្នកបួស ត្រូវតែឈរត្រង់ទ្វារចូលស្រុក ហើយក្រឡេកមើលនូវផ្លូវដើរទៅក្នុងស្រុក ដើម្បីប្រយោជន៍ដល់ការគេចវេះនូវអន្តរាយ មានដំរីកាច និង ឆ្កែកាចជាដើម ។

របស់បដិកូល មានគ្រឿងកម្រាលជាខាងដើម មានសាកសពច្រើនជាអនេកជាបរិយោសាន ដូចបានពោលមកដូច្នេះនេះ ជារឿងដែលអ្នកបួស ត្រូវអត់សង្កត់ផង ត្រូវសំឡឹងមើលផង ត្រូវហិតក្លិនផង ព្រោះអាហារជាហេតុ, សេចក្តីបដិកូល ដោយដំណើរដើរ គឺព្រះយោគីគប្បីពិចារណាឲ្យឃើញ យ៉ាងដូច្នេះថា “ឱហ្ន៎! អ្នកដ៏ចំរើន អាហារ ជារបស់បដិកូលគួរខ្ពើមមែនហ្ន៎ ” ដូច្នេះ ។

(បដិកូលដោយការស្វែងរក)

(២០៤) (សេចក្តីបដិកូល) ដោយការស្វែងរក តើដូចម្តេច ? ។ សេចក្តីបដិកូលដោយការស្វែងរក គឺព្រះយោគី ត្រូវពិចារណាឲ្យឃើញច្បាស់យ៉ាងនេះថា “បព្វជិត សូម្បីអត់ធន់នូវសេចក្តីបដិកូល ក្នុងការធ្វើដំណើរយ៉ាងនេះហើយ ចូលទៅកាន់ស្រុក ឃ្លុំដោយសំពត់សង្ឃាដី ត្រូវតែត្រាច់ទៅតាមជង្ហល់ ក្នុងស្រុក តាមលំដាប់ផ្ទះ ដូចជាមនុស្សកំព្រា មានដៃកាន់អំបែង ត្រាច់ទៅដូច្នោះ, ត្រង់ផ្លូវឯណា ក្នុងរដូវភ្លៀង លើទីដែលជាន់ហើយៗ ជើងទាំងឡាយចូលទៅ ក្នុងទឹក និង ភក់ រហូតដល់សាច់ស្មង, បព្វជិត ត្រូវតែកាន់បាត្រ ដោយដៃមួយ លើកចីពរដោយដៃមួយ, ក្នុងរដូវក្តៅ ត្រូវតែត្រាច់ទៅ ទាំងរាងកាយប្រឡាក់ប្រឡូសហើយ

ដោយអាចម៍ដីនិងកំទេចស្មៅ ដែលប៉ើងឡើងហើយ ដោយកំឡាំងខ្យល់, ទៅដល់មាត់ទ្វារផ្ទះនោះៗ ហើយ ក៏ត្រូវជួបប្រទះ ពេលខ្លះ ត្រូវជាន់នូវរណ្តៅជ្រាំ និង ថ្លុកជ្រាំ ដែលច្របូកច្របល់ ដោយរបស់មិនស្អាត មានទឹកលាងត្រី, ទឹកលាងសាច់, ទឹកលាងអង្ករ, ទឹកមាត់, ទឹកច្រមុះ និង លាមកឆ្កែ និង ជ្រូកជាដើម ដែលដេរដាសហើយ ដោយហ្វូងដង្កូវ និង រុយក្បាលខៀវជាដើម ដែលជាទីកន្លែងដែលសត្វរុយក្នុងស្រុកហើរឡើងមកទំអែបលើសង្ឃាដីខ្លះ លើបាត្រខ្លះ លើក្បាលខ្លះ, កាលបព្វជិតនោះសូម្បីចូលទៅដល់ផ្ទះហើយ ម្ចាស់ផ្ទះពួកខ្លះប្រគេន ពួកខ្លះមិនប្រគេនទេ សូម្បីអ្នកដែលប្រគេន ពួកខ្លះ ប្រគេនតែបាយដែលដាំហើយ កាលពីថ្ងៃម្សិលខ្លះ នូវរបស់ឆាន់ដែលសេសសល់ខ្លះ នូវសម្លមានសម្លស្ណែកដែលផ្អូមជាដើមខ្លះ, ពួកអ្នកមិនប្រគេនសោត អ្នកខ្លះពោលថា “បពិត្រព្រះគុណម្ចាស់ ចូរនិមន្តប្រោសសត្វទៅខាងមុខចុះ” ដូច្នេះ តែប៉ុណ្ណោះ, តែពួកខ្លះនៅស្ងៀមឈឹង ធ្វើហាក់បីដូចជាមិនឃើញ, ពួកខ្លះ ក៏បែរមុខទៅទីដទៃ(បែរមុខចេញ), ពួកខ្លះ ក៏ស្រែកទ្រគោះ ដោយពាក្យអាក្រក់ៗថា “នែ វើយ! មនុស្សក្បាលត្រងោល ទៅទៅ” ដូច្នេះជាដើម, ពិតមែនទោះបីជាយ៉ាងនេះក៏ដោយ បព្វជិត ត្រូវតែត្រាច់ទៅបិណ្ឌបាត ក្នុងស្រុកដូចជាមនុស្សកំព្រា ហើយចេញទៅ យ៉ាងនេះឯង ។

របស់បដិកូល មានរណ្តៅទឹកជ្រាំជាដើម ដូចពោលមកដូច្នេះនេះ ជារបស់ដែលបព្វជិតត្រូវជាន់ផង ត្រូវជួបប្រទះផង ត្រូវអត់សង្កត់ផង ចាប់តាំងអំពីចូលទៅ ក្នុងស្រុក រហូតដល់ចេញមកវិញ ក៏ព្រោះអាហារជាហេតុដោយពិតប្រាកដ, ឱហ្ន៎ អ្នកដ៏ចំរើន អាហារ ជារបស់បដិកូលគួរខ្ពើមរអើម ពិតមែនហ្ន៎!” ដូច្នេះឯង ។

(បដិកូលដោយការបរិភោគ)

(២០៥) (សេចក្តីបដិកូល) ដោយការបរិភោគ តើដូចម្តេច ? ។ សេចក្តីបដិកូលដោយការបរិភោគ គឺព្រះយោគី ត្រូវពិចារណាឲ្យឃើញច្បាស់ យ៉ាងនេះថា "ក៏សេចក្តីបដិកូល ដោយការបរិភោគ បព្វជិតអ្នកមានអាហារដែលស្វែងរកបានមកហើយ យ៉ាងនេះ អង្គុយតាមសប្បាយក្នុងទីដែលសប្បាយ ខាងក្រៅស្រុក ត្រូវឃើញ យ៉ាងនេះថា "អ្នកមិនទាន់លូកដៃចូលទៅ ក្នុងអាហារនោះ ដរាបណា អ្នកឃើញ នូវភិក្ខុដែលគួរគោរពក្តី នូវមនុស្សដែលមានការអៀនខ្មាសក្តី ប្រាកដដូច្នោះហើយ ក៏អាចនិមន្ត (ឲ្យឆាន់នូវអាហារនោះ) បានដរាបនោះ, ប៉ុន្តែគ្រាន់តែបព្វជិតនោះ ដាក់ដៃចូលទៅ ក្នុងអាហារនោះ ដោយមានបំណងនឹងឆាន់ កាលពោលថា"ចូរអ្នកទទួលចុះ" ដូច្នេះ ត្រូវមានតែការខ្មាសអៀន, ក៏កាលបើបព្វជិតនោះ ដាក់ដៃចូលទៅហើយប្របាច់ ញើសហូរចេញ តាមម្រាមដៃទាំង ៥ ញ៉ាំងភត្តស្ងួតស្ងួតដែលរឹងព្រោះស្ងួតឲ្យសើម ធ្វើឲ្យទន់, គ្រានោះកាលបើបិណ្ឌបាតនោះ ខូចភាពដែលល្អហើយ ព្រោះការធ្វើស្ងួតត្រឹមតែប្របាច់ គឺបព្វជិតនោះ ធ្វើឲ្យទៅជាពំនូត ដាក់ចូលទៅក្នុងមាត់ហើយ, ធ្មេញក្រោម ញ៉ាំងកិច្ចនៃត្បាល់ឲ្យសំរេច ធ្មេញលើ ញ៉ាំងកិច្ចនៃអង្រែឲ្យសំរេច អណ្តាត ញ៉ាំងកិច្ចនៃដៃឲ្យសំរេច, ទឹកមាត់ដ៏ថ្លាភាវ លើចុងអណ្តាត ប្រឡាក់នូវបិណ្ឌបាតនោះ ដែលត្រូវអង្រែគឺធ្មេញ ទំពាលំអិតហើយ គ្រលេវប្រមូលផ្តុំ ដោយអណ្តាត ដូចជាកំអួតឆ្កែលើស្នូកបាយឆ្កែនៅក្នុងមាត់នោះ, ទឹកមាត់ខាប់ ចាប់តាំងពីពាក់កណ្តាលអណ្តាតចូលទៅរមែងប្រឡាក់, ជើងធ្មេញ ក្នុងទីដែលឈើជម្រះធ្មេញទៅមិនដល់ រមែងប្រឡាក់, បិណ្ឌបាតនោះ ដែលត្រូវទំពាកំទេច និង ប្រឡាក់ហើយ យ៉ាង

នេះ មានពណ៌ ក្លិន និង ការតាក់តែងដ៏វិសេស វិនាសបាត់អស់ហើយក្នុងខណៈនោះភ្លាម រមែងចូលដល់ភាពគួរខ្ពើមរអើមយ៉ាងក្រៃលែង ដូចជាកំអួតឆ្កែដែលនៅក្នុងស្នូកបាយឆ្កែដូច្នោះ, បិណ្ឌបាតនោះ សូម្បីប្រាកដយ៉ាងដូច្នេះ ក៏ជារបស់ដែលត្រូវតែលេបចូលទៅ ព្រោះបិណ្ឌបាតនោះកន្លងនូវគន្លងនៃចក្ខុ" ដូច្នេះឯង ។

(បដិកូលដោយទីអាស្រ័យ)

(២០៦) (សេចក្តីបដិកល) ដោយទីអាស្រ័យ តើដូចម្តេច ? ។ សេចក្តីបដិកូលដោយទីអាស្រ័យ ព្រះយោគីគប្បីពិចារណា យ៉ាងនេះថា "ក៏អាហារនោះ ដែលបានបរិភោគចូលទៅហើយយ៉ាងនេះ កាលចូលទៅពួដ៏ខាងក្នុង, បណ្តាទីអាស្រ័យ(អាសយៈ) ទាំងឡាយបួន គឺទីអាស្រ័យរបស់ប្រមាត់ ទីអាស្រ័យរបស់ស្លេស្ម ទីអាស្រ័យរបស់ខ្ទុះ ទីអាស្រ័យរបស់ឈាម ទីអាស្រ័យណាមួយ រមែងមាន ដល់ព្រះពុទ្ធ និង ព្រះបច្ចេកពុទ្ធទាំងឡាយផង ដល់ស្តេចចក្រពត្តិផងតែប៉ុណ្ណោះ ក៏ប៉ុន្តែសំរាប់បុគ្គលទាំងឡាយដែលមានបញ្ញាតិច រមែងមានទីអាស្រ័យគ្រប់ទាំង ៤ ព្រោះហេតុណា, ព្រោះហេតុនោះ បើបុគ្គលណាដែលមានទីអាស្រ័យរបស់ប្រមាត់ច្រើន, អាហារដែលបុគ្គលនោះលេបចូលទៅ ប្រៀបដូចជាប្រឡាក់ដោយប្រេងស្រគំយ៉ាងខាប់គួរខ្ពើមក្រៃពេក, បុគ្គលណា មានទីអាស្រ័យរបស់ស្លេស្មច្រើន អាហារដែលបុគ្គលនោះលេបចូលទៅ ដូចជាប្រឡាក់ដោយរសនៃផ្លែខ្ទឹង ឬ ស្លឹកខ្ទឹងគួរខ្ពើមក្រៃលែង, បុគ្គលណាមានទីអាស្រ័យរបស់ខ្ទុះច្រើន អាហារដែលបុគ្គលនោះ លេបចូលទៅប្រៀបដូចជាប្រឡាក់ដោយទឹកដោះជូរដែលផ្អូមគួរខ្ពើមក្រៃលែង, បុគ្គលណា មានទីអាស្រ័យរបស់ឈាមច្រើន, អាហារ ដែលបុគ្គលនោះលេប

ចូលទៅហើយ បីដូចជាទឹកជ្រលក់គួរខ្ពើមក្រៃលែង” ដូច្នេះ ។

(បដិកូលដោយកន្លែងតាំងលំនៅក្នុងផ្ទៃ)

(២០៧) (សេចក្តីបដិកូល)ដោយកន្លែងដែលតាំងលំនៅក្នុងផ្ទៃ តើដូចម្តេច ? ។ សេចក្តីបដិកូលដោយកន្លែងដែលតាំងលំនៅក្នុងផ្ទៃ គឺព្រះយោគី ត្រូវពិចារណាឲ្យឃើញច្បាស់ យ៉ាងនេះថា “អាហារដែលលេបចូលទៅប្រឡាក់ដោយអាសយៈណាមួយ ក្នុងចំណោមអាសយៈទាំង ៤ នេះ ចូលទៅហើយក្នុងផ្ទៃនោះ មិនមែនទៅតាំងលំនៅ ក្នុងភាជនៈមានភាជនៈមាសជាដើមឡើយ មិនមែនទៅតាំងលំនៅ ក្នុងភាជនៈទាំងឡាយមានភាជនៈធ្វើពីកែវមណី និង ភាជនៈធ្វើអំពីប្រាក់ជាដើមឡើយ, តែថាបើមនុស្សមានអាយុ ១០ ឆ្នាំ លេបចូលទៅ ក៏ទៅតាំងលំនៅ ក្នុងឱកាសដែលប្រាកដស្មើដោយរណ្តៅលាមកដែលមិនបានលាងហើយ អស់ ១០ ឆ្នាំ, បើមនុស្សមានអាយុ ២០ ឆ្នាំ ៣០ ឆ្នាំ ៤០ ឆ្នាំ ៥០ ឆ្នាំ ៦០ ឆ្នាំ ៧០ ឆ្នាំ ៨០ ឆ្នាំ ៩០ ឆ្នាំ លេបចូលទៅ ក៏ទៅតាំងលំនៅ ក្នុងឱកាសដែលប្រាកដស្មើដោយរណ្តៅលាមក ដែលមិនបានលាងហើយ អស់ ២០ ឆ្នាំ ៣០ ឆ្នាំ ៤០ ឆ្នាំ ៥០ ឆ្នាំ ៦០ ឆ្នាំ ៧០ ឆ្នាំ ៨០ ឆ្នាំ ៩០ ឆ្នាំ, បើមនុស្សមានអាយុ ១០០ ឆ្នាំ លេបចូលទៅ ក៏ទៅតាំងលំនៅ ក្នុងឱកាសដែលប្រាកដស្មើដោយរណ្តៅលាមកដែលមិនបានលាងហើយ អស់ ១០០ឆ្នាំ” ដូច្នេះឯង ។

(បដិកូលដោយភាពដែលមិនទាន់រលួយ)

(២០៨) (សេចក្តីបដិកូល) ដោយភាពដែលមិនទាន់រលួយ តើដូចម្តេច ? ។ សេចក្តីបដិកូល ដោយភាពដែលមិនទាន់រលួយ គឺព្រះយោគី គប្បីពិចារណាឲ្យឃើញច្បាស់ យ៉ាងនេះ ថា “ក៏អាហារនេះនោះ

ដែលចូលទៅតាំងលំនៅ ក្នុងឱកាស(គួរខ្ពើម) បែបនេះហើយ ជាអាហារនៅមិនទាន់រលួយ ដរាបណា សូម្បីអាហារនោះទើបបរិភោគ ក្នុងថ្ងៃនោះក្តី បរិភោគក្នុងថ្ងៃម្សិលក្តី ក្នុងថ្ងៃមុនៗ មកក្តី ក៏ទៅផ្តុំនៅជាមួយគ្នាទាំងអស់ រួបរឹតទៅដោយដុំស្លេស្ម កើតទៅជាពពុះ ជាក្រពេញតូច-ធំ ត្រូវភ្លើងធាតុក្នុងរាងកាយ ចំហុយកំដៅហើយ ដល់នូវភាពគួរខ្ពើមរអើមក្រៃលែង ហើយឋិតនៅ ក្នុងទឹកខ្ទែង មានប្រការដូចបានពោលមកហើយនោះឯង ដែលជាទីងងឹតជិតសូន្យឈឹងពន់ពេក អាប់អួរប្រឡូកប្រឡាក់ដោយក្លិនសាកសពផ្សេងៗ មានក្លិនស្អុយគួរខ្ពើមរអើមក្រៃលែង ដរាបនោះ ប្រៀបដូចជារបស់មិនស្អាតផ្សេងៗ មានស្មៅ ស្លឹកឈើ កន្ទេលរហែកដាច់ដាច សាកសពពស់ សាកសពឆ្កែ និង សាកសពមនុស្សជាដើម ដែលធ្លាក់ហើយក្នុងរណ្តៅក្បែរមាត់ទ្វារចូលផ្ទះនៃជនចណ្ឌាល ត្រូវមេឃ (ភ្លៀង) ដែលមិនមែនជារដូវកាល ក្នុងរដូវក្តៅ ធ្លាក់ស្រោចស្រប់ហើយ ត្រូវកំដៅព្រះអាទិត្យ ដុតកំដៅហើយ កកើតទៅជាពពុះ ជាពង (ដល់នូវភាពគួរខ្ពើមក្រៃលែង) យ៉ាងដូច្នោះឯង” ដូច្នេះ ។

(បដិកូលដោយភាពដែលរលួយហើយ)

(២០៩) (សេចក្តីបដិកូល) ដោយភាពដែលរលួយហើយ តើដូចម្តេច? ។ សេចក្តីបដិកូល ដោយភាពដែលរលួយហើយ គឺព្រះយោគី គប្បីពិចារណាឲ្យឃើញច្បាស់ យ៉ាងនេះ ថា “អាហារនោះ កាលត្រូវភ្លើងធាតុក្នុងកាយដុតឲ្យរលួយហើយក្នុងឱកាសដែលឋិតនៅនោះ ក៏មិនមែនក្លាយទៅជាមាស និង ប្រាក់ជាដើម ដូចជារ៉ែមាស និង រ៉ែប្រាក់ ជាដើមបានឡើយ គ្រាន់តែបញ្ចេញនូវពពុះ និង ក្រពេញតូច-ធំ ដល់នូវភាពជាអាហារចាស់ ក៏ចូលទៅតាំងលំនៅ ក្នុងទីលំនៅ នៃអាហារចាស់

ដូចជាដីស្អិត មានពណ៌លឿង ដែលគេកិនទីងត្បាល់កិន ហើយដាក់ចុះទៅ ក្នុងបំពង់ដូច្នោះ និង ដល់នូវភាពជាទឹកមូត្រហើយ ក៏ជ្រាបទៅដក់នៅ ក្នុងផ្ទោកទឹកមូត្រ” ដូច្នេះ ។

(បដិកូលដោយផល)

(២១០) (សេចក្ដីបដិកូល) ដោយផល តើដូចម្ដេច ? ។ សេចក្ដីបដិកូល ដោយផល គឺព្រះយោគីគប្បីពិចារណាឲ្យឃើញច្បាស់ យ៉ាងនេះថា “ក៏អាហារនេះដែលល្អួយទៅដោយល្អបុណ្ណោះ ទើបញ៉ាំងសាកសពផ្សេងៗ មានសក់ រោម ក្រចក និង ធ្មេញជាដើម ឲ្យចំរើនស្រស់ស្រោងឡើងបាន ដែលមិនល្អួយបានល្អទេ ក៏បណ្ដាលឲ្យកើតទៅជារោគ ១០០ ជំពូក មានរោគកម រមាស់ ឃ្លង់ ស្រែង ហឹត ក្អក និង រោគធ្លាក់ឈាម, នេះជាផលរបស់អាហារនោះ” ដូច្នេះ ។

(បដិកូលដោយហូរចេញ)

(២១១) (សេចក្ដីបដិកូល) ដោយហូរចេញ តើយ៉ាងដូចម្ដេច? ។ សេចក្ដីបដិកូល ដោយហូរចេញ គឺព្រះយោគីគប្បីពិចារណាឲ្យឃើញច្បាស់ យ៉ាងនេះថា “ក៏អាហារនេះ កាលដែលលេបចូលទៅ ក៏ចូលទៅតាមទ្វារតែមួយ កាលដែលហូរចេញមកវិញ រមែងហូរចេញមកវិញតាមទ្វារច្រើនជាអនេក ដោយប្រការៈជាដើម គឺ ដែលចេញមកតាមភ្នែកហៅថាពពឹកភ្នែក ដែលចេញមកតាមត្រចៀកហៅថាអាចម៍ត្រចៀក, ពុំនោះសោត អាហារនេះ ក្នុងពេលដែលលេបចូលទៅ លេបចូលទៅដោយពួកបរិវារជាច្រើននាក់ពិតមែន ប៉ុន្តែក្នុងពេលដែលហូរចេញមកវិញ ក៏ក្លាយទៅជារបស់មិនស្អាតមានឧច្ចារៈ និង បស្សាវៈជាដើមហើយ ក៏បន្ទួរចេញមកវិញតែម្នាក់ឯងគត់, មួយទៀត ក្នុងថ្ងៃដំបូង បុគ្គលកាល

បរិភោគនូវអាហារនោះ ជាអ្នកសប្បាយហឺហា មានចិត្តរីករាយហើយ កើតបីតិ និង សោមនស្ស ក៏មាន (តែ) ក្នុងថ្ងៃទីពីរ កាលដែលអាហារនោះហូរចេញមកវិញ ត្រូវមនុស្សបិទច្រមុះ គេបែរមុខចេញ គេខ្ពើមរអើម គេមានការអៀនខ្មាសទៅវិញ, មួយទៀត ក្នុងថ្ងៃទីមួយ មនុស្សត្រេកអរ ល្មោភ ជាប់ចិត្ត ជ្រុលជ្រប់ហើយ លេបនូវអាហារនោះចូលទៅក៏មាន តែក្នុងថ្ងៃទីពីរ ព្រោះវានៅអស់មួយរាត្រី មនុស្សមិនត្រេកអរនឿយណាយ អៀនខ្មាស ខ្ពើមរអើម ហូរចេញមកវិញ, ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយ ពោលហើយ ថា :

> “បាយ ទឹក ខាទនីយៈ និង ភោជន ដែលមានតម្លៃច្រើន ចូលទៅតាមទ្វារមួយ (តែ) ចេញមកវិញ តាមទ្វារទាំងឡាយ ៩, បុគ្គល ព្រមទាំងបរិវារ បរិភោគនូវបាយ ទឹក ខាទនីយៈ និង ភោជន ដែលមានតម្លៃច្រើន (តែ) កាលបន្ទោបង់វាចេញមកវិញ រមែងទៅលាក់ពួន, បាយ ទឹក ខាទនីយៈ និង ភោជន ដែលមានតម្លៃច្រើន បុគ្គល តែងនិយម ចូលចិត្តបរិភោគ (តែ) កាលបន្ទោបង់វាចេញមកវិញ ក៏ខ្ពើមរអើមទៅវិញ, បាយ ទឹក ខាទនីយៈ និង ភោជន ដែលមានតម្លៃច្រើន ព្រោះវានៅអស់មួយរាត្រី ក៏ប្រែទៅជារបស់ស្អុយទាំងអស់” *ដូច្នេះឯង ។*

(បដិកូលដោយប្រឡាក់ប្រឡូស)

(២១២) (សេចក្ដីបដិកូល)ដោយប្រឡាក់ប្រឡូសតើដូចម្ដេច? ។

សេចក្ដីបដិកូល ដោយប្រឡាក់ប្រឡូស គឺព្រះយោគី គប្បីពិចារណា ឲ្យឃើញច្បាស់ យ៉ាងនេះថា “ក៏អាហារនេះ សូម្បីក្នុងកាលដែលបរិភោគ ក៏រមែងប្រឡាក់ប្រឡូស នូវដៃ បបូរមាត់ អណ្ដាត និង ពិតាន, ដៃ បបូរមាត់ អណ្ដាត និង ពិតានទាំងឡាយណា សូម្បីគេលាងហើយ ក៏ត្រូវតែលាងម្ដងហើយម្ដងទៀត ដើម្បីប្រយោជន៍ដល់ការបំបាត់ក្លិន ដៃ បបូរមាត់ អណ្ដាត និង ពិតានទាំងឡាយនោះ ជារបស់បដិកូលហើយ ព្រោះត្រូវអាហារនោះប្រឡាក់ប្រឡូសហើយ, អាហារនោះ កាលបុគ្គលបរិភោគចូលទៅហើយ រមែងចំអិននូវកាយឲ្យប៉ោងឡើង ដោយភ្លើងធាតុក្នុងរាងកាយ ដែលផាត់ប្រានទៅសព្វសរីរៈទាំងមូល ហើយក៏ផុសឡើង ប្រឡាក់ប្រឡូសនូវធ្មេញទាំងឡាយ ដោយភាពជាអាចម៍ធ្មេញ តែងប្រឡាក់ប្រឡូសចាប់ដើមអំពីអណ្ដាត និង ពិតានទៅ ដោយភាពជាទឹកមាត់ និង ស្លេស្មជាដើម តែងប្រឡាក់ប្រឡូសនូវទ្វារទាំងឡាយ មានរន្ធភ្នែក រន្ធត្រចៀក រន្ធប្រមុះ និង ទ្វារខាងក្រោម(ទ្វារធំ) ជាដើម ដោយភាពជាពពឹកភ្នែក អាចម៍ត្រចៀក ទឹកសំបោរ ទឹកមូត្រ និង អាហារចាស់ជាដើម ប្រៀបដូចជាកាលបើបាយត្រូវគេចំអិន របស់ដែលជាកាកសំណល់ទាំងឡាយ មានអង្កាម កន្ទក់ និង ទឹកបាយ រមែងផុសឡើងមកប្រឡាក់នូវក្របមាត់ឆ្នាំង និង គម្របឆ្នាំង ដូច្នោះ, ក្នុងទ្វារទាំងឡាយណា ព្រោះលាងទ្វារមួយ ដៃជារបស់ដែលត្រូវលាងដោយទឹកម្ដងទៀត ព្រោះលាងទ្វារមួយ ដៃសូម្បីលាង ដោយលាមកគោខ្លះ ដោយដីខ្លះ ដោយលំអិតគ្រឿងក្រអូបខ្លះ រហូតដល់ពីរបីដង ក៏មិនប្រាសចាកអំពីភាពបដិកូលបានឡើយ ទ្វារទាំងឡាយនេះនោះ ដែលអាហារប្រឡាក់ហើយ សូម្បីជាលាងសំអាត រាល់ៗ ថ្ងៃ ក៏រមែងជារបស់មិនស្អាត ជា

របស់មិនជាទីគាប់ចិត្តដដែល” ដូច្នេះ ។

(អាហារេបដិកូលសញ្ញាឈាន)

កាលព្រះយោគី ពិចារណាឃើញនូវភាពបដិកូល ដោយអាការៈទាំង ១០ យ៉ាងនេះ ធ្វើទុកក្នុងចិត្ត ឲ្យជាធម្មជាតគឺសេចក្ដីត្រិះរិះស្ទួយឡើងហើយ ឲ្យជាធម្មជាតគឺសេចក្ដីរិះគិតស្ទួយឡើងហើយ, កពឡិង្ការាហារ រមែងប្រាកដ ដោយអំណាចនៃអាការៈបដិកូល ។ ព្រះយោគីនោះ សេព ចំរើន ធ្វើឲ្យច្រើន នូវនិមិត្តនោះ ជារឿយៗ ។ កាលព្រះយោគីនោះ ធ្វើយ៉ាងនេះ នីវរណៈទាំងឡាយ រមែងស្ងប់រម្ងាប់ ។ ចិត្តរមែងតាំងនៅមាំ ដោយឧបចារសមាធិ ដែលមិនដល់នូវអប្បនា ព្រោះកពឡិង្ការាហារជាគម្ពីរភាពជ្រាលជ្រៅតាមសភាពជាធម្មតា ។ តែសញ្ញាក្នុងកពឡិង្ការាហារនុ៎ះ រមែងប្រាកដ ដោយអំណាចនៃការកាន់យក នូវអាការៈបដិកូល ។ ព្រោះហេតុនោះ កម្មដ្ឋាននេះ ដល់ហើយនូវការរាប់ថា “អាហារេបដិកូលសញ្ញា” ដូច្នេះ ។

(អានិសង្សនៃអាហារេបដិកូលសញ្ញា)

ក៏ចិត្តរបស់ភិក្ខុអ្នកប្រកបរឿយៗ នូវសេចក្ដីសំគាល់ថាជារបស់គួរខ្ពើម ក្នុងអាហារនេះ រមែងថយចុះ រមែងរួញ រមែងបដិវត្តិ ចាកសេចក្ដីចំណង់ក្នុងរស ។ ព្រះយោគីនោះជាអ្នកប្រាសចាកសេចក្ដីស្រវឹងលេបនូវអាហារ គ្រាន់តែដើម្បីជាប្រយោជន៍ដល់ការរលាស់នូវទុក្ខចេញ ដូចជាបុគ្គលអ្នកត្រូវការឆ្លងផ្លូវឆ្ងាយ ស៊ីនូវសាច់កូនដូច្នោះ ។ បន្ទាប់មកតម្រេក ដែលប្រព្រឹត្តទៅ ក្នុងបញ្ចកាមគុណ របស់ព្រះយោគីនោះ ក៏រមែងដល់នូវការកំណត់ដឹង ដោយមិនពិបាកឡើយ ព្រោះមានការកំណត់ដឹងនូវកពឡិង្ការាហារជាប្រធាន ។ ព្រះយោគីនោះ រមែងកំណត់

ដឹងនូវរូបក្ខន្ធបាន ព្រោះមានការកំណត់ដឹងនូវបញ្ចកាមគុណជាប្រធាន ។ មួយទៀត សូម្បីការចំរើនកាយគតាសតិ របស់ព្រះយោគីនោះ ក៏រមែងដល់នូវការពេញបរិបូណ៌ ដោយអំណាចនៃភាពបដិកូល មានអាហារដែលមិនទាន់រលួយជាដើមផង។ ព្រះយោគីនោះជាអ្នកបដិបត្តិនូវសេចក្តីបដិបត្តិដែលអនុលោម ដល់អសុភសញ្ញាផង ។ ម្យ៉ាងទៀត ព្រះយោគីនោះ អាស្រ័យនូវសេចក្តីប្រតិបត្តិនេះហើយ កាលមិនទាន់បានសំរេចនូវទីបំផុតគឺព្រះនិព្វាន ក្នុងបច្ចុប្បន្ននេះទេ រមែងជាអ្នកមានសុគតិ ប្រព្រឹត្តទៅ ក្នុងខាងមុខ ។

នេះជាកថាដោយពិស្តារក្នុងការចំរើនអាហារេបដិកូលសញ្ញា ។

ចតុធាតុវវដ្ឋាន

(២១៣) ក្នុងកាលឥឡូវនេះ ការសំដែងចេញនូវការចំរើន នូវកិរិយាកំណត់នូវធាតុបួន ដែលលោកសំដែងហើយ បន្ទាប់អំពីអាហារេបដិកូលសញ្ញា ថា "វវដ្ឋាន ១" ដូច្នេះ មកដល់ហើយដោយលំដាប់ ។

(ពាក្យអធិប្បាយបទមាតិកា)

វិនិច្ឆ័យក្នុងបទមាតិកានោះ បទថា "វវដ្ឋាន" បានដល់សន្និដ្ឋានដោយអំណាចការកំណត់ឃើញសភាវៈ (របស់វា) ។ ការកំណត់មើលធាតុទាំង ៤ ឈ្មោះថា ចតុធាតុវវដ្ឋាន ។ ពាក្យថា "ធាតុមនសិការ ធាតុកម្មដ្ឋាន ចតុធាតុវវដ្ឋាន" ដោយសេចក្តី គឺតែមួយទេ ។

(ចតុធាតុវវដ្ឋាន ២ យ៉ាង)

ចតុធាតុវវដ្ឋាននេះនោះ មកហើយ ២ យ៉ាងគឺ ដោយសង្ខេប ១ ដោយពិស្តារ ១ ។ ចតុធាតុវវដ្ឋាន ដោយសង្ខេបនោះ មកហើយ ក្នុងមហាសតិបដ្ឋានសូត្រ ដោយពិស្តារមកហើយក្នុងមហាហត្ថិបទុបមសូត្រ

ក្នុងរាហុលោវាទសូត្រ និង ក្នុងធាតុវិភង្គសូត្រ ។

(ចតុធាតុវវដ្ឋានដោយសង្ខេប)

មែនពិត ចតុធាតុវវដ្ឋាននោះ មកហើយ ដោយសង្ខេប ក្នុងមហាសតិបដ្ឋានសូត្រ ដោយអំណាចនៃបុគ្គលអ្នកចំរើនធាតុកម្មដ្ឋាន ជាអ្នកមានបញ្ញាដ៏ខ្លាំងក្លា យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ បុរសអ្នកពិឃាតគោក្តី កូនសិស្សនៃបុរសអ្នកពិឃាតគោក្តី ដែលប៉ិនប្រសប់ គប្បីពិឃាតគោហើយរំលែកជាចំណែកៗ អង្គុយទៀបផ្លូវធំបែកជាបួន មានឧបមាដូចម្តេចមិញ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់ នូវកាយនេះឯង ដែលឋិតនៅយ៉ាងណា ដែលតាំងនៅយ៉ាងណា ដោយកំណត់ថា គ្រាន់តែជាធាតុដូច្នេះថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ មានឧបមេយ្យយ៉ាងដូច្នោះឯង [១] " ។

(ពង្រីកសេចក្តីនៃព្រះសូត្រ)

សេចក្តីនៃព្រះសូត្រនោះថា "បុរសអ្នកពិឃាតគោ ឬ កូនសិស្សនៃបុរសអ្នកពិឃាតគោនោះឯង ដ៏ប៉ិនប្រសប់ ដែលគេជួលដោយបាយនិងថ្លៃឈ្នួល គប្បីសម្លាប់នូវគោហើយ រំលែកធ្វើឲ្យទៅជាចំណែកៗ អង្គុយទៀបផ្លូវធំបែកជាបួន ពោលគឺត្រង់ទីកណ្តាល នៃផ្លូវធំទាំងឡាយ ដែលទៅកាន់ទិសទាំងឡាយបួន យ៉ាងណាមិញ, ភិក្ខុ ក៏យ៉ាងដូច្នោះដែរ ពិចារណានូវកាយដែលឈ្មោះថា ឋិតនៅយ៉ាងណា ព្រោះឋិតនៅ ដោយអាការៈឯណានីមួយ នៃឥរិយាបថទាំងបួន ឈ្មោះថាតាំងនៅយ៉ាងណា ព្រោះតាំងនៅយ៉ាងណានោះឯង ដោយកំណត់ថាគ្រាន់តែជាធាតុ យ៉ាងដូច្នេះថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់" ។

១- សុ. ទី. ម. ភាគទី ១៧ ទំព័រទី ២៥៤ ។

សួរថា: តើមានសេចក្ដីអធិប្បាយដូចម្ដេច? ។ ឆ្លើយថា: កាលបើបុរសអ្នកពិឃាតគោ ចិញ្ចឹមបំប៉នគោក្ដី ដឹក(វា)យកទៅកាន់ទីសម្លាប់ក្ដី លុះដឹកទៅដល់ហើយ ក៏ចងក្រៀកទុក ក្នុងទីសម្លាប់នោះក្ដី កំពុងតែសម្លាប់ក្ដី ឃើញគោត្រូវបានគេសម្លាប់ ស្លាប់ហើយក្ដី, សេចក្ដីសម្គាល់ថា "គោ" មិនទាន់សាបសូន្យបាត់ទេ ដរាបណាដែលគេមិនទាន់បានពន្លះវះវា រំលែកជាចំណែកៗ, ប៉ុន្តែកាលបើរំលែកហើយ (យកទៅ) អង្គុយ (លក់) សេចក្ដីសម្គាល់ថា "គោ" ទើបបាត់ទៅ រមែងសម្គាល់ថាជាសាច់ទៅវិញ ។ សេចក្ដីនឹកគិត ថា "អញលក់គោ មនុស្សទាំងនេះនាំយកគោទៅ" យ៉ាងនេះ មិនមាន ដល់បុរសនោះឡើយ ។ តែតាមពិតបុរសនោះ មានសេចក្ដីគិត យ៉ាងនេះថា "អញលក់សាច់ ឯមនុស្សទាំងនេះ (ទិញ)យកសាច់ទៅ" យ៉ាងណាមិញ, សូម្បីកាលភិក្ខុរូបនេះ នៅជាគ្រហស្ថក្ដី បួសហើយក្ដី ក្នុងកាលមុន ក្នុងពេលដែលនៅជាបុថុជ្ជនល្ងង់ខ្លៅនៅឡើយ សេចក្ដីសម្គាល់ថា "ជាសត្វ ជាបុរស ជាបុគ្គល" មិនទាន់បាត់ទៅ ដរាបណាដែលភិក្ខុនោះ មិនទាន់ពិចារណានូវកាយនេះឯង ដែលឋិតនៅ យ៉ាងណា ដែលខ្លួនតាំងទុកហើយ យ៉ាងណា ដោយធាតុ បំបែកដុំឲ្យទៅជាផ្នែកៗ ក៏ប៉ុន្តែកាលបើភិក្ខុពិចារណា ដោយធាតុ សេចក្ដីសម្គាល់ថា សត្វ ទើបបាត់ទៅ, ចិត្ត រមែងតាំងនៅ ដោយថាគ្រាន់តែជាធាតុតែប៉ុណ្ណោះ ។ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បុរសអ្នកពិឃាតគោ ដែលប៉ិនប្រសប់ ។ល។ គប្បីអង្គុយទៀបផ្លូវធំបែកជាបួន មានឧបមាយ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់ នូវកាយនេះឯង ។ល។ ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់" ។

(២១៤) ចំណែកក្នុងមហាហត្ថិបទូបមសូត្រ មកហើយ ដោយពិស្ដារ ដោយអំណាចនៃបុគ្គលអ្នកចំរើនធាតុកម្មដ្ឋាន ដែលជាអ្នកមិនមានប្រាជ្ញាចាស់ក្លាពេក យ៉ាងនេះ គឺ :

"ម្នាលអ្នកទាំងឡាយមានអាយុ បឋវីធាតុខាងក្នុង តើដូចម្ដេច? ធាតុណាជាខាងក្នុង អាស្រ័យនឹងខ្លួន ជារបស់រឹង ជារបស់គ្រោតគ្រាត ដែលវិញ្ញាណចូលទៅកាន់យក គឺសក់ទាំងឡាយ រោមទាំងឡាយ ក្រចកទាំងឡាយ ធ្មេញទាំងឡាយ ។ល។ អាហារថ្មី អាហារចាស់ ឬក៏ធាតុដទៃណាមួយ ជាខាងក្នុង អាស្រ័យនឹងខ្លួន ជារបស់រឹង ជារបស់គ្រោតគ្រាត ដែលវិញ្ញាណចូលទៅកាន់យក ម្នាលអ្នកទាំងឡាយមានអាយុ នេះហៅថា បឋវីធាតុ ខាងក្នុង [១] " ។

និងថា "ម្នាលអ្នកទាំងឡាយមានអាយុ អាបោធាតុ ខាងក្នុង តើដូចម្ដេច? ធាតុណាដែលជាខាងក្នុង ដែលអាស្រ័យនូវខ្លួន ជាទឹក ឬមានសភាពប្រហែលនឹងទឹក ដែលវិញ្ញាណចូលទៅកាន់យក គឺប្រមាត់ ស្លេស្ម ។ល។ ទឹកមូត្រ ឬក៏ ធាតុដទៃណានីមួយជាខាងក្នុង ដែលអាស្រ័យនូវខ្លួន ជាទឹក ឬ មានសភាពប្រហែលនឹងទឹក ដែលវិញ្ញាណចូលទៅកាន់យក ម្នាលអ្នកទាំងឡាយមានអាយុ នេះហៅថា អាបោធាតុ ខាងក្នុង [២] " ។

និងថា "ម្នាលអ្នកទាំងឡាយមានអាយុ តេជោធាតុ ខាងក្នុងតើដូចម្ដេច? ធាតុណាដែលជាខាងក្នុង ដែលអាស្រ័យនឹងខ្លួន ជាភ្លើង ឬមានសភាពប្រហែលនឹងភ្លើង ដែលវិញ្ញាណចូលទៅកាន់យក គឺតេជោ-ធាតុ ដែលញ៉ាំងកាយឲ្យក្ដៅសព្វ ១ តេជោធាតុ ដែលធ្វើកាយ ឲ្យគ្រាំ

១- សុ. ម. មូ. ភាគទី ២១ ទំព័រទី ១៩៩, ២- ទំព័រទី ២០០ ។

គ្រា ១ តេជោធាតុ ដែលដុតកាយឲ្យក្រហល់ក្រហាយ ១ តេជោធាតុ សម្រាប់ដុតកោជនដែលបុគ្គលស៊ី ផឹក ទំពាស៊ី ជញ្ជក់ជញ្ជាប់ ឲ្យទ្រុឌទ្រោម ទៅដោយប្រពៃ ១ មួយទៀត ធាតុដទៃណានីមួយ ជាខាងក្នុង ដែលអាស្រ័យនូវខ្លួន ជាភ្លើង ឬ មានសភាពប្រហែលនឹងភ្លើង ដែលវិញ្ញាណចូលទៅកាន់យក ម្នាលអ្នកទាំងឡាយមានអាយុ នេះហៅថា តេជោធាតុ ខាងក្នុង ” ។

និង ថា “ម្នាលអ្នកទាំងឡាយមានអាយុ វាយោធាតុ ជាខាងក្នុង តើដូចម្តេច? ធាតុណាដែលជាខាងក្នុង ដែលអាស្រ័យនូវខ្លួន ជាខ្យល់ ឬ មានសភាពប្រហែលនឹងខ្យល់ ដែលវិញ្ញាណចូលទៅកាន់យក គឺ ខ្យល់បក់ឡើងលើ ១ ខ្យល់បក់ចុះក្រោម ១ ខ្យល់បក់នៅក្នុងផ្ទៃ គឺបក់ខាងក្រៅពោះវៀន ១ ខ្យល់បក់ក្នុងពោះវៀន ១ ខ្យល់បក់សព្វសព៌ាង្គកាយ ១ ខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញ ១ មួយវិញទៀត វាយោធាតុដទៃណានីមួយ ជាខាងក្នុង អាស្រ័យនូវខ្លួន ជាខ្យល់ ឬ មានសភាពប្រហែលនឹងខ្យល់ ដែលវិញ្ញាណចូលទៅកាន់យក ម្នាលអ្នកទាំងឡាយមានអាយុ នេះហៅថា វាយោធាតុខាងក្នុង ” ។

ក៏ចតុធាតុវវដ្ឋាន ក្នុងមហាហត្ថិបទុបមសូត្រនេះ យ៉ាងណាមិញ សូម្បីក្នុងរាហុលោវាទសូត្រ និង ធាតុវិភង្គសូត្រ ក៏យ៉ាងនោះដែរ ។

(អធិប្បាយក្នុងមហាហត្ថិបទុបមសូត្រ)

(២១៥) នេះជាពាក្យកែបទដែលជ្រៅ ក្នុងព្រះសូត្រនោះ ។ ជាបឋម បទថា “អជ្ឈត្តំ បច្ចត្តំ” ទាំងពីរនេះ ជាឈ្មោះ នៃនិយកស័ព្ទ ។ ធម្មជាតដែលកើត ក្នុងខ្លួន សេចក្តីថា អាស្រ័យនៅក្នុងសន្តានរបស់ខ្លួន ឈ្មោះថា និយកៈ ។ និយកៈ នេះនុ៎ះ លោកហៅថា “អជ្ឈត្តំ” ព្រោះ

របស់នោះប្រព្រឹត្តទៅ ក្នុងខ្លួន លោកហៅថា “បច្ចត្តំ” ព្រោះរបស់នោះ អាស្រ័យនូវខ្លួនប្រព្រឹត្តទៅ ដូចជាពាក្យ ក្នុងពួកស្ត្រីទាំងឡាយ ក្នុងលោក គេហៅថា អធិត្ថី យ៉ាងនោះឯង ។

បទថា “កក្ខឡំ” ប្រែថា រឹង ។ បទថា “ខរិគតំ” ប្រែថា គ្រោតគ្រាត ។ បណ្តាបទទាំង ២ នោះ បទទី ១ ប្រាប់នូវលក្ខណៈ បទទី ២ ប្រាប់នូវអាការៈ ។ ព្រោះបឋវីធាតុ មានលក្ខណៈរឹង ។ បឋវីធាតុនោះ មានអាការៈគ្រោតគ្រាត ព្រោះហេតុនោះ ទើបលោកពោលថា “កក្ខឡំ ខរិគតំ” ។

បទថា “ឧបាទិន្នំ” ប្រែថា ប្រកាន់ខ្ជាប់ អធិប្បាយថា កាន់យក ប្រកាន់ខ្ជាប់ ប្រកាន់យក យ៉ាងជាប់ ថា អញ ថា របស់អញ ។

បទថា “សេយ្យថីទំ” ជានិបាត ។ និបាតនោះ មានសេចក្តីថា សួរថា របស់នោះ តើដូចម្តេច ? ។ បន្ទាប់អំពីនោះ លោកកាលសំដែង សេចក្តីសួរនោះ ទើបពោលថា “កេសា លោមា” ប៉ុណ្ណេះជាដើម ។

ក៏ក្នុងបឋវីធាតុនេះ គប្បីជ្រាបថា : បឋវីធាតុ លោកសំដែង ដោយអាការៈ ២០ ព្រោះមន្ថែមមត្ថលុង្គំ (ខួរក្នុងក្បាល) ។ បឋវីធាតុ លោកសង្គ្រោះហើយ ក្នុងចំណែកទាំងឡាយ បី ដ៏សេស ដោយបទថា “យំ វា បនញ្ញម្បិ កិញ្ចិ” ។

(អាបោ)

របស់ណា ជ្រួតជ្រាប គឺទៅដល់ទីនោះៗ ដោយអំណាចនៃការហូរទៅ ព្រោះហេតុនោះ របស់នោះ ឈ្មោះថា អាបោ ។ របស់ណា ទៅក្នុងអាបោទាំងឡាយ ដែលមានប្រការផ្សេងៗ ដោយអំណាចនៃសមុដ្ឋាន មានកម្មសមុដ្ឋានជាដើម ព្រោះហេតុនោះ របស់នោះ ទើបឈ្មោះថា

អាបោគតៈ (ប្រហែលនឹងទឹក) ។ របស់នោះ បានដល់អ្វី? ។ បានដល់លក្ខណៈ គឺការជ្រួតជ្រាប នៃអាបោធាតុ ។

(តេជោ)

របស់ដែលឈ្មោះថា ភ្លើង ព្រោះអំណាចនៃការធ្វើឲ្យក្តៅ ។ វត្ថុណា ទៅហើយ ក្នុងតេជោទាំងឡាយ ដោយន័យដែលបានពោលមកហើយនុ៎ះឯង ព្រោះហេតុនោះ វត្ថុនោះ ទើបឈ្មោះថា តេជោគតៈ (ប្រហែលនឹងភ្លើង) ។ វត្ថុនោះ បានដល់អ្វី ? ។ វត្ថុនោះ បានដល់លក្ខណៈ គឺជារបស់ដែលក្តៅ ។

ពាក្យថា "យេន ច" សេចក្តីថា រាងកាយនេះ រមែងក្តៅសព្វ គឺកើតជំហាយក្តៅ ដោយភាពជាគ្រុនមានគ្រុនមួយថ្ងៃជាទៅវិញជាដើម ព្រោះតេជោគតៈឯណាមួយដែលកំរើកឡើង ។

ពាក្យថា "យេន ច ជីរិយតិ" សេចក្តីថា រាងកាយនេះ តែងទ្រុឌទ្រោមទៅ គឺតែងដល់នូវភាពជាអ្នកមានឥន្ទ្រីយ៍មិនគ្រប់គ្រាន់ នូវភាពអស់កម្លាំងកំហែង និង នូវភាពជាអ្នកមានស្បែកជ្រីវជ្រួញ និងមានសក់ស្កូវជាដើម ព្រោះតេជោគតៈឯណាមួយ ។

ពាក្យថា "យេន ច ជបរិទយ្ហតិ" សេចក្តីថា រាងកាយនេះ តែងក្រហល់ក្រហាយ ព្រោះតេជោគតៈឯណាមួយដែលកំរើកហើយ ។ ក៏បុគ្គលនោះ កន្ទក់កន្ទេញថា "អាត្មាអញក្តៅមែន អាត្មាអញក្តៅមែន" ប្រាថ្នាចង់បាននូវថ្នាំសំរាប់ព្យាបាលកំដៅ មានសតធោតសប្បី (ទឹកដោះថ្លាដែលគេរំងាស់ហើយយកទៅត្រាំទឹកៗ មួយរយដង) នូវគោសីតចន្ទន៍ (ប្រេងច័ន្ទន៍ ដែលគេផ្សំដោយទឹកដោះគោ) ជាដើម និង នូវខ្យល់ដែលបក់ចេញអំពីផាងត្នោតផង ។

ពាក្យថា "យេន ច អសិតបីតខាយិតសាយិតំ សម្មា បរិណាមំ គច្ឆតិ" សេចក្តីថា របស់ដែលបុគ្គលស៊ី មានបាយជាដើមក្តី របស់ដែលបុគ្គលផឹក មានទឹកបានៈជាដើមក្តី របស់ដែលបុគ្គលទំពាស៊ី មាននំអំបែងជាដើមក្តី របស់ដែលបុគ្គលជញ្ជក់ជញ្ជាប់ មានស្វាយទុំ ទឹកឃ្មុំ និង ទឹកអំពៅជាដើមក្តី នោះ រមែងដល់នូវការរលួយទៅ យ៉ាងស្រួល អធិប្បាយថា រមែងដល់នូវការបែងចែកទៅ ដោយភាវៈមានរសជាដើម ដោយតេជោគតៈ ឯណាមួយ ។

ក៏ក្នុងអាការៈ ៤ យ៉ាងនុ៎ះ អាការៈ ៣ ខាងដើម មានតេជោធាតុជាសមុដ្ឋាន អាការៈចុងក្រោមគេ មានកម្មជាសមុដ្ឋានមែនពិត ។

(វាយោ)

ធម្មជាតដែលឈ្មោះថា វាយោ ព្រោះអំណាចនៃការបក់ផាត់ ។ វត្ថុណា ទៅក្នុងវាយោទាំងឡាយ ដោយន័យដែលបានពោលមកហើយនុ៎ះឯង ព្រោះហេតុនោះ វត្ថុនោះ ឈ្មោះថា វាយោគតៈ (ប្រហែលនឹងខ្យល់) ។ វត្ថុនោះ បានដល់អ្វី ? ។ វត្ថុនោះ បានដល់លក្ខណៈ គឺការកំរើក ។

ពាក្យថា "ឧទ្ធង្គមា វាតា" គឺខ្យល់ដែលបក់ទៅខាងលើ ញុំាងអាការៈមានគ្រើ និង ត្រអើកជាដើម ឲ្យប្រព្រឹត្តទៅ ។ ពាក្យថា "អធោគមា វាតា" គឺខ្យល់ដែលបក់ចុះមកក្រោម នាំយកឧច្ចារៈ និង បស្សាវៈជាដើមឲ្យចេញមក ។ បទថា "កុច្ឆិសយា វាតា" គឺខ្យល់នៅខាងក្រៅពោះវៀន ។ បទថា "កោដ្ឋាសយា វាតា" គឺខ្យល់ខាងក្នុងពោះវៀន ។ បទថា "អង្គមង្គានុសារិនោ វាតា" គឺខ្យល់ដែលបក់ទៅតាមសព្វសពាង្គកាយតូចធំ ក្នុងសរីរៈទាំងមូល តាមខ្សែសរសៃឈាម ញុំាងការ

បត់ និង ការលាតចេញ (នូវអវយវៈ) ជាដើម ឲ្យកើតឡើង ។ បទថា “អស្សាសោ” បានដល់ ខ្យល់ដកដង្ហើមចូលទៅឰដ៏ខាងក្នុង ។ បទថា “បស្សាសោ” បានដល់ ខ្យល់ដកដង្ហើមចេញទៅខាងក្រៅ ។

ក៏ក្នុងខ្យល់ ៦ យ៉ាងនេះ ខ្យល់ ៥ ខាងដើម ជាចតុសមុដ្ឋាន (គឺមានចិត្ត កម្ម រដូវ និង អាហារជាសមុដ្ឋាន) ខ្យល់អស្សាសៈ និង បស្សាសៈ មានចិត្តជាសមុដ្ឋានតែម្យ៉ាង ។

ដោយបទថា “យំ វា បនញ្ញម្បិកិញ្ចិ” នេះ គឺលោកសង្គ្រោះអាបោធាតុជាដើម ក្នុងចំណែកដ៏សេសទាំងឡាយ ក្នុងនិទ្ទេសទាំងពួង ។

ដោយប្រការដូចពោលមកនេះ ធាតុទាំង៤ គឺលោកធ្វើឲ្យពិស្តារហើយ ដោយអាការៈទាំងឡាយ ៤២ គឺ បឋវីធាតុ ដោយអាការៈ ២០ អាបោធាតុ ដោយអាការ ១២ តេជោធាតុ ដោយអាការៈ ៤ វាយោធាតុ ដោយអាការៈ ៦ យ៉ាងនេះឯង ។ នេះជាការពណ៌នាសេចក្តីនៃបាលី ក្នុងចតុធាតុវវត្ថានទោះ ជាបឋម ។

(ភាវនានយ័ យ៉ាងសង្ខេប)

(២១៦) ចំណែកវិនិច្ឆ័យ ក្នុងភាវនានយ័ ក្នុងធាតុកម្មដ្ឋាននេះ បណ្ឌិតគប្បីជ្រាបដូចតទៅនេះ ។ សម្រាប់ភិក្ខុអ្នកមានប្រាជ្ញាខ្លាំងក្លា ការកំណត់ធាតុដោយពិស្តារថា “សក់ទាំងឡាយជាធាតុដី រោមទាំងឡាយជាធាតុដី” យ៉ាងនេះជាដើម រមែងប្រាកដ ដោយយឺតយូរ ។ ប៉ុន្តែកាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តថា “វត្ថុណា មានលក្ខណៈរឹង វត្ថុនេះ គឺធាតុដី, វត្ថុណា មានលក្ខណៈរាវជ្រួតជ្រាប វត្ថុនេះ គឺធាតុទឹក, វត្ថុណា មានលក្ខណៈក្តៅ វត្ថុនេះ គឺធាតុភ្លើង, វត្ថុណា មានលក្ខណៈកំរើកទៅបាន វត្ថុនេះ គឺធាតុខ្យល់” ដូច្នេះ, កម្មដ្ឋាន រមែងប្រាដកច្បាស់ ។ ចំណែក

ខាងសម្រាប់ភិក្ខុអ្នកមានប្រាជ្ញាមិនសូវខ្លាំងក្លាវិញ កាលបើធ្វើទុកក្នុងចិត្តយ៉ាងដូច្នេះ, កម្មដ្ឋាន រមែងងងឹតអន្ធការ មិនប្រាកដច្បាស់ ។ ទាល់តែភិក្ខុនោះធ្វើទុកក្នុងចិត្ត ដោយពិស្តារ ដោយន័យមុន ទើបកម្មដ្ឋានប្រាកដច្បាស់ ។ សេចក្តីនេះ មានឧបមាយ៉ាងដូចម្តេច? ។ មានឧបមាថា កាលបើភិក្ខុ ២ រូប ស្វាធ្យាយ នូវវិធីដែលមានបេយ្យាលច្រើន, ភិក្ខុអ្នកមានបញ្ញាខ្លាំងក្លា ញុំាងបេយ្យាលមុខ ឲ្យពិស្តារ មួយចប់ ឬ ពីរចប់ហើយបន្ទាប់មក កាលធ្វើនូវការស្វាធ្យាយ ដោយអំណាចនៃទីបំផុតទាំងពីរហ្នឹងឯង ទៅ, បណ្តាភិក្ខុទាំង ២ រូប នោះ ភិក្ខុអ្នកមានប្រាជ្ញាមិនខ្លាំងក្លា នឹងជាអ្នកពោល យ៉ាងនេះថា “នោះគឺជាការស្វាធ្យាយអ្វី មិនទាន់បានធ្វើឲ្យត្រឹមតែបបូរមាត់ប៉ះពាល់គ្នាផង, កាលបើធ្វើការស្វាធ្យាយបែបនេះពេលណាទៅ វិធីបែបបទ នឹងស្ទាត់ជំនាញបាន” ។ ភិក្ខុនោះ ញុំាងបេយ្យាលមុខដែលមកដល់ហើយៗ ឲ្យពិស្តារក្លាមៗ ហើយធ្វើនូវការស្វាធ្យាយ, ភិក្ខុក្រៅពីនេះ ក៏ពោលទៅកាន់ភិក្ខុរូបនោះ យ៉ាងនេះថា “នុ៎ះគឺជាការស្វាធ្យាយអ្វី មិនទាន់បានដល់ទីបំផុតផង កាលធ្វើការស្វាធ្យាយយ៉ាងនេះ ពេលណាទៅ របៀបបែបបទ នឹងដល់នូវទីបំផុតបាន” ដូច្នេះយ៉ាងណាមិញ, ការកំណត់ធាតុ ដោយពិស្តារ ដោយអំណាចនៃអាការៈមានសក់ជាដើម រមែងប្រាកដ យឺតយូរ សម្រាប់ភិក្ខុអ្នកមានបញ្ញាខ្លាំងក្លា, កាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្ត ដោយសង្ខេប តាមន័យថា “វត្ថុណា មានលក្ខណៈរឹង វត្ថុនេះ គឺធាតុដី” ដូច្នេះជាដើម, កម្មដ្ឋាន ទើបប្រាកដ, ចំណែកខាងភិក្ខុក្រៅពីនេះ កាលធ្វើទុកក្នុងចិត្ត យ៉ាងដូច្នោះដែរ កម្មដ្ឋាន រមែងងងឹតអន្ធការ មិនប្រាកដច្បាស់, កាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្ត ដោយពិស្តារ ដោយអំណាចនៃអាការៈមានសក់ជាដើម កម្មដ្ឋាន

រមែងប្រាកដច្បាស់ ក៏យ៉ាងនោះដែរ ។

(វិធីចំរើនធាតុកម្មដ្ឋានសំរាប់ភិក្ខុអ្នកមានបញ្ញាក្លា)

ព្រោះហេតុនោះ ភិក្ខុអ្នកមានបញ្ញាខ្លាំងក្លា ជាអ្នកប្រាថ្នានឹងចំរើនកម្មដ្ឋាននេះ ជាដំបូង គប្បីទៅក្នុងទីស្ងាត់ ពួនសម្ងំ ពិចារណានូវរូបកាយរបស់ខ្លួនទាំងមូល ហើយកំណត់នូវធាតុទាំងឡាយ ដោយសង្ខេប យ៉ាងនេះថា "ភាពជារបស់រឹងក្តី ភាពជារបស់រឹងមាំក្តី ឯណា (មាន) ក្នុងកាយនេះ នេះគឺធាតុដី, ភាពជារបស់ជ្រួតជ្រាបទៅបានក្តី ភាពជារបស់រាវក្តី ឯណា (មាន) ក្នុងកាយនេះ នេះគឺធាតុទឹក, ភាពជារបស់ចេះក្តៅ ភាពជារបស់ក្តៅ ឯណា (មាន) ក្នុងកាយនេះ នេះគឺធាតុភ្លើង, ភាពជារបស់បក់បោកក្តី ភាពជារបស់កំរើកក្តី ឯណា (មាន) ក្នុងកាយនេះ នេះគឺធាតុខ្យល់" ដូច្នេះ ហើយគប្បីនឹករំពឹងធ្វើទុកក្នុងចិត្ត ពិចារណា ដោយថាគ្រាន់តែជាធាតុ មិនមែនជាសត្វ មិនមែនជាជីវៈ ថា "ធាតុដី ធាតុទឹក" ដូច្នេះជាដើម ឲ្យបានរឿយៗ ។ កាលបើភិក្ខុនោះ ព្យាយាម យ៉ាងដូច្នេះ សមាធិ ដែលបញ្ញាបំភ្លឺនូវភាពផ្សេងគ្នានៃធាតុ កំណត់យកហើយ ជាសមាធិ មិនដល់នូវអប្បនា បានត្រឹមតែឧបចារៈ ព្រោះជាសមាធិដែលមានសភាវធម៌ជាអារម្មណ៍ រមែងកើតឡើង ដោយមិនយឺតយូរឡើយ ។

ឬបើមិនដូច្នោះទេ កោដ្ឋាស (ចំណែក) ទាំងឡាយ ៤ នេះឯណា ដែលព្រះធម្មសេនាបតី ពោលហើយ ដើម្បីជំរែងនូវភាពនៃមហាភូតរូបទាំង ៤ មិនមែនជាសត្វ ថា "អាកាស ដែលអាស្រ័យឆ្អឹងខ្លះ អាស្រ័យសរសៃខ្លះ អាស្រ័យសាច់ខ្លះ អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយទើបហៅថា រូបបាន [1] " ដូច្នោះឯង ។ ភិក្ខុ គប្បីចំណែកនូវកោដ្ឋាស

១- សុ. ម. មូ. ភាគទី ២១ ទំព័រទី ២១១ ។

ទាំងឡាយនោះ ដោយដៃគឺញាណដែលស្ទុះទៅតាមចន្លោះៗ នៃកោដ្ឋាសនោះៗ ហើយកំណត់នូវធាតុទាំងឡាយ តាមន័យខាងដើមនោះឯង ថា "ភាពជារបស់រឹងក្តី ភាពជារបស់រឹងមាំក្តី ឯណា ក្នុងកោដ្ឋាសទាំងឡាយនេះ នេះគឺជាធាតុដី" ដូច្នេះជាដើម ហើយនឹកជញ្ជឹងរំពឹងគិត ធ្វើទុកក្នុងចិត្ត ពិចារណា ដោយថាគ្រាន់តែជាធាតុ មិនមែនជាសត្វ មិនមែនជាជីវៈ ថា "ធាតុដី ធាតុទឹក" ដូច្នេះជាដើម ឲ្យបានរឿយៗ ។ កាលបើភិក្ខុនោះ ព្យាយាម យ៉ាងដូច្នោះ, សមាធិ ដែលបញ្ញាបំភ្លឺនូវភាពផ្សេងគ្នានៃធាតុ កំណត់យកហើយ ជាសមាធិ មិនដល់នូវអប្បនា បានត្រឹមតែឧបចារៈ ព្រោះជាសមាធិដែលមានសភាវធម៌ជាអារម្មណ៍ រមែងកើតឡើង ដោយមិនយឺតយូរឡើយ ។

នេះជាការនាន័យ ក្នុងចតុធាតុវវដ្ឋានដែលមកហើយដោយសង្ខេប ។

(វិត្ថារន័យ)

(២១៧) ចំណែកការនាន័យ ក្នុងចតុធាតុវវដ្ឋាន ដែលមកហើយដោយពិស្តារ បណ្ឌិតគប្បីជ្រាប ដូចតទៅនេះ ។

ក៏ព្រះយោគី អ្នកមានបញ្ញាមិនខ្លាំងក្លា ប្រាថ្នានឹងចំរើនកម្មដ្ឋាននេះ គប្បីរៀនយកនូវធាតុទាំងឡាយ ដោយពិស្តារ ដោយអាការៈទាំងឡាយ ៤២ ក្នុងសំណាក់នៃអាចារ្យ ហើយនៅក្នុងទីសេនាសនៈ មានប្រការដូចពោលមកហើយ ធ្វើកិច្ចទាំងពួងឲ្យបានសម្រេច ទៅក្នុងទីស្ងាត់ ពួនសម្ងំ គប្បីចំរើនកម្មដ្ឋាន ដោយអាការៈទាំងឡាយ ៤ យ៉ាងដូច្នេះ ថា "ដោយសសម្ភារសង្ខេប (សង្ខេបកោដ្ឋាសទាំងឡាយចូលជាពួកៗ តាមអាការៈនៃធាតុនោះៗ) ដោយសសម្ភារវិភត្តិ (ចំណែកកោដ្ឋាសនៃធាតុទាំងនោះៗ កំណត់អាការៈ ដោយឡែកអំពីគ្នា) ដោយសលក្ខណសង្ខេប (សង្ខេប

កោដ្ឋាសទាំងឡាយចូលជាពួកៗ តាមលក្ខណៈនៃធាតុនោះៗ) ដោយសលក្ខណវិភត្តិ (ចំណែកកោដ្ឋាសនៃធាតុនោះៗ កំណត់លក្ខណៈដោយឡែកអំពីគ្នា)” ។

(ចំរើនដោយសសម្ភារសង្ខេប)

ក្នុងអាការៈទាំង ៤ នោះ ចំរើន ដោយសសម្ភារសង្ខេប តើដូចម្តេច? ។ ភិក្ខុ ក្នុងសាសនានេះ កំណត់យកអាការៈរឹង ក្នុងកោដ្ឋាស ២០ ថា “បឋវីធាតុ” កំណត់យកអាការៈជ្រួតជ្រាប ដែលជារបស់រាវ ពោលគឺទឹក ក្នុងកោដ្ឋាស ១២ ថា “អាបោធាតុ” កំណត់យកកំដៅដែលជាគ្រឿងដុត ក្នុងកោដ្ឋាស ៤ ថា “តេជោធាតុ” កំណត់យកអាការៈបក់បោកទៅមក ក្នុងកោដ្ឋាស ៦ ថា “វាយោធាតុ” ។ កាលបើភិក្ខុនោះកំណត់ យ៉ាងដូច្នោះឯង, ធាតុទាំងឡាយ ក៏រមែងប្រាកដ ។ កាលបើភិក្ខុនោះ រំពឹងគិត ធ្វើទុកក្នុងចិត្តនូវធាតុទាំងឡាយនោះរឿយៗ ឧបចារ-សមាធិ រមែងកើតឡើង តាមន័យដែលបានពោលមកហើយនោះឯង ។ ក៏ប៉ុន្តែបើភិក្ខុណា ចំរើនយ៉ាងដូច្នោះ កម្មដ្ឋាន មិនបានសម្រេច, ភិក្ខុនោះគប្បីចំរើន ដោយសសម្ភារវិភត្តិចុះ ។

(ចំរើនដោយសសម្ភារវិភត្តិ)

ចំរើន ដោយសសម្ភារវិភត្តិ តើដូចម្តេច? ។ គឺជាដំបូង ភិក្ខុនោះគប្បីធ្វើនូវឧគ្គហកោសល (គឺស្ទាត់ជំនាញក្នុងការរៀនយក) ៧ ប្រការ និង មនសិការកោសល (គឺស្ទាត់ជំនាញ ក្នុងការធ្វើទុកក្នុងចិត្ត) ១០ ប្រការ ដែលបានពោលមកហើយ ក្នុងកាយគតាសតិកម្មដ្ឋាននិទ្ទេសទាំងអស់ មិនឲ្យសាបសូន្យ ហើយធ្វើវិធីដែលពោលហើយ ក្នុងកាយគតា-សតិកម្មដ្ឋាននិទ្ទេសនោះ គ្រប់យ៉ាង ចាប់ផ្តើមតាំងតែអំពីការស្វាធ្យាយ

ដោយវាចា នូវអាការទាំងឡាយ មានតចបញ្ចកៈជាដើម ក្នុងអាការៈ ៣២ ទាំងដោយអនុលោម និង បដិលោម ។ ចំណែកសេចក្តីផ្សេងគ្នាមានតែប៉ុណ្ណេះឯង ។ គឺសូម្បីធ្វើទុកក្នុងចិត្ត នូវអាការៈទាំងឡាយ មានសក់ជាដើម ដោយអំណាចពណ៌ ទ្រង់ទ្រាយ ឱកាស និង បរិច្ឆេទ ក្នុងកាយគតាសតិនោះ ត្រូវតាំកល់ចិត្តទុក ដោយអំណាចនៃបដិកូល, ក្នុងធាតុវវដ្ឋាននេះ ត្រូវតាំកល់ចិត្តទុក ដោយអំណាចនៃធាតុ ។ ព្រោះហេតុនោះ យោគាវចរភិក្ខុ លុះធ្វើទុកក្នុងចិត្តនូវអាការទាំងឡាមានសក់ជាដើមដោយ(មួយក្រុម)ប្រាំៗ ដោយអំណាចនៃពណ៌ជាដើមហើយ ក្នុងទីបំផុតគប្បីញុំាងមនសិការ ឲ្យប្រព្រឹត្តទៅ ដូចតទៅនេះ គឺ : ។

(បឋវីកោដ្ឋាស)

(កេសា)

ធម្មតា សក់ទាំងឡាយនេះ កើតហើយ ត្រង់ស្បែកដែលរុំព័ទ្ធនូវលលាដ៍ក្បាល ។ ក្នុងស្បែកដែលរុំព័ទ្ធលលាដ៍ក្បាលជាមួយនឹងសក់ទាំងឡាយនោះ ស្បែកដែលរុំព័ទ្ធលលាដ៍ក្បាល មិនដឹងឡើយថា សក់ទាំងឡាយ កើតហើយលើអញ, ឯសក់ទាំងឡាយ ក៏មិនដឹងដែរថា អញកើតហើយ លើស្បែកដែលរុំព័ទ្ធលលាដ៍ក្បាល ប្រៀបដូចជា ក្នុងស្មៅដ៏ល្អិតទាំងឡាយ ដែលកើតហើយ លើក្បាលដំបូក ក្បាលដំបូក ក៏មិនដឹងថា ស្មៅដ៏ល្អិតទាំងឡយ កើតហើយ លើអញ, ចំណែកឯស្មៅដ៏ល្អិតទាំងឡាយ ក៏មិនដឹងផងដែរថា អញកើតហើយ លើក្បាលដំបូកយ៉ាងដូច្នោះឯង ។ ធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាដល់គ្នានឹងគ្នា ។ ធម្មតាសក់ទាំងឡាយ ជាកោដ្ឋាស ផ្នែកមួយក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ

ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(លោមា)

(២១៨) រោមទាំងឡាយ កើតហើយ លើស្បែករុំព័ទ្ធសរីរៈ ។ បណ្ដាស្បែករុំព័ទ្ធសរីរៈ និង រោមទាំងឡាយនោះ ស្បែករុំព័ទ្ធសរីរៈ មិនដឹងថា រោមទាំងឡាយ កើតហើយ លើអញ, ចំណែកឯរោមទាំងឡាយ ក៏មិនដឹងផងដែរថា អញ កើតហើយលើស្បែករុំព័ទ្ធសរីរៈ ប្រៀបដូចជា ក្នុងស្មៅរណ្ដាសទាំងឡាយ ដែលកើត ត្រង់ទីកន្ទេលផ្ទះដែលស្ងាត់ ទីកន្ទេលផ្ទះដែលស្ងាត់ ក៏មិនដឹងថា ស្មៅរណ្ដាស កើតហើយ លើអញ, ចំណែកឯស្មៅរណ្ដាសសោត ក៏មិនដឹងផងដែរថា អញកើតហើយ ត្រង់កន្ទេលផ្ទះដែលស្ងាត់ យ៉ាងដូច្នោះឯង ។ ធម៌ទាំងនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតារោមទាំងឡាយ ជាចំណែកមួយដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដូច្នេះឯង ។

(នខា)

ក្រចកទាំងឡាយ កើតហើយ លើចុងនៃម្រាមដៃទាំងឡាយ ។ បណ្ដាម្រាមដៃ និង ក្រចកទាំងឡាយនោះ ម្រាមដៃទាំងឡាយ មិនដឹងថា ក្រចកទាំងឡាយ កើតហើយលើចុងរបស់អញ, ឯក្រចកទាំងឡាយវិញ ក៏មិនដឹងផងដែរថា អញ កើតហើយ លើចុងម្រាមដៃទាំងឡាយ ប្រៀបដូចជា នាកាលកុមារទាំងឡាយ យកឈើទៅដោត គ្រាប់មាក់សាងទាំងឡាយ ហើយលេង, ឈើទាំងឡាយ មិនដឹងថា គ្រាប់មាក់សាង ជាប់ហើយលើអញ, ចំណែកឯគ្រាប់មាក់សាង ក៏មិនដឹងផងដែរថា អញ ជាប់ហើយ លើឈើទាំងឡាយ យ៉ាងដូច្នោះឯង ។ ធម៌ទាំងឡាយនុ៎ះ

ប្រាសចាកការរំពឹងគិត និងការពិចារណាទៅវិញទៅមក ។ ធម្មតាក្រចកទាំងឡាយ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(ទន្តា)

ធ្មេញទាំងឡាយ កើតហើយ ត្រង់ឆ្អឹងចង្ការទាំងឡាយ ។ បណ្ដាឆ្អឹងចង្ការ និង ធ្មេញទាំងឡាយនោះ ឆ្អឹងចង្ការ មិនដឹងថា ធ្មេញទាំងឡាយ កើតហើយ លើអញ, ចំណែកឯធ្មេញទាំងឡាយ ក៏មិនដឹងផងដែរថា អញ កើតហើយ ក្នុងឆ្អឹងចង្ការទាំងឡាយ ប្រៀបដូចជា ក្នុងសសរដែលពួកជាងឈើទាំងឡាយ លាបដោយជ័រស្អិត ឯណានីមួយហើយ ដាក់ទៅក្នុងរណ្ដៅថ្មទាំងឡាយ រណ្ដៅទាំងឡាយ មិនដឹងថា សសរទាំងឡាយ តាំងនៅហើយ លើអញ, ចំណែកឯសសរទាំងឡាយវិញ ក៏មិនដឹងផងដែរថា អញ តាំងនៅហើយ ក្នុងរណ្ដៅទាំងឡាយ យ៉ាងដូច្នោះឯង ។ ធម្មតាធម៌ទាំងនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាធ្មេញទាំងឡាយ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(តចោ)

ស្បែក រុំព័ទ្ធសរីរៈទាំងមូល ហើយតាំងនៅ ។ បណ្ដាសរីរៈ និង ស្បែកទាំងនោះ សរីរៈ មិនដឹងថា អញ គឺស្បែករុំព័ទ្ធហើយ, ចំណែកឯស្បែកវិញ ក៏មិនដឹងផងដែរថា សរីរៈ ត្រូវអញរុំព័ទ្ធហើយ ប្រៀបដូចជា បណ្ដាពិណធំ ដែលរុំព័ទ្ធដោយស្បែកគោទទឹក ពិណធំ មិនដឹងថា អញ

ត្រូវស្បែកគោទទឹក រុំព័ទ្ធហើយ, ចំណែកស្បែកគោទទឹក ក៏មិនដឹងផងដែរថា ពិណាធំ ត្រូវអញរុំព័ទ្ធហើយ យ៉ាងដូច្នោះឯង ។ ធម្មតាធម៌ទាំងនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាស្បែក ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(មំសំ)

សាច់ បូកលាបតាមគ្រោងឆ្អឹង ហើយតាំងនៅ ។ បណ្តាសាច់ និង គ្រោងឆ្អឹងទាំងនោះ គ្រោងឆ្អឹងមិនដឹងថា អញ ត្រូវប្រភេទនៃសាច់ ៩០០ ដុំ បូកលាបហើយ, ចំណែកឯសាច់វិញ ក៏មិនដឹងដែរថា គ្រោងឆ្អឹង ត្រូវអញបូកលាបហើយ ប្រៀបដូចជា បណ្តាជញ្ជាំងផ្ទះដែលគេបូកលាបហើយ ដោយដីស្អិតដុំធំ ជញ្ជាំង មិនដឹងថា អញ ត្រូវដីស្អិតដុំដ៏ធំបូកហើយ, ចំណែកឯដីស្អិតដុំធំវិញ ក៏មិនដឹងផងដែរថា ជញ្ជាំង ត្រូវអញបូកហើយ យ៉ាងដូច្នោះឯង ។ ធម្មតាធម៌ទាំងនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាសាច់ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(សរសៃ)

សរសៃទាំងឡាយ រួបរឹតឆ្អឹងទាំងឡាយ តាំងនៅ ក្នុងចន្លោះ នៃសរីរៈ ។ បណ្តាសរសៃ និងឆ្អឹងទាំងនោះ ឆ្អឹងទាំងឡាយមិនដឹងថា អញ ត្រូវសរសៃទាំងឡាយរួបរឹតហើយ, ចំណែកឯសរសៃទាំងឡាយ ក៏មិនដឹងផងដែរថា ឆ្អឹងទាំងឡាយ ត្រូវអញរួបរឹតហើយ ប្រៀបដូចជា បណ្តា

ឈើជញ្ជាំងទាំងឡាយដែលគេចងដោយវល្លិ៍ទាំងឡាយ ឈើជញ្ជាំងទាំងឡាយ មិនដឹងថា អញ ត្រូវវល្លិ៍ទាំងឡាយ រួបរឹតហើយ, ចំណែកវល្លិ៍ទាំងឡាយវិញ ក៏មិនដឹងផងដែរថា ឈើជញ្ជាំងទាំងឡាយ ត្រូវអញរួបរឹតហើយ យ៉ាងដូច្នោះឯង ។ ធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាសរសៃទាំងឡាយជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(អដ្ឋិ)

បណ្តាឆ្អឹងទាំងឡាយ ឆ្អឹងកែងជើងទ្រនូវឆ្អឹងកជើងហើយឋិតនៅ, ឆ្អឹងកជើង ទ្រនូវជង្គង់ហើយឋិតនៅ, ឆ្អឹងជង្គង់ ទ្រនូវឆ្អឹងភ្លៅហើយឋិតនៅ, ឆ្អឹងភ្លៅទ្រនូវឆ្អឹងចង្កេះហើយឋិតនៅ, ឆ្អឹងចង្កេះទ្រនូវឆ្អឹងខ្នងហើយឋិតនៅ, ឆ្អឹងខ្នង ទ្រនូវឆ្អឹង-ក ហើយឋិតនៅ, ឆ្អឹង-ក ទ្រនូវឆ្អឹងក្បាលហើយឋិតនៅ, ឆ្អឹងក្បាល ឋិតនៅលើឆ្អឹង-ក, ឆ្អឹង-ក ឋិតនៅលើឆ្អឹងខ្នង, ឆ្អឹងខ្នង ឋិតនៅលើឆ្អឹងចង្កេះ, ឆ្អឹងចង្កេះ ឋិតនៅលើឆ្អឹងភ្លៅ, ឆ្អឹងភ្លៅ ឋិតនៅលើឆ្អឹងជង្គង់, ឆ្អឹងជង្គង់ ឋិតនៅលើឆ្អឹងកជើង, ឆ្អឹងកជើង ឋិតនៅលើឆ្អឹងកែងជើង ។ បណ្តាឆ្អឹងទាំងនោះ ឆ្អឹងកែងជើង មិនដឹងថា អញ ទ្រនូវឆ្អឹងកជើង ហើយឋិតនៅ, ចំណែកឆ្អឹងកជើង ក៏មិនដឹងដែរថា អញ ទ្រនូវឆ្អឹងជង្គង់ ហើយឋិតនៅ, ឆ្អឹងជង្គង់ ក៏មិនដឹងថា អញ ទ្រនូវឆ្អឹងភ្លៅ ហើយឋិតនៅ, ឆ្អឹងភ្លៅ ក៏មិនដឹងថា អញ ទ្រនូវឆ្អឹងចង្កេះ ហើយឋិតនៅ, ឆ្អឹងចង្កេះ ក៏មិនដឹងដែរថា អញ ទ្រនូវឆ្អឹងខ្នង ហើយឋិតនៅ, ឆ្អឹងខ្នង ក៏មិនដឹងដែរថា អញ ទ្រនូវឆ្អឹង-ក ហើយឋិតនៅ, ឆ្អឹង-ក ក៏មិនដឹងដែរថា អញ ទ្រនូវឆ្អឹងក្បាល ហើយឋិតនៅ, ឆ្អឹងក្បាល ក៏មិន

ដឹងដែរថា អញ បិតនៅលើឆ្អឹង-ក, ឆ្អឹង-ក ក៏មិនដឹងដែរថា អញ បិតនៅលើឆ្អឹងខ្នង, ឆ្អឹងខ្នង ក៏មិនដឹងដែរថា អញ បិតនៅលើឆ្អឹងចង្កេះ, ឆ្អឹងចង្កេះ ក៏មិនដឹងដែរថា អញ បិតនៅលើឆ្អឹងភ្លៅ, ឆ្អឹងភ្លៅ ក៏មិនដឹងដែរថា អញ បិតនៅលើឆ្អឹងជង្គង់, ឆ្អឹងជង្គង់ ក៏មិនដឹងដែរថា អញ បិតនៅលើឆ្អឹងកជើង, ឆ្អឹងកជើង ក៏មិនដឹងដែរថា អញ បិតនៅលើឆ្អឹងកែងជើង ប្រៀបបីដូចជាបណ្តាស្រទាប់នៃវត្ថុ មានឥដ្ឋ ឈើ និង គោម័យជាដើម វត្ថុដែលនៅខាងក្រោមៗ មិនដឹងថា អញ ទ្រទ្រង់នូវវត្ថុដែលនៅខាងលើៗ ហើយបិតនៅ, ចំណែកឯវត្ថុដែលនៅខាងលើៗ ក៏មិនដឹងដែរថា អញ បិតនៅលើវត្ថុខាងក្រោមៗ យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាឆ្អឹង ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(អដ្ឋិមិញ្ជំ)

ខួរក្នុងឆ្អឹង បិតនៅត្រង់ចន្លោះខាងក្នុង នៃឆ្អឹងទាំងឡាយនោះៗ ។ បណ្តាឆ្អឹង និង ខួរទាំងនោះ ឆ្អឹងទាំងឡាយ មិនដឹងថា ខួរ បិតនៅហើយ ព្ធដ៏ខាងក្នុងអញ, ចំណែកឯខួរវិញ ក៏មិនដឹងដែរថា អញ បិតនៅហើយ ព្ធដ៏ខាងក្នុង នៃឆ្អឹងទាំងឡាយ ប្រៀបបីដូចជា បណ្តាបណ្តូលទាំងឡាយ មានបណ្តូលផ្តៅ ដែលគេស្រុះហើយជាដើម ត្រូវគេប្រេកចូលទៅ ព្ធដ៏ខាងក្នុង នៃបំពង់ទាំងឡាយមានបំពង់ឫស្សីជាដើម វត្ថុមានបំពង់ឫស្សីជាដើម មិនដឹងថា បណ្តូលផ្តៅទាំងឡាយ គឺគេប្រេកហើយ ក្នុងអញ, ឯបណ្តូលផ្តៅទាំងឡាយ ក៏មិនដឹងដែរថា អញ បិតនៅហើយ ក្នុងវត្ថុទាំង

ឡាយ មានបំពង់ឫស្សីជាដើម យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាខួរក្នុងឆ្អឹង ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(វក្កំ)

ទាច ជាដុំសាច់ដែលជាប់ជាមួយនឹងសរសៃធំ ដើមមានតែមួយសរសៃ ចេញអំពីបំពង់កទៅបន្តិច ក៏បែកជា ២ សរសៃ រុំសាច់បេះដូង ហើយបិតនៅ ។ បណ្តាសរសៃធំ និង ទាចនោះ សរសៃធំ មិនដឹង ថា ទាច ជាប់រុំព័ទ្ធ ដោយអញ, ចំណែកឯទាច ក៏មិនដឹងដែរថា អញ រុំព័ទ្ធសរសៃធំ ប្រៀបដូចជា បណ្តាផ្លែស្វាយភ្លោះ ដែលជាប់ជាមួយនឹងទង ទងមិនដឹងថា ផ្លែស្វាយភ្លោះ ជាប់ដោយសាអញ, ចំណែកផ្លែស្វាយភ្លោះ ក៏មិនដឹងផងដែរថា អញ ជាប់ដោយសាទង យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាទាច ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(ហទយំ)

បេះដូង អាស្រ័យត្រង់កណ្តាលគ្រោង នៃឆ្អឹងដើមទ្រូង បិតនៅព្ធដ៏ខាងក្នុងនៃសរីរៈ ។ បណ្តាព្ធដ៏ខាងក្នុងគ្រោងនៃឆ្អឹងទ្រូង និង បេះដូងនោះ ព្ធដ៏ខាងក្នុងគ្រោងនៃឆ្អឹងដើមទ្រូង មិនដឹងថា បេះដូង បិតនៅបានព្រោះអាស្រ័យអញ, ចំណែកឯបេះដូង ក៏មិនដឹងដែរថា អញ បិតនៅ

បាន ព្រោះអាស្រ័យខាងក្នុង នៃគ្រោងនៃឆ្អឹងដើមទ្រូង ប្រៀបបីដូចជាបណ្តុំសាច់ ដែលបុគ្គលតំកល់ទុក អាស្រ័យខាងក្នុងនៃគ្រោងនៃស្នែងសម្រាប់សែងដែលចាស់ ខាងក្នុងនៃគ្រោងនៃស្នែងសែងដែលចាស់ មិនដឹងថា ដុំសាច់ ត្រូវបុគ្គលតំកល់ទុក ព្រោះអាស្រ័យអញ, ចំណែកឯដុំសាច់ ក៏មិនដឹងដែរថា ខាងក្នុងនៃគ្រោងនៃស្នែងសែង ត្រូវបុគ្គលតំកល់ទុក ព្រោះអាស្រ័យអញ យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាបេះដូង ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(យកនំ)

ថ្លើម បិតនៅហើយ អាស្រ័យនូវជំហៀងខាងស្តាំ ពួដ៏ខាងក្នុងនៃដោះទាំងពីរ ខាងក្នុងនៃសរីរៈ ។ បណ្តាជំហៀងខាងស្តាំ ពួដ៏ខាងក្នុងនៃដោះ និង ថ្លើមនោះ ជំហៀងខាងស្តាំ ក្នុងខាងក្នុងនៃដោះទាំងឡាយ មិនដឹងថា ថ្លើមបិតនៅហើយ ព្រោះអាស្រ័យអញ, ចំណែកឯថ្លើមវិញ ក៏មិនដឹងដែរថា អញបិតនៅហើយ ព្រោះអាស្រ័យជំហៀងខាងស្តាំ ក្នុងខាងក្នុងនៃដោះទាំងឡាយ ប្រៀបដូចជាបណ្តុំសាច់ក្ងោះ ដែលជាប់នៅត្រង់ទីខាងនៃអំបែងឆ្នាំង ទីខាងនៃអំបែងឆ្នាំង មិនដឹងថា ដុំសាច់ក្ងោះជាប់នៅលើអញ, ចំណែកឯដុំសាច់ក្ងោះ ក៏មិនដឹងដែរថា អញជាប់នៅត្រង់ទីខាងនៃអំបែងឆ្នាំង យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាថ្លើម ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត

សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

(កិលោមកំ)

បណ្តាភាវទាំងឡាយ ភាវដែលកំបាំង រួបរឹតនូវបេះដូងផង នូវទាចផង ហើយបិតនៅ, ភាវដែលមិនកំបាំង រុំសាច់ខាងក្រោម នៃស្បែកក្នុងសរីរៈទាំងមូល ហើយបិតនៅ ។ ជំនុំទាច បេះដូង និង សាច់ ក្នុងសរីរៈទាំងមូលនោះ ទាច បេះដូង និង សាច់ ក្នុងសរីរៈទាំងមូលនោះ មិនដឹងថា អញ ត្រូវបិទបាំងហើយ ដោយភាវ, ភាវ ក៏មិនដឹងថា ទាច បេះដូង និង សាច់ក្នុងសរីរៈទាំងមូល ត្រូវអញបិទបាំងហើយ ប្រៀបបីដូចជា នាកាលសាច់ ដែលបុគ្គលយកកំណាត់សំពត់ខ្ចប់ហើយ សាច់មិនដឹងថា អញ ត្រូវគេខ្ចប់ហើយ ដោយកំណាត់សំពត់, ចំណែកឯកំណាត់សំពត់ ក៏មិនដឹងផងដែរថា សាច់ ត្រូវគេខ្ចប់ហើយ ដោយអញ យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាភាវ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(បិហកំ)

ក្រពះ បិតនៅ អាស្រ័យនូវខាងនៃក្បាលនៃជំបារពោះ ត្រង់ខាងឆ្វេង នៃបេះដូង ។ នាកាលដុំបាយអ ដែលបុគ្គលដាក់ហើយ អាស្រ័យនូវខាងកំពូលនៃជង្រុក ទីខាងកំពូលនៃជង្រុក មិនដឹងថា ដុំបាយអ បិតនៅហើយ ព្រោះអាស្រ័យនូវអញ, ចំណែកដុំបាយអ ក៏មិនដឹងដែរថា អញ បិតនៅហើយ ព្រោះអាស្រ័យនូវខាងកំពូលនៃជង្រុក យ៉ាងណាមិញ, បណ្តាទីខាងលើជំបារពោះខាងឆ្វេង និង ក្រពះនោះ ទីខាងក្បាល

នៃដំបារពោះ មិនដឹងថា ក្រពះ ឋិតនៅហើយ ព្រោះអាស្រ័យនូវអញ, ចំណែកឯក្រពះ ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ព្រោះអាស្រ័យនូវទីខាងនៃកំពូលនៃដំបារពោះ ក៏យ៉ាងដូច្នោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាក្រពះ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(បប្ផាសំ)

សួត បិទបាំងខាងលើបេះដូងផង ថ្លើមផង នៅត្រង់ចន្លោះ នៃដោះទាំងពីរ ក្នុងខាងក្នុងនៃសរីរៈ ហើយសំយុងចុះ ឋិតនៅ ។ នាកាលសំបុកនៃសត្វស្វាប ផ្តក់ព្យួរ ក្នុងខាងក្នុងនៃជង្រុកចាស់ ទីខាងក្នុង នៃជង្រុកចាស់ មិនដឹងថា សំបុកនៃសត្វស្វាប កាលផ្តក់ហើយឋិតនៅ លើអញ, ចំណែកឯសំបុកសត្វស្វាប ក៏មិនដឹងដែរថា អញ កាលផ្តក់ហើយឋិតនៅ ក្នុងខាងក្នុងនៃជង្រុកចាស់ យ៉ាងណាមិញ, បណ្តាទីខាងក្នុង នៃសរីរៈ និង សួតនោះ ទីខាងក្នុងនៃសរីរៈ មិនដឹងថា សួត កាលផ្តក់ហើយ ឋិតនៅលើអញ, ចំណែកសួត ក៏មិនដឹងដែរថា អញ កាលផ្តក់ហើយ ឋិតនៅ ក្នុងខាងក្នុងសរីរៈ មានសភាពបែបនេះ យ៉ាងនោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាសួត ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(អន្តំ)

ពោះវៀនធំ ឋិតនៅ ក្នុងខាងក្នុងនៃសរីរៈ ត្រង់ទីបំផុត នៃសន្ទុះបំពង់ក និង ផ្លូវនៃអាហារចាស់ ។ បណ្តាទីខាងក្នុងនៃសរីរៈ និង ពោះវៀនធំនោះ ទីខាងក្នុងនៃសរីរៈ មិនដឹងថា ពោះវៀនធំ ឋិតនៅ លើអញ, ចំណែកឯពោះវៀនធំ ក៏មិនដឹងដែរថា អញឋិតនៅ ក្នុងខាងក្នុងនៃសរីរៈ ប្រៀបដូចជា នាកាលសាកសពនៃពស់ មានក្បាលគឺបុគ្គលកាត់ហើយ ដែលគេដាក់បំពេន ក្នុងស្នូកនៃឈាម, ស្នូកនៃឈាម មិនដឹងថា សាកសពនៃពស់ ឋិតនៅលើអញ, ចំណែកឯសាកសពនៃពស់ ក៏មិនដឹងដែរថា អញ ឋិតនៅ ក្នុងស្នូកនៃឈាម យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាពោះវៀនធំ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(អន្តគុណំ)

ពោះវៀនតូច ព័ទ្ធព័ន្ធ នូវផ្នត់នៃពោះវៀនធំទាំងឡាយ ២១ ផ្នត់ ត្រង់ចន្លោះនៃពោះវៀនធំ ហើយឋិតនៅ ។ នាកាលខ្សែទាំងឡាយដែលខ្ចាស់នូវវង្វង់នៃខ្សែសំរាប់ជើង ហើយឋិតនៅ, ចង្វាយខ្សែសំរាប់ជូតជើង មិនដឹងថា ខ្សែទាំងឡាយចាក់ស្រេះនូវយើង ហើយឋិតនៅ, ចំណែកខ្សែទាំងឡាយ ក៏មិនដឹងដែរថា យើងចាក់ស្រេះនូវវង្វង់នៃខ្សែសំរាប់ជូតជើង ហើយឋិតនៅ យ៉ាងណាមិញ, បណ្តាពោះវៀនធំ និង ពោះវៀនតូចនោះ ពោះវៀនធំ មិនដឹងថា ពោះវៀនតូច ចងទូទៅនូវអញ ហើយឋិតនៅ, ចំណែកឯពោះវៀនតូច ក៏មិនដឹងដែរថា អញ ចងទូទៅនូវពោះវៀនធំ ហើយឋិតនៅ ក៏យ៉ាងដូច្នោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាក

ការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាពោះវៀនតូច ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(ឧទរិយំ)

វត្ថុដែលគេស៊ី ផឹក ទំពាស៊ី ជញ្ជក់ជញ្ជាប់ ឋិតនៅ ក្នុងពោះ ឈ្មោះថា អាហារថ្មី ។ បណ្ដាពោះ និង អាហារថ្មីនោះ ពោះ មិនដឹងថា អាហារថ្មី ឋិតនៅលើអញ, ចំណែកឯអាហារថ្មី ក៏មិនដឹងដែរថា អញ ឋិតនៅ ក្នុងពោះ ប្រៀបបីដូចជា នាកាលកំអួតនៃឆ្កែ ដែលឋិតនៅហើយ ក្នុងស្នូកនៃឆ្កែ, ស្នូកនៃឆ្កែ មិនដឹងថា កំអួតនៃឆ្កែ ឋិតនៅហើយលើអញ, ចំណែកឯកំអួតនៃឆ្កែ ក៏មិនដឹងថា អញ ឋិតនៅហើយ ក្នុងស្នូកនៃឆ្កែ យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាអាហារថ្មី ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(ករីសំ)

អាហារចាស់ ឋិតនៅក្នុងទីបំផុតនៃពោះវៀនធំ ប្រាកដស្មើដោយថ្នាំងនៃឫស្សី ៨ ធ្នាប់ ពោលគឺក្រពះនៃអាហារចាស់ ។ នាកាលដីស្អិតមានពណ៌លឿងដ៏ទន់ ដែលបុគ្គលច្របាច់ ហើយច្រកទៅក្នុងថ្នាំងឫស្សី, ថ្នាំងនៃឫស្សី មិនដឹងថា ដីស្អិតមានពណ៌លឿង ឋិតនៅហើយលើយើង, ចំណែកឯដីស្អិតវិញ ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ក្នុងថ្នាំង នៃឫស្សី យ៉ាងណាមិញ, បណ្ដាក្រពះឧច្ចារៈ និង អាហារចាស់នោះ ក្រពះនៃឧច្ចារៈ មិនដឹងថា អាហារចាស់ ឋិតនៅហើយ លើយើង, ចំណែកឯ

អាហារចាស់ ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ក្នុងក្រពះនៃឧច្ចារៈ ក៏យ៉ាងនោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាអាហារចាស់ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(មត្ថលុង្គំ)

ខួរក្នុងក្បាល ឋិតនៅ ក្នុងខាងក្នុង នៃលលាដ៍ក្បាល ។ បណ្ដាខាងក្នុងនៃលលាដ៍ក្បាល និង ខួរក្នុងក្បាលនោះ ទីខាងក្នុងនៃលលាដ៍ក្បាល មិនដឹងថា ខួរក្នុងក្បាល ឋិតនៅហើយ លើអញ, ចំណែកខួរក្នុងក្បាល ក៏មិនដឹងផងដែរថា អញ ឋិតនៅហើយ ក្នុងខាងក្នុងនៃលលាដ៍ក្បាល ប្រៀបដូចជា នាកាលដុំនៃម្សៅ ដែលបុគ្គលច្រកហើយក្នុងសំបកឃ្លោកចាស់, លលាដ៍ឃ្លោក មិនដឹងថា ដុំនៃម្សៅ ឋិតនៅហើយ លើអញ, ចំណែកដុំនៃម្សៅ ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ក្នុងសំបកឃ្លោក យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាខួរក្នុងក្បាល ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជារបស់រឹង ជាបឋវីធាតុ ដោយប្រការដូច្នេះឯង ។

(អាបោកោដ្ឋាស)

(បិត្តំ)

បណ្ដាប្រមាត់ទាំងឡាយ ប្រមាត់ឥតស្រោម ជ្រួតជ្រាបនូវសរីរៈទាំងមូល ជាប់ចំពោះហើយនូវជីវិតិន្ទ្រីយ៍ ហើយឋិតនៅ, ប្រមាត់មានស្រោមឋិតនៅហើយ ក្នុងស្រោមនៃប្រមាត់ ។ នាកាលប្រេងជ្រួតជ្រាប

នូវនំហើយឋិតនៅ, នំមិនដឹងថា ប្រេងជ្រួតជ្រាបនូវអញ ហើយឋិតនៅ, ចំណែកប្រេង ក៏មិនដឹងដែរថា អញជ្រួតជ្រាបនូវនំ ហើយឋិតនៅ យ៉ាងណាមិញ, បណ្តាសរីរៈ និង ប្រមាត់ឥតស្រោម និង ប្រមាត់មានស្រោមនោះ សរីរៈ មិនដឹងថា ប្រមាត់ឥតស្រោមជ្រួតជ្រាបអញ ហើយឋិតនៅ, ចំណែកឯប្រមាត់ឥតស្រោម ក៏មិនដឹងដែរថា អញ ជ្រួតជ្រាបនូវសរីរៈ ហើយឋិតនៅ ក៏យ៉ាងនោះដែរ ។ (មួយទៀត) នាកាលសាញនៃនទោងដែលពេញហើយ ដោយទឹក ក្នុងរដូវភ្លៀង, សំបកនទោងសាញ មិនដឹងថា ទឹកក្នុងរដូវភ្លៀង ឋិតនៅហើយ ក្នុងអញ, ចំណែកទឹកក្នុងរដូវភ្លៀង ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ក្នុងសំបកនទោង យ៉ាងណាមិញ, ស្រោមនៃប្រមាត់ មិនដឹងថា ប្រមាត់មានស្រោមឋិតនៅហើយ ក្នុងអញ, ចំណែកប្រមាត់មានស្រោម ក៏មិនដឹងផងដែរថា អញ ឋិតនៅហើយ ក្នុងស្រោមនៃប្រមាត់ ក៏យ៉ាងដូច្នោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាប្រមាត់ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាទឹកសើម មានការជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(សេម្ហំ)

ស្លេស្ម មានប្រមាណពេញមួយទូកដៃ ឋិតនៅ ក្នុងដំបារពោះ ។ នាកាលអណ្តូងនៃជ្រាំ មានដុំនៃក្រពែង ដែលកើតក្នុងខាងលើ, អណ្តូងនៃជ្រាំ មិនដឹងថា ដុំនៃក្រពែងទឹក ឋិតនៅហើយលើអញ, ឯក្រពែងទឹក ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ក្នុងអណ្តូងនៃជ្រាំ យ៉ាងណាមិញ, បណ្តាដំបារពោះ និង ស្លេស្មទាំងនោះ ដំបារពោះ មិនដឹងថា ស្លេស្ម

ឋិតនៅហើយ លើអញ, ចំណែកឯស្លេស្ម ក៏មិនដឹងដែរថា អញ ឋិតនៅហើយក្នុងដំបារពោះ ក៏យ៉ាងនោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាស្លេស្ម ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាទឹកសើម មានការជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(បុព្វោ)

ខ្ទុះ ពុំមានឱកាសនៅប្រចាំឡើយ ក្នុងសរីរប្បទេសណាៗ ដែលត្រូវវត្ថុទាំងឡាយ មានដង្កត់ច្រំ បន្លាមុត និង អណ្តាតភ្លើងជាដើម ប៉ះទង្គិចហើយ, ឈាម យាំងនៅហើយ ក៏ខូចទៅ, មួយ៉ាងទៀត រោគទាំងឡាយមានពក និង រលកកែវជាដើម រមែងកើតឡើង ក៏ឋិតនៅ ក្នុងសរីរប្បទេសនោះៗឯង ។ នាកាលឈើមានជ័រហូរចេញហើយ ដោយអំណាចនៃការប្រហារ ដោយប៉ូវថៅជាដើម, ប្រទេសមានការប្រហារជាដើមនៃឈើ មិនដឹងថា ជ័រឋិតនៅហើយ លើយើងទាំងឡាយ, ចំណែកជ័រ ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ក្នុងប្រទេសមានការប្រហារជាដើម នៃដើមឈើ យ៉ាងណាមិញ, បណ្តាសរីរប្បទេសដែលត្រូវដង្កត់ និង បន្លាជាដើម ប៉ះទង្គិច និង ខ្ទុះនោះ ប្រទេសនៃសរីរៈដែលត្រូវដង្កត់ និង បន្លាជាដើម ប៉ះទង្គិចហើយ មិនដឹងថា ខ្ទុះ ឋិតនៅហើយ លើពួកយើង, ចំណែកខ្ទុះ ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ក្នុងប្រទេសទាំងឡាយនោះ ក៏យ៉ាងនោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាខ្ទុះជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិន

មែនជាសត្វ ជាទឹកសើម មានកិរិយាជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(លោហិតំ)

បណ្ដាឈាមទាំងឡាយ សំសរណលោហិត (ឈាមដែលរត់ទៅមក) ជ្រួតជ្រាបសរីរៈទាំងមូល ដូចជាប្រមាត់ ហើយឋិតនៅ, សន្និចិត-លោហិត (ឈាមដែលដក់នៅ) បំពេញផ្នែកខាងក្រោម នៃកន្លែងរបស់ថ្លើម ហើយផ្សើមនូវទាច បេះដូង ថ្លើម និង សួតទាំងឡាយ ប្រមាណពេញមួយទូកដៃ ហើយឋិតនៅ ។ បណ្ដាលោហិតទាំងពីរនោះ វិនិច្ឆ័យក្នុងសំសរណលោហិត គឺប្រហែលគ្នានឹងប្រមាត់ឥតមានស្រោមដែរ ។ ចំណែកក្នុងសន្និចិតលោហិត ក្រៅអំពីនេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ គឺ : នាកាលទឹក ស្រក់ចុះហើយ ក្នុងអំបែងដែលចាស់ ញុំាងវត្ថុទាំងឡាយមានគំនរដុំដីជាដើម ឰដ៏ខាងក្រោម ឲ្យសើម, វត្ថុទាំងឡាយមានគំនរដុំដីជាដើម មិនដឹងថា យើងទាំងឡាយត្រូវទឹកធ្វើឲ្យសើម, ទឹកក៏មិនដឹងផងដែរថា អញ ញុំាងវត្ថុទាំងឡាយមានគំនរដុំដីជាដើមឲ្យសើមយ៉ាងណាមិញ, ទីនៃភាគខាងក្រោមនៃថ្លើមក្ដី វត្ថុមានទាចជាដើមក្ដី មិនដឹងថា ឈាម ឋិតនៅ ក្នុងយើង ឬ កាលផ្សើមនូវយើងហើយក៏ឋិតនៅ, ឈាម ក៏មិនដឹងដែរថា អញបំពេញផ្នែកខាងក្រោមនៃថ្លើម ហើយផ្សើមទាចជាដើមឲ្យសើម ហើយឋិតនៅ ក៏យ៉ាងនោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាឈាមជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាទឹកសើម មានការជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(សេទោ)

ញើស បំពេញចន្លោះនៃរណ្ដៅ នៃសក់ និង រោម ហើយឋិតនៅខ្លះ ហូរចេញមក ក្នុងពេលទាំងឡាយ មានពេលដែលក្ដៅសព្វ ដោយភ្លើងជាដើមខ្លះ ។ ក្នុងប្រហោងរណ្ដៅសក់ និង រោម ជាមួយនឹងញើសនោះ ប្រហោងរណ្ដៅនៃសក់ និង រោមទាំងឡាយ មិនដឹងថា ញើសហូរចេញចាកយើងទាំងឡាយ, ញើស ក៏មិនដឹងដែរថា អញ ហូរចេញចាកប្រហោងរណ្ដៅនៃសក់ និង រោមទាំងឡាយ ប្រៀបដូចជា នាកាលបាច់នៃក្រឧិឈូក និង ទងនៃឈូកជាដើម គ្រាន់តែបុគ្គលដកឡើងចេញអំពីទឹកហើយ, ចន្លោះនៃបាច់មានបាច់នៃក្រឧិឈូកជាដើមមិនដឹងថា ទឹកហូរចេញចាកយើងទាំងឡាយ, ទឹក កាលហូរចេញចាកប្រហោងនៃបាច់ នៃក្រឧិឈូកជាដើម ក៏មិនដឹងដែរថា អញ ហូរចេញចាកប្រហោង នៃបាច់ក្រឧិឈូកជាដើម យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាញើសជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាទឹកសើម មានការជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(មេទោ)

ខ្លាញ់ខាប់ ជាជ័រដែលផ្សាយទៅកាន់សរីរៈទាំងមូល នៃមនុស្សដែលធាត់ ជាជ័រដ៏ខាប់ឋិតនៅ អាស្រ័យនូវសាច់ទាំងឡាយ មានសាច់ស្មងជាដើម របស់មនុស្សស្គម ។ នាកាលដុំនៃសាច់ ដែលគេបិទបាំងហើយ ដោយកំណាត់សំពត់ ដែលបុគ្គលជ្រលក់ហើយដោយរមៀត, ដុំនៃសាច់ មិនដឹងថា កំណាត់សំពត់ដែលគេជ្រលក់ហើយ ដោយរមៀត

បិតនៅហើយ ព្រោះអាស្រ័យនូវអញ, ចំណែកកំណាត់សំពត់ ដែលគេជ្រលក់ដោយរមៀត ក៏មិនដឹងដែរថា អញបិតនៅហើយ ព្រោះអាស្រ័យនូវដុំសាច់ យ៉ាងណាមិញ, បណ្ដាសាច់ជាមួយខ្ទាញ់ខាប់នោះ សាច់ ក្នុងសរីរៈទាំងមូលក្ដី ក្នុងអវយវៈមានស្មងជាដើមក្ដី មិនដឹងថា ខ្ទាញ់ខាប់បិតនៅហើយ ព្រោះអាស្រ័យនូវអញ, ចំណែកខ្ទាញ់ខាប់ ក៏មិនដឹងដែរថា អញ បិតនៅហើយ ព្រោះអាស្រ័យនូវសាច់ ក្នុងសរីរៈទាំងមូល ឬក្នុងអវយវៈមានស្មងជាដើម ក៏យ៉ាងនោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និងការពិចារណាទៅវិញទៅមក ។ ធម្មតាខ្ទាញ់ខាប់ជាចំណែកផ្សេងដោយឡែកក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាជ័រស្អិត មានការជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(អស្សុ)

ទឹកភ្នែក កើតព្រម ក្នុងពេលណា ក្នុងពេលនោះ ទឹកភ្នែក ញុំាងរណ្ដៅភ្នែក ឲ្យពេញ ហើយបិតនៅខ្លះ ហូរចេញមកខ្លះ ។ បណ្ដារណ្ដៅភ្នែក និង ទឹកភ្នែកនោះ រណ្ដៅនៃភ្នែក មិនដឹងថា ទឹកភ្នែកបិតនៅហើយក្នុងយើងទាំងឡាយ, ចំណែកទឹកភ្នែក ក៏មិនដឹងផងដែរថា អញ បិតនៅហើយ ក្នុងរណ្ដៅនៃភ្នែកទាំងឡាយ ប្រៀបបីដូចជា នាកាលរណ្ដៅ នៃគ្រាប់ត្នោតខ្ចីទាំងឡាយ ដែលពេញហើយ ដោយទឹក, រណ្ដៅ នៃគ្រាប់ត្នោតខ្ចី មិនដឹងថា ទឹកបិតនៅហើយ ក្នុងយើងទាំងឡាយ, ចំណែកទឹកក្នុងរណ្ដៅនៃគ្រាប់ត្នោតខ្ចីទាំងឡាយ ក៏មិនដឹងដែរថា អញ បិតនៅហើយក្នុងរណ្ដៅនៃគ្រាប់ត្នោតខ្ចីទាំងឡាយ យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាគ្នាទៅវិញទៅមក ។

ធម្មតាទឹកភ្នែក ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាទឹកសើម មានការជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(វសា)

ខ្ទាញ់រាវ ជាខ្ទាញ់ដែលរលាយបិតនៅ ក្នុងផ្ទៃនៃបាតដៃ ខ្នងបាតដៃ ផ្ទៃបាតជើង ខ្នងបាតជើង កញ្ចប់ច្រមុះ ថ្ងាស់ និង ចង្កួយនៃស្មាទាំងឡាយ ក្នុងពេលដែលក្ដៅសព្វព្រោះភ្លើងជាដើម ។ បណ្ដាប្រទេសមានផ្ទៃបាតដៃជាដើម និង ខ្ទាញ់រាវនោះ ប្រទេសមានផ្ទៃ នៃបាតដៃជាដើម មិនដឹងថា ខ្ទាញ់រាវជ្រួតជ្រាបនូវអញ ហើយបិតនៅ, ចំណែកខ្ទាញ់រាវ ក៏មិនដឹងដែរថា អញជ្រួតជ្រាប ក្នុងប្រទេសមានផ្ទៃនៃបាតដៃជាដើមហើយបិតនៅ ប្រៀបបីដូចជា នាកាលបាយក្ដាំង មានប្រេងត្រូវបុគ្គលដាក់ហើយ, បាយក្ដាំង មិនដឹងថា ប្រេងជ្រួតជ្រាបនូវអញហើយបិតនៅ, ចំណែកប្រេង ក៏មិនដឹងដែរថា អញជ្រួតជ្រាប នូវបាយក្ដាំង ហើយបិតនៅ យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាខ្ទាញ់រាវ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាទឹកសើម មានកិរិយាជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(ខេឡោ)

ទឹកមាត់, នាកាលបច្ច័យជាទីកើតឡើងនៃទឹកមាត់ ប្រាកដយ៉ាងដូច្នោះ កើតមាន, ចុះហើយចាកខាងនៃថ្ពាល់ទាំងពីរ ហើយបិតនៅក្នុងផ្ទៃនៃអណ្ដាត ។ នាកាលរណ្ដៅ នៃត្រើយស្ទឹង ដែលមានទឹកហូរមិនដាច់

ផ្ទៃនៃរណ្ដៅ មិនដឹងថា ទឹកដក់ជាប់នៅ ក្នុងយើង, ទឹក ក៏មិនដឹងដែរថា អញ ដក់ជាប់នៅក្នុងផ្ទៃនៃរណ្ដៅ យ៉ាងណាមិញ, ផ្ទៃនៃអណ្ដាត មិនដឹងថា ទឹកមាត់ ចុះធ្លាក់ចាកខាងនៃថ្ពាល់ទាំងពីរ ហើយឋិតនៅ ក្នុងយើង, ចំណែកទឹកមាត់ក៏មិនដឹងដែរថា អញ ចុះចាកខាងនៃថ្ពាល់ទាំងឡាយពីរ ហើយឋិតនៅ លើផ្ទៃនៃអណ្ដាត ក៏យ៉ាងដូច្នោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាទឹកមាត់ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាទឹកសើម មានកិរិយាជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(សិង្ឃាណិកា)

ទឹកសំបោរ កើតព្រម ក្នុងពេលណា ក្នុងពេលនោះ ញុំាងក្ដោងច្រមុះឲ្យពេញ ហើយឋិតនៅខ្លះ ហូរចេញខ្លះ ។ បណ្ដាក្ដោងច្រមុះ និង ទឹកសំបោរនោះ ក្ដោងច្រមុះ មិនដឹងថា ទឹកសំបោរ ឋិតនៅហើយ ក្នុងយើង, ចំណែកទឹកសំបោរ ក៏មិនដឹងដែរថា អញ ឋិតនៅហើយក្នុងក្ដោងច្រមុះទាំងឡាយ ប្រៀបបីដូចជា នាកាលសំបកខ្យង ដែលពេញហើយដោយទឹកដោះជូរផ្អូម, សំបកខ្យង មិនដឹងថា ទឹកដោះជូរផ្អូម ឋិតនៅហើយ ក្នុងយើង, ចំណែកទឹកដោះជូរផ្អូម ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ក្នុងសំបកខ្យង យ៉ាងដូច្នោះឯង ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាទឹកសំបោរ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាទឹកសើម មានកិរិយាជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(លសិកា)

ទឹករំអិល កាលញុំាងកិច្ចគឺការលាបនូវសន្លាក់ នៃឆ្អឹងទាំងឡាយឲ្យសំរេច ឋិតនៅហើយ ក្នុងសន្លាក់ ១៨០ ។ នាកាលភ្លៅនៃរទេះ ដែលបុគ្គលលាបហើយដោយប្រេង, ភ្លៅរទេះ មិនដឹងថា ប្រេងប្រឡាក់អញ ហើយឋិតនៅ, ចំណែកឯប្រេង ក៏មិនដឹងផងដែរថា អញ លាបភ្លៅរទេះ ហើយឋិតនៅ យ៉ាងណាមិញ, បណ្ដាសន្លាក់ ១៨០ និង ទឹករំអិលនោះ សន្លាក់នៃឆ្អឹង ១៨០ មិនដឹងថា ទឹករំអិលលាបនូវយើងទាំងឡាយហើយ ឋិតនៅ, ចំណែកទឹករំអិល ក៏មិនដឹងដែរថា អញ លាបនូវសន្លាក់ ១៨០ ហើយឋិតនៅ ក៏យ៉ាងនោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាទៅវិញទៅមក ។ ធម្មតាទឹករំអិល ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាទឹកសើម មានកិរិយាជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ។

(មុត្តំ)

ទឹកមូត្រ ឋិតនៅ ក្នុងខាងក្នុង នៃប្លោកនោម ។ នាកាលក្អមស្រាំ ដែលគេដាក់ហើយ មានមាត់ចុះក្រោម ក្នុងរណ្ដៅជ្រាំហ្នឹងឯង, ក្អមស្រាំ មិនដឹងថា រសនៃទឹកជ្រាំ ឋិតនៅហើយក្នុងយើង, ចំណែករសនៃទឹកជ្រាំ ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ក្នុងក្អមស្រាំ យ៉ាងណាមិញ, បណ្ដាប្លោកនោម និង ទឹកមូត្រនោះ ប្លោកនោម មិនដឹងថា ទឹកមូត្រ ឋិតនៅហើយ ក្នុងយើង, ចំណែកទឹកមូត្រ ក៏មិនដឹងដែរថា អញ ឋិតនៅហើយ ក្នុងប្លោកនោម ក៏យ៉ាងនោះដែរ ។ សភាវធម៌ទាំងឡាយនុ៎ះ ប្រាសចាកការរំពឹងគិត និង ការពិចារណាគ្នាទៅវិញទៅមក ។ ធម្មតាទឹកមូត្រ ជា

ចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត សោះសូន្យ មិនមែនសត្វ ជាទឹកសើម មានកិរិយាជ្រួតជ្រាបជាអាការៈ ជាអាបោធាតុ ដោយប្រការដូច្នេះឯង ” ។

(តេជោកោដ្ឋាស)

(២១៩) ព្រះយោគាវចរ លុះញុំាងមនសិការ ឲ្យប្រព្រឹត្តទៅ ក្នុងបឋវីកោដ្ឋាស និង អាបោកោដ្ឋាសទាំងឡាយ មានសក់ជាដើម ដូចបានពណ៌នាមក យ៉ាងនេះហើយ គប្បីញុំាងមនសិការ ឲ្យប្រព្រឹត្តទៅ ក្នុងតេជោកោដ្ឋាស (ចំណែកនៃភ្លើង) ទាំងឡាយ យ៉ាងនេះ ថា :

“កាយ រមែងក្ដៅសព្វ ដោយភ្លើងឯណា, ភ្លើងនេះ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត ទទេ មិនមែនសត្វ មានកិរិយាអប់កំដៅជាអាការៈ ឈ្មោះថា តេជោធាតុ” ដូច្នេះ,

“កាយ តែងទ្រុឌទ្រោម ដោយភ្លើងឯណា, ភ្លើងនេះ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត ទទេ មិនមែនសត្វ មានកិរិយាអប់កំដៅជាអាការៈ ឈ្មោះថា តេជោធាតុ” ដូច្នេះ,

“កាយ តែងឆេះរោលរាល ដោយភ្លើងឯណា, ភ្លើងនេះ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត ទទេ មិនមែនសត្វ មានការអប់កំដៅជាអាការៈ ឈ្មោះថា តេជោធាតុ” ដូច្នេះ,

“វត្ថុមានបាយជាដើម ដែលបុគ្គលស៊ីហើយ ផឹកហើយ ទំពាស៊ីហើយ និង លិទ្ធហើយ តែងដល់នូវកិរិយាប្រែប្រួលទៅ ដោយប្រពៃ ដោយភ្លើងឯណា, ភ្លើងនេះ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត ទទេ មិនមែនសត្វ មានកិរិយាអប់កំដៅជាអាការៈ ឈ្មោះថា តេជោធាតុ” ដូច្នេះឯង ។

(វាយោកោដ្ឋាស)

(២២០) បន្ទាប់អំពីនោះមក ព្រះយោគី គប្បីកំណត់ នូវខ្យល់ដែលបក់ឡើងលើ ដោយអំណាចនៃខ្យល់ដែលបក់ឡើងលើ កំណត់នូវខ្យល់ដែលបក់ចុះក្រោម ដោយអំណាចខ្យល់ដែលបក់ចុះក្រោម កំណត់នូវខ្យល់ដែលដេកនៅក្នុងពោះ ដោយអំណាចនៃខ្យល់ដែលដេកនៅ ក្នុងពោះ កំណត់នូវខ្យល់ដែលដេកនៅក្នុងសរសៃ ដោយអំណាចនៃខ្យល់ដែលដេកនៅក្នុងសរសៃ កំណត់នូវខ្យល់ដែលបក់ ក្នុងអវយវៈតូច-ធំ ដោយអំណាចនៃខ្យល់ដែលបក់ក្នុងអវយវៈតូច-ធំ កំណត់នូវខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូល ដោយអំណាចនៃខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូល ហើយគប្បីញុំាងមនសិការ ឲ្យប្រព្រឹត្តទៅ ក្នុងចំណែកនៃខ្យល់ទាំងឡាយ យ៉ាងដូច្នេះ ថា :

“ធម្មតាខ្យល់ទាំងឡាយ ដែលបក់ឡើងទៅលើ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត ទទេ មិនមែនសត្វ មានអាការៈបក់បោកទៅមក ជាវាយោធាតុ” ដូច្នេះ,

“ធម្មតាខ្យល់ទាំងឡាយ ដែលបក់ចុះក្រោម ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត ទទេ មិនមែនសត្វ មានអាការៈបក់បោកទៅមក ជាវាយោធាតុ” ដូច្នេះ,

“ធម្មតាខ្យល់ទាំងឡាយ ដែលដេកនៅក្នុងពោះ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត ទទេ មិនមែនសត្វ មានអាការៈបក់បោកទៅមក ជាវាយោធាតុ” ដូច្នេះ,

“ធម្មតាខ្យល់ទាំងឡាយ ដែលដេកនៅក្នុងសរសៃ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត ទទេ មិន

មែនសត្វ មានអាការៈបក់បោកទៅមក ជាវាយោធាតុ” ដូច្នេះ,

“ធម្មតាខ្យល់ទាំងឡាយ ដែលបក់ក្នុងអវយវៈតូចធំ ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត ទទេ មិនមែនសត្វ មានអាការៈបក់បោកទៅមក ជាវាយោធាតុ” ដូច្នេះ,

“ធម្មតាខ្យល់ទាំងឡាយ ដែលសំរាប់ដកដង្ហើញចេញ និង ដកដង្ហើមចូល ជាចំណែកផ្សេងដោយឡែក ក្នុងសរីរៈនេះ មិនមានចិត្ត ជាអព្យាក្រឹត ទទេ មិនមែនជាសត្វ មានអាការៈបក់បោកទៅមក ជាវាយោធាតុ” យ៉ាងដូច្នេះ ។

ធាតុទាំងឡាយ តែងប្រាកដ ដល់ព្រះយោគាវចរនោះ អ្នកមានមនសិការប្រព្រឹត្តទៅ យ៉ាងនេះ ។ កាលព្រះយោគីនោះ នឹករំពឹង ធ្វើទុកក្នុងចិត្ត នូវធាតុទាំងឡាយនោះ រឿយៗ ឧបចារសមាធិ រមែងកើតឡើង តាមន័យដែលលោកបានពោលមកហើយនុ៎ះឯង ។

តែថា កាលព្រះយោគីណា ចំរើនយ៉ាងនេះ កម្មដ្ឋាន មិនសំរេច, ព្រះយោគីនោះ គប្បីចំរើន ដោយសលក្ខណសង្ខេបចុះ ។

(ចំរើនដោយសលក្ខណសង្ខេប)

សួរថា : គប្បីចំរើន ដោយសលក្ខណសង្ខេប ដូចម្ដេច ? ។

ឆ្លើយថា : ព្រះយោគី គប្បីកំណត់យកលក្ខណៈដែលរឹង ក្នុងចំណែកទាំងឡាយ ២០ ថា “ជាធាតុដី” ដូច្នេះ ។ គប្បីកំណត់យកលក្ខណៈដែលជ្រួតជ្រាប ក្នុងចំណែកទាំងឡាយ ២០ នោះឯង ថា “ជាធាតុទឹក” ដូច្នេះ, គប្បីកំណត់យកលក្ខណៈដែលអប់កំដៅ ក្នុងចំណែកទាំងឡាយ ២០ នោះឯង ថា “ជាធាតុភ្លើង” ដូច្នេះ, គប្បីកំណត់យកលក្ខណៈដែលបក់បោកទៅមក ក្នុងចំណែកទាំងឡាយ ២០ នោះឯង ថា

“ជាធាតុខ្យល់” យ៉ាងដូច្នេះ ។

ព្រះយោគីគប្បីកំណត់លក្ខណៈដែលជ្រួតជ្រាប ក្នុងចំណែកទាំងឡាយ ១២ ថា “អាបោធាតុ” ។ កំណត់លក្ខណៈដែលដុតកំដៅ ក្នុងចំណែកទាំង ១២ នោះឯង ថា “តេជោធាតុ” ។ កំណត់លក្ខណៈដែលបក់បោកទៅមក ក្នុងចំណែកទាំង ១២ នោះឯង ថា “តេជោធាតុ” ។ កំណត់លក្ខណៈដែលរឹង ក្នុងចំណែកទាំង ១២ នោះឯង ថា “បឋវីធាតុ” ដូច្នេះឯង ។

ព្រះយោគី គប្បីកំណត់លក្ខណៈដែលដុតកំដៅ ក្នុងចំណែកទាំងឡាយ ៤ ថា “តេជោធាតុ” ។ គប្បីកំណត់លក្ខណៈដែលបក់បោកទៅមក ដែលមិនបែកខ្វែកចេញពីធាតុភ្លើងនោះ ថា “វាយោធាតុ” ។ កំណត់លក្ខណៈដែលរឹង ដែលមិនបែកខ្វែកពីធាតុភ្លើងនោះ ថា “បឋវីធាតុ” ។ កំណត់លក្ខណៈដែលជ្រួតជ្រាបដែលមិនបែកខ្វែកចេញពីធាតុភ្លើងនោះ ថា “អាបោធាតុ” ដូច្នេះឯង ។

ព្រះយោគី គប្បីកំណត់យកលក្ខណៈដែលបក់បោកទៅមក ក្នុងចំណែកទាំងឡាយ៦ ថា “វាយោធាតុ” ។ កំណត់លក្ខណៈដែលរឹង ក្នុងចំណែកទាំង ៦ នោះឯង ថា “បឋវីធាតុ” ។ កំណត់លក្ខណៈដែលជ្រួតជ្រាប ក្នុងចំណែកទាំង ៦ នោះឯង ថា “អាបោធាតុ” ។ កំណត់យកលក្ខណៈដែលអប់កំដៅក្នុងចំណែកទាំង ៦ នោះដែរថា “តេជោធាតុ” ។

កាលព្រះយោគីនោះ កំណត់ យ៉ាងដូច្នេះ ធាតុទាំងឡាយ រមែងប្រាកដ ។ កាលព្រះយោគីនោះ រំពឹង ធ្វើទុកក្នុងចិត្ត នូវធាតុទាំងឡាយនោះ រឿយៗ, ឧបចារសមាធិ រមែងកើតឡើង តាមន័យដែលលោកពោលហើយនោះឯង ។

តែថា កាលព្រះយោគីណា ចំរើនយ៉ាងនេះ កម្មដ្ឋាន មិនសំរេច, ព្រះយោគីនោះ គប្បីចំរើន ដោយការវែកញែកតាមលក្ខណៈរបស់ខ្លួន ។

(ចំរើនដោយសលក្ខណវិភត្តិ)

សួរថា: ព្រះយោគីគប្បីចំរើន ដោយការវែកញែកតាមលក្ខណៈរបស់ខ្លួន យ៉ាងដូចម្តេច ? ។

ឆ្លើយថា: ព្រះយោគីគប្បីកំណត់នូវអាការៈទាំងឡាយ មានសក់ជាដើម តាមន័យដែលលោកពោលហើយ ក្នុងកាលមុននោះឯង ហើយកំណត់នូវលក្ខណៈរឹង ក្នុងសក់ ថា "បឋវីធាតុ" ។ កំណត់នូវលក្ខណៈដែលជ្រួតជ្រាប ក្នុងសក់នោះឯង ថា "អាបោធាតុ" ។ កំណត់លក្ខណៈដែលអប់កំដៅ ក្នុងសក់នោះឯង ថា "តេជោធាតុ" ។ កំណត់លក្ខណៈដែលបក់បោកទៅមក ក្នុងសក់នោះដែរ ថា "វាយោធាតុ" ។ ព្រះយោគីគប្បីកំណត់ធាតុបួនៗ ក្នុងធាតុមួយៗ ក្នុងចំណែកទាំងអស់ យ៉ាងនេះ ។ កាលព្រះយោគីនោះ កំណត់យ៉ាងនេះ ធាតុទាំងឡាយ រមែងប្រាកដ ។ កាលព្រះយោគី នឹករំពឹង ធ្វើទុកក្នុងចិត្តនូវធាតុទាំងនោះ ឲ្យបានរឿយៗ ឧបចារសមាធិ រមែងកើតឡើងតាមន័យដែលបានពោលហើយនុ៎ះឯង ។

(មនសិការ ដោយអាការៈ ១៣ ក៏បាន)

(២២១) ម្យ៉ាងវិញទៀត ព្រះយោគី គប្បីធ្វើទុកក្នុងចិត្ត នូវធាតុទាំងឡាយ ដោយអាការៈទាំងឡាយនេះ ក៏បាន គឺ :

វចនដ្ឋតោ ដោយកែអត្ថរបស់ពាក្យ,

កលាបតោ ដោយកលាបៈ (ពួក),

ចុណ្ណតោ ដោយលំអិត,

លក្ខណាទិតោ ដោយលក្ខណៈជាដើម,

សមុដ្ឋានតោ ដោយសមុដ្ឋាន,

នានត្តេកត្តតោ ដោយភាពផ្សេងគ្នា និង ត្រូវគ្នា,

វិនិព្ភោគាវិនិព្ភោគតោ ដោយភាពដែលបែកពីគ្នា និង មិនបែកអំពីគ្នា,

សភាគវិសភាគតោ ដោយភាពដែលមានចំណែកស្មើគ្នា និង មិនស្មើគ្នា,

អជ្ឈត្តិកពាហិរវិសេសតោ ដោយភាពដែលប្លែកគ្នារបស់ធាតុជាខាងក្នុង និង ធាតុជាខាងក្រៅ,

សង្គហតោ ដោយសង្គ្រោះ,

បច្ចយតោ ដោយបច្ច័យ,

អសមន្នាហារតោ ដោយភាពដែលមិនដឹងនូវគ្នានឹងគ្នា,

បច្ចយវិភាគតោ ដោយកិរិយាចែកនូវបច្ច័យ ។

កែបទវចនដ្ឋតោ

ក្នុងអាការៈទាំងនោះ ព្រះយោគី កាលធ្វើទុកក្នុងចិត្ត ដោយកែអត្ថរបស់ពាក្យ គប្បីធ្វើទុកក្នុងចិត្ត ដោយកែអត្ថរបស់ពាក្យ ដោយអំណាចនៃភាវៈវិសេស និង ស្មើគ្នា យ៉ាងដូច្នេះ ថា "ឈ្មោះថា បឋវីធាតុ ព្រោះភាវៈនៃធាតុនោះក្រាស់, ឈ្មោះថា អបោ ព្រោះធ្វើឲ្យសើម ធ្វើឲ្យជោក ឬ ធ្វើឲ្យជ្រួតជ្រាប, ឈ្មោះថា តេជោ ព្រោះអប់ឲ្យក្តៅ, ឈ្មោះថា វាយោ ព្រោះបក់បោក" ដូច្នេះ ។ បើពោលដោយសេចក្តីមិនប្លែកគ្នា ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួនផង ព្រោះជាទីតាំងនៃសេចក្តីទុក្ខផង ព្រោះជាទីរងនូវសេចក្តីទុក្ខផង ។

កែបទកលាបតោ

(២២២) ពាក្យថា “កលាបតោ” *មានពិណ៌នាថា : ព្រះអដ្ឋកថាសំដែងបឋវីធាតុ ដោយអាការៈទាំងឡាយ ២០ ដោយន័យថា “សក់ រោម” ដូច្នេះជាដើមផង, សំដែងអាបោធាតុ ដោយអាការៈទាំងឡាយ ១២ ដោយន័យថា “ប្រមាត់ ស្លេស្ម” ដូច្នេះជាដើមផង នេះឯណា, ក្នុងអាការៈទាំងឡាយនោះ*

ព្រោះកិរិយាប្រជុំគ្នានៃធម៌ ៨ យ៉ាង គឺៈ ព៌ណ ក្លិន រស ឱជា និង ធាតុទាំង ៤ ការសន្មតិថា “សក់” ទើបមាន, ព្រោះកិរិយាញែក នូវធម៌ទាំង ៨ នោះឯង ការសន្មតិថា “សក់” ទើបមិនមាន,

ព្រោះហេតុណា, ព្រោះហេតុនោះ ពាក្យថា “កេសា” *គ្រាន់តែជាពួក នៃធម៌ ៨ ប៉ុណ្ណោះឯង ។ ពាក្យថា* “រោម ជាដើម” *ក៏យ៉ាងដូច្នោះដែរ ។ ប៉ុន្តែក្នុងចំណែកទាំងនោះ ចំណែកណា មានកម្ម ជាសមុដ្ឋាន ចំណែកនោះ ចាត់ជាពួកនៃធម៌ ១០ ជាមួយគ្នានឹងជីវិតិន្ទ្រីយ៍ផង និង ភាវៈផង, តែថា ចំណែកនោះ ដល់នូវការរាប់ថា “បឋវីធាតុ អាបោធាតុ” ដោយអំណាចនៃស័ព្ទដែលប្រើមកដោយច្រើន ។ ព្រះយោគីគប្បីធ្វើទុក ក្នុងចិត្ត ដោយកលាប (ពួក) យ៉ាងនេះឯង ។*

កែបទចុណ្ណតោ

(២២៣) ពាក្យថា “ចុណ្ណតោ” *សេចក្តីថា មែនពិត បឋវីធាតុ គឺអាចារ្យ កាលកំណត់យក ដោយប្រមាណជាកណ្តាល ក្នុងសរីរៈនេះ មានលំអិត ដោយប្រភេទដ៏តូចក្រៃលែង ជាធូលីដ៏ល្អិត គប្បីជាលំអិត មានប្រមាណមួយទោណៈ (១៦ នាឡិ) ។ បឋវីធាតុនោះ គឺអាបោធាតុ*

ប្រមាណពាក់កណ្តាល អំពីបឋវីធាតុនោះ សង្គ្រោះហើយ គឺតេជោធាតុ រក្សាទុកហើយ គឺវាយោធាតុ បោកបក់ហើយ គង់មិនរោយរាយ មិនខ្ចាត់ខ្ចាយទៅ, បឋវីធាតុនោះ កាលមិនរោយរាយ មិនខ្ចាត់ខ្ចាយ រមែងចូលទៅជិតដល់នូវកិរិយាកំណត់ច្បាស់ មានវិធីជាច្រើនយ៉ាង មានការរាប់ ថា “ជាស្រី ជាប្រុស” ដូច្នេះជាដើមផង តែងប្រកាស នូវភាពនៃអាការៈ មានស្គម ធាត់ វែង ខ្លី រឹងប៉ឹង និង ទន់ភ្លន់ជាដើមផង ។

ចំណែក អាបោធាតុ ដែលដល់នូវភាពសើម មានអាការៈជ្រួតជ្រាប ក្នុងសរីរៈនេះ មានបឋវីធាតុជាទីតាំង ត្រូវតេជោធាតុតាមរក្សាហើយ ត្រូវវាយោធាតុបក់ផាត់ហើយ រមែងមិនហូរចេញ មិនស្រកចុះ, កាលមិនហូរចេញ មិនស្រកចុះ ទើបរមែងបង្ហាញនូវភាពពេញព្រៀប ។

ចំណែកតេជោធាតុ ដែលមានភាពក្តៅជាលក្ខណៈ មានចំហាយជាអាការៈកើតហើយ ញុំាងរបស់ដែលគេស៊ី-ផឹកជាដើម ឲ្យរលួយ ក្នុងសរីរៈនេះ អាស្រ័យបឋវីធាតុ ត្រូវអាបោធាតុ ជួយសង្គ្រោះហើយ ត្រូវវាយោធាតុ បក់ផាត់ហើយ រមែងធ្វើកាយនេះឲ្យក្តៅផង រមែងនាំមកនូវការដល់ព្រម ដោយពណ៌សម្បុរ ដល់រាងកាយនោះផង ។ មួយទៀតកាយនេះ ត្រូវតេជោធាតុកំដៅហើយ ទើបមិនសំដែងនូវភាពស្អុយ ។

ចំណែកឯ វាយោធាតុ ផ្សាយទៅកាន់អវយវៈតូច និង ធំ មានលក្ខណៈបោកបក់ឲ្យញាប់ញ័របាន តាំងនៅបានព្រោះបឋវីធាតុ ត្រូវបានអាបោធាតុសង្គ្រោះហើយ ត្រូវតេជោធាតុ រក្សាទុកហើយ ទើបញុំាងកាយនេះ ឲ្យហើមបាន ។ ក៏កាយនេះ ត្រូវវាយោធាតុឲ្យហើមហើយ រមែងមិនទ្រុតទ្រោត បិតនៅត្រង់, កាយនេះ ត្រូវវាយោធាតុដទៃទៀត បក់បន្ថែមហើយ តែងបង្ហាញនូវការដើងច្បាស់ ក្នុងឥរិយាបថដើរ ឈរ

អង្គុយ និង ដេក បត់ចូល លាចេញ រលាស់ដៃជើងបាន ។ យន្តគឺធាតុនេះ ជាគ្រឿងបញ្ឆោត នៃជនពាល ដោយភាពមានភាពជាស្រីប្រុស ជាដើម ប្រាកដស្មើដោយមាយារូប តែងប្រព្រឹត្តទៅយ៉ាងដូច្នេះឯង ។ ព្រះយោគី គប្បីធ្វើទុកក្នុងចិត្ត នូវធាតុទាំងនោះ ដោយលំអិត យ៉ាងនេះ ។

កែបទលក្ខណាទិតោ

(២២៤) ពាក្យថា "លក្ខណាទិតោ" សេចក្តីថា ព្រះយោគីគប្បីពិចារណា នូវធាតុទាំង ៤ យ៉ាងនេះថា "បឋវីធាតុ មានអ្វីជាលក្ខណៈ មានអ្វីជាកិច្ច មានអ្វីជាផល" យ៉ាងដូច្នេះហើយ ត្រូវធ្វើទុកក្នុងចិត្តដោយអាការៈមានលក្ខណៈជាដើម យ៉ាងនេះថា :

"បឋវីធាតុ មានភាពរឹងគ្រោតគ្រាតជាលក្ខណៈ មានការតាំងនៅស៊ប់ជាកិច្ច មានការទទួលព្រមជាផល,

អាបោធាតុ មានការហូរចេញទៅជាលក្ខណៈ មានការចំរើនជាកិច្ច មានកិរិយាជ្រោមជ្រែងជាផល,

តេជោធាតុ មានភាពក្តៅជាលក្ខណៈ មានការអប់កំដៅជាកិច្ច មានកិរិយាផ្តល់ឲ្យនូវភាពទន់ជាផល,

វាយោធាតុ មានកិរិយាបក់ផាត់ជាលក្ខណៈ មានកិរិយាលាន់ឮឡើងជាកិច្ច មានកិរិយារេបានជាផល" ដូច្នេះ ។

កែបទសមុដ្ឋានតោ

(២២៥) ពាក្យថា "សមុដ្ឋានតោ" សេចក្តីថា ព្រះយោគីគប្បីធ្វើទុកក្នុងចិត្តនូវធាតុទាំងឡាយ ដោយសមុដ្ឋាន យ៉ាងនេះថា "ព្រះមានព្រះភាគ ទ្រង់សំដែងនូវចំណែក ៤២ មានសក់ជាដើម ដោយអំណាចនៃការសំដែងនូវចំណែកនៃធាតុ មានបឋវីធាតុជាដើម ដោយពិស្តារ នេះឯណា

ក្នុងចំណែកទាំងឡាយនោះ ចំណែកទាំងឡាយ ៤ នេះ គឺ "អាហារថ្មី អាហារចាស់ ខ្ទុះ ទឹកមូត្រ" មានរដូវ ជាសមុដ្ឋានតែម្យ៉ាង, ចំណែកទាំងឡាយ ៤ នេះ "ទឹកភ្នែក ញើស ទឹកមាត់ ទឹកសំបោរ" មានរដូវ និង ចិត្តជាសមុដ្ឋាន, ភ្លើងសំរាប់ចំអិននូវអាហារដែលបុគ្គលស៊ីហើយជាដើម មានកម្មជាសមុដ្ឋានតែម្យ៉ាង, ខ្យល់ដកដង្ហើមចេញ និង ខ្យល់ដកដង្ហើមចូល មានចិត្តជាសមុដ្ឋានតែម្យ៉ាង, ឯចំណែកទាំងឡាយដ៏សេសមានសមុដ្ឋាន ៤" ដូច្នេះឯង ។

កែបទនានត្តេកត្តតោ

(២២៦) ពាក្យថា "នានត្តេកត្តតោ" សេចក្តីថា ធាតុទាំងឡាយទាំងពួង មានភាពផ្សេងៗគ្នា ដោយអាការៈមានលក្ខណៈជាដើម ។ មែនពិត លក្ខណៈ កិច្ច និង ផល នៃបឋវីធាតុ សុទ្ធតែផ្សេងគ្នា ។ លក្ខណៈ កិច្ច និង ផល នៃធាតុទាំងឡាយមានអាបោធាតុជាដើមក៏ផ្សេងគ្នាដែរ ។ តែធាតុទាំងឡាយនោះ សូម្បីមានភាពផ្សេងៗគ្នា ដោយអំណាចអាការៈមានលក្ខណៈជាដើម និង ដោយអំណាចនៃសមុដ្ឋាន មានកម្មសមុដ្ឋានជាដើម ក៏នៅតែមានសេចក្តីតែមួយ ដោយអំណាចនៃភាពជារូប ជាមហាភូត ជាធាតុ ជាធម៌ និង ជារបស់មិនទៀងទាត់ជាដើម ។

មែនពិត ធាតុទាំងអស់ ឈ្មោះថា រូប ព្រោះធាតុទាំងនោះ មិនកន្លងនូវលក្ខណៈ នៃការវិនាសទ្រុឌទ្រោមទៅបាន, ឈ្មោះថា មហាភូត ព្រោះហេតុទាំងឡាយ មានភាពនៃកាយមានការប្រាកដច្រើនជាដើម ។

កែបទមហន្តបាតុភាវាទីហិ

(២២៧) ពាក្យថា "មហន្តបាតុភាវាទីហិ" សេចក្តីថា ក៏ធាតុទាំងឡាយនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា មហាភូត ដោយហេតុទាំង

ឡាយនេះ គឺ: ដោយភាពនៃធាតុនោះជាធាតុប្រាកដច្រើនផង ដោយភាពស្មើគ្នាដោយមហាភូតផង ដោយការថែរក្សាធំផង ដោយការប្រែប្រួលធំផង ដោយព្រោះជាធម្មជាតធំ និង ព្រោះជារបស់ពិតផង ។

កែបទមហន្តបាតុភាវតោ

បណ្ដាបទទាំងនោះ បទថា "មហន្តបាតុភាវតោ" សេចក្ដីថា ពិតមែនហើយ មហាភូតទាំង ៤ នេះ ប្រាកដ ជារបស់ធំ ក្នុងសន្ដានដែលមិនមានចិត្តគ្រប់គ្រងផង ក្នុងសន្ដានដែលមានចិត្តគ្រប់គ្រងផង ។ ភាពដែលប្រាកដជារបស់ធំ នៃសន្ដានទាំងពីរនោះ ក្នុងសន្ដានដែលមិនមានចិត្តគ្រប់គ្រង ខ្ញុំពោលហើយមែនពិត ក្នុងពុទ្ធានុស្សតិនិទ្ទេស ដោយន័យមានន័យ ថា :

ផែនដីនេះ បណ្ឌិតពោលដោយកំរាស់ថាមានប្រមាណ
ប៉ុណ្ណេះ គឺ : ២៤០,០០០ យោជន៍ ដូច្នេះជាដើម ។

ឯបាតុភូតទាំងឡាយ ដ៏ជាធំហ្នឹងឯង តែងមានសូម្បីក្នុងសន្ដានដែលមានចិត្តគ្រប់គ្រង ដោយអំណាចនៃត្រី អណ្ដើក ទេវតា និង អសុរជាដើម ។ សមដូចជា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អត្តភាពទាំងឡាយ សូម្បីមានប្រវែងមួយរយយោជន៍ ក៏មានដែរ ក្នុងមហាសមុទ្រ" ដូច្នេះជាដើម ។

កែបទមហាភូតសាមញ្ញតោ

បទថា "មហាភូតសាមញ្ញតោ" សេចក្ដីថា ក៏មហាភូតទាំងនេះ ខ្លួនឯង មិនមែនមានពណ៌ខៀវទេ (តែ)សំដែងនូវឧបាទាយរូប (រូបដែលអែបអាស្រ័យ) ជាពណ៌ខៀវបាន, ខ្លួនឯង មិនមែនមានពណ៌លឿងទេ (តែ) សំដែងនូវឧបាទាយរូប ជាពណ៌លឿងបាន, ខ្លួនឯង មិនមែនមាន

ពណ៌ក្រហមទេ (តែ) សំដែងឧបាទាយរូប ជាពណ៌ក្រហមបាន, ខ្លួនឯង មិនមែនមានពណ៌សសោះ (តែ)សំដែងនូវឧបាទាយរូប ជាពណ៌សបាន ប្រៀបបីដូចជា មនុស្សអ្នកមានកលល្បិច សំដែងធ្វើទឹកដែលមិនមែនជាកែវមណីសោះ ឲ្យទៅជាកែវមណីបាន, សំដែង ធ្វើដុំដី ដែលមិនមែនជាមាសសោះ ឲ្យទៅជាមាសបាន, មួយទៀត ប្រៀបបីដូចជា មនុស្សអ្នកមានកលល្បិចនោះ ខ្លួនឯង មិនមែនជាយក្ខ មិនមែនជាបក្សីសោះ (តែ) សំដែងនូវភាពជាយក្ខ ក៏បាន នូវភាពជាបក្សី ក៏បាន យ៉ាងដូច្នោះឯង ។ ព្រោះហេតុនោះ ធាតុទាំងឡាយនោះ ទើបឈ្មោះថា មហាភូត ព្រោះស្មើគ្នាដោយមនុស្សមានមាយាច្រើន គឺមនុស្សមានកលល្បិច ។

មួយទៀត មហាភូតទាំងឡាយ មានយក្ខជាដើម ចាប់នូវបុគ្គលណា, ទីខាងក្នុងនៃមហាភូតទាំងនោះ គឺបុគ្គលនោះកំណត់ដឹងមិនបាន ទីខាងក្រៅ នៃមហាភូតទាំងនោះ គឺបុគ្គលនោះ កំណត់ដឹងមិនបាន តែថា មហាភូតទាំងឡាយនោះ មិនមែនមិនអាស្រ័យនូវបុគ្គលនោះ ឋិតនៅទេ យ៉ាងណាមិញ, សូម្បីភូតគឺធាតុទាំងឡាយនេះ ជាធម្មជាតិមិនឋិតនៅឰដ៏ខាងក្នុង មិនឋិតនៅឰដ៏ខាងក្រៅ នៃគ្នានឹងគ្នាទេ គឺបុគ្គលកំណត់ដឹងបាន តែថា វាមិនមែនមិនឋិតនៅអាស្រ័យនូវគ្នានឹងគ្នាទេ ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ ធាតុទាំងឡាយនោះ ឈ្មោះថា មហាភូត ក៏ព្រោះភាវៈជារបស់ស្មើគ្នា ដោយមហាភូត មានយក្ខជាដើម ព្រោះភាវៈនៃទីតាំង គឺបុគ្គលមិនគួរគិត ប្រការមួយ ។

មួយទៀត មហាភូតទាំងឡាយ ពោលគឺយក្ខិនី បិទបាំងនូវភាពនៃខ្លួនជាភូតដែលគួរឲ្យភ័យខ្លាច ហើយបញ្ឆោតនូវសត្វទាំងឡាយដោយការសំដែងនូវពណ៌សម្បុរ និង ទ្រង់ទ្រាយ ដែលជាទីពេញចិត្ត យ៉ាង

ណាមិញ, សូម្បីភូតគឺធាតុទាំងឡាយនេះ បិទបាំងនូវរស និង លក្ខណៈរបស់ខ្លួន ផ្សេងដោយសភាពមានភាពនៃខ្លួនជារបស់រឹងជាដើម បញ្ឆោតនូវជនពាល ដោយឆវីវណ្ណ ដែលជាទីគាប់ចិត្តផង ដោយទ្រង់ទ្រាយ នៃអវយវៈតូចធំ ដែលជាទីគាប់ចិត្តផង ដោយការសំដែងនូវដៃ ជើង ម្រាមដៃ និង ចិញ្ចើមជាដើម ដែលជាទីគាប់ចិត្តផង មិនឲ្យឃើញ នូវសភាពរបស់ខ្លួនបាន ក៏យ៉ាងដូច្នោះដែរ ។ ព្រោះហេតុនោះ ធាតុទាំងឡាយនោះទើបឈ្មោះថា មហាភូត ព្រោះភាវៈជាធាតុមានភាពស្មើគ្នា ដោយមហាភូត គឺ យក្ខិនី ព្រោះភាវៈនៃធាតុជាគ្រឿងបញ្ឆោត ប្រការមួយ ។

តែបទមហាបរិហារតោ

(២២៨) បទថា “មហាបរិហារតោ” *សេចក្តីថា ព្រោះភាវៈនៃធាតុជារបស់ដែលបុគ្គលគប្បីថែរក្សា ដោយបច្ច័យទាំងឡាយដ៏ច្រើន ។ មែនពិត ភូតគឺធាតុទាំងឡាយនោះមានហើយ គឺប្រព្រឹត្តទៅហើយដោយបច្ច័យទាំងឡាយមានគ្រឿងស៊ី និង គ្រឿងស្លៀកពាក់ជាដើមយ៉ាងច្រើន ព្រោះភាវៈនៃបច្ច័យនោះ គឺបុគ្គលគប្បីនាំចូលទៅ រៀងរាល់ថ្ងៃៗ ព្រោះហេតុនោះ ទើបឈ្មោះថា មហាភូត ។ម្យ៉ាងទៀត ឈ្មោះថា មហាភូត ព្រោះជាភូតដែលមានកិរិយាថែរក្សាដ៏ច្រើន ដូច្នេះក៏បានដែរ ។*

តែបទមហាវិការតោ

បទថា “មហាវិការតោ” *សេចក្តីថា ពិតមែនហើយ ភូតគឺធាតុទាំងឡាយនុ៎ះ ជាមហាភូតដែលមានវិញ្ញាណប្រកាន់ខ្លះ មិនមានវិញ្ញាណប្រកាន់ខ្លះ ជាមហាភូតមានវិការដ៏ច្រើន ។ ក្នុងចំណោម ២ យ៉ាងនោះ សំរាប់មហាភូតដែលមិនមានវិញ្ញាណប្រកាន់ ភាពនៃមហាភូតមានវិការៈដ៏ធំ រមែងប្រាកដ ក្នុងពេលដែលកប្បវិនាស សំរាប់មហាភូត ដែលមាន*

វិញ្ញាណប្រកាន់យក ភាពនៃមហាភូតមានវិការៈដ៏ធំ រមែងប្រាដក ក្នុងពេលដែលធាតុកំរើក ។ ពិតដូច្នោះមែន

អណ្តាតភ្លើងរាលដាលឡើងអំពីផែនដី ឆាបឡើង
រហូតទៅដល់ព្រហ្មលោក នាកាលលោក ត្រូវភ្លើង
ដែលមានអណ្តាតឆាបឆេះ ។

លោក តែងវិនាស ដោយទឹក ដែលកំរើកហើយ
ក្នុងពេលណា ក្នុងពេលនោះ ចក្រវាឡមួយ មានមួយ
សែនកោដិ រមែងរលាយ ។

លោក វិនាស ដោយការកំរើកនៃវាយោធាតុ ក្នុង
ពេលណា ក្នុងពេលនោះ ចក្រវាឡមួយ មានមួយ
សែនកោដិ រមែងរលាយ ។

កាយត្រូវពស់មានមាត់ជាវិការៈនៃឈើចឹកហើយ
រមែងជាកាយរឹងតាំង ឬថា កាយនោះ ជាកាយរឹងតាំង
ក្នុងមាត់នៃពស់ជាវិការៈនៃឈើ ព្រោះកិរិយាកំរើក នៃ
បឋវីធាតុហ្នឹងឯង ។

កាយ ត្រូវពស់មានមាត់ស្អុយចឹកហើយ ជាកាយ
ស្អុយ ឬថា កាយនោះ ជាកាយស្អុយ ក្នុងមាត់នៃពស់
មានមាត់ស្អុយ ព្រោះការកំរើកនៃអាបោធាតុហ្នឹងឯង ។

កាយ ត្រូវពស់មានមាត់ជាវិការៈនៃភ្លើងចឹកហើយ
ជាកាយក្តៅសព្វ ឬថា កាយនោះ ជាកាយក្តៅសព្វ ក្នុង
មាត់នៃពស់ជាវិការៈនៃភ្លើង ព្រោះតេជោធាតុកំរើក ។

កាយ ត្រូវពស់មានមាត់ដូចជាកាំបិត ចឹកហើយ

> រមែងជាកាយដាច់ដាចហើយ ឬថា កាយនោះ ជាកាយដាច់ដាច ក្នុងមាត់នៃពស់មានមាត់ដូចជាកាំបិត ព្រោះការកំរើកនៃវាយោធាតុហ្នឹងឯង ។

ភូត គឺធាតុទាំងឡាយ មានវិការៈច្រើន យ៉ាងនេះ ព្រោះហេតុនោះ ទើបឈ្មោះថា មហាភូត ។

កែបទមហត្តា ភូតត្តា ច

ពីរបទថា “មហត្តា ភូតត្តា ច” *សេចក្តីថា ភូតគឺធាតុទាំងឡាយនោះ ឈ្មោះថា ជារបស់ធំ ព្រោះភាវៈនៃភូតទាំងនោះ ជាភូតគឺបុគ្គលថែរក្សា ដោយសេចក្តីព្យាយាមដ៏ធំ ឈ្មោះថា ភូត (របស់ពិត) ព្រោះភាវៈនៃភូតទាំងនោះជារបស់មាននៅ ព្រោះហេតុដូច្នោះ ភូតគឺធាតុទាំងនោះ ឈ្មោះថា មហាភូត ព្រោះជារបស់ធំផង ព្រោះជារបស់ពិតផង ។*

ធាតុទាំងអស់ហ្នឹងឯង ឈ្មោះថា មហាភូត ដោយហេតុទាំងឡាយ មានភាពជាធំ និង ភាពប្រាកដជាដើម ។ តែធាតុទាំងអស់នោះ ឈ្មោះថា ធាតុ ព្រោះទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ១ ព្រោះជាទីតាំងនៃសេចក្តីទុក្ខ ១ ព្រោះបង្ហូរមកនូវសេចក្តីទុក្ខ ១ ព្រោះមិនកន្លងនូវលក្ខណៈនៃធាតុ ។ ឈ្មោះថា ធម៌ ព្រោះទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួនផង ព្រោះទ្រទ្រង់តាមសមគួរដល់ខណៈរបស់ខ្លួនផង ។ ឈ្មោះថា មិនទៀង ព្រោះសេចក្តីថា អស់ទៅ, ឈ្មោះថា ជាទុក្ខ ព្រោះសេចក្តីថា ប្រកបដោយភ័យ ឈ្មោះថា មិនមែនខ្លួន ព្រោះសេចក្តីថា មិនមានខ្លឹមសារ ។ ភាពនៃធាតុទាំងពួង ជាធាតុមានសេចក្តីតែមួយ ដោយអំណាចភាវៈជារូប ជាមហាភូត ជាធាតុ ជាធម៌ និង ជារបស់មិនទៀងជាដើម

ដោយប្រការដូច្នេះឯង ។ ព្រះយោគី គប្បីធ្វើទុកក្នុងចិត្ត ដោយភាពដែលផ្សេងគ្នា និង ភាពដែលត្រូវគ្នា ដូចបានពណ៌នាមកនេះឯង ។

កែបទវិនិព្ភោគាវិនិព្ភោគតោ

(២២៩) បទថា “វិនិព្ភោគាវិនិព្ភោគតោ” *សេចក្តីថា ធាតុទាំងនោះ កើតព្រមគ្នាមែនពិត ជាធាតុបែកគ្នាមិនបាន តាមចំណែក សូម្បីក្នុងកលាប(បាច់)មួយៗ មានសុទ្ធដ្ឋកលាបជាដើម ក្នុងទីបំផុតនៃកលាបទាំងពួង ។ ប៉ុន្តែដោយលក្ខណៈ ធាតុទាំងនោះ បែកគ្នាបាន ព្រោះហេតុនោះ ព្រះយោគី គប្បីធ្វើទុកក្នុងចិត្ត ដោយភាពញែកគ្នាបាន និង ភាពញែកគ្នាមិនបាន ដូចបានពោលមកនេះឯង ។*

កែបទសភាគវិសភាគតោ

(២៣០) បទថា “សភាគវិសភាគតោ” *សេចក្តីថា បណ្តាធាតុទាំង ៤ នោះ សូម្បីដែលញែកពីគ្នាមិនបាន យ៉ាងនេះ ធាតុ ២ ខាងដើម មានចំណែកស្មើគ្នា ព្រោះភាវៈនៃធាតុទាំងនោះមានភាពធ្ងន់, ធាតុ ២ ខាងចុង ក៏យ៉ាងនោះដែរគឺមានចំណែកស្មើគ្នា ព្រោះមានភាពស្រាលដូចគ្នា, ប៉ុន្តែធាតុ ២ ខាងដើម មានចំណែកមិនស្មើគ្នាដោយធាតុ ២ ខាង ចុង និង ធាតុ ២ ខាងចុង មានចំណែកមិនស្មើគ្នា ដោយធាតុ ២ ខាងដើម ព្រោះហេតុនោះ ព្រះយោគីគប្បីធ្វើទុកក្នុងចិត្ត ដោយភាពដែលមានចំណែកស្មើគ្នា និង មិនស្មើគ្នា ដូចបានពោលមកនេះឯង ។*

កែបទអជ្ឈត្តិកពាហិរវិសេសតោ

បទថា “អជ្ឈត្តិកពាហិរវិសេសតោ” *សេចក្តីថា ធាតុទាំងឡាយជាខាងក្នុង ជាទីអាស្រ័យ នៃវិញ្ញាណវត្ថុ វិញ្ញត្តិ និង ឥន្ទ្រិយ៍ទាំងឡាយប្រកបដោយឥរិយាបថ មានសមុដ្ឋាន ៤, ចំណែកឯធាតុទាំងឡាយខាង*

ក្រៅ មានប្រការផ្ទុយផ្សេងគ្នានឹងធាតុដែលលោកពោលហើយ ព្រោះហេតុនោះ ព្រះយោគី គប្បីធ្វើទុកក្នុងចិត្ត ដោយភាពប្លែកគ្នានៃធាតុខាងក្នុង និង ធាតុខាងក្រៅ ដូចបានពោលមកនេះឯង ។

តែបទសង្គហតោ

(២៣១) បទថា "សង្គហតោ" សេចក្តីថា ព្រះយោគីគប្បីធ្វើទុកក្នុងចិត្ត ដោយការសង្គ្រោះ យ៉ាងនេះថា "បឋវីធាតុ មានកម្មជាសមុដ្ឋាន សង្គ្រោះចូលជាមួយគ្នា ដោយធាតុទាំងឡាយក្រៅនេះ ដែលមានកម្មជាសមុដ្ឋាន ព្រោះមិនមានភាពផ្សេងៗ គ្នា នៃសមុដ្ឋាន, បឋវីធាតុ ដែលមានចិត្តជាដើមជាសមុដ្ឋាន ក៏យ៉ាងនោះដែរ គឺសង្គ្រោះចូលជាមួយគ្នា ដោយធាតុទាំងឡាយ ដែលមានចិត្តជាដើមជាសមុដ្ឋាន" ។

តែបទបច្ចយតោ

បទថា "បច្ចយតោ" សេចក្តីថា បឋវីធាតុ ត្រូវអាបោធាតុបំរុងទុក ត្រូវតេជោធាតុ ថែរក្សាទុក ត្រូវវាយោធាតុ បក់ផ្លុំទុក ជាបច្ច័យជាទីពឹងផ្អែក នៃមហាភូតទាំងឡាយបី,

អាបោធាតុ ត្រូវបឋវីធាតុតំកល់ទុក ត្រូវតេជោធាតុតាមរក្សាទុក ត្រូវវាយោធាតុបក់ផ្លុំទុក ជាបច្ច័យគ្រឿងជ្រាបសើមនៃមហាភូតទាំងបី,

តេជោធាតុ ត្រូវបឋវីធាតុតំកល់ទុក ត្រូវអាបោធាតុសង្គ្រោះទុក ត្រូវវាយោធាតុបក់ផ្លុំទុក ជាបច្ច័យគ្រឿងចំអិនទុក នៃមហាភូតទាំងបី,

វាយោធាតុ ត្រូវបឋវីធាតុតំកល់ទុក ត្រូវអាបោធាតុសង្គ្រោះ ត្រូវតេជោធាតុចំអិនទុក ជាបច្ច័យជាគ្រឿងបក់ផ្លុំ នៃមហាភូតទាំងបី,

ព្រោះហេតុនោះ ព្រះយោគី គប្បីធ្វើទុកក្នុងចិត្ត ដោយបច្ច័យដូចបានពណ៌នាមកយ៉ាងនេះឯង ។

តែបទអសមន្នាហារតោ

បទថា "អសមន្នាហារតោ" សេចក្តីថា ក៏បណ្តាធាតុទាំងបួននុ៎ះ បឋវីធាតុ មិនដឹងថា "អញជាបឋវីធាតុ" ដូច្នេះផង ថា "អញជាទីពឹងនៃមហាភូតទាំងបី ជាបច្ច័យ(នៃមហាភូតទាំងបី)" ដូច្នេះផង, សូម្បីមហាភូតទាំងបីក្រៅនេះ ក៏មិនដឹងថា "បឋវីធាតុ ជាទីពឹង ជាបច្ច័យនៃយើងទាំងឡាយ" ដូច្នេះដែរ, ន័យក្នុងធាតុទាំងពួង ក៏ដូចន័យនេះឯង ព្រោះហេតុនោះ ព្រះយោគី គប្បីធ្វើទុកក្នុងចិត្ត ដោយភាពដែលមិនដឹងនូវគ្នានឹងគ្នា ដូចបានពោលមកនេះឯង ។

តែបទបច្ចយវិភាគតោ

បទថា "បច្ចយវិភាគតោ" សេចក្តីថា ក៏បច្ច័យ របស់ធាតុទាំងបួន គឺកម្ម ចិត្ត អាហារ និង រដូវ ។ បណ្តាធាតុទាំងនោះ កម្មតែម្យ៉ាងជាបច្ច័យនៃធាតុទាំងឡាយដែលមានកម្មជាសមុដ្ឋាន, សភាវៈទាំងឡាយមានចិត្តជាដើម មិនមែនជាបច្ច័យទេ ។ សភាវៈទាំងឡាយ មានចិត្តជាដើម ជាបច្ច័យនៃធាតុទាំងឡាយដែលមានចិត្តជាដើមជាសមុដ្ឋានហ្នឹងឯង សភាវៈក្រៅពីនេះ មិនមែនជាបច្ច័យទេ ។

មួយទៀត កម្ម ជាបច្ច័យជាហេតុឲ្យកើត (ជនកបច្ច័យ) នៃធាតុទាំងឡាយដែលមានកម្មជាសមុដ្ឋាន ជាបច្ច័យដែលចូលទៅអាស្រ័យ (ឧបនិស្សយបច្ច័យ) នៃធាតុទាំងឡាយដ៏សេស ដោយបរិយាយ ។

ចិត្ត ជាបច្ច័យជាហេតុឲ្យកើត នៃធាតុទាំងឡាយដែលមានចិត្តជាសមុដ្ឋាន ជាបច្ឆាជាតប្បច្ច័យ (បច្ច័យដែលកើតក្រោយ) ជាអត្ថិប្បច្ច័យ (បច្ច័យដែលមាន) និងជាអវិគតប្បច្ច័យ(បច្ច័យដែលមិនទៅប្រាសពីគ្នា) នៃធាតុទាំងឡាយដ៏សេស ។

អាហារ ជាជនកប្បច្ច័យ (បច្ច័យជាហេតុឲ្យកើត) នៃធាតុទាំងឡាយដែលមានអាហារជាសមុដ្ឋាន, ជាអាហារប្បច្ច័យ (បច្ច័យជាគ្រឿងនាំមកនូវផល) ជាអត្ថិប្បច្ច័យ និង ជាអវិគតប្បច្ច័យ នៃធាតុទាំងឡាយដ៏សេស ។

រដូវ ជាឧតុជនកប្បច្ច័យ នៃធាតុទាំងឡាយ ដែលមានរដូវជាសមុដ្ឋាន, ជាអត្ថិប្បច្ច័យ និង ជាអវិគតប្បច្ច័យ នៃធាតុទាំងឡាយដ៏សេស ។

មហាភូត ដែលមានកម្មជាសមុដ្ឋាន ជាបច្ច័យនៃមហាភូតទាំងឡាយ ដែលមានកម្មជាសមុដ្ឋានផង ជាបច្ច័យនៃធាតុទាំងឡាយ ដែលមានចិត្តជាដើមជាសមុដ្ឋានផង,

មួយទៀត មហាភូតដែលមានចិត្តជាសមុដ្ឋាន ជាបច្ច័យនៃមហាភូតទាំងឡាយ ដែលមានចិត្តជាសមុដ្ឋានផង ជាបច្ច័យនៃធាតុទាំងឡាយ ដែលមានកម្មជាដើមជាសមុដ្ឋានផង ។

មហាភូត ដែលមានអាហារជាសមុដ្ឋាន ជាបច្ច័យនៃមហាភូតទាំងឡាយ ដែលមានអាហារជាសមុដ្ឋានផង ជាបច្ច័យនៃធាតុទាំងឡាយ ដែលមានកម្មជាដើមជាសមុដ្ឋានផង ។

មហាភូត ដែលមានរដូវជាសមុដ្ឋាន ជាបច្ច័យនៃមហាភូតទាំងឡាយ ដែលមានរដូវជាសមុដ្ឋានផង ជាបច្ច័យនៃធាតុទាំងឡាយដែលមានកម្មជាដើមជាសមុដ្ឋានផង ។

បណ្តាមហាភូត ដែលមានកម្មជាសមុដ្ឋានទាំងនោះ បឋវីធាតុ ដែលមានកម្មជាសមុដ្ឋាន ជាបច្ច័យនៃធាតុទាំងឡាយក្រៅនេះ ដែលមានកម្មជាសមុដ្ឋាន ដោយអំណាច នៃសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ

និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យផង ដោយអំណាចនៃទីតាំងផង, មិនមែនជាបច្ច័យ ដោយអំណាចនៃជនកប្បច្ច័យទេ, ជាបច្ច័យនៃមហាភូតដែលមានសន្តតិបី ក្រៅនេះ (គឺមហាភូតដែលមានចិត្ត អាហារ និង រដូវជាសមុដ្ឋាន) ដោយអំណាចនៃនិស្សយប្បច្ច័យ អត្ថិ-ប្បច្ច័យ និង អវិគតប្បច្ច័យ, មិនមែនជាបច្ច័យ ដោយអំណាចនៃទីតាំង មិនមែនជាបច្ច័យ ដោយអំណាចនៃជនកប្បច្ច័យទេ ។

មួយទៀត បណ្តាមហាភូតដែលមានកម្មជាសមុដ្ឋានទាំងនោះ អាបោធាតុ ជាបច្ច័យនៃធាតុទាំងឡាយបី ក្រៅពីនេះ ដោយអំណាចនៃសហជាតប្បច្ច័យជាដើមផង ដោយអំណាចនៃកិរិយាស្អុះទុកផង, មិនមែនជាបច្ច័យដោយអំណាចនៃជនកប្បច្ច័យទេ, ជាបច្ច័យដោយអំណាចនៃនិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យ នៃមហាភូតដែលមានសន្តតិបីក្រៅនេះដូចគ្នា, មិនមែនជាបច្ច័យ ដោយអំណាចនៃការស្អុះទុក មិនមែនដោយអំណាចនៃជនកប្បច្ច័យទេ ។

មួយទៀត បណ្តាមហាភូតដែលមានកម្មជាសមុដ្ឋានទាំងនោះ តេជោធាតុ ជាបច្ច័យនៃធាតុទាំងឡាយបី ក្រៅពីនេះ ដោយអំណាចនៃសហជាតប្បច្ច័យជាដើមផង ដោយអំណាចនៃកិរិយាអប់កំដៅផង, មិនមែនដោយអំណាចនៃជនកប្បច្ច័យទេ, ជាបច្ច័យ នៃមហាភូតទាំងឡាយដែលមានសន្តតិបីក្រៅនេះ ដោយអំណាចនិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យដូចគ្នា, មិនមែនជាបច្ច័យ ដោយអំណាចនៃកិរិយាអប់កំដៅ មិនមែនជាបច្ច័យ ដោយអំណាចនៃជនកប្បច្ច័យទេ ។

មួយទៀត បណ្តាមហាភូតដែលមានកម្មជាសមុដ្ឋានទាំងនោះ វាយោធាតុ ជាបច្ច័យ នៃធាតុទាំងឡាយបីក្រៅពីនេះ ដោយអំណាច នៃ

សហជាតប្បច្ច័យជាដើមផង ដោយអំណាចនៃកិរិយាបោកបក់ផង, មិនមែនដោយអំណាចនៃជនកប្បច្ច័យទេ, ជាបច្ច័យនៃមហាភូតទាំងឡាយដែលមានសន្តតិ ៣ ក្រៅអំពីនេះ ដោយអំណាចនៃនិស្សយប្បច្ច័យ, អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យដូចគ្នា, មិនមែនដោយអំណាចនៃកិរិយាបោកបក់ មិនមែនដោយអំណាចនៃជនកប្បច្ច័យទេ ។

ន័យ សូម្បីក្នុងមហាភូត មានបឋវីធាតុ ដែលមានចិត្ត អាហារ និង រដូវ ជាសមុដ្ឋានជាដើម ក៏ន័យនេះដែរ ។

ក៏ឯ បណ្តាធាតុទាំងឡាយនោះ ដែលប្រព្រឹត្តទៅ ដោយអំណាចបច្ច័យមានសហជាតប្បច្ច័យជាដើម ដូចពោលមកនេះ ធាតុទាំងឡាយបី អាស្រ័យនូវធាតុមួយ រមែងប្រែប្រួលដោយចំណែកបួន, ឯធាតុមួយអាស្រ័យនូវធាតុទាំងឡាយបី រមែងប្រែប្រួល ដោយចំណែកបួនដែរ, ធាតុទាំងឡាយពីរ អាស្រ័យនូវធាតុពីរ រមែងបានទៅជាប្រាំមួយ ។

មែនពិត បណ្តាធាតុទាំងឡាយ មានបឋវីធាតុជាដើម ធាតុទាំងឡាយ ៣ អាស្រ័យនូវធាតុ ១ យ៉ាងនេះ គឺ: “ធាតុទាំងឡាយបីៗ ក្រៅនេះ អាស្រ័យហើយនូវធាតុមួយៗ” រមែងប្រែប្រួលដោយចំណែក ៤ ។ យ៉ាងដូចគ្នានោះដែរ បណ្តាធាតុទាំងឡាយមានបឋវីធាតុជាដើម ធាតុមួយ អាស្រ័យនូវធាតុទាំងឡាយបី យ៉ាងនេះគឺ “ធាតុមួយ អាស្រ័យនូវធាតុទាំងឡាយបីក្រៅនេះ” រមែងប្រែប្រួលដោយចំណែក ៤ ។ ប៉ុន្តែធាតុទាំងឡាយពីរ អាស្រ័យនូវធាតុទាំងឡាយពីរ យ៉ាងនេះគឺ “ធាតុទាំងឡាយពីរខាងចុង អាស្រ័យនូវធាតុទាំងឡាយពីរខាងដើម និង ធាតុទាំងឡាយពីរខាងដើម អាស្រ័យនូវធាតុទាំងឡាយពីរខាងចុង, ធាតុទីពីរ និង ធាតុទីបួន អាស្រ័យនូវធាតុទីមួយ និង ធាតុទីបី, ធាតុទីមួយ និង

ធាតុទីបី អាស្រ័យនូវធាតុទីពីរ និង ធាតុទីបួន, ធាតុទីពីរ និង ធាតុទីបី អាស្រ័យនូវធាតុទីមួយ និង ធាតុទីបួន, ឯធាតុទីមួយ និង ធាតុទីបួន អាស្រ័យធាតុទីពីរ និង ធាតុទីបី” រមែងបានទៅជាចំណែកប្រាំមួយ ។

បណ្តាធាតុទាំងនោះ បឋវីធាតុ ជាបច្ច័យនៃការបៀតបៀន ក្នុងកាលនៃកិច្ចមានការឈានទៅមុខ និង ការឈានថយក្រោយជាដើម ។ បឋវីធាតុនោះឯង គឺអាបោធាតុជ្រួតជ្រាបទៅហើយ ជាបច្ច័យនៃកិរិយាញុំាងកាយឲ្យតាំងនៅ, ឯអាបោធាតុគឺបឋវីធាតុទៅតាមហើយ ជាបច្ច័យនៃការមិនខ្ចាត់ខ្ចាយ, វាយោធាតុ គឺវាយោធាតុទៅតាមហើយ ជាបច្ច័យនៃការលាន់ឮឡើង, វាយោធាតុ គឺតេជោធាតុទៅតាមហើយ ជាបច្ច័យនៃការឈានកន្ទង និង ការឈានថយក្រោយ យ៉ាងដូច្នេះឯង ។

ព្រះយោគីគប្បីធ្វើទុកក្នុងចិត្ត ដោយការញែកបច្ច័យ យ៉ាងនេះឯង ។

(ធាតុវវដ្ឋានធ្វើឱ្យសំរេចឧបចារសមាធិ)

មែនពិត កាលព្រះយោគី ធ្វើទុកក្នុងចិត្ត ដោយអំណាចនៃហេតុមានសេចក្តីនៃពាក្យជាដើម យ៉ាងដូច្នេះ, ធាតុទាំងឡាយ រមែងប្រាកដតាមមុខមួយៗ ។ កាលព្រះយោគី នឹករំពឹង ធ្វើទុកក្នុងចិត្តនូវធាតុទាំងនោះ រឿយៗ, ឧបចារសមាធិ រមែងកើតឡើង តាមន័យដែលលោកពោលហើយនោះឯង ។ ឧបចារសមាធិនេះនោះ រមែងដល់នូវការរាប់ថា “ចតុធាតុវវដ្ឋាន” ដូច្នេះមែនពិត ព្រោះការកើតឡើង ដោយអានុភាពនៃញាណដែលព្រះយោគីកំណត់នូវធាតុទាំង ៤ ។

(អានិសង្សនៃធាតុវវដ្ឋាន)

ចំណែកឯ ភិក្ខុអ្នកប្រកបរឿយៗ នូវចតុធាតុវវដ្ឋាននេះ គង់ចូលដល់សុញ្ញតា (ភាពសូន្យចាកខ្លួនប្រាណ) រមែងដកចេញនូវសត្តសញ្ញា

(ការសម្គាល់ថាជាសត្វជាបុគ្គល) បាន ។ ភិក្ខុនោះ ព្រោះខ្លួនដកឡើងសត្តសញ្ញាបានហើយ មិនដល់នូវការរន្ធត់ព្រោះភ័យ មានភ័យអំពីម្រឹគសាហាវ យក្ខ និង អារក្សទឹកជាដើម ជាអ្នកអត់សង្កត់បាននូវភ័យដ៏ពន្លឹក ជាអ្នកអត់សង្កត់ក្នុងសោមនស្ស និង ទោមនស្សបាន មិនដល់នូវការស្ងប់ស្ងល់ និង ការទន្ទឹះចិត្ត ក្នុងឥដ្ឋារម្មណ៍ និង អនិដ្ឋារម្មណ៍ទាំងឡាយ ។ មួយទៀត ភិក្ខុនោះ ជាអ្នកមានប្រាជ្ញាច្រើន ជាអ្នកមានព្រះនិព្វានឈ្មោះអមតៈជាទីបំផុត ឬ បើមិនដូច្នោះទេ ជាអ្នកមានសុគតិជាទីប្រព្រឹត្តទៅ ក្នុងកាលខាងមុខ ដោយប្រការដូច្នេះ ។

អ្នកមានប្រាជ្ញា គប្បីសេពគប់ ឲ្យជាប់ជានិច្ច នូវធាតុវវដ្ឋាន
នេះ ដែលមានអានុភាពច្រើន យ៉ាងនេះ ដែលព្រះយោគីដ៏
ប្រសើរ ដូចជាសីហៈ ធ្លាប់ប្រសប់មកហើយ ។

នេះគឺជាការនានិទ្ទេស នៃចតុធាតុវវដ្ឋាន ។

សរុបសមាធិនិទ្ទេស

(២៣៣) ចំណែកឯ បញ្ហាកម្មឯណា ដែលខ្ញុំធ្វើហើយដោយន័យមានន័យជាដើមថា "អ្វី ឈ្មោះថា សមាធិ ? ដែលឈ្មោះថា សមាធិ ដោយអត្ថថាដូចម្ដេច? " ដូច្នេះ ដើម្បីសំដែងសេចក្ដីពិស្ដារ និងន័យនៃការចំរើនសមាធិ, ក្នុងបញ្ហាកម្មនោះ អដ្ឋកថាជាគ្រឿងពណ៌នានូវសេចក្ដីនៃបទនេះថា " តើសមាធិ គប្បីចំរើន យ៉ាងដូចម្ដេច? " ដូច្នេះ បានចប់ហើយ ដោយប្រការទាំងពួង ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

សមាធិនេះនោះ មាន ២ យ៉ាងប៉ុណ្ណោះ ដែលបានអធិប្បាយហើយ ក្នុងទីនេះ គឺៈ ឧបចារសមាធិ ១ អប្បនាសមាធិ ១ ។ បណ្ដាសមាធិ ទាំង ២ យ៉ាងនោះ ភាពនៃចិត្តមានអារម្មណ៍តែមួយ ក្នុងកម្មដ្ឋាន

ទាំង ១០ និង ក្នុងចិត្តដែលជាចំណែកខាងដើមនៃអប្បនា ឈ្មោះថា ឧបចារសមាធិ, ភាពនៃចិត្តមានអារម្មណ៍តែមួយ ក្នុងកម្មដ្ឋានដ៏សេសទាំងឡាយ ឈ្មោះថា អប្បនាសមាធិ ។ សមាធិ ទាំង ២ យ៉ាងនោះ ឈ្មោះថា ជាធម៌គឺព្រះយោគីបានចំរើនហើយ ព្រោះកម្មដ្ឋានទាំងនោះ គឺលោកបានចំរើនហើយ ។ ព្រោះហេតុដូច្នោះ ខ្ញុំពោលហើយថា "ការពណ៌នានូវសេចក្ដី នៃបទនេះ ថា សមាធិ តើត្រូវចំរើន យ៉ាងដូចម្ដេច? ចប់សព្វគ្រប់ហើយ ដោយប្រការទាំងពួង" ដូច្នេះឯង ។

(អានិសង្សនៃការចំរើនសមាធិ)

ក៏ពាក្យឯណាដែលខ្ញុំពោលហើយ ថា "អ្វីជាអានិសង្ស នៃការចំរើនសមាធិ?" ដូច្នេះ, ក្នុងពាក្យនោះ មានសេចក្ដីឆ្លើយថា អានិសង្សនៃការចំរើនសមាធិ មាន ៥ ប្រការ មានការរស់នៅជាសុខ ក្នុងបច្ចុប្បន្នជាដើម ។

(មានការនៅជាសុខក្នុងបច្ចុប្បន្នជាអានិសង្ស)

ពិតដូច្នោះមែន ភិក្ខុទាំងឡាយណា ជាព្រះអរហន្ត មានអាសវៈអស់ហើយ ចំរើននូវសមាធិ ដោយតាំងចិត្តថា "យើងនឹងចូលសមាបត្តិមានចិត្តមានអារម្មណ៍តែមួយ នឹងនៅជាសុខស្រួល អស់មួយថ្ងៃ" ដូច្នេះ ការចំរើននូវអប្បនាសមាធិ របស់ភិក្ខុជាព្រះអរហន្តទាំងនោះ ឈ្មោះថា មានការរស់នៅជាសុខស្រួល ក្នុងបច្ចុប្បន្ន ជាអានិសង្ស ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលចុន្ទៈ តែតថាគត មិនទាន់ឲ្យឈ្មោះធម៌ទាំងនុ៎ះថា ជាសេចក្ដីផូរផង់ ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនុ៎ះថា ជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយ-វិន័យតែប៉ុណ្ណោះ" ដូច្នេះជាដើម ។

(មានវិបស្សនា ជាអានិសង្ស)

ទាំងការចំរើននូវអប្បនាសមាធិ ទាំងការចំរើននូវឧបចារសមាធិ ដោយន័យនៃការបាននូវឱកាសក្នុងទីចង្អៀត របស់ព្រះសេក្ខៈនិងបុថុជ្ជនទាំងឡាយអ្នកចំរើន ដោយមានបំណងថា "យើងទាំងឡាយ ចេញអំពីសមាបត្តិហើយនឹងធ្វើវិបស្សនា ដោយមានចិត្តដែលតំកល់នៅមាំ" ដូច្នេះ ឈ្មោះថា មានវិបស្សនាជាអានិសង្ស ព្រោះសមាធិនោះជាបទដ្ឋាន នៃវិបស្សនា ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចំរើននូវសមាធិ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុ មានចិត្តតំកល់មាំហើយ រមែងដឹងច្បាស់ តាមសេចក្តី (១) ពិត" ដូច្នេះជាដើម ។

(មានអភិញ្ញាជាអានិសង្ស)

ចំណែក ភិក្ខុទាំងឡាយណា ញុំាងសមាបត្តិ ៨ ឲ្យកើតហើយ ចូលឈានមានអភិញ្ញាជាទីតាំង ចេញពីសមាបត្តិហើយប្រាថ្នាធ្វើអភិញ្ញាទាំងឡាយ ដែលមានន័យដូចលោកពោលហើយថា "មនុស្សម្នាក់ធ្វើ ឲ្យទៅជាមនុស្សច្រើននាក់ក៏បាន (២) " ដូច្នេះជាដើម ឲ្យកើតឡើងបាន ។ ការចំរើនអប្បនាសមាធិ របស់ភិក្ខុទាំងឡាយនោះ ឈ្មោះថាមានអភិញ្ញាជាអានិសង្ស ព្រោះសមាធិនោះ កាលបើហេតុ (ដែលនឹងឲ្យបាន នូវអភិញ្ញា) មានព្រម ជាបទដ្ឋាននៃអភិញ្ញាបាន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "មួយទៀត ភិក្ខុនោះ បង្អោនចិត្តទៅ ដើម្បីធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាណាៗ, កាលបើហេតុមាន, រមែងដល់ នូវភាពគួរជាបន្ទាល់ ក្នុងធម៌នោះៗ ព្រោះធ្វើឲ្យជាក់ច្បាស់

១- សុ. សំ. ខ. ភាគទី ២០ ទំព័រទី៣៣ ។ ២- អំ. ឆ. ភាគទី ៤៦ ទំព័រទី ៣ ។

ដោយប្រាជ្ញា (១) " ដូច្នេះជាដើម ។

(មានភពវិសេសជាអានិសង្ស)

ភិក្ខុ ជាបុថុជ្ជនទាំងឡាយណាៗ មានឈានមិនសាបសូន្យហើយ កាលប្រាថ្នា នូវកិរិយាកើតក្នុងព្រហ្មលោកថា "យើងនឹងកើត ក្នុងព្រហ្មលោក" ដូច្នេះក្តី កាលមិនប្រាថ្នាក្តី រមែងមិនសាបសូន្យចាកសមាធិ, ការចំរើននូវអប្បនាសមាធិ របស់ភិក្ខុជាបុថុជ្ជនទាំងឡាយនោះ ឈ្មោះថា មានភពវិសេសជាអានិសង្ស ព្រោះសមាធិនោះ ជាគុណនាំមកនូវភពដ៏វិសេស ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ចុះបុគ្គលទាំងឡាយ ចំរើនបឋមជ្ឈាន យ៉ាងឧិនថយ តើកើតក្នុងភពណា, រមែងទៅកើតជាមួយនឹងពួកទេវតា ជាន់ព្រហ្មបារិសជ្ជា (២) " ដូច្នេះជាដើម ។ ចំណែកការចំរើនអប្បនាសមាធិ រមែងនាំមកនូវភពដ៏វិសេស គឺសុគតិ ជាន់កាមាវចរ ៦ ជាន់ ដូចគ្នាដែរ ។

(មាននិរោធជាអានិសង្ស)

ចំណែកឯព្រះអរិយទាំងឡាយណា ញុំាងសមាបត្តិទាំងឡាយ ៨ ឲ្យកើតឡើង ហើយចូលនិរោធសមាបត្តិ ចំរើនសមាធិ ដោយគិត ថា "យើងទាំងឡាយ ជាអ្នកមិនមានចិត្ត ដល់នូវនិរោធនិព្វាន នៅជាសុខក្នុងបច្ចុប្បន្ន អស់ថ្ងៃទាំងឡាយ ៧ " ដូច្នេះ, ការចំរើនអប្បនាសមាធិ របស់ព្រះអរិយៈទាំងឡាយនោះ ឈ្មោះថា មាននិរោធ ជាអានិសង្ស ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា "ប្រាជ្ញា ក្នុងការចំរើនយ៉ាងស្ទាត់ ដោយញាណចរិយា ១៦ និង ដោយសមាធិចរិយា ៩ ឈ្មោះថា ញាណ ក្នុងនិរោធសមាបត្តិ" ដូច្នេះជាដើម ។

១- សុ. អំ. តិ. ភាគទី៤១ ទំព័រទី ៣៧៩ ។ ២- អភិ. ភាគទី៤២ ទំព័រទី ៣៣៣ ។

នេះជាអានិសង្ស នៃការចំរើនសមាធិ ៥ ប្រការ មានកិរិយានៅជាសុខស្រួល ក្នុងបច្ចុប្បន្នជាដើម ដូចបានពណ៌នាមកនេះឯង ។

ព្រោះហេតុដូច្នេះ បណ្ឌិតមិនគួរប្រមាទ ក្នុងការប្រកបនូវ
ការចំរើនសមាធិ ដែលមានអានិសង្សច្រើនជាអនេក ជា
គ្រឿងជម្រះនូវមន្ទិល គឺកិលេសឡើយ ។

ក៏សមាធិ ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ដោយធម៌ជាប្រធាន គឺ សីល សមាធិ និង បញ្ញា ដោយព្រះគាថានេះ ថា "សីលេ បតិដ្ឋាយ នរោ សបញ្ញោ" ដូច្នេះជាដើម គឺខ្ញុំបានអធិប្បាយចប់ហើយ ដោយសេចក្តីមានប្រមាណប៉ុណ្ណោះឯង ។

បរិច្ឆេទ ទី១១ ឈ្មោះសមាធិនិទ្ទេស ក្នុងបករណ៍វិសេស
ឈ្មោះវិសុទ្ធិមគ្គ ដែលខ្ញុំរៀបរៀងហើយ
ដើម្បីប្រយោជន៍ ដល់កិរិយាញុំាងសាធុជន ឲ្យរីករាយទួទៅ
ចប់ជាសំរេចហើយ ដោយអម្បាលនេះឯងហោង ។

(បទសរុបនិទ្ទេសដែលបានពោលមកហើយ)

និទ្ទេស ទី ១ ឈ្មោះ សីលនិទ្ទេស,
និទ្ទេស ទី ២ ឈ្មោះ ធុតង្គនិទ្ទេស,
និទ្ទេស ទី ៣ ឈ្មោះ កម្មដ្ឋានគ្គហណនិទ្ទេស,
និទ្ទេស ទី ៤ ឈ្មោះ បឋវីកសិណនិទ្ទេស,
និទ្ទេស ទី ៥ ឈ្មោះ សេសកសិណនិទ្ទេស,
និទ្ទេស ទី ៦ ឈ្មោះ អសុភនិទ្ទេស,

និទ្ទេស ទី ៧ ឈ្មោះ ឆានុស្សតិនិទ្ទេស,
និទ្ទេស ទី ៨ ឈ្មោះ សេសានុស្សតិនិទ្ទេស,
និទ្ទេស ទី ៩ ឈ្មោះ ព្រហ្មវិហារនិទ្ទេស,
និទ្ទេស ទី ១០ ឈ្មោះ អារុប្បនិទ្ទេស,
និទ្ទេស ២ គឺ បដិកូលសញ្ញា និង ធាតុវវដ្ឋាន
ជានិទ្ទេស ទី ១១ ។

បានរៀបរៀងចប់សព្វគ្រប់
នៅថ្ងៃព្រហស្បតិ៍ ៦ រោច ខែអស្សុជ ព. ស. ២៥៥១
ទី១ ខែ១១ ឆ្នាំ២០០៧

ឥទ្ធិវិធនិទ្ទេស

(២៣៤) ឥឡូវនេះ ការចំរើនសមាធិនេះ គឺខ្ញុំបានពោលហើយថា "មានអភិញ្ញាជាអានិសង្ស" ដោយអំណាចនៃលោកិយអភិញ្ញាទាំងឡាយឯណា, ព្រះយោគីអ្នកបានសំរេចចតុត្ថជ្ឈាន ក្នុងកសិណទាំងឡាយមានបឋវីកសិណជាដើមហើយ គប្បីធ្វើសេចក្តីព្យាយាម ដើម្បីញ៉ាំងអភិញ្ញាទាំងឡាយនោះ ឲ្យដល់ព្រម, ព្រោះថា កាលបើធ្វើបាន យ៉ាងដូច្នោះ, ការចំរើននូវសមាធិនោះ របស់ព្រះយោគីនោះ នឹងជាសមាធិដែលមានអានិសង្ស គឺខ្លួនបានហើយផង នឹងជាសមាធិ ដ៏ខ្ជាប់ខ្ជួនជាងផង, ព្រះយោគីនោះ ជាអ្នកប្រកបព្រមហើយ ដោយសមាធិភាវនា ដ៏ខ្ជាប់ខ្ជួនជាងដែលមានអានិសង្ស គឺខ្លួនបានសំរេចហើយ នឹងញ៉ាំងការចំរើននូវបញ្ញាឲ្យដល់ព្រម ដោយស្រួលមែនពិត ព្រោះហេតុណា, ព្រោះហេតុនោះយើងទាំងឡាយ នឹងប្រារព្ធ នូវអភិញ្ញាកថា ជាមុន ។

(លោកិយអភិញ្ញា ៥)

ក៏លោកិយអភិញ្ញាទាំងឡាយ ៥ គឺ :

១- ឥទ្ធិវិធ សំដែងឫទ្ធិផ្សេងៗ បាន,

២- ទិព្វសោតធាតុញ្ញាណ ប្រាជ្ញាអាចស្តាប់ដឹងបាន នូវសំឡេងរបស់មនុស្ស និង ទេវតា ដោយសោតធាតុដែលជាទិព្វ,

៣- ចេតោបរិយញ្ញាណ ប្រាជ្ញាអាចកំណត់ដឹងទឹកចិត្តអ្នកដទៃបាន,

៤- បុព្វេនិវាសានុស្សតិញ្ញាណ ប្រាជ្ញាអាចរឭកជាតិមុនបាន,

៥- សត្តានំ ចុតូបបាតញ្ញាណ ប្រាជ្ញាអាចដឹងបាន នូវការចុតិ និងបដិសន្ធិ របស់សត្វទាំងឡាយ

គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយន័យថា "ភិក្ខុនោះ កាលបើ

ចិត្តតំកល់នៅមាំ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តដ៏ទន់ភ្លន់ សមគួរដល់ការងារ ឋិតនៅ ដល់នូវភាពមិនរំជើបរំជួយ យ៉ាងដូច្នេះហើយ, រមែងនាំចិត្តចូលទៅ បង្អោនចិត្តចូលទៅ តាមបែបនៃឫទ្ធិ, ព្រះយោគីនោះ បាននូវការតាក់តែងឫទ្ធិបានជាច្រើនប្រការ គឺមនុស្សម្នាក់ ឲ្យទៅជាច្រើននាក់ក៏បាន [1] "ដូច្នេះជាដើម ដើម្បីទ្រង់សំដែង នូវអានិសង្សនៃការចំរើនសមាធិផង ដើម្បីទ្រង់សំដែងនូវធម៌ដ៏ប្រណីត លើសលប់ក្រៃលែងផង ដល់ពួកកុលបុត្រទាំងឡាយដែលបានសំរេចសមាធិ ក្នុងចតុត្ថជ្ឈានហើយ ។

(វិធីអប់រំចិត្ត)

បណ្តាលោកិយអភិញ្ញាទាំង ៥ នោះ ព្រះយោគី អ្នកធ្វើជាដំបូងមានបំណងដើម្បីធ្វើនូវការធ្វើនូវឫទ្ធិផ្សេងៗ មានជាដើមថា "មនុស្សតែម្នាក់ឯង ធ្វើឲ្យទៅជាមនុស្សច្រើននាក់បាន" ដូច្នេះ គប្បីញ៉ាំងសមាបត្តិទាំងឡាយ ៨ ៗ ក្នុងកសិណទាំងឡាយ ៨ មានឱទាតកសិណ ជាទីបំផុត ឲ្យកើតឡើង ហើយអប់រំចិត្ត ដោយអាការៈទាំងឡាយ ១៤ នេះ គឺ

កសិណានុលោមតោ ដោយការចូលកាន់ឈានបណ្តោយទៅតាមលំដាប់នៃកសិណ,

កសិណប្បដិលោមតោ ដោយការចូលកាន់ឈានសាប្រាសឡើងមកវិញ តាមលំដាប់នៃកសិណ,

កសិណានុលោមប្បដិលោមតោ ដោយការចូលកាន់ឈានបណ្តោយទៅតាមលំដាប់នៃកសិណ និង ចូលកាន់ឈានសាប្រាសឡើងមកវិញ តាមលំដាប់នៃកសិណ,

---

១- សុ. ទី. សី. ភាគទី ១៥ ទំព័រទី ២០៣ ។

ឈានានុលោមតោ ដោយការចូលកាន់ឈាន បណ្តោយទៅតាមលំដាប់នៃឈាន,

ឈានប្បដិលោមតោ ដោយការចូលកាន់ឈានច្រាសមកវិញ,

ឈានានុលោមប្បដិលោមតោ ដោយការចូលកាន់ឈានបណ្តោយទៅតាមលំដាប់នៃឈាន ហើយសាច្រាសឡើងមកវិញ,

ឈានានុក្កន្តកតោ ដោយការចូលផ្លោះរំលងឈាន,

កសិណុក្កន្តកតោ ដោយការចូលផ្លោះរំលងកសិណ,

ឈានកសិណុក្កន្តកតោ ដោយការចូលផ្លោះរំលងទាំងឈានទាំងកសិណ,

អង្គសង្កន្តិតោ ដោយការប្រព្រឹត្តិកន្លងនូវអង្គ,

អារម្មណសង្កន្តិតោ ដោយការប្រព្រឹត្តិកន្លងនូវអារម្មណ៍,

អង្គារម្មណសង្កន្តិតោ ដោយការប្រព្រឹត្តិកន្លងអង្គ និងអារម្មណ៍,

អង្គវវដ្ឋាបនតោ ដោយការកំណត់នូវអង្គ,

អារម្មណវវដ្ឋាបនតោ ដោយការកំណត់អារម្មណ៍ ។

សួរថា "ក៏ក្នុងអាការៈទាំងនុ៎ះ ការអនុលោមតាមកសិណ តើដូចម្តេច ? ។ល។ ការកំណត់នូវអារម្មណ៍ តើយ៉ាងដូចម្តេច ?" ។

(ចូលតាមលំដាប់កសិណ)

ឆ្លើយថា : ភិក្ខុ ក្នុងសាសនានេះ ចូលឈានអស់វារៈ ១០០ដងខ្លះ អស់វារៈ ១,០០០ដងខ្លះ ក្នុងកសិណទាំងឡាយ ៨ ដោយលំដាប់ យ៉ាងនេះគឺ "ចូលឈានក្នុងបឋវីកសិណ បន្ទាប់មក ក្នុងអាបោកសិណ" ដូច្នេះ, ការចូលឈាននេះ ឈ្មោះថា អនុលោមតាមកសិណ ។

(ចូលបញ្ច្រាសកសិណ)

ចំណែកការចូល តាមលំដាប់នៃការច្រាស ដូចគ្នានោះដែរ ចាប់ផ្តើមអំពីឱទាតកសិណមក ឈ្មោះថា ការចូលបញ្ច្រាសកសិណ ។

(ការចូលដោយអនុលោមនិងបដិលោមនៃកសិណ)

ការចូលឈានរឿយៗ ដោយអំណាចអនុលោម និង បដិលោម យ៉ាងនេះ គឺ : ចាប់ផ្តើមអំពីបឋវីកសិណមក រហូតដល់ឱទាតកសិណ ចាប់ផ្តើមអំពីឱទាតកសិណ រហូតដល់បឋវីកសិណ ឈ្មោះថា ការចូលដោយអនុលោម និង បដិលោម តាមលំដាប់នៃកសិណ ។

(ការចូលតាមលំដាប់នៃឈាន)

ការចូលឈានរឿយៗ តាមលំដាប់ ចាប់ផ្តើមតាំងពីបឋមជ្ឈានមករហូតដល់នេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា ការចូលតាមលំដាប់នៃឈាន ។

(ការចូលច្រាសឈាន)

ការចូលឈានរឿយៗ ចាប់ផ្តើមអំពីនេវសញ្ញានាសញ្ញាយតនៈ រហូតដល់បឋមជ្ឈាន ឈ្មោះថា ការចូលច្រាសឈាន ។

(ការចូលឈានទាំងតាមលំដាប់ទាំងបញ្ច្រាស)

ការចូលឈានរឿយៗ ដោយអំណាចការចូលតាមលំដាប់ និង បញ្ច្រាស យ៉ាងនេះ គឺ: ចាប់ផ្តើមអំពីបឋមជ្ឈាន រហូតដល់នេវសញ្ញា-នាសញ្ញាយតនជ្ឈាន និង ចាប់ផ្តើមអំពីនេវសញ្ញានាសញ្ញាយតនជ្ឈាន ឈ្មោះថា ការចូលឈាន តាមលំដាប់ និង បញ្ច្រាស ។

(ការចូលផ្លោះរំលងឈាន)

ឯការមិនរំលងនូវកសិណ តែរំលងនូវឈាន ដោយភាពប្រកបដោយចន្លោះតែមួយ យ៉ាងដូច្នេះ គឺ : ចូលបឋមជ្ឈាន ក្នុងបឋវីកសិណ

ហើយចូលនូវតតិយជ្ឈាន ក្នុងបឋវីកសិណនោះដែរ បន្ទាប់មក បើកនូវបឋវីកសិណនោះវិញ ហើយចូលអាកាសានញ្ចាយតនជ្ឈាន បន្ទាប់មក ចូលអាកិញ្ចញ្ញាយតនជ្ឈាន ដូច្នេះ ឈ្មោះថា ចូលរំលងនូវឈាន ។

ព្រះយោគី គប្បីធ្វើការប្រកប ដែលមានមូលនៃកសិណ មានអាបោកសិណជាដើម យ៉ាងដូច្នេះ ។

(ការចូលរំលងនូវកសិណ)

ការមិនរំលងឈាន តែរំលងកសិណ ដោយភាពប្រកបដោយចន្លោះតែមួយ ដោយន័យនេះថា "ព្រះយោគី ចូលបឋមជ្ឈាន ក្នុងបឋវី-កសិណ ហើយចូលបឋមជ្ឈាននោះម្ដងទៀត ក្នុងតេជោកសិណ តមកក្នុងនីលកសិណ បន្តមកទៀត ក្នុងលោហិតកសិណ" ដូច្នេះ ឈ្មោះថា ការចូលរំលងកសិណ ។

(ការចូលរំលងទាំងឈានទាំងកសិណ)

ការរំលងនូវឈានផង នូវកសិណផង ដោយន័យនេះថា "ព្រះយោគី ចូលបឋមជ្ឈាន ក្នុងបឋវីកសិណ ហើយ បន្ទាប់មក ចូលនូវតតិយជ្ឈាន ក្នុងតេជោកសិណ ហើយបើកនូវនីលកសិណ ចូលនូវអាកាសានញ្ចាយតនជ្ឈាន ហើយចូលនូវអាកិញ្ចញ្ញាយតនជ្ឈាន អំពីលោហិតកសិណ" ដូច្នេះ ឈ្មោះថា ចូលរំលងទាំងឈានទាំងកសិណ ។

(ការប្រព្រឹត្តិកន្លងនូវអង្គ)

ចំណែកការចូលបឋមជ្ឈាន ក្នុងបឋវីកសិណ ហើយចូលឈានទាំងឡាយក្រៅអំពីនេះ ក្នុងបឋវីកសិណនោះដូចគ្នាដែរ ឈ្មោះថា ការប្រព្រឹត្តិកន្លងនូវអង្គ ។

(ការប្រព្រឹត្តិកន្លងនូវអារម្មណ៍)

ការចូលកាន់ឈានតែមួយ ក្នុងកសិណទាំងអស់ យ៉ាងនេះ គឺ ព្រះយោគី ចូលបឋមជ្ឈាន ក្នុងបឋវីកសិណ រួចចូលបឋមជ្ឈាននោះដែរ ក្នុងអាបោកសិណ ។លៗ ចូលបឋមជ្ឈាននោះវិញ ក្នុងឱទាតកសិណ ដូច្នេះ ឈ្មោះថា ចូលប្រព្រឹត្តកន្លងនូវអារម្មណ៍ ។

(ការប្រព្រឹត្តិកន្លងទាំងអង្គទាំងអារម្មណ៍)

កិរិយាកន្លងនូវអង្គទាំងឡាយ និង អារម្មណ៍ទាំងឡាយ ដោយអំណាចនៃភាពប្រកប ដោយចន្លោះតែមួយ យ៉ាងដូច្នេះ គឺ ព្រះយោគី ចូលបឋមជ្ឈាន ក្នុងបឋវីកសិណ ហើយចូលទុតិយជ្ឈាន ក្នុងអាបោ-កសិណ ចូលកាន់តតិយជ្ឈាន ក្នុងតេជោកសិណ ហើយចូលចតុត្ថជ្ឈាន ក្នុងវាយោកសិណ បើកឡើងនូវនីលកសិណ ហើយចូលកាន់អាកាសា-នញ្ចាយតនជ្ឈាន ចូលវិញ្ញាណញ្ចាយតនជ្ឈាន អំពីបីតកសិណ ចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន អំពីលោកហិតកសិណ ចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន អំពីឱទាតកសិណ ដូច្នេះ ឈ្មោះថា ការប្រព្រឹត្តិកន្លងទាំងអង្គទាំងអារម្មណ៍ ។

(ការកំណត់អង្គឈាន)

ឯការកំណត់ត្រឹមតែអង្គឈានប៉ុណ្ណោះ យ៉ាងនេះ គឺៈ ព្រះយោគី កំណត់ថា បឋមជ្ឈាន មានអង្គ ៥ ហើយកំណត់ថា ទុតិយជ្ឈាន មានអង្គ ៣ កំណត់ថា តតិយជ្ឈាន មានអង្គ ២ ហើយកំណត់ថា ចតុត្ថ-ជ្ឈាន អាកាសានញ្ចាយតនជ្ឈាន ។លៗ នេវសញ្ញានាសញ្ញាយតនជ្ឈាន ក៏មានអង្គ ២ ដូចគ្នាដែរ ដូច្នេះ ឈ្មោះថា កំណត់នូវអង្គ ។

(ការកំណត់អារម្មណ៍)

មួយទៀត ការកំណត់ត្រឹមតែអារម្មណ៍ប៉ុណ្ណោះ យ៉ាងដូច្នេះ គឺ

ព្រះយោគី កំណត់ថា “នេះ ជាបឋវីកសិណ” ហើយកំណត់ថា “នេះជាអាបោកសិណ” ។ល។ ថា “នេះ ជាឱទាតកសិណ” ដូច្នេះ ឈ្មោះថាការកំណត់នូវអារម្មណ៍ ។

ឯអាចារ្យពួកមួយ ចង់បាននូវការកំណត់នូវអង្គ និង អារម្មណ៍ ។ ប៉ុន្តែព្រោះការកំណត់នូវអង្គនិងអារម្មណ៍នោះ មិនមកហើយ ក្នុងអដ្ឋកថាទាំងឡាយ ទើបការកំណត់អង្គ និង អារម្មណ៍នោះ មិនមែនជាប្រធាននៃការចំរើន ដោយពិត ។

(ការធ្វើឫទ្ធិ ជាភារៈធ្ងន់)

ពាក្យដែលថា ព្រះយោគាវចរដែលជាអាទិកម្មិកៈ មិនបានអប់រំចិត្ត ដោយអាការ ១៤ យ៉ាងនេះ ដូចបានពោលមកនេះ មិនបានចំរើនភាវនាក្នុងកាលមុនមក នឹងញុំាងការធ្វើឫទ្ធិផ្សេងៗ ឲ្យសំរេចបាន នេះ មិនមែនជាហេតុជាទីតាំងទេ ។ ព្រោះថា ការបរិកម្មកសិណហ្នឹងឯង គឺជាភារៈធ្ងន់ របស់ព្រះយោគាវចរ ដែលជាអាទិកម្មិកៈ ។ បណ្តាកុលបុត្រមួយរយក្តី មួយពាន់ក្តី កុលបុត្រតែមួយគត់ ទើបអាច (ដើម្បីបរិកម្មបាន) ។ ការធ្វើ (បដិភាគ) និមិត្តឲ្យកើតឡើង ជាភារៈធ្ងន់ របស់ព្រះយោគាវចរ ដែលបានធ្វើកសិណបរិកម្មហើយ ។ បណ្តាកុលបុត្រមួយរយក្តី មួយពាន់ក្តី កុលបុត្រតែមួយរូបប៉ុណ្ណោះទេ ទើបអាច (ដើម្បីធ្វើនិមិត្តឲ្យកើតឡើងបាន) ។ កាលបើនិមិត្ត កើតឡើងហើយ, ការញុំាងនិមិត្តនោះ ឲ្យចំរើនឡើង រហូតបានសំរេចដល់អប្បនា គឺជាភារៈ (របស់ព្រះយោគាវចរ) ។ បណ្តាកុលបុត្រមួយរយក្តី មួយពាន់ក្តី កុលបុត្រតែមួយរូបប៉ុណ្ណោះទេ ទើបអាច (ដើម្បីសំរេចដល់អប្បនា) ។ ការអប់រំចិត្តគ្រប់គ្រាន់ ដោយអាការៈ ១៤ យ៉ាង គឺជាភារៈ របស់ព្រះយោគាវចរ ដែល

បានសំរេចអប្បនាហើយ ។ បណ្តាកុលបុត្រមួយរយក្តី មួយពាន់ក្តី កុលបុត្រតែមួយរូបប៉ុណ្ណោះទេ ទើបអាច (ដើម្បីអប់រំចិត្ត ដោយអាការៈ ១៤ យ៉ាងបាន) ។ ធម្មតាការដំណែងនូវឫទ្ធិផ្សេងៗ គឺជាភារៈ របស់ព្រះយោគាវចរ ដែលបានទូន្មានចិត្ត ដោយអាការៈ ១៤ យ៉ាង ស្រេចហើយ ។ បណ្តាកុលបុត្រមួយរយក្តី មួយពាន់ក្តី កុលបុត្រតែមួយរូបប៉ុណ្ណោះទេ ទើបអាច (ដើម្បីដំណែងឫទ្ធិផ្សេងៗបាន) ។ ឈ្មោះថា ភារៈនៃការចូលកាន់ឈាន បានយ៉ាងឆាប់រហ័ស គឺជាភារៈនៃព្រះយោគាវចរ ដែលបានសំរេច នូវការដំណែងឫទ្ធិ ។ បណ្តាកុលបុត្រមួយរយក្តី មួយពាន់ក្តី កុលបុត្រតែមួយរូបប៉ុណ្ណោះទេ ឈ្មោះថា ជាអ្នកចូលឈានបានយ៉ាងឆាប់រហ័ស ។

សេចក្តីថា កុលបុត្រមួយរូបនោះ ប្រៀបដូចជាព្រះរក្ខិតត្ថេរ អ្នកមានវស្សា ៨ រាប់ពីឧបសម្បទាមក ក្នុងបណ្តាភិក្ខុអ្នកមានឫទ្ធិ មានចំនួន ៣០,០០០ រូប ដែលនិមន្តមកកាន់គិលានុបដ្ឋាន របស់ព្រះថេរៈឈ្មោះមហារោហណគុត្តត្ថេរ ក្នុងវត្តឈ្មោះថេរម្ពត្ថលៈ យ៉ាងនោះឯង ។ អានុភាព របស់លោក ត្រូវអដ្ឋកថាចារ្យពោលហើយ ក្នុងបឋវីកសិណ-និទ្ទេសឯណោះ ។ ក៏ព្រះថេរៈ ឃើញអានុភាពនោះ របស់ព្រះរក្ខិតត្ថេរនោះហើយពោលថា “ម្នាលអាវុសោ ប្រសិនបើព្រះរក្ខិតត្ថេរ នឹងមិនមានហើយ, យើងទាំងអស់គ្នា គប្បីជាអ្នកដល់នូវការតិះដៀល ថា “ភិក្ខុទាំងឡាយ មិនបានអាចហើយ ដើម្បីនឹងរក្សានូវនាគរាជ” ដូច្នេះ, ព្រោះហេតុនោះ ឈ្មោះថាអាវុធ គឺអ្នកគប្បីកាន់យកដោយខ្លួនឯង ហើយត្រាច់ទៅ, ការដែលអ្នកជំរះប្រែះឲ្យអស់សិនហើយ កាន់យកទៅ ទើបគួរ” ។ ភិក្ខុ ៣០,០០០ រូបនោះ ឋិតនៅក្នុងឱវាទ របស់ព្រះថេរៈហើយ ក៏បាន

ជាអ្នកមានកិរិយាចូលឈានបានឆាប់រួសរាន់ ។ ក៏សូម្បីកាលបើមានការចូលឈានបានឆាប់រហ័ស, ភាពជាទីពឹង នៃបុគ្គលដទៃ គឺជាភារៈ ។ បណ្ដាកុលបុត្រមួយរយក្ដី មួយពាន់ក្ដី កុលបុត្រតែមួយប៉ុណ្ណោះ ទើបអាច (ដើម្បីជាទីពឹងនៃអ្នកដទៃបាន) ។ កុលបុត្ររូបនោះ បីដូចជាព្រះថេរៈ អ្នក-កាលបើភ្លៀងជាវិការៈនៃរងើកភ្លើងគឺមារឲ្យប្រព្រឹត្តទៅហើយ ក្នុងទីបូជាឈ្មោះគិរិកណ្ឌវិហារៈ សាងនូវផែនដី ព្ធដ៏អាកាសហើយ ការពារភ្លៀងជាវិការៈនៃរងើកភ្លើងបានយ៉ាងនោះឯង ។

តែសំរាប់បុគ្គលវិសេសទាំងឡាយ អ្នកដែលមានសេចក្ដីព្យាយាមជាគ្រឿងប្រកបក្នុងខាងដើម ដ៏មានកម្លាំង មានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ព្រះអគ្គសាវ័កជាដើម តែវៀរចាកការនានុក្រម គឺការអប់រំចិត្តតាមលំដាប់ មានប្រការដូចបានពោលមកហើយនេះ ការដំណែងនូវឫទ្ធិនេះផង គុណទាំងឡាយដទៃ មានបដិសម្ភិទាជាដើមផង រមែងសំរេចបានដោយអំណាចនៃកិរិយាបានចំពោះនូវព្រះអរហត្តមែនពិត ។ ព្រោះហេតុដូច្នោះ ព្រះយោគាវចរដែលជាអាទិកម្មិកៈ គប្បីទូន្មានចិត្តឲ្យបានស្រេចដោយអាការៈ ១៤ យ៉ាងនេះហើយ ធ្វើចិត្តឲ្យទន់ ឲ្យគួរដល់ការងារដោយអំណាចនៃការចូល (ឈាន) ធ្វើឆ័ន្ទៈឲ្យជាប្រធាន ធ្វើចិត្តឲ្យជាប្រធាន ធ្វើវិរិយៈឲ្យជាប្រធាន និង ធ្វើវិមំសាឲ្យជាប្រធានផង ដោយអំណាច (ធ្វើឲ្យ) ជាវសី មានអាវជ្ជនវសីជាដើមផង ហើយគប្បីធ្វើសេចក្ដីព្យាយាមជាគ្រឿងប្រកប ដើម្បីឥទ្ធិវិធញ្ញាណចុះ ប្រៀបបីដូចជាជាងមាសអ្នកប្រាថ្នាដើម្បីធ្វើនូវគ្រឿងប្រដាប់ឲ្យប្លែក ធ្វើមាសឲ្យទន់ ឲ្យគួរដល់ការងារពិត ដោយវិធីទាំងឡាយ មានការផ្ដុំភ្លើងជាដើម ហើយទើបធ្វើ យ៉ាងដូច្នោះឯង, មួយទៀត ប្រៀបបីដូចជានាយស្មូនឆ្នាំង អ្នក

ប្រាថ្នាដើម្បីធ្វើនូវភាជន៍ឲ្យប្លែក ធ្វើនូវដីស្អិត ឲ្យជាដីគឺខ្ទនបំប៉នល្អហើយ ឲ្យទន់ពិត ហើយទើបធ្វើ ដូច្នោះឯង ។ តែព្រះយោគីអ្នកបរិបូរដោយហេតុខាងដើម សូម្បីមានការស្ទាត់ជំនាញប្រព្រឹត្តទៅហើយ ក្នុងគុណត្រឹមតែចតុត្ថជ្ឈាន ក្នុងកសិណទាំងឡាយ ក៏គួរដើម្បីធ្វើបាន ។

(វិធីធ្វើសេចក្ដីព្យាយាម)

(២៣៥) ក៏ព្រះយោគី គប្បីធ្វើសេចក្ដីព្យាយាមជាគ្រឿងប្រកប ក្នុងការធ្វើឥទ្ធិវិធៈ ឲ្យសំរេចនុ៎ះ ដោយវិធីណា, ព្រះមានព្រះភាគ កាលទ្រង់សំដែងនូវវិធីនោះ ទើបទ្រង់ត្រាស់ថា "សោ ឯវំ សមាហិតេ ចិត្តេ ព្រះយោគីនោះ កាលបើចិត្តតាំងនៅស៊ប់ហើយ" ដូច្នេះជាដើម ។

នេះគឺជាពាក្យវិនិច្ឆ័យ តាមលំអាននៃន័យបាលី ក្នុងឥទ្ធិវិធញ្ញាណនោះហ្នឹងឯង ។ បណ្ដាបទទាំងនោះ បទថា "សោ" បានដល់ព្រះយោគីអ្នកបានសំរេចចតុត្ថជ្ឈានហើយនោះ ។ ពាក្យថា "ឯវំ" នេះ ជាពាក្យសំដែងចេញនូវលំដាប់នៃចតុត្ថជ្ឈាន ។ មានពាក្យអធិប្បាយថាៈ បានចំពោះនូវចតុត្ថជ្ឈាន តាមលំដាប់នៃការបានសំរេច ចាប់ដើមតាំងអំពីការបាននូវបឋមជ្ឈានមកនេះ ។ បទថា "សមាហិតេ" គឺតាំងនៅស៊ប់ហើយ ដោយចតុត្ថជ្ឈានសមាធិនេះ ។ បទថា "ចិត្តេ" សំដៅយករូបាវចរចិត្ត ។

ចំណែកក្នុងបទទាំងឡាយដ៏សេស មានបទថា "បរិសុទ្ធេ" ដូច្នេះជាដើម មានវិនិច្ឆ័យដូចតទៅនេះ ។ (ចិត្ត) ឈ្មោះថា បរិសុទ្ធហើយ ព្រោះភាវៈគឺសេចក្ដីបរិសុទ្ធិនៃសតិ ដោយអំណាចនៃឧបេក្ខា ។ ក៏ព្រោះចិត្តបរិសុទ្ធហ្នឹងឯង ទើបឈ្មោះថា ផូរផង់ អធិប្បាយថា ជាដែនផ្សាយចេញនៃរស្មី ។ ឈ្មោះថា មិនមានទីទួល គឺកិលេស ព្រោះភាវៈនៃទី

ទួលគឺកិលេស មានរាគៈជាដើម បន្សាត់បង់ហើយ ដោយកិរិយាសម្លាប់នូវបច្ច័យទាំងឡាយមានសុខជាដើម ។ ឈ្មោះថា មានឧបក្កិលេស ទៅប្រាសហើយ ព្រោះភាវៈនៃទីទួលគឺកិលេសមិនមានហ្នឹងឯង ។ មែនពិត ចិត្ត រមែងសៅហ្មង ដោយទីទួលគឺកិលេស ។ ឈ្មោះថា ជាចិត្តទន់ ព្រោះភាវៈជាចិត្ត ដែលព្រះយោគីបានអប់រំល្អហើយ អធិប្បាយថា ជាចិត្តដល់ហើយនូវការស្ទាត់ជំនាញ ។ ព្រោះចិត្តប្រព្រឹត្តទៅ ក្នុងអំណាចទើបហៅថា ចិត្តទន់ ។ ព្រោះភាវៈនៃចិត្តទន់ហ្នឹងឯង ទើបឈ្មោះថា គួរដល់ការងារ អធិប្បាយថា អត់ធន់ដល់ការងារ ប្រកបក្នុងការងារ ។ ពិតមែន ចិត្តទន់ ជាចិត្តគួរដល់ការងារ ប្រៀបបីដូចជាមាស ដែលជាងពន្រាបបានល្អហើយ យ៉ាងនោះឯង ។ ក៏ចិត្តទន់ និង ចិត្តគួរដល់ការងារទាំងពីរនោះឯង កើតមាន ក៏ព្រោះភាវៈនៃចិត្តដែលព្រះយោគី អប់រំល្អហើយហ្នឹងឯង ។ សមដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ តថាគត រំពឹងរកមិនឃើញនូវសភាវៈដទៃ សូម្បីតែសភាវៈមួយ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាសភាវៈទន់ផង គួរដល់ការងារផង ដូចជាចិត្តនេះសោះឡើយ [១] ” ដូច្នេះជាដើម ។ ព្រោះភាវៈនៃចិត្តឋិតនៅហើយ ក្នុងគុណទាំងឡាយ មានភាពដ៏បរិសុទ្ធជាដើមនោះ ទើបឈ្មោះថា ឋិតនៅហើយ ។ ព្រោះចិត្តឋិតនៅហ្នឹងឯង ទើបឈ្មោះថា ដល់នូវភាពមិនញាប់ញ័រ អធិប្បាយថា មិនឃ្លេងឃ្លោង មិនរំជើបរំជួយ ។ មួយទៀត ឈ្មោះថា ឋិតនៅហើយ ព្រោះឋិតនៅក្នុងអំណាចរបស់ខ្លួន ដោយភាពនៃចិត្តទន់ និង ចិត្តគួរដល់ការងារ ឈ្មោះថា ដល់នូវភាពមិនញាប់ញ័រ ព្រោះភាវៈនៃចិត្តត្រូវគុណជាតិទាំងឡាយ

១- សុ. អំ. ឯ. ភាគទី ៤០ ទំព័រទី ១៨ ។

មានសទ្ធាជាដើម ហួងហែងរក្សាហើយ ។ មែនពិត ចិត្តដែលសទ្ធារក្សាហើយ រមែងមិនញាប់ញ័រ ដោយភាពមិនមានសទ្ធា, ចិត្ត ដែលវិរិយៈរក្សាហើយ រមែងមិនញាប់ញ័រ ដោយភាពខ្ជិលច្រអូស, ចិត្តដែលសតិរក្សាហើយ រមែងមិនញាប់ញ័រ ដោយសេចក្តីប្រមាទ, ចិត្តដែលសមាធិរក្សាហើយ រមែងមិនញាប់ញ័រដោយសេចក្តីរាយមាយ, ចិត្តដែលបញ្ញារក្សាហើយ រមែងមិនញាប់ញ័រ ដោយអវិជ្ជា, ចិត្តដែលដល់ហើយ នូវពន្លឺ រមែងមិនញាប់ញ័រ ដោយភាពងងឹតគឺកិលេស ។ ចិត្តដែលធម៌ទាំង ៦ នេះ រក្សាហើយ ជាចិត្តដល់នូវភាពមិនញាប់ញ័រ ។ ចិត្តដែលដល់ព្រមហើយដោយអង្គ ៨ ដូចពោលមកនេះ ទើបជាចិត្តគួរដល់អភិនីហារដើម្បីកិរិយាធ្វើឲ្យជាក់ច្បាស់ ដោយការត្រាស់ដឹងដ៏ក្រៃលែង នូវធម៌ទាំងឡាយ ដែលបុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែង ។

គប្បីជ្រាបន័យមួយទៀត ។ ឈ្មោះថា ឋិតនៅស៊ប់ហើយ ព្រោះសមាធិក្នុងចតុត្ថជ្ឈាន, ឈ្មោះថា បរិសុទ្ធ ព្រោះជាចិត្តឋិតនៅឆ្ងាយអំពីនីវរណៈ, ឈ្មោះថា ផូរផង់ ព្រោះប្រព្រឹត្តកន្លងនូវអង្គមានវិតក្កៈជាដើម, ឈ្មោះថា មិនមានទីទួល ព្រោះមិនមានធម៌ដែលឆ្លងចុះក្នុងសេចក្តីប្រាថ្នាទាំងឡាយដ៏លាមក ដែលជាសត្រូវដល់ការបានចំពោះនូវឈាន ឈ្មោះថា មានឧបក្កិលេសទៅប្រាសហើយ ព្រោះកិរិយាទៅប្រាស នៃសេចក្តីសៅហ្មងនៃចិត្ត មានអភិជ្ឈាជាដើម ។ ក៏បណ្ឌិត គប្បីជ្រាបពាក្យទាំងពីរយ៉ាងនេះ តាមលំអាននៃន័យ ក្នុងអង្គណសូត្រ និង វត្ថសូត្រ ។ ឈ្មោះថា ជាចិត្តទន់ ព្រោះដល់នូវការស្ទាត់, ឈ្មោះថា ជាចិត្តគួរដល់ការងារ ព្រោះចូលទៅដល់ភាពជាឥទ្ធិបាទ, ឈ្មោះថា ឋិតនៅហើយ ព្រោះចូលទៅដល់ភាពប្រណីត ដោយភាពពេញលេញនៃភាវនា ឈ្មោះថា ដល់

នូវភាពមិនញាប់ញ័រ ។ អធិប្បាយថា ចិត្ត ជាធម្មជាតដល់នូវភាពមិនញាប់ញ័រ ដោយប្រការណា, ឋិតនៅហើយ ដោយប្រការនោះ ។ ចិត្តប្រកបដោយអង្គ ៨ ដោយន័យនេះ ជាចិត្តគួរដល់អភិនីហារ គឺជាបាទជាបទដ្ឋាន ដើម្បីកិរិយាធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែង នូវធម៌ទាំងឡាយ ដែលបុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែង យ៉ាងដូច្នេះឯង ។

(២៣៦) គប្បីជ្រាបវិនិច្ឆ័យ ក្នុងបាលីថា "ព្រះយោគី នាំចិត្តចូលទៅ បង្អោនចិត្តចូលទៅ ដើម្បីសំដែងឫទ្ធិ" ដូចតទៅនេះ ។

ឈ្មោះថា ឫទ្ធិ ដោយអត្ថថា ការសំរេច អធិប្បាយថា ដោយអត្ថថា កើតផលផង ដោយអត្ថថា បានចំពោះផង ។ ព្រោះថា វត្ថុណាកើតផល បុគ្គលបានចំពោះនូវវត្ថុណា, វត្ថុនោះ លោកហៅថា រមែងសំរេច ។ សមដូចជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា "កាលសត្វប្រាថ្នា នូវកាមណា, បើកាមនោះ សំរេចដល់សត្វនោះ [១] ។ ន័យដូចគ្នានោះដែរ ។ បាលីថា "ឈ្មោះថា ឫទ្ធិ ព្រោះនេក្ខម្មៈ សំរេច, ឈ្មោះថា បាដិហារ្យ ព្រោះកំចាត់បង់, ឈ្មោះថា ឫទ្ធិ ព្រោះអរហត្តមគ្គសំរេច, ឈ្មោះថា បាដិហារ្យ ព្រោះកំចាត់បង់ [២] " ។

ន័យមួយទៀត ឈ្មោះថា ឫទ្ធិ ដោយអត្ថថាសំរេច ។ ពាក្យថា ឫទ្ធិនេះ ជាឈ្មោះនៃកិរិយាដល់ព្រមដោយឧបាយ ។ មែនពិត ឧបាយសម្បទា រមែងសំរេច ព្រោះកិរិយាសោយផលដែលខ្លួនប្រាថ្នាហើយ ។ ដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ថា "មែនពិត ចិត្តគហបតីនេះឯង ជាអ្នកមានសីល មានធម៌ដ៏ល្អ ប្រសិនបើនឹងប៉ងប្រាថ្នាថា: អាត្មាអញគប្បី

១- សុ. ខុ. ភាគទី ៥៩ ទំព័រទី ២៦៥ ។ ២- សុ. ភាគទី ៧១ ទំព័រទី ៣១៥ ។

បានជាស្តេចចក្រពត្តិ ក្នុងអនាគតកាល ដូច្នេះ, សេចក្តីប្រាថ្នា របស់ចិត្តគហបតីនោះ រមែងសំរេចបាន ព្រោះការតាំងចិត្តប្រាថ្នា របស់អ្នកមានសីល ជាកិរិយាបរិសុទ្ធស្អាត [១] " ដូច្នេះ ។

ន័យមួយទៀត សត្វទាំងឡាយ រមែងសំរេច ដោយគុណជាតនោះ ព្រោះហេតុនោះ គុណជាតនោះ ឈ្មោះថា ឫទ្ធិ ។ អធិប្បាយថា ពាក្យថា "រមែងសំរេច" នេះ សេចក្តីថា ជាអ្នកសំរេច ចំរើនរុងរឿង ជាអ្នកដល់នូវគុណដ៏ខ្ពង់ខ្ពស់" ដូច្នេះ ។

(ឫទ្ធិ ១០ យ៉ាង)

ឫទ្ធិនោះ មាន ១០ យ៉ាង ។ ដូចព្រះសារីបុត្រពោលថា ពាក្យថា "ឫទ្ធិ ទាំងឡាយ" បានដល់ឫទ្ធិ ១០ យ៉ាង ។ ព្រះសារីបុត្រ ពោលពាក្យដទៃទៀតថា "ឫទ្ធិទាំង ១០ យ៉ាង តើដូចម្តេចខ្លះ?" ។ ឫទ្ធិ ១០ យ៉ាងនោះ គឺ :

១- អធិដ្ឋានា ឥទ្ធិ ឫទ្ធិ សំរេចដោយការអធិដ្ឋាន,
២- វិកុព្វនា ឥទ្ធិ ឫទ្ធិ ដោយការធ្វើឲ្យប្លែក,
៣- មនោមយា ឥទ្ធិ ឫទ្ធិ ដែលសំរេចមកអំពីចិត្ត,
៤- ញាណវិប្ផារា ឥទ្ធិ ឫទ្ធិ ដែលផ្សាយចេញពីអរហត្តមគ្គញាណ,
៥- សមាធិវិប្ផារា ឥទ្ធិ ឫទ្ធិ ដែលផ្សាយចេញមកអំពីសមាធិ,
៦- អរិយា ឥទ្ធិ ឫទ្ធិ របស់ព្រះអរិយៈ,
៧- កម្មវិបាកជា ឥទ្ធិ ឫទ្ធិ ដែលកើតមកអំពីកម្មវិបាក,
៨- បុញ្ញវតោ ឥទ្ធិ ឫទ្ធិ របស់បុគ្គលអ្នកមានបុណ្យ,
៩- វិជ្ជាមយា ឥទ្ធិ ឫទ្ធិ ដែលសំរេចមកអំពីវិជ្ជា,

១- សុ. សំ. ស. ភាគទី ៣៦ ទំព័រទី ២២៣ ។

១០- តត្ថ តត្ថ សម្មាបយោគបច្ចយា ឥជ្ឈនដ្ឋេន ឥទ្ធិ ឫទ្ធិ ព្រោះអត្ថថាសំរេច ព្រោះបច្ច័យនៃការប្រកបត្រឹមត្រូវ ក្នុងកិច្ចនោះៗ [១] ។

(១- អធិដ្ឋានឫទ្ធិ)

បណ្តាឫទ្ធិទាំងនោះ ឫទ្ធិ ដែលព្រះសារីបុត្រសំដែងវែកញែក យ៉ាងនេះថា "ភិក្ខុតែមួយរូបទេ ដោយប្រក្រតី តែនឹកចង់ឲ្យបានច្រើនរូប គឺនឹកចង់ឲ្យទៅជាមួយរយរូបក្តី មួយពាន់រូបក្តី មួយហ្មឺនរូបក្តី លុះនឹកចង់ហើយ ក៏អធិដ្ឋាន ដោយញាណថា: សូមឲ្យអាត្មាអញ មានរូបច្រើន" ដូច្នេះជាដើម [២] ឈ្មោះថា ឫទ្ធិ គឺការអធិដ្ឋាន ព្រោះភាវៈនៃឫទ្ធិនោះសំរេចហើយ ដោយអំណាចនៃការអធិដ្ឋាន ។

(២- វិកុព្វនឫទ្ធិ)

ឫទ្ធិ ដែលមកហើយ ដោយបាលីយ៉ាងនេះថា "ព្រះអភិក្ខុនោះ លះបង់ភេទជាប្រក្រតី ហើយសំដែងភេទជាកុមារខ្លះ សំដែងភេទជានាគខ្លះ ។ល។ សំដែងភេទជាកងទាហានប្លែកៗ គ្នាខ្លះ [៣] " ដូច្នេះជាដើម ឈ្មោះថា ឫទ្ធ គឺការធ្វើឲ្យប្លែក ព្រោះភាវៈនៃឫទ្ធិនោះ ប្រព្រឹត្តទៅដោយអំណាចការលះបង់ភេទប្រក្រតី និង ធ្វើឲ្យខុសប្លែក (ពីភេទប្រក្រតី) ។

(៣- មនោមយឫទ្ធិ)

ឫទ្ធិ ដែលមកហើយ ដោយន័យនេះថា "ភិក្ខុ ក្នុងសាសនានេះ និម្មិត នូវកាយដទៃ អំពីកាយនេះ មានរូបដែលសំរេចអំពីចិត្ត" ដូច្នេះជាដើម ឈ្មោះថា ឫទ្ធិ ដែលសំរេចអំពីចិត្ត ព្រោះភាវៈនៃឫទ្ធិនោះប្រព្រឹត្តទៅ ដោយអំណាចនៃការកើតឡើង នៃសរីរៈដទៃទៀត ដែលសំរេចមកអំពីចិត្ត ពួដ៏ខាងក្នុងនៃរាងកាយ ។

១- សុ. ភាគទី ៧១ ទំព័រ ២៦៤ ។ ២- ទំព័រ ២៦៩ ។ ៣- ទំព័រ ២៧៧ ។

(៤- ញាណវិប្ផារឫទ្ធិ)

គុណវិសេស ដែលកើតដោយអានុភាពនៃញាណ ក្នុងកាលមុនក្តី ក្នុងកាលជាខាងក្រោយក្តី ព្រោះការប្រព្រឹត្តិទៅនៃញាណ ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញនៃញាណ ។ សមដូចជាព្រះបាលីថា "ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញនៃញាណ ព្រោះសម្រេចអត្ថនៃការលះបង់ នូវសេចក្តីសំគាល់ថា ទៀង ដោយការពិចារណាឃើញថា មិនទៀង ។ល។ ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញនៃញាណ ព្រោះសម្រេចអត្ថនៃការលះបង់នូវកិលេសទាំងពួង ដោយអរហត្តមគ្គ (ដូចជា) ឫទ្ធិ គឺការផ្សាយចេញ នៃញាណ របស់ព្រះពាកុលៈ ដ៏មានអាយុ ឫទ្ធិ គឺការផ្សាយចេញនៃញាណរបស់ព្រះសំកិច្ចៈ ដ៏មានអាយុ នឹង ឫទ្ធិ គឺការផ្សាយចេញនៃញាណរបស់ព្រះភូតបាល ដ៏មានអាយុ [១] " ដូច្នេះ ។

(ញាណវិប្ផារឫទ្ធិ របស់ព្រះពាកុលៈ)

បណ្តាព្រះថេរៈទាំងបីនោះ ជាបឋម ព្រះពាកុលៈដ៏មានអាយុ នៅក្មេងនៅឡើយ ក្នុងថ្ងៃមង្គល ត្រូវគេផ្ងូតទឹក ក្នុងស្ទឹង ធ្លាក់ហើយក្នុងខ្សែទឹក ដោយសេចក្តីប្រហែសនៃមេនំ ។ ត្រីលេបនូវកុមារនោះ ហើយបានទៅកាន់កំពង់នៃក្រុងពារាណសី ។ អ្នកប្រម៉ង់ត្រី ចាប់ត្រីនោះបានហើយក្នុងកំពង់នោះ ក៏លក់ទៅឲ្យភរិយានៃសេដ្ឋី ។ ភរិយាសេដ្ឋីនោះ ក៏កើតសេចក្តីចូលចិត្តលើត្រី ហើយពោលថា "ខ្ញុំនឹងអាំងត្រីនុ៎ះខ្លួនឯង" ដូច្នេះកំពុងតែវះ ក៏ស្រាប់តែឃើញទារក ដូចជារូបជាវិការនៃមាស ក្នុងពោះត្រី ក៏កើតសេចក្តីសោមនស្សថា "អាត្មាអញបានកូនហើយ" ដូច្នេះ ។ ភាពមិនមាននៃរោគ ក្នុងពោះនៃត្រី ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញនៃ

១- សុ. ខុ. ភាគទី ៧១ ទំព័រទី ២៧៨ ។

ញាណ របស់ព្រះពាកុលៈដ៏មានអាយុ ជាអ្នកកើត ក្នុងភពជាទីបំផុត ព្រោះភាពមិនមានរោគក្នុងពោះនៃត្រីនោះ កើតហើយ ដោយអានុភាពនៃព្រះអរហត្តមគ្គញាណ ដែលលោកគប្បីបាន ដោយអត្តភាពនោះ ដូច្នេះ ។ ក៏បណ្ឌិតគប្បីសំដែងរឿង (ព្រះពាកុលៈ) ដោយពិស្តារ ។

(ញាណវិប្ផារឫទ្ធិ របស់ព្រះសំកិច្ចៈ)

ក៏កាលព្រះសង្កិច្ចត្ថេរ តាំងនៅក្នុងគភ៌នៅឡើយ មាតាក៏បានធ្វើមរណកាលទៅ ។ កាលដែលមាតានោះ ត្រូវគេលើកឡើងកាន់ជើងថ្ករ ចាក់ដោយឈើស្រួចហើយដុត, ទារក ប៉ះគ្រឿងប្រហារត្រង់កន្ទុយភ្នែក ដោយចុងឈើស្រួច បានស្រែកហើយ ។ លំដាប់នោះ ពួកមនុស្សទាំងឡាយ ក៏បានដាក់ទារកនោះចុះហើយ ដោយគិតថា “ទារកនៅមានជីវិត” ដូច្នេះ វះពោះរួចហើយ ក៏បានឲ្យទារកទៅជីដូន ។ ទារកនោះ ត្រូវជីដូននោះ ថែទាំ លុះធំចំរើនវ័យហើយ ក៏ទៅបួស បានសំរេចនូវព្រះអរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយ ។ ភាពមិនមានរោគ លើជើងថ្ករនៃឧសតាមន័យដែលលោកពោលហើយ យ៉ាងនេះឯង ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញនៃញាណ របស់ព្រះសង្កិច្ចៈ ដ៏មានអាយុ ។

(ញាណវិប្ផារឫទ្ធិ របស់ព្រះភូតបាល)

រឿងមួយទៀត ឪពុក របស់ភូតបាលទារក ជាមនុស្សទ័លក្រ ក្នុងទីក្រុងរាជគ្រឹះ ។ ឪពុកនោះ ទៅកាន់ព្រៃដោយរទេះ ដើម្បីប្រយោជន៍ដល់ឧស ផ្ទុកឧសស្រេចហើយ ទៅដល់ទីជិតទ្វារក្រុងក្នុងពេលល្ងាច ។ ជួនគ្រានោះ គោទាំងឡាយរបស់គាត់ ដោះចេញពីនឹមហើយ ក៏ចូលទៅកាន់ទីក្រុង ។ ឪពុកនោះ ឲ្យកូនតូចអង្គុយលើទូករទេះហើយ ក៏ទៅតាមដានជើងគោទាំងឡាយ បានចូលទៅកាន់ទីក្រុងផងដែរ ។ កាលគាត់មិន

ទាន់ចេញមកវិញនៅឡើយ ទ្វារបិទហើយ ។ ភាពដែលទារក មិនមានរោគ អស់រាត្រីមានយាមបី ខាងក្រៅក្រុង សូម្បីជាទីត្រាច់ទៅ នៃយក្សសាហាវ ឈ្មោះថា ឫទ្ធិ គឺការផ្សាយទៅនៃញាណ តាមន័យដែលលោកពោលហើយនោះឯង ។ ក៏បណ្ឌិត គប្បីសំដែងរឿង ឲ្យពិស្តារផង ។

(៥- សមាធិវិប្ផារឫទ្ធិ)

គុណវិសេស ដែលកើតហើយ ដោយអានុភាពនៃសមថៈ មុន ឬក្រោយសមាធិ ឬក៏ ក្នុងខណៈនៃសមាធិនោះ ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ថា “ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ ព្រោះសម្រេចអត្ថនៃការលះបង់ នូវនីវរណៈទាំងឡាយ ដោយបឋមជ្ឈាន ។ល។ ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញ នៃសមាធិ ព្រោះសំរេចអត្ថនៃការលះបង់នូវអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ (ដូចជា) ឫទ្ធិ គឺការផ្សាយចេញ នៃសមាធិ របស់ព្រះសារីបុត្តដ៏មានអាយុ, ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ របស់ព្រះសញ្ជីវៈមានអាយុ, ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ របស់ព្រះខាណុកោណ្ឌញ្ញៈ ដ៏មានអាយុ, ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ របស់ឧបាសិកាឈ្មោះឧត្តរា, ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ របស់ឧបាសិកាឈ្មោះសាមាវតី [១] ” ។

(សមាធិវិប្ផារឫទ្ធិ របស់ព្រះសារីបុត្រ)

បណ្តាព្រះថេរៈទាំងនោះ កាលព្រះសារីបុត្រដ៏មានអាយុ គង់នៅក្បែរញកភ្នំឈ្មោះតបោតៈ ជាមួយនឹងព្រះមហាមោគ្គល្លានត្ថេរ កោរសក់ហើយថ្មីៗ អង្គុយក្នុងទីវាល ក្នុងរាត្រីខាងខ្នើត, មានយក្សកំណាចមួយ

១- សុ. ខុ. គាគទី ៧១ ទំព័រទី ២៨០ ។

ទុកជាយក្សជាសំឡាញ់ហាមឃាត់ ក៏បានឲ្យហើយនូវការប្រហារ លើព្រះកេស, សំឡេងដែលគំរាម បានកើតហើយដូចជាសំឡេងនៃមេឃ ក្នុងកាលណា, ក្នុងកាលនោះ ព្រះថេរៈចូលសមាបត្តិហើយ ក្នុងសម័យជាទីប្រហាររបស់យក្សនោះ ។ គ្រានោះ អាពាធតិចតួចមិនបានកើតមានដល់លោក ព្រោះការប្រហារនោះឡើយ ។ ឫទ្ធិនេះ ឈ្មោះថាឫទ្ធិ គឺការផ្សាយចេញនៃសមាធិ របស់ព្រះសារីបុត្រដ៏មានអាយុនោះ ។ ឯរឿងមកហើយ ក្នុងឧទានឯណោះ ។

(សមាធិវិប្ផារឫទ្ធិ របស់ព្រះសញ្ជីវៈ)

រឿងមួយទៀត អ្នកគង្វាលគោទាំងឡាយ សំគាល់ហើយ នូវព្រះសញ្ជីវត្ថេរ ដែលចូលនិរោធសមាបត្តិថា "ធ្វើកាលកិរិយាហើយ" បានជញ្ជូននូវស្មៅ កំណាត់ឈើ និង អាចម៍គោ មកដុតភ្លើង ។ សូម្បីវត្ថុត្រឹមតែចុងនៃចេស ក្នុងចីវររបស់ព្រះថេរៈ ក៏ភ្លើងមិនឆេះឡើយ ។ ការមិនមានអន្តរាយដោយភ្លើងនេះ ឈ្មោះថាឫទ្ធិគឺការផ្សាយចេញនៃសមាធិ ព្រោះភាវៈនៃឫទ្ធិនោះ កើតហើយ ដោយអានុភាពនៃសមថៈ ដែលបានប្រព្រឹត្តទៅហើយ ដោយអំណាចនៃសមាបត្តិតាមលំដាប់របស់លោក ។ ឯរឿង មកហើយ ក្នុងព្រះសូត្រឯណោះ ។

(សមាធិវិប្ផារឫទ្ធិ របស់ព្រះខាណុកោណ្ឌញ្ញត្ថេរ)

ចំណែកព្រះខាណុកោណ្ឌញ្ញត្ថេរ តាមប្រក្រតី ជាអ្នកច្រើនដោយសមាបត្តិមែនពិត ។ ព្រះថេរៈអង្គនោះ អង្គុយចូលសមាបត្តិ អស់មួយរាត្រី ក្នុងព្រៃមួយ ។ ពួកចោរ ៥០០ នាក់ លួចទ្រព្យគេហើយទៅ មានប្រាថ្នាដើម្បីឈប់សំរាក ដោយគិតថា "ឥឡូវនេះ មិនមានម្ចាស់ទ្រព្យមកតាមផ្លូវពួកយើងទេ" ដូច្នេះ កាលដាក់នូវបង្វេចទ្រព្យ ក៏សំគាល់ថា

"នេះជាដង្គត់" បានដាក់បង្វេចទ្រព្យទាំងអស់ ខាងលើព្រះថេរៈតែម្តង ។ កាលពួកចោរទាំងនោះសំរាកហើយចេញទៅ, ព្រះថេរៈចេញពីសមាបត្តិ ហើយដោយអំណាចនៃកិរិយាកំណត់នូវកាល ក្នុងកាលជាទីកាន់យកនូវបង្វេចទ្រព្យដែលចោរដាក់ហើយជាដំបូង ។ ពួកចោរទាំងនោះ ឃើញនូវអាការៈកំរើក របស់ព្រះថេរៈហើយ ក៏ភ័យរត់បែកផ្លូវគ្នាទៅ ។ ព្រះថេរៈពោលថា "នែឧបាសកទាំងឡាយ ពួកអ្នកកុំខ្លាចឡើយ អាត្មាជាភិក្ខុ" ។ ពួកចោរទាំងនោះ មកថ្វាយបង្គំហើយ បួសដោយសេចក្តីជ្រះថ្លាដែលឋិតនៅក្នុងព្រះថេរៈហើយ បានសំរេចនូវព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ។ ការមិនមានអាពាធនៃព្រះថេរៈដែលត្រូវបង្វេចទ្រព្យ ៥០០ កញ្ចប់ គ្របសង្កត់ហើយក្នុងព្រៃនោះ ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ ។

(សមាធិវិប្ផារឫទ្ធិ របស់ឧត្តរាឧបាសិកា)

ចំណែកនាងឧត្តរាឧបាសិកា ជាធីតា របស់បុណ្ណកសេដ្ឋី ។ ស្រីផ្កាមាស ឈ្មោះសិរិមា មានសេចក្តីប្រណែនគ្របសង្កត់ហើយ បានស្រោចប្រេងដ៏ក្តៅទាំងខ្ទះ លើក្បាលនាងឧត្តរា ។ នាងឧត្តរា ចូលមេត្តាហើយ ក្នុងខណៈនោះឯង ។ ប្រេងបានខ្ទាតចេញទៅ ដូចជាទឹកខ្ទាតចេញពីស្លឹកឈូក ។ នេះជាឫទ្ធិ គឺការផ្សាយចេញនៃសមាធិរបស់នាងឧត្តរានោះ ។ ឯរឿងបណ្ឌិតគប្បី (សំដែង) ឲ្យពិស្តារចុះ ។

(សមាធិវិប្ផារឫទ្ធិ របស់ព្រះនាងសាមាវតី)

អគ្គមហេសី នៃព្រះបាទឧទេន ព្រះនាមសាមាវតី ។ មាគណ្ឌិយ-ព្រាហ្មណ៍ ប្រាថ្នាតំណែងជាអគ្គមហេសី ដល់ធីតារបស់ខ្លួន បានឲ្យគេដាក់ពស់អាសិរពិស ក្នុងពិណរបស់ព្រះនាងសាមាវតីនោះ ហើយទូលព្រះរាជាថា "បពិត្រមហារាជ ព្រះនាងសាមាវតី ប្រាថ្នាចង់ធ្វើគត់ព្រះ

អង្គ ចាប់ពស់អាសិរពិស រក្សាទុកក្នុងពិណ” ។ ព្រះរាជាទ្រង់ទតពស់នោះ ទ្រង់ខ្លាចហើយ លើកឡើងនូវធ្នូ ដោយមានបំណងថា “អញនឹងសម្លាប់នាងសាមាវតី” ហើយសៀតនូវកូនសរ ដែលត្រាំហើយដោយថ្នាំពិស ។ ព្រះនាងសាមាវតី ព្រមទាំងបរិវារ បានផ្សាយមេត្តា ទៅកាន់ព្រះរាជា ។ ព្រះរាជា កាលមិនអាចដើម្បីបាញ់ និង មិនអាចដើម្បីដាក់ចុះនូវកូនសរបាន ក៏ទ្រង់ញាប់ញ័រប្រថាប់នៅហើយ ។ លំដាប់នោះ ព្រះនាងទេវីទូលព្រះអង្គថា “បពិត្រមហារាជ តើព្រះអង្គទ្រង់លំបាកឬ?” ។ “អើខ្ញុំលំបាក” ព្រះរាជាឆ្លើយ ។ “បើដូច្នោះ សូមព្រះអង្គទ្រង់ដាក់ធ្នូចុះ” ព្រះនាងទូល ។ កូនសរបានធ្លាក់ហើយ ក្បែរទីជិតនៃព្រះបាទ របស់ព្រះរាជាតែម្ដង ។ លំដាប់នោះ ព្រះនាងទេវី ទូន្មានព្រះរាជានោះថា “បពិត្រមហារាជ ព្រះអង្គមិនត្រូវប្រទូស្ត ចំពោះអ្នកដែលមិនប្រទូស្តតបទេ” ។ ភាពនៃព្រះរាជាមិនអាចដើម្បីលែងនូវសរ ដូចពោលមកនេះ ឈ្មោះថាឫទ្ធិ គឺការផ្សាយចេញនៃសមាធិ របស់ឧបាសិកាសាមាវតី ដូច្នេះឯង ។

(៦- អរិយឫទ្ធិ)

ចំណែកខាងឫទ្ធិ មានឫទ្ធិនៃជនអ្នកមានកិរិយានៅ ដោយសេចក្ដីសំគាល់ថា មិនគួរខ្ពើមជាដើម ក្នុងវត្ថុដែលគួរខ្ពើមជាដើម ជាប្រក្រតី ឈ្មោះថាអរិយឫទ្ធិ ។ ឫទ្ធិ គឺភាពអ្នកខ្ពង់ខ្ពស់ តើដូចម្ដេច? ។ ភិក្ខុ ក្នុងសាសនានេះ បើប្រាថ្នាថា “អាត្មាអញ គប្បីមានសេចក្ដីសំគាល់ថា មិនគួរខ្ពើម ក្នុងរបស់ដែលគួរខ្ពើម, លោកក៏ជាអ្នកសំគាល់ថា មិនគួរខ្ពើម ក្នុងរបស់នោះ ។ល។ ជាអ្នកមានស្មារតី ដឹងខ្លួន ប្រកបដោយឧបេក្ខា ក្នុងរបស់ដែលគួរខ្ពើមនោះ [១] ” ។ មែន ឫទ្ធិ មានភាពជាអ្នកសំគាល់

១- សុ. ខុ. ភាគទី ៧១ ទំព័រទី ២៨១ ។

ថា មិនគួរខ្ពើម ក្នុងរបស់គួរខ្ពើមជាដើមនេះ ហៅថា “អរិយឫទ្ធិ” ព្រោះកើតមានចំពោះព្រះអរិយទាំងឡាយ ដែលដល់ហើយនូវការស្ទាត់ដោយអំណាចនៃចិត្តប៉ុណ្ណោះ ។ មែនពិត ភិក្ខុជាព្រះខីណាស្រព ប្រកបព្រមដោយអរិយឫទ្ធិនេះ កាលធ្វើនូវការផ្សាយមេត្តាក្ដី នូវការធ្វើទុកក្នុងចិត្តនូវធាតុក្ដី ក្នុងវត្ថុដែលគួរខ្ពើម គឺមិនជាទីប្រាថ្នា ឈ្មោះថា ជាអ្នកមានសេចក្ដីសំគាល់ថា មិនគួរខ្ពើមគង់នៅ, កាលធ្វើនូវការផ្សាយនូវអសុភក្ដី នូវការធ្វើទុកក្នុងចិត្តថា “មិនទៀង” ដូច្នេះក្ដី ក្នុងវត្ថុដែលមិនគួរខ្ពើម គឺដែលជាទីប្រាថ្នា ឈ្មោះថា អ្នកមានសេចក្ដីសំគាល់ថាគួរខ្ពើម គង់នៅ ។ ន័យដូចគ្នានោះដែរ ភិក្ខុកាលធ្វើការផ្សាយមេត្តាក្ដី នូវការធ្វើទុកក្នុងចិត្តនូវធាតុក្ដី នោះឯង ក្នុងវត្ថុដែលគួរខ្ពើម និង មិនគួរខ្ពើម ឈ្មោះថា អ្នកមានសេចក្ដីសំគាល់ថា មិនគួរខ្ពើមគង់នៅ, និង កាលធ្វើនូវការផ្សាយអសុភៈក្ដី នូវការធ្វើទុកក្នុងចិត្តថា “មិនទៀង” ដូច្នេះក្ដី នោះឯង ក្នុងវត្ថុដែលមិនគួរខ្ពើម និង គួរខ្ពើម ក៏ឈ្មោះថា ជាអ្នកមានសេចក្ដីសំគាល់ថាមិនគួរគង់នៅ ។ ចំណែកភិក្ខុ កាលញុំាងឆឡង្គុបេក្ខា ដែលពោលហើយដោយន័យថា “ភិក្ខុ ឃើញនូវរូប ដោយភ្នែកហើយ ជាអ្នកមិនត្រេកអរ” ដូច្នេះជាដើម ឲ្យប្រព្រឹត្តទៅ វៀរចេញនូវអារម្មណ៍ទាំងពីរនោះ ទាំងក្នុងវត្ថុដែលគួរខ្ពើមផង និង វត្ថុមិនគួរខ្ពើមផង ក៏ឈ្មោះថា ជាអ្នកព្រងើយកន្តើយ មានសតិសម្បជញ្ញៈ គង់នៅ ។ ព្រោះថា ក្នុងបដិសម្ភិទា ព្រះសារីបុត្រ ចំណែកសេចក្ដីនេះឯង ដោយន័យជាដើមថា “សួរថាៈ ភិក្ខុមានសេចក្ដីសំគាល់ថា មិនគួរខ្ពើម ក្នុងវត្ថុដែលគួរខ្ពើមគង់នៅ តើដូចម្ដេច? ។ ឆ្លើយថាៈ ភិក្ខុផ្សាយមេត្តាចិត្ត ឬ ពិចារណាថា ជាធាតុ ក្នុងវត្ថុដែលមិនជាទីប្រាថ្នា” ដូច្នេះ ដោយប្រការយ៉ាងនេះឯង ។

ឫទ្ធិ មានភាពជាអ្នកមានសេចក្ដីសំគាល់ថា មិនគួរ ក្នុងវត្ថុដែលគួរ ជាដើមនេះ លោកហៅថា អរិយឫទ្ធិ ព្រោះកើតមានចំពោះព្រះអរិយៈទាំងឡាយ ដែលបាននូវចេតោវសី តែប៉ុណ្ណោះ ដោយប្រការដូច្នេះឯង ។

(៧- កម្មវិបាកជឫទ្ធិ)

ចំណែកឫទ្ធិ មានការទៅតាមអាកាសជាដើម របស់សត្វទាំងឡាយ មានសត្វស្លាបជាដើម ឈ្មោះថា ឫទ្ធិ កើតអំពីផលកម្ម ។ ដូចបាលីថា "សួរថា: ឫទ្ធិ កើតអំពីផលកម្ម តើដូចម្ដេច? ។ ឆ្លើយថា: ឫទ្ធិ របស់សត្វស្លាបទាំងអស់ របស់ទេវតាទាំងអស់ របស់ពួកមនុស្សខ្លះ របស់សត្វជាវិនិបាតិកៈខ្លះ នេះ គឺឫទ្ធិ កើតអំពីផលកម្ម" ដូច្នេះ ។ មែនពិត បណ្ដាសត្វទាំងនោះ ការទៅតាមអាកាសបាន របស់សត្វស្លាបទាំងអស់ វៀរចាកឈាន ឬ វិបស្សនា ជាឫទ្ធិ កើតអំពីផលកម្ម, ក៏ដូចគ្នានោះដែរ ការទៅតាមអាកាសបាន របស់ពួកទេវតាទាំងអស់ និង មនុស្សពួកខ្លះ ដែលកើតក្នុងបឋមកប្ប ក៏ជាឫទ្ធិ កើតអំពីផលកម្មដែរ, ដូចគ្នានោះដែរ ការទៅតាមអាកាសបាន របស់វិនិបាតិកៈទាំងឡាយពួកខ្លះ មានជាអាទិ៍ គឺ យក្ខិនី ជាមាតារបស់ព្រះបិយង្ករ, យក្ខិនី ជាមាតារបស់ឧត្តរមាណព, យក្ខិនី ឈ្មោះបុស្សមិត្តា, យក្ខិនី ឈ្មោះធម្មគុត្តា ក៏ជាឫទ្ធិ កើតអំពីផលកម្មដែរ យ៉ាងនេះឯង ។

(៨- បុញ្ញវតោឥទ្ធិ)

ចំណែកឯឫទ្ធិ មានការទៅតាមអាកាសជាដើម នៃវិសេសជនទាំងឡាយ មានស្ដេចចក្រពត្តិជាដើម ឈ្មោះថា ឫទ្ធិ របស់បុគ្គលអ្នកមានបុណ្យ ។ សមដូចព្រះសារីបុត្រពោលថា "ឫទ្ធិ របស់បុគ្គលអ្នកមានបុណ្យ តើដូចម្ដេច? ។ ព្រះរាជា ចក្រពត្តិ ទ្រង់ស្ដេចទៅកាន់អាកាស

បាន មួយអន្លើដោយសេនា ប្រកបដោយអង្គ ៤ ដោយហោចទៅ រាប់តាំងអំពីបុរសអ្នកចងសេះ និង អ្នករក្សាគោ, ឫទ្ធិ របស់អ្នកមានបុណ្យ ឈ្មោះជោតិកគហបតី, ឫទ្ធិ របស់អ្នកមានបុណ្យ ឈ្មោះជដិលគហបតី, ឫទ្ធិ របស់អ្នកមានបុណ្យ ឈ្មោះឃោសិតគហបតី, ឫទ្ធិ របស់អ្នកមានបុណ្យ ឈ្មោះមេណ្ឌកគហបតី, ឫទ្ធិ របស់បុគ្គលអ្នកមានបុណ្យធំ ៥ នាក់, ឫទ្ធិនេះ ឈ្មោះថា ឫទ្ធិ របស់បុគ្គលអ្នកមានបុណ្យ [១] "ដូច្នេះ ។ បើនិយាយដោយសង្ខេប គុណវិសេស របស់បុគ្គលដែលសំរេច ក្នុងបុញ្ញសម្ភារ ដែលដល់នូវការពេញលេញហើយ ឈ្មោះថា ឫទ្ធិ របស់បុគ្គលអ្នកមានបុណ្យ ។

ក៏បណ្ដាបុគ្គលអ្នកមានបុណ្យទាំងនោះ សំរាប់ជោតិកគហបតី មានប្រាសាទកែវមណី និង ដើមកប្បព្រឹក្ស ៦៤ ដើម ទំលាយនូវផែនដីផុសឡើងហើយ, នេះជាឫទ្ធិ របស់អ្នកមានបុណ្យ ឈ្មោះជោតិកគហបតីនោះ ។ សំរាប់ជដិលគហបតី មានភ្នំមាសកំពស់ ៨០ ហត្ថ កើតឡើងហើយ ។ កាលបើគេធ្វើសេចក្ដីព្យាយាមដើម្បីសម្លាប់ ក្នុងទី ៧ កន្លែង ភាពមិនមានរោគ ជាឫទ្ធិ របស់អ្នកមានបុណ្យឈ្មោះឃោសកគហបតី។ ការៈនៃពពែទាំងឡាយ ដែលសំរេចហើយអំពីរតនៈ ៧ ប្រការ ប្រាកដឡើង ក្នុងប្រទេសត្រឹមតែក្ដួរបានមួយគន្លង ជាឫទ្ធិ របស់អ្នកមានបុណ្យ ឈ្មោះមេណ្ឌកគហបតី ។ ឈ្មោះថា បុគ្គលអ្នកមានបុណ្យទាំងឡាយ ៥ នាក់ គឺ: មេណ្ឌកសេដ្ឋី ១, ភរិយារបស់គាត់ ឈ្មោះចន្ទបទុមសិរិ ១, កូនប្រុស ឈ្មោះធនញ្ជយសេដ្ឋី ១, កូនប្រសាស្រី ឈ្មោះសុមនទេវី ១, ខ្ញុំប្រុស ឈ្មោះបុណ្ណៈ ១ ។ បណ្ដាបុគ្គលអ្នកមានបុណ្យទាំង ៥ នោះ

១- សុ. ខុ. គាតទី ៧១ ទំព័រទី ២៨៨ ។

ក្នុងពេលដែលសេដ្ឋីកក់ក្បាលហើយ ងើយមើលទូវអាកាស ជង្រុកស្រូវ ១,២៥០ ខ្នង ពេញដោយស្រូវសាលីពណ៌ក្រហមអំពីអាកាស ។ កាលភរិយា ចាប់យកបាយត្រឹមតែមួយនាឡិ ហើយអង្គាសនូវជនទាំងឡាយ អ្នកនៅក្នុងជម្ពូទ្វីបទាំងមូល, បាយក៏នៅតែមិនអស់ដែរ ។ កាលដែលកូនប្រុស យកនូវថង់កហាបណៈមួយពាន់ហើយ ឲ្យដល់ពួកជនអ្នកនៅក្នុងជម្ពូទ្វីបទាំងអស់ កហាបណៈទាំងឡាយ ក៏នៅតែមិនអស់ ។ កាលកូនប្រសាស្រី យកស្រូវមួយកញ្ជើ ហើយប្រើឲ្យគេចែក ដល់ជនអ្នកនៅក្នុងជម្ពូទ្វីបទាំងមូល ស្រូវក៏នៅតែមិនអស់ដែរ ។ កាលខ្ញុំប្រុសភ្ជួរដោយនង្គ័លមួយ កើតមាន ១៤ គន្លង គឺ ខាងនេះ ៧ គន្លង ខាងនេះ ៧ គន្លង ។ នេះជាឫទ្ធិ របស់អ្នកមានបុណ្យ នៃជនទាំង ៥ នោះ ។

(៩- វិជ្ជាមយឫទ្ធិ)

ចំណែកឫទ្ធិ មានដំណើរទៅកាន់អាកាសជាដើម នៃជនទាំងឡាយមានជនអ្នកទ្រទ្រង់ នូវវិជ្ជាជាដើម ឈ្មោះថា ឫទ្ធិ សម្រេចដោយវិជ្ជា ។ សមដូចបាលីថា “ឫទ្ធិសំរេចដោយវិជ្ជា តើដូចម្ដេច? ។ ពួកអ្នកវិជ្ជាធរ រាយនូវវិជ្ជាហើយ ហោះទៅកាន់អាកាសបាន សំដែងខ្លួនជាដំរី នៅលើអាកាសទទេក៏បាន ។ល។ សំដែងខ្លួនជាកងទាហានផ្សេងៗ ក៏បាន ។

(១០- តត្ថ តត្ថ... ឥជ្ឈនដ្ឋេន ឥទ្ធិ)

ចំណែកការសំរេចនូវកម្មនោះៗ ព្រោះការប្រកបត្រូវនោះៗ ឈ្មោះថាឫទ្ធិ ដោយអត្ថថាសំរេច ព្រោះការប្រកបត្រូវក្នុងកម្មនោះៗជាបច្ច័យ។ សមដូចបាលីថា “ឈ្មោះថា ឫទ្ធិ ដោយអត្ថថាសំរេច ព្រោះការប្រកបត្រូវក្នុងអំពើនោះៗ ជាបច្ច័យ ព្រោះសំរេចអត្ថនៃការលះបង់នូវកាមច្ឆន្ទៈដោយនេក្ខម្មៈ ។ល។ ឈ្មោះថា ឫទ្ធិដោយអត្ថថាសំរេច ព្រោះការប្រកប

ត្រូវ ក្នុងអំពើនោះៗជាបច្ច័យ ព្រោះសំរេចអត្ថនៃការលះបង់នូវកិលេសទាំងឡាយទាំងពួង ដោយអរហត្តមគ្គ [១] ” ដូច្នេះ ។

ឯបាលីមកហើយ ក្នុងនិទ្ទេសនៃឫទ្ធិទាំង១០ នេះ ក៏ដូចគ្នានឹងបាលីក្នុងនិទ្ទេសនៃឫទ្ធិមុនដែរ ដោយអំណាចនៃការសំដែង នូវសេចក្ដីប្រកបត្រូវ ពោលគឺការប្រតិបត្តិដូចគ្នា ។ ចំណែកឯឫទ្ធិ ដែលមកហើយ ក្នុងអដ្ឋកថាថា “គុណវិសេសដែលកើតឡើងហើយ ព្រោះធ្វើកម្មនោះៗ គឺសិល្បកម្ម ណានីមួយ ដោយអំណាចនៃការធ្វើនូវវិធីមានក្បួនរទេះ ជាដើម វេជ្ជកម្ម ណានីមួយ ការរៀននូវវេទទាំងបី ការរៀនព្រះត្រៃបិដកទាំងបី ដោយហោចទៅ មានការភ្ជួរនិងការសាបព្រោះជាដើម ឈ្មោះថាឫទ្ធិដោយអត្ថថាសំរេច ព្រោះការប្រកបត្រូវក្នុងកម្មនោះៗ ជាបច្ច័យ” ។

ក្នុងឫទ្ធិទាំង ១០ ដែលពោលមកនេះ អធិដ្ឋានឫទ្ធិ ប៉ុណ្ណោះ មកហើយ ក្នុងបទនេះថា “ឥទ្ធិវិធាយ” ដូច្នេះ ។ តែក្នុងសេចក្ដីនេះ បណ្ឌិតគប្បីប្រាថ្នា វិកុព្វនឫទ្ធិ និង មនោមយឫទ្ធិ មែនពិត ។

(កែអត្ថបទបាលី)

(២៣៧) បទថា “ឥទ្ធិវិធាយ” សេចក្ដីថា ក្នុងចំណែកនៃឫទ្ធិ ឬក៏ក្នុងដំណែងនៃឫទ្ធិ ។ ច្រើនបទថា “ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ” សេចក្ដីថា ភិក្ខុនោះ កាលបើចិត្តនោះ គឺឈានមានអភិញ្ញាជាទីតាំង កើតហើយ ដោយអំណាចនៃការអប់រំចិត្ត មានប្រការដូចពោលមកហើយ រមែងបង្អោន នូវបរិកម្មចិត្តទៅ ដើម្បីប្រយោជន៍ដល់ការបានចំណែក នៃឫទ្ធិ គឺនាំចេញ(នូវចិត្ត) ចាកអារម្មណ៍នៃកសិណហើយ តែងបញ្ជូន (នូវចិត្តនោះ)ឲ្យមានមុខឆ្ពោះទៅរកការដំណែងឫទ្ធិ ។ បទថា “អភិនិន្នាមេតិ”

១- សុ. ខុ ភាគទី ៧១ ទំព័រទី ២៨៥ ។

សេចក្តីថា ធ្វើ (នូវចិត្ត) ឲ្យទេរទៅរកឫទ្ធិ គឺឲ្យញោចទៅរកឫទ្ធិ ដែលខ្លួនគប្បីបាន ។ បទថា "សោ" បានដល់ភិក្ខុនោះ ជាអ្នកមានការកសាងក្នុងចិត្តបានធ្វើហើយ យ៉ាងដូច្នោះ ។ បទថា "អនេកវិហិតំ" ប្រែថា មានច្រើនបែប គឺមានប្រការផ្សេងៗ ។ បទថា "ឥទ្ធិវិធំ" ប្រែថាចំណែកនៃឫទ្ធិ ។ បទថា "បច្ចនុភោតិ" សេចក្តីថា បានសោយ គឺបានពាល់ត្រូវ បានធ្វើឲ្យជាក់ច្បាស់ បានសំរេច ។

(ពហុភាវបាដិហារ្យ)

ក្នុងកាលឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សំដែង នូវភាវៈនៃចំណែកនៃឫទ្ធិនោះមានច្រើនយ៉ាង ទើបទ្រង់ត្រាស់ថា "ឯកោបិ ហុត្វា" ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា "ឯកោបិ ហុត្វា" គឺ តាមប្រក្រតី ក្នុងពេលមុន អំពីការធ្វើនូវឫទ្ធិហ្នឹងឯង ក៏ជាបុគ្គលតែមួយរូប ។ ពីរបទថា "ពហុធា ហោតិ" សេចក្តីថា (ភិក្ខុមួយរូប) ជាអ្នកប្រាថ្នាដើម្បីចង្ក្រមក្តី ជាអ្នកប្រាថ្នាដើម្បីធ្វើនូវការស្វាធ្យាយក្តី ជាអ្នកប្រាថ្នាដើម្បីសួរប្រស្នាក្តី ក្នុងសំណាក់នៃភិក្ខុច្រើនរូប (ឲ្យ) ទៅជាមួយរយរូបក៏បាន មួយពាន់រូបក៏បាន ។

(ឥទ្ធិវិធី)

សួរថា "ចុះភិក្ខុរូបនេះ កើតយ៉ាងនេះ ដោយប្រការដូចម្តេច?" ។ ឆ្លើយថា "ភិក្ខុរូបនោះ ញ៉ាំងភូមិ ៤ នៃឫទ្ធិ បាទ ៤ បទ ៨ មូល ១៦ នៃឫទ្ធិ ឲ្យដល់ព្រមហើយ អធិដ្ឋានដោយញាណ ។

(ភូមិ ៤ នៃឫទ្ធិ)

ក្នុងវិធីទាំងនោះ ឈាន ៤ បណ្ឌិតគប្បីជ្រាបថា ភូមិ ៤ ។ សមដូចជាព្រះធម្មសេនាបតី ពោលហើយថា "ភូមិ ៤ នៃឫទ្ធិ តើដូចម្តេច ? ។

ភូមិជាទីកើតនៃវិវេក គឺបឋមជ្ឈាន ១ ភូមិជាទីកើតនៃបីតិ និង សុខៈ គឺទុតិយជ្ឈាន ១ ភូមិជាទីកើតនៃឧបេក្ខានិងសុខៈ គឺតតិយជ្ឈាន ១ ភូមិជាទីកើតនៃវេទនាមិនទុក្ខមិនសុខៈ គឺចតុត្ថជ្ឈាន ១, នេះឯង ភូមិទាំង ៤ របស់ឫទ្ធិ ប្រព្រឹត្តទៅ ដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ដើម្បីការធ្វើឲ្យប្លែកនៃឫទ្ធិ ដើម្បីបង្ហួរទៅនៃឫទ្ធិ ដើម្បីភាពនៃការស្ទាត់ក្នុងឫទ្ធិ ដើម្បីសេចក្តីក្លៀវក្លា ក្នុងឫទ្ធិ [១] " ។

ក៏ព្រះយោគី ឈានចូលហើយ នូវសុខសញ្ញាផង នូវលហុសញ្ញាផង ហើយជាអ្នកមានកាយស្រាល ទន់ និង គួរដល់ការងារ ហើយសំរេចនូវឫទ្ធិ ព្រោះការផ្សាយនូវបីតិ និង ព្រោះការផ្សាយនូវសុខៈ ព្រោះហេតុណា ព្រោះហេតុនោះ បណ្តាឈានទាំង ៤ នោះ បណ្ឌិតគប្បីជ្រាបឈាន ៣ ខាងដើម ថា "ឈ្មោះថា មានភូមិសំរាប់ជាគ្រឿងប្រកប" ព្រោះប្រព្រឹត្តទៅដើម្បីបានចំពោះនូវឫទ្ធិ ដោយបរិយាយនេះ ។ ចំណែកចតុត្ថជ្ឈាន ឈ្មោះថា ភូមិជាប្រក្រតី ព្រោះប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិមែនពិត ។

(បាទនៃឫទ្ធិ ៤)

ឥទ្ធិបាទ ៤ បណ្ឌិតគប្បីជ្រាបថា បាទ ៤ ។ សមដូចជាព្រះបាលីថា "ឫទ្ធិ មានបាទ ៤ តើដូចម្តេច? ។ ភិក្ខុ ក្នុងសាសនានេះ ចំរើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និង បធានសង្ខារ ១ ចំរើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ និង បធានសង្ខារ ១ ចំរើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ និង បធានសង្ខារ ១ ចំរើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និង បធានសង្ខារ ១, នេះឯងបាទទាំង ៤ នៃឫទ្ធិ ប្រព្រឹត្ត

១- សុ. ខុ. គាគទី ៧១ ទំព័រទី ២៦៤ ។

ទៅ ដើម្បីបាននូវឫទ្ធិ ។ល។ ដើម្បីសេចក្តីក្លៀវក្លា ក្នុងឫទ្ធិ " ។

ក៏ក្នុងនិទ្ទេសនៃឥទ្ធិបាទនេះ សមាធិដែលមានឆន្ទៈជាហេតុក្តី មានឆន្ទៈដ៏លើសលុបក្តី ឈ្មោះថា ឆន្ទសមាធិ ។ ពាក្យថា ឆន្ទសមាធិនេះ ជាឈ្មោះនៃសមាធិ ដែលព្រះយោគីធ្វើនូវឆន្ទៈ គឺភាពនៃខ្លួនជាអ្នកចង់ធ្វើឲ្យជាអធិបតី ហើយទើបបានសំរេច ។

សង្ខារទាំងឡាយដែលជាតួនៃសេចក្តីព្យាយាម ឈ្មោះថា បធានសង្ខារ ។ ពាក្យថា បធានសង្ខារនេះ ជាឈ្មោះ នៃសេចក្តីព្យាយាម ពោលគឺសេចក្តីព្យាយាមត្រូវ ដែលញុំាងកិច្ច ៤ ឲ្យសំរេច ។ ពាក្យថា "សមន្នាគតំ" គឺប្រកបហើយ ដោយឆន្ទសមាធិ និង បធានសង្ខារ ។ ពាក្យថា "ឥទ្ធិបាទំ" សេចក្តីថា គំនរនៃចិត្ត និង ចេតសិកដ៏សេសដែលឈ្មោះថា បាទ ព្រោះសេចក្តីថាជាទីតាំងនៃឆន្ទសមាធិ និង បធានសង្ខារទាំងឡាយ ដែលប្រកបហើយ ដោយអភិញ្ញាចិត្ត ដែលដល់នូវការរាប់ថា ឫទ្ធិ ដោយអត្ថថាសំរេច ដោយបរិយាយថាកើតផល ន័យមួយទៀតដល់នូវការរាប់ថា ឫទ្ធិ ព្រោះជាគ្រឿងសំរេចនៃសត្វទាំងឡាយ ដោយបរិយាយនេះថា ជាគ្រឿងរុងរឿង ជាគ្រឿងចំរើន ជាគ្រឿងដ៏ខ្ពង់ខ្ពស់ ។ សមដូចជាព្រះបាលី ថា : "ពាក្យថា ឥទ្ធិបាទ បានដល់ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នៃភិក្ខុអ្នកប្រាកដដូច្នោះ " ។

ន័យមួយទៀត ឈ្មោះថា បាទ ព្រោះជាគ្រឿងដែលបុគ្គលគប្បីដល់ អធិប្បាយថា ជាគ្រឿងសំរេច ។ បាទនៃឫទ្ធិ ឈ្មោះថា ឥទ្ធិបាទ ។ ពាក្យថា ឥទ្ធិបាទ នេះ ជាឈ្មោះនៃធម៌ទាំងឡាយ មានឆន្ទៈជាដើម ។ សមដូចជាព្រះបាលីថា "ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអាស្រ័យ នូវឆន្ទៈ ហើយបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ, នេះហៅ

ថា ឆន្ទសមាធិ, ភិក្ខុនោះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ។ល។ ទាំងនេះហៅថា បធានសង្ខារ, នេះហៅថា ឆន្ទៈផង នេះហៅថា ឆន្ទសមាធិផងនេះហៅថា បធានសង្ខារផង ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា ឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និង បធានសង្ខារ [១] " ។ សូម្បីក្នុងឥទ្ធិបាទដ៏សេស ក៏បណ្ឌិតគប្បីជ្រាបសេចក្តី យ៉ាងនេះដែរ ។

(បទ ៨ នៃឫទ្ធិ)

(២៣៨) បទទាំងឡាយ ៨ មានឆន្ទៈជាដើម បណ្ឌិតគប្បីជ្រាបថាបទ៨ ។ សមដូចព្រះបាលីថា "ឫទ្ធិ មានបទ ៨ តើដូចម្តេច? ។ បើភិក្ខុអាស្រ័យឆន្ទៈ ហើយបាននូវសមាធិ គឺបាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ១, ឆន្ទៈមិនមែនសមាធិ សមាធិមិនមែនឆន្ទៈ ឆន្ទៈដោយឡែកសមាធិដោយឡែក ១, បើភិក្ខុអាស្រ័យនូវវីរិយៈ ហើយបាននូវសមាធិគឺបាននូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ១, វីរិយៈ មិនមែនសមាធិសមាធិមិនមែនវីរិយៈ វីរិយៈដោយឡែក សមាធិដោយឡែក ១, បើភិក្ខុអាស្រ័យចិត្ត ហើយបានសមាធិ គឺបាននូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ១, ចិត្តមិនមែនសមាធិ សមាធិមិនមែនចិត្ត ចិត្តដោយឡែកសមាធិដោយឡែក ១, បើភិក្ខុអាស្រ័យនូវវីមំសា ហើយបានសមាធិគឺបាននូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ១, វីមំសា មិនមែនសមាធិសមាធិមិនមែនវីមំសា វីមំសាដោយឡែក សមាធិដោយឡែក ១, ទាំងនេះឯង បទ ៨ របស់ឫទ្ធិ ប្រព្រឹត្តទៅ ដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះ

១- សុ. សំ. ម. ភាគទី ៣៨ ទំព័រទី ២៩១ ។

នូវឫទ្ធិ ដើម្បីការធ្វើឲ្យប្លែកនៃឫទ្ធិ ដើម្បីបង្ហូរទៅនៃឫទ្ធិ ដើម្បីភាពនៃការស្ទាត់ក្នុងឫទ្ធិ ដើម្បីសេចក្តីក្លៀវក្លាក្នុងឫទ្ធិ” ។ ព្រោះក្នុងបាលីនោះ ឆន្ទៈ គឺភាពជាអ្នកប្រាថ្នាដើម្បីញុំាងឫទ្ធិ ឲ្យកើតឡើង លុះតែប្រកបហើយក្នុងទីជាមួយគ្នា ដោយសមាធិប៉ុណ្ណោះ ទើបប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិ ។ ឥទ្ធិបាទទាំងឡាយដ៏សេស មានវីរិយៈជាដើម ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បទទាំង ៨ មានឆន្ទៈជាដើមនេះ បណ្ឌិតគប្បីជ្រាបថា លោកពោលហើយថា បទ ៨ ។

(មូល ១៦ នៃឫទ្ធិ)

ភាពនៃចិត្តមិនញាប់ញ័រ ដោយអាការៈ ១៦ បណ្ឌិតគប្បីជ្រាបថា មូល ១៦ ។ សមដូចព្រះបាលីថា “ឫទ្ធិ មានមូល ១៦ តើដូចម្តេច? ។

(១) ចិត្ត ដែលមិនទ្រោម រមែងមិនញាប់ញ័រ ដោយសេចក្តីខ្ជិលច្រអូស ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(២) ចិត្ត ដែលមិនប៉ោងឡើង រមែងមិនញាប់ញ័រ ដោយសេចក្តីរវើរវាយ ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(៣) ចិត្ត ដែលមិនទន់ទោរ រមែងមិនញាប់ញ័រ ដោយរាគៈ ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(៤) ចិត្ត ដែលមិនបង្អោន រមែងមិនញាប់ញ័រ ដោយព្យាបាទ ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(៥) ចិត្ត ដែលមិនអាស្រ័យ រមែងមិនញាប់ញ័រ ដោយទិដ្ឋិ ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(៦) ចិត្ត ដែលមិនជាប់ជំពាក់ រមែងមិនញាប់ញ័រ ដោយឆន្ទរាគៈ ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(៧) ចិត្ត ដែលផុតស្រឡះ រមែងមិនញាប់ញ័រ ដោយកាមរាគៈ ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(៨) ចិត្ត ដែលមិនមានគ្រឿងប្រកប រមែងមិនញាប់ញ័រ ដោយកិលេស ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(៩) ចិត្ត ដែលគ្មានភ្លឺគឺកិលេស រមែងមិនញាប់ញ័រ ដោយភ្លឺគឺកិលេស ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(១០) ចិត្ត ដែលមានអារម្មណ៍តែមួយ រមែងមិនញាប់ញ័រ ដោយកិលេសមានសភាពផ្សេងៗ ហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(១១) ចិត្ត ដែលមានសទ្ធាថែរក្សា រមែងមិនញាប់ញ័រ ដោយវត្ថុដែលមិនគួរជឿ ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(១២) ចិត្ត ដែលមានវីរិយៈថែរក្សា រមែងមិនញាប់ញ័រ ដោយការខ្ជិលច្រអូស ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(១៣) ចិត្តដែលមានសតិថែរក្សា រមែងមិនញាប់ញ័រដោយសេចក្តីប្រមាទ ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(១៤) ចិត្ត ដែលមានសមាធិថែរក្សា រមែងមិនញាប់ញ័រ ដោយសេចក្តីរាយមាយ ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(១៥) ចិត្ត ដែលមានបញ្ញាថែរក្សា រមែងមិនញាប់ញ័រដោយអវិជ្ជា ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

(១៦) ចិត្ត ដែលភ្លឺស្វាង រមែងមិនញាប់ញ័រ ដោយងងឹតគឺអវិជ្ជា ព្រោះហេតុនោះ ទើបឈ្មោះថា ចិត្តមិនញាប់ញ័រ,

ទាំងនេះ ជាមូល ១៦ របស់ឫទ្ធិ តែងប្រព្រឹត្តទៅ ដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ដើម្បីការធ្វើឲ្យប្លែកនៃឫទ្ធិ ដើម្បីបង្ហូរទៅនៃឫទ្ធិ

ដើម្បីភាពនៃការស្ទាត់ក្នុងឫទ្ធិ ដើម្បីសេចក្តីក្លៀវក្លាក្នុងឫទ្ធិ [១]” ដូច្នេះ ។

សេចក្តីនេះ ទុកជាសម្រេចហើយ ដោយបទថា “ឯវំ សមាហិតេ ចិត្តេ” ដូច្នេះជាដើម ក៏ពិតមែនហើយ ។ តែបើទុកជាដូច្នោះ លោកបានពោលហើយ ម្តងទៀត ដើម្បីសំដែងនូវភាពនៃឈានទាំងឡាយ មានបឋមជ្ឈានជាដើម ជាភូមិ ជាបាទ ជាបទ និង ជាមូលនៃឫទ្ធិ ។ ចំណែកន័យខាងដើម ជាន័យមកហើយ ក្នុងព្រះសូត្រទាំងឡាយ ។ ន័យនេះមកហើយ ក្នុងបដិសម្ភិទា ។ លោកពោលន័យនេះ ម្តងទៀត ដើម្បីកុំឲ្យភាន់ច្រឡំ ក្នុងសូត្រទាំងពីរ ដូច្នេះក៏បាន ។

(អធិដ្ឋានដោយញាណ)

(២៣៩) ឯពាក្យថា “ញាណេន អធិដ្ឋហន្តោ” សេចក្តីថា ក៏ឯព្រះយោគីនេះនោះ លុះញុំាងធម៌ទាំងឡាយនេះ ដែលជាភូមិ ជាបាទ ជាបទ និង ជាមូល នៃឫទ្ធិ ឲ្យសំរេចហើយ ក៏ចូលឈានមានអភិញ្ញាជាទីតាំង ចេញហើយ ថាបើប្រាថ្នាមនុស្ស ១០០ នាក់ ធ្វើបរិកម្ម ថា “អាត្មាអញ ចូរជាមនុស្ស ១០០ នាក់, អាត្មាអញ ចូរជាមនុស្ស ១០០ នាក់” ដូច្នេះហើយ ចូលឈានមានអភិញ្ញាជាទីតាំងម្តងទៀត ចេញហើយអធិដ្ឋាន ។ ព្រមទាំងចិត្តអធិដ្ឋានហ្នឹងឯង ភិក្ខុនោះ នឹងកើតជាមនុស្ស ១០០ នាក់ ។ ន័យសូម្បីក្នុងមនុស្ស ១,០០០ នាក់ជាដើម ក៏ន័យនេះដែរ ។ ប្រសិនបើ (ធ្វើ) យ៉ាងនេះ មិនបានសំរេច ព្រះយោគី ត្រូវធ្វើបរិកម្មម្តងទៀតហើយ ញុំាងឈានឲ្យសំរេច អស់វារៈ ២ ដង ចេញហើយ អធិដ្ឋានក៏បាន ។ ព្រោះក្នុងអដ្ឋកថាសំយុត្តនិកាយ លោកពោលហើយថា “ព្រះយោគីចូល (ឈាន) អស់វារៈមួយដង អស់វារៈពីរដង ក៏គួរ” ដូច្នេះ ។ ក្នុងការ

១- សុ. ខុ. គាគទី ៧១ ទំព័រទី ២៦៦ ។

អធិដ្ឋាននោះ ចិត្ត ដែលមានឈានជាទីតាំង មាននិមិត្តជាអារម្មណ៍, ចិត្តក្នុងបរិកម្មទាំងឡាយ មានមនុស្សចំនួន១០០ ជាអារម្មណ៍ ឬមានមនុស្សចំនួន ១,០០០ ជាអារម្មណ៍ ។ តែអារម្មណ៍ទាំងនោះ កើតមាន ដោយអំណាចនៃពណ៌ មិនមែនដោយអំណាចនៃបញ្ញត្តិទេ។ សូម្បីអធិដ្ឋានចិត្តក៏យ៉ាងដូច្នោះដែរ គឺមានមនុស្សចំនួន១០០ ជាអារម្មណ៍ ឬ មានមនុស្សចំនួន ១,០០០ ជាអារម្មណ៍ ។ អធិដ្ឋានចិត្តនោះ ជាចិត្តតែមួយប៉ុណ្ណោះ ប្រកបដោយរូបាវចរចតុត្ថជ្ឈាន រមែងកើតឡើង បន្ទាប់អំពីគោត្រភូចិត្ត ដូចជាអប្បនាចិត្ត ដែលលោកពោលហើយ ក្នុងកាលមុន ។ ពាក្យឯណា ដែលលោកពោលហើយ ក្នុងបដិសម្ភិទាថា “ដោយប្រក្រតី ភិក្ខុតែមួយរូបទេ តែនឹកចង់ឲ្យបានច្រើនរូប គឺនឹកឲ្យទៅជាមួយរយរូបក្តី មួយពាន់រូបក្តី មួយម៉ឺនរូបក្តី លុះនឹកចង់ហើយ ក៏អធិដ្ឋានដោយញាណថា: សូមឲ្យអាត្មាអញមានរូបច្រើន ភិក្ខុនោះ ក៏បានរូបច្រើន ដូចជាព្រះចុល្លបន្ថកដ៏មានអាយុ [១] ” ដូច្នេះ, សូម្បីក្នុងពាក្យដែលលោកពោលហើយ ក្នុងបដិសម្ភិទានោះ ពាក្យថា “នឹករំពឹង” លោកពោលហើយ ដោយអំណាចនៃបរិកម្មហ្នឹងឯង ។ ពាក្យថា “លុះនឹកហើយ ក៏អធិដ្ឋាន ដោយញាណ” គឺលោកពោលហើយ ដោយអំណាចនៃញាណក្នុងអភិញ្ញា ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបសេចក្តី ក្នុងពាក្យថា អធិដ្ឋានដោយញាណនោះ យ៉ាងដូច្នេះថា “ព្រះយោគី នឹកចង់ឲ្យបានច្រើនរូប បន្ទាប់អំពីនោះ ចូលសមាបត្តិ ក្នុងទីបំផុតនៃបរិកម្មចិត្តទាំងនោះ ចេញអំពីសមាបត្តិហើយ នឹកម្តងទៀតថា “សូមឲ្យអាត្មាអញមានរូបច្រើន” ដូច្នេះហើយ អធិដ្ឋាន ដោយអភិញ្ញាញាណ តែមួយប៉ុណ្ណោះ កើតឡើងហើយ ក្នុងលំដាប់

១- សុ. ខុ. គាគទី ៧១ ទំព័រទី ២៦៩ ។

នៃចិត្តដែលជាបុព្វភាគ បី ឬ បួន ដែលប្រព្រឹត្តទៅ បន្ទាប់អំពីអាវជ្ជន-ចិត្តនោះ ដែលបានឈ្មោះថា អធិដ្ឋាន(ញាណ) ដោយអំណាចនៃការញុំាងចិត្តឲ្យសំរេច” ដូច្នេះៗ ចំណែកពាក្យណាដែលលោកពោលហើយថា ដូចជាព្រះចុល្លបន្ថក ដ៏មានអាយុ, ពាក្យនោះ លោកពោលហើយដើម្បីសំដែងនូវកាយជាបន្ទាល់ នៃភាពមានចំណែកច្រើន ។ ប៉ុន្តែពាក្យនោះ បណ្ឌិតគប្បីសំដែងដោយរឿង ។

(រឿងព្រះចុល្លបន្ថក)

(២៤០) បានឮមកថា បងប្អូនពីរនាក់នោះ បានឈ្មោះថា បន្ថកៈព្រោះភាវៈនៃខ្លួនជាអ្នកកើតហើយក្នុងផ្លូវ ។ បណ្ដាបងប្អូនទាំងពីរនាក់នោះ បងឈ្មោះថា មហាបន្ថកៈ ។ លោកបួសហើយ ក៏បានសំរេចនូវព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ លុះបានជាព្រះអរហន្តហើយក៏បានបំបួសចុល្លបន្ថកៈ បានឲ្យនូវគាថានេះ ថា :

ចូរអ្នកមើលនូវព្រះអង្គីរស ដែលកំពុងតែរុងរឿង ដូចជាផ្កាឈូក ដែលមានក្លិនក្រអូប ជាទីរីករាយនៃសត្វកន្លង់ មានក្លិនមិនទៅប្រាសហើយ ក្នុងពេលព្រឹកយ៉ាងដូច្នោះ, ចូរអ្នកមើលនូវព្រះអង្គីរស ដែលភ្លឺស្វាង ប្រៀបដូចជាព្រះអាទិត្យដែលកំពុងតែរុងរឿង ឰដ៏អាកាស ដូច្នោះ ។

ព្រះចុល្លបន្ថកនោះ មិនអាចដើម្បីធ្វើគាថានោះឲ្យស្ទាត់បាន ដោយ ៤ ខែ ។ គ្រានោះ ព្រះថេរៈ បានបណ្ដេញព្រះចុល្លបន្ថកនោះ ចេញពីវត្តដោយពាក្យថា “អ្នកជាបុគ្គលអភព្វ ក្នុងសាសនា” ។ ក៏ក្នុងកាលនោះព្រះថេរៈ ជាភត្តុទ្ទេសក៍ ។ ពេទ្យឈ្មោះ ជីវកៈ ចូលទៅគាល់ព្រះថេរៈ

ហើយទូលថា “បពិត្រព្រះថេរៈដ៏ចំរើន ក្នុងថ្ងៃស្អែក សូមលោកម្ចាស់នាំយកភិក្ខុ៥០០ អង្គ មួយអន្លើដោយព្រះមានព្រះភាគ ទទួលចង្ហាន់ ក្នុងផ្ទះយើងខ្ញុំ” ។ ឯព្រះថេរៈ បានទទួលនិមន្តហើយ ដោយពាក្យថា “អាត្មាទទួលនិមន្តសំរាប់ភិក្ខុដ៏សេសបាន លើកលែងតែព្រះចុល្លបន្ថក” ។ ព្រះចុល្លបន្ថក ឈរស្រែកយំក្បែរខ្លោងទ្វារ, ព្រះមានព្រះភាគ ទតព្រះនេត្រឃើញដោយទិព្វចក្ខុហើយ ទ្រង់យាងចូលទៅរកព្រះចុល្លបន្ថក ត្រាស់ថា “ព្រោះហេតុអ្វីបានជាអ្នកយំ?” ។ លោកបានក្រាបទូលរឿងនោះហើយៗ ព្រះមានព្រះភាគទ្រង់ត្រាស់ថា “ភិក្ខុអ្នកមិនអាច ដើម្បីធ្វើការស្វាធ្យាយមិនឈ្មោះថា ជាអ្នកអភព្វ ក្នុងសាសនា នៃតថាគតទេ, នៃភិក្ខុ ចូរអ្នកកុំសោយសោកឡើយ” ហើយទ្រង់ចាប់ព្រះចុល្លបន្ថកនោះ ត្រង់ដើមដៃហើយយាងចូលទៅកាន់វិហារ ទ្រង់និម្មិត នូវចំណែកនៃកំណាត់សំពត់ដោយឫទ្ធិ ហើយទ្រង់ណែនាំថា “ហ៏ភិក្ខុ អ្នកកាលឈ្លីនូវកំណាត់សំពត់នេះ ចូរធ្វើនូវការស្វាធ្យាយ ឲ្យបានញយៗ ថា “កំណាត់សំពត់ជាគ្រឿងនាំមកនូវធូលីៗ” ។ កាលព្រះចុល្លបន្ថកនោះ ធ្វើយ៉ាងដូច្នោះ, កំណាត់សំពត់នោះ បានក្លាយទៅជាមានពណ៌ខ្មៅហើយ ។ ព្រះចុល្លបន្ថនោះបានចំពោះនូវសេចក្ដីសំគាល់ថា “សំពត់ បរិសុទ្ធល្អ, ទោស ក្នុងសំពត់នេះមិនមានទេ, តែនេះជាទោសរបស់រាងកាយ” ដូច្នេះហើយ ចុះកាន់ញាណក្នុងខន្ធ ៥ ចំរើនវិបស្សនាហើយ ក៏បានញុំាងញាណឲ្យដល់នូវទីជិត នៃគោត្រភូញាណ ដោយអនុលោមញាណ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នូវឱភាសគាថា ដល់ព្រះចុល្លបន្ថក ថា :

រាគៈ តថាគតឲ្យឈ្មោះថា ធូលី, តែលំអង តថាគតមិនហៅថា ធូលីទេ, ពាក្យថា លំអងនោះ ជាឈ្មោះនៃរាគៈ

បុគ្គលទាំងឡាយណាលះបង់នូវធូលីគឺរាគៈនោះបានហើយ បុគ្គលទាំងឡាយនោះ ជាបណ្ឌិត មាននៅ ក្នុងសាសនារបស់តថាគត ដែលមានធូលីទៅប្រាសហើយ ។

ទោសៈ តថាគតឲ្យឈ្មោះថា ធូលី, តែលំអងតថាគតមិនហៅថា ធូលីទេ, ពាក្យថាធូលីនោះជាឈ្មោះនៃទោសៈ, បុគ្គលទាំងឡាយណាលះបង់ធូលីគឺទោសៈនោះបានហើយ បុគ្គលទាំងឡាយនោះ ជាបណ្ឌិត មាននៅ ក្នុងសាសនារបស់តថាគត ដែលមានធូលីទៅប្រាសហើយ ។

មោហៈ តថាគតឲ្យឈ្មោះថា ធូលី, តែលំអងតថាគតមិនហៅថា ធូលីទេ, ពាក្យថាធូលីនោះជាឈ្មោះនៃមោហៈ, បុគ្គលទាំងឡាយណាលះបង់ធូលីគឺមោហៈនោះបានហើយ បុគ្គលទាំងឡាយនោះ ជាបណ្ឌិត មាននៅ ក្នុងសាសនារបស់តថាគត ដែលមានធូលីទៅប្រាសហើយ ។

(២៤១) ក្នុងកាលជាទីបំផុតនៃព្រះគាថា លោកុត្តរធម៌ ៩ ដែលមានបដិសម្ភិទា ៤ និង អភិញ្ញា ៦ ជាបរិវារ បានតាំងនៅហើយ ក្នុងដៃរបស់ព្រះចុល្លបន្ថកនោះមែនពិត ។ ក្នុងថ្ងៃទីពីរ ព្រះសាស្ដា ព្រមទាំងភិក្ខុសង្ឃ ទ្រង់បានស្ដេចយាងទៅកាន់ផ្ទះពេទ្យឈ្មោះជីវកៈ ។ គ្រានោះ ក្នុងពេលជាទីបំផុតនៃទឹកជាគ្រឿងចំរើន កាលបើគ្រូពេទ្យ ឈ្មោះជីវកប្រគេនយាគូ, ព្រះសាស្ដាទ្រង់បិទបាត្រ ដោយព្រះហត្ថ ។ គ្រូពេទ្យជីវកទូលសួរថា “បពិត្រព្រះអង្គដ៏ចំរើន តើយ៉ាងដូចម្ដេច?” ។ ព្រះអង្គទ្រង់ត្រាស់ថា “ក្នុងវត្ត មានភិក្ខុមួយរូប” ។ ពេទ្យជីវកនោះ បញ្ជូននូវបុរសទៅដោយពាក្យថា “ចូរអ្នកទៅនិមន្តយកលោកម្ចាស់ មកឲ្យបានឆាប់” ។

ក៏កាលព្រះដ៏មានព្រះភាគ ស្ដេចយាងចេញអំពីវត្ត

ព្រះបន្ថក បាននិមិត្ត នូវអត្តភាព អស់វារៈ គំរប់មួយពាន់ គង់នៅក្នុងវត្តអម្ពវ័ន ជាទីគួររីករាយ ដរាបដល់ពេលប្រកាសភត្តកាល ។

លំដាប់នោះ បុរសនោះ ទៅហើយ ឃើញនូវអារាមដែលមានពន្លឺតែមួយ ដោយសំពត់កាសាវៈទាំងឡាយមកហើយក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន អារាមពេញហើយ ដោយភិក្ខុទាំងឡាយ, ខ្ញុំព្រះអង្គ មិនដឹងថាៈ លោកម្ចាស់នោះ តើអង្គណាទេ” ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងបុរសនោះថា “អ្នកចូរទៅ អ្នកឃើញនូវភិក្ខុអង្គណាមុនគេ ចូរចាប់នូវភិក្ខុអង្គនោះ ត្រង់ជាយចីពរ ហើយពោលថាៈ ព្រះសាស្ដា ទ្រង់ត្រាស់ហៅលោក ដូច្នេះហើយ នាំមក” ។ បុរសនោះ ទៅហើយ បានចាប់ត្រង់ជាយចីពរ របស់ព្រះថេរៈតែម្ដង ។ ខណៈនោះឯងភិក្ខុដែលលោកនិម្មិតទាំងអស់ ក៏បាត់អស់ហើយ ។ ព្រះថេរៈ បញ្ជូនបុរសនោះទៅវិញហើយ ដោយពាក្យថា “ចូរអ្នកទៅចុះ” ហើយសំរេចសរីរកិច្ចមានការលាងមុខជាដើមស្រេចហើយ ក៏និមន្តទៅមុន ហើយគង់លើអាសនៈ ដែលបុគ្គលក្រាលហើយ ។

ពាក្យថា “ដូចព្រះចុល្លបន្ថក ដ៏មានអាយុ” លោកពោលហើយសំដៅយករឿងឫទ្ធិនេះ ដោយប្រការដូច្នេះ ។

ភិក្ខុទាំងឡាយនោះឯណា ដែលអ្នកមានឫទ្ធិ និម្មិតហើយ ក្នុងរឿងដែលពោលមកនោះ, ភិក្ខុទាំងនោះ ក៏ដូចគ្នាបេះបិទនឹងភិក្ខុអ្នកមានឫទ្ធិនុ៎ះឯង ព្រោះលោកនិម្មិតហើយមិនកំណត់ ។ ភិក្ខុអ្នកមានឫទ្ធិទាំងឡាយធ្វើនូវកិច្ចណាៗ ក្នុងឥរិយាបថទាំងឡាយ មានឈរ និងអង្គុយជាដើមក្ដី

ក្នុងអាការៈទាំងឡាយ មានការនិយាយស្តី និង ភាពនៅស្ងៀមជាដើមក្តី ភិក្ខុដែលលោកនិម្មិតហើយ ក៏ធ្វើនូវកិរិយានោះៗ ដូចគ្នា ។ ប្រសិនណាបើ ភិក្ខុអ្នកមានឫទ្ធិ ប្រាថ្នាចង់ធ្វើភិក្ខុដែលលោកនិម្មិតហើយទាំងឡាយ ឲ្យមានសម្បុរផ្សេងៗ គ្នា, ពួកខ្លះ ឋិតនៅក្នុងបឋមវ័យ, ពួកខ្លះ ឋិតនៅក្នុងមជ្ឈិមវ័យ, ពួកខ្លះឋិតនៅក្នុងបច្ឆិមវ័យ, ម៉្យាងទៀត ភិក្ខុអ្នកមានឫទ្ធិ ប្រាថ្នាចង់ធ្វើភិក្ខុដែលលោកនិម្មិតហើយទាំងឡាយ ឲ្យមានសក់វែង ឲ្យមានក្បាលត្រងោលមួយចំហៀង ឲ្យមានសក់ស្កូវរបាយ ឲ្យមានចីពរមានពណ៌ក្រហមពាក់កណ្តាល ឲ្យមានចីពរពណ៌លឿង កំពុងធ្វើកិច្ចការផ្សេងៗ គ្នា មានសូធ្យនូវបទ អធិប្បាយធម៌ សូធ្យដោយសំឡេង សួរនូវបញ្ហា ដោះស្រាយនូវបញ្ហា និង អប់បាត្រ ដេរចីពរ ជ្រលក់ចីពរ ជាដើម ឬថា ជាអ្នកប្រាថ្នាចង់ធ្វើភិក្ខុដែលលោកនិម្មិតហើយទាំងឡាយដទៃទៀត ឲ្យមានប្រការផ្សេងៗ, ភិក្ខុអ្នកមានឫទ្ធិនោះ ចេញចាកឈានដែលជាទីតាំងហើយ គប្បីធ្វើបរិកម្ម ដោយន័យថា "ភិក្ខុមានប្រមាណប៉ុណ្ណេះ ចូរជាអ្នកបឋមវ័យ" ដូច្នេះជាដើម ចូលសមាបត្តិម្តងទៀត ចេញហើយ ទើបអធិដ្ឋាន ។ ភិក្ខុដែលលោកនិម្មិតហើយទាំងឡាយនោះ ក៏នឹងបានដូចជាលោកអ្នកមានឫទ្ធិប្រាថ្នាហើយគ្រប់ប្រការ ជាមួយនឹងអធិដ្ឋានចិត្តយ៉ាងនោះឯង ។ ន័យ ក្នុងបទទាំងឡាយមានបទថា "សូម្បីមានរូបច្រើនក៏រួមមកតែរូបមួយវិញបាន" ដូច្នេះជាដើម ក៏ន័យនេះដែរ ។ ក៏ប៉ុន្តែន័យវិសេស មានដូចតទៅនេះ ។

(ឯកភាវបាដិហារ្យ)

ភិក្ខុនេះ លុះនិម្មិត ឲ្យទៅជាមនុស្សច្រើននាក់ យ៉ាងនេះហើយ គិតថា "សូមឲ្យអាត្មាអញ មានរូបតែមួយវិញ ម្តងទៀត នឹងចង្ក្រម នឹងធ្វើ

នូវការស្វាធ្យាយ នឹងសួរនូវបញ្ហា" ដូច្នេះក្តី ហើយគិត ដោយសេចក្តីប្រាថ្នាតិច ថា "វិហារនេះ មានភិក្ខុតិច, បើបុគ្គលពួកខ្លះ នឹងមក នឹងនឹកថា: ភិក្ខុទាំងឡាយនេះ មានចំនួនប៉ុណ្ណេះ តែប្រាកដស្មើដោយភិក្ខុមួយរូប នឹងមានមកពីណា, នេះជាអានុភាពនៃព្រះថេរៈដោយពិត ដូច្នេះហើយ នឹងដឹងនូវអាត្មាអញ" ដូច្នេះក្តី ហើយប្រាថ្នាថា "អាត្មាអញ ជាបុគ្គលម្នាក់ ក្នុងចន្លោះមែនពិត" ដូច្នេះ គប្បីចូលឈាន ដែលជាទីតាំងចេញហើយ ធ្វើនូវបរិកម្មថា "សូមឲ្យអាត្មាអញមានរូបតែមួយ" ដូច្នេះហើយ ចូលឈានម្តងទៀត ចេញហើយគប្បីអធិដ្ឋានថា "សូម្បីឲ្យអាត្មាអញមានរូបតែមួយ" ។ ភិក្ខុនោះក៏មានរូបតែមួយ ជាមួយគ្នានឹងអធិដ្ឋានចិត្តហ្នឹងឯង ។ តែភិក្ខុនោះ កាលមិនធ្វើយ៉ាងនេះ ខ្លួនឯង ក៏ជាបុគ្គលតែម្នាក់មែនពិត ដោយអំណាចនៃកាលដែលខ្លួនកំណត់ហើយយ៉ាងណា ។

(អាវិភាវបាដិហារ្យ តិរោភាវបាដិហារ្យ)

(២៤២) ក្នុងពាក្យថា "អាវិភាវំ តិរោភាវំ" នេះ គប្បីជ្រាបសេចក្តីនេះថា "ភិក្ខុអ្នកមានឫទ្ធិ ធ្វើឲ្យមានភាពក្នុងទីស្រឡះ ធ្វើឲ្យមានភាពក្នុងទីខាងក្រៅ" ។ មែនពិត ព្រះសារីបុត្រ សំដៅយកការធ្វើនូវអាវិភាវៈ និង តិរោភាវៈនេះឯង ទើបពោលក្នុងបដិសម្ភិទា ថា "បទថា អាវិភាវំ សេចក្តីថា (ធ្វើឲ្យ) ជាទីដែលវត្ថុអ្វីមួយមិនរាំង មិនបិទបាំង ជាទីវាលជាទីច្បាស់លាស់ ។ បទថា តិរោភាវំ សេចក្តីថា (ធ្វើឲ្យ)ជាទីដែលមានវត្ថុអ្វីមួយរាំង បាំង បិទ គ្របហើយ [១] " ដូច្នេះ ។

(អាវិភាវបាដិហារ្យ)

ក្នុងបាដិហារ្យពីរនោះ ភិក្ខុអ្នកមានឫទ្ធិនេះ មានបំណងចង់ធ្វើ នូវ

១- សុ. ខុ. គាតទី ៧១ ទំព័រទី ២៧០ ។

អាវិការបាដិហារ្យ ធ្វើនូវទីងងឹតឲ្យមានពន្លឺក្តី ធ្វើនូវទីកំបាំងឲ្យជាទីវាលក្តី ធ្វើនូវទីមិនមានវង្វង់ ឲ្យជាទីមានវង្វង់ក្តី ។ តើធ្វើយ៉ាងដូចម្តេច ? ។ មែនពិត ភិក្ខុអ្នកមានឫទ្ធិនេះ ប្រាថ្នាដើម្បីនឹងធ្វើនូវខ្លួន ឬ នូវបុគ្គលដទៃ ដោយប្រការដែលខ្លួន ឬ បុគ្គលដទៃ សូម្បីត្រូវបិទបាំងហើយក្តី សូម្បីឋិតនៅហើយ ក្នុងទីឆ្ងាយក្តី ក៏មើលឃើញបានដែរ ចេញពីឈានដែលជាទីតាំងហើយ ពិចារណា ធ្វើបរិកម្ម ថា "ទីងងឹតនេះ ចូរក្លាយទៅជាទីមានពន្លឺ" ដូច្នេះផង ថា "ទីកំបាំងនេះ ចូរក្លាយទៅជាទីវាល" ដូច្នេះផង ថា "ទីមិនមានវង្វង់នេះ ចូរក្លាយទៅជាទីមានវង្វង់" ដូច្នេះផង ហើយទើបអធិដ្ឋាន តាមន័យដែលលោកពោលហើយហ្នឹងឯង ។ ព្រមជាមួយនឹងអធិដ្ឋានចិត្ត ការអធិដ្ឋាន ក៏បានសំរេច ដូចដែលលោកបានអធិដ្ឋានហើយតែម្តង ។ ជនទាំងឡាយអ្នកដទៃ សូម្បីឋិតនៅហើយ ក្នុងទីឆ្ងាយ ក៏មើលឃើញបាន ។ សូម្បីខ្លួនឯង ប្រាថ្នាចង់ឃើញ ក៏ឃើញបានដែរ ។

សួរថា " ចុះបាដិហារ្យនេះ អ្នកណាធ្លាប់ធ្វើហើយ? " ។ ឆ្លើយថា "ព្រះមានព្រះភាគ ធ្លាប់ធ្វើហើយ" ។ មែនពិត ព្រះដ៏មានព្រះភាគ ត្រូវនាងចុល្លសុភទ្ទា ទូលនិមន្តហើយ កាលស្តេចយាងទៅកាន់ក្រុងសាកេត អស់រយៈផ្លូវ ៧ យោជន៍ អំពីទីក្រុងសាវត្ថី ដោយផ្ទះកំពូល៥០០ ដែលវិស្សកម្មទេវបុត្រនិម្មិតថ្វាយ ទ្រង់អធិដ្ឋានហើយ ដូចដែលពួកជនអ្នកនៅក្នុងក្រុងសាកេត មើលឃើញ នូវពួកជនអ្នកនៅក្នុងក្រុងសាវត្ថីបាន និងដូចដែលពួកជនអ្នកនៅក្នុងក្រុងសាវត្ថី មើលឃើញ នូវពួកជនអ្នកនៅក្នុងក្រុងសាកេតបាន យ៉ាងនោះឯង ។ ព្រះមានព្រះភាគ ទ្រង់យាងចុះត្រង់កណ្តាលនគរតែម្តង ហើយទ្រង់សំដែង ទំលាយនូវផែនដី ជាពីរចំណែក រហូតទល់អវិចីនរក និង ទ្រង់វែកបង្ហាញ នូវអាកាស ជាពីរ

ចំណែក រហូតដល់ព្រហ្មលោក ។ ក៏សេចក្តីនេះ បណ្ឌិតគប្បីសំដែងឲ្យជាក់ច្បាស់ ដោយកាលជាទីយាងចុះចាកទេវលោក ។

បានឮមកថា ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវយមកបាដិហារ្យហើយ ទ្រង់ដោះនូវពួកសត្វចំនួន ៨៤,០០០ ចេញពីចំណងហើយ ទ្រង់រំពឹងថា "ក្នុងកាលជាទីបំផុតនៃយមកបាដិហារ្យ អតីតពុទ្ធទាំងឡាយ ទ្រង់ស្តេចយាងទៅក្នុងទីណា" ដូច្នេះហើយ ទ្រង់បានទតឃើញថា "អតីតពុទ្ធទាំងឡាយ ទ្រង់ស្តេចយាងទៅកាន់តាវតិង្សពិភព" ។ គ្រានោះ សម្តេចព្រះដ៏មានព្រះភាគ ទ្រង់ជាន់ផ្ទៃផែនដី ដោយព្រះបាទម្ខាង ព្រះបាទទីពីរ ទ្រង់ប្រតិស្ឋានលើភ្នំយុគន្ធរ ទ្រង់លើកព្រះបាទមុនម្តងទៀត ហើយទ្រង់ជាន់កំពូលភ្នំសិនេរុ ទ្រង់យាងចូលទៅចាំព្រះវស្សា លើផ្ទៃនៃថ្មមណ្ឌុកម្ពលក្នុងភពតាវតិង្សនោះ ទ្រង់ប្រារព្ធសំដែងអភិធម្មកថា ដល់ពួកទេវតាមួយសែនចក្រវាឡ ដែលមកប្រជុំគ្នាហើយ ចាប់ផ្តើមអំពីដើម ហើយទ្រង់និម្មិតនូវពុទ្ធនិម្មិត ។ ពុទ្ធនិម្មិតនោះ សំដែងព្រះធម៌ (ជំនួសព្រះអង្គ) ។ ព្រះមានព្រះភាគ ទ្រង់សោយឈើស្ទន់ជាវិការៈនៃវល្លិម្លូព្រៃ ទ្រង់ស្រប់ព្រះភក្ត្រ ក្នុងអនោតត្តស្រះ ទ្រង់ទទួលនូវបិណ្ឌបាត ក្នុងពួកជនអ្នកនៅក្នុងឧត្តរកុរុទ្វីប ទ្រង់សោយចង្ហាន់ នៅក្បែរឆ្នេរអនោតត្តស្រះ ។ ព្រះសារីបុត្តត្ថេរ និមន្តទៅថ្វាយបង្គំព្រះមានព្រះភាគ ក្នុងទីនោះ ។ ព្រះមានព្រះភាគ ទ្រង់ប្រទាននូវន័យ ដល់ព្រះថេរៈ ថា "នៅក្នុងថ្ងៃនេះ តថាគតសំដែងនូវព្រះធម៌ មានប្រមាណប៉ុណ្ណេះហើយ" ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដែង នូវអភិធម្មកថា មិនដាច់រយៈ រហូត ៣ ខែ យ៉ាងនេះឯង ។ ពួកទេវតា ៨០ កោដិ បានត្រាស់ដឹងធម៌ ព្រោះស្តាប់អភិធម្មកថានោះ ។ ចំណែកពួកបរិស័ទ ប្រមាណ ១២ យោជន៍ ដែលមកប្រជុំគ្នាហើយ ក្នុង

ថ្ងៃសំដែងយមកប្បាដិហារ្យ បានគិតគ្នា ថា “ពួកយើង នឹងជួបនូវព្រះមានព្រះភាគ ជាមុនសិនហើយសឹមទៅ” ដូច្នេះហើយ ក៏បានបោះជំរំបិតនៅហើយ ។ ឯចុល្លអនាថបិណ្ឌិកសេដ្ឋីវិញ បានបំរើពួកជននោះដោយបច្ច័យគ្រប់បែបយ៉ាង ។

មនុស្សទាំងឡាយ បានអង្វរនូវព្រះអនុរុទ្ធត្ថេរ ដើម្បីឲ្យបានដឹងថា “ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីណា” ។ ព្រះថេរៈ ចំរើនអាលោក-កសិណ បានឃើញព្រះមានព្រះភាគដែលចូលទៅគង់ចាំព្រះវស្សា ក្នុងភពតាវតិង្សនោះ ដោយទិព្វចក្ខុ លុះឃើញហើយ ក៏បានប្រាប់ហើយ ។ ពួកមនុស្សទាំងនោះ អង្វរព្រះមហាមោគ្គល្លានត្ថេរ ដើម្បីប្រយោជន៍ដល់ការថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ ។ ព្រះថេរៈ មុជជ្រែកមហាប្រឹថពីត្រង់កណ្ដាលនៃបរិស័ទហ្នឹងឯង ជ្រែកនូវភ្នំសិនេរុ ក្រាបថ្វាយបង្គំ នូវព្រះបាទទាំងឡាយនៃព្រះមានព្រះភាគ ហើយងើប ទៀបបាទមូលនៃព្រះតថាគត ហើយក្រាបទូលពាក្យនេះ នឹងព្រះមានព្រះភាគថា “បពិត្រព្រះអង្គដ៏ចំរើន ពួកជនអ្នកនៅក្នុងជម្ពូទ្វីប ថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគ និយាយគ្នាថា ពួកយើងខ្ញុំ បានឃើញហើយពិត ក៏នឹងទៅវិញ” ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “ម្នាលមោគ្គល្លាន ឥឡូវនេះតើព្រះធម្មសេនាបតី បងប្រុសរបស់អ្នក នៅក្នុងទីណា ?” ។ ព្រះមហាមោគ្គល្លានក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន នៅក្នុងសង្កស្សនគរ” ។ ព្រះអង្គទ្រង់ត្រាស់ថា “ម្នាលមោគ្គល្លាន ជនទាំងឡាយណា ចង់ឃើញតថាគត ជនទាំងនោះ ចូរមកកាន់សង្កស្សនគរ ក្នុងថ្ងៃស្អែក, តថាគតនឹងចុះក្នុងសង្កស្សនគរ ក្នុងថ្ងៃស្អែក ក្នុងថ្ងៃជាទីពេញនៃមហាបវារណា និង ថ្ងៃឧបោសថ ” ។ ព្រះថេរៈ ក្រាបទូលថា “ប្រពៃហើយ ព្រះអង្គ”

ថ្វាយបង្គំនូវព្រះទសពលហើយ ចុះមកតាមផ្លូវដែលលោកនិមន្តមកហ្នឹងឯង បានដល់សំណាក់ នៃមនុស្សទាំងឡាយហើយ ។ ក្នុងកាលជាទីទៅនិង កាលជាទីមកនោះឯង ព្រះថេរៈ បានអធិដ្ឋានឲ្យល្មមតែមនុស្សទាំងឡាយឃើញនូវលោកបាន ។ ព្រះមហាមោគ្គល្លានត្ថេរ បានធ្វើបាដិហារ្យដែលមានភាពប្រាកដនេះ ក្នុងទីនេះមុន ។ ព្រះថេរៈនោះ និមន្តមកហើយយ៉ាងនេះ បានប្រាប់នូវដំណឹងនោះ ហើយពោលថា “អ្នកទាំងឡាយកុំធ្វើសេចក្ដីសំគាល់ថា ឆ្ងាយអ្វី លុះទទួលទានបាយព្រឹករួចហើយ ចូរចេញទៅ” ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់ស្ដេចទេវតា ព្រះនាមសក្កៈ ថា “បពិត្រមហារាជ ក្នុងថ្ងៃស្អែក តថាគត នឹងទៅកាន់មនុស្សលោក” ។ ស្ដេចទេវតា ត្រាស់បង្គាប់វិស្សកម្មទេវបុត្រថា “នែបា ក្នុងថ្ងៃស្អែក ព្រះដ៏មានព្រះភាគ ស្ដេចប្រាថ្នាយាងទៅកាន់មនុស្សលោក ចូរអ្នកនិម្មិត នូវរបៀបនៃជណ្ដើរទាំងឡាយ ៣ គឺៈ ជណ្ដើរមួយជាមាស ជណ្ដើរមួយជាប្រាក់ ជណ្ដើរមួយជាកែវមណី” ។ វិស្សកម្មទេវបុត្រនោះ បានធ្វើតាមព្រះតម្រាស់ហើយ ។

ក្នុងថ្ងៃទីពីរ ព្រះមានព្រះភាគ ទ្រង់គង់នៅលើកំពូលភ្នំសិនេរុ ទ្រង់ទតព្រះនេត្រមើលនូវលោកធាតុ ក្នុងទិសខាងកើត ។ សែននៃចក្រវាឡទាំងឡាយ មិនតែមួយ ជាទីស្រឡះ ប្រាកដហើយ ហាក់បីដូចជាទីលានតែមួយ ។ ក៏ព្រះមានព្រះភាគ ទ្រង់ទតព្រះនេត្រឃើញនូវទីស្រឡះទាំងអស់ ដោយទិសខាងកើត យ៉ាងណាមិញ, សូម្បីដោយទិសខាងលិច ទិសខាងជើង ទិសខាងត្បូង ក៏ទ្រង់ទតព្រះនេត្រឃើញនូវទីស្រឡះ ទាំងអស់យ៉ាងដូច្នោះដែរ ។ សូម្បីទិសខាងក្រោម ក៏ទ្រង់ទតព្រះនេត្រឃើញ

រហូតដល់អវិចីនរក ទិសខាងលើ រហូតដល់អកនិដ្ឋភពន៍ ។ បានឮថា ថ្ងៃនោះ បានឈ្មោះថា ជាថ្ងៃបើកលោក ។ ឯមនុស្សទាំងឡាយ ឃើញនូវទេវតាទាំងឡាយ, ឯទេវតាទាំងឡាយ ក៏ឃើញនូវពួកមនុស្សដែរ ។ ក្នុងការឃើញគ្នានោះ មនុស្សទាំងឡាយ មិនបាច់ងើយមើលមក ខាងលើទេ ទេវតាទាំងឡាយ ក៏មិនបាច់ឱនមើលមកខាងក្រោមដែរ ទាំងអស់គ្នា មើលឃើញគ្នាទៅវិញទៅមក ចំពោះមុខតែម្តង ។

ព្រះមានព្រះភាគ ទ្រង់យាងចុះ តាមជណ្តើរ ជាវិការៈនៃកែវមណី ត្រង់កណ្តាល, ពួកទេវតាជាន់កាមាវចរសួគ៌ទាំង ៦ ចុះតាមជណ្តើរ ជាវិការៈនៃមាស ត្រង់ខាងឆ្វេង, សុទ្ធាវាសព្រហ្មទាំងឡាយ និង មហាព្រហ្មទាំងឡាយ ចុះតាមជណ្តើរ ជាវិការៈនៃប្រាក់ ត្រង់ផ្នែកខាងស្តាំ ។ ស្តេចទេវតា បានកាន់យកនូវបាត្រ និងចីពរ ។ មហាព្រហ្មបានកាន់យកនូវស្វេតច្ឆត្រ ប្រមាណបីយោជន៍ ។ សុយាមទេវបុត្រ បានកាន់យកនូវផ្លិតដែលធ្វើអំពីរោមសត្វ ។ បញ្ចសិខៈ បុត្រគន្ធព បានកាន់យកពិណមានពណ៌លឿង ដូចជាផ្លែព្នៅទុំ ប្រវែង ៣ គាវុត ធ្វើនូវការបូជា ចំពោះព្រះតថាគត ចុះមក ។ ឈ្មោះថា សត្វដែលឃើញ នូវព្រះមានព្រះភាគហើយ មិនញ៉ាំងសេចក្តីប្រាថ្នាឲ្យកើតឡើង ដើម្បីភាពជាព្រះពុទ្ធ មិនមានឡើយ ។ ព្រះមានព្រះភាគ ទ្រង់បានធ្វើនូវបាដិហារ្យ ឲ្យមានភាវៈក្នុងទីស្រឡះនេះហើយ ក្នុងមហាប្រជុំនោះ ។

ម្យ៉ាងទៀត ព្រះធម្មទិន្នត្ថេរ អ្នកនៅក្នុងស្រុកឈ្មោះតឡង្គរ ក្នុងតម្ពបណ្ណិទ្វីប គង់ក្នុងព្រះលាននៃចេតិយ ក្នុងតិស្សមហាវិហារ សំដែងនូវអបណ្ណកសូត្រ ថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបហើយ ដោយធម៌បីយ៉ាង ឈ្មោះថា ជាអ្នកប្រតិបត្តិនូវសេចក្តីប្រតិបត្តិមិនខុស” ដូច្នេះ

ជាដើម បានធ្វើនូវផ្លិត ឲ្យមានមុខចុះក្រោមហើយ ។ ទីនោះ ជាទីលានតែមួយ រហូតដល់អវិចីនរក ។ បន្ទាប់នោះ ព្រះថេរៈ បានធ្វើនូវផ្លិត ឲ្យមានមុខឡើងលើហើយ ។ ទីនោះ បានជាទីលានតែមួយ រហូតដល់ទៅព្រហ្មលោក ។ ព្រះថេរៈ សំដែងនូវធម៌ គំរាម ដោយភ័យក្នុងនរកផង លួងលោម ដោយសេចក្តីសុខក្នុងឋានសួគ៌ផង ។ អ្នកស្តាប់ពួកខ្លះ បានជាព្រះសោតាបន្នបុគ្គល ពួកខ្លះ បានជាព្រះសកទាគាមី ពួកខ្លះ បានជាព្រះអនាគាមី ពួកខ្លះ បានជាព្រះអរហន្ត ដោយប្រការដូច្នេះឯង ។

(តិរោភាវបាដិហារ្យ)

ចំណែកភិក្ខុអ្នកប្រាថ្នាដើម្បីធ្វើនូវបាដិហារ្យឲ្យមានភាពជាខាងក្រៅ រមែងធ្វើនូវទីវាលស្រឡះ ឲ្យជាទីងងឹតខ្លះ ធ្វើនូវវត្ថុដែលមិនកំបាំង ឲ្យជាវត្ថុដែលកំបាំងខ្លះ ធ្វើនូវវត្ថុដែលមានក្នុងវង្វង់ ឲ្យជាវត្ថុដែលមិនមានក្នុងវង្វង់ខ្លះ ។ ធ្វើដោយប្រការដូចម្តេច? ។ ក៏ភិក្ខុអ្នកមានឫទ្ធិនេះ មានបំណងដើម្បីធ្វើនូវខ្លួន ឬ អ្នកដទៃ ដោយប្រការដែលខ្លួន និង អ្នកដទៃមិនមានអ្វីបិទបាំងក្តី ឋិតនៅក្នុងទីជិតក្តី ក៏មើលមិនឃើញដែរ ចេញចាកឈានដែលជាទីតាំងហើយ ក៏នឹករំពឹង ធ្វើបរិកម្មថា “ទីមានពន្លឺនេះ ចូរទៅជាទីងងឹត” ដូច្នេះក្តី ថា “ទីដែលមិនបិទបាំងនេះ ចូរទៅជាទីបិទបាំង” ដូច្នេះក្តី ថា “ទីដែលមានក្នុងវង្វង់នេះ ចូរទៅជាទីមិនមានក្នុងវង្វង់” ដូច្នេះក្តី ហើយអធិដ្ឋាន តាមន័យដែលពោលមកហើយនុ៎ះឯង ។ ព្រមជាមួយនឹងអធិដ្ឋានចិត្ត ការអធិដ្ឋានក៏បានសំរេច ដូចដែលលោកអធិដ្ឋានហើយហ្នឹងឯង ។ ពួកជនដទៃ សូម្បីឈរនៅក្នុងទីជិត ក៏មើលមិនឃើញដែរ ។ ចំណែកខ្លួនឯង មិនមានបំណងដើម្បីឃើញ ក៏មើលមិនឃើញ ។

សួរថា “ចុះតិរោភាវបាដិហារ្យនោះ តើនរណា ធ្លាប់ធ្វើហើយ?” ។

ឆ្លើយថា “ព្រះមានព្រះភាគ” ។ មែនពិត ព្រះមានព្រះភាគ ទ្រង់បានធ្វើនូវយសកុលបុត្រ ដែលគង់ក្នុងទីជិតនោះឯង ដោយប្រការដែលបិតារបស់លោក មើលលោកមិនឃើញ ។ ដូចគ្នានោះដែរ ព្រះមានព្រះភាគទ្រង់ធ្វើ នូវការទទួលព្រះមហាកប្បិនរាជ អស់រយៈផ្លូវ ១២០ យោជន៍ ហើយញ៉ាំងព្រះអង្គឲ្យតាំងនៅស៊ប់ ក្នុងអនាគាមិផលផង ញ៉ាំងអាមាត្យមួយពាន់នាក់ របស់ព្រះអង្គ ឲ្យតាំងនៅស៊ប់ ក្នុងសោតាបត្តិផលផង ហើយទ្រង់ធ្វើឲ្យព្រះនាងអនោជាទេវីព្រមទាំងស្រ្តីជាបរិវារ ១,០០០ នាក់ ដែលយាងមក តាមលំដាប់ផ្លូវ របស់ព្រះមហាកប្បិនរាជនោះ សូម្បីមកដល់ហើយ អង្គុយនៅក្នុងទីជិត ទតមើលមិនឃើញ នូវព្រះរាជា ព្រមទាំងបរិស័ទ, កាលបើព្រះនាងទេវីទូលថា “បពិត្រព្រះអង្គដ៏ចំរើន តើព្រះអង្គទតឃើញព្រះរាជាដែរឬទេ?” ទ្រង់ត្រាស់ថា “តើព្រះនាងស្វែងរកព្រះរាជាប្រសើរជាង ឬក៏ ស្វែងរកខ្លួនប្រសើរជាង?” កាលព្រះនាងទូលថា “បពិត្រព្រះអង្គដ៏ចំរើន ស្វែងរកខ្លួនប្រសើរជាង” ដូច្នេះហើយ ទ្រង់គង់, ទើបទ្រង់សំដែងព្រះធម៌ ដោយប្រការដែល (ចប់ធម៌ទេសនាហើយ) ព្រះនាងទេវីព្រមទាំងស្ត្រី ១,០០០ នាក់ តាំងនៅស៊ប់ហើយក្នុងសោតាបត្តិផល អាមាត្យទាំងឡាយ តាំងនៅស៊ប់ ក្នុងអនាគាមិផល ព្រះរាជា តាំងនៅស៊ប់ ក្នុងព្រះអរហត្ត ។ ន័យមួយទៀត សូម្បីព្រះមហិន្ទត្ថេរ កាលធ្វើឲ្យល្មមតែព្រះរាជា ទតមិនឃើញនូវជនដ៏សេសទាំងឡាយ ដែលមកជាមួយនឹងព្រះអង្គ ក្នុងថ្ងៃដែលមកដល់តម្ពបណ្ណិទ្វីបហើយ ក៏ឈ្មោះថា បានធ្វើតិរោភាវបាដិហារិយ៍នេះ ដូចគ្នាដែរ ។

ម្យ៉ាងវិញទៀត បាដិហារិយ៍ ដែលប្រាកដទាំងអស់ ឈ្មោះថាអាវិភាវបាដិហារិយ៍ (បាដិហារិយ៍ក្នុងទីវាល) ។ បាដិហារិយ៍ ដែលមិនប្រាកដ ឈ្មោះថា តិរោភាវបាដិហារិយ៍ (បាដិហារិយ៍ក្នុងទីខាងក្រៅ) ។ ក្នុងចំណោមបាដិហារិយ៍ទាំង ២ នោះ ឫទ្ធិផង បុគ្គលអ្នកមានឫទ្ធិផង រមែងប្រាកដមែនពិត ក្នុងបាកដប្បាដិហារិយ៍ ។ បាកដប្បាដិហារិយ៍នោះ គប្បីសំដែង ដោយយមកប្បាដិហារិយ៍ ។ មែនពិត ក្នុងយមកប្បាដិ-ហារិយ៍នោះ ព្រះតថាគត ទ្រង់ធ្វើនូវយមកប្បាដិហារិយ៍ ក្នុងទីនេះ មិនទូទៅ ដោយសាវ័កទាំងឡាយទេ ។ បាដិហារិយ៍ទាំង ២ ប្រាកដហើយយ៉ាងនេះគឺ: គំនរភ្លើង ប្រព្រឹត្តទៅអំពីព្រះកាយខាងលើ ទ-ទឹក ប្រព្រឹត្តទៅ អំពីព្រះកាយខាងក្រោម ។

ឫទ្ធិតែម្យ៉ាង រមែងប្រាកដ ក្នុងអបាកដប្បាដិហារិយ៍, បុគ្គលអ្នកមានឫទ្ធិ មិនប្រាកដទេ ។ អបាកដប្បាដិហារិយ៍នោះ គប្បីសំដែង ដោយមហាកសូត្រ និង ព្រហ្មនិមន្តនិកសូត្រ ។ មែនពិត ក្នុងបាដិហារិយ៍ដែលពោលក្នុងសូត្រទាំងពីរនោះ ឫទ្ធិតែម្យ៉ាង របស់ព្រះមហាកៈដ៏មានអាយុ និង របស់ព្រះមានព្រះភាគ រមែងប្រាកដ, បុគ្គលអ្នកមានឫទ្ធិ រមែងមិនប្រាកដទេ ។ សមដូចជាលោកពោលថា “លុះចិត្តគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលទៅនឹងព្រះមហាកៈ ដ៏មានអាយុ ដូច្នេះថា បពិត្រលោកដ៏ចំរើន សូមព្រះមហាកៈជាម្ចាស់ សំដែងនូវឥទ្ធិបាដិហារ្យជាធម៌របស់មនុស្សដ៏លើសលុប ដល់ខ្ញុំករុណាឲ្យទាន ។ ព្រះមហាកៈពោលថា ម្នាលគហបតី បើដូច្នោះ ចូរអ្នកក្រាលសំពត់ឧត្តរាសង្គ គ្របលើបាច់ស្មៅ ឰដ៏របៀង ។ ចិត្តគហបតី ទទួលពាក្យរបស់ព្រះមហាកៈដ៏មានអាយុថា ព្រះករុណា លោកម្ចាស់ ហើយក៏ក្រាលសំពត់ឧត្តរាសង្គគ្របលើបាច់ស្មៅ ឰដ៏របៀង ។ លំដាប់នោះ ព្រះមហាកៈដ៏មានអាយុចូលទៅកាន់វិហារ ចាក់គន្លឹះទ្វារហើយ ក៏តាក់តែងនូវឥទ្ធាភិសង្ខារ មាន

សភាពដូច្នោះ បណ្តាលឲ្យមានអណ្តាតភ្លើង ចេញទៅតាមប្រហោងកូនសោផង តាមចន្លោះទ្វារផង ឆេះនូវស្មៅទាំងឡាយ តែមិនឆេះនូវឧត្តរាសង្គឡើយ [១] " ។

សូត្រមួយទៀតថា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតនិម្មិតនូវឥទ្ធាភិសង្ខារមានសភាពដូច្នោះ ថា ព្រហ្ម និង ព្រហ្មបរិស័ទ ព្រមទាំងព្រហ្មបារិសជ្ជា ឲ្យឮតែសំឡេងរបស់តថាគតប៉ុណ្ណោះ តែមិនបានឃើញនូវតថាគតឡើយ" ដូច្នេះហើយ ទ្រង់បាត់ព្រះអង្គទៅហើយ ទ្រង់បានត្រាស់នូវព្រះគាថានេះ ថា :

តថាគតឃើញភ័យក្នុងភពផង ឃើញនូវពួកសត្វដែលកំពុង
ស្វែងរកនូវភពផង ហើយមិនបានពោលសរសើរ គឺមិន
ស្វែងរកភពណាមួយ ទាំងមិនប្រកាន់ នូវសេចក្តីត្រេកអរ
(ក្នុងភព) ឡើយ [២] " ។

(ដើរទំលុះវត្ថុបិទបាំងមានជញ្ជាំងជាដើមបាន)

(២៤៣) បណ្ឌិត គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងបាដិហារ្យនេះ ថា "បុគ្គលអ្នកមានឫទ្ធិ ដើរ (ទំលុះ) ទៅកាន់ទីក្រៅជញ្ជាំង ទីក្រៅកំពែង ទីក្រៅភ្នំ មិនទើសទាក់ ដូចគេដើរក្នុងអាកាស" ដូចតទៅនេះ ។

បទថា "តិរោកុឌ្ឌំ" ប្រែថា ខាងក្រៅជញ្ជាំង ។ អធិប្បាយថា ចំណែកខាងក្រៅនៃជញ្ជាំង ។ ក្នុងបទទាំងឡាយឯទៀតក៏ន័យនេះដែរ ។ ឯពាក្យថា "ជញ្ជាំង" នេះ គឺជាឈ្មោះនៃជញ្ជាំងផ្ទះ ។ បទថា "កំពែង" គឺកំពែងជុំវិញនៃទីទាំងឡាយមានផ្ទះ វិហារ និងស្រុកជាដើម ។ បទថា "ភ្នំ" បានដល់ ភ្នំដែលសុទ្ធតែអាចម៍ដី ឬ ភ្នំដែលសុទ្ធតែថ្ម ។ បទថា

១- សុ. សំ. គាគទី៣៦ ទំព័រទី ១៩៣ ។ ២-សុ. ភាគទី២២ ទំព័រទី ៣៧៣ ។

"មិនទើសទាក់" ប្រែថា មិនជាប់ជំពាក់ ។ ពាក្យថា "សេយ្យថាបិ អាកាសេ" ប្រែថា ដូចជាទៅ ឰដ៏អាកាស ។

បើភិក្ខុអ្នកមានឫទ្ធិ ប្រាថ្នាចង់ទៅយ៉ាងនេះ ចូលអាកាសកសិណចេញហើយ ពិចារណានឹកទៅជញ្ជាំង ឬ កំពែង ឬក៏ ក្នុងចំណោមភ្នំសិនេរុ និង ភ្នំចក្រវាឡ ភ្នំណាមួយក៏បាន ធ្វើបរិកម្មហើយ គប្បីអធិដ្ឋានថា "សូមឲ្យប្រទេសនុ៎ះទៅជាអាកាស" ។ ទីនោះ ក៏ក្លាយទៅជាអាកាសភ្លាម ។ កាលបើអ្នកមានឫទ្ធិ ប្រាថ្នាចង់ចុះទៅខាងក្រោមក្តី ប្រាថ្នាចង់ឡើងទៅខាងលើក្តី ក៏មានប្រហោង (បើកឲ្យ) ។ សំរាប់អ្នកមានឫទ្ធិ ប្រាថ្នាចង់ទំលុះហើយទៅ តែងមានប្រហោង ។ អ្នកមានឫទ្ធិនោះ ទៅក្នុងប្រហោងនោះ មិនទើសទាក់ឡើយ ។

ចំណែកព្រះតិបិដកចូឡាភយត្ថេរ ពោលហើយក្នុងការធ្វើបាដិហារ្យនេះថា "ម្នាលអាវុសោទាំងឡាយ ការចូលអាកាសកសិណ មានអ្វីជាប្រយោជន៍ (មានអ្វីជាអានិសង្ស) បុគ្គលអ្នកមានឫទ្ធិ ប្រាថ្នាដើម្បីនិម្មិតនូវរូបផ្សេងៗ មានរូបដំរី និង សេះជាដើម ក៏ចូលកសិណមានដំរី និង សេះជាដើម ក្រែងភារៈជាអ្នកស្ទាត់ជំនាញ ក្នុងសមាបត្តិ ៨ ព្រោះធ្វើនូវបរិកម្ម ក្នុងកសិណណាមួយនោះឯង ជាប្រមាណ, អ្នកស្ទាត់ជំនាញក្នុងសមាបត្តិ ៨ ប្រាថ្នាវត្ថុអ្វីៗ វត្ថុនោះៗ ក៏សំរេចឯងមិនមែនទេឬ? " ។ ភិក្ខុទាំងឡាយ ពោលថា "បពិត្រលោកដ៏ចំរើន អាកាសកសិណហ្នឹងឯង មកហើយក្នុងបាលី ព្រោះហេតុនោះ ការចូលអាកាសកសិណនោះ គប្បីពោលដោយពិត" ។ នេះជាបាលី ក្នុងអាកាសកសិណនោះថា :

"ភិក្ខុអ្នកបាននូវសមាបត្តិ មានអាកាសកសិណជាអារម្មណ៍ ដោយប្រក្រតី តែងនឹកចង់ទៅកាន់ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាង

ក្រៅភ្នំ លុះនឹកចង់ហើយ ក៏អធិដ្ឋានដោយញាណថា សូមឲ្យប្រទេសនុ៎ះទៅជាអាកាស” ដូច្នេះ, ទីនោះ ក៏បានទៅជាអាកាស, ភិក្ខុនោះ ក៏ដើរ (ទំលុះ) ទៅកាន់ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ មិនទើសទាក់ ដូចពួកមនុស្សដែលមិនមានឫទ្ធិ ដោយប្រក្រតី កាលដើរទៅមិនជាប់ជំពាក់ ក្នុងទីដែលមិនមានវត្ថុអ្វីមួយ រាំង បិទបាំងឡើយ, ឯភិក្ខុដែលមានឫទ្ធិ ដល់ហើយ នូវការស្ទាត់ជំនាញ ក្នុងចិត្តនោះ តែងដើរ (ទំលុះ) ទៅកាន់ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ មិនទើសទាក់ ដូចជាគេដើរទៅ ក្នុងអាកាស យ៉ាងនោះឯង [១] ” ។

សួរថា “ប្រសិនបើភិក្ខុនោះ អធិដ្ឋានហើយ កំពុងតែដើរទៅ, ភ្នំក្តី ដើមឈើក្តី ផុសឡើងក្នុងចន្លោះ, ភិក្ខុគប្បីចូលហើយ អធិដ្ឋានម្តងទៀតឬ?” ។ ឆ្លើយថា “មិនមានទោសទេ” ។ ព្រោះថា ការចូលសមាបត្តិហើយអធិដ្ឋានម្តងទៀត ជាការចូលប្រហែលគ្នានឹងការទទួលនូវនិស្ស័យក្នុងសំណាក់នៃព្រះឧបជ្ឈាយ៍ ។ ក៏ព្រោះភាវៈនៃភ្នំនោះ ភិក្ខុនេះអធិដ្ឋានហើយថា “ភ្នំចូរទៅជាអាកាស” ដូច្នេះ ភ្នំក៏បានទៅជាអាកាសហ្នឹងឯង ។ ក៏ពាក្យដែលថា “ភ្នំ ឬ ដើមឈើ ដទៃទៀត ដែលសំរេចអំពីរដូវ នឹងផុះឡើងក្នុងចន្លោះ ដោយកំឡាំងនៃការអធិដ្ឋាន ក្នុងខាងដើម របស់ភិក្ខុនោះឯង” ដូច្នេះនេះ មិនមែនជាហេតុជាទីតាំងទេ ។ ការនិម្មិតដំបូងដែលអ្នកមានឫទ្ធិណាមួយនិម្មិតហើយ ជានិម្មិតដ៏មានកំឡាំង ។ ការនិម្មិតខាងក្រោយ គប្បីទៅឰដ៏ខាងលើ ឬ ខាងក្រោម នៃទីមានភ្នំជាដើមនោះ ។

(ងើប និង មុជក្នុងផែនដីបាន)

បណ្ឌិត គប្បីជ្រាបសេចក្តី ក្នុងបាដិហារ្យថា “ការងើបឡើង និង

១- សុ. ខុ. បដិ. គាគទី ៧១ ទំព័រទី ២៧០ ។

ការមុជចុះទៅក្នុងផែនដីក៏បាន” នេះដូចតទៅ ។ ការក្រោកឡើង លោកហៅថា ការងើបឡើង ។ ការលិចចុះ លោកហៅថាការមុជចុះ ។ ការងើបឡើងផង ការមុជចុះផង ឈ្មោះថា ការងើបឡើង និង ការមុជចុះ ។ ភិក្ខុអ្នកប្រាថ្នាដើម្បីនឹងធ្វើយ៉ាងនេះ ចូលអាបោកសិណហើយចេញ គប្បីធ្វើបរិកម្មកំណត់ថា “ផែនដី ក្នុងទីមានប្រមាណប៉ុណ្ណោះ ចូរទៅជាទឹកចុះ” ហើយ គប្បីអធិដ្ឋាន តាមន័យដែលបានពោលហើយហ្នឹងឯង ។ ជាមួយនឹងការអធិដ្ឋាន ដីក្នុងទីដែលលោកកំណត់ហើយយ៉ាងណា ក៏បានទៅជាទឹកវិញ ។ ភិក្ខុនោះធ្វើនូវការងើបឡើងនិងការមុជចុះក្នុងដីនោះបាន ។

បាលី ក្នុងអាបោកសិណនោះដូច្នេះថា “ភិក្ខុដែលបាននូវសមាបត្តិមានអាបោកសិណជាអារម្មណ៍ ដោយប្រក្រតី តែងនឹកចង់ដេក ក្នុងដីលុះនឹកហើយ ក៏អធិដ្ឋាន ដោយញាណថា “សូមឲ្យ(ផែនដីត្រង់នេះ) ទៅជាទឹក” ដូច្នេះ, ទីនោះ ក៏បានទៅជាទឹក, ភិក្ខុនោះ ក៏ធ្វើនូវការងើបមុជក្នុងផែនដី ដូចពួកមនុស្សដែលមិនមានឫទ្ធិ ដោយប្រក្រតី ធ្វើនូវការងើបមុចក្នុងទឹក, ឯភិក្ខុដែលមានឫទ្ធិ ដល់ហើយនូវការស្ទាត់ជំនាញ ក្នុងចិត្តនោះ តែងធ្វើនូវការងើបមុជ ក្នុងផែនដី ដូចជាគេងើបមុជក្នុងទឹកបាន ក៏យ៉ាងនោះឯង” ។

មួយទៀត មិនមែនគ្រាន់តែការងើបឡើង និង មុជចុះ ប៉ុណ្ណោះទេ, បុគ្គលអ្នកមានឫទ្ធិ ប្រាថ្នានូវកិច្ចណាៗ ក្នុងកិច្ចទាំងឡាយមានទឹកសំរាប់ងូត សំរាប់លុបមុខ សំរាប់បោកគក់ នូវភណ្ឌៈជាដើម ក៏ធ្វើនូវកិច្ចនោះៗ បាន ។ ម្យ៉ាងទៀត មិនមែនត្រឹមតែទឹកប៉ុណ្ណោះទេ កាលបើភិក្ខុអ្នកមានឫទ្ធិ ប្រាថ្នានូវវត្ថុណាៗ សូម្បីក្នុងវត្ថុទាំងឡាយ មានទឹកដោះថ្លាប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើម ក៏នឹកពិចារណានូវវត្ថុនោះៗ ហើយ

ធ្វើបរិកម្មថា "វត្ថុនេះផងៗ ចូរទៅជាវត្ថុមានប្រមាណប៉ុណ្ណេះចុះ" ដូច្នេះហើយអធិដ្ឋាន, វត្ថុនោះ ក៏បានដូចដែលលោកអធិដ្ឋានហើយហ្នឹងឯង ។ កាលភិក្ខុអ្នកមានឫទ្ធិ ដកចេញហើយ ធ្វើឲ្យទៅជាភាជន៍, ទឹកដោះថ្លា ក៏រមែងទៅជាទឹកដោះថ្លាមែនពិត, វត្ថុទាំងឡាយ មានប្រេងជាដើម រមែងជាវត្ថុមានប្រេងជាដើមមែនពិត, ទឹក ក៏រមែងជាទឹកមែនពិត ។ ក្នុងទឹកនោះ ភិក្ខុអ្នកមានឫទ្ធិនោះ ប្រាថ្នាចង់ទទឹកនោះឯង ទើបទទឹក, មិនប្រាថ្នាចង់ឲ្យទទឹក ក៏មិនទទឹកដែរ ។ មួយទៀត ផែនដីនោះ ជាទឹកសំរាប់ភិក្ខុអ្នកមានឫទ្ធិតែប៉ុណ្ណោះ ។ ជាផែនដីសំរាប់ជនដ៏សេសដដែល ។ ក្នុងផែនដីត្រង់នោះ ពួកមនុស្សសូម្បីជាអ្នកថ្មើរជើង ក៏ដើរទៅបាន តែងដើរទៅ ដោយវាហនៈទាំងឡាយមានយានជាដើមក៏បាន តែងធ្វើនូវកម្មទាំងឡាយ មានកសិកម្មជាដើមក៏បានមែនពិត ។ ប្រសិនណាបើ អ្នកមានឫទ្ធិនេះ ប្រាថ្នាថា "(ដីត្រង់នោះ) ចូរជាទឹក សំរាប់មនុស្សទាំងឡាយនោះផងចុះ" ដូច្នេះ, ក៏ទៅជាទឹកមែនពិត ។ ចំណែកឯ ទីដែលលោកកំណត់ហើយដ៏សេស លើកលែងតែទឹក ក្នុងទីទាំងឡាយ មានក្អម និងត្រពាំងជាដើមដែលមាននៅតាមប្រក្រតី ព្រោះកន្លងនូវកាលដែលលោកកំណត់ហើយ រមែងជាដីដដែល ។

(ដើរលើទឹកមិនបែកធ្លាយបាន)

(២៨៤) ក្នុងបាដិហារ្យនេះថា "ដើរលើទឹកមិនបែកធ្លាយបាន" នេះ មានសេចក្តីអធិប្បាយថា : បុគ្គលជាន់លិចហើយនូវទឹកណា, ទឹកនោះលោកហៅថា ទឹកបែក ។ ទឹកផ្ទុយអំពីនេះ ឈ្មោះថាទឹកមិនបែក ។ បើភិក្ខុអ្នកមានឫទ្ធិ ប្រាថ្នាដើម្បីដើរទៅយ៉ាងនេះ ចូលបឋវីកសិណ ចេញហើយធ្វើនូវបរិកម្មកំណត់ថា "ទឹកក្នុងទីប្រមាណប៉ុណ្ណេះ ចូរទៅជាដីចុះ"

ដូច្នេះហើយ គប្បីអធិដ្ឋាន តាមន័យដែលលោកពោលហើយហ្នឹងឯង ។ ព្រមជាមួយនឹងការអធិដ្ឋាន ទឹកក្នុងទីដែលលោកកំណត់ហើយយ៉ាងណា ក៏ទៅជាដីមែនពិត ។ ភិក្ខុអ្នកមានឫទ្ធិនោះ ក៏ដើរលើដីនោះ ។

នេះគឺជាបាលី ក្នុងការអធិដ្ឋាននោះថា "ភិក្ខុបាននូវសមាបត្តិ មានបឋវីកសិណជាអារម្មណ៍ ដោយប្រក្រតី តែងនឹកចង់ដើរលើទឹក លុះនឹកចង់ហើយ ក៏អធិដ្ឋាន ដោយញាណថា "សូមឲ្យ (ទឹកត្រង់ទីនេះ) ទៅជាផែនដី" ដូច្នេះ, ទឹកក៏ទៅជាផែនដី ភិក្ខុនោះដើរលើទឹកមិនបែកធ្លាយ ដូចពួកមនុស្សមិនមានឫទ្ធិ ដោយប្រក្រតី ដើរលើផែនដីមិនបែកធ្លាយ យ៉ាងណា, ឯភិក្ខុអ្នកមានឫទ្ធិ ដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ដើរទៅលើទឹកមិនបែកធ្លាយ ដូចគេដើរលើផែនដី យ៉ាងនោះឯង [១] " ។

មិនត្រឹមតែដើទៅបានប៉ុណ្ណោះទេ, ភិក្ខុអ្នកមានឫទ្ធិ ប្រាថ្នាចង់បាននូវឥរិយាបថណាៗ ក៏ធ្វើនូវឥរិយបថនោះៗបាន ។ មិនត្រឹមតែធ្វើទឹកឲ្យទៅជាដីបានប៉ុណ្ណោះទេ, សូម្បីក្នុងវត្ថុទាំងឡាយ មានកែវមណី មាស ភ្នំ និង ដើមឈើជាដើម បុគ្គលអ្នកមានឫទ្ធិ ប្រាថ្នាវត្ថុណាៗ ក៏ពិចារណានូវវត្ថុនោះៗ ហើយអធិដ្ឋាន តាមន័យដែលបានពោលហើយហ្នឹងឯង ។ វត្ថុទាំងនោះ ក៏សំរេចដូចដែលលោកអធិដ្ឋានមែនពិត ។ ក៏ទឹកនោះ ទៅជាដី សំរាប់តែអ្នកមានឫទ្ធិនោះប៉ុណ្ណោះទេ, សំរាប់ជនដ៏សេស គង់នៅជាទឹកដដែល ។ ត្រីអណ្តើក និង សត្វទាំងឡាយមានសត្វដែលកើតក្នុងទឹកជាដើម ត្រាច់ទៅផ្សេងៗ គ្នា តាមសេចក្តីគាប់ចិត្ត ។ ក៏ប្រសិនបើបុគ្គលអ្នកមានឫទ្ធិនេះ ប្រាថ្នាដើម្បីធ្វើទឹកនោះឲ្យទៅជាដី ដើម្បីមនុស្សទាំងឡាយដទៃទៀត ក៏ធ្វើបានមែនពិត ។ ក៏ដោយការកន្លងកាលដែល

១- សុ. ខុ. បដិ. គាគទី ៧១ ទំព័រទី ២៧២ ។

លោកបានកំណត់ហើយ ទឹកនោះ ក៏ទៅជាទឹកវិញដដែល ។

(ទៅទាំងភ្នែនក្នុងអាកាសបាន)

ពាក្យថា “ទៅទាំងបល្លង្ក” សេចក្តីថា ទៅទាំងភ្នែនបាន ។ ពាក្យថា “បក្ខី សកុណោ” ប្រែថាសត្វស្លាបដែលប្រកបដោយស្លាបទាំង២ ។ ក៏ភិក្ខុអ្នកមានឫទ្ធិប្រាថ្នាដើម្បីធ្វើយ៉ាងនេះ ចូលបឋវីកសិណចេញហើយ ថាបើខ្លួនអង្គុយហើយ ប្រាថ្នាដើម្បីទៅ ក៏គប្បីកំណត់ នូវទីមានភ្នែនជាប្រមាណ ធ្វើបរិកម្ម ហើយអធិដ្ឋាន តាមន័យដែលលោកពោលហើយហ្នឹងឯង, ថាបើខ្លួនដេកហើយ ជាអ្នកប្រាថ្នាដើម្បីទៅ គប្បីកំណត់ទីមានគ្រែជាប្រមាណ ថាបើខ្លួនជាអ្នកប្រាថ្នាដើម្បីទៅដោយជើង គប្បីកំណត់ទីមានផ្លូវជាប្រមាណ ធ្វើនូវបរិកម្ម ហើយអធិដ្ឋាន តាមន័យដែលលោកពោលហើយហ្នឹងឯង ព្រោះហេតុនោះ គប្បីកំណត់ទីតាមសមគួរយ៉ាងនេះហើយ អធិដ្ឋានថា “អាកាស ចូរទៅជាផែនដី” ដូច្នេះ តាមន័យដែលលោកពោលហើយមែនពិត ។ ជាមួយនឹងការអធិដ្ឋាន អាកាស រមែងទៅជាដីវិញ ។ បាលី ក្នុងបាដិហារ្យនោះ មានដូចតទៅនេះ :

ពាក្យថា “ទៅទាំងភ្នែនក្នុងអាកាសដូចបក្សីសកុណជាតិ” សេចក្តីថា ភិក្ខុអ្នកដែលបាននូវសមាបត្តិ មានបឋវីកសិណជាអារម្មណ៍ ដោយប្រក្រតី តែងនឹកចង់ដើរក្នុងអាកាស លុះនឹកចង់ហើយ ក៏អធិដ្ឋាន ដោយញាណថា “សូមឲ្យអាកាសទៅជាផែនដី” ដូច្នេះ អាកាសក៏ទៅជាផែនដី, ភិក្ខុនោះ ដើរក្តី ឈរក្តី អង្គុយក្តី សិងក្តី ក្នុងអាកាសទទេបាន ដូចពួកមនុស្សដែលមិនមានឫទ្ធិ ដោយប្រក្រតី ដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី លើផែនដី យ៉ាងណា, ឯភិក្ខុដែលមានឫទ្ធិ បានដល់ហើយ នូវការស្ទាត់ជំនាញ ក្នុងចិត្តនោះ ដើរក្តី ឈរក្តី អង្គុយក្តី សិងក្តី ក្នុងអាកាសទទេ

ដូចបក្សីសកុណជាតិ យ៉ាងនោះឯង [១] ” ។

ចំណែកភិក្ខុអ្នកប្រាថ្នាដើម្បីទៅពួដ៏អាកាស គប្បីជាអ្នកបាននូវទិព្វចក្ខុផងដែរ ។ សួរថា: ព្រោះហេតុអ្វី? ។ ឆ្លើយថា: ធម្មជាតិទាំងឡាយ មានភ្នំ និង ដើមឈើជាដើម ដែលកើតឡើងដោយអំណាចរដូវ ក៏មានខ្លះ ក្នុងចន្លោះ(ផ្លូវ), សត្វទាំងឡាយ មាននាគ និង គ្រុឌជាដើម កាលប្រណែន តែងនិម្មិត ដើម្បីសំដែងដល់អ្នកមានឫទ្ធិទាំងនោះខ្លះ ។ សួរថា ចុះអ្នកមានឫទ្ធិ ឃើញនូវសត្វទាំងនោះហើយ តើត្រូវធ្វើដូចម្តេចដែរ? ។ ឆ្លើយថា: បុគ្គលអ្នកមានឫទ្ធិ គប្បីចូលសមាបត្តិ មានឈានជាទីតាំងចេញហើយ ធ្វើបរិកម្ម អធិដ្ឋានថា “សូមឲ្យវត្ថុនោះទៅជាអាកាសចុះ” ។

ចំណែកព្រះថេរៈ ពោលថា “ម្នាលអាវុសោទាំងឡាយ ការចូលសមាបត្តិ មានអ្វីជាប្រយោជន៍, ក្រែងចិត្តរបស់ភិក្ខុអ្នកមានឫទ្ធិនោះ តាំងនៅមាំហើយមែនពិត, ភិក្ខុអ្នកមានឫទ្ធិនោះ អធិដ្ឋាននូវទីណាៗ ដោយចិត្តនោះថា “ចូរទៅជាអាកាស” ដូច្នេះ, ទីនោះៗ បានទៅជាអាកាសមែនពិត មិនមែនទេឬ?” ។ ព្រះថេរៈ ពោលហើយយ៉ាងនេះក៏ពិតមែនហើយ តែបើទុកជាយ៉ាងដូច្នោះ ក៏គប្បីប្រតិបត្តិ តាមន័យដែលបានពោលហើយ ក្នុងតិរោកុឌ្ឌបាដិហារ្យឯណោះ ។

ម្យ៉ាងទៀត ភិក្ខុនេះ គប្បីជាអ្នកបាននូវទិព្វចក្ខុ ដើម្បីកិរិយាចុះ ក្នុងទីដែលជាឱកាសក៏បាន ។ ព្រោះថា ភិក្ខុនេះ ថាបើ ចុះក្នុងទីមិនមែនជាឱកាស ជាកំពង់សំរាប់ងូតក្តី ជាទ្វារនៃស្រុកក្តី គឺជាអ្នកប្រាកដ ដល់មហាជន ព្រោះហេតុនោះ ភិក្ខុនោះ ឃើញ (នូវឱកាស) ដោយទិព្វចក្ខុហើយ វៀរនូវទីមិនមែនជាឱកាស ហើយចុះក្នុងទីដែលជាឱកាស ។

១- សុ. ខុ. បដិ. គាគទី ៧១ ទំព័រទី ២៧២ ។

(យកដៃស្ទាបអង្អែលព្រះច័ន្ទនិងព្រះអាទិត្យក៏បាន)

ក្នុងបាដិហារ្យនេះថា “យកដៃស្ទាបអង្អែល នូវព្រះច័ន្ទ និង ព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ” មានអធិប្បាយថា: ភាពនៃព្រះច័ន្ទ និង ព្រះអាទិត្យ មានឫទ្ធិច្រើន បណ្ឌិតគប្បីជ្រាប ដោយកិរិយាត្រាច់ទៅ ឰដ៏ខាងលើផែនដី ដែលមានប្រមាណជា ៤២,០០០ យោជន៍, ភាពនៃព្រះច័ន្ទ និង ព្រះអាទិត្យ មានអានុភាពច្រើន បណ្ឌិតគប្បីជ្រាប ព្រោះកិរិយាធ្វើនូវពន្លឺ ក្នុងទ្វីបទាំង ៣ ក្នុងខណៈតែមួយ ។ មួយវិញទៀត ឈ្មោះថា មានឫទ្ធិច្រើន ព្រោះការត្រាច់ទៅ ឰដ៏ខាងលើ(ផែនដី) និង ធ្វើនូវពន្លឺ យ៉ាងនេះបាន, ឈ្មោះថា មានអានុភាពច្រើន ព្រោះភាវៈនៃព្រះច័ន្ទ និង ព្រះអាទិត្យនោះ មានឫទ្ធិច្រើននោះឯង ។ បទថា “បរាមជ្ជតិ” គឺ ស្ទាបអង្អែល ដោយជុំវិញ ដូចជាគេស្ទាបអង្អែលនូវផ្ទៃនៃកញ្ចក់ ។

ក៏ឫទ្ធិនេះ របស់ភិក្ខុអ្នកមានឫទ្ធិនោះ រមែងសំរេច ដោយអំណាចនៃឈានដែលមានអភិញ្ញាជាទីតាំងតែម្យ៉ាង ។ ការកំណត់ដោយកសិណសមាបត្តិ ក្នុងឫទ្ធិនោះ មិនមានទេ ។ សមដូចព្រះសារីបុត្រពោលហើយក្នុងបដិសម្ភិទាថា: បទថា “ឥមេបិ ចន្ទិមសុរិយេ ។បេ។ បរិមជ្ជតិ” មានសេចក្តីថា ភិក្ខុអ្នកមានឫទ្ធិ ក្នុងសាសនានេះ ដែលបានដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ នឹកចង់ស្ទាបអង្អែលនូវព្រះច័ន្ទ និង ព្រះអាទិត្យ លុះនឹកចង់ហើយ ក៏អធិដ្ឋាន ដោយញាណថា “សូមឲ្យ(ព្រះច័ន្ទ ឬ ព្រះអាទិត្យ) មកនៅក្នុងហត្ថបាស” ដូច្នេះ, (ព្រះច័ន្ទ ឬ ព្រះអាទិត្យ) ក៏បានមកនៅក្នុងហត្ថបាស, ភិក្ខុនោះ ជាអ្នកអង្គុយ ឬ សិង យកដៃទៅពាល់ស្ទាបអង្អែល នូវព្រះច័ន្ទ និង ព្រះអាទិត្យបាន ដូចពួកមនុស្សដែល

មិនមានឫទ្ធិ ដោយប្រក្រតី ពាល់ស្ទាបអង្អែល នូវវត្ថុអ្វីនីមួយ ជារបស់មានរូប តាំងនៅក្នុងហត្ថបាស យ៉ាងណា, ឯភិក្ខុអ្នកមានឫទ្ធិ បានដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ជាអ្នកអង្គុយ ឬ សិង យកដៃទៅពាល់ស្ទាបអង្អែល នូវព្រះច័ន្ទ និង ព្រះអាទិត្យ ក៏យ៉ាងនោះឯង ។

ភិក្ខុដែលមានឫទ្ធិនេះនោះ ថាបើប្រាថ្នា ដើម្បីទៅស្ទាបអង្អែល (នូវព្រះច័ន្ទ និងព្រះអាទិត្យ) ក៏ទៅស្ទាបអង្អែលបាន, តែថា បើជាអ្នកអង្គុយក្តី សិងក្តី ប្រាថ្នាចង់ស្ទាបអង្អែល ក្នុងទីនេះឯង អធិដ្ឋានថា “ព្រះច័ន្ទ និង ព្រះអាទិត្យ ចូរមានក្នុងហត្ថបាស” ។ ភិក្ខុអ្នកមានឫទ្ធិនោះ ស្ទាបអង្អែល នូវព្រះច័ន្ទ និងព្រះអាទិត្យ ដែលមកឋិតនៅហើយក្នុងហត្ថបាស ដោយកំឡាំងនៃការអធិដ្ឋានក៏បាន ដូចជាគេស្ទាបអង្អែលផ្លែត្នោត ដែលរបេះចាកទង យ៉ាងនោះឯង ឬ លូកដៃចាប់ក៏បាន ។

សួរថា “កាលអ្នកមានឫទ្ធិលូកទៅ, រូបដែលមានវិញ្ញាណប្រកាន់យកលូត ឬ រូបដែលមិនមានវិញ្ញាណប្រកាន់យកលូត?” ។ ឆ្លើយថា “ព្រោះអាស្រ័យឧបាទិន្នករូប ទើបអនុបាទិន្នករូបលូត” ។ ក្នុងឧបាទិន្នកៈ និងអនុបាទិន្នកៈនោះ ព្រះតិបិដកចូឡនាគត្ថេរ ពោលថា “ម្នាលអាវុសោទាំងឡាយ ក៏ឧបាទិន្នករូប ជារបស់តូចខ្លះ ធំខ្លះ មិនបានទេឬ? ក្រែងក្នុងពេលណា ភិក្ខុ (សំដែងឫទ្ធិ) ចេញទៅតាមប្រហោងទាំងឡាយ មានប្រហោងសោជាដើមបាន ក្នុងពេលនោះ ឧបាទិន្នករូប ជារបស់តូចបាន ក្នុងពេលណា ភិក្ខុធ្វើអត្តភាពឲ្យធំ ក្នុងពេលនោះ ឧបាទិន្នករូប ក៏ទៅជាធំបាន ដូចឧបាទិន្នករូប របស់ព្រះមហាមោគ្គល្លានត្ថេរមិនមែនទេឬ?” ។

(រឿងនន្ទោបនន្ទនាគរាជ)

បានឮថា សម័យមួយ អនាថបិណ្ឌិកគហបតី ស្តាប់ធម្មទេសនា

របស់ព្រះមានព្រះភាគហើយ ក្រាបទូលនិមន្តថា “បពិត្រព្រះអង្គដ៏ចំរើន ក្នុងថ្ងៃស្អែក សូមព្រះអង្គទទួលនូវភ័ត្ត ក្នុងផ្ទះរបស់យើងខ្ញុំព្រះអង្គ មួយអន្លើដោយភិក្ខុ ៥០០ អង្គ” ដូច្នេះហើយ ក៏ចៀសចេញទៅ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ទ្រង់ញ៉ាំងចំណែកនៃរាត្រី ក្នុងថ្ងៃនោះ ឲ្យកន្លងទៅហើយ ទើបទ្រង់ប្រមើលមើលនូវលោកធាតុមួយហ្មឺនក្នុងបច្ចូសសម័យ ។ គ្រានោះ នាគរាជឈ្មោះនន្ទោបនន្ទៈ មកកាន់រង្វង់ព្រះចក្ខុ ក្នុងប្រធាននៃញាណ របស់ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់រំពឹងមើលថា “នាគរាជ ឈ្មោះនន្ទោបនន្ទៈនេះ មកកាន់រង្វង់ចក្ខុ ក្នុងប្រធាននៃញាណ របស់តថាគត ។ តើឧបនិស្ស័យ របស់នាគរាជនេះមានដែរឬហ្ន៎?” ដូច្នេះ ក៏ទ្រង់ទតឃើញថា “នាគរាជនេះ ជាមិច្ឆាទិដ្ឋិ មិនជ្រះថ្លាក្នុងព្រះត្រៃរ័ត្នទេ” ទ្រង់រំពឹងមើលថា “អ្នកណាទៅហ្ន៎ គប្បីរំដោះនាគរាជនេះ ចេញអំពីមិច្ឆាទិដ្ឋិបាន?” ក៏ទ្រង់បានទតឃើញ នូវព្រះមហាមោគ្គល្លានត្ថេរ ។ លំដាប់នោះ នាកាលរាត្រីភ្លឺច្បាស់ហើយ ព្រះមានព្រះភាគ ទ្រង់ធ្វើនូវការជំរះព្រះសរីរៈ ហើយទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា “ម្នាលអានន្ទ ចូរអ្នកប្រាប់ភិក្ខុ ៥០០ រូប ថា តថាគត ទៅកាន់ទេវចារិក” ។

ក៏ក្នុងថ្ងៃនោះ ពួកនាគរាជ បានចាត់ចែកនូវទីសំរាប់ស៊ីផឹក សំរាប់នន្ទោបនន្ទនាគរាជ ។ ស្តេចនាគរាជនោះ មានស្វេតច្ឆ័ត្រដ៏ជាទិព្វបាំង គឺពួកអ្នករបាំ ៣ ក្រុម និង នាគបរិស័ទចោមរោមហើយ ជាអ្នកពៃនមើលនូវវិធីសោយបាយនិងទឹក ដែលគេដាក់ហើយ លើភាជនៈទិព្វទាំងឡាយ លើរតនបល្ល័ង្កដ៏ជាទិព្វ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ធ្វើឲ្យល្មមតែនាគរាជមើលឃើញ ទ្រង់យាងទៅ មានព្រះភក្ត្រឆ្ពោះទៅកាន់ទេវលោក

ជាន់តាវត្តិង្ស ជាមួយនឹងភិក្ខុ ៥០០ អង្គ តាមកំពូលនៃពិតានរបស់ស្តេចនាគរាជនោះឯង ។

ក៏ក្នុងសម័យនោះ ទិដ្ឋិ ដ៏អាក្រក់ មានសភាពបែបនេះ កើតឡើងហើយ ដល់នន្ទោបនន្ទនាគរាជថា “មិនគួរបើពួកសមណៈ ត្រងោលទាំងនេះ ចូលៗ ចេញៗ ភពតាវត្តិង្ស របស់ទេវតាទាំងឡាយ តាមភពខាងលើរបស់ពួកយើងទេ, ឥឡូវនេះ ចាប់តាំងពីថ្ងៃនេះតទៅ អញនឹងមិនឲ្យពួកសមណៈត្រងោលទាំងនេះ ទៅរោយធូលីជើង លើក្បាលរបស់ពួកយើងបានទេ” ។ នាគរាជនោះ ក្រោកឡើងហើយ ទៅកាន់ជើងភ្នំសិនេរុ លះបង់នូវអត្តភាពនោះ ព័ទ្ធព័ន្ធនូវភ្នំសិនេរុ ៧ ជុំ ដោយភ្កែនទាំងឡាយ ដកពពារ ព្ធដ៏ខាងលើ ចាប់យកភពជាន់តាវត្តិង្ស ដោយពពារដែលគ្រប ជិត ដល់ហើយនូវការមើលមិនឃើញ ។

គ្រានោះឯង ព្រះរដ្ឋបាល ដ៏មានអាយុ បានក្រាបទូលនូវពាក្យនេះចំពោះព្រះមានព្រះភាគថា “បពិត្រព្រះអង្គដ៏ចំរើន ក្នុងកាលមុន ខ្ញុំព្រះអង្គឈរនៅក្នុងប្រទេសនេះ មើលឃើញភ្នំសិនេរុ ឃើញសិនេរុបរិភណ្ឌ ឃើញភពតាវត្តិង្ស ឃើញវេជយន្តប្រាសាទ ឃើញទង់ខាងលើវេជយន្តប្រាសាទ, បពិត្រព្រះអង្គដ៏ចំរើន តើអ្វីទៅហ្ន៎ជាហេតុ អ្វីទៅហ្ន៎ជាបច្ច័យ ក្នុងកាលឥឡូវនេះ ដែលមិនឲ្យខ្ញុំព្រះអង្គមើលឃើញនូវភ្នំសិនេរុ ។ល។ មិនឲ្យខ្ញុំព្រះអង្គមើលឃើញទង់ លើវេជយន្តប្រាសាទនោះ?” ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា “ម្នាលរដ្ឋបាល នាគរាជ ឈ្មោះនន្ទោបនន្ទៈនេះ ក្រោធខឹងចំពោះពួកអ្នក ព័ទ្ធភ្នំសិនេរុ ដោយភ្កែនទាំងឡាយ ៧ ជុំ បាំងដោយពពារ ខាងលើ ធ្វើឲ្យងងឹត ឈរនៅហើយ” ។

ព្រះរដ្ឋបាល ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ នឹង

ទូន្មាននូវនាគរាជនោះ” ។ ព្រះមានព្រះភាគ មិនទ្រង់អនុញ្ញាតឡើយ ។ គ្រានោះ ភិក្ខុទាំងអស់អង្គ គឺៈ ព្រះភទ្ទិយៈដ៏មានអាយុ ព្រះរាហុលដ៏មានអាយុ ក្រោកឡើងហើយ តាមលំដាប់ ។ ព្រះដ៏មានព្រះភាគ មិនទ្រង់អនុញ្ញាតឡើយ ។ ក្នុងទីបំផុត ព្រះមហាមោគ្គល្លានត្ថេរ ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងទូន្មាន” ។ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយថា “ម្នាលមោគ្គល្លាន ចូរអ្នកទូន្មានចុះ” ។

ព្រះថេរៈ លះបង់នូវអត្តភាព និម្មិតនូវភេទជាស្តេចនាគដ៏ធំ រុំព័ទ្ធស្តេចនាគឈ្មោះនន្ទោបនន្ទៈ ដោយភ្នែន អស់វារៈ ១៤ ជង់ ដាក់ពពាររបស់ខ្លួន លើក្បាលនៃពពារនន្ទោបនន្ទនាគរាជនោះ គៀបរឹតហើយ ជាមួយនឹងភ្នំសិនេរុ ។ នាគរាជ បង្ហុយផ្សែងហើយ ។ ចំណែកព្រះថេរៈ ពោលថា “មិនមែនផ្សែងមានតែក្នុងសរីរៈរបស់អ្នកតែប៉ុណ្ណោះទេ, សូម្បីក្នុងសរីរៈរបស់យើងក៏មានដូចគ្នាដែរ” ដូច្នេះ បង្ហុយផ្សែងហើយ។ ផ្សែងរបស់នាគរាជ មិនបៀតបៀនព្រះថេរៈទេ, តែផ្សែងរបស់ព្រះថេរៈ បៀតបៀននូវនាគរាជ ។ លំដាប់នោះ នាគរាជ ព្រួសភ្លើងហើយ ។ ឯព្រះថេរៈពោលថា “មិនមែនមានភ្លើងតែក្នុងសរីរៈ របស់អ្នកតែម្នាក់ឯងទេ, សូម្បីក្នុងសរីរៈរបស់យើងក៏មានភ្លើងដូចគ្នា”ដូច្នេះ បញ្ចេញភ្លើងហើយ។ ភ្លើងរបស់នាគរាជ មិនបៀតបៀននូវព្រះថេរៈទេ, តែភ្លើងរបស់ព្រះថេរៈ បៀតបៀននាគរាជ ។ នាគរាជ គិតថា “សមណៈនេះ គៀបរឹតអញ ជាមួយនឹងភ្នំសិនេរុ ហើយបង្ហុយផ្សែងផង បញ្ចេញភ្លើងផង” ដូច្នេះហើយ សួរថា “នែលោកដ៏ចំរើន អ្នកជាអ្នកណា?” ។ ព្រះថេរៈ ពោលថា “នែនន្ទៈ អាត្មាហ្នឹងឯង ជាមោគ្គល្លានៈ” ។ នាគរាជទូលថា “បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់បិតនៅ ដោយភាពនៃខ្លួនជាភិក្ខុចុះ” ។

ព្រះថេរៈ លះនូវអត្តភាពនោះហើយ ចូលទៅ តាមរន្ធត្រចៀកខាងស្តាំរបស់នាគរាជនោះហើយ ចេញទៅវិញ តាមរន្ធត្រចៀកខាងឆ្វេង ។ ព្រះថេរៈ ចូលទៅ តាមរន្ធត្រចៀកខាងឆ្វេង ហើយចេញទៅវិញ តាមរន្ធត្រចៀកខាងស្តាំ ។ ព្រះថេរៈ ចូលទៅតាមរន្ធច្រមុះខាងស្តាំ ហើយចេញទៅវិញ តាមរន្ធច្រមុះខាងឆ្វេងដូចគ្នា ។ លោកចូលទៅ តាមរន្ធច្រមុះខាងឆ្វេង ហើយចេញទៅវិញ តាមរន្ធច្រមុះខាងស្តាំ ។ លំដាប់នោះ នាគរាជ បើកមាត់ហើយ ។ ព្រះថេរៈ ចូលទៅ តាមមាត់ហើយ ដើរចង្ក្រមទៅមក តាមទិសខាងកើត និង ទិសខាងលិច ខាងក្នុងពោះ(នាគរាជ) ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “ម្នាលមោគ្គល្លាន ចូរអ្នកធ្វើទុកក្នុងចិត្តថា នាគរាជនេះ ជាអ្នកមានឫទ្ធិច្រើន” ។ ព្រះថេរៈ ទូលថា “បពិត្រព្រះអង្គដ៏ចំរើន ឥទ្ធិបាទទាំង ៤ គឺខ្ញុំព្រះអង្គចំរើនហើយ ធ្វើឲ្យច្រើនហើយ ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីតាំងហើយ ធ្វើមិនឲ្យកំរើកហើយ ធ្វើឲ្យថ្នឹកហើយ ប្រារព្ធល្អហើយ, បពិត្រព្រះអង្គដ៏ចំរើន នន្ទោបនន្ទៈ ចូរបិតនៅចុះ, ខ្ញុំព្រះអង្គ គប្បីទូន្មានទាំងរយ ទាំងពាន់ ទាំងសែន នៃនាគរាជទាំងឡាយ ដូចជានន្ទោបនន្ទនាគរាជបាន” ។

ឯនាគរាជ គិតថា “សមណៈនេះ កាលចូលទៅ គឺអញមិនឃើញមុនក៏ហុយទៅចុះ ក្នុងពេលចេញមកវិញ ឥឡូវនេះ អញនឹងត្របាក់នូវសមណៈនោះ ត្រង់ចន្លោះនៃចង្កូម ហើយនឹងទំពាឲ្យខ្ទេច” ដូច្នេះហើយ ពោលថា “បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់និមន្តចេញមក សូមកុំដើរទៅមក ខាងក្នុងពោះ ធ្វើឲ្យខ្ញុំលំបាកឡើយ” ។ ព្រះថេរៈ បានចេញមកទៅឈរនៅខាងក្រៅហើយ ។ នាគរាជ ឃើញថា “នេះគឺលោក” លែងទៅហើយនូវខ្យល់ក្នុងច្រមុះ ។ ព្រះថេរៈ ចូលហើយនូវ

ចតុត្ថជ្ឈាន ។ ខ្យល់មិនអាច ដើម្បីញ៉ាំងសូម្បីនូវរណ្ដៅនៃរោមរបស់ព្រះថេរៈនោះ ឲ្យកំរើកបានឡើយ ។

បានឮមកថា ភិក្ខុដ៏សេសទាំងឡាយ មិនអាចដើម្បីធ្វើនូវបាដិហារ្យទាំងពួងបាន ចាប់តាំងតែអំពីដើមមក, តែដល់ទីនេះ ភិក្ខុពួកដ៏សេស ក៏នឹងមិនអាចដើម្បីជាអ្នកចូលសមាបត្តិយ៉ាងឆាប់រហ័សយ៉ាងនេះបានទេ ព្រោះហេតុនោះ ព្រះមានព្រះភាគ មិនទ្រង់អនុញ្ញាតនូវការទូន្មាននាគរាជ ដល់ភិក្ខុទាំងឡាយនោះ ។

នាគរាជ គិតថា "អញមិនអាច ដើម្បីញ៉ាំងសូម្បីត្រឹមតែរណ្ដៅ នៃរោម របស់សមណៈនេះ ឲ្យកំរើក ដោយខ្យល់ក្នុងច្រមុះ បានឡើយ, សមណៈ មានឫទ្ធិច្រើន" ដូច្នេះ ។ ព្រះថេរៈ លះបង់នូវអត្តភាព និម្មិតជារូបគ្រុឌ ហើយសំដែងនូវខ្យល់នៃគ្រុឌ ដេញជាប់តាមនាគរាជហើយ។ នាគរាជ លះបង់នូវអត្តភាពនោះ និម្មិតនូវភេទជាមាណព ហើយពោលថា "បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំសូមដល់លោកម្ចាស់ជាទីពឹងទីរលឹក" ដូច្នេះ ថ្វាយបង្គំហើយ នូវព្រះបាទទាំងឡាយរបស់ព្រះថេរៈ ។ ព្រះថេរៈ ពោលថា "នៃនន្ទៈ ព្រះសាស្ដាស្ដេចយាងមកហើយ, អ្នកចូរមក យើងនឹងទៅ" ដូច្នេះហើយ ទូន្មាននាគរាជ ធ្វើមិនឲ្យមានពុតត្បុតហើយ បាននាំយកទៅកាន់សំណាក់ នៃព្រះមានព្រះភាគ ។ នាគរាជ ថ្វាយបង្គំព្រះមានព្រះភាគហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាសូមដល់នូវព្រះអង្គជាទីពឹងទីរលឹក" ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលនាគរាជ ចូរអ្នកមានសេចក្ដីសុខចុះ" ទ្រង់មានភិក្ខុសង្ឃចោមរោមហើយ បានស្ដេចយាងទៅកាន់និវេសន៍ នៃអនាថបិណ្ឌិកសេដ្ឋី ។

អនាថបិណ្ឌិកសេដ្ឋី ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន ហេតុអ្វី

បានជាព្រះអង្គទ្រង់យាងមកទាំងថ្ងៃត្រង់?" ។ ព្រះសាស្ដា ទ្រង់ត្រាស់ថា "សង្គ្រាមបានកើតហើយដល់មហាមោគ្គល្លាន និងនន្ទោបនន្ទនាគរាជ" ។ សេដ្ឋី ក្រាបទូលសួរថា "បពិត្រព្រះអង្គដ៏ចំរើន តើអ្នកណាមានជ័យជំនះ អ្នកណាចាញ់?" ។ ព្រះអង្គទ្រង់ត្រាស់ថា "មោគ្គល្លាន មានជ័យជំនះ នន្ទោបនន្ទះចាញ់" ។ អនាថបិណ្ឌិកសេដ្ឋី ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់ទទួលនូវភត្ត របស់ទូលព្រះបង្គំ តាមលំដាប់នៃភាជន៍មួយ អស់ ៧ ថ្ងៃ, ខ្ញុំព្រះអង្គ នឹងធ្វើនូវសក្ការៈ ដល់ព្រះថេរៈ រហូត ៧ ថ្ងៃ" បានធ្វើហើយនូវសក្ការៈដ៏ច្រើន ចំពោះភិក្ខុ ៥០០ អង្គ មានព្រះពុទ្ធជាប្រធាន អស់ ៧ ថ្ងៃ ។

ពាក្យថា "ក្នុងពេលណា ភិក្ខុអ្នកមានឫទ្ធិ ធ្វើនូវអត្តភាពឲ្យធំ ក្នុងពេលនោះ អត្តភាពបានជាធំ ដូចអត្តភាពរបស់ព្រះមហាមោគ្គល្លានត្ថេរយ៉ាងនោះឯង" នេះ គឺព្រះតិបិដកចូឡនាគត្ថេរ ពោលហើយសំដៅយកនូវអត្តភាពដ៏ធំ ដែលព្រះមហាមោគ្គល្លានត្ថេរធ្វើហើយ ក្នុងការទូន្មាននូវនន្ទោបនន្ទនាគរាជនេះ ដោយប្រការដូច្នេះឯង ។ កាលបើលោកពោលហើយយ៉ាងនេះ, ភិក្ខុទាំងឡាយ ពោលថា "អនុបាទិន្នករូបហ្នឹងឯង តែងចំរើន ព្រោះអាស្រ័យនូវឧបាទិន្នករូប" ។ ក៏វាទៈ របស់ភិក្ខុទាំងឡាយនេះឯង ជាសេចក្ដីត្រឹមត្រូវ ក្នុងបាដិហារ្យនុ៎ះ ។

ភិក្ខុអ្នកមានឫទ្ធិនោះ លុះធ្វើយ៉ាងនេះហើយ មិនមែនគ្រាន់តែស្ទាបអង្អែលនូវព្រះចន្ទ និង ព្រះអាទិត្យទាំងឡាយតែប៉ុណ្ណោះទេ ថាបើប្រាថ្នាធ្វើនូវព្រះចន្ទ និង ព្រះអាទិត្យ ឲ្យទៅជាជ្រញ់សំរាប់ទ្រជើង ហើយដាក់ជើង (លើព្រះចន្ទនិងព្រះអាទិត្យនោះក៏បាន), ធ្វើឲ្យទៅជាតាំង ហើយអង្គុយក៏បាន, ធ្វើឲ្យទៅជាគ្រែដេកក៏បាន, ធ្វើ (ព្រះចន្ទ និង ព្រះអាទិត្យ)

ឲ្យទៅជាក្អាក់ដែសំរាប់ផ្អែក ហើយផ្អែកក៏បាន ។ ក៏បុគ្គលអ្នកមានឫទ្ធិមួយរូប ធ្វើបានយ៉ាងណា, សូម្បីបុគ្គលអ្នកមានឫទ្ធិដទៃទៀត ក៏ធ្វើបានយ៉ាងនោះដែរ ។ មែនពិត នាកាលពួកភិក្ខុសូម្បីច្រើនសែនរូប ធ្វើយ៉ាងនេះ, បាដិហារ្យ រមែងសំរេច ដល់បណ្តាភិក្ខុទាំងឡាយនោះ ភិក្ខុមួយរូបៗ ដូចគ្នាដែរ និង ដំណើរទៅក្តី ការធ្វើនូវពន្លឺក្តី របស់ព្រះច័ន្ទ និងព្រះអាទិត្យ តែងមានដូចគ្នាផងដែរ ។ ប្រៀបដូចជា កាលបើពាងទឹកមួយពាន់ ដែលពេញដោយទឹកមាន, មណ្ឌលនៃព្រះច័ន្ទ រមែងប្រាកដ ក្នុងពាងទាំងអស់, ដំណើរទៅក្តី ការធ្វើពន្លឺនៃព្រះច័ន្ទក្តី ក៏តាំងនៅជាប្រក្រតីដដែលយ៉ាងណាមិញ, បាដិហារ្យនេះ មានឧបមា ដោយមណ្ឌលនៃព្រះច័ន្ទ ក៏យ៉ាងនោះដែរ ។

(ប្រើអំណាចដោយកាយទៅព្រហ្មលោកក៏បាន)

(២៤៥) ពាក្យថា "យាវ ព្រហ្មលោកាបិ" សេចក្តីថា ធ្វើនូវព្រហ្មលោក ឲ្យជាគ្រឿងកំណត់បាន ។ ពាក្យថា "កាយេន វសំ វត្តេតិ" សេចក្តីថា អ្នកមានឫទ្ធិ ញុំាងអំណាចរបស់ខ្លួនឲ្យប្រព្រឹត្តទៅដោយកាយក្នុងព្រហ្មលោកនោះ ។ សេចក្តីនៃបាឋៈនោះ បណ្ឌិតគប្បីជ្រាប ទៅតាមបាលីផងចុះ ។

ក៏បាលី ក្នុងបាដិហារ្យនុ៎ះ មានដូចតទៅនេះ គឺ : បាលីថា "យាវ ព្រហ្មលោកាបិ យេន វសំ វត្តេតិ" សេចក្តីថា បើភិក្ខុអ្នកមានឫទ្ធិ ដែលបានសំរេចនូវការស្ទាត់ជំនាញក្នុងចិត្តនោះ មានប្រាថ្នាដើម្បីទៅកាន់ព្រហ្មលោក ក៏អធិដ្ឋាន(នូវវត្ថុ) ក្នុងទីឆ្ងាយ ឲ្យមកក្នុងទីជិតថា សូមឲ្យ (វត្ថុនោះ) មកតាំងនៅក្នុងទីជិត, (វត្ថុនោះ) ក៏មកតាំងនៅក្នុងទីជិតក៏បាន, អធិដ្ឋាន (នូវវត្ថុ) ក្នុងទីជិត ឲ្យទៅក្នុងទីឆ្ងាយថា សូមឲ្យ (វត្ថុនេះ) តាំង

នៅក្នុងទីឆ្ងាយ, (វត្ថុនោះ) ក៏តាំងនៅក្នុងទីឆ្ងាយក៏បាន, អធិដ្ឋាន នូវវត្ថុច្រើន ឲ្យទៅជាវត្ថុតិចថា សូមឲ្យវត្ថុនេះមានចំនួនតិច វត្ថុនោះ ក៏ទៅជាវត្ថុតិចក៏បាន, អធិដ្ឋាននូវវត្ថុតិច ឲ្យទៅជាវត្ថុច្រើនថា សូមឲ្យវត្ថុនេះទៅជាវត្ថុច្រើន, វត្ថុនោះ ក៏ទៅជាវត្ថុច្រើនក៏បាន, (ភិក្ខុនោះ) ឃើញច្បាស់នូវរូបនៃព្រហ្មនោះ ដោយចក្ខុដូចជាទិព្វ ឮសំឡេងនៃព្រហ្មនោះ ដោយសោតធាតុដូចជាទិព្វ ដឹងច្បាស់នូវចិត្ត នៃព្រហ្មនោះ ដោយញាណជាគ្រឿងកំណត់នូវចិត្ត, បើភិក្ខុអ្នកមានឫទ្ធិ ដែលបានសំរេចនូវការស្ទាត់ជំនាញក្នុងចិត្តនោះ មានប្រាថ្នាដើម្បីទៅ កាន់ព្រហ្មលោក ដោយកាយដ៏ប្រាកដ ក៏បង្អោនចិត្តទៅ ដោយអំណាចនៃកាយ អធិដ្ឋានចិត្ត ដោយអំណាចនៃកាយ លុះបង្អោនចិត្តទៅ ដោយអំណាចនៃកាយ អធិដ្ឋានចិត្តទៅដោយអំណាចនៃកាយហើយ ទើបចុះកាន់សុខសញ្ញាផង កាន់លហុសញ្ញាផង ហើយទៅកាន់ព្រហ្មលោក ដោយកាយដ៏ប្រាកដបាន, បើភិក្ខុអ្នកមានឫទ្ធិ ដែលបានសំរេចនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ជាអ្នកមានប្រាថ្នាដើម្បីទៅកាន់ព្រហ្មលោក ដោយកាយមិនប្រាកដ ក៏បង្អោនកាយដោយអំណាចនៃចិត្ត អធិដ្ឋាននូវកាយ ដោយអំណាចនៃចិត្ត លុះបង្អោនកាយទៅ ដោយអំណាចនៃចិត្ត អធិដ្ឋាននូវកាយ ដោយអំណាចនៃចិត្តហើយ ទើបចុះកាន់សុខសញ្ញាផង កាន់លហុសញ្ញាផង ហើយទៅកាន់ព្រហ្មលោក ដោយកាយមិនប្រាកដ, ភិក្ខុនោះ និម្មិតរូបខ្លួន ដែលសំរេចអំពីចិត្ត មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រីយ៍មិនថោកទាប នៅខាងមុខនៃព្រហ្មនោះ, បើភិក្ខុអ្នកមានឫទ្ធិនោះចង្រ្កម រូបនិម្មិតក៏ចង្រ្កម ក្នុងទីនោះដែរ, បើភិក្ខុអ្នកមានឫទ្ធិនោះឈរ រូបនិម្មិតក៏ឈរ ក្នុងទីនោះដែរ, បើភិក្ខុអ្នកមានឫទ្ធិនោះ អង្គុយ, រូបនិម្មិតក៏អង្គុយ ក្នុងទីនោះដែរ, បើភិក្ខុ

អ្នកមានឫទ្ធិនោះបញ្ចេញផ្សែង រូបនិម្មិត ក៏បញ្ចេញផ្សែង ក្នុងទីនោះដែរ, បើភិក្ខុអ្នកមានឫទ្ធិនោះ ឆេះទៅជាភ្លើង រូបនិម្មិត ក៏ឆេះទៅជាភ្លើង ក្នុងទីនោះដែរ, បើភិក្ខុអ្នកមានឫទ្ធិនោះ សំដែងនូវធម៌ រូបនិម្មិត្ត ក៏សំដែងនូវធម៌ ក្នុងទីនោះដែរ, បើភិក្ខុអ្នកមានឫទ្ធិនោះ សួរនូវប្រស្នា រូបនិម្មិតក៏សួរនូវប្រស្នា ក្នុងទីនោះដែរ, បើភិក្ខុអ្នកមានឫទ្ធិនោះ ត្រូវគេសួរនូវប្រស្នា ហើយកំពុងដោះស្រាយ រូបនិម្មិត ក៏ត្រូវគេសួរនូវប្រស្នា ហើយកំពុងដោះស្រាយ ក្នុងទីនោះដែរ, បើភិក្ខុអ្នកមានឫទ្ធិនោះ កំពុងឈរចរចា ធ្វើសាកច្ឆា ជាមួយព្រហ្មនោះ រូបនិម្មិត ក៏កំពុងឈរចរចា ធ្វើសាកច្ឆា ជាមួយព្រហ្មនោះ ក្នុងទីនោះដែរ, សរុបមក ភិក្ខុអ្នកមានឫទ្ធិនោះ ធ្វើនូវការណាៗ បាន រូបនិម្មិត ក៏ធ្វើនូវការនោះៗ បានដែរ យ៉ាងដូច្នេះឯង [១] ។

(អធិប្បាយសេចក្តីនៃបាលី)

ក្នុងបាលីទាំងនោះ បាលីថា "ទូរេបិ សន្តិកេ អធិដ្ឋាតិ" សេចក្តីថា ភិក្ខុអ្នកមានឫទ្ធិនោះ ចេញចាកសមាបត្តិ ដែលមានឈានជាទីតាំងហើយ ពិចារណានូវទេវលោក ឬ ព្រហ្មលោក ក្នុងទីឆ្ងាយថា "ទេវលោក និង ព្រហ្មលោក ចូរមានក្នុងទីជិត" ដូច្នេះ លុះពិចារណាហើយ ធ្វើនូវបរិកម្ម ចូលនូវសមាបត្តិ ម្តងទៀត អធិដ្ឋាន ដោយញាណថា "ទេវលោក និង ព្រហ្មលោក ចូរមានក្នុងទីជិត" ដូច្នេះ, ទេវលោក និង ព្រហ្មលោក ក៏មានក្នុងទីជិត ។ គប្បីជ្រាបន័យនេះ ក្នុងបទដ៏សេសទាំងឡាយផងចុះ ។

(ធ្វើទីឆ្ងាយឲ្យទៅជាជិត)

សួរថា "ក្នុងបាដិហារ្យនោះ អ្នកណាចាប់យកនូវទីឆ្ងាយ ធ្វើឲ្យទៅជាទីជិត?" ។ ឆ្លើយថា "ព្រះដ៏មានព្រះភាគ" ។ មែនពិត ព្រះដ៏មានព្រះ

១- សុ. ខុ. បដិ. គាគទី ៧១ ទំព័រទី ២៧៣ ។

ភាគ កាលស្តេចយាងទៅកាន់ទេវលោក ក្នុងកាលជាទីបំផុតនៃយមក-បាដិហារ្យ ទ្រង់ធ្វើនូវភ្នំយុគន្ធរ និង ភ្នំសិនេរុ ក្នុងទីជិត ទ្រង់ដាក់ព្រះបាទម្ខាង អំពីផ្ទៃផែនដី លើភ្នំយុគន្ធរ ហើយទ្រង់ដាក់នូវព្រះបាទទីពីរ លើកំពូលភ្នំសិនេរុ ។

សួរថា "អ្នកណាដទៃទៀត បានធ្វើ(នូវទីជិតឲ្យទៅជាទីឆ្ងាយ) បានខ្លះ?" ។ ឆ្លើយថា "ព្រះមហាមោគ្គល្លានត្ថេរ" ។ មែនពិត ព្រះថេរៈ បំព្រួញនូវផ្លូវទៅកាន់សង្កស្សនគរ ប្រមាណ ៣០ យោជន៍ ញ៉ាំងបរិស័ទ ១២ យោជន៍ ដែលកំពុងធ្វើភត្តកិច្ច ហើយចេញមក អំពីក្រុងសាវត្ថី ឲ្យដល់ព្រម ក្នុងខណៈនោះភ្លាម ។

មួយទៀត ព្រះចូឡសមុទ្ទត្ថេរ ក៏បានធ្វើហើយ ក្នុងតម្ពបណ្ណិទ្វីប ។ បានឮមកថា ក្នុងសម័យនៃស្រុកកើតទុរ្ភិក្ស ភិក្ខុ ៧០០ អង្គ បានទៅកាន់សំណាក់នៃព្រះថេរៈ តាំងពីព្រឹកព្រលឹម ។ ព្រះថេរៈ គិតថា "ភិក្ខុសង្ឃដ៏ច្រើន ការត្រាច់ទៅដើម្បីភិក្ខា នឹងមានក្នុងទីណា?" ដូច្នេះ មិនឃើញ (នូវទីភិក្ខាចារ) ក្នុងតម្ពបណ្ណិទ្វីបទាំងមូល ឃើញថា "ភិក្ខាចារនឹងមាន ក្នុងក្រុងបាតលីបុត្រ ត្រង់ឆ្នេរខាងនាយ" ដូច្នេះ ញ៉ាំងភិក្ខុទាំងឡាយឲ្យកាន់យក នូវបាត្រ និង ចីពរ ហើយពោលថា "ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរមក ពួកយើងនឹងទៅកាន់ភិក្ខាចារ" ដូច្នេះ ហើយ បំប្រួញនូវផែនដី ហើយទៅកាន់ក្រុងបាតលីបុត្រ ។ ពួកភិក្ខុទាំងឡាយ សួរថា "បពិត្រលោកម្ចាស់ដ៏ចំរើន នេះជានគរអ្វី?" ។ ព្រះថេរៈពោលថា "ម្នាលអាវុសោទាំងឡាយ នេះជានគរបាតលីបុត្រ" ។ ភិក្ខុទាំងឡាយសួរថា "បពិត្រលោកម្ចាស់ដ៏ចំរើន នគរបាតលីបុត្រ នៅក្នុងទីឆ្ងាយឬ?" ។ ព្រះថេរៈពោលថា "ម្នាលអាវុសោទាំងឡាយ ធម្មតាព្រះ

ថេរៈចាស់ទាំងឡាយ កំណត់ក្នុងទីឆ្ងាយធ្វើឲ្យនៅក្នុងទីជិតក៏បាន" ។ ភិក្ខុទាំងឡាយទូលថា "បពិត្រលោកម្ចាស់ដ៏ចំរើន តើមហាសមុទ្រ នៅក្នុងទីណា?" ។ ព្រះថេរៈពោលថា "ម្នាលអាវុសោទាំងឡាយ ក្រែងលោកទាំងឡាយ កន្លងនូវប្រឡាយមានពណ៌ខៀវមួយ ក្នុងចន្លោះ ជាអ្នកមកហើយឬ?" ។ ភិក្ខុទាំងនោះ ទូលថា "មែនហើយ លោកម្ចាស់ដ៏ចំរើន តែមហាសមុទ្រធំឬ?" ។ ព្រះថេរៈ ពោលថា "ម្នាលអាវុសោទាំងឡាយ ធម្មតាព្រះថេរៈចាស់ទាំងឡាយ តែងធ្វើនូវរបស់ធំឲ្យទៅជាតូចក៏បាន" ។

មួយទៀត ព្រះចូឡសមុទ្ទត្ថេរនេះ ធ្វើនូវរបស់ធំឲ្យទៅជាតូចបានយ៉ាងណា, សូម្បីព្រះតិស្សទត្តត្ថេរ ក៏យ៉ាងនោះដែរ ស្រង់ទឹកហើយ ក្នុងសម័យថ្ងៃរសៀល គ្រងចីពរហើយ, កាលបើចិត្ត កើតឡើងហើយ ថា "អាត្មាអញ នឹងថ្វាយបង្គំនូវមហាពោធិព្រឹក្ស" ដូច្នេះ, បានធ្វើហើយ ឲ្យមានក្នុងទីជិតបាន ។

(ធ្វើទីជិតឲ្យទៅជាទីឆ្ងាយបាន)

សួរថា "ចុះអ្នកណាកំណត់ទីជិតធ្វើឲ្យទៅជាទីឆ្ងាយ?" ។ ឆ្លើយថា "ព្រះមានព្រះភាគ" ។ មែនពិត ព្រះមានព្រះភាគ ទ្រង់បានធ្វើនូវចន្លោះដល់ព្រះអង្គ និង ដល់ព្រះអង្គុលិមាលសូម្បីទីជិតឲ្យទៅជាទីឆ្ងាយបាន ។

(ធ្វើនូវវត្ថុច្រើនឲ្យទៅជាតិចបាន)

សួរថា "ចុះអ្នកណា ធ្វើវត្ថុច្រើន ឲ្យទៅជាតិចបាន?" ។ ឆ្លើយថា "ព្រះមហាកស្សបត្ថេរ" ។ បានឮថា ក្នុងក្រុងរាជគ្រឹះ ក្នុងថ្ងៃជាទីលេងនូវនក្ខត្តឫក្ស កុមារីប្រមាណ ៥០០ នាក់ កាន់យកនូវនំដូចជាព្រះច័ន្ទដើរទៅដើម្បីប្រយោជន៍ដល់ការលេងនក្ខត្តឫក្ស ឃើញនូវព្រះមានព្រះភាគហើយ មិនបានថ្វាយហើយនូវនំបន្តិចបន្តួច, តែលុះឃើញព្រះថេរៈកំពុង

និមន្តមកតាមក្រោយ ក៏ពោលថា "ព្រះថេរៈ របស់ពួកយើង និមន្តមក ពួកយើង នឹងប្រគេននូវនំ" ហើយកាន់យកនំទាំងអស់ ចូលទៅរកព្រះថេរៈ ។ ព្រះថេរៈ យកបាត្រចេញមកបានធ្វើហើយនូវនំទាំងអស់ ឲ្យត្រឹមតែពេញមួយបាត្រ ។ ព្រះមានព្រះភាគ កាលរង់ចាំព្រះថេរៈ ទ្រង់គង់នៅខាងមុខហើយ ។ ព្រះថេរៈ បាននាំមកថ្វាយព្រះមានព្រះភាគ ។

(ធ្វើនូវវត្ថុតិចឲ្យទៅជាវត្ថុច្រើនបាន)

ចំណែកក្នុងរឿងឥល្លិសសេដ្ឋី ព្រះមហាមោគ្គល្លានត្ថេរ បានធ្វើនូវវត្ថុតិចឲ្យទៅជាវត្ថុច្រើន ។ មួយទៀត ក្នុងរឿងមនុស្សទុគ៌តឈ្មោះកាក-វឡិយៈ ព្រះមានព្រះភាគ ក៏ទ្រង់បានធ្វើវត្ថុតិចឲ្យច្រើនដែរ ។ បានឮថា ព្រះមហាកស្សបត្ថេរ ញុំាំងកាលឲ្យប្រព្រឹត្តកន្លងទៅ ក្នុងសមាបត្តិ អស់ ៧ ថ្ងៃ ហើយ ធ្វើនូវការសង្គ្រោះដល់មនុស្សទ័លក្រ បានឈរនៅក្បែរទ្វារផ្ទះ របស់មនុស្សទុគ៌តឈ្មោះកាកវឡិយៈ ។ ភរិយារបស់គាត់ឃើញព្រះថេរៈហើយ បានរោយរាយហើយ នូវបបរឥតមានរសប្រៃនិងរសជូរដែលខ្លួនចំអិនហើយដើម្បីស្វាមី ទៅក្នុងបាត្រ ។ ព្រះថេរៈ នាំយកបបរនោះ ទៅដាក់លើព្រះហស្តព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់អធិដ្ឋាន ធ្វើឲ្យល្មមគ្រាន់ដល់ភិក្ខុសង្ឃច្រើន ។ បបរដែលព្រះថេរៈ នាំមកដោយបាត្រមួយ ល្មមគ្រប់គ្រាន់ហើយដល់ភិក្ខុទាំងអស់ ។ ឯមនុស្សទុគ៌ត ឈ្មោះកាកវឡិយៈ បានហើយនូវតំណែងនៃសេដ្ឋី ក្នុងថ្ងៃទី ៧ ។

(ធ្វើវត្ថុមិនឆ្ងាញ់ឲ្យឆ្ងាញ់បាន)

មិនត្រឹមតែធ្វើនូវវត្ថុតិច ឲ្យច្រើនប៉ុណ្ណោះឡើយ, បុគ្គលអ្នកមានឫទ្ធិ ប្រាថ្នានូវវត្ថុណាៗ ក្នុងវត្ថុទាំងឡាយ មានវត្ថុឆ្ងាញ់ ឲ្យទៅជាវត្ថុមិនឆ្ងាញ់ វត្ថុមិនឆ្ងាញ់ ឲ្យទៅជាវត្ថុឆ្ងាញ់ ដូច្នេះជាដើមក៏បាន វត្ថុទាំងអស់នោះ ៗ

រមែងសំរេច ដល់បុគ្គលអ្នកមានឫទ្ធិ ។ ពិតដូច្នោះមែន អម្បាលយ៉ាង ព្រះមហាអនុរុទ្ធត្ថេរ ឃើញនូវភិក្ខុច្រើនអង្គ និមន្តទៅ ដើម្បីបិណ្ឌបាត្រ ហើយបាននូវភត្តដ៏សៅហ្មងមែនពិត កំពុងតែអង្គុយឆាន់ ក្បែរឆ្នេរស្ទឹង គង្គា ហើយអធិដ្ឋានថា “សូមឲ្យទឹក ក្នុងស្ទឹងគង្គា ក្លាយទៅជាទឹកដោះ រាវថ្លា” ដូច្នេះហើយ បានឲ្យនូវសញ្ញា ដល់សាមណេរទាំងឡាយ ។ ពួក សាមណេរទាំងនោះ បាននាំយក ដោយទីកោ មកប្រគេនភិក្ខុសង្ឃ ។ ភិក្ខុទាំងអស់អង្គ ឆាន់ហើយដោយទឹកដោះរាវថ្លា ដែលមានរសផ្អែម ។

ពាក្យថា “ទិព្វេន ចក្ខុនា” សេចក្តីថា ភិក្ខុអ្នកមានឫទ្ធិ ឋិតនៅក្នុង មនុស្សលោកនេះឯង ចំរើនអាលោកកសិណ មើលឃើញនូវរូបរបស់ ព្រហ្មនោះ និង ឋិតនៅក្នុងមនុស្សលោកនេះឯង កាលព្រហ្មនោះនិយាយ គ្នា ក៏ឮសំឡេងទាំងអស់ ដឹងច្បាស់នូវចិត្ត (របស់ព្រហ្មនោះ) បាន ។

(បង្អោនចិត្តទៅដោយអំណាចកាយបាន)

ពាក្យថា “កាយវសេន ចិត្តំ បរិណាមេតិ” សេចក្តីថាភិក្ខុអ្នកមាន ឫទ្ធិ បង្អោនចិត្តទៅ ដោយអំណាចនៃករជកាយ គឺកំណត់ចិត្តមានឈាន ជាទីតាំង លើកចិត្តឡើងក្នុងកាយ គឺធ្វើចិត្តឲ្យមានដំណើរទៅតាមកាយ គឺថា ឲ្យមានដំណើរទៅយឺតយូរ ។ ព្រោះថា ដំណើរនៃកាយ ជាដំណើរ យឺតយូរ ។ ពាក្យថា “សុខសញ្ញញ្ច លហុសញ្ញញ្ច ឱក្កមតិ” សេចក្តីថា ភិក្ខុអ្នកមានឫទ្ធិ យាងចុះកាន់ គឺចូលទៅ ពាល់ត្រូវ ដល់ព្រមនូវសុខ-សញ្ញា និង លហុសញ្ញា ដែលកើតព្រមដោយឥទ្ធិចិត្ត មានឈានជាទី តាំងជាអារម្មណ៍ ។ សញ្ញា ដែលសម្បយុត្តដោយឧបេក្ខា ឈ្មោះថា សុខសញ្ញា ។ ព្រោះថា ឧបេក្ខា ព្រះមានព្រះភាគ ត្រាស់ថា “ជាសុខ ដ៏ស្ងប់” ។ ក៏ឯសញ្ញានោះឯង គប្បីជ្រាបថា “ឈ្មោះថា លហុសញ្ញា”

ដូច្នេះក៏បាន ព្រោះភាវៈនៃសញ្ញានោះ រួចស្រឡះហើយចាកនីវរណៈទាំង ឡាយផង ចាកធម៌ជាសត្រូវទាំងឡាយមានវិតក្កៈជាដើមផង ។ កាលបើ បុគ្គលអ្នកមានឫទ្ធិនោះ យាងចុះកាន់សុខសញ្ញានោះ, សូម្បីករជកាយ ក៏ជាកាយស្រាល ដូចជាប៉ុយនៃគ ។ អ្នកមានឫទ្ធិនោះ ទៅកាន់ព្រហ្ម លោក ដោយកាយដ៏ស្រាលដែលប្រាកដ ដូចជាប៉ុយនៃគដែលត្រូវខ្យល់ បក់ប៉ើងឡើងហើយ យ៉ាងនោះ, ក៏អ្នកមានឫទ្ធិ កាលទៅយ៉ាងនេះ ថាបើ ប្រាថ្នា និម្មិតនូវផ្លូវព្ធដ៏អាកាស ដោយអំណាចនៃបឋវីកសិណ ហើយ ទៅ ដោយជើងបាន, ថាបើប្រាថ្នា អធិដ្ឋាន នូវខ្យល់ ដោយអំណាចនៃ វាយោកសិណ ហើយទៅដោយខ្យល់ ដូចជាប៉ុយនៃគក៏បាន ។ តែភាព នៃអ្នកមានឫទ្ធិចង់ដើម្បីទៅហ្នឹងឯង ជាប្រមាណបាន ក្នុងការទៅដោយ កាយដែលប្រាកដនុ៎ះ ។ ព្រោះថា កាលបើមានភាពនៃអ្នកមានឫទ្ធិប្រាថ្នា ដើម្បីទៅ, បុគ្គលអ្នកមានឫទ្ធិនោះ មានអធិដ្ឋាន ក្នុងចិត្តធ្វើហើយ យ៉ាង នេះ ជាអ្នកត្រូវកំឡាំងនៃការអធិដ្ឋានស្ទួយឡើងហើយមែនពិត រមែងទៅ កាន់ (ព្រហ្មលោក) បាន ដែលអ្នកណាក៏មើលមិនឃើញ ដូចជាកូនសរ ដែលនាយខ្មាន់ធ្នូ បាញ់ទៅហើយ ដូច្នោះឯង ។

(ទៅដោយអទិស្សមានកាយបាន)

(២៤៦) ពាក្យថា “ចិត្តវសេន កាយំ បរិណាមេតិ” សេចក្តីថា អ្នកមានឫទ្ធិកំណត់នូវកាយហើយលើកឡើងក្នុងចិត្ត គឺធ្វើ(កាយ)ឲ្យមាន ដំណើរទៅតាមចិត្ត គឺថា ធ្វើឲ្យមានដំណើររហ័ស ។ ព្រោះថា ដំណើរ នៃចិត្ត គឺជាធម្មជាតរហ័ស ។ ពាក្យថា “សុខសញ្ញញ្ច លហុសញ្ញញ្ច ឱក្កមតិ” សេចក្តីថា បុគ្គលអ្នកមានឫទ្ធិយាងចុះកាន់សុខសញ្ញា និង កាន់ លហុសញ្ញាដែលកើតព្រមដោយឥទ្ធិចិត្ត ដែលមានរូបកាយជាអារម្មណ៍

ដោយប្រការដូច្នេះឯង ។ ពាក្យដ៏សេស បណ្ឌិតគប្បីជ្រាប តាមន័យដែលលោកពោលហើយហ្នឹងឯង ។

ឯបាដិហារ្យ គឺការបង្អោននូវកាយ ដោយអំណាចនៃចិត្តនេះ គឺជាដំណើរនៃចិត្តហ្នឹងឯង ។ តែកាលបើមានពាក្យពោលថា “បុគ្គលអ្នកមានឫទ្ធិនេះ កាលទៅដោយកាយដែលមិនប្រាកដយ៉ាងនេះ ទៅក្នុងខណៈ នៃការកើតឡើង នៃអធិដ្ឋានចិត្តនោះឬ ឬថា ទៅក្នុងខណៈ នៃចិត្តតាំងនៅឬក៏ ក្នុងខណៈ នៃចិត្តបែកធ្លាយ?” ដូច្នេះ, ព្រះថេរៈពោលថា “អ្នកមានឫទ្ធិទៅក្នុងខណៈទាំងបី” ។ សួរថា “ចុះបុគ្គលអ្នកមានឫទ្ធិនោះទៅដោយខ្លួនឯង ឬ បញ្ជូននូវរូបដែលលោកនិម្មិតហើយឬ?” ។ ឆ្លើយថា “អ្នកមានឫទ្ធិ ធ្វើតាមសមគួរដល់សេចក្ដីគាប់ចិត្ត” ។ តែការទៅដោយខ្លួនឯងហ្នឹងឯងនៃបុគ្គលអ្នកមានឫទ្ធិនោះ មកហើយក្នុងបាដិហារ្យនេះ ។ បទថា “មនោមយំ” គឺរូបនោះ ឈ្មោះថា សំរេចដោយចិត្ត ព្រោះភាវៈនៃអ្នកមានឫទ្ធិនោះ និម្មិតហើយដោយចិត្តសំរាប់អធិដ្ឋាន ។ ពាក្យថា “អហីនិន្ទ្រិយំ” នេះ គឺលោកពោលហើយ ដោយអំណាចនៃការតាំងនៅព្រមនៃអាយតនៈទាំងឡាយមានភ្នែកនិងត្រចៀកជាដើម ។ តែជម្ពូតាប្រសាទក្នុងរូបនិម្មិត មិនមានទេ ។ ពាក្យទាំងពួងមានពាក្យថា “សចេ ឥទ្ធិមា ចង្កមតិ និម្មិតោបិ តត្ថ ចង្កមតិ” ដូច្នេះជាដើម គឺលោកពោលហើយព្រោះសំដៅយកនូវសាវកនិម្មិតទាំងអស់ ។ ចំណែកព្រះពុទ្ធនិម្មិត ព្រះមានព្រះភាគទ្រង់ធ្វើនូវកិច្ចណាៗ ក៏ធ្វើនូវកិច្ចនោះៗ ដែរ ធ្វើនូវកិច្ចដទៃទៀត ដោយអំណាចនៃកិរិយាគាប់ព្រះទ័យ នៃព្រះមានព្រះភាគផងដែរដោយប្រការដូច្នេះ ។

ក៏ក្នុងបាដិហារ្យនេះ បុគ្គលអ្នកមានឫទ្ធិនោះ ឋិតនៅហើយ ក្នុង

មនុស្សលោកនេះឯង មើលឃើញនូវរូប (ព្រហ្ម) ដោយចក្ខុ ដូចជាទិព្វ ស្ដាប់សំឡេង ដោយសោតធាតុ ដូចជាទិព្វ ដឹងច្បាស់នូវចិត្ត ដោយញាណជាគ្រឿងកំណត់ដឹងដោយចិត្ត ហេតុណា, ហេតុមានប្រមាណប៉ុណ្ណោះនោះ មិនឈ្មោះថា ញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយកាយទេ ។ បុគ្គលអ្នកមានឫទ្ធិនោះ ឋិតនៅក្នុងមនុស្សលោកនេះឯង កំពុងឈរចរចាធ្វើសាកច្ឆា ជាមួយនឹងព្រហ្មនោះ ដោយហេតុណា ហេតុមានប្រមាណប៉ុណ្ណោះឯង ក៏មិនឈ្មោះថាញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយកាយទេ ។ សូម្បីការអធិដ្ឋានរបស់អ្នកមានឫទ្ធិនោះថា “អធិដ្ឋានសូម្បីក្នុងទីឆ្ងាយឲ្យទៅជាទីជិតក៏បាន” ដូច្នេះជាដើម ដោយហេតុណា ហេតុមានប្រមាណប៉ុណ្ណោះនោះ មិនឈ្មោះថាញុំាងអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយទេ ។ បុគ្គលអ្នកមានឫទ្ធិនោះ ទៅកាន់ព្រហ្មលោក ដោយកាយដែលប្រាកដក្ដី មិនប្រាកដក្ដី ដោយហេតុណា ហេតុមានប្រមាណប៉ុណ្ណោះ ក៏មិនឈ្មោះថា ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយបានដែរ ។ ឯបុគ្គលអ្នកមានឫទ្ធិនោះ ដល់នូវវិធីដែលលោកពោលហើយ ដោយន័យថា “និម្មិតរូបខាងមុខនៃព្រហ្មនោះ” ដូច្នេះជាដើម ដោយហេតុណា ហេតុមានប្រមាណប៉ុណ្ណោះនោះ ទើបបានឈ្មោះថាញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ។ ចំណែកវិធីដ៏សេស លោកពោលហើយដើម្បីសំដែងនូវចំណែកខាងដើមនៃការប្រព្រឹត្តិទៅកាន់អំណាច ដោយកាយ ក្នុងអធិការនេះឯង ។ ឫទ្ធិនេះ ឈ្មោះថា អធិដ្ឋានឫទ្ធិ ជាមុនសិន ។

(វិកុព្វនឫទ្ធិ)

(២៤៧) ចំណែកការធ្វើឲ្យផ្សេងៗ នៃឫទ្ធិដែលធ្វើឲ្យប្លែក និង ឫទ្ធិដែលសំរេចមកអំពីចិត្ត មានដូតទៅនេះ គឺ :

ម្យ៉ាងទៀត ភិក្ខុអ្នកមានឫទ្ធិ កាលធ្វើនូវឫទ្ធិ គឺការធ្វើឲ្យប្លែកដំបូង ខ្លួនប្រាថ្នានូវរូបណាៗ គប្បីអធិដ្ឋាននូវរូបនោះៗ ក្នុងភេទទាំងឡាយមានភេទនៃកុមារជាដើម ដែលលោកពោលហើយ យ៉ាងនេះថា "ព្រះអភិក្ខុនោះ លះបង់ភេទជាប្រក្រតី ហើយសំដែងភេទជាកុមារខ្លះ សំដែងភេទជានាគខ្លះ សំដែងភេទជាគ្រុឌខ្លះ សំដែងភេទជាអសុរខ្លះ សំដែងភេទជាព្រះឥន្ទ្រខ្លះ សំដែងភេទជាទេវតាខ្លះ សំដែងភេទជាព្រហ្មខ្លះ សំដែងភេទជាសមុទ្រខ្លះ សំដែងភេទជាភ្នំខ្លះ សំដែងភេទជាសីហៈខ្លះ សំដែងភេទជាខ្លាធំខ្លះ សំដែងភេទជាខ្លាដំបងខ្លះ សំដែងភេទជាដំរីខ្លះ សំដែងភេទជាសេះខ្លះ សំដែងភេទជារថខ្លះ សំដែងភេទជាពលថ្មើរជើងខ្លះ សំដែងភេទជាកងទាហានប្លែកៗ គ្នាខ្លះ [១] " ។ ក៏អ្នកមានឫទ្ធិ កាលអធិដ្ឋានចេញចាកឈាន មានអភិញ្ញាជាទីតាំង មានកសិណឯណាមួយ ក្នុងចំណោមកសិណទាំងឡាយ មានបឋវីកសិណជាដើមជាអារម្មណ៍ហើយ គប្បីពិចារណាភេទកុមាររបស់ខ្លួនហ្នឹងឯង ។ បុគ្គលអ្នកមានឫទ្ធិនោះលុះពិចារណាហើយ ក្នុងទីបំផុតនៃបរិកម្ម គប្បីចូលឈានម្តងទៀត ចេញហើយ គប្បីអធិដ្ឋាន ថា "អាត្មាអញចូរជាកុមារមានឈ្មោះបែបនេះ" ។ ព្រមជាមួយនឹងចិត្តអធិដ្ឋាន អ្នកមានឫទ្ធិនោះក៏បានទៅជាក្មេងប្រុស ដូចជាភិក្ខុទេវទត្ត ។ ក្នុងបទទាំងពួង ក៏ន័យដូចគ្នានេះដែរ ។ ចំណែកបទថា "ហត្ថិម្បិ ទស្សេតិ" ដូច្នេះជាដើម ក្នុងបាលីនោះ លោកពោលហើយដោយអំណាចនៃការសំដែង នូវភេទមានដំរីជាដើម ពួដ៏ខាងក្រៅខ្លះ ។ ក្នុងការសំដែងខាងក្រៅនោះ បុគ្គលអ្នកមានឫទ្ធិនោះ មិនអធិដ្ឋាន ថា : "អាត្មាអញចូរជាដំរី" ដូច្នេះ គប្បីអធិដ្ឋានថា "ចូរជាដំរី" ដូច្នេះ ។ ន័យ

១- សុ. ខុ. បដិ. គាគទី ៧១ ទំព័រទី ២៧៧ ។

សូម្បីក្នុងភេទទាំងឡាយមានសេះជាដើម ក៏ន័យនេះដែរ ។ នេះជាឫទ្ធិ គឺការធ្វើឲ្យប្លែក (វិកុព្វនឫទ្ធិ) ។

(ឫទ្ធិសំរេចអំពីចិត្ត)

(២៤៨) ចំណែកភិក្ខុអ្នកចង់ដើម្បីធ្វើ នូវឫទ្ធិសំរេចអំពីចិត្ត ចេញចាកឈានជាទីតាំងហើយ ពិចារណាកាយជាមុន ហើយអធិដ្ឋាន តាមន័យដែលពោលហើយហ្នឹងឯងថា "កាយចូរជាប្រហោងចុះ" ។ កាយ ក៏ទៅជាប្រហោង ។ លំដាប់នោះ បុគ្គលអ្នកមានឫទ្ធិ ពិចារណាកាយដទៃក្នុងចន្លោះនៃកាយនោះ ធ្វើបរិកម្មហើយ អធិដ្ឋាន តាមន័យដែលលោកពោលហើយហ្នឹងឯងថា "កាយដទៃ ចូរមានក្នុងចន្លោះនៃកាយនោះ" ។ បុគ្គលអ្នកមានឫទ្ធិនោះ ដកនូវកាយនោះ ដូចបុគ្គលដកចេញនូវបណ្តូលអំពីស្មៅយាប្លង ដូចជាបុគ្គលហូតនូវដាវអំពីស្រោម និង ដូចជាបុគ្គលទាញនូវពស់អំពីត្រក យ៉ាងនោះឯង ។ ព្រោះហេតុដូច្នោះ បានជាលោកពោលពាក្យ មានជាអាទិ៍ថា "ភិក្ខុ ក្នុងសាសនានេះ និម្មិតនូវកាយ មានរូប ដែលសំរេចអំពីចិត្ត មានអវយវៈធំតូចសព្វគ្រប់ មានឥន្ទ្រីយ៍មិនថោកទាបជាកាយដទៃអំពីកាយនេះ ប្រៀបដូចបុរសដកចេញនូវបណ្តូលអំពីស្មៅយាប្លង, បុរសនោះ មានសេចក្តីដឹង យ៉ាងនេះឯងថា "នេះជាស្មៅយាប្លង នេះជាបណ្តូល ឯស្មៅយាប្លងដោយឡែក បណ្តូលដោយឡែក បណ្តូលគេដកចេញមក អំពីស្មៅយាប្លងហ្នឹងឯង [១] " ដូច្នេះ ។ ក៏ក្នុងបាលីនោះ សេចក្តីឧបមានេះ គឺលោកពោលហើយដើម្បីសំដែងថា "សម្ភារៈទាំងឡាយ មានបណ្តូលជាដើម ជារបស់ប្រហែលគ្នានឹងស្មៅយាប្លងជាដើម យ៉ាងណាមិញ, រូបដែលសំរេចអំពីចិត្ត ក៏យ៉ាងដូច្នោះ

១- សុ. ខុ. បដិ. គាគទី ៧១ ទំព័រទី ២៧៧ ។

ដែរ ជារូបប្រហែលគ្នានឹងបុគ្គលអ្នកមានឫទ្ធិហ្នឹងឯង” ដូច្នេះ ។ នេះគឺជាឫទ្ធិ ដែលសំរេចមកអំពីចិត្ត (មនោមយឫទ្ធិ) ។

បរិច្ឆេទ ទី១២ ឈ្មោះថា ឥទ្ធិវិធនិទ្ទេស
ក្នុងបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គ ដែលខ្ញុំធ្វើហើយ
ដើម្បីប្រយោជន៍ដល់កិរិយាញុំាងសាធុជនឲ្យរីករាយ
ចប់ហើយ ដោយប្រការអម្បាលនេះឯងហោង ។

❋ ❋ ❋

(ទិព្វសោតធាតុកថា)

(២៤៩) ក្នុងកាលឥឡូវនេះ លំដាប់នៃនិទ្ទេស នៃទិព្វសោតធាតុមកដល់ហើយ តាមលំដាប់ ។ បណ្ឌិតគប្បីជ្រាបសេចក្តី នៃបាលីទាំងឡាយ មានជាអាទិ៍ថា “ភិក្ខុនោះ កាលបើចិត្តជាសមាធិហើយយ៉ាងនេះ” ដូច្នេះ តាមន័យដែលលោកពោលហើយ ក្នុងទិព្វសោតធាតុនិទ្ទេសនោះផង ក្នុងអភិញ្ញាទាំងឡាយបី ដទៃអំពីនោះផង ។ តែយើងទាំងឡាយនឹងពណ៌នានូវត្រឹមតែសេចក្តីវិសេសប៉ុណ្ណោះ ក្នុងអភិញ្ញាទាំងពួង ។

(អធិប្បាយស័ព្ទបាលី)

ក្នុងបាលីនោះ បណ្ឌិតគប្បីជ្រាបសេចក្តី ក្នុងពាក្យថា “ទិព្វាយ សោតធាតុយា” នេះ ដូចតទៅ ។ សោតធាតុនោះ ឈ្មោះថាទិព្វ ព្រោះភាវៈនៃសោតធាតុនោះដូចជាទិព្វ ។ មែនពិត សោតធាតុនៃប្រសាទរបស់ទេវតាទាំងឡាយ ជាធម្មជាតិកើតហើយ ដោយសុចរិតកម្ម ដែលមិនប្រឡាក់ហើយ ដោយវត្ថុមិនស្អាតទាំងឡាយ មានប្រមាត់ ស្លេស្ម និងឈាមជាដើម អាចទទួលនូវអារម្មណ៍ក្នុងទីឆ្ងាយបានព្រោះរួចស្រឡះចាកគ្រឿងសៅហ្មងទើបដូចជារបស់ទិព្វ ។ ក៏ឯសោតធាតុនៃញាណនេះ ដែលកើតហើយដោយកំឡាំងនៃវីរិយភាវនា របស់ភិក្ខុនេះ ក៏ប្រាកដដូចគ្នានោះដែរ ព្រោះហេតុនោះ ទើបឈ្មោះថាទិព្វ ព្រោះញាណសោតធាតុនោះប្រាកដស្មើដូចជាទិព្វ ។ម្យ៉ាងទៀត ញាណសោតធាតុនោះ ឈ្មោះថា ជាទិព្វ ព្រោះភាវៈនៃញាណសោតធាតុនោះ គឺលោកបានមក ដោយអំណាចនៃធម៌ជាគ្រឿងនៅដូចជាទិព្វផង ព្រោះអាស្រ័យនូវធម៌ជាគ្រឿងនៅដូចជាទិព្វ របស់ខ្លួនផង ។

ញាណ ឈ្មោះថាសោតធាតុ ព្រោះអត្ថថា ឮផង ព្រោះអត្ថថា មិនមានជីវិតផង, មួយទៀត ឈ្មោះថា សោតធាតុ ព្រោះប្រៀបដូចជាសោតធាតុ ព្រោះធ្វើនូវកិច្ចនៃសោតធាតុ ដូច្នេះក៏មានដែរ ។ (អ្នកមានឫទ្ធិ ស្តាប់នូវសំឡេង) ដោយសោតធាតុ ដូចជាទិព្វនោះ ។

បទថា “វិសុទ្ធាយ” គឺព្រោះបរិសុទ្ធ គឺថា មិនមានឧបក្កិលេស ។ បទថា “អតិក្កន្តមានុសិកាយ” សេចក្តីថា កន្លង គឺប្រព្រឹត្តកន្លង នូវមំសសោតធាតុ ដែលជារបស់មនុស្ស ហើយឋិតនៅ ដោយអំណាចនៃការស្តាប់សំឡេងកន្លងនូវឧបចារៈនៃមនុស្ស ។ ពាក្យថា “ឧភោ សទ្ទេ” ប្រែថា អ្នកបានទិព្វសោត តែងឮសំឡេងទាំងពីរ ។ សួរថា “សំឡេងទាំងពីរគឺអ្វីខ្លះ?” ។ ឆ្លើយថា “សំឡេងទិព្វ ១ សំឡេងមនុស្ស ១” ។ អធិប្បាយថា “សំឡេងរបស់ទេវតាទាំងឡាយផង និង សំឡេងរបស់មនុស្សទាំងឡាយផង” ។ បណ្ឌិតគប្បីជ្រាបការប្រកាន់យកបរិយាយជាគ្រឿងអាង ដោយបទថា “ឧភោ សទ្ទេ” នេះ ។ ពាក្យថា “យេ ទូរេ សន្តិកេ ច” មានសេចក្តីអធិប្បាយថា “សំឡេងទាំងឡាយណា ក្នុងទីឆ្ងាយ និង សំឡេងទាំងឡាយណា ក្នុងទីជិត សូម្បីក្នុងចក្កវាឡដទៃ ដោយហោចទៅ សូម្បីសំឡេងនៃសត្វល្អិត ដែលអាស្រ័យនៅ ក្នុងរាងកាយរបស់ខ្លួន, បុគ្គលអ្នកបានទិព្វសោត តែងបានឮនូវសំឡេងទាំងឡាយនោះ” ។ បណ្ឌិតគប្បីជ្រាបការប្រកាន់យកបរិយាយ ដែលមិនមែនជាគ្រឿងអាង ដោយបទថា “យេ ទូរេ សន្តិកេ ច” នេះ ។

(វិធីធ្វើទិព្វសោត)

សួរថា “ចុះទិព្វសោតធាតុនេះ គឺយោគាវចរភិក្ខុ គប្បីធ្វើឲ្យកើតឡើងដោយប្រការដូចម្តេច?” ។ ឆ្លើយថា “ភិក្ខុនោះ ចូលកាន់ឈានមាន

អភិញ្ញាជាទីតាំង ចេញហើយ គប្បីពិចារណាសំឡេងនៃសត្វទាំងឡាយ មានសីហៈជាដើមក្នុងព្រៃ ដែលជាសំឡេងគ្រោតគ្រាត ក្នុងទីឆ្ងាយ ជាគន្លងនៃត្រចៀកជាប្រក្រតី មុនដោយវិសេស ដោយសមាធិចិត្តដែលជាបរិកម្ម ។ ព្រះយោគីគប្បីពិចារណាសំឡេងដ៏ល្អិតសុខុមទាំងឡាយ តាមសមគួរដល់លំដាប់ ចាប់ផ្តើមអំពីសំឡេងដ៏គ្រោតគ្រាតមុនគេទាំងអស់យ៉ាងនេះ គឺៈ សំឡេងរគាំង ក្នុងវត្ត សំឡេងស្គរ សំឡេងស័ង្ខ សំឡេងនៃការស្វាធ្យាយ របស់សាមណេរ និង ភិក្ខុកម្លោះទាំងឡាយដែលកំពុងស្វាធ្យាយ ដោយការប្រឹងប្រែងគ្រប់យ៉ាង, សំឡេងថា “បពិត្រព្រះគុណម្ចាស់ តើដូចម្តេច? ម្នាលអាវុសោទាំងឡាយតើដូចម្តេច?” ដូច្នេះជាដើមរបស់ភិក្ខុសាមណេរទាំងនោះ ដែលកំពុងសន្ទនាគ្នា ជាប្រក្រតី, សំឡេងនៃសត្វស្លាប សំឡេងខ្យល់ សំឡេងជើង សំឡេងនៃទឹកដែលពុះគ្រាក់ៗ សំឡេងស្លឹកត្នោតក្រៀមស្ងួតនាកំដៅថ្ងៃ សំឡេងសត្វល្អិតមានស្រមោចខ្មៅ និង ស្រមោចក្រហមជាដើម” ដូច្នេះ ។ ព្រះយោគីនោះ គប្បីធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងទាំងឡាយ ក្នុងទិសខាងកើត គប្បីធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងទាំងឡាយ ក្នុងទិសខាងលិច ទិសខាងជើង ទិសខាងត្បូង ទិសខាងក្រោម ទិសខាងលើ ទិសអាគ្នេយ៍ ទិសពាយព្យ ទិសឦសាន ទិសនិរតី ។ ព្រះយោគីនោះ គប្បីធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងទាំងឡាយ ទាំងគ្រោតគ្រាតទាំងល្អិត ។ សំឡេងទាំងឡាយនោះ រមែងប្រាកដដល់ព្រះយោគីនោះដែលមានចិត្តតាំងនៅជាប្រក្រតី ។ តែសំឡេងទាំងនោះ ជាសំឡេងប្រាកដក្រៃលែង ដល់ព្រះយោគីអ្នកមានសមាធិចិត្តក្នុងបរិកម្ម ។

កាលបើព្រះយោគីនោះធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តហ្នឹងឯង, មនោ-

ទ្វារាវជ្ជនចិត្ត ធ្វើនូវសំឡេងណាមួយ ក្នុងចំណោមសំឡេងទាំងឡាយនោះ ឲ្យជាអារម្មណ៍ហើយ កើតឡើងថា “ទិព្វសោតធាតុ នឹងកើតឡើងក្នុងកាលឥឡូវនេះ”។ កាលបើមនោទ្វារាវជ្ជនចិត្តនោះរលត់ហើយ, ជវនទាំងឡាយ ៣ ឬ ៤ ខាងដើម ជាកាមាវចរៈ មានឈ្មោះថា បរិកម្មជវន ឧបចារជវន អនុលោមជវន និង គោត្រភូជវន, ជវនទី ៤ ឬ ទី ៥ ជាអប្បនាចិត្ត ជារូបាវចរ ប្រកបដោយចតុត្ថជ្ឈាន នៃជវនទាំងឡាយណា, ជវនទាំងឡាយ ៤ ឬ ៥ នោះ រមែងស្ទុះទៅ ។ ក្នុងជវននោះ ញាណណា កើតឡើងហើយ ជាមួយនឹងអប្បនាចិត្តនោះ, ធាតុគឺញាណនេះ បណ្ឌិតគប្បីជ្រាបថា “ទិព្វសោតធាតុ” ។ បន្ទាប់អំពីនោះ ទិព្វសោតធាតុនោះ ក៏ជាធាតុធ្លាក់ចុះហើយ ក្នុងសោតៈនោះ ។

ព្រះយោគី កាលធ្វើនូវទិព្វសោតនោះ ឲ្យកើតជាគុណជាតរឹងប៉ឹង គប្បីកំណត់ត្រឹមតែមួយចង្អុលដៃ ហើយចំរើន ដោយតាំងចិត្តថា “អញនឹងស្តាប់នូវសំឡេង ក្នុងចន្លោះនុ៎ះ” ។ បន្ទាប់មក ព្រះយោគីគប្បីកំណត់រហូតដល់ចក្រវាឡ ឬកំណត់ដោយក្រៃលែងជាងចក្រវាឡនោះទៅទៀត ហើយគប្បីចំរើន ដោយអំណាចនៃទីមានពីរធ្នាប់ បួនធ្នាប់ ប្រាំបីធ្នាប់ មួយចំអាម មួយគក់ ខាងក្នុងបន្ទប់ បរិវេណនៃល្បៀងប្រាសាទ អារាម របស់សង្ឃ គោចរគ្រាម និង ជនបទជាដើម ។ ព្រះយោគី អ្នកបានសំរេចអភិញ្ញាហើយយ៉ាងនេះនុ៎ះ រមែងឮនូវសំឡេងទាំងឡាយដែលតាំងនៅក្នុងចន្លោះនៃអាកាស ដែលអារម្មណ៍មានឈានជាទីតាំង ពាល់ត្រូវហើយមែនពិត ។ តែថា ព្រះយោគី កាលឮយ៉ាងនេះ ប្រសិនបើមានការជ្រួលជ្រើមតែមួយ ដោយសំឡេងនៃក្ងែង មានស័ង្ខ ស្គរ និង ខ្លុយជាដើម រហូតដល់ព្រហ្មលោកក៏ដោយ, កាលបើមានភាពជាអ្នកប្រាថ្នា

ដើម្បីកំណត់នូវសំឡេងផ្សេងៗ ដោយឡែក, រមែងអាចដើម្បីកំណត់មែនពិត ថា “នេះសំឡេងស័ង្ខ នេះសំឡេងស្គរ” ដូច្នេះបានផងដែរ ។

ទិព្វសោតធាតុកថា ចប់ ។

❈ ❃ ❈

ចេតោបរិយញ្ញាណកថា

(អធិប្បាយស័ព្ទបាលីចេតោបរិញ្ញាណ)

(២៥០) ក្នុងចេតោបរិញ្ញាណកថា បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា “ចេតោបរិញ្ញាណាយ” នេះ ដូចតទៅនេះ ។ ញាណ ឈ្មោះថា បរិយៈ ព្រោះកំណត់ សេចក្តីថា កំណត់ស្ទង់ ។ ញាណដែលកំណត់នូវចិត្ត (របស់អ្នកដទៃ) ឈ្មោះថា ចេតោបរិយៈ, ញាណនោះផង កំណត់នូវចិត្ត (របស់អ្នកដទៃ)ផង ព្រោះហេតុនោះ ទើបឈ្មោះថា ចេតោបរិយញ្ញាណ (ញាណដែលកំណត់ចិត្តរបស់អ្នកដទៃបាន) ។ អធិប្បាយថា ដើម្បីប្រយោជន៍ដល់ចេតោបរិយញ្ញាណនោះ ។

បទថា “បរសត្តានំ” គឺ នៃសត្វដ៏សេសទាំងឡាយ លើកលែងតែខ្លួនចេញ ។ សូម្បីបទថា “បរបុគ្គលានំ” នេះ ក៏មានសេចក្តីតែមួយដោយបទនេះដែរ ។ តែព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវភាពផ្សេងៗ នៃព្យញ្ជនៈ ដោយអំណាចនៃសត្វដែលព្រះអង្គទ្រង់ទូន្មានផង ដោយលំនាំនៃទេសនាផង ។ ពាក្យថា “ចេតសា ចេតោ” គឺ នូវចិត្ត របស់សត្វដទៃ បុគ្គលដទៃទាំងឡាយនោះ ដោយចិត្តរបស់ខ្លួន ។ បទថា “បរិច្ច” ប្រែថាកំណត់ហើយ ។ បទថា “បជានាតិ” សេចក្តីថា ដឹងដោយប្រការផ្សេងៗ ដោយអំណាចនៃចិត្តទាំងឡាយ មានចិត្តដែលប្រកបទៅដោយរាគៈជាដើម ។

(វិធីធ្វើចេតោបរិញ្ញាណ)

សួរថា “ក៏ញាណនេះ ព្រះយោគីគប្បីធ្វើឲ្យកើតឡើងដូចម្តេច?” ។ ឆ្លើយថា “ព្រោះថា ញាណនេះ រមែងសំរេច ដោយអំណាចនៃទិព្វចក្ខុ, ទិព្វចក្ខុញាណនោះ ជាបរិកម្ម នៃបរិយញ្ញាណនោះឯង ព្រោះហេតុនោះ ភិក្ខុ (អ្នកបានទិព្វចក្ខុញាណហើយប្រាថ្នាដើម្បីធ្វើចេតោបរិយញ្ញាណនេះឲ្យកើតឡើង) នោះ គប្បីចំរើនអាលោកកសិណ ហើយមើលនូវពណ៌នៃឈាមដែលអាស្រ័យនូវហទយរូប របស់បុគ្គលដទៃ ហើយប្រព្រឹត្តទៅ ហើយស្វែងរកនូវចិត្ត ដោយចក្ខុដ៏ជាទិព្វ ។ ក៏សោមនស្សចិត្ត តែងប្រព្រឹត្តទៅ ក្នុងពេលណា, ក្នុងពេលនោះ លោហិត មានពណ៌ក្រហមប្រហែលគ្នានឹងផ្លែជ្រៃទុំ, ក្នុងពេលណា ទោមនស្សចិត្ត ប្រព្រឹត្តទៅ, ក្នុងពេលនោះ លោហិត មានពណ៌ខ្មៅ ប្រហែលគ្នានឹងផ្លែព្រីងទុំ ។ ក្នុងពេលណា ឧបេក្ខាចិត្ត ប្រព្រឹត្តទៅ, ក្នុងពេលនោះ លោហិត មានពណ៌ថ្លា ប្រហែលគ្នានឹងប្រេងល្ង ។ ព្រោះហេតុនោះ ភិក្ខុនោះ កាលស្វែងរកមើល នូវពណ៌នៃលោហិត ក្នុងបេះដូង របស់ជនដទៃ ថា “រូបនេះមានសោមនស្សិន្ទ្រិយ៍ជាសមុដ្ឋាន រូបនេះ មានទោមនស្សិន្ទ្រិយ៍ជាសមុដ្ឋាន រូបនេះ មានឧបេក្ខិន្ទ្រិយ៍ជាសមុដ្ឋាន” ដូច្នេះហើយ គប្បីធ្វើនូវចេតោបរិយញ្ញាណ ឲ្យជាគុណជាតតាំងនៅរឹងមាំ ។ ព្រោះថា កាលបើចេតោបរិយញ្ញាណនោះ តាំងនៅរឹងប៉ឹង យ៉ាងនេះហើយ, ព្រះយោគីនោះ ដឹងនូវកាមាវចរចិត្ត រូបាវចរចិត្ត និង អរូបាវចរចិត្ត ទាំងអស់ ដោយលំដាប់ រំកិលនូវចិត្ត ចាកចិត្ត សូម្បីវៀរចាកការឃើញនូវហទយរូបក៏ដោយ ។ សមដូចពាក្យដែលលោកពោលហើយ ក្នុងអដ្ឋកថា ថា “សួរថា ព្រះយោគី អ្នកចង់ដើម្បីដឹងនូវចិត្ត នៃជនដទៃ ក្នុងអារុប្បជ្ឈាន ឃើញនូវ

ហទយរូបរបស់អ្នកណា ក្រឡេកមើលនូវការប្រែប្រួលនៃឥន្ទ្រិយ៍ របស់អ្នកណា ។ ឆ្លើយថា : មិនក្រឡេកមើល របស់អ្នកណាទេ, ព្រះយោគីកាលពិចារណានូវចិត្ត (នៃអ្នកដទៃ) ក្នុងភពណានីមួយ ដឹងនូវចិត្ត មាន ១៦ ប្រភេទ នេះឯណា, នេះជាវិស័យរបស់ភិក្ខុអ្នកមានឫទ្ធិ, ចំណែកសំដីនេះ គឺព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចនៃការប្រកាន់ស្អិត ដែលព្រះយោគីមិនបានធ្វើហើយ ដោយប្រការដូច្នេះឯង ។

(អធិប្បាយចិត្ត ១៦ ប្រភេទ)

ចំណែកក្នុងបាលីថា “សរាគំ វា ចិត្តំ” ដូច្នេះជាដើម បណ្ឌិតគប្បីជ្រាបសេចក្តីអធិប្បាយ ដូចតទៅនេះ ។ ចិត្ត ប្រកបដោយលោភៈ ៨ ប្រការ បណ្ឌិតគប្បីជ្រាបថា “ចិត្តប្រកបដោយរាគៈ” ។ ចិត្តដ៏សេស គឺចិត្តជាកុសល និង អព្យាក្រឹត ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថាចិត្តប្រាសចាករាគៈ ។ ចំណែកចិត្តទាំងឡាយ ៤ នេះ គឺ ទោមនស្សចិត្ត ២ វិចិកិច្ឆាចិត្ត និង ឧទ្ធច្ចចិត្ត ២ មិនដល់នូវការសង្គ្រោះ ក្នុងប្រមាណ ២ នៃចិត្តនេះទេ ។ តែព្រះថេរៈពួកខ្លះ រួបរួមនូវចិត្តទាំង ៤ នេះផងដែរ ។

ចំណែកទោមនស្សចិត្ត ២ ប្រការ ឈ្មោះថា ចិត្តប្រកបដោយទោសៈ ។ ចិត្តជាកុសល និង អព្យាក្រឹត ប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ ឈ្មោះថា ចិត្តប្រាសចាកទោសៈ ។ ចិត្តដ៏សេសទាំងឡាយ គឺអកុសលចិត្ត ១០ មិនដល់នូវការរួបរួមក្នុងប្រមាណ ២ នៃចិត្តនេះទេ ។ ប៉ុន្តែ ព្រះថេរៈពួកខ្លះ រួបរួមនូវអកុសលចិត្តទាំង ១០ នេះផងដែរ ។

ចំណែកក្នុងបទថា “សមោហំ វីតមោហំ” នេះ បណ្ឌិតគប្បីជ្រាបដូចតទៅនេះ ។ ចិត្តដែលប្រកបដោយវិចិកិច្ឆា និង ឧទ្ធច្ចៈ ២ ប្រការ ដោយន័យចំពោះរូបបុគ្គលប៉ុណ្ណោះ ឈ្មោះថាចិត្តប្រកបដោយមោហៈ ។

តែសូម្បីអកុសលចិត្តទាំង១២ ប្រការ ក៏បណ្ឌិតគប្បីជ្រាបថា “ចិត្តប្រកបដោយមោហៈ” ព្រោះមោហៈមាននៅព្រម ក្នុងអកុសលទាំងពួង ។ ចិត្តដ៏សេស ឈ្មោះថា ចិត្តប្រាសចាកមោហៈ (វីតមោហចិត្ត) ។

ចំណែកចិត្តដែលប្រព្រឹត្តទៅតាមថីនមិទ្ធៈ ឈ្មោះថា ចិត្តរួញរា ។ ចិត្តដែលប្រព្រឹត្តទៅតាមឧទ្ធច្ចៈ ឈ្មោះថា ចិត្តរាយមាយ ។

ចិត្តដែលជារូបាវចរ និង អរូបាវចរ ឈ្មោះថា ចិត្តដែលដល់ នូវភាពជាធំ (មហគ្គតចិត្ត) ។ ចិត្តដ៏សេស ឈ្មោះថា ចិត្តមិនដល់នូវភាពជាធំ (អមហគ្គតចិត្ត) ។

ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ឈ្មោះថា ចិត្តដែលមានធម៌ប្រសើរជាង (សឧត្តរចិត្ត) ។ ចិត្តដែលជាលោកុត្តរៈ ឈ្មោះថា ចិត្តដែលមិនមានធម៌ប្រសើរជាង (អនុត្តរចិត្ត ។

ចិត្តដែលដល់នូវឧបចារៈ និង ចិត្តដែលដល់នូវអប្បនា ឈ្មោះថា ចិត្តតាំងនៅមាំ (សមាធិចិត្ត) ។ ចិត្តដែលមិនទាន់បានដល់ទាំងពីរយ៉ាង ឈ្មោះថា ចិត្ត មិនតាំងនៅមាំ (អសមាធិចិត្ត) ។

ចិត្តដែលដល់នូវតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និង និស្សរណវិមុត្តិ ឈ្មោះថា ចិត្តរួចស្រឡះ (វិមុតចិត្ត) ។ ចិត្តដែលមិនទាន់បានដល់វិមុត្តិទាំង ៥ ប្រការនុ៎ះ បណ្ឌិតគប្បីជ្រាបថា ចិត្តដែលមិនទាន់រួចស្រឡះ (អវិមុត្តចិត្ត) ។

ភិក្ខុអ្នកបានចេតោបរិយញ្ញាណ រមែងដឹងច្បាស់ នូវចិត្តគ្រប់យ៉ាងថា “ចិត្តនេះ ជាចិត្តមានរាគៈ ឬ ។ល។ ឬថា ចិត្តនេះ ជាចិត្តមិនរួចស្រឡះ” ដោយប្រការដូច្នេះឯង ។

ចេតោបរិយញ្ញាណកថា ចប់ហើយ ។

(បុព្វេនិវាសានុស្សតិញ្ញាណកថា)

(២៥១) ក្នុងបុព្វេនិវាសានុស្សតិញ្ញាណកថា មានអធិប្បាយថា : បទថា “បុព្វេនិវាសានុស្សតិញ្ញាណាយ” សេចក្ដីថា ញាណណា ក្នុងបុព្វេនិវាសានុស្សតិ (ព្រះយោគី បង្អោនចិត្តទៅ) ដើម្បីជាប្រយោជន៍ដល់ញាណនោះ ។ ពាក្យថា “បុព្វេនិវាសា” សេចក្ដីថា ខន្ធដែលខ្លួនអាស្រ័យហើយក្នុងកាលមុនគឺក្នុងអតីតជាតិទាំងឡាយ។ បទថា “និវុដ្ឋា” សេចក្ដីថា ខន្ធដែលខ្លួនគ្រប់គ្រងហើយ គឺដែលខ្លួនសោយហើយ គឺថាដែលកើតហើយរលត់ទៅវិញក្នុងសន្ដានរបស់ខ្លួន, មួយទៀត ធម៌ដែលខ្លួននៅអាស្រ័យហើយ ក៏ឈ្មោះថា និវុដ្ឋា ។ សេចក្ដីថា “ធម៌ទាំងឡាយដែលខ្លួននៅអាស្រ័យហើយ ដោយកិរិយានៅអាស្រ័យជាគោចរ ដែលកំណត់ដឹង ដោយវិញ្ញាណរបស់ខ្លួន, មួយទៀត សូម្បីកំណត់ដឹងច្បាស់ហើយ ដោយវិញ្ញាណ របស់បុគ្គលដទៃ ក្នុងកាលទាំងឡាយមានកាលជាទីនឹករលឹក នូវបុគ្គលមានគ្រឿងវិលវល់ដាច់ហើយជាដើម ក៏ឈ្មោះថា និវុដ្ឋា ។ ចំពោះព្រះពុទ្ធទាំងឡាយតែម្យ៉ាង តែងបាននូវនិវុដ្ឋធម៌ទាំងឡាយនោះ ។

បទថា “បុព្វេនិវាសានុស្សតិ” សេចក្ដីថា ភិក្ខុរលឹករឿយៗ នូវខន្ធដែលខ្លួនអាស្រ័យហើយក្នុងកាលមុន ដោយសតិណា, សតិនោះ ឈ្មោះថា បុព្វេនិវាសានុស្សតិ ។ ពាក្យថា “ញាណ” គឺញាណដែលសម្បយុត្តហើយ ដោយសតិនោះ ។ ដើម្បីប្រយោជន៍ដល់បុព្វេនិវាសានុស្សតិ-ញាណនេះ ដូចពោលមកនេះឯង ។ អធិប្បាយថា “ដើម្បីបានសំរេច គឺដើម្បីដល់នូវញាណនេះ ដោយបុព្វេនិវាសានុស្សតិញ្ញាណ” ។

បទថា “អនេកវិហិតំ” សេចក្ដីថា មានបែបច្រើនយ៉ាង ម្យ៉ាងទៀត

សេចក្តីថា ឲ្យប្រព្រឹត្តទៅ គឺដែលលោកពណ៌នាហើយ ដោយប្រការដ៏ច្រើន ។ បទថា "បុព្វេនិវាសំ" បានដល់ ខន្ធសន្តានដែលខ្លួនអាស្រ័យហើយ ក្នុងភពនោះៗ ចាប់តាំងពីភពដែលជាអតីតដ៏ជិតបំផុត ។ បទថា "អនុស្សរតិ" គឺ រលឹកទៅតាមហើយៗ ដោយអំណាចលំដាប់នៃខន្ធ ឬ ដោយអំណាចនៃចុតិ និង បដិសន្ធិ ។

(បុគ្គល ៦ ពួក រលឹកបាននូវបុព្វេនិវាស))

ក៏ជនទាំងឡាយ ៦ ពួក គឺ តិរ្ថិយទាំងឡាយ បកតិសាវកទាំងឡាយ មហាសាវកទាំងឡាយ អគ្គសាវកទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ ព្រះពុទ្ធទាំងឡាយ រលឹករឿយៗ នូវបុព្វេនិវាសនេះបាន ។

បណ្តាជនទាំង ៦ ពួកនោះ តិរ្ថិយទាំងឡាយ រលឹកបានតែ ៤០ កប្បទេ ។ លើសអំពីនោះ រលឹកមិនបានឡើយ ។ ព្រោះហេតុអ្វី? ។ ព្រោះតិរ្ថិយទាំងនោះមានប្រាជ្ញាទន់ខ្សោយ ។ មែនពិត បញ្ញា របស់ពួកតិរ្ថិយទាំងនោះជាបញ្ញាទន់ខ្សោយ ព្រោះភាវៈនៃបញ្ញាជាគុណជាតប្រាសហើយ ចាកការកំណត់នូវនាម និង រូប ។ ព្រះបកតិសាវកទាំងឡាយ រលឹកបាន ១០០ កប្បខ្លះ ១,០០០ កប្បខ្លះ ព្រោះជាអ្នកមានបញ្ញាដ៏ខ្លាំងក្លា ។ ព្រះអសីតិមហាសាវកទាំងឡាយរលឹកបានអស់មួយសែនកប្ប ។ ព្រះអគ្គសាវកទាំងពីរអង្គ រលឹកបានអស់មួយអសង្ខេយ្យ នឹងមួយសែនកប្ប ។ ព្រះបច្ចេកពុទ្ធទាំងឡាយ រលឹកបានអស់ពីរអសង្ខេយ្យនឹងមួយសែនកប្ប ។ ព្រោះអភិនីហាររបស់ព្រះបច្ចេកពុទ្ធទាំងនោះមានប្រមាណប៉ុណ្ណោះ ។ តែសំរាប់ព្រះពុទ្ធទាំងឡាយ មិនមានកំណត់ឡើយ ។

(រលឹកបានផ្សេងគ្នា)

មួយទៀត តិរ្ថិយទាំងឡាយ រលឹកបានតែលំដាប់នៃខន្ធប៉ុណ្ណោះ ។

លោកទាំងនោះ មិនអាចដើម្បីលែងនូវលំដាប់ហើយរលឹកដោយអំណាចនៃចុតិ នឹង បដិសន្ធិបានទេ ។ ព្រោះការចុះកាន់ប្រទេសដែលខ្លួនប្រាថ្នាហើយ មិនមាន ដល់ពួកតិរ្ថិយទាំងនោះដែលដូចជាមនុស្សខ្វាក់ ។ មួយទៀត មនុស្សខ្វាក់ទាំងឡាយ មិនបោលនូវឈើច្រត់សោះហើយដើរទៅយ៉ាងណាមិញ, ពួកតិរ្ថិយទាំងនោះ មិនបោលនូវលំដាប់នៃខន្ធពិត ទើបរលឹកបាន ក៏យ៉ាងនោះដែរ ។ ព្រះបកតិសាវកទាំងឡាយរលឹកបានតាមលំដាប់ខន្ធខ្លះ រំកិលចូលបានដោយអំណាចនៃចុតិនឹងបដិសន្ធិខ្លះ ។ ព្រះអសីតិមហាសាវកទាំងឡាយ ក៏យ៉ាងដូច្នោះដែរ ។ ចំណែកឯព្រះអគ្គសាវកទាំងពីរ កិច្ចដោយលំដាប់នៃខន្ធ មិនមានទេ ។ ព្រះអគ្គសាវកទាំងពីរអង្គនោះ រំកិលហើយទៅ ដោយអំណាចនៃចុតិ នឹង បដិសន្ធិហ្នឹងឯងយ៉ាងនេះ គឺ "លោកឃើញនូវចុតិ របស់អត្តភាពមួយ ហើយឃើញ នូវបដិសន្ធិ ឃើញចុតិរបស់អត្តភាពដទៃទៀតហើយឃើញនូវបដិសន្ធិ, ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏យ៉ាងដូច្នោះដែរ ។ ចំណែកព្រះពុទ្ធទាំងឡាយ កិច្ចដោយលំដាប់នៃខន្ធ មិនមានសោះឡើយ, កិច្ចដោយការរំកិលចូលដោយអំណាចនៃចុតិ នឹង បដិសន្ធិ ក៏មិនមានសោះឡើយ ។ មែនពិត ព្រះពុទ្ធទាំងឡាយ ប្រាថ្នានូវទីណាៗ ខាងក្រោមក្តី ខាងលើក្តី ក្នុងកោដិនៃកប្បទាំងឡាយដ៏ច្រើន, ទីនោះៗ ជាទីប្រាកដមែនពិតដល់ព្រះពុទ្ធទាំងឡាយនោះ, ព្រោះហេតុនោះ ព្រះពុទ្ធទាំងនោះ ទ្រង់បំព្រួញហើយប្រាថ្នានូវទីណាៗ អស់កោដិនៃកប្បទាំងឡាយ សូម្បីមិនតែមួយ ដូចបំព្រួញនូវបាលីមានអត្ថគឺខ្លួនរក្សាទុក ហើយក៏រំកិលចូលទៅក្នុងទីនោះៗ តែម្តងតែងយាងទៅ ដោយអំណាចនៃកិរិយាឈានចុះដូចជាសត្វសីហៈ ។ ក៏កាលព្រះពុទ្ធទាំងឡាយនោះទ្រង់ស្តេចយាងទៅយ៉ាងដូច្នោះ, ព្រះញាណ

របស់ព្រះអង្គ រមែងមិនទើសទាក់ មិនឃ្លៀងឃ្លាត ក្នុងជាតិទាំងឡាយជាចន្លោះៗ កាលមិនទើសទាក់ មិនឃ្លៀងឃ្លាត ក៏រមែងទ្រង់ចាប់យកនូវទីដែលព្រះអង្គទ្រង់ប្រាថ្នាហើយ ៗ មែនពិត ឈ្មោះថា ប្រៀបដូចជាកូនសរដែលខ្នាន់ធ្នូប្រាកដស្មើដោយព្រះពោធិសត្វឈ្មោះសរភង្គៈ អ្នកស្ទាត់ជំនាញក្នុងការបាញ់នូវរោមចាមរីធ្វើហើយ បាញ់ទៅហើយ មិនទើសទាក់ ក្នុងទីទាំងឡាយមានឈើនិងវល្លិជាដើម ក្នុងចន្លោះ រមែងធ្លាក់ក្នុងទីជាទីកំណត់មែនពិត មិនទើសទាក់ មិនក្លាត់ខុស ដូច្នោះឯង ។

(ប្រៀបអានុភាពនៃញាណ)

ក៏ឯក្នុងជនទាំងឡាយ ដែលរលឹកនូវបុព្វេនិវាសបានទាំងនេះ ការឃើញនូវបុព្វេនិវាសនៃតិត្ថិយទាំងឡាយ រមែងប្រាកដឡើង ប្រហែលគ្នានឹងពន្លឺនៃសត្វអំពិលអំពែក, ការឃើញនូវបុព្វេនិវាសរបស់បកតិសាវកទាំងឡាយ ប្រហែលគ្នានឹងពន្លឺប្រទីប, របស់ព្រះមហាសាវកទាំងឡាយ ប្រហែលគ្នានឹងពន្លឺគប់ភ្លើង, របស់ព្រះអគ្គសាវកទាំងឡាយ ប្រហែលគ្នានឹងពន្លឺនៃផ្កាយព្រឹក, របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ប្រហែលគ្នានឹងពន្លឺព្រះច័ន្ទ, របស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដឡើង ប្រហែលគ្នានឹងពន្លឺនៃមណ្ឌលនៃព្រះអាទិត្យមួយពាន់ ក្នុងរដូវប្រាំង ដែលប្រដាប់ហើយដោយពាន់នៃរស្មី ។

ឯការរលឹករឿយៗនូវបុព្វេនិវាស នៃតិត្ថិយទាំងឡាយ ជាការរលឹកឃើញ ដូចជាការធ្វើដំណើរទៅ តាមចុងនៃឈើប្រត់ របស់មនុស្សខ្វាក់ទាំងឡាយ ។ របស់ព្រះបកតិសាវកទាំងឡាយ ដូចជាការធ្វើដំណើរទៅតាមស្ពានដោយឈើប្រត់ ។ របស់ព្រះមហាសាវកទាំងឡាយ ដូចជាការធ្វើដំណើរទៅតាមស្ពាន ដោយជង្គង់ ។ របស់ព្រះអគ្គសាវកទាំងឡាយ

ដូចជាការធ្វើដំណើរទៅតាមស្ពាន ដោយរទេះ ។ របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ដូចជាការធ្វើដំណើរទៅតាមផ្លូវ ដោយស្ទួងជើងដ៏ធំ, របស់ព្រះពុទ្ធទាំងឡាយ ដូចជាការធ្វើដំណើរទៅតាមផ្លូវរទេះដ៏ធំ ។

តែក្នុងអធិការនេះ ការរលឹករឿយៗនូវបុព្វេនិវាស របស់សាវកទាំងឡាយ គឺខ្ញុំសំដែងហើយ ។ ព្រោះហេតុនោះ បានជាខ្ញុំពោលហើយថា : បទថា “អនុស្សរតិ” គឺ រលឹកទៅតាមហើយ ៗ ដោយអំណាចនៃលំដាប់នៃខន្ធ ឬ ដោយអំណាចនៃចុតិ និង បដិសន្ធិ ដូច្នេះឯង ។

(វិធីធ្វើបុព្វេនិវាសានុស្សតិ)

ព្រោះហេតុនោះ ភិក្ខុជាអាទិកម្មិកៈ អ្នកប្រាថ្នាដើម្បីរលឹករឿយៗយ៉ាងនេះ ត្រឡប់មកអំពីបិណ្ឌបាត្រវិញហើយ ក្នុងកាលជាខាងក្រោយនៃភត្ត ទៅក្នុងទីស្ងាត់ គេចចេញអំពីពួកហើយសម្ងំនៅ ចូលកាន់ឈានទាំង ៤ ដោយលំដាប់ ចេញចាកចតុត្ថជ្ឈានមានអភិញ្ញាជាទីតាំងហើយ គប្បីពិចារណាបន្ថយ ក្រោយគេបង្អស់ ។ បន្ទាប់ពីនោះ គប្បីពិចារណាកិច្ចដែលខ្លួនធ្វើហើយ អស់យប់ និង ថ្ងៃទាំងមូល ដោយលំដាប់ប្រាស (បដិលោម) យ៉ាងដូច្នេះ គឺ “ការក្រាលអាសនៈ ការចូលកាន់អាសនៈ ការរៀបចំនូវបាត្រនិងចីពរ ពេលវេលាឆាន់ ពេលមកអំពីស្រុក ពេលត្រាច់ទៅក្នុងស្រុក ដើម្បីបិណ្ឌបាត្រ ពេលចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត្រ ពេលចេញមកអំពីវត្ត ពេលថ្វាយបង្គំនូវព្រះលាននៃចេតិយ និងព្រះលាននៃព្រះពោធិព្រឹក្ស ពេលលាងនូវបាត្រ ពេលទទួលនូវបាត្រ កិច្ចដែលខ្លួនធ្វើហើយ អំពីការទទួលបាត្រ រហូតដល់ការលុបមុខ កិច្ចដែលខ្លួនធ្វើហើយ ក្នុងកាលជាទីកំចាត់បង់នូវងងឹត កិច្ចដែលខ្លួនធ្វើហើយ ក្នុងមជ្ឈិមយាម កិច្ចដែលខ្លួនធ្វើហើយ ក្នុងបឋមយាម ។

ក៏ឯកិច្ចមានប្រមាណប៉ុណ្ណេះ ជាកិច្ចប្រាកដ ដល់ចិត្តជាប្រក្រតីហ្នឹងឯង នឹងបានជាកិច្ចប្រាកដ ហាក់បីដូចជាក្រៃពេក ដល់សមាធិចិត្តក្នុងបរិកម្មតែម្តង ។ តែថាប្រសិនបើ ក្នុងកិច្ចទាំងនុ៎ះ កិច្ចតិចតួច ជាកិច្ចមិនប្រាកដទេ, ព្រះយោគី ត្រូវចូលឈានជាទីតាំង ចេញហើយ គប្បីពិចារណាម្តងទៀត ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ កិច្ចទាំងអស់ជាកិច្ចប្រាកដ ដូចជា (ក្នុងពេលងងឹត) កាលបើប្រទីបឆេះហើយ អ្វីៗក៏ប្រាកដ ដូច្នោះដែរ ។

ព្រះយោគី គប្បីពិចារណាកិច្ចដែលខ្លួនធ្វើហើយ ដោយបដិលោមហ្នឹងឯង យ៉ាងនេះគឺ ក្នុងថ្ងៃទី២ ខ្លះ ក្នុងថ្ងៃទី៣ ទី៤ និង ទី ៥ ខ្លះ ក្នុង ១០ ថ្ងៃខ្លះ ក្នុងកន្លះខែខ្លះ ក្នុង ១ ខែខ្លះ រហូតដល់ ១ ឆ្នាំខ្លះ ។ ដោយឧបាយនេះឯង ព្រះយោគី កាលពិចារណា អស់ ១០ ឆ្នាំ ២០ ឆ្នាំ ដូច្នេះជាដើម រហូតដល់បដិសន្ធិ របស់ខ្លួន ក្នុងភពនេះ គប្បីពិចារណានាមរូបដែលប្រព្រឹត្តទៅហើយ ក្នុងខណៈនៃចុតិ ក្នុងភពមុន ។ មែនពិត ភិក្ខុជាបណ្ឌិត តែងល្មមគ្រាន់ដើម្បីបើកនូវបដិសន្ធិ ហើយធ្វើនូវនាមរូប ក្នុងខណៈនៃចុតិ ឲ្យជាអារម្មណ៍ ដោយវារៈជាដំបូងតែម្តង ។ ប៉ុន្តែនាមរូបក្នុងភពមុន រលត់ហើយ មិនមានសេសសល់ នាមរូបដទៃ កើតឡើងហើយ ព្រោះហេតុណា, ព្រោះហេតុនោះ ទីនោះ ជាទីចោលនាមរូបដែលជាសជិតខាងលើ ដូចជាទីងងឹតប្រហែលបុគ្គលខ្វាក់ ដែលបុគ្គលមិនមានប្រាជ្ញា កម្រនឹងឃើញបាន ។ ទោះជាដូច្នោះ ភិក្ខុនោះក៏មិនគប្បីធ្វើការបោះបង់នូវធុរៈ ដោយគិតថា “អាត្មាអញ មិនអាចដើម្បីបើក នូវបដិសន្ធិ ហើយធ្វើនូវនាមរូប ដែលប្រព្រឹត្តទៅ ក្នុងខណៈនៃចុតិ ឲ្យជាអារម្មណ៍បាន” ដូច្នេះទេ ។ តែថា ភិក្ខុគប្បីចូលឈានជាទីតាំងនោះឯង

ឲ្យបានរឿយៗ ។ ហើយចេញអំពីឈាននោះហើយ ក៏គប្បីពិចារណាទីនោះចុះ ។ ព្រោះថា ព្រះយោគី កាលធ្វើយ៉ាងនោះ ចេញអំពីឈានជាទីតាំង ហើយមិនពិចារណា នូវឈានដែលខ្លួនពិចារណាហើយ ក្នុងកាលមុន ហើយពិចារណានូវបដិសន្ធិតែម្យ៉ាង បើកហើយ នូវបដិសន្ធិអស់កាលមិនយូរប៉ុន្មានហ្នឹងឯង គប្បីធ្វើនូវនាមរូបដែលប្រព្រឹត្តទៅ ក្នុងខណៈនៃចុតិឲ្យជាអារម្មណ៍ ឈ្មោះថា ប្រៀបដូចជាបុរសអ្នកមានកំឡាំងកាត់នូវដើមឈើធំ ដើម្បីប្រយោជន៍ដល់ហោជាងនៃបុស្បុក, កាលបើមុខប៉ូវថៅឆែបហើយ, កាលមិនអាចដើម្បីកាត់នូវដើមឈើធំបាន ក៏មិនធ្វើនូវការបោះបង់ចោលនូវធុរៈឡើយ ហើយទៅកាន់រោងជាង ឲ្យជាងធ្វើប៉ូវថៅឲ្យមុតហើយ ក៏ត្រឡប់មកវិញកាត់ម្តងទៀត, កាលបើប៉ូវថៅឆែបម្តងទៀត, ក៏ឲ្យជាងធ្វើដូច្នោះឯង ហើយកាត់សាជាថ្មី, បុរសនោះកាលកាត់យ៉ាងនេះ មិនយូរប៉ុន្មានឡើយ ក៏គប្បីផ្តួលដើមឈើធំបានមែនពិត ព្រោះឈើដែលខ្លួនកាត់ហើយ មិនមែនជារបស់ដែលគប្បីកាត់ ម្តងទៀត និង ព្រោះកាត់នូវឈើដែលមិនទាន់បានកាត់ហើយ ដូច្នោះឯង ។

សេចក្តីនេះ បណ្ឌិតគប្បីសំដែង ដោយរឿងទាំងឡាយ មានរឿងបុគ្គលអ្នកពុះឧស និង ជាងកាត់សក់ជាដើមក៏បានដែរ ។

(ការដឹងក្នុងបុព្វេនិវាសញ្ញាណ)

ក្នុងកិច្ចទាំងនោះ ញាណ ដែលធ្វើ (កិច្ច) ចាប់ផ្តើមអំពីបន្ទុយចុងក្រោយ រហូតដល់បដិសន្ធិ ឲ្យជាអារម្មណ៍ហើយ ប្រព្រឹត្តទៅ មិនបានឈ្មោះថា បុព្វេនិវាសញ្ញាណទេ ។ ក៏ប៉ុន្តែ ញាណនោះ មានឈ្មោះថា បរិកម្មសមាធិញ្ញាណ (ញាណដែលប្រកបជាមួយនឹងបរិកម្មសមាធិ) ។ អាចារ្យពួកខ្លះ ហៅថា អតីតំសញ្ញាណ (ញាណជាគ្រឿងដឹងនូវចំណែក

ដែលកន្លងទៅហើយ)” ដូច្នេះក៏មាន ។ ពាក្យ (របស់អាចារ្យពួកខ្លះ)នោះ មិនត្រូវទេ ព្រោះ (អតីតំសញ្ញាណ) សំដៅយករូបាវចរ ។ (ចំណែកឯបរិកម្មសមាធិញ្ញាណ ជាកាមាវចរ) ។

ក៏ក្នុងពេលណា មនោទ្វារាវជ្ជនៈ កន្លងនូវបដិសន្ធិ ធ្វើនាមរូបដែលប្រព្រឹត្តទៅ ក្នុងខណៈនៃចុតិ ឲ្យជាអារម្មណ៍ហើយកើតឡើង ដល់ភិក្ខុនេះ និង កាលបើមនោទ្វារាវជ្ជនៈនោះ រលត់ទៅហើយ ជវនទាំងឡាយ ៤ ឬ ៥ ធ្វើនូវនាមរូបនោះឯង ឲ្យជាអារម្មណ៍ហើយ រមែងស្ទុះទៅ, បណ្តាជវនទាំងឡាយណា ជវនទាំងឡាយមានក្នុងកាលមុន ដែលឈ្មោះថា បរិកម្មជវនជាដើម ជាកាមាវចរ, ជវនចុងក្រោយជារូបាវចរ ប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាន ជាអប្បនាចិត្ត តាមន័យដែលបានពោលហើយ ក្នុងកាលមុនហ្នឹងឯង, ក្នុងពេលនោះ ញាណណា កើតឡើង ដល់ភិក្ខុនោះ ជាមួយនឹងចិត្តនោះ ញាណនេះ ឈ្មោះថា បុព្វេនិវាសានុស្សតិញ្ញាណ ។ ភិក្ខុនោះ រលឹករឿយៗ នូវបុព្វេនិវាស មានបែបច្រើនយ៉ាង ដោយសតិដែលសម្បយុត្តហើយ ដោយញាណនោះ ។ មានបែបច្រើនយ៉ាង តើដូចម្តេចខ្លះ? ។ គឺភិក្ខុ រលឹករឿយៗ នូវបុព្វេនិវាស មានបែបច្រើនយ៉ាង ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស របូតកាលដូច្នេះ គឺ មួយជាតិក៏មាន ពីរជាតិក៏មាន ។ល។ ” ដូច្នេះឯង ។

(អត្ថន័យនៃជាតិ និង កប្ប)

(២៥២) ក្នុងបាឋៈទាំងនោះ ពាក្យថា “ឯកម្បិ ជាតឹ” សេចក្តីថា ខន្ធសន្តានមួយ មានបដិសន្ធិជាខាងដើម មានចុតិជាទីបំផុត រាប់បញ្ចូលហើយក្នុងភពមួយក៏មាន ។ សូម្បីក្នុងពាក្យថា “ទ្វេបិ ជាតិយោ” ដូច្នេះជាដើម ក៏ន័យដូចគ្នានេះដែរ ។

(សំវដ្តកប្ប វិវដ្តកប្ប)

ចំណែកក្នុងពាក្យថា “អនេកេបិ សំវដ្តកប្បេ” ដូច្នេះជាដើមបណ្ឌិតគប្បីជ្រាបដូចតទៅ ។ កប្បដែលកំពុងសាបសូន្យ បណ្ឌិតគប្បីជ្រាបថា “សំវដ្តកប្ប” កប្បដែលកំពុងចំរើន គប្បីជ្រាបថា “វិវដ្តកប្ប” ។ បណ្តាកប្បទាំងពីរនោះ សំវដ្តដ្ឋាយីកប្ប ជាកប្បគឺលោកកំណត់ហើយ ដោយសំវដ្តកប្ប ។ ព្រោះហេតុអ្វី? ។ ព្រោះសំវដ្តដ្ឋាយីកប្ប មានសំវដ្តកប្បនោះជាមូល ។ វិវដ្តដ្ឋាយីកប្ប ជាកប្បគឺលោកកំណត់ហើយ ដោយវិវដ្តកប្ប ។ កាលបើមានហេតុយ៉ាងនេះ អសង្ខេយ្យកប្បទាំងឡាយណាដែលព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់ហើយថា “ម្នាលភិក្ខុទាំងឡាយអសង្ខេយ្យ(កាលដែលយូររាប់មិនបាន)នៃកប្បនេះមាន៤ ។ អសង្ខេយ្យ ៤ គឺអ្វីខ្លះ? គឺ សំវដ្តកប្ប, សំវដ្តដ្ឋាយីកប្ប, វិវដ្តកប្ប, វិវដ្តដ្ឋាយីកប្ប” ដូច្នេះ, [១] អសង្ខេយ្យកប្បទាំងឡាយនោះ ជាកប្បដែលលោកកំណត់យកហើយ ។

(សំវដ្តកប្ប)

បណ្តាកប្បទាំងនោះ សំវដ្តកប្ប មានបីគត់ គឺ : អាបោសំវដ្តកប្ប (កប្បដែលវិនាសដោយទឹក) តេជោសំវដ្តកប្ប (កប្បដែលវិនាសដោយភ្លើង) វាយោសំវដ្តកប្ប (កប្បដែលវិនាសដោយខ្យល់) ។

(ព្រំដែននៃសេចក្តីវិនាស)

ព្រំដែននៃសេចក្តីវិនាស ក៏មាន ៣ គឺ ព្រហ្មលោកជាន់អាភស្សរា ជាន់សុភកិណ្ហា ជាន់វេហប្ផលា ។ ក្នុងកាលដែលកប្បវិនាស ដោយភ្លើង (លោក)ត្រូវភ្លើងឆេះ ខាងក្រោមអំពីអាភស្សរាព្រហ្ម ។ ក្នុងកាល

១- សុ. អំ. គាគទី ៨៣ ទំព័រទី ២ ។

ដែលកប្បវិនាសដោយទឹក (លោក) រលាយដោយទឹក ឰដ៏ខាងក្រោមសុភកិណ្ហាព្រហ្ម ។ ក្នុងកាលដែលកប្បវិនាស ដោយខ្យល់ (លោក) ខ្ចាត់ខ្ចាយ ដោយខ្យល់ ឰដ៏ខាងក្រោមវេហប្ផលាព្រហ្ម ។ តែបើពោលដោយពិស្តារ ពុទ្ធក្ខេត្តមួយ តែងវិនាស សព្វកាលដែរ ។

(ពុទ្ធក្ខេត្ត ៣)

ឈ្មោះថា ពុទ្ធក្ខេត្ត មាន ៣ យ៉ាងគឺ ជាតិក្ខេត្ត ១, អាណាខេត្ត ១, វិសយក្ខេត្ត ១ ។ បណ្តាពុទ្ធក្ខេត្តទាំងបីនោះ ជាតិក្ខេត្ត ជាខេត្តមានមួយម៉ឺនចក្រវាឡជាទីបំផុត ជាខេត្តជាទីកំរើកញាប់ញ័រ ក្នុងហេតុអស្ចារ្យទាំងឡាយ មានការចាប់បដិសន្ធិជាដើម នៃព្រះតថាគត ។ អាណាខេត្តមានសែនកោដិចក្រវាឡជាទីបំផុត គឺជាខេត្តដែលអានុភាព នៃព្រះបរិត្តទាំងឡាយនេះ គឺ រតនបរិត្ត ខន្ធបរិត្ត ធជគ្គបរិត្ត អាដានាដិយបរិត្ត និងមោរបរិត្ត ប្រព្រឹត្តទៅ ។ វិសយក្ខេត្ត ជាខេត្តមិនមានទីបំផុត មិនមានប្រមាណដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា "ឬថា តថាគតគប្បីប្រាថ្នាដល់ត្រឹមណាក៏បាន [១] " ដូច្នេះជាដើម ជាខេត្តដែលព្រះតថាគតប្រាថ្នានូវហេតុណាៗ ក៏ទ្រង់ជ្រាបនូវហេតុនោះៗ ។

ក្នុងពុទ្ធក្ខេត្តទាំងឡាយ ៣ នេះ ដូចពោលមកនេះ ខេត្តមួយ គឺអាណាខេត្ត តែងវិនាស ។ តែថាកាលបើអាណាខេត្តនោះវិនាស, សូម្បីជាតិក្ខេត្ត ក៏ជាខេត្តវិនាសទៅផងដែរ ។ ក៏ពុទ្ធក្ខេត្តទាំង ២ នោះ កាលវិនាស ក៏តែងវិនាស ក្នុងទីជាមួយគ្នាដែរ ។ សូម្បីកាលតាំងនៅ ក៏តាំងនៅ ក្នុងទីជាមួយគ្នាដែរ ។ សេចក្តីវិនាស និង ការតាំងនៅ នៃពុទ្ធក្ខេត្តនោះ បណ្ឌិតគប្បីជ្រាប ដូចតទៅនេះ :

១- សុ. អំ. គាគទី ៤១ ទំព័រទី ៣១៥ ។

(តេជោសំវដ្តកប្ប)

សេចក្តីថា ក្នុងសម័យដែលកប្បវិនាសដោយភ្លើង ។ ភ្លៀងធំញ៉ាំងកប្បឲ្យវិនាស តាំងឡើង ចាប់តាំងអំពីដើមហ្នឹងឯង បង្អុរភ្លៀងមួយមេធំអស់មួយសែនកោដិចក្រវាឡ ។ មនុស្សទាំងឡាយ ត្រេកអរហើយ នាំយកពូជគ្រប់យ៉ាងទៅសាបព្រោះ ។ ប៉ុន្តែ លុះសន្ទូងទាំងឡាយដុះបានល្មមគោស៊ីបានហើយ, មហាមេឃនោះ ក៏ស្រែកគ្រហឹម ដូចជាសម្រែកនៃសត្វលា មិនបង្អុរចុះនូវទឹកភ្លៀងសូម្បីមួយតំណក់ឡើយ ។ ក្នុងកាលនោះ ភ្លៀងដាច់ស្រឡះហើយ ។ មែនពិត ព្រះមានព្រះភាគ ទ្រង់សំដៅយកភ្លៀងដាច់សូន្យនេះ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មានសម័យដែលភ្លៀងមិនបង្អុរចុះ អស់ច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំច្រើនសែនឆ្នាំ [១]" ដូច្នេះ ។ សត្វទាំងឡាយដែលរស់នៅអាស្រ័យទឹកភ្លៀង ធ្វើកាលកិរិយាហើយទៅកើត ក្នុងព្រហ្មលោក, ពួកទេវតា ដែលរស់នៅព្រោះអាស្រ័យនូវផ្កាឈើ និង ផ្លែឈើ ចុតិហើយក៏ទៅកើត ក្នុងព្រហ្មលោកដែរ ។ កាលបើពេលវេលាដ៏វែង កន្លងទៅ ដោយការដាច់ភ្លៀងយ៉ាងនេះ ទឹកក្នុងទីនោះៗ ក៏ដល់នូវការអស់រលីង ។ គ្រានោះ ត្រីនិងអណ្តើកទាំងឡាយ ក៏ស្លាប់ដោយលំដាប់ ទៅកើតក្នុងព្រហ្មលោកខ្លះសូម្បីសត្វនរកទាំងឡាយ ស្លាប់ហើយ ក៏ទៅកើតក្នុងព្រហ្មលោកដែរ ។ អាចារ្យពួកខ្លះ ពោលថា "បណ្តាសត្វទាំងនោះ ពួកសត្វនរក វិនាសព្រោះភាវៈនៃការប្រាកដឡើង នៃព្រះអាទិត្យ ទី៧ " ដូច្នេះ ក៏មាន ។

សួរថា "ការកើត ក្នុងព្រហ្មលោក វៀរចាកឈាន មិនមានទេ, ក៏បណ្តាសត្វទាំងនោះ សត្វទាំងឡាយពួកខ្លះ ត្រូវសេចក្តីអត់ឃ្លានបៀត

១- សុ. អំ. គាគទី ៤៧ ទំព័រទី ១៨៤ ។

បៀនហើយ សត្វពួកខ្លះជាសត្វអភ័ព្វ ចាកការបានឈាន, សត្វទាំងនោះ ទៅកើត ក្នុងព្រហ្មលោកនោះ យ៉ាងដូចម្ដេចកើត?" ដូច្នេះ ។ ឆ្លើយថា "សត្វទាំងនោះ ទៅកើត ក្នុងព្រហ្មលោកបាន ដោយអំណាចឈានដែលខ្លួនបានហើយក្នុងទេវលោក" ។ មែនពិត ក្នុងកាលនោះ ពួកកាមាវចរទេវតា ឈ្មោះថាជាអ្នកកៀគរនូវសត្វលោក ដឹងថា "អំណើះតទៅ មួយសែនឆ្នាំ នឹងមានការប្រល័យកប្ប" ដូច្នេះ មានក្បាលសក់របូតហើយ មានសក់រំសាយហើយ មានមុខស្រែកយំ យកដៃជូតទឹកភ្នែក ស្លៀកសំពត់ពណ៌ក្រហម ជាអ្នកទ្រទ្រង់នូវភេទនៃបុគ្គលដ៏ចំឡែកក្រៃពេក ត្រាច់ទៅក្នុងផ្លូវមនុស្ស ប្រកាសប្រាប់ យ៉ាងនេះថា "ម្នាលអ្នកនិទ៌ុក្ខទាំងឡាយៗ អំណើះមួយសែនឆ្នាំ អំពីឆ្នាំនេះទៅ នឹងមានការប្រល័យកប្ប, លោកនេះនឹងវិនាស សូម្បីមហាសមុទ្រ ក៏នឹងរីងស្ងួត, មហាប្រឹថពី និង ភ្នំសិនេរុរាជ ក៏នឹងត្រូវភ្លើងឆេះឡើង នឹងវិនាសទៅ, សេចក្ដីវិនាស នឹងមានដរាបដល់ព្រហ្មលោក, ម្នាលអ្នកនិទ៌ុក្ខទាំងឡាយអើយ អ្នកទាំងឡាយចូរចំរើននូវមេត្តា ម្នាលអ្នកនិទ៌ុក្ខទាំងឡាយអើយ អ្នកទាំងឡាយ ចូរចំរើននូវករុណា ចូរចំរើននូវមុទិតា ចូរចំរើននូវឧបេក្ខា ចូរអ្នកទាំងឡាយបម្រើនូវមាតា ចូរបម្រើនូវបិតា អ្នកទាំងឡាយចូរជាអ្នកមានការប្រព្រឹត្តិក្រោតក្រែងដល់បុគ្គលជាច្បងក្នុងត្រកូល" ដូច្នេះ ។ មនុស្សទាំងឡាយនិងភុម្មទេវតាទាំងឡាយ ដោយច្រើន មានសេចក្ដីតក់ស្លុតដ៏ធំកើតឡើងហើយ ព្រោះបានស្ដាប់នូវពាក្យ របស់កាមាវចរទេវតាទាំងនោះ ជាអ្នកមានចិត្តទោរទន់ទៅវិញទៅមករកគ្នា ធ្វើបុណ្យទាំងឡាយ មានមេត្តាជាដើម (ស្លាប់ទៅ) ក៏រមែងទៅកើត ក្នុងព្រហ្មលោក ។ ទេវតាទាំងនោះ សោយនូវសុធាភោជន៍ដ៏ជាទិព្វហើយ ធ្វើបរិកម្មក្នុងវាយោកសិណ ទើប

បាននូវឈាន ក្នុងទេវលោកនោះ ។ ចំណែកសត្វទាំងឡាយ ដទៃអំពីអបាយិកសត្វនោះ កើតក្នុងទេវលោក ដោយកម្មដែលខ្លួនគប្បីសោយតៗ គ្នា ។ មែនពិត ឈ្មោះថាសត្វដែលអន្ទោលក្នុងសំសារ ដែលប្រាសចាកកម្មដែលខ្លួនគប្បីសោយជាបន្តបន្ទាប់ មិនមានទេ ។ សូម្បីសត្វទាំងនោះ ក៏បានចំពោះនូវឈាន ក្នុងទេវលោកនោះ ដូចគ្នាដែរ ។ សត្វទាំងឡាយសូម្បីទាំងពួង ក៏ទៅកើត ក្នុងព្រហ្មលោកបាន ដោយអំណាចនៃឈានដែលខ្លួនបានហើយ ក្នុងទេវលោក ដោយប្រការដូច្នេះឯង ។

(កើតព្រះអាទិត្យ ៧)

មួយទៀត បន្ទាប់អំពីការរាំងភ្លៀង ដោយអំណើះកាលដ៏វែង ព្រះអាទិត្យ ទី២ ក៏កើតប្រាកដឡើង ។ សមដូចជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សម័យនោះមាន" ដូច្នេះជាដើម ។ ព្រះអាទិត្យ ទី៧ បណ្ឌិតគប្បីសំដែង ឲ្យពិស្ដារចុះ ។ លុះដល់ព្រះអាទិត្យទី២ នោះ កើតប្រាកដហើយ, ការកំណត់នូវពេលយប់ ក៏មិនប្រាកដការកំណត់នូវពេលថ្ងៃ ក៏មិនប្រាកដដែរ ។ ព្រះអាទិត្យមួយ រះឡើង ។ ព្រះអាទិត្យមួយ លិចបាត់ទៅ ។ លោក មានកំដៅមកអំពីព្រះអាទិត្យមិនដាច់សោះ ។ ក៏សុរិយទេវបុត្រ មាន ក្នុងព្រះអាទិត្យជាប្រក្រតី យ៉ាងណា, ក្នុងព្រះអាទិត្យដែលញ៉ាំងកប្បឲ្យវិនាស មិនមានសុរិយទេវបុត្រយ៉ាងនោះទេ ។ ក្នុងព្រះអាទិត្យទាំង ២ នោះ កាលបើព្រះអាទិត្យ ជាប្រក្រតី កំពុងប្រព្រឹត្តទៅ, ពពកក្ដី អណ្ដាតភ្លើងក្ដី តែងត្រាច់ទៅ ឰដ៏អាកាស ។ កាលបើព្រះអាទិត្យដែលញ៉ាំងកប្បឲ្យវិនាស ប្រព្រឹត្តទៅ, ផ្ទៃនៃអាកាស មានផ្សែង និងពពកទៅប្រាសហើយ ជាផ្ទៃភ្លឺស្រឡះ ដូចជាមណ្ឌលនៃកញ្ចក់ ។ លើកលែងតែស្ទឹងធំទាំង ៥ ចេញ ទឹកក្នុងទី

ទាំងឡាយ មានស្ទឹងតូចដ៏សេសជាដើម រីងស្ងួតអស់ ។

បន្ទាប់អំពីនោះ ដោយអំណើះទៅនៃកាលដ៏វែង ស្ទឹងធំទាំងឡាយផងដែរ ក៏រីងស្ងួតអស់ ព្រោះការកើតប្រាកដឡើង នៃព្រះអាទិត្យ ទី ៣ ណា, ព្រះអាទិត្យ ទី ៣ នោះ ក៏កើតប្រាកដឡើង ។

តអំពីនោះមកទៀត ដោយអំណើះទៅនៃកាលដ៏វែង មហាស្រះទាំង ៧ នេះ គឺ: ស្រះសីហបាតនៈ ស្រះហំសបាតនៈ ស្រះកណ្ណមុណ្ឌកៈ ស្រះរថការៈ ស្រះអនោត្តៈ ស្រះឆទ្ទន្តៈ ស្រះកុណាលៈ ដែលជាប្រភពនៃស្ទឹងដ៏ធំ ក្នុងព្រៃហិមពាន្ត រីងស្ងួតអស់ ព្រោះការកើតប្រាកដឡើងនៃព្រះអាទិត្យ ទី ៤ ណា, ព្រះអាទិត្យ ទី ៤ នោះ ក៏កើតប្រាកដឡើង ។

បន្ទាប់អំពីនោះមកទៀត ដោយអំណើះទៅនៃកាលដ៏វែង ទឹកសូម្បីត្រឹមតែទទឹកថ្នាំងនៃម្រាមដៃ ក៏មិនដក់នៅក្នុងមហាសមុទ្រ ដោយលំដាប់ ព្រោះការកើតប្រាកដឡើងនៃព្រះអាទិត្យ ទី ៥ ណា, ព្រះអាទិត្យ ទី ៥ នោះ ក៏កើតប្រាកដឡើង ។

បន្ទាប់អំពីនោះមកទៀត ដោយអំណើះទៅនៃកាលដ៏វែង ចក្រវាឡទាំងមូលមានផ្សែងតែមួយ មានជ័រគ្របសង្កត់ហើយដោយផ្សែង ព្រោះភាពកើតប្រាកដនៃព្រះអាទិត្យទី ៦ ណា, ព្រះអាទិត្យទី ៦ នោះ កើតប្រាកដឡើង ។ ក៏ចក្រវាឡនេះ យ៉ាងណា, សូម្បីសែនកោដិចក្រវាឡក៏យ៉ាងនោះដែរ ។

បន្ទាប់អំពីនោះមកទៀត ដោយអំណើះទៅនៃកាលដ៏វែង ចក្រវាឡទាំងមូល ជាចក្រវាឡមានអណ្តាតភ្លើងតែមួយ ជាមួយនឹងសែនកោដិចក្រវាឡទាំងឡាយ ព្រោះភាពប្រាកដឡើង នៃព្រះអាទិត្យ ទី ៧ ណា, ព្រះអាទិត្យ ទី ៧ នោះ កើតប្រាកដឡើង ។ សូម្បីកំពូលភ្នំសិនេរុទាំងឡាយ មានកំពូលខ្ពស់ ១០០ យោជន៍ជាដើម ក៏រលេះបាត់សូន្យហើយក្នុងអាកាសនោះឯង ។ អណ្តាតភ្លើងនោះ ឆាបឡើងចាប់យកទេវលោកជាន់ចាតុម្មហារាជិកា ។ អណ្តាតភ្លើងនោះឆេះនូវវិមានមាស វិមានរតនៈ និង វិមានកែវមណីទាំងឡាយ ក្នុងទេវលោក ជាន់ចាតុម្មហារាជិកានោះហើយ ក៏ចាប់យកភពតាវត្តឹង្ស ។ ដោយឧបាយនេះឯង អណ្តាតភ្លើងរាលចាប់យក រហូតដល់ (ព្រហ្មលោក) ជាន់បឋមជ្ឈានភូមិ ។ អណ្តាតភ្លើងនោះ ឆេះនូវព្រហ្មលោកទាំង ៣ ក្នុងបឋមជ្ឈានភូមិនោះអស់ហើយទល់អាភស្សរាព្រហ្ម ទើបឈប់ ។ សង្ខារ សូម្បីដ៏ល្អិត មានដរាបណា, អណ្តាតភ្លើងនោះ ក៏មិនរលត់ ដរាបនោះ ។ ក៏ព្រោះអស់ទៅនៃសង្ខារទាំងពួង អណ្តាតភ្លើងនោះ ទើបរលត់ទៅ មិនឲ្យសេសសល់អ្វីៗ សូម្បីតែផេះ ដូចជាអណ្តាតភ្លើងដែលឆេះនូវទឹកដោះថ្លា និងប្រេងដូច្នោះឯង ។ អាកាសខាងលើ ព្រមទាំងអាកាសខាងក្រោម ក៏កើតងងឹតដ៏ធំតែមួយ ។

(រយៈពេលដែលវិនាស)

បន្ទាប់ពីនោះមក ដោយអំណើះទៅនៃកាលដ៏វែង មហាមេឃតាំងឡើងហើយ ជាដំបូង ក៏បង្អុរចុះនូវភ្លៀងដ៏ល្អិត កាលញុំាងភ្លៀងឲ្យធ្លាក់ចុះ ដោយទ-ទឹកទាំងឡាយ ប៉ុនទងឈូក ប៉ុនឈើប្រត់ ប៉ុនអង្រែ និងប៉ុនដើមត្នោតជាដើម ដោយលំដាប់ ញុំាងទីដែលភ្លើងឆេះហើយទាំងអស់ ក្នុងសែនកោដិចក្រវាឡ ឲ្យពេញហើយ ទើបបាត់ទៅ ។ ខ្យល់ទ្រនូវទឹកនោះ ខាងក្រោមផង ខាងទទឹងផង ធ្វើឲ្យទៅជាដុំ ។ ទឹកនោះមូល ប្រហែលគ្នានឹងដំណក់ទឹក លើស្លឹកឈូក ។

បើមានពាក្យចោទសួរថា "ខ្យល់ ធ្វើនូវគំនរនៃទឹកដ៏ធំដល់ម្ល៉ោះ ឲ្យជាដុំបាន យ៉ាងដូចម្តេច?" ។ គប្បីឆ្លើយថា "ធ្វើបាន ព្រោះទឹកបើកនូវ

ប្រហោងឲ្យ” ។ មែនពិត ទឹកនោះឲ្យនូវប្រហោង ដល់ខ្យល់នោះ ក្នុងទីនោះៗ ។ ទឹកនោះ ត្រូវខ្យល់ប្រមូលផ្តុំ ធ្វើឲ្យទៅជាដុំ យ៉ាងនោះ ក៏អស់ទៅ ហួតចុះទៅខាងក្រោម ដោយលំដាប់ ។ កាលបើទឹកហួតចុះហើយៗ ព្រហ្មលោក ក៏កើតប្រាកដឡើង ក្នុងកន្លែងដែលធ្លាប់ជាព្រហ្មលោក និងទេវលោកទាំងឡាយ ក៏កើតឡើងប្រាកដ ក្នុងកន្លែងដែលធ្លាប់ជាកាមាវចរទេវលោក ៤ ជាន់ ពួដ៏ខាងលើ ។ តែថា កាលបើទឹកហួតចុះហើយ មកដល់ទីដែលធ្លាប់ជាផែនដីមកពីមុន, ខ្យល់ដ៏មានកំឡាំងក៏កើតឡើង ។ ខ្យល់ដ៏មានកំឡាំងនោះ តែងស្ទះទុកនូវទឹកនោះ ធ្វើមិនឲ្យជ្រួតជ្រាបបាន ដូចទឹកដែលឋិតនៅក្នុងធម្មក្រក ដែលបុគ្គលបិទមាត់ជិតហើយដូច្នោះ ។ ទឹកមានរសផ្អែម ដល់នូវការអស់ទៅ ញុំាងផែនដីមានរស ពួដ៏ខាងលើឲ្យកើតឡើងព្រម ។ ផែនដីមានរសនោះ ជាវត្ថុដែលដល់ព្រមហើយ ដោយពណ៌ និង ដល់ព្រមដោយក្លិន និង រស ដូចជាខ្ទិះ ពួដ៏ខាងលើនៃបាយបាយាសដែលមិនមានទឹកដូច្នោះឯង ។

(អាភស្សរព្រហ្មសោយរសផែនដីជាអាហារ)

ក៏ក្នុងកាលនោះ សត្វទាំងឡាយ ដែលកើតមុនគេ ក្នុងអាភស្សរព្រហ្មលោក ចុតិ ចាកអាភស្សរព្រហ្មលោកនោះ ព្រោះអស់អាយុ ឬអស់បុណ្យ ជាឧបបាតិកៈ តែងចូលទៅកើតក្នុងលោកនេះ ។ សត្វទាំងនោះ ជាអ្នកមានរស្មីភ្លឺដោយខ្លួនឯង ត្រាច់ទៅក្នុងអាកាសបាន ។ សត្វទាំងនោះ ភ្លក្សហើយនូវផែនដីមានរសនោះ ត្រូវតណ្ហាគ្របសង្កត់ហើយ ព្យាយាមប្រើងប្រែង ដើម្បីធ្វើឲ្យជាពំនូតហើយបរិភោគ តាមន័យដែលលោកពោលហើយ ក្នុងអគ្គញ្ញសូត្រឯណោះ ។ គ្រានោះ រស្មីភ្លឺដោយខ្លួនឯង របស់សត្វទាំងនោះក៏បាត់ទៅ ងងឹតក៏កើតមាន ។ សត្វទាំងនោះ

ឃើញនូវងងឹត ក៏ភ័យខ្លាច ។ លំដាប់នោះ មណ្ឌលនៃព្រះអាទិត្យ ទំហំ ៥០ យោជន៍ ដែលញុំាងភ័យ ឲ្យវិនាសហើយ បង្កើតនូវភាពក្លៀវក្លា ដល់សត្វទាំងនោះ កើតឡើងប្រាកដ ។ សត្វទាំងនោះឃើញនូវមណ្ឌលនៃព្រះអាទិត្យនោះហើយ ក៏មានចិត្តត្រេកអរថា “យើងទាំងឡាយ បាននូវពន្លឺហើយ” ទើបធ្វើនូវឈ្មោះនៃមណ្ឌលព្រះអាទិត្យនោះថា “សុរិយៈ” ហ្នឹងឯង ព្រោះពាក្យដែលសត្វទាំងឡាយនោះពោលថា “មណ្ឌលនៃពន្លឺដ៏វិសេសដែលញុំាងភ័យ របស់ពួកយើងដែលភ័យខ្លាច ឲ្យវិនាសហើយ ញុំាងភាពក្លៀវក្លាឲ្យកើតឡើង រះឡើងហើយ ព្រោះហេតុនោះ មណ្ឌលនៃពន្លឺដ៏វិសេសនោះ ចូរឈ្មោះសុរិយៈ” ដូច្នេះ ។

(កើតមានព្រះច័ន្ទ)

លំដាប់នោះ កាលបើព្រះអាទិត្យ ធ្វើនូវពន្លឺ ក្នុងវេលាថ្ងៃហើយ លិចបាត់ទៅ, ពួកសត្វទាំងនោះ ក៏ភ័យខ្លាចម្តងទៀត ដោយស្រែកយំថា “ពួកយើងបានហើយនូវពន្លឺឯណា ពន្លឺរបស់ពួកយើងនោះឯង បានបាត់ទៅហើយ” ដូច្នេះ ។ សត្វទាំងនោះ តែងមានសេចក្តីរិះគិត យ៉ាងនេះថា “គប្បីជាការប្រពៃណាស់ហ្ន៎ ថាបើពួកយើងគប្បីបានពន្លឺដទៃទៀត! ” ។ មណ្ឌលនៃព្រះច័ន្ទ ទំហំ ៤៩ យោជន៍ ហាក់ដូចជាដឹងនូវចិត្ត របស់សត្វទាំងនោះ កើតឡើងប្រាកដ ។ សត្វទាំងនោះឃើញនូវមណ្ឌលនៃព្រះច័ន្ទនោះហើយ មានចិត្តត្រេកអរក្រៃពេក ហួសប្រមាណ ក៏នាំគ្នាដាក់ឈ្មោះមណ្ឌលព្រះច័ន្ទនោះថា “ព្រះច័ន្ទ” ដូច្នេះហ្នឹងឯង ព្រោះពាក្យដែលពួកគេពោលហើយថា “មណ្ឌលពន្លឺដ៏វិសេសនេះ ហាក់ដូចជាដឹងសេចក្តីពេញចិត្ត របស់ពួកយើង រះឡើងហើយ ព្រោះហេតុនោះ មណ្ឌល នៃពន្លឺដ៏វិសេសនេះ ចូរជាព្រះច័ន្ទ” ដូច្នេះ ។

(កើតមាននក្ខត្តឫក្ស)

កាលបើព្រះច័ន្ទនិងព្រះអាទិត្យ កើតឡើងប្រាកដយ៉ាងដូច្នេះហើយ, នក្ខត្តឫក្ស (ផ្កាយ) ទាំងឡាយ ក៏កើតឡើងប្រាកដ ។ ចាប់តាំងអំពីនោះមក យប់ និង ថ្ងៃ ក៏កើតប្រាកដ និង ខែ កន្លះខែ រដូវ និង ឆ្នាំទាំងឡាយ ក៏កើតប្រាកដ ដោយលំដាប់ ។

មួយទៀត ក្នុងថ្ងៃដែលព្រះច័ន្ទ និង ព្រះអាទិត្យ កើតឡើងប្រាកដនុ៎ះឯង ភ្នំសិនេរុ ភ្នំចក្រវាឡ និង ភ្នំហិមពាន្ត ក៏កើតឡើងប្រាកដ ។ ក៏ឯភ្នំទាំង ៣ នោះ កើតឡើងប្រាកដ ក្នុងថ្ងៃពេញបូណ៌មី ខែផល្គុណ មែនពិត មិនមុនមិនក្រោយគ្នាឡើយ ។ សួរថា ព្រោះហេតុអ្វី? ។ ឆ្លើយថា កាលបើបាយនៃអង្ករថ្លៃ ដែលគេចំអិន តាំងឡើងនូវពពុះទាំងឡាយដោយដំណាលគ្នាតែម្តង, ប្រទេសទាំងឡាយពួកមួយ ជាពំនូកៗ ពួកមួយជាទំនាបៗ ពួកមួយរាបស្មើៗ យ៉ាងណាមិញ, ប្រទេសទាំងនោះក្នុងទីខ្ពស់ៗ កើតជាភ្នំទាំងឡាយ, ក្នុងទីទំនាបៗ គឺជាសមុទ្រទាំងឡាយ, ក្នុងទីរាបស្មើៗ គឺទៅជាទ្វីបទាំងឡាយ ក៏យ៉ាងនោះឯង ។

(អាហារដ៏ប្រណីតក៏បាត់ទៅ)

គ្រានោះ កាលបើសត្វទាំងនោះ បរិភោគនូវផែនដីមានរស, សត្វពួកខ្លះ មានសម្បុរល្អ សត្វពួកខ្លះ មានសម្បុរអាក្រក់ ដោយលំដាប់ ។ បណ្តាសត្វទាំងនោះ ពួកសត្វមានសម្បុរល្អ តែងមើលងាយនូវពួកសត្វដែលមានសម្បុរអាក្រក់ ។ ផែនដីមានរសនោះឯង ក៏អន្តរធានបាត់ទៅព្រោះបច្ច័យនៃអតិមានះ (ការប្រកាន់ក្រៃពេក) នៃសត្វទាំងឡាយនោះ ។ ក្រមរផែនដី កើតប្រាកដ ។ បន្ទាប់មក ដោយន័យនោះឯង សូម្បីក្រមរផែនដីនោះ របស់ពួកគេ ក៏អន្តរធានបាត់ទៅដែរ ។ វល្លិដ៏ចំរើនមានរស

ឆ្ងាញ់ ក៏កើតប្រាកដ ។ ដោយន័យដូចគ្នានោះដែរ វល្លិដ៏ចំរើន មានរសឆ្ងាញ់នោះឯង ក៏អន្តរធានបាត់ទៅ ។ ស្រូវសាលី ជារបស់មិនបាច់ដាំដោយខុស មិនមានកន្ទក់ មិនមានអង្កាម មានក្លិនក្រអូប មានផ្លែជាអង្ករកើតឡើងប្រាកដ ។ បន្ទាប់មក ភាជនៈទាំងឡាយក៏កើតឡើង ដល់សត្វទាំងនោះ ។ សត្វទាំងនោះ ដាក់ស្រូវសាលី ក្នុងភាជនៈហើយ ទុកលើខ្នងនៃផ្ទាំងថ្ម ។ អណ្តាតភ្លើង តាំងឡើងដោយខ្លួនឯងហើយ ចំអិននូវអង្ករស្រូវសាលីនោះឯង ។ អង្ករនោះ ក្លាយទៅជាបាយ ប្រហែលគ្នានឹងផ្កាម្លិះរួតមែនពិត ។ បាយនោះ មិនមានកិច្ចដែលត្រូវធ្វើ ដោយសម្ល ឬដោយម្ហូបក្រៀមទេ ។ ពួកសត្វទាំងនោះ ជាអ្នកប្រាថ្នាដើម្បីបរិភោគ នូវរសណាៗ បាយក៏មានរសនោះៗ តែម្តង ។

(មូត្រ,ករីស,ទ្វារ និង មេថុន កើតមាន)

កាលបើសត្វទាំងនោះ បរិភោគនូវអាហារដ៏គ្រោតគ្រាតនោះ មូត្រ និង ករីស ក៏កើតព្រម ចាប់ដើមពីការបរិភោគអាហារនោះ ។ គ្រានោះមុខនៃដំបៅទាំងឡាយ ក៏បែកចេញមក ដើម្បីប្រយោជន៍ដល់កិរិយាហូរចេញនូវមូត្រ និង ករីសនោះ របស់សត្វទាំងនោះ ។ ភាពជាបុរសក៏កើតប្រាកដ ដល់បុរស ឯភាពជាស្ត្រី ក៏កើតប្រាកដ ដល់ស្ត្រីដែរ ។ បានឮមកថា បណ្តាបុរស និងស្ត្រីទាំងនោះ ស្ត្រីសំឡឹងមើលបុរស និង បុរសសំឡឹងមើលស្ត្រី ហួសកំណត់ ។ ការក្រហល់ក្រហាយព្រោះកាម កើតមាន ដល់សត្វទាំងនោះ ព្រោះការសំឡឹងមើលហួសកំណត់ជាបច្ច័យ ។ បន្ទាប់ពីនោះមក សត្វទាំងនោះ ក៏សេពនូវមេថុនធម្ម ។ ព្រោះការសេពនូវអសទ្ធម្មជាបច្ច័យ ពួកគេទាំងនោះ ត្រូវពួកវិញ្ញូជន តិះដៀល បៀតបៀន ធ្វើនូវផ្ទះទាំងឡាយ ព្រោះហេតុនៃការបិទបាំងនូវអសទ្ធម្មនោះ ។

(កើតមានអទិន្នាទាន)

សត្វទាំងឡាយនោះ នៅគ្រប់គ្រងផ្ទះ ដល់នូវទិដ្ឋានុគតិ នៃសត្វអ្នកប្រកបដោយជាតិជាអ្នកខ្ជិលច្រអូសណាមួយ ទើបធ្វើការសន្សំ ដោយលំដាប់ ។ ចាប់ផ្តើមអំពីពេលនោះមក ទាំងកន្ទក់ទាំងអង្កាម រួបរឹតនូវអង្ករ ។ សូម្បីទីដែលគេច្រូតហើយក៏មិនត្រឡប់ដុះឡើងវិញដែរ ។ សត្វទាំងនោះ អង្គុយប្រជុំគ្នា ដកដង្ហើមធំថា "ម្នាលគ្នាយើងទាំងឡាយ ធម៌ទាំងឡាយដ៏លាមក កើតប្រាកដ ក្នុងសត្វទាំងឡាយហើយហ្ន៎, មែនពិតក្នុងកាលមុន ពួកយើងជាសត្វកើតដោយឈានចិត្ត(មនោមយៈ)" ដូច្នេះជាដើម ។ ពាក្យទាំងពួង បណ្ឌិតគប្បីសំដែងឲ្យពិស្តារ តាមន័យដែលលោកពោលហើយ ក្នុងអគ្គញ្ញសូត្រចុះ [១] ។ តពីនោះមក សត្វទាំងនោះ ទើបរៀបចំភ្លឺស្រែ(ព្រំដែន) ។ គ្រានោះ សត្វដទៃទៀត កាន់យកនូវចំណែក របស់សត្វមួយទៀត ដែលគេមិនបានឲ្យហើយ ។ សត្វទាំងនោះ ផ្ដាសានូវសត្វនោះ អស់វារៈពីរដង ក្នុងលើកទីបី ក៏ប្រហារដោយគ្រឿងប្រហារទាំងឡាយ មានបាតដៃ ដុំដី និង ដំបងជាដើម ។

(កើតមានព្រះរាជាដំបូង)

កាលបើការលួចទ្រព្យ ការតិះដៀលគ្នា ការនិយាយកុហក និងការកាន់យកនូវដំបង កើតឡើងហើយ, សត្វទាំងនោះ ក៏មកប្រជុំ ប្រឹក្សាគ្នាថា "បើដូច្នោះមានតែពួកយើងគប្បីសន្មតនូវសត្វមួយរូប, ក្នុងចំណោមពួកយើង សត្វណា គប្បីបង្ក្រាបនូវសត្វដែលខ្វួនគប្បីបង្ក្រាប គប្បីតិះដៀល នូវសត្វដែលខ្វួនគប្បីតិះដៀល គប្បីបណ្តេញចេញ នូវសត្វដែលខ្វួនគប្បីបណ្តេញចេញបាន ដោយប្រពៃ, មួយទៀត យើងទាំងឡាយ

១- អគ្គញ្ញសូត្រ មាននៅក្នុង សុ. ទី. បា. គាគទី ១៨ ទំព័រទី ៥៣ ។

នឹងបន្ថែមឲ្យនូវចំណែកនៃស្រូវសាលីដល់សត្វនោះ" ដូច្នេះៗ ក៏កាលបើសត្វទាំងឡាយ ធ្វើការប្រជុំគ្នាយ៉ាងនេះស្រេចហើយ, ព្រះដ៏មានព្រះភាគអង្គនេះឯង ជាព្រះពោធិសត្វ ក្នុងកប្បនេះមុនគេ សម័យនោះ ព្រះអង្គជាអ្នកមានព្រះរូបល្អក្រៃលែងជាង ក្នុងសត្វទាំងឡាយនោះ ។ ព្រះអង្គជាអ្នកគឺបុគ្គលគួរគយគន់ជាង និង ជាអ្នកមានស័ក្តិច្រើនជាង ទ្រង់ដល់ដោយពុទ្ធិ ទ្រង់អាចដើម្បីធ្វើនូវការផ្ចុញផ្ចាល់ និង ការផ្គងឡើង ។ សត្វទាំងនោះ ក៏ចូលទៅរកព្រះអង្គ អង្វរករហើយក៏បានសន្មតឡើង ។ ព្រះពោធិសត្វនោះ ប្រាកដហើយ ដោយព្រះនាមទាំងឡាយ ៣ គឺ ព្រះនាមថា "មហាសម្មតៈ" ព្រោះជាអ្នកដែលមហាជននោះ សន្មតឡើងហើយ, ព្រះនាមថា "ក្សត្រ" ព្រោះព្រះអង្គជាអធិបតីជាធំ លើខេត្តទាំងឡាយ, ព្រះនាមថា "រាជា" ព្រោះទ្រង់ញ៉ាំងអ្នកដទៃឲ្យត្រេកអរ ដោយព្រះធម៌ដ៏ស្មើគ្នា ។ ក៏តំណែងឯណាជាតំណែងដ៏អស្ចារ្យក្នុងលោក, ព្រះពោធិសត្វហ្នឹងឯង ទ្រង់ជាបុរសមុនគេ ក្នុងតំណែងនោះ ។ កាលបើមណ្ឌលក្សត្រលើកតាំងព្រះពោធិសត្វ ឲ្យជាអ្នកមុនគេ យ៉ាងនេះហើយ, សូម្បីវណ្ណៈទាំងឡាយមានវណ្ណៈព្រាហ្មណ៍ជាដើម ក៏កើតឡើង ដោយលំដាប់ ។

(រយៈកាលនៃអសង្ខេយ្យកប្បក្នុងតេជោសំវដ្តៈ)

ក្នុងកប្បទាំង ៤ នោះ ចាប់តាំងអំពីមហាមេឃដែលញ៉ាំងកប្បឲ្យវិនាស រហូតដល់ការដាច់ស្រឡះនៃអណ្តាតភ្លើង នេះជាអសង្ខេយ្យមួយហៅថា "សំវដ្តកប្ប" ។ ចាប់តាំងអំពីអណ្តាតភ្លើង ដែលញ៉ាំងកប្បឲ្យវិនាស ដាច់ស្រឡះអស់ទៅ រហូតដល់កកើតបានជាមហាមេឃ ដែលញ៉ាំងសែនកោដិចក្រវាឡឲ្យពេញ នេះជាអសង្ខេយ្យទី ២ លោកហៅថា "សំវដ្តដ្ឋាយីកប្ប" ។ ចាប់តាំងអំពីកកើតមហាមេឃមក រហូតដល់ការ

កើតប្រាកដឡើង នៃព្រះច័ន្ទ និង ព្រះអាទិត្យនេះ ជាអសង្ខេយ្យ ទី៣ លោកឲ្យឈ្មោះថា "វិវដ្តកប្ប" ។ ចាប់តាំងអំពីការកើតប្រាកដឡើង នៃព្រះច័ន្ទ និង ព្រះអាទិត្យ មក រហូតដល់មហាមេឃប្រល័យកប្ប ម្តង ទៀត នេះជាអសង្ខេយ្យ ទី៤ លោកហៅថា "វិវដ្តដ្ឋាយីកប្ប" ។ បួន អសង្ខេយ្យនេះ ជាមហាកប្បមួយ ។

ការវិនាស ដោយភ្លើង និង ការតាំងឡើងថ្មី (នៃពុទ្ធក្ខេត្ត) បណ្ឌិត គប្បីជ្រាប តាមន័យដែលពោលមកនេះ ជាចម្បង ។

(អាបោសំវដ្តៈ)

(២៥៣) ចំណែកក្នុងសម័យណា កប្ប វិនាសដោយទឹក ។ បណ្ឌិត គប្បីសំដែងឲ្យពិស្តារ តាមន័យដែលពោលហើយក្នុងកាលមុនថា "តាំង តែអំពីដើមមក មហាមេឃដែលញ៉ាំងកប្បឲ្យវិនាស តាំងឡើងហើយ" ដូច្នេះជាដើមនុ៎ះឯង ។ ប៉ុន្តែសេចក្តីនេះ ជាសេចក្តីប្លែកគ្នា ។ មហាមេឃ ទឹកក្រុត ដែលជាអ្នកប្រល័យកប្ប ក្នុងអាបោសំវដ្តៈនេះ តាំងឡើង ដូច ជាព្រះអាទិត្យ ទី២ ក្នុងតេជោសំវដ្តៈនោះឯង ។ មហាមេឃទឹកក្រុតនោះ ជាដំបូង កាលបង្អុរភ្លៀងល្អិតៗ ធ្លាក់ចុះមក ក៏បង្អុរចុះ ដោយគ្រាប់ភ្លៀង ធំ ដោយលំដាប់ ញ៉ាំងសែនកោដិចក្រវាឡឲ្យពេញ ។ ទីទាំងឡាយមាន ប្រឹថពីនិងភ្នំជាដើម ដែលទឹកក្រុត ពាល់ត្រូវហើយៗ ក៏រលាយ ។ ទឹក ត្រូវខ្យល់ទាំងឡាយទ្រដោយជុំវិញ ។ ទឹកចាប់យកតាំងអំពីផែនដី រហូត ដល់ព្រហ្មលោកជាន់ទុតិយជ្ឈានភូមិ ។ ទឹកនោះ ញ៉ាំងព្រហ្មលោកទាំងបី ក្នុងព្រហ្មលោកជាន់ទុតិយជ្ឈានភូមិនោះ ឲ្យរលាយហើយ តាំងនៅ ចុះ ចំព្រហ្មលោកជាន់សុភកិណ្ហៈ ។ ទឹកដែលប្រល័យកប្បនោះ ដែលដល់ នូវការរាប់ថា សង្ខារ សូម្បីត្រឹមតែតូចឆ្មារ មាននៅ ដរាបណា, ក៏មិន

ស្ងប់ដរាបនោះ, ប៉ុន្តែលុះគ្របសង្កត់នូវរបស់ដែលរាប់ថា សង្ខារទាំងពួង ដែលទៅតាមទឹកហើយ ទើបស្ងប់រម្ងាប់ គឺដល់នូវការបាត់ទៅ យ៉ាងឆាប់ រហ័ស, អាកាស ខាងលើ ជាមួយនឹងអាកាស ខាងក្រោម ក៏ងងឹតសូន្យ ឈឹងតែមួយ ដូច្នេះឯង ។ ពាក្យទាំងពួង ដូចគ្នានឹងពាក្យដែលពោល ហើយ (ក្នុងតេជោសំវដ្តៈ) ។ ប៉ុន្តែ ក្នុងអាបោសំវដ្តៈនេះ លោកធ្វើនូវ អាភស្សរព្រហ្មលោក ឲ្យជាចម្បង កើតឡើងប្រាកដ តែម្យ៉ាង ។ មួយ ទៀត សត្វទាំងឡាយ ដែលចុតិចាកព្រហ្មលោកជាន់សុភកិណ្ហៈ ហើយ ទៅកើត ក្នុងទីផ្សេងៗ មានព្រហ្មលោកជាន់អាភស្សរៈជាដើម ។

(រយៈកាលនៃអសង្ខេយ្យកប្បក្នុងអាបោសំវដ្តៈ)

ក្នុងកប្បទាំង ៤ នោះ តាំងពីមហាមេឃប្រល័យកប្ប ដរាបដល់ ទឹកក្រុតប្រល័យកប្បជាច់ស្រឡះទៅ នេះ ជាអសង្ខេយ្យមួយ ។ តាំង អំពីទឹកក្រុតជាច់ស្រឡះអស់ ដរាបដល់មហាមេឃ កកើតឡើង នេះជា អសង្ខេយ្យ ទី២ ។ តាំងអំពីមហាមេឃ កកើតឡើង ដរាបដល់ការកើត ឡើងប្រាកដ នៃព្រះច័ន្ទ និង ព្រះអាទិត្យ នេះជាអសង្ខេយ្យ ទី៣ ។ តាំង អំពីការកើតឡើងប្រាកដ នៃព្រះច័ន្ទនិងព្រះអាទិត្យ ដរាបដល់មហាមេឃ ញ៉ាំងកប្បឲ្យវិនាសសាជាថ្មីទៀត នេះ ជាអសង្ខេយ្យ ទី៤ ។ (បូករួម) អសង្ខេយ្យ ៤ នេះ ជាមហាកប្បមួយ ។

ការវិនាស ដោយទឹក និង ការតាំងឡើងថ្មី (នៃពុទ្ធក្ខេត្ត) បណ្ឌិត គប្បីជ្រាប តាមន័យដែលបានពោលមកនេះឯង ។

(វាយោសំវដ្តៈ)

ក្នុងសម័យណា កប្ប វិនាស ដោយខ្យល់ ។ បណ្ឌិតគប្បីសំដែង ពាក្យទាំងពួងឲ្យបានពិស្តារ តាមន័យដែលពោលហើយ ក្នុងកាលមុនថា

“តាំងតែអំពីដើមមក មហាមេឃដែលញ៉ាំងកប្បឲ្យវិនាស តាំងឡើងហើយ” ដូច្នេះជាដើមនុ៎ះឯង ។ តែសេចក្តីនេះជាសេចក្តីប្លែកគ្នា ។ ខ្យល់តាំងឡើងព្រម ដើម្បីប្រល័យកប្ប ក្នុងវាយោសំវដ្តៈនេះ ប្រៀបដូចជាព្រះអាទិត្យ ទី២ ក្នុងតេជោសំវដ្តៈនោះឯង ។ ខ្យល់នោះ ជាដំបូង ញ៉ាំងធូលីគ្រើម ឲ្យតាំងឡើង បន្ទាប់មក ក៏ញ៉ាំងធូលីល្អិតឲ្យតាំងឡើង ញ៉ាំងខ្សាច់ល្អិត ញ៉ាំងខ្សាច់គ្រើម ញ៉ាំងវត្ថុទាំងឡាយមានក្រួស និង ថ្មជាដើមឲ្យតាំងឡើង ដូច្នេះ ដរាបដល់ញ៉ាំងថ្មទំហំប៉ុនផ្ទះកំពូល និង ដើមឈើធំដែលឋិតនៅ ក្នុងទីគោក ឲ្យតាំងឡើង ។ វត្ថុទាំងឡាយនោះ ឡើងពីដីទៅកាន់អាកាស តែមិនធ្លាក់មកទៀតទេ ។ វត្ថុទាំងនោះរលាយបាត់ខ្ទេចខ្ទីអស់ ក្នុងអាកាសនោះតែម្តង ។ លំដាប់នោះ ខ្យល់តាំងឡើងហើយពួជ៏ខាងក្រោមនៃមហាប្រឹថពី ញ៉ាំងផែនដីឲ្យត្រឡប់ បាស់ជើងឡើងទៅខាងលើហើយបោះទៅពួជ៏អាកាស ។ បំណែកមួយៗ នៃផែនដីប្រមាណ ១០០ យោជន៍ ក៏មាន ប្រមាណ ២០០ យោជន៍ ៣០០, ៤០០, និង ប្រមាណ ៥០០ យោជន៍ក៏មាន បានបែកខ្ចាយហើយ ត្រូវកំឡាំងខ្យល់បក់ឡើង ហើយល្អិតខ្ទេចខ្ទីរលាយបាត់អស់ពួជ៏អាកាសដូចគ្នា ។ សូម្បីភ្នំចក្រវាឡ សូម្បីភ្នំសិនេរុ ក៏ខ្យល់បក់ឡើងទៅលើហើយបោះទៅ ពួជ៏អាកាសដែរ ។ ភ្នំទាំងពីរនោះ ប៉ះទង្គិចនូវគ្នានឹងគ្នាហើយ ក៏ល្អិតខ្ទេចខ្ទីរលាយបាត់អស់ ។ ខ្យល់នោះ កាលញ៉ាំងវិមាន នៃភុម្មដ្ឋកទេវតាទាំងឡាយ និង វិមានអាកាសដ្ឋកទេវតាទាំងឡាយ ឲ្យវិនាស ដោយឧបាយដូចគ្នានោះឯង ធ្វើនូវកាមាវចរទេវលោក ៦ ជាន់ ឲ្យវិនាសហើយ ទើបញ៉ាំងសែនកោដិចក្រវាឡ ឲ្យវិនាស ។ ភ្នំចក្រវាឡជាមួយនឹងភ្នំចក្រវាឡ ភ្នំហិមពាន្ត ជាមួយនឹងភ្នំហិមពាន្ត ភ្នំសិនេរុ ជាមួយនឹងភ្នំសិនេរុ ទាំង

ឡាយ ក្នុងសែនកោដិចក្រវាឡនោះ ប៉ះទង្គិចដល់គ្នានឹងគ្នាហើយ ក៏ទៅជាល្អិតខ្ទេចខ្ទី វិនាសអស់ទៅ ។ ខ្យល់ចាប់យក តាំងអំពីផែនដីឡើងទៅ ដរាបដល់ព្រហ្មលោកជាន់តតិយជ្ឈានភូមិ ។ ខ្យល់នុ៎ះ ញ៉ាំងព្រហ្មលោក បីជាន់ ក្នុងតតិយជ្ឈានភូមិនោះ ឲ្យវិនាសហើយ ក៏តាំងនៅចុចយកព្រហ្មលោកជាន់វេហប្ផលៈ ។ ខ្យល់នោះ ញ៉ាំងវត្ថុដែលរាប់ថាសង្ខារទាំងពួង ឲ្យវិនាស យ៉ាងនេះហើយ ក៏វិនាសខ្លួនឯងទៅផងដែរ ។ អាកាស ពួជ៏ខាងលើ ជាមួយនឹងអាកាសពួជ៏ខាងក្រោម ក៏ងងឹតសូន្យឈឹងតែមួយ ។ ពាក្យទាំងពួង ដូចគ្នានឹងពាក្យដែលពោលហើយ (ក្នុងតេជោសំវដ្តៈ) ។ ប៉ុន្តែ ក្នុងវាយោសំវដ្តៈនេះ លោក រាប់ពីសុភកិណ្ហព្រហ្មលោក ជាដើមទៅ ក៏កើតប្រាកដ ។ ចំណែកឯសត្វទាំងឡាយ ចុតិ ចាកព្រហ្មលោកជាន់វេហប្ផលៈហើយ ក៏ទៅកើត ក្នុងទីទាំងឡាយ មានព្រហ្មលោក ជាន់សុភកិណ្ហៈជាដើម ។

(រយៈកាលនៃអសង្ខេយ្យកប្បក្នុងវាយោសំវដ្តៈ)

ក្នុងកប្បទាំង ៤ នោះ តាំងពីមហាមេឃញ៉ាំងកប្បឲ្យវិនាស ដរាបដល់ខ្យល់ញ៉ាំងកប្បឲ្យវិនាសដាច់ស្រឡះទៅ នេះ ជាអសង្ខេយ្យមួយ ។ តាំងពីដាច់ស្រឡះបាត់ខ្យល់ទៅ ដរាបដល់មហាមេឃកើត (ភ្លៀងធំជាគ្រឿងសំរេច) នេះជាអសង្ខេយ្យ ទី២, តាំងពីមហាមេឃកើត ដរាបដល់ការកើតឡើងប្រាកដ នៃព្រះច័ន្ទនិងព្រះអាទិត្យ នេះជាអសង្ខេយ្យ ទី៣, តាំងពីការកើតឡើងប្រាកដ នៃព្រះច័ន្ទ និង ព្រះអាទិត្យ ដរាបដល់មហាមេឃញ៉ាំងកប្បឲ្យវិនាសម្តងទៀត នេះជាអសង្ខេយ្យ ទី៤ ។ បួនអសង្ខេយ្យនេះ ជាមហាកប្បមួយ ។

ការវិនាស ដោយខ្យល់ និង ការតាំងឡើងសាជាថ្មី (នៃពុទ្ធក្ខេត្ត)

បណ្ឌិតគប្បីជ្រាប តាមន័យដែលបានពោលមកហើយនោះឯង ។

(លោកវិនាសដោយអកុសលមូលជាហេតុ)

(២៥៤) សួរថា "លោកវិនាសយ៉ាងនេះព្រោះហេតុអ្វី?"។ ឆ្លើយថា "ព្រោះអកុសលមូលជាហេតុ" ។ មែនពិត កាលបើអកុសលមូល ដុះដាលឡើងហើយ, លោក តែងវិនាស យ៉ាងនេះ ។ ក៏លោកនោះ កាលបើរាគៈ ក្រាស់ជាង ក៏វិនាស ដោយភ្លើង, កាលបើទោសៈ ក្រាស់ជាង វិនាស ដោយទឹក ។ ប៉ុន្តែអាចារ្យពួកខ្លះ ពោលថា "កាលបើទោសៈ ក្រាស់ជាង លោក វិនាសដោយភ្លើង, កាលបើរាគៈ ក្រាស់ជាង វិនាស ដោយទឹក" ដូច្នេះ ។ កាលបើមោហៈ ក្រាស់ជាង វិនាសដោយខ្យល់ ។

ក៏ឯលោក កាលវិនាសយ៉ាងនេះ វិនាស ដោយភ្លើង អស់ ៧ ថ្ងៃ មិនមានចន្លោះឡើយ, ក្នុងថ្ងៃ ទី៨ ទើបវិនាស ដោយទឹក, វិនាស ដោយភ្លើង អស់ ៧ ថ្ងៃ ក្នុងថ្ងៃ ទី៨ វិនាស ដោយទឹក ម្តងទៀត ដោយន័យនេះឯង លោក កាលវិនាស ក្នុងថ្ងៃជាគម្រប់ ៨ ៗ យ៉ាងនេះ វិនាស ដោយទឹក អស់វារៈ ៧ ដង វិនាសដោយភ្លើង អស់ ៧ ថ្ងៃ ម្តងទៀត ។ ដោយកាលមានប្រមាណប៉ុណ្ណោះ ៦៣ កប្ប បានកន្លងទៅហើយ ។ ក្នុងចន្លោះ ៦៣ កប្បនោះ ខ្យល់ដែលទប់ នូវថ្ងៃដែលនឹងវិនាស ដោយទឹក សូម្បីមកដល់ហើយ បាននូវឱកាសហើយ ក៏កំចាត់កំចាយនូវសុភកិណ្ហព្រហ្មដែលមានអាយុ ៦៤ កប្បពេញបរិបូរ ញ៉ាំងលោកឲ្យវិនាសបាន ។

(កែបាលីដែលសំដែងអាការៈរលឹក)

ក៏ភិក្ខុ អ្នករលឹកបាន អស់កប្បទាំងឡាយ សូម្បីកាលរលឹកឃើញនូវបុព្វេនិវាស ក្នុងចំណោមកប្បទាំងនោះ តែងរលឹកឃើញ អស់សំវដ្ដកប្ប មិនតែមួយខ្លះ អស់វិវដ្ដកប្ប មិនតែមួយខ្លះ អស់សំវដ្ដវិវដ្ដកប្ប

មិនតែមួយខ្លះ ។ រលឹកបាន ដោយប្រការដូចម្តេច? ។ រលឹកបានដោយន័យថា "អមុត្រាសឹ" ដូច្នេះជាដើម ។

ក្នុងបាឋៈនោះ ពាក្យថា "អមុត្រាសឹ" សេចក្តីថា ក្នុងសំវដ្ដកប្បឯណោះក្តី ក្នុងភពឯណោះក្តី ក្នុងកំណើតឯណោះក្តី ក្នុងគតិឯណោះក្តី ក្នុងវិញ្ញាណដ្ឋិតិ ឯណោះក្តី ក្នុងសត្តាវាស ឯណោះក្តី ក្នុងសត្តនិកាយឯណោះក្តី ខ្ញុំបានកើតហើយ ។ ពាក្យថា "ឯវំនាមោ" គឺ ខ្ញុំឈ្មោះតិស្សៈ ឬ បុស្សៈ ។ ពាក្យថា "ឯវំគោត្តោ" គឺ ខ្ញុំជាកច្ចាយនគោត្រ ឬ កស្សបគោត្រ ។ ពាក្យទាំងពីរនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអំណាចនៃការរលឹកឃើញនូវឈ្មោះ និង គោត្រ របស់ខ្លួន ក្នុងភពដែលកន្លងទៅហើយ របស់ភិក្ខុនោះ ។ ប្រសិនណាបើ ភិក្ខុជាអ្នកប្រាថ្នាដើម្បីរលឹកឃើញ នូវការដល់ព្រមដោយពិណសម្បុរក្តី នូវភាវៈនៃខ្លួនជាអ្នករស់នៅថោកទាប ឬ ថ្លៃថ្លាក្តី នូវភាពជាអ្នកមានសេចក្តីសុខ ឬ ទុក្ខ ដ៏ក្រាស់ក្រៃលក្តី នូវភាវៈនៃខ្លួនជាអ្នកមានអាយុវែង ឬ អាយុខ្លីក្តី របស់ខ្លួន ក្នុងកាលនោះ ភិក្ខុនោះ រមែងរលឹកឃើញ នូវកំណើតទាំងនោះបានមែនពិត ។ ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា "មានពិណសម្បុរយ៉ាងនេះ ។ល។ មានកំណត់កាលនៃអាយុយ៉ាងនេះ" ដូច្នេះជាដើម ។

ក្នុងបាឋៈទាំងនោះ ពាក្យថា "ឯវំវណ្ណោ" គឺ ជាអ្នកមានសម្បុរ-ស ឬ មានសម្បុរខ្មៅ ។ ពាក្យថា "ឯវមាហារោ"គឺ ជាអ្នកមានបាយនៃអង្ករស្រូវសាលីដែលផ្សំដោយសាច់ ឬ មានផ្លែឈើប្រព្រឹត្តទៅជាភោជន ។ ពាក្យថា "ឯវំ សុខទុក្ខប្បដិសំវេទី" សេចក្តីថា ជាអ្នកសោយនូវសុខនិងទុក្ខដែលប្រព្រឹត្តទៅក្នុងកាយ និង ចិត្ត ឬ មានវត្ថុដែលប្រកបដោយ

អាមិស និង មិនមានអាមិសជាដើមជាប្រភេទ ដោយអនេកប្បការ ។ ពាក្យថា “ឯវមាយុបរិយន្តោ” គឺមានកំណត់អាយុប្រមាណ ១០០ ឆ្នាំ ឬ មានអាយុដល់ទៅ ៨៤,០០០ កប្ប យ៉ាងនេះ ។ ពាក្យថា “សោ តតោ ចុតោ អមុត្រ ឧទបាទឹ” សេចក្តីថា មួយទៀត អាត្មាអញនោះ ចុតិចាកភព ឬ ចាកកំណើត ចាកគតិ ចាកវិញ្ញាណដ្ឋិតិ ចាកសត្តាវាស ចាកសត្តនិកាយនោះ ហើយកើត ក្នុងភព ឬ ក្នុងកំណើត ក្នុងគតិ ក្នុងវិញ្ញាណដ្ឋិតិ ក្នុងសត្តាវាស ក្នុងសត្តនិកាយ ឈ្មោះឯណោះ ។ ពាក្យថា “តត្រាបាសឹ” សេចក្តីថា បន្ទាប់មក សូម្បីក្នុងភព ឬ ក្នុងកំណើត ក្នុងគតិ ក្នុងវិញ្ញាណដ្ឋិតិ ក្នុងសត្តាវាស ក្នុងសត្តនិកាយនោះ អាត្មាអញក៏បានកើតហើយ ម្តងទៀត ។ ពាក្យថា “ឯវំនាមោ” ដូច្នេះជាដើម ក៏មានន័យដូចបានពោលមកហើយហ្នឹងឯង ។

ន័យមួយទៀត ពាក្យថា “អមុត្រាសឹ” នេះ ជាពាក្យរលឹកឃើញតាមប្រាថ្នារបស់ភិក្ខុនោះ អ្នកចុះកាន់ការរលឹក តាមលំដាប់ ។ ពាក្យថា “សោ តតោ ចុតោ” នេះ ជាពាក្យពិចារណា របស់ភិក្ខុដែលនឹកត្រឡប់មកវិញ ព្រោះហេតុណា, ព្រោះហេតុនោះ ពាក្យថា “អមុត្រ ឧទបាសឹ” នេះ បណ្ឌិតគប្បីជ្រាបថា “ជាពាក្យ គឺព្រះមានព្រះភាគ ទ្រង់សំដៅយក នូវទីជាទីកើតនៃភិក្ខុនោះ ជាលំដាប់ នៃការកើត ក្នុងភពនេះហ្នឹងឯង ត្រាស់ហើយក្នុងបទថា “ទៅកើតហើយ ក្នុងភពនេះ” ដូច្នេះ ។ ចំណែកពាក្យថា “តត្រាបាសឹ” ដូច្នេះ យ៉ាងនេះជាដើម គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដើម្បីសំដែងនូវការរលឹករឿយៗ នូវឈ្មោះ និងគោត្រជាដើម ក្នុងទីជាទីចូលទៅកើត មិនមានចន្លោះ នៃការចូលទៅកើតនេះ ក្នុងភពនោះនៃភិក្ខុនុ៎ះ ។ ពាក្យថា “សោ តតោ ចុតោ ឥធុបបន្នោ”

សេចក្តីថា អាត្មាអញនោះ ច្យុតចាកទីនោះ គឺ ចាកទីជាទីចូលទៅកើត មិនមានចន្លោះ ហើយបានកើត ក្នុងទីនេះ គឺក្នុងត្រកូលក្សត្រ ឬ ក្នុងត្រកូលព្រហ្មណ៍ឈ្មោះឯណោះ ។

ពាក្យថា “ឥតិ” គឺ ឯវំ ប្រែថា ដោយប្រការដូចពោលមកនេះ ។ ពាក្យថា “សាការំ សឧទ្ទេសំ” សេចក្តីថា នូវបុព្វេនិវាស ដែលឈ្មោះថា ប្រព្រឹត្តទៅមួយអន្លើដោយឧទ្ទេស ដោយអំណាចនាម និង គោត្រ, ឈ្មោះថា ប្រព្រឹត្តទៅមួយអន្លើដោយអាការៈ ដោយអំណាចពណ៌សម្បុរជាដើម ។ មែនពិត ដោយនាមនិងគោត្រ សត្វ គឺលោកសំដែងឡើងថា “តិស្សៈ កស្សបៈ” ដូច្នេះជាដើម ។ ដោយប្រការផ្សេងៗ មានពណ៌សម្បុរជាដើម សត្វ ត្រូវគេដឹងបាន ដោយផ្សេងគ្នាថា “មនុស្សស្រអែម មនុស្សស” ដូច្នេះ ។ ព្រោះហេតុនោះ នាមនិងគោត្រ ឈ្មោះថាឧទ្ទេស, ហេតុទាំងឡាយផ្សេងពីនេះ ឈ្មោះថាអាការៈ ។ ពាក្យថា “អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ” នេះសុទ្ធតែជាពាក្យមានសេចក្តីងាយយល់ទេ ។

បុព្វេនិវាសានុស្សតិញ្ញាណកថា ចប់ហើយ ។

❁ ❁ ❁

ចុតូបបាតញ្ញាណកថា

(២៥៥) បណ្ឌិតគប្បីជ្រាបសេចក្តី ក្នុងការពណ៌នានូវញាណ ក្នុងការច្យុត និង ការចូលទៅកើត នៃសត្វទាំងឡាយ ដូចតទៅនេះ ។

(កែអត្ថបាលីក្នុងចុតូបបាតញ្ញាណ)

ពាក្យថា "ចុតូបបាតញ្ញាណាយ" សេចក្តីថា ដើម្បីដឹងក្នុងការច្យុត និង ក្នុងការចូលទៅកើត ។ មានអធិប្បាយថា "ការច្យុត និង ការចូលទៅកើត នៃសត្វទាំងឡាយ គឺព្រះមានព្រះភាគទ្រង់ជ្រាប ដោយញាណឯណា, ដើម្បីប្រយោជន៍ដល់ញាណនោះ គឺដើម្បីប្រយោជន៍ដល់ទិព្វចក្ខុញាណ" ។ ពាក្យថា "ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ" សេចក្តីថា ភិក្ខុនោះ បង្អោនបរិកម្មចិត្តទៅ និងបញ្ជូនបរិកម្មចិត្តទៅ ។ ពាក្យថា "សោ" គឺភិក្ខុអ្នកមានការបង្អោនចិត្តទៅ បានធ្វើហើយនោះ ។ ចំណែកក្នុងពាក្យទាំងឡាយមានពាក្យថា "ទិព្វេន" ដូច្នេះជាដើម មានអធិប្បាយដូចតទៅ

(ទិព្វចក្ខុ)

ចក្ខុ ឈ្មោះថា ទិព្វ ព្រោះភាវៈនៃចក្ខុនោះដូចជារបស់ទិព្វ ។ មែនពិត បសាទចក្ខុ របស់ទេវតាទាំងឡាយ ជាធម្មជាតកើតអំពីសុចរិតកម្ម គឺទោសទាំងឡាយ មានប្រមាត់ ស្លេស្ម និង ឈាមជាដើម មិនរាំងស្ទះហើយ អាចទទួលនូវអារម្មណ៍ សូម្បីក្នុងទីឆ្ងាយបាន ព្រោះភាវៈនៃទិព្វចក្ខុនោះ រួចស្រឡះហើយចាកគ្រឿងសៅហ្មង ទើបឈ្មោះថាជាទិព្វ ។ ក៏សូម្បីញាណចក្ខុ ដែលកើតអំពីកំឡាំង នៃវីរិយភាវនានេះ ក៏ប្រាកដដូចជាបសាទចក្ខុនោះដែរ ព្រោះហេតុនោះ ញាណចក្ខុនោះ ទើបឈ្មោះថាទិព្វ ព្រោះភាវៈនៃញាណចក្ខុនោះ ប្រាកដស្មើដូចជាទិព្វ ។ ញាណចក្ខុនោះ ឈ្មោះថា ទិព្វ ព្រោះភាវៈនៃញាណនោះ គឺភិក្ខុបានចំពោះហើយ

ដោយអំណាចនៃធម៌ជាគ្រឿងនៅដូចជាទិព្វ និង ព្រោះជាទីអាស្រ័យនូវធម៌ជាគ្រឿងនៅដូចជាទិព្វ របស់ខ្លួនផង ។ ញាណចក្ខុ ឈ្មោះថា ជាទិព្វ ព្រោះមានពន្លឺភ្លឺខ្លាំង ដោយការកំណត់នូវអាលោកកសិណផង ។ ឈ្មោះថា ជាទិព្វ ព្រោះមានដំណើរទៅខ្លាំង ដោយការឃើញនូវរូប ដែលតាំងនៅ ក្នុងទីមានខាងក្រៅជញ្ជាំងជាដើមបានផង ។ ពាក្យថា "ទិព្វ" ទាំងអស់នោះ បណ្ឌិតគប្បីជ្រាប តាមទំនងនៃគម្ពីរសំរាប់កែស័ព្ទឯណោះចុះ ។

ញាណនោះឈ្មោះថា ចក្ខុ ព្រោះអត្ថថា ឃើញ មួយទៀត ឈ្មោះថា ចក្ខុ ព្រោះដូចជាភ្នែក ហេតុធ្វើកិច្ចនៃភ្នែក ។

ញាណចក្ខុនោះ ឈ្មោះថា ស្អាតប្លែក ព្រោះភាវៈនៃញាណនោះ មានការស្អាតដោយវិសេសគឺទិដ្ឋិជាហេតុ ព្រោះកិរិយាឃើញនូវការច្យុតិ និងការចូលទៅកើត ។ ព្រោះថា បុគ្គលណា ឃើញត្រឹមតែចុតិប៉ុណ្ណោះ មិនឃើញនូវការចូលទៅកើត បុគ្គលនោះ តែងប្រកាន់យកឧច្ឆេទទិដ្ឋិ ។ បុគ្គលណា ឃើញនូវត្រឹមតែការចូលទៅកើតប៉ុណ្ណោះ មិនឃើញនូវចុតិ បុគ្គលនោះ តែងប្រកាន់យកសស្សតទិដ្ឋិ ព្រោះការកើតឡើងប្រាកដ នៃសត្វថ្មី ។ ចំណែកបុគ្គលណាឃើញនូវចុតិ និង ការចូលទៅកើតទាំងពីរនោះ បុគ្គលនោះ ព្រោះហេតុដែលរំលងផុតនូវទិដ្ឋិទាំងពីរយ៉ាងនោះបាន ទើបការឃើញនោះ របស់បុគ្គលនោះ ជាហេតុនៃទិដ្ឋិវិសុទ្ធិ ។ ចំណែកឯភិក្ខុពុទ្ធបុត្រទាំងឡាយ តែងឃើញនូវចុតិ និង ឧបបាតទាំងពីរនេះពិត ។ ព្រោះហេតុនោះ បានជាខ្ញុំពោលថា "ញាណចក្ខុនោះ ឈ្មោះថា ស្អាតប្លែក ព្រោះជាហេតុនៃទិដ្ឋិវិសុទ្ធិ ព្រោះការឃើញទាំងចុតិទាំងឧបបាត" ។

ញាណចក្ខុនោះ បណ្ឌិតគប្បីជ្រាបថា "ឈ្មោះថា កន្លងនូវចក្ខុជារបស់មនុស្ស ព្រោះឃើញនូវរូបកន្លងឧបចារៈ របស់មនុស្សបាន ឬ ឈ្មោះថា

កន្លងនូវចក្ខុជារបស់មនុស្ស ព្រោះភាវៈនៃញាណនោះ កន្លងនូវមំសចក្ខុដែលជារបស់នៃមនុស្ស ។ ដោយទិព្វចក្ខុ ដ៏បរិសុទ្ធស្អាត កន្លងនូវចក្ខុជារបស់មនុស្សនោះ ។

ពាក្យថា "សត្តេ បស្សតិ" គឺ ភិក្ខុក្រឡេកមើលនូវសត្វទាំងឡាយដូចជាគេមើលឃើញ ដោយមំសចក្ខុដែលជារបស់មនុស្ស ។ ក្នុងពីរបទថា "ចវមានេ ឧបបជ្ជមានេ" នោះ មានអធិប្បាយថា : ក្នុងខណៈនៃចុតិក្តី ក្នុងខណៈនៃឧបបត្តិក្តី អ្នកណាមួយមិនអាចដើម្បីឃើញ ដោយទិព្វចក្ខុបានទេ ។ ចំណែកសត្វទាំងឡាយណា ជាអ្នកមានចុតិជិត នឹងច្យុត ក្នុងពេលឥឡូវនេះ ព្រោះហេតុនោះ សត្វទាំងឡាយនោះ ព្រះមានព្រះភាគ ទ្រង់សំដែងហើយថា "កំពុងច្យុត" ដូច្នេះ, ចំណែកឯសត្វទាំងឡាយឯណា ដែលចាប់បដិសន្ធិហើយ កើតហើយ អម្បាញ់មិញនេះ ព្រោះហេតុនោះ សត្វទាំងឡាយនោះ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយថា "កំពុងចូលទៅកើត" ។ ព្រះមានព្រះភាគទ្រង់សំដែងថា "ភិក្ខុនោះឃើញ នូវសត្វទាំងឡាយនោះ ដែលកំពុងច្យុត និង កំពុងចូលទៅកើត មានសភាពបែបនេះ" ដូច្នេះ ។

ពាក្យថា "ហីនេ" សេចក្តីថា ឈ្មោះថាត្រូវគេបៀតបៀនហើយ គឺបៀតបៀនជ្រុលហើយ លាមហើយ លាមញោសហើយ ដោយអំណាចនៃហេតុទាំងឡាយ មានជាតិត្រកូល និង ភោគៈ ជាដើម ដែលឈ្មោះថាទាបថោក ព្រោះប្រកបដោយផលនៃមោហៈ ។ ពាក្យថា "បណីតេ" គឺ ឈ្មោះថាផុយអំពីថោកទាបនោះ ព្រោះប្រកបដោយផលនៃអមោហៈ ។ ពាក្យថា "សុវណ្ណេ" គឺ ឈ្មោះថា ប្រកបហើយដោយសម្បុរជាទីប្រាថ្នា ជាទីរីករាយ និង ជាទីពេញចិត្ត ព្រោះប្រកបដោយផលនៃអទោសៈ ។

ពាក្យថា "ទុព្វណ្ណេ" គឺ ឈ្មោះថា ប្រកបដោយសម្បុរមិនជាទីប្រាថ្នា មិនជាទីរីករាយ និង មិនជាទីពេញចិត្ត ព្រោះប្រកបដោយផលនៃទោសៈ អធិប្បាយថា "មានរូបមិនល្អផ្សេងពីរូបសមរម្យ" ។ ពាក្យថា "សុគតេ" គឺដល់ហើយនូវគតិល្អ ឬ គឺថា ជាអ្នកស្តុកស្តម្ភ ជាអ្នកមានទ្រព្យច្រើន ព្រោះប្រកបដោយផលនៃអលោភៈ ។ ពាក្យថា "ទុគ្គតេ" គឺ ដល់នូវទុគតិ ឬ ទីទ័លក្រ គឺថា មានបាយនិងទឹកតិច ព្រោះប្រកបដោយផលនៃលោភៈ ។ ពាក្យថា "យថាកម្មុបគេ" គឺ កម្មណាៗ ដែលខ្លួនសន្សំទុកហើយ ចូលដល់ហើយ ដោយកម្មនោះៗ ។

(យថាកម្មុបគញ្ញាណ)

(២៥៦) ក្នុងបទទាំងនោះ កិច្ចនៃទិព្វចក្ខុ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបទខាងដើមទាំងឡាយ មានបទថា "ចវមានេ" ដូច្នេះជាដើម ។ ចំណែកកិច្ចនៃយថាកម្មុបគញ្ញាណ (ញាណដឹងថា សត្វចូលដល់គតិតាមកម្មរបស់ខ្លួន) គឺព្រះអង្គទ្រង់ត្រាស់ហើយ ដោយបទ (យថាកម្មុបគេ)នេះ ។ ក៏នេះជាលំដាប់នៃការកើតឡើងនៃញាណនោះ ។

ភិក្ខុ ក្នុងសាសនានេះ ចំរើនអាលោកកសិណ ឲ្យមានមុខឆ្ពោះទៅកាន់នរក ឰដ៏ខាងក្រោម រមែងឃើញនូវសត្វទាំងឡាយ ដែលកើតក្នុងនរក ដែលកំពុងតែសោយនូវសេចក្តីទុក្ខដ៏ធំ, ការឃើញនោះ គ្រាន់តែជាកិច្ច នៃទិព្វចក្ខុប៉ុណ្ណោះឯង ។ ភិក្ខុនោះ ធ្វើទុកក្នុងចិត្ត យ៉ាងនេះថា "សត្វទាំងឡាយនេះ ធ្វើនូវកម្មអ្វីហ្ន៎ បានជាសោយនូវសេចក្តីទុក្ខនេះ" ។ លំដាប់នោះ ញាណដែលមានកម្មនោះជាអារម្មណ៍ ក៏កើតឡើង ដល់ភិក្ខុនោះថា "សត្វទាំងនេះ សោយនូវមហាទុក្ខនេះ ព្រោះធ្វើកម្មឈ្មោះនេះ" ដូច្នេះ ។ ន័យដូចគ្នានោះ ភិក្ខុ ចំរើនអាលោកកសិណឲ្យមានមុខឆ្ពោះទៅ

កាន់ទេវលោក ឮដ៏ខាងលើ រមែងឃើញនូវសត្វទាំងឡាយ ដែលកំពុងតែសោយសម្បត្តិដ៏ច្រើន ក្នុងទិព្វវិមានទាំងឡាយ មាននន្ទវន មិស្សកវន និង ផារុសកវនជាដើម, សូម្បីការឃើញនោះ ក៏គ្រាន់តែជាកិច្ចនៃទិព្វចក្ខុហ្នឹងឯង ។ ភិក្ខុនោះ ធ្វើទុកក្នុងចិត្ត យ៉ាងនេះថា "សត្វទាំងឡាយនេះ ធ្វើនូវកម្មអ្វីហ្ន៎ ទើបសោយនូវសម្បត្តិនេះ" ។ លំដាប់នោះ ញាណដែលមានកម្មនោះជាអារម្មណ៍ ក៏កើតឡើង ដល់ភិក្ខុនោះថា "សត្វទាំងនេះ សោយនូវសម្បត្តិនេះ ព្រោះធ្វើនូវកម្មឈ្មោះនេះ" ដូច្នេះ ។ ញាណគឺការដឹងនេះ ឈ្មោះថា យថាកម្មុបគញ្ញាណ ។ ឈ្មោះថា បរិកម្មផ្សេង មិនមានដល់ញាណនេះទេ ។ ក៏បរិកម្មផ្សេង នៃញាណនេះ មិនមាន យ៉ាងណា, សូម្បីអនាគតំសញ្ញាណ ក៏មិនមាន បរិកម្មផ្សេង យ៉ាងនោះដែរ ។ ព្រោះថា ញាណដែលមានទិព្វចក្ខុជាទីតាំងទាំងឡាយហ្នឹងឯង រមែងសំរេចបាន ជាមួយនឹងទិព្វចក្ខុនេះមែនពិត ។

(ទុច្ចរិត)

ក្នុងបទទាំងឡាយមានបទថា "កាយទុច្ចរិតេន" ដូច្នេះជាដើម មានអធិប្បាយថា : ការប្រព្រឹត្តិអាក្រក់ ឬ ការប្រព្រឹត្តិ ត្រូវទោសប្រទូស្តហើយ ព្រោះជាការប្រព្រឹត្តិដែលស្អុយដោយកិលេស ព្រោះហេតុនោះ ទើបឈ្មោះថា ទុច្ចរិត ។ ការប្រព្រឹត្តិអាក្រក់ដោយកាយ ឬ ការប្រព្រឹត្តិអាក្រក់ ដែលកើតឡើងហើយ តាមផ្លូវកាយ ហេតុនោះ ទើបឈ្មោះថា កាយទុច្ចរិត ។ ន័យ សូម្បីក្នុងបទទាំងឡាយក្រៅនេះ ក៏ន័យនេះដែរ ។ បទថា "សមន្នាគតា" ជាអ្នកប្រកបព្រមហើយ ។

(អរិយុបវាទ)

ពាក្យថា "អរិយានំ ឧបវាទកា" សេចក្តីថា ជាអ្នកប្រាថ្នានូវសេចក្តី

វិនាស ជាអ្នករិះគន់ អធិប្បាយថា ជាអ្នកជេរ ជាអ្នកតិះដៀល នូវព្រះអរិយៈ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ព្រះសាវកទាំងឡាយ ដោយហោចទៅសូម្បីព្រះសោតាបន្នជាគ្រហស្ថទាំងឡាយ ដោយអន្តិមវត្ថុ ឬ ដោយការកំចាត់គុណ ។ ក្នុងអាការៈទាំង ២ នោះ បុគ្គលអ្នកពោលថា "សមណធម៌ របស់បុគ្គលទាំងឡាយនេះ មិនមានទេ, បុគ្គលទាំងនេះមិនមែនជាសមណៈទេ" ដូច្នេះ គប្បីជ្រាបថា "តិះដៀល ដោយអន្តិមវត្ថុ" ។ បុគ្គលកាលពោល នូវពាក្យទាំងឡាយមានពាក្យថា "ឈានក្តី វិមោក្ខក្តី មគ្គក្តី ផលក្តី របស់បុគ្គលទាំងឡាយនេះមិនមានទេ" ដូច្នេះជាដើម គប្បីជ្រាបថា "ពោលតិះដៀលដោយអំណាចនៃការកំចាត់គុណ" ។ ក៏បុគ្គលអ្នកតិះដៀលនោះ កាលដឹង ពោលតិះដៀលក្តី កាលមិនដឹង ក៏ពោលតិះដៀលនូវព្រះអរិយៈក្តី, (ការតិះដៀលនេះ) ជាការតិះដៀល នូវអរិយៈ ដោយប្រការទាំងពីរមែនពិត ។ ការតិះដៀលព្រះអរិយៈនេះ ជាកម្មដ៏ធ្ងន់ ឃាត់សួគ៌ផង ឃាត់មគ្គផង ប្រហែលគ្នានឹងអនន្តរិយកម្មដែរ ប៉ុន្តែជាកម្មដែលនៅកែបាន ។ ដើម្បីបំភ្លឺ នូវកម្មគឺការតិះដៀល នូវព្រះអរិយៈនោះ ឲ្យបានច្បាស់លាស់ បណ្ឌិតគប្បីជ្រាបរឿងនេះ ដូចតទៅ ។

(រឿងភិក្ខុកំឡោះតិះដៀលព្រះអរិយៈ)

បានឮមកថា ព្រះថេរៈមួយអង្គ និង ភិក្ខុកំឡោះមួយអង្គ ត្រាច់ទៅបិណ្ឌបាត្រ ក្នុងស្រុកមួយ ។ លោកទាំង ២ អង្គនោះ បាននូវបបរក្តៅត្រឹមតែមួយបោយ ក្នុងផ្ទះជាដំបូងហ្នឹងឯង ។ ឯចំពោះព្រះថេរៈ ខ្យល់ក្នុងពោះ ចាត់ដោត ។ ព្រះថេរៈនោះ គិតថា "បបរនេះ ជាទីសប្បាយដល់អាត្មាអញ, បបរនេះ មិនទាន់ត្រជាក់ ដរាបណា អាត្មាអញនឹងហុតនូវបបរនោះ ដរាបនោះ" ដូច្នេះ ។ លោកគង់ហុតបបរ លើកំណាត់ឈើ

ដែលបុគ្គលទាំងឡាយ នាំមកហើយ ដើម្បីប្រយោជន៍ ដល់ធរណីទ្វារ ។ ភិក្ខុកំឡោះក្រៅនេះ ក៏ខ្នាញ់ចំពោះព្រះថេរៈនោះ ពោលថា "លោកតាចាស់ ស្រេកឃ្លានខ្លាំងក្លាណាស់ ទើបបានធ្វើនូវកម្មដែលគួរខ្មាសអៀនដល់អត្តាអញ" ។ ព្រះថេរៈ ត្រាច់ទៅ ក្នុងស្រុកហើយ ក៏និមន្តទៅវត្ត ពោលទៅកាន់ភិក្ខុកំឡោះថា "ម្នាលអាវុសោ ទីពឹង ក្នុងព្រះសាសនានេះ របស់អ្នក មានដែរឬទេ?" ។ ភិក្ខុកំឡោះទូលថា "ព្រះករុណា ព្រះគុណម្ចាស់ ខ្ញុំព្រះករុណា ជាសោតាបន្នបុគ្គល" ។ ព្រះថេរៈពោលថា "ម្នាលអាវុសោ បើដូច្នោះ អ្នកកុំបានធ្វើហើយ នូវសេចក្តីព្យាយាម ដើម្បីមគ្គព្ឋដ៏ខាងលើឡើយ" ។ ភិក្ខុកំឡោះ ទូលសួរថា "ព្រោះហេតុអ្វី ព្រះគុណម្ចាស់?" ។ ព្រះថេរៈពោលថា "ព្រះខីណាស្រពគឺអ្នកតិះដៀលហើយ"។ ភិក្ខុកំឡោះនោះ ញ៉ាំងព្រះថេរៈនោះ ឲ្យអត់ទោសហើយ ។ ព្រោះការសុំខមាទោសនោះ កម្មនោះ របស់ភិក្ខុកំឡោះនោះ ក៏បានជាកម្មតាំងនៅតាមប្រក្រតីវិញហើយ ។

(វិធីខមាទោស)

ព្រោះហេតុនោះ សូម្បីបុគ្គលឯណាមួយ តិះដៀល នូវព្រះអរិយៈ, បុគ្គលអ្នកតិះដៀលនោះ គប្បីទៅ, ថាបើលោកចាស់ជាងខ្លួន គប្បីអង្គុយប្រហោងហើយ ញ៉ាំងព្រះអរិយៈឲ្យអត់ទោសឲ្យថា "ខ្ញុំបានពោលហើយនូវពាក្យនេះផងៗ ចំពោះលោកដ៏មានអាយុ, សូមលោកម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំផង" ដូច្នេះហើយ, ថាបើ ភិក្ខុអ្នកតិះដៀលនោះក្មេងជាង ត្រូវថ្វាយបង្គំហើយអង្គុយប្រហោង ផ្គងអញ្ជលី ញ៉ាំងព្រះអរិយៈឲ្យអត់ទោសឲ្យថា "បពិត្រព្រះគុណម្ចាស់ ខ្ញុំករុណា បានពោលហើយនូវពាក្យនេះផងៗ ចំពោះព្រះគុណម្ចាស់ សូមព្រះគុណម្ចាស់ អត់នូវ

ទោសនោះ ដល់ខ្ញុំព្រះករុណាផងចុះ" ។

ប្រសិនណាបើ ព្រះអរិយៈ ជាអ្នកចៀសចេញទៅហើយកាន់ទិស ភិក្ខុអ្នកតិះដៀល គប្បីទៅដោយខ្លួនឯង ឬ បញ្ជូនសហធម្មិកទាំងឡាយមានសទ្ធិវិហារិកជាដើមទៅ ហើយគប្បីញ៉ាំងព្រះអរិយៈឲ្យអត់ទោសឲ្យ, តែថា ប្រសិនបើភិក្ខុអ្នកតិះដៀល ជាអ្នកមិនអាចដើម្បីទៅ ទាំងមិនអាចដើម្បីបញ្ជូនទៅទេ, ត្រូវទៅកាន់សំណាក់នៃភិក្ខុទាំងឡាយ ដែលគង់នៅក្នុងវត្តនោះ, ថាបើ ភិក្ខុទាំងនោះ ជាអ្នកក្មេងជាង, គប្បីអង្គុយប្រហោង, ថាបើភិក្ខុទាំងនោះជាអ្នកចាស់ជាង, គប្បីប្រតិបត្តិ តាមន័យដែលលោកពោលហើយ ក្នុងវុឌ្ឍបុគ្គលទុំះឯង ហើយគប្បីពោល សុំខមាទោសថា "បពិត្រព្រះគុណម្ចាស់ ខ្ញុំបានពោលហើយ នូវពាក្យនេះផងៗ ចំពោះលោកដ៏មានអាយុឈ្មោះឯណោះ សូមលោកដ៏មានអាយុអង្គនោះ អត់នូវទោសនោះដល់ខ្ញុំផង" ដូច្នេះ ។ កាលបើព្រះអរិយៈមិនអត់ទោសឲ្យក្នុងទីចំពោះមុខទេ, ភិក្ខុអ្នកតិះដៀល គប្បីធ្វើការញ៉ាំងភិក្ខុទាំងនោះ ឲ្យអត់ទោសនោះឲ្យមែនពិត ។

ប្រសិនណាបើ ព្រះអរិយៈនោះ ជាភិក្ខុអ្នកត្រាច់ទៅតែម្នាក់ឯង, ទីកន្លែងដែលលោកគង់នៅ ក៏មិនប្រាកដ ទីដែលលោកទៅ ក៏មិនប្រាកដ, ភិក្ខុអ្នកតិះដៀល គប្បីទៅកាន់សំណាក់ នៃភិក្ខុជាបណ្ឌិតមួយរូប ហើយគប្បីពោលថា "បពិត្រព្រះគុណម្ចាស់ ខ្ញុំបានពោល នូវពាក្យនេះផងៗ ចំពោះលោក ដ៏មានអាយុឈ្មោះឯណោះ, កាលខ្ញុំរលឹកឃើញនូវពាក្យនោះរឿយៗ តែងមានសេចក្តីស្តាយក្រោយ តើខ្ញុំនឹងធ្វើដូចម្តេចទៅ?" ។ ភិក្ខុជាបណ្ឌិតនោះ នឹងពោលថា "លោកម្ចាស់ កុំគិតឡើយ, ព្រះថេរៈនឹងអត់ទោសឲ្យដល់លោកម្ចាស់, សូមលោកម្ចាស់ធ្វើចិត្តឲ្យស្ងប់ចុះ" ។

ឯភិក្ខុអ្នកតិះដៀលព្រះអរិយៈនោះ ត្រូវបែរមុខឆ្ពោះទៅកាន់ទិសដែលព្រះអរិយៈនិមន្តទៅហើយ ផ្គងនូវអញ្ជលីហើយ គប្បីពោលថា "សូមព្រះអរិយៈនោះអត់ទោសឲ្យផង" ។

ប្រសិនណាបើ ព្រះអរិយៈនោះ ជាអ្នកបរិនិព្វានទៅហើយ, ភិក្ខុអ្នកតិះដៀលនោះ គប្បីទៅកាន់កន្លែងគ្រែដែលលោកបរិនិព្វាន ឬក៏ ទៅកាន់ទីត្រឹមតែព្រៃស្មសាន ហើយគប្បីសុំខមាទោស ។

កាលបើភិក្ខុអ្នកតិះដៀលធ្វើ (ការសុំខមាទោស) យ៉ាងនេះហើយ, កម្មនោះ មិនបានឃាត់សួគ៌ មិនបានឃាត់មគ្គទេ គឺជាកម្មតាំងនៅតាមប្រក្រតីវិញហ្នឹងឯង ដោយប្រការដូច្នេះ ។

(មិច្ឆាទិដ្ឋិ)

(២៥៧) បុគ្គលអ្នកមានការយល់ឃើញវិបរិត ឈ្មោះថា អ្នកមានសេចក្តីយល់ឃើញខុស ។ បុគ្គលទាំងឡាយណា ជាអ្នកមានកម្មមានបែបផ្សេងៗ សមាទានហើយ ដោយអំណាចនៃការយល់ឃើញខុសផងញ៉ាំងជនទាំងឡាយឯទៀតៗ ឲ្យដល់ព្រម ក្នុងកម្មទាំងឡាយ មានកាយកម្មជាដើម ដែលមានការយល់ខុសជាឫសគល់ផង បុគ្គលទាំងឡាយនោះ ឈ្មោះថា ជាអ្នកមានកម្មសមាទាន ដោយអំណាចនៃមិច្ឆាទិដ្ឋិ ។

ក៏ក្នុងអរិយុបវាទ និង មិច្ឆាទិដ្ឋិនេះ សូម្បីកាលបើអរិយុបវាទ គឺលោកសង្គ្រោះហើយ ដោយស័ព្ទគឺវចីទុច្ចរិតហ្នឹងឯង និង កាលបើមិច្ឆាទិដ្ឋិ គឺលោកសង្គ្រោះហើយ ដោយមនោទុច្ចរិតស័ព្ទក៏ដោយ, តែការត្រាស់នូវបទទាំងពីរនេះ បណ្ឌិតគប្បីជ្រាបថា "ដើម្បីទ្រង់សំដែងនូវភាវៈនៃអរិយុបវាទ និង មិច្ឆាទិដ្ឋិនោះ មានទោសច្រើន" ។ ពិតមែនហើយ អរិយុបវាទ ឈ្មោះថា មានទោសច្រើន ព្រោះជាទោសប្រហែលគ្នានឹង

អនន្តរិយកម្មមែនពិត ។ ពិតមែន សូម្បីព្រះដ៏មានព្រះភាគ ក៏ទ្រង់បានត្រាស់ព្រះតម្រាស់នេះ ថា "ម្នាលសារីបុត្រ ភិក្ខុ បរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ គប្បីសំរេចអរហត្តផល ក្នុងបច្ចុប្បន្ននេះឯង យ៉ាងណាមិញ, ម្នាលសារីបុត្រ តថាគត ពោលនូវហេតុ (នៃការមិនលះបង់នូវវាចាជាដើម របស់បុគ្គលនោះ) ថា មានឧបមេយ្យប្រហែលគ្នាយ៉ាងនោះដែរ ។ បុគ្គលនោះបើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅវង់ទុក្ខ ក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ យ៉ាងដូច្នោះឯង [១] " ។ មួយទៀត ទោសដទៃ ឈ្មោះថាមានទោសធំជាងមិច្ឆាទិដ្ឋិ មិនមានឡើយ ។ សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយដែលមានទោសធំយ៉ាងនេះ ដូចមិច្ឆាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ មានតែមិចាទិដ្ឋិជាទោសក្រៃលែង [២] " ដូច្នេះឯង ។

(អបាយ ទុគ្គតិ វិនិបាត និរយៈ)

ពាក្យថា "ព្រោះការបែកធ្លាយនៃរាងកាយ" គឺ ព្រោះលះបង់នូវឧបាទិន្នក្ខន្ធ ។ ពាក្យថា "បន្ទាប់អំពីសេចក្តីស្លាប់ទៅ" គឺក្នុងការកាន់យកនូវខន្ធ ដែលកើតហើយ ក្នុងលំដាប់ នៃឧបាទិន្នក្ខន្ធនោះ ។ម្យ៉ាងទៀត ពាក្យថា "ព្រោះការបែកធ្លាយនៃរាងកាយ" គឺ ព្រោះកិរិយាកាត់ផ្តាច់នូវជីវិតិន្ទ្រិយ៍ ។ ពាក្យថា "បន្ទាប់អំពីសេចក្តីស្លាប់ទៅ" គឺក្នុងខាងលើ អំពីចុតិចិត្តទៅ ។

១- សុ. ម. គាគទី ២០ ទំព័រទី ២៧១ ។ ២- អំ. ឯក. ភាគទី ៤០ ទំព័រ ៧៦ ។

ពាក្យថា "អបាយ" យ៉ាងនេះដូច្នេះជាដើម ទាំងអស់ជាពាក្យផ្លាស់ប្តូរនឹងពាក្យថា នរក ហ្នឹងឯង ។

មែនពិត និរយៈ ឈ្មោះថាអបាយ ព្រោះប្រាសហើយ ចាកសេចក្តីចំរើន ដែលសន្មតហើយថា បុណ្យដែលជាហេតុនៃស្ថិគ និង និព្វាន ឬថា ព្រោះមិនមានសេចក្តីចំរើន នៃសេចក្តីសុខទាំងឡាយ ។

និរយៈ ឈ្មោះថា ជាទុគ្គតិ ព្រោះជាដំណើរ គឺជាទីអាស្រ័យ នៃសេចក្តីទុក្ខ ។ម្យ៉ាងទៀត ឈ្មោះថា ទុគ្គតិ ព្រោះជាដំណើរ ដែលកើតហើយ ដោយកម្មដែលឈ្មោះថា អាក្រក់ ព្រោះភាវៈនៃកម្មនោះច្រើនដោយទោសៈ ។

និរយៈ ឈ្មោះថា វិនិបាត ព្រោះជាទីធ្លាក់ចុះទៅ ដោយមិនមានអំណាចនៃបុគ្គលអ្នកធ្វើនូវសេចក្តីអាក្រក់ទាំងឡាយ ។ ម្យ៉ាងវិញទៀត ឈ្មោះថា វិនិបាត ព្រោះជាទីធ្លាក់ចុះទៅ យ៉ាងវិនាស គឺមានអវយវៈតូចធំ បែកធ្លាយ (នៃបុគ្គលអ្នកធ្វើអាក្រក់ទាំងឡាយ) ដូច្នេះក៏បាន ។

អាយៈ (សេចក្តីចំរើន) ដែលសំគាល់ហើយថាសេចក្តីត្រេកអរ មិនមានក្នុងទីនោះ ព្រោះហេតុនោះ ទីនោះ ទើបឈ្មោះថា និរយៈ ។

ន័យមួយទៀត ព្រះមានព្រះភាគ ទ្រង់សំដែងនូវកំណើត នៃសត្វតិរច្ឆាន ដោយអបាយស័ព្ទ ។ មែនពិត កំណើត នៃសត្វតិរច្ឆានទាំងឡាយ ឈ្មោះថាអបាយ ព្រោះប្រាសចាកសុគតិ, តែមិនឈ្មោះថា ទុគ្គតិ ព្រោះជាទីកើតព្រមនៃសត្វតិរច្ឆានទាំងឡាយ ដែលមានស័ក្តិធំមានស្តេចនាគជាដើម ។

ព្រះមានព្រះភាគ ទ្រង់សំដែងនូវប្រេតវិស័យ ដោយទុគ្គតិស័ព្ទ ។ មែនពិត ប្រេតវិស័យនោះ ឈ្មោះថា អបាយផងមែនពិត ឈ្មោះថា

ទុគ្គតិផង ព្រោះប្រាសចាកសុគតិ និង ព្រោះជាដំណើរនៃសេចក្តីទុក្ខ ។ តែមិនឈ្មោះថា វិនិបាត ព្រោះប្រេតវិស័យនោះមិនបានធ្លាក់ទៅ យ៉ាងវិនាស ដូចជាអសុរ ឡើយ ។

ព្រះមានព្រះភាគ ទ្រង់សំដែងនូវអសុរកាយ ដោយវិនិបាតស័ព្ទ ។ មែនពិត អសុរកាយនោះ ឈ្មោះថា អបាយផង ឈ្មោះថា ទុគ្គតិផង មែនពិត ដោយសេចក្តីដូចដែលលោកពោលហើយ និង លោកហៅថា វិនិបាត ព្រោះអសុរកាយនោះ ធ្លាក់ប្រាសចាកសេចក្តីចំរើនសព្វគ្រប់ ។

ព្រះដ៏មានព្រះភាគ ទ្រង់សំដែងនូវនិរយៈ មានច្រើនប្រការ មានអវិចីជាដើមហ្នឹងឯង ដោយនិរយស័ព្ទ ។

បទថា "ឧបបន្នា" គឺ ចូលដល់ហើយ អធិប្បាយថា "កើតចំពោះហើយ ក្នុងអបាយជាដើមនោះ" ។

(សុគតិ)

ចំណែកខាងល្អ បណ្ឌិតគប្បីជ្រាប ដោយបរិយាយផ្ទុយ ដែលលោកពោលហើយហ្នឹងឯង ។ តែសេចក្តីប្លែកគ្នា ដូចតទៅនេះ ។

ក្នុងពាក្យថា សុគតិ ជាដើមនោះ ឯដំណើរទៅកាន់មនុស្ស លោកសង្គ្រោះ ដោយសុគតិស័ព្ទ ។ លោកសង្គ្រោះ ដំណើរទៅកាន់ទេវលោកហ្នឹងឯង ដោយសគ្គស័ព្ទ ។ សេចក្តីនៃពាក្យនេះថា "ក្នុងពាក្យថាសុគតិនោះ ឈ្មោះថា សុគតិ ព្រោះជាដំណើរល្អ ។ ឈ្មោះថា សួគ៌ ព្រោះប្រសើរដោយប្រពៃ ដោយអារម្មណ៍ទាំងឡាយមានរូបជាដើម ។ ទាំងអស់នោះឯង ឈ្មោះថា លោក ព្រោះអត្ថថា ទ្រុឌទ្រោមទៅ" ដូច្នេះ ។

ពាក្យមានពាក្យថា "ឥតិ ទិព្វេន ចក្ខុនា" ដូច្នេះជាដើម គឺជានិគមវចនៈទាំងអស់ ។ សេចក្តីដែលពោលមកនេះ ជាសេចក្តីសង្ខេប

ក្នុងបាលីនេះថា “ភិក្ខុឃើញ ដោយចក្ខុដូចជាទិព្វ” ដោយប្រការដូច្នេះ ។

(ចាប់ផ្ដើមធ្វើទិព្វចក្ខុ)

(២៥៨) ចំណែកឯកុលបុត្រជាអាទិកម្មិកៈ អ្នកប្រាថ្នាដើម្បីឃើញយ៉ាងនេះ គប្បីធ្វើនូវឈាន មានអភិញ្ញាជាទីតាំង ដែលមានកសិណជាអារម្មណ៍ឲ្យគួរដល់ការនាំចិត្តទៅដោយអាការទាំងពួងហើយ ធ្វើកសិណណាមួយ ក្នុងចំណោមកសិណទាំងឡាយ ៣ នេះ គឺ តេជោកសិណ ឱទាតកសិណ អាលោកកសិណ ឲ្យជាកសិណជិត ។ កុលបុត្រនោះគប្បីចំរើនឧបចារជ្ឈាន ធ្វើឲ្យជាអារម្មណ៍ហើយ តម្កល់ទុក ។ អធិប្បាយថា “អប្បនា គឺព្រះយោគី មិនគួរឲ្យកើតឡើង ក្នុងអារម្មណ៍ដែលបានចំរើនហើយនោះទេ” ។ ព្រោះថា ប្រសិនបើព្រះយោគី ញុំាងអប្បនាឲ្យកើតឡើង ។ អារម្មណ៍នោះ ក៏ជាទីអាស្រ័យនៃឈានដែលជាគ្រឿងទ្រ មិនមែនជាទីអាស្រ័យនៃបរិកម្មទេ ។

ក៏ក្នុងកសិណទាំង ៣ នេះ អាលោកកសិណ តែម្យ៉ាង ប្រសើរបំផុតជាង ព្រោះហេតុនោះ ព្រះយោគី គប្បីញុំាងអាលោកកសិណនោះ ឬញុំាងបណ្ដាកសិណទាំងឡាយក្រៅពីនេះ កសិណណាមួយ ឲ្យកើឡើង តាមន័យដែលលោកពោលហើយ ក្នុងកសិណនិទ្ទេសហើយ ឲ្យតាំងនៅ ក្នុងឧបចារភូមិនេះឯង ហើយគប្បីចំរើនចុះ ។ សូម្បីន័យ ក្នុងការចំរើនអារម្មណ៍នោះ ក៏បណ្ឌិតគប្បីជ្រាប តាមន័យដែលបានពោលហើយ ក្នុងកសិណនិទ្ទេសនោះដូចគ្នាដែរ ។

ព្រះយោគី គប្បីឃើញរូបដែលមាន ខាងក្នុងនៃទីដែលខ្ទួនចំរើនហើយៗ តែម្យ៉ាង ។ ក៏កាលព្រះយោគីនោះ ឃើញនូវរូប, វារៈនៃបរិកម្មតែងប្រព្រឹត្តទៅ ។ បន្ទាប់ពីនោះមក ពន្លឺ ក៏បាត់ទៅ ។ កាលបើពន្លឺនោះ

បាត់ទៅហើយ សូម្បីវត្ថុដែលដល់នូវរូប ក៏មិនប្រាកដ ។ កាលបើដូច្នោះ ព្រះយោគីនេះ គប្បីចូលនូវឈានជាទីតាំងនោះឯង ចេញអំពីឈាននោះហើយ គប្បីផ្សាយពន្លឺ ឲ្យបានរឿយៗ ចុះ ។ កាលបើធ្វើយ៉ាងនេះ ពន្លឺក៏រមែងដល់នូវភាពរឹងមាំ ដោយលំដាប់ ។ ព្រះយោគីនោះ អធិដ្ឋានថា “ពន្លឺចូរមានក្នុងទីនេះ” ដូច្នេះហើយ កំណត់អស់ទីត្រឹមណា, ពន្លឺ ក៏ឋិតនៅ ក្នុងទីត្រឹមនោះឯង ។ ការឃើញរូប រមែងមាន ដល់ព្រះយោគីអ្នកអង្គុយមើលអស់មួយថ្ងៃក៏បាន ។ ក៏បុរសអ្នកដើរទៅកាន់ផ្លូវ ក្នុងពេលយប់ ដោយគប់ភ្លើងធ្វើពីស្មៅ ជាឧបមា ក្នុងពាក្យដែលពោលនេះ ។

បានឮមកថា បុរសម្នាក់ទៅកាន់ផ្លូវ ក្នុងវេលាយប់ ដោយគប់ភ្លើងធ្វើអំពីស្មៅ ។ គប់ភ្លើងធ្វើអំពីស្មៅនោះ របស់បុរសនោះ រលត់ហើយ ។ គ្រានោះ ទីរាបស្មើ និង មិនរាបស្មើ មិនប្រាកដហើយដល់បុរសនោះ ។ បុរសនោះ កៀរនូវគប់ភ្លើងធ្វើពីស្មៅនោះ លើផែនដី ញុំាងគប់ភ្លើងឲ្យឆេះហើយម្ដងទៀត ។ ក៏គប់ភ្លើងធ្វើពីស្មៅនោះ លុះឆេះហើយ បានធ្វើហើយនូវពន្លឺដ៏វិសេសជាងពន្លឺដែលមានមកពីមុន ។ កាលបើបុរសនោះធ្វើគប់ភ្លើងធ្វើពីស្មៅ ដែលរលត់ហើយៗ ឲ្យឆេះឡើងវិញរឿយៗ យ៉ាងនេះ, ព្រះអាទិត្យ ក៏រះឡើងហើយ តាមលំដាប់ ។ កាលបើព្រះអាទិត្យរះឡើងហើយ, ការប្រើគប់ភ្លើង ក៏មិនមាន ដូច្នោះ បុរសនោះ ក៏ចោលនូវគប់ភ្លើងធ្វើពីស្មៅនោះ បានទៅហើយ អស់មួយថ្ងៃក៏បាន ។

ក្នុងពាក្យឧបមាទាំងឡាយនោះ ពន្លឺនៃកសិណ ក្នុងកាលជាទីធ្វើនូវបរិកម្ម ប្រៀបដូចជាពន្លឺនៃគប់ភ្លើង ។ ការដែល...កាលបើពន្លឺ រលត់ហើយ ព្រោះហេតុដែល... កាលព្រះយោគីមើលនូវរូប កន្លងនូវវារៈនៃបរិកម្ម ក៏មិនឃើញរូបទាំងឡាយ ប្រៀបដូចជា កាលបើគប់ភ្លើង រលត់

ហើយ មិនឃើញ នូវទីរាបស្មើ និង មិនរាបស្មើ យ៉ាងដូច្នោះឯង ។ ការចូលទៅរឿយៗ ហាក់បីដូចជាការញុចញុំនូវគប់ភ្លើង ។ កាលបើព្រះយោគីធ្វើនូវបរិកម្ម ម្តងទៀត ការផ្សាយនូវពន្លឺដ៏មានកំឡាំងដោយវិសេសទៅ ហាក់បីដូចជាការដែលគប់ភ្លើងធ្វើនូវពន្លឺដ៏ធំដោយវិសេស ជាងពន្លឺដែលមានមកក្នុងកាលមុន ។ ការដែលពន្លឺដ៏មានកំឡាំងរឹងមាំ ឋិតនៅ តាមទីដែលបានកំណត់ទុក ហាក់បីដូចជាការដែលព្រះអាទិត្យរះឡើង ។ ការដែលព្រះយោគី លះបង់ចោលនូវពន្លឺដ៏តិចតួច ហើយមើលនូវរូប អស់ពេញមួយថ្ងៃ ដោយពន្លឺដែលមានកំឡាំងរឹងមាំ ហាក់បីដូចជាការដែលបុរស បោះនូវគប់ភ្លើងធ្វើពីស្មៅចោលហើយ ដើរទៅបាន រហូតពេញមួយថ្ងៃ យ៉ាងដូច្នោះ ។

(កាលបើទិព្វចក្ខុកើតឡើង)

ក្នុងការឃើញនូវរូបនោះ រូបនេះ គឺ រូបដែលនៅខាងក្នុងពោះ រូបដែលអាស្រ័យនៅ ក្នុងហទយវត្ថុ រូបដែលអាស្រ័យនៅ ក្នុងផ្ទៃនៃផែនដីឰដ៏ខាងក្រោម រូបដែលនៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំ និង ខាងក្រៅកំពែង រូបដែលតាំងនៅ ក្នុងចក្រវាឡដទៃ ដែលមិនមកកាន់វង្វង់ នៃមំសចក្ខុ របស់ភិក្ខុនោះ តែងមកកាន់វង្វង់នៃញាណចក្ខុ (របស់ភិក្ខុនោះ) ជារូបហាក់បីដូចជាប្រាកដដល់មំសចក្ខុ ក្នុងកាលណា ក្នុងកាលនោះ បណ្ឌិតគប្បីជ្រាបថា “ទិព្វចក្ខុ ជាចក្ខុកើតឡើងហើយ” ដូច្នេះ ។ ក៏ក្នុងបណ្តាចិត្តដែលប្រារព្ធរូបនេះ ទិព្វចក្ខុប៉ុណ្ណោះ អាចក្នុងការឃើញរូប ចិត្តជាចំណែកខាងដើមទាំងឡាយ គ្មានសមត្ថភាពក្នុងការឃើញរូបទេ ។

(ទិព្វចក្ខុជាអន្តរាយដល់បុថុជ្ជន)

ក៏ទិព្វចក្ខុនុ៎ះឯងជាសេចក្តីអន្តរាយដល់បុថុជ្ជន ។ ព្រោះហេតុអ្វី? ។

ព្រោះហេតុថា បុថុជ្ជននោះ អធិដ្ឋានថា “ពន្លឺចូរមាន” ដូច្នេះ ក្នុងទីណាៗ, ទីនោះៗ ជាទីមានពន្លឺតែមួយ ទំលុះនូវផែនដី សមុទ្រ និង ភ្នំក៏បាន, ក្នុងគ្រានោះ កាលបើបុថុជ្ជននោះ ឃើញនូវរូបនៃអមនុស្ស មានយក្ស និង អារក្សទឹកជាដើមដែលគួរឲ្យភ័យខ្លាច ក្នុងទីនោះ ភ័យ រមែងកើតឡើង, ដែលជាហេតុឲ្យបុថុជ្ជននោះ ដល់នូវការរវើរវាយចិត្ត ជាអ្នកច្កួតវង្វេងព្រោះឈានក៏ថាបាន ព្រោះហេតុនោះ ព្រះយោគី មិនគួរប្រមាទ ក្នុងការឃើញរូបឡើយ ។

(លំដាប់នៃការកើតឡើងនៃទិព្វចក្ខុ)

ក្នុងខណៈដែលទិព្វចក្ខុកើតនោះ នេះគឺជាលំដាប់ នៃការកើតឡើងនៃទិព្វចក្ខុ ។ កាលបើមនោទ្វារាវជ្ជនចិត្ត ធ្វើនូវរូបមានប្រការដូចពោលមកហើយនេះ ឲ្យជាអារម្មណ៍ កើតឡើងហើយ រលត់ទៅវិញ, ជវនទាំងឡាយ បួន ឬ ប្រាំ ធ្វើនូវរូបនោះឯង ឲ្យជាអារម្មណ៍ហើយ កើតឡើងព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបពាក្យទាំងពួង តាមន័យដែលមានមកក្នុងកាលមុនចុះ ។ សូម្បីក្នុងញាណនេះ កាមាវចរចិត្តទាំងឡាយ ដែលប្រកបដោយវិតក្កៈ និង វិចារៈ ជាបុព្វភាគចិត្ត (ចិត្តជាចំណែកខាងដើមនៃញាណនេះ) រូបាវចរចិត្ត ដែលប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាន ជាចិត្តញុំាងប្រយោជន៍គឺញាណនេះឲ្យសំរេច ក្នុងទីបំផុត, ញាណ ដែលកើតព្រមជាមួយនឹងកាមាវចរចិត្តនោះឯង លោកហៅថា “សត្តានំ ចុតូបបាតញ្ញាណ” ដូច្នេះខ្លះ ថា “ទិព្វចក្ខុញ្ញាណ” ដូច្នេះខ្លះ ។

ចតូបបាតញ្ញាណកថា ចប់ហើយ ។

(បកិណ្ណកកថា)

ក៏ព្រះពុទ្ធជាទីពឹង ព្រះអង្គទ្រង់ជ្រាបនូវខន្ធ ៥ ទ្រង់បាន

ត្រាស់ហើយ នូវអភិញ្ញាទាំង ៥ ឯណា ដោយប្រការ
ដូចពោលមកនេះ, បណ្ឌិតបានជ្រាប នូវអភិញ្ញាទាំង ៥
នោះហើយ គប្បីជ្រាបបកិណ្ណកកថានេះ ក្នុងអភិញ្ញាទាំង
៥ នោះ ថែមទៀតផង ។

ក៏ក្នុងអភិញ្ញាទាំង ៥ នោះ ទិព្វចក្ខុ ពោលគឺចុតូបបាតញ្ញាណនោះ មានបរិភណ្ឌញ្ញាណ(ញាណជាបរិវារ) ដល់ទៅ ២ គឺ អនាគតំសញ្ញាណ ១ យថាកម្មុបគញ្ញាណ ១ ។ ព្រោះហេតុនោះ អភិញ្ញាញាណទាំងឡាយ ៧ មកហើយ ក្នុងទីនេះ គឺ បរិភណ្ឌញ្ញាណទាំងឡាយ ២ នេះផង និង អភិញ្ញាញាណ ៥ មានឥទ្ធិវិធជាដើមផង ។ ក្នុងកាលឥឡូវនេះ

បណ្ឌិតគប្បីសំដែង នូវការប្រព្រឹត្តិទៅ នៃអភិញ្ញាញាណ
ទាំងឡាយ ៧ ក្នុងអារម្មណត្តិកៈទាំងឡាយ ៤ ដែល
ព្រះពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ទ្រង់ត្រាស់ទុកហើយ

ដើម្បីកុំឲ្យវង្វេងប្រឡំ ក្នុងការវែកញែកនូវអារម្មណ៍ នៃអារម្មណត្តិកៈទាំងឡាយនោះ ។ នេះគឺជាការសំដែង ក្នុងអារម្មណត្តិកៈនោះ ។

(២៥៩) ក៏ប្រមាណបីនៃអារម្មណ៍ទាំងឡាយ ៤ គឺព្រះមហេសីទ្រង់ត្រាស់ហើយ, អារម្មណត្តិកៈ ទាំង ៤ គឺអ្វីខ្លះ ។ គឺ បរិត្តារម្មណត្តិកៈ (គឺប្រមាណ ៣ នៃបរិត្តារម្មណ៍) ១, មគ្គារម្មណត្តិកៈ (ប្រមាណ ៣ នៃមគ្គារម្មណ៍) ១, អតីតារម្មណត្តិកៈ (ប្រមាណ ៣ នៃអតីតារម្មណ៍) ១, អជ្ឈត្តារម្មណត្តិកៈ (ប្រមាណ ៣ នៃអជ្ឈត្តារម្មណ៍) ១ ។

(ឥទ្ធិវិធញ្ញាណ ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៧)

ក្នុងអភិញ្ញាញាណទាំងនោះ ឥទ្ធិវិធញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍

ទាំង ៧ ដោយអំណាចនៃបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អតីតារម្មណ៍ អនាគតារម្មណ៍ បច្ចុប្បន្នារម្មណ៍ អជ្ឈត្តារម្មណ៍ និង ពហិទ្ធារម្មណ៍ ។ សួរថា : ឥទ្ធិវិធញ្ញាណនោះ ប្រព្រឹត្តទៅ យ៉ាងដូចម្តេច? ។ ឆ្លើយថា:

ក៏ឥទ្ធិវិធញ្ញាណនោះជាបរិត្តារម្មណ៍ ព្រោះមានរូបកាយជាអារម្មណ៍ ដោយធ្វើសេចក្តីអធិប្បាយថា “ក្នុងពេលណា ព្រះយោគី ធ្វើនូវកាយឲ្យអាស្រ័យនូវចិត្ត ហើយប្រាថ្នាដើម្បីទៅ ដោយកាយដែលមិនប្រាកដ ទើបបង្អោននូវកាយទៅដោយអំណាចនៃចិត្ត លើកឡើងនូវរូបកាយ ក្នុងមហគ្គតចិត្ត ញុំាងរូបកាយឲ្យកើតឡើង ក្នុងមហគ្គតចិត្ត, ក្នុងពេលនោះ រូបកាយ ជាអារម្មណ៍ដែលបានហើយដោយការចូលទៅប្រកប” ដូច្នេះ,

ឥទ្ធិវិធញ្ញាណនោះ ជាមហគ្គតារម្មណ៍ ក៏ព្រោះមានមហគ្គចិត្ត ជាអារម្មណ៍ ព្រោះធ្វើសេចក្តីអធិប្បាយថា “ក្នុងពេលណា ព្រះយោគី ធ្វើនូវចិត្តឲ្យអាស្រ័យនូវកាយ ប្រាថ្នាដើម្បីទៅ ដោយកាយដែលប្រាកដ ក៏បង្អោនចិត្តទៅ ដោយអំណាចនៃកាយ ទើបលើកឡើងនូវចិត្តដែលមានឈានជាទីតាំង ក្នុងរូបកាយ ញុំាងចិត្តដែលមានឈានជាទីតាំង ឲ្យកើតឡើង ក្នុងរូបកាយ, ក្នុងពេលនោះ ចិត្តដែលមានឈានជាទីតាំង ជាអារម្មណ៍ ដែលបានហើយ ដោយការចូលទៅប្រកប” ដូច្នេះ,

មួយទៀត ឥទ្ធិវិធញ្ញាណនោះ ជាអតីតារម្មណ៍ ក៏ព្រោះធ្វើនូវចិត្តនុ៎ះឯង ដែលកន្លងទៅហើយ គឺដែលរលត់ទៅហើយ ឲ្យជាអារម្មណ៍,

ឥទ្ធិវិធញ្ញាណនោះ ជាអនាគតារម្មណ៍ សំរាប់ព្រះយោគីទាំងឡាយអ្នកអធិដ្ឋាន (ឫទ្ធិ) ជាអនាគត ដូចជាឥទ្ធិវិធញ្ញាណ របស់ព្រះថេរៈទាំងឡាយមានព្រះមហាកស្សបត្ថេរជាដើម ក្នុងកាលបញ្ចុះព្រះមហាធាតុ ។ បានឮមកថា ព្រះមហាកស្សត្ថេរកាលធ្វើនូវការបញ្ចុះព្រះមហាធាតុ បាន

អធិដ្ឋានហើយថា "ក្លិនទាំងឡាយនេះ ចូរកុំសាបរលាបឡើយ ផ្កាទាំងឡាយនេះ កុំស្វិតស្រពោនឡើយ ប្រទីបទាំងឡាយនេះ កុំរលត់ឡើយ អស់ ២១៨ ឆ្នាំ ក្នុងអនាគតកាល" ដូច្នេះ ។ គ្រឿងក្រអូបផ្កានិងប្រទីបទាំងអស់នោះ បានមានហើយ ដូចដែលលោកអធិដ្ឋាននោះឯង ។

ព្រះអស្សគុត្តត្ថេរ ឃើញនូវភិក្ខុសង្ឃកំពុងឆាន់នូវបាយក្រៀម ក្នុងវត្តនិយសេនាសនៈ ក៏បានអធិដ្ឋានថា "ត្រពាំងទឹក ចូរទៅជាទឹកដោះជូរ ក្នុងពេលមុនភត្ត រាល់ៗ ថ្ងៃ" ដូច្នេះ ។ ទឹកដែលលោកដងហើយ ក្នុងពេលមុនភត្ត កើតទៅជាទឹកដោះជូរ, ក្នុងពេលក្រោយភត្ត វាក៏ទៅជាទឹកតាមប្រក្រតីហ្នឹងឯង ។

ប៉ុន្តែ ឥទ្ធិវិធញ្ញាណនោះ ជាបច្ចុប្បន្នារម្មណ៍ ក្នុងកាលជាទីធ្វើនូវកាយ ឲ្យអាស្រ័យនូវចិត្តហើយ ទៅដោយកាយដែលមិនប្រាកដ ។

ឥទ្ធិវិធញ្ញាណនោះ ជាអជ្ឈត្តារម្មណ៍ ព្រោះធ្វើនូវកាយនិងចិត្តរបស់ខ្លួនឲ្យជាអារម្មណ៍ ក្នុងពេលដែលបង្អោនចិត្តទៅ ដោយអំណាចនៃកាយ ឬ បង្អោនកាយទៅ ដោយអំណាចនៃចិត្ត និង ក្នុងពេលដែលដំណែងខ្លួនទៅជាភេទផ្សេងៗ មានភេទកុមារជាដើម ។

ប៉ុន្តែ ឥទ្ធិវិធញ្ញាណនោះ ជាពហិទ្ធារម្មណ៍ ក្នុងពេលដែលសំដែងនូវរូបផ្សេងៗ មានដំរី និង សេះជាដើមជាខាងក្រៅ ដូច្នេះឯង ។

បណ្ឌិតគប្បីជ្រាបការប្រព្រឹត្តិទៅ នៃឥទ្ធិវិធញ្ញាណ ក្នុងអារម្មណ៍ទាំងឡាយ ៧ ដូចពោលមកនេះឯង ជាដំបូង ។

(ទិព្វសោតធាតុញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤)

ទិព្វសោតធាតុញ្ញាណ តែងប្រព្រឹត្តទៅ ក្នុងអារម្មណ៍ទាំងឡាយ ៤ ដោយអំណាចនៃបរិត្តារម្មណ៍ បច្ចុប្បន្នារម្មណ៍ អជ្ឈត្តារម្មណ៍ ហើយនិង

ពហិទ្ធារម្មណ៍ ។ សួរថា : ប្រព្រឹត្តទៅ យ៉ាងដូចម្តេច? ។ ឆ្លើយថា ក៏ទិព្វសោតធាតុញ្ញាណនោះ ព្រោះហេតុដែលធ្វើសំឡេង ឲ្យជាអារម្មណ៍ និង សំឡេងជាបរិត្តធម៌ (ជាកាមាវចរ) ហេតុនោះ ទើបជាបរិត្តារម្មណ៍, ប៉ុន្តែព្រោះធ្វើសំឡេងដែលមាននោះឯង ឲ្យជាអារម្មណ៍ ហើយប្រព្រឹត្តទៅ ទើបជាបច្ចុប្បន្នារម្មណ៍, ក្នុងពេលដែលស្តាប់សំឡេងក្នុងពោះរបស់ខ្លួន ទិព្វសោតធាតុញ្ញាណនោះ ជាអជ្ឈត្តារម្មណ៍, ក្នុងពេលដែលស្តាប់សំឡេង នៃជនទាំងឡាយដទៃទៀត ជាពហិទ្ធារម្មណ៍ ដូច្នេះឯង ។

ការដែលទិព្វសោតធាតុញ្ញាណ ប្រព្រឹត្តទៅ ក្នុងអារម្មណ៍ទាំងឡាយ ៤ បណ្ឌិតគប្បីជ្រាប តាមន័យនេះឯង ដោយប្រការដូច្នេះ ។

(ចេតោបរិយញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨)

(២៦០) ចេតោបរិយញ្ញាណ រមែងប្រព្រឹត្តទៅ ក្នុងអារម្មណ៍ទាំងឡាយ ៨ ដោយអំណាចនៃបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អប្បមាណា-រម្មណ៍ មគ្គារម្មណ៍ អតីតារម្មណ៍ អនាគតារម្មណ៍ បច្ចុប្បន្នារម្មណ៍ និង ពហិទ្ធារម្មណ៍ ។ សួរថា : ប្រព្រឹត្តទៅ យ៉ាងដូចម្តេច? ។ ឆ្លើយថា : ក៏ចេតោបរិយញ្ញាណនោះ ជាបរិត្តារម្មណ៍ ក្នុងពេលដែលដឹងនូវចិត្តដែលជាកាមាវចរ នៃពួកជនដទៃ ជាមហគ្គតារម្មណ៍ ក្នុងពេលដែលដឹងនូវចិត្តដែលជារូបាវចរ និង អរូបាវចរ (នៃពួកជនដទៃ) ជាអប្បមាណា-រម្មណ៍ ក្នុងពេលដែលដឹងនូវមគ្គ និង ផល (នៃពួកជនដទៃ) ។

ក៏ក្នុងអប្បមាណារម្មណ៍នេះ បណ្ឌិតគប្បីជ្រាបសេចក្តីប្លែកគ្នា ដូចតទៅនេះ គឺ : "បុថុជ្ជន មិនដឹងនូវចិត្ត នៃព្រះសោតាបន្នបុគ្គល, ព្រះសោតបន្នបុគ្គលសោត ក៏មិនដឹងនូវចិត្ត នៃព្រះសកទាគាមី.... បណ្ឌិតគប្បីនាំយកពាក្យដូចពោលមកនេះ (ថែម) រហូតដល់ព្រះអរហន្ត ។ តែ

ព្រះអរហន្ត ទើបដឹងនូវចិត្ត នៃព្រះអរិយៈទាំងពួង ។ សូម្បីព្រះអរិយៈជាន់ខ្ពស់ដទៃទៀត រមែងដឹងនូវចិត្តនៃព្រះអរិយៈជាន់ទាប” ដូច្នេះឯង ។

ចេតោបរិយញ្ញាណនោះ ក្នុងពេលដែលមានមគ្គចិត្ត ជាអារម្មណ៍ ជាមគ្គារម្មណ៍ ។ ចំណែកព្រះយោគី ដឹងនូវចិត្តនៃពួកជនដទៃបាន ក្នុងពេលខាងក្នុងនៃថ្ងៃ ៧ ដែលកន្លងទៅហើយក្តី ក្នុងពេលខាងក្នុងនៃថ្ងៃ ៧ ដែលមិនទាន់បានមកដល់ហើយក្តី ក្នុងពេលណា, ក្នុងពេលនោះ ចេតោបរិយញ្ញាណនោះ ជាអតីតារម្មណ៍ផង ជាអនាគតារម្មណ៍ផង ។

(បច្ចុប្បន្នចិត្ត ៣)

សួរថា “ចេតោបរិយញ្ញាញាណនោះ ជាបច្ចុប្បន្នារម្មណ៍ តើយ៉ាងដូចម្តេច ? ” ។ ឆ្លើយថា “ឈ្មោះថា បច្ចុប្បន្ន (ចិត្ត) មាន ៣ គឺ : ខណប្បច្ចុប្បន្ន ១ សន្តតិប្បច្ចុប្បន្ន ១ អទ្ធាបច្ចុប្បន្ន ១ ។

ក្នុងបច្ចុប្បន្ន(ចិត្ត) ទាំង ៣ នោះ (ចិត្ត) ដែលដល់នូវការកើតឡើង ការតាំងនៅ និង ការបែកធ្លាយ ឈ្មោះថា ខណប្បច្ចុប្បន្ន ។ ចិត្តដែលរាប់បញ្ចូលក្នុងវារៈនៃតំណាចិត្តមួយនិងពីរ ឈ្មោះថា សន្តតិប្បច្ចុប្បន្ន ។

(សន្តតិប្បច្ចុប្បន្ន)

បណ្ឌិតគប្បីជ្រាបអធិប្បាយ ក្នុងសន្តតិប្បច្ចុប្បន្ននោះ ដូចតទៅនេះ អារម្មណ៍ រមែងមិនប្រាកដ ដល់បុគ្គលដែលអង្គុយ ក្នុងទីងងឹត ហើយទៅកាន់ទីដែលមានពន្លឺភ្លាមទេ លុះតែដរាបណា អារម្មណ៍នោះ ប្រាកដសិន, ក្នុងចន្លោះនោះ បណ្ឌិតគប្បីជ្រាបវារៈ នៃតំណមួយពីរ ។

រូប តែងមិនប្រាកដ សូម្បីដល់បុគ្គលដែលត្រាច់ទៅ ក្នុងទីមានពន្លឺ ហើយ ចូលទៅបន្ទប់តូច ដោយឆាប់ភ្លាមទេ, លុះតែដរាបណា រូបនោះ ប្រាកដសិន, បណ្ឌិតគប្បីជ្រាបវារៈ នៃសន្តតិមួយពីរ ក្នុងចន្លោះនោះ ។

មួយទៀត ព្រះយោគី ឈរក្នុងទីឆ្ងាយ សូម្បីឃើញនូវការកំរើកដៃនៃជាងជ្រលក់ និង នូវវិការៈនៃការជំនូវវត្ថុមានស្គរជាច់ជាដើម ក៏មិនទាន់ឮនូវសំឡេងនៅឡើយទេ, លុះតែដរាបណា ស្តាប់នូវសំឡេងនោះសិន, សូម្បីចន្លោះនោះ ក៏គប្បីជ្រាបសន្តតិវារៈ មួយពីរ ។

ព្រះមជ្ឈិមភាណកាចារ្យទាំងឡាយពោលយ៉ាងនេះមុន ។ ចំណែកព្រះសំយុត្តភាណកាចារ្យទាំងឡាយ ពោលនូវសន្តតិ ២ គឺ រូបសន្តតិ ១ អរូបសន្តតិ ១ ហើយពោលថា “កាលបុគ្គលដើរជាន់ទឹក, លុះតែដរាបណា គំនូសនៃទឹកដែលជាន់ហើយ ក្បែរច្រាំង មិនទាន់ថ្លា, នេះឈ្មោះថា រូបសន្តិតិ (១), កាលបើបុគ្គលមកអំពីផ្លូវឆ្ងាយ, លុះតែដរាបណា ភាពក្តៅស្អុះ ក្នុងកាយ មិនទាន់រម្ងាប់, នេះឈ្មោះថា រូបសន្តតិ (១), កាលបុគ្គលមកអំពីកំដៅថ្ងៃ ហើយចូលទៅកាន់បន្ទប់, លុះតែដរាបណា ភាពនៃងងឹតមិនទាន់ទៅប្រាស, នេះឈ្មោះថា រូបសន្តតិ (១), កាលភិក្ខុធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន ខាងក្នុងបន្ទប់ ហើយបើកបង្អួចក្រឡេកមើល ក្នុងពេលថ្ងៃ, លុះតែដរាបណា ភាពព្រិលនៃភ្នែកមិនទាន់រម្ងាប់, នេះឈ្មោះថា រូបសន្តតិ (១) ដរាបនោះ, វារៈនៃជវនៃ ២-៣ ឈ្មោះថាអរូបសន្តតិ” ដូច្នេះហើយ ពោលថា “សន្តតិទាំងពីរនោះ ឈ្មោះថាសន្តតិប្បច្ចុប្បន្ន” ។

(អទ្ធាបច្ចុប្បន្ន)

ធម្មជាតដែលកំណត់ត្រឹមតែភពមួយ ឈ្មោះថា អទ្ធាបច្ចុប្បន្ន ដែលព្រះមហាកច្ចាយនៈ សំដៅយក ពោលហើយ ក្នុងភទ្ទេករត្តសូត្រ ថា “ម្នាលអាវុសោ ចិតឯណាផង ធម្មារម្មណ៍ទាំងឡាយណាផង, ចិត្ត និងធម្មារម្មណ៍ទាំងពីរនោះឯង ជាបច្ចុប្បន្ន, វិញ្ញាណ ជាធម្មជាតជាប់ចំពាក់នឹងឆន្ទរាគ ក្នុងចិត្តនិងធម្មារម្មណ៍ជាបច្ចុប្បន្ននោះឯង, បុគ្គលរមែង

ត្រេកអរចំពោះចិត្ត និង ធម្មារម្មណ៍ ជាបច្ចុប្បន្ននោះ ព្រោះវិញ្ញាណជាប់ចំពាក់នឹងឆន្ទរាគ, បុគ្គល កាលត្រេកអរចំពោះចិត្ត និង ធម្មារម្មណ៍ ជាបច្ចុប្បន្ននោះ ឈ្មោះថា រសេមរសាម ក្នុងពួកធម៌ទាំងឡាយ ដែលជាបច្ចុប្បន្ន [១] " ដូច្នេះ ។

ក៏ក្នុងបច្ចុប្បន្នទាំងពីរនោះ សន្តតិប្បច្ចុប្បន្ន មកហើយ ក្នុងអដ្ឋកថាទាំងឡាយ, អទ្ធាបច្ចុប្បន្ន មកហើយ ក្នុងព្រះសូត្រ ។

ក្នុងបច្ចុប្បន្នចិត្តទាំង ៣ នោះ អាចារ្យពួកខ្លះ ពោលថា "ចិត្ត ជាខណប្បច្ចុប្បន្ន ចាត់ជាអារម្មណ៍ នៃចេតោបរិយញ្ញាណបាន" ។ សួរថា "ព្រោះហេតុអ្វី?" ។ ឆ្លើយថា "ព្រោះថា ចិត្ត របស់បុគ្គលអ្នកមានឫទ្ធិ និងបុគ្គលដទៃ រមែងកើតឡើង ក្នុងខណៈតែមួយបាន" ។ ចំណែកឯពាក្យនេះ ជាពាក្យឧបមា នៃចិត្តទាំងឡាយនោះថា "កាលបើបាច់ផ្កា គឺបុគ្គលបោះទៅហើយឰដ៏អាកាស, ផ្កាមួយទង រមែងជាប់ទង ដោយទងនៃផ្កាមួយ ដោយពិត យ៉ាងណាមិញ, កាលបើចិត្ត ដែលមហាជននឹកគិតហើយ ដោយអំណាចជាក្រុមថា "អាត្មាអញ នឹងដឹងនូវចិត្ត នៃបុគ្គលដទៃ" ដូច្នេះ, ចិត្ត នៃបុគ្គលម្នាក់ រមែងចាក់ធ្លុះចំពោះ ដោយចិត្តមួយ (នៃបុគ្គលណាម្នាក់) ក្នុងឧប្បាទក្ខណៈ ឬ ឋិតិក្ខណៈ ឬ ភង្គក្ខណៈ ដោយពិតប្រាកដ ក៏យ៉ាងដូច្នោះឯង" ។

ប៉ុន្តែពាក្យនៃកេចិអាចារ្យទាំងនោះ ត្រូវបានគេបដិសេធហើយ ក្នុងអដ្ឋកថាទាំងឡាយថា "ពាក្យនោះ មិនគួរ" ព្រោះបុគ្គលសូម្បីនឹករំពឹងអស់ ១០០ ដងក្តី ១,០០០ ដងក្តី ចិត្តជាគ្រឿងគិតរំពឹង និង ចិត្ត ជាគ្រឿងដឹងទាំងពីរនោះ មិនមានទីជាមួយគ្នា និងព្រោះទោសគឺអាវជ្ជនចិត្ត

១- សុ. ម. ឧ. ភាគទី ២៨ ទំព័រទី ៣៥ ។

និង ជវនចិត្ត ដល់នូវភាពមានអារម្មណ៍ផ្សេងៗ ក្នុងទីជាទីមិនប្រាថ្នា" ។

ចំណែកសន្តតិប្បច្ចុប្បន្ន និង អទ្ធាបច្ចុប្បន្ន បណ្ឌិត គប្បីជ្រាបថា "ជាអារម្មណ៍ (នៃចេតោបរិយញ្ញាណ)" ដូច្នេះ ។ ក្នុងអដ្ឋកថាសំយុត្តលោកពោលហើយថា "ក្នុងបច្ចុប្បន្នទាំងពីរនោះ ចិត្តណា នៃបុគ្គលដទៃក្នុងកាលប្រមាណ ២-៣ ជវនវិថី ដោយអំណាចនៃអតីត ឬ អនាគតអំពីជវនវិថីដែលកំពុងតែប្រព្រឹត្តទៅ, ចិត្ត នៃបុគ្គលដទៃ ទាំងអស់នោះឈ្មោះថា សន្តតិប្បច្ចុប្បន្ន, ចំណែក អទ្ធាបច្ចុប្បន្ន បណ្ឌិតគប្បីសំដែងដោយអំណាចនៃជវនវារៈ" ដូច្នេះ ។ ពាក្យនៃព្រះអដ្ឋកថាចារ្យទាំងនោះគឺលោកពោលហើយដោយប្រពៃ ។ នេះជាការសំដែង ក្នុងអទ្ធាបច្ចុប្បន្ននោះ ដូចតទៅ :

ភិក្ខុអ្នកមានឫទ្ធិ ប្រាថ្នាដើម្បីដឹងចិត្តនៃបុគ្គលដទៃ ទើបនឹករំពឹង ។ អាវជ្ជនៈ(ចិត្តនោះ) ធ្វើខណប្បច្ចុប្បន្ន ឲ្យជាអារម្មណ៍ហើយ ទើបរលត់ទៅ ជាមួយនឹងអារម្មណ៍នោះឯង ។ បន្ទាប់ពីនោះមក ជវនទាំងឡាយ ៤ ឬ ៥ ដែលចុងក្រោយ ជាឥទ្ធិចិត្ត, ជវនទាំងឡាយ ដ៏សេសនោះ ជាកាមាវចរ, ចិត្ត ដែលរលត់ទៅហើយនោះឯង ជាអារម្មណ៍ នៃចិត្តទាំងពួងទាំងឡាយនោះ និង ចិត្តទាំងឡាយនោះ មិនមែនជាចិត្តមានអារម្មណ៍ផ្សេងៗ ទេ ព្រោះភាវៈនៃចិត្តទាំងនោះ មានបច្ចុប្បន្នជាអារម្មណ៍ ដោយអំណាចនៃកាល ។ មួយទៀត សូម្បីកាលបើមានភាវៈនៃចិត្ត មានអារម្មណ៍តែមួយ ឥទ្ធិចិត្តហ្នឹងឯង តែងដឹងនូវចិត្ត របស់បុគ្គលដទៃបាន, ចិត្តទាំងឡាយក្រៅអំពីនេះ ដឹងមិនបានទេ ប្រៀបដូចជាចក្ខុវិញ្ញាណ ក្នុងចក្ខុទ្វារប៉ុណ្ណោះ តែងឃើញនូវរូប, វិញ្ញាណក្រៅអំពីនេះ មិនឃើញទេ យ៉ាងនោះឯង ។

ចេតោបរិយញ្ញាណនេះ មានអារម្មណ៍ជាបច្ចុប្បន្ន ដោយអំណាចនៃសន្តតិប្បច្ចុប្បន្ន និង អទ្ធាបច្ចុប្បន្ន ដោយប្រការដូច្នេះឯង ។

ម្យ៉ាងទៀត សូម្បីសន្តតិប្បច្ចុប្បន្ន ក៏ប្រព្រឹត្តទៅ ក្នុងអទ្ធាបច្ចុប្បន្នផងដែរ ព្រោះហេតុណា, ព្រោះហេតុនោះ សន្តតិប្បច្ចុប្បន្ននោះ បណ្ឌិតគប្បីជ្រាបថា បច្ចុប្បន្នារម្មណ៍ ដោយអំណាចនៃអទ្ធាបច្ចុប្បន្ននោះឯង ។

ឯចេតោបរិយញ្ញាណនោះ ឈ្មោះថា ពហិទ្ធារម្មណ៍ ក៏ព្រោះមានចិត្តនៃបុគ្គលដទៃជាអារម្មណ៍មែនពិត ដោយប្រការដូច្នេះឯង ។

ការប្រព្រឹត្តិទៅ ក្នុងអារម្មណ៍ទាំងឡាយ ៨ នៃចេតោបរិយញ្ញាណ បណ្ឌិតគប្បីជ្រាប ដោយប្រការដូចបានពណ៌នាមកហើយនេះឯង ។

(បុព្វេនិវាសញ្ញាណ ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨)

(២៦១) បុព្វេនិវាសញ្ញាណ ប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងឡាយ ៨ ដោយអំណាចនៃបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អប្បមាណារម្មណ៍ មគ្គារម្មណ៍ អតីតារម្មណ៍ អជ្ឈត្តារម្មណ៍ ពហិទ្ធារម្មណ៍ និងនវត្តព្វារម្មណ៍ ។ សួរថា "ប្រព្រឹត្តទៅ យ៉ាងដូចម្តេច?" ។ ឆ្លើយថា "ក៏បុព្វេនិវាសញ្ញាណនោះ ក្នុងកាលជាទីរលឹករឿយៗនូវខន្ធដែលជាកាមាវចរ ជាបរិត្តារម្មណ៍, ក្នុងកាលជាទីរលឹករឿយៗ នូវខន្ធដែលជារូបាវចរ និង អរូបាវចរ ជាមហគ្គតារម្មណ៍, ក្នុងកាលជាទីរលឹករឿយៗ នូវមគ្គដែលខ្លួន ឬ បុគ្គលដទៃចំរើនហើយ និង នូវផលដែលខ្លួន ឬ បុគ្គលដទៃ ធ្វើឲ្យជាក់ច្បាស់ហើយក្នុងអតីតកាល ជាអប្បមាណារម្មណ៍, ក្នុងកាលជាទីរលឹករឿយៗ នូវមគ្គដែលខ្លួន ឬ បុគ្គលដទៃចំរើនហើយតែម្យ៉ាង ជាមគ្គារម្មណ៍ ។

ប៉ុន្តែតាមការនិយម ចេតោបរិយញ្ញាណនោះ ជាអតីតារម្មណ៍ មែនពិត ។ បណ្ឌិតគប្បីជ្រាបសេចក្តីប្លែកគ្នានេះគឺ "ក្នុងញាណទាំងឡាយទាំំង

សូម្បីចេតោបរិយញ្ញាណ និង យថាកម្មូបគញ្ញាណទាំងឡាយ ចាត់ជាអតីតារម្មណ៍ ក៏ពិតមែនហើយ ប៉ុន្តែបើទុកជាដូច្នោះ បណ្តាញាណទាំងពីរនោះ ចេតោបរិយញ្ញាណ មានចិត្តជាអតីត ឰដ៏ខាងក្នុង នៃថ្ងៃ ៧ ជាអារម្មណ៍ ។ ព្រោះថា ចេតោបរិយញ្ញាណនោះ មិនដឹងនូវខន្ធដទៃ ឬ នូវវត្ថុដែលជាប់ដោយខន្ធដទៃទេ, តែដោយបរិយាយ លោកពោលហើយថា "មគ្គារម្មណ៍" ព្រោះមានចិត្តដែលសម្បយុត្តដោយមគ្គជាអារម្មណ៍ ។ ឯយថាកម្មូបគញ្ញាណ ក៏មានត្រឹមតែចេតនា ដែលជាអតីតប៉ុណ្ណោះ ជាអារម្មណ៍ ។ ប៉ុន្តែខន្ធទាំងឡាយ និង វត្ថុអ្វីមួយ ដែលជាប់ទាក់ទងដោយខន្ធដែលជាអតីត ឈ្មោះថា មិនមែនជាអារម្មណ៍ នៃបុព្វេនិវាសញ្ញាណមិនមានទេ ។ ព្រោះថា បុព្វេនិវាសញ្ញាណនោះ ជាញាណមានដំណើរស្មើដោយសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងឡាយ គឺ ខន្ធ និង វត្ថុដែលជាប់ទាក់ទងដោយខន្ធ ដែលជាអតីត" ដូច្នេះ ។ នេះជាន័យនៃអដ្ឋកថា ក្នុងរឿងអតីតារម្មណញ្ញាណនោះ ។

ចំណែកក្នុងគម្ពីរបដ្ឋាន លោកពោលហើយថា "ខន្ធទាំងឡាយ ជាកុសល ជាបច្ច័យ នៃឥទ្ធិវិធញ្ញាណ នៃចេតោបរិយញ្ញាណ នៃបុព្វេនិវាសានុស្សតិញ្ញាណ នៃយថាកម្មូបគញ្ញាណ នៃអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ (១) " ព្រោះហេតុណា, ព្រោះហេតុនោះ ខន្ធទាំងឡាយ ៤ ក៏ជាអារម្មណ៍ នៃចេតោបរិយញ្ញាណ និង យថាកម្មូបគញ្ញាណបាន ។ មួយទៀត ក្នុងញាណទាំង ២ នោះ ខន្ធទាំងឡាយ ទាំងកុសល ទាំងអកុសលហ្នឹងឯង ជាអារម្មណ៍នៃយថាកម្មូបគញ្ញាណ ពិត យ៉ាងនេះ ។

ឯបុព្វេនិវាសញ្ញាណនោះ ក្នុងកាលជាទីរលឹកឃើញនូវខន្ធ របស់

១- អភិ. ប. ភាគទី ៩៨ ទំព័រទី ២៣១ ។

ខ្លួន ជាអជ្ឈត្តារម្មណ៍ ក្នុងកាលជាទីរលឹកឃើញនូវខន្ធ របស់អ្នកដទៃ ជាពហិទ្ធារម្មណ៍ ។ ក្នុងកាលជាទីរលឹកឃើញនូវវត្ថុដែលជាប់ដោយខន្ធ មាននាម គោត្រ និង និមិត្តនៃផែនដីជាដើម ដោយន័យ មានជាអាទិ៍ថា "ក្នុងអតីតកាល ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមវិបស្សី ទ្រង់បានកើតហើយ, ព្រះមាតារបស់ព្រះអង្គ ទ្រង់ព្រះនាមពន្ធុមតី, ព្រះបិតា ទ្រង់ព្រះនាមពន្ធុមា" ដូច្នេះ បុព្វេនិវាសញ្ញាណនោះ ជានវត្តព្វារម្មណ៍ ។

ក៏ពាក្យថា "នាមនិងគោត្រ" ក្នុងបទនេះ បានដល់សភាវៈ ដែលជាប់ដោយខន្ធ សំរេចដោយការសម្មតិ, គប្បីជ្រាបសេចក្តីនៃព្យញ្ជនៈ, មិនមែនជាព្យញ្ជនៈទេ, ព្រោះថា ព្យញ្ជនៈជាធម្មជាតគួបច្ឆារ ព្រោះភាវៈនៃព្យញ្ជនៈនោះ គឺលោកសង្គ្រោះហើយ ដោយទីជាទីកើតនៃស័ព្ទ (សទ្ទាយតនៈ) ។ សមដូចជាព្រះមានព្រះភាគ ត្រាស់ថា "និរុត្តិប្បដិសម្ភិទា មានអារម្មណ៍តួបច្ឆារ [១] " ដូច្នេះ ។

ការប្រព្រឹត្តិទៅ ក្នុងអារម្មណ៍ទាំងឡាយ ៨ នៃបុព្វេនិវាសញ្ញាណ បណ្ឌិតគប្បីជ្រាប ដូចបានពោលមកនេះឯង ។ នេះជាសេចក្តីគាប់ចិត្ត របស់យើង ក្នុងនវត្តព្វារម្មណ៍នុ៎ះ ។

(ទិព្វចក្ខុញ្ញាណ ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤)

ទិព្វចក្ខុញ្ញាណ ប្រព្រឹត្តទៅ ក្នុងអារម្មណ៍ទាំង ៤ ដោយអំណាចនៃបរិត្តារម្មណ៍ បច្ចុប្បន្នារម្មណ៍ អជ្ឈត្តារម្មណ៍ និង ពហិទ្ធារម្មណ៍ ។ សួរថា "ប្រព្រឹត្តទៅយ៉ាងដូចម្តេច?" ឆ្លើយថា "មែនពិត ទិព្វចក្ខុញ្ញាណនោះ ធ្វើនូវរូបឲ្យជាអារម្មណ៍ផង ធ្វើនូវរូបជាកាមាវចរផង ព្រោះហេតុណា ព្រោះហេតុនោះ ទិព្វចក្ខុញ្ញាណ ទើបជាបរិត្តារម្មណ៍, មួយទៀត

១- អភិ. វិ. ភាគទី ៨២ ទំព័រទី ៥០ ។

ឈ្មោះថា បច្ចុប្បន្នារម្មណ៍ ព្រោះទិព្វចក្ខុនោះ ប្រព្រឹត្តទៅ ក្នុងរូបដែលកំពុងមានប៉ុណ្ណោះ, ក្នុងកាលជាទីឃើញនូវរូបកំបាំង មានរូបដែលនៅក្នុងពោះជាដើម របស់ខ្លួន ជាអជ្ឈត្តារម្មណ៍, ក្នុងកាលជាទីឃើញនូវរូបនៃបុគ្គលដទៃ ជាពហិទ្ធារម្មណ៍" ដូច្នេះឯង ។

ការប្រព្រឹត្តិទៅ ក្នុងអារម្មណ៍ទាំង ៤ នៃទិព្វចក្ខុញ្ញាណ បណ្ឌិតគប្បីជ្រាបដូចពោលមកនេះឯង ។

(អនាគតំសញ្ញាណ ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨)

(២៦២) អនាគតំសញ្ញាណ ប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងឡាយ ៨ ដោយអំណាចនៃបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អប្បមាណារម្មណ៍ មគ្គារម្មណ៍ អនាគតារម្មណ៍ អជ្ឈត្តារម្មណ៍ ពហិទ្ធារម្មណ៍និងនវត្តព្វារម្មណ៍។ សួរថា "ប្រព្រឹត្តទៅ យ៉ាងដូចម្តេច?" ។ ឆ្លើយថា "ក៏អនាគតំសញ្ញាណនោះ ជាបរិត្តារម្មណ៍ ក្នុងកាលជាទីដឹងថា "ក្នុងអនាគត បុគ្គលនេះ នឹងកើតក្នុងកាមាវចរភព" ដូច្នេះ, ជាមហគ្គតារម្មណ៍ ក្នុងកាលជាទីដឹងថា "ក្នុងអនាគត បុគ្គលនេះនឹងកើតក្នុងរូបាវចរភព ឬអរូបាវចរភព" ដូច្នេះ, ជាអប្បមាណារម្មណ៍ ក្នុងកាលជាទីដឹងថា "ក្នុងអនាគត បុគ្គលនេះ នឹងញ៉ាំងមគ្គឲ្យចំរើន នឹងធ្វើជាក់ច្បាស់នូវផល" ដូច្នេះ, ជាមគ្គារម្មណ៍ ក្នុងកាលជាទីដឹងថា "ក្នុងអនាគត បុគ្គលនេះនឹងចំរើនមគ្គ" ដូច្នេះហ្នឹងឯង ។

តែបើពោលតាមនិយមហើយ អនាគតំសញ្ញាណនុ៎ះ ជាអនាគតារម្មណ៍ មែនពិត ។ ក្នុងអនាគតារម្មណញ្ញាណទាំងឡាយនោះ សូម្បីចេតោបរិយញ្ញាណ ជាអនាគតារម្មណ៍ ក៏ពិតមែនហើយ តែបើទុកជាដូច្នោះ ចេតោបរិយញ្ញាណនោះ មានចិត្តជាអនាគត ក្នុងខាងក្នុងនៃថ្ងៃ ៧ តែប៉ុណ្ណោះ ជាអារម្មណ៍ ។ ព្រោះថា ចេតោបរិយញ្ញាណនោះ មិនដឹង

ខន្ធដទៃផង នូវវត្ថុដែលជាប់ដោយខន្ធដទៃផង ។ (តែ) វត្ថុអ្វីមួយ ក្នុងអនាគតកាល ឈ្មោះថា មិនមែនជាអារម្មណ៍ នៃអនាគតំសញ្ញាណ មិនមានទេ តាមន័យដែលពោលហើយ ក្នុងបុព្វេនិវាសញ្ញាណ ។

ជាអជ្ឈត្តារម្មណ៍ ក្នុងកាលជាទីដឹងថា "អាត្មាអញនឹងកើត ក្នុងភពឯណោះ (ក្នុងអនាគត)" ដូច្នេះ ។ ជាពហិទ្ធារម្មណ៍ ក្នុងកាលជាទីដឹងថា "(ក្នុងអនាគត) បុគ្គលឯណោះ នឹងកើតក្នុងភពឯណោះ" ដូច្នេះ ។ ក្នុងកាលជាទីដឹងនូវនាម និង គោត្រ ដោយន័យថា "ក្នុងអនាគត ព្រះមានព្រះភាគ ព្រះនាមមេតេយ្យ នឹងឧប្បត្តិឡើង, ព្រាហ្មណ៍ ឈ្មោះសុព្រហ្ម នឹងជាបិតារបស់ព្រះអង្គ, ព្រាហ្មណី ឈ្មោះព្រហ្មវតី នឹងជាមាតា របស់ព្រះអង្គ" ដូច្នេះជាដើម ជានវត្តព្វារម្មណ៍ តាមន័យដែលបានពោលមកហើយ ក្នុងបុព្វេនិវាសញ្ញាណហ្នឹងឯង ។

ការប្រព្រឹត្តិទៅ ក្នុងអារម្មណ៍ទាំងឡាយ ៨ នៃអនាគតំសញ្ញាណ បណ្ឌិតគប្បីជ្រាប ដោយប្រការដូចបានពោលមកហើយនេះឯង ។

(យថាកម្មូបគញ្ញាណ ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៥)

យថាកម្មូបគញ្ញាណ ប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងឡាយ ៥ ដោយអំណាចនៃបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អតីតារម្មណ៍ អជ្ឈត្តារម្មណ៍ និងពហិទ្ធារម្មណ៍។ សួរថា "ប្រព្រឹត្តទៅដូចម្តេច?"។ ឆ្លើយថា "មែនពិត យថាកម្មូបគញ្ញាណនោះ ជាបរិត្តារម្មណ៍ ក្នុងកាលជាទីដឹងនូវកម្មដែលជាកាមាវចរ, ជាមហគ្គតារម្មណ៍ ក្នុងកាលជាទីដឹងនូវកម្មដែលជារូបាវចរ និង អរូបាវចរ, ជាអតីតារម្មណ៍ ព្រោះដឹងនូវកម្មដែលជាអតីតតែម្យ៉ាងប៉ុណ្ណោះ, ជាអជ្ឈត្តារម្មណ៍ ក្នុងកាលជាទីដឹងនូវកម្ម របស់ខ្លួន, ជាពហិទ្ធារម្មណ៍ ក្នុងកាលជាទីដឹងនូវកម្ម របស់អ្នកដទៃ" ដូច្នេះ ។

ការប្រព្រឹត្តិទៅ ក្នុងអារម្មណ៍ទាំងឡាយ ៥ នៃយថាកម្មូបគញ្ញាណ បណ្ឌិតគប្បីជ្រាប ដោយប្រការដូចបានពោលមកនេះឯង ។

ចំណែកក្នុងការពណ៌នា នូវអជ្ឈត្តារម្មណ៍ និង ពហិទ្ធារម្មណ៍នេះ ពាក្យឯណាដែលព្រះមានព្រះភាគត្រាស់ហើយថា "យថាកម្មូបគញ្ញាណនោះ ជាអជ្ឈត្តារម្មណ៍ផង ជាពហិទ្ធារម្មណ៍ផងមែនពិត" ដូច្នេះ, ពាក្យនោះ ព្រះអង្គត្រាស់ហើយថា "យថាកម្មូបគញ្ញាណនុ៎ះ ជាអជ្ឈត្តារម្មណ៍ផង ជាពហិទ្ធារម្មណ៍ផង ក្នុងកាលជាទីដឹងក្នុងខាងក្នុង តាមកាល ក្នុងខាងក្រៅតាមកាល ប៉ុណ្ណោះឯង" ដូច្នេះ ។

បរិច្ឆេទ ទី១៣ ឈ្មោះអភិញ្ញានិទ្ទេស
ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ
ដែលខ្ញុំរៀបរៀងហើយ ដើម្បីប្រយោជន៍ដល់កិរិយារីករាយទួទៅ
ចប់ហើយ ដោយនូវប្រការអម្បាលនេះឯងហោង ។

បករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គប្រែ ភាគទី២ ចប់

♣ ♣ ♣

បានរៀបរៀងចប់សព្វគ្រប់
នៅថ្ងៃអង្គារ ៣ កើត ខែចែត្រ ព.ស. ២៥៥១
ត្រូវនឹងថ្ងៃ ទី៨ ខែមេសា គ.ស. ២០០៨
វេលាម៉ោង ៧ យប់

សូមសិក្សាបន្តទៅ ភាគ ទី៣ ទៀត !

រាយនាមពុទ្ធបរិស័ទ ជួយឧបត្ថម្ភ ក្នុងធម្មទាននេះ

ប្រអប់ធម្មបូជា (វត្តខ្មែរសាន់តាអាណា)	៣,២០០ដុ
លោក ឡូ-ប៊ុនឡេង អ្នកស្រីអៀប-ឆៃគីម	២,៦៩០ដុ
ឧបាសិកាអៀប-ឆៃគិម ឧបាសក ឡូ-ប៊ុនឡេង	២,០០០ដុ
ធម្មបូជា បុណ្យចំរើនព្រះជន្ម ព្រះភិក្ខុ សែម-សុឃឿន	១,៧៩០ដុ
ពុទ្ធបរិស័ទ វត្តសន្សំកុសល អាចារ្យអឿ-សៅ	១,០០០ដុ
ឧបាសិកា អៀប-ឆៃហុង	១,០០០ដុ
ឧបាសិកាឈឹម-គីមស្រ៊ិន និង កូនចៅ ព្រមទាំងញាតិមិត្រ	១,០០០ដុ
ឧបាសិកា នួន-វណ្ណា ព្រមទាំងកូនចៅ	១,០០០ដុ
ឧបាសិកា នួន-វណ្ណា	៩០០ដុ
លោក វង់-ម៉ៅ អ្នកស្រីឆាន់-កាន់ដួង	៨៩០ដុ
ឧបាសក វង្ស-ម៉ៅ ឧ:សិកា ឆាន់-កាន់ដួង	៥៩៥ដុ
អ្នកស្រី ឆាន់-ហៃគីង	៥០០ដុ
វត្តមិនីសុតារាម	៥០០ដុ
ភិក្ខុ មាស-គីមអេង សីលបញ្ញា	៥០០ដុ
ភិក្ខុ ភាគ់-ឈួន	៥០០ដុ
ឧបាសិកា ឆាន់-ហាយ ព្រមទាំងកូនចៅ	៥០០ដុ
បុណ្យបច្ច័យ ៤ ឧបាសិកា យឹម-លឹម កូនចៅ និង ញាតិមិត្រ	៥០០ដុ
ឧបាសិកា វ៉េន-លួន់ (សុខ-រស់) និង កូនចៅ	៤៥០ដុ
ធម្មទេសនា ព្រះអង្គសឿន	៤៤៨ដុ
ពុទ្ធបរិស័ទវត្តសាន់តាអាណា ថ្ងៃសីល	៤២០ដុ
ឧបាសិកា ស៊ីណា-ផូ SOPHANNA LAO	៤០២ដុ
បុណ្យឧបាសិកា លី-ឡាំងជាង និង កូនចៅ	៤០០ដុ
ភិក្ខុ អាំង-ឃុង ឧបាសិកា តាន់-គីមថាន់ បុត្រធីតា និង ចៅ	៤០០ដុ
លោកតែ-ទាសៀ អ្នកស្រីលឹម-ណៃហ៊ួង ព្រមទាំងញាតិមិត្រ	៤០០ដុ
ភិក្ខុ អ៊ុង-អ៊ិន ឧបាសិកា សែម-ស៊ីផន	៤០០ដុ
ភិក្ខុមហាសម-យស (វត្តម៉ាក់សី ប្រទេសបារាំង)	៤០០ដុ
បច្ច័យ ៤ ពុទ្ធបរិស័ទ វត្តរតនប្រទីប អូតាវ៉ា	៣៥០ដុ
បុណ្យលោកតា អ៊ាប-ភាវ	៣៣០ដុ
ឧបាសិកាលឹម-គាមទី ព្រមទាំងបុត្រ, គី-សេរី ភរិយានិងបុត្រ, សុភាព-តាន់, ឈាងហ៊-តាន់, ម៉ុរីណា-តាន់, ចាន់បូណា-ហេង	៣៣០ដុ
ព្រះធម្មទេសនា ធម្មាចារ្យ កែវ-វិមុត្តិ ក្នុងវត្តសាន់តាអាណា	៣២៧ដុ
ព្រះតេជះគុណប្រកប វត្តជម្ពូរុក្ខាវនារាម	៣១៥ដុ

លោក ស៊ុន-សៀក ព្រមទាំងគ្រួសារ	៣០៧ដុ
ភិក្ខុ អ៊ុន-រិន សង្ឃរក្ខិតោ	៣០០ដុ
ឧបាសិកា អ៊ុក-ទូរេត	៣០០ដុ
អ្នកស្រី សុផាត-ភឿង, ឧបាសិកា ផុន និង គ្រួសារ	៣០០ដុ
ឧបាសក យស់-សាអ៊ុល ឧបាសិកា យស់-អានីតា (ឌី-ស៊ីវឡាំង	៣០០ដុ
ព្រះតេជះព្រះគុណ ប្រកប វត្តជម្ពូរុក្ខារាម	៣០០ដុ
ភិក្ខុវិនយធរោ មហាឃិន-នឿន	៣០០ដុ
ឧបាសក នង-ហាក់ ព្រមទាំងគ្រួសារ កូនចៅ	៣០០ដុ
លោកគ្រូរក្ខិតធម្មោ គង់-សូផាន	៣០០ដុ
លោកអាចារ្យ អ៊ុង-អ៊ិន ព្រមទាំងគ្រួសារ និង កូនចៅ	៣០០ដុ
លោកសុជាតតោ-សំលឿង អ្នកស្រីស៊ុម-សាឡាត់	៣០០ដុ
អ្នកស្រី RATH KIM & BILL CHHAY	២៦០ដុ
ពុទ្ធបរិស័ទ វត្តខ្មែរបាលិលេយ្យ	២៦០ដុ
បច្ច័យបូជាព្រះធម៌ទេសនា ឆ្លងកុដិវត្តសាន់ហូសេ ០៨-០៦-១០	២៥៨ដុ
ឧបាសិកា សៅ-យ៉ៃ ព្រមទាំងកូនចៅ	២៥០ដុ
ព្រះតេជះព្រះគុណធម្មថេរោ (សៅ-ឃន)	២៥០ដុ
ឧបាសក ចេក-ឃាន ឧបាសិកា ច័ន្ទ-ឈួម ព្រមទាំងកូនចៅ	២៥០ដុ
ឧបាសក ស៊ុម-ស៊ីម និង គ្រួសារ កូនចៅ	២៥០ដុ
អ្នកស្រី ធីរ៉ា RICHARCH (GA)	២២០ដុ
លោកអាចារ្យ ភាគ-ឈួន គ្រួសារ និង កូនចៅ	២២០ដុ
ឧបាសិកា លឹម-គាមទី និង បុត្រធីតា	២២០ដុ
ញោម សារុន និង កូន	២១៧ដុ
លោក រិទ្ធិ-ស៊ាន អ្នកស្រីស៊ីវ-ង៉ោ,សុផានី, លីនដា, សោភ័ណ	២១០ដុ
កេតុ-ថូ	២០០ដុ
ឧបាសិកា លឹម-ណៃស្រីម កូនចៅ	២០០ដុ
អ្នកស្រីស៊ូ-ហាច និង កូនចៅ	២០០ដុ
លោកឈាន-សារឿន អ្នកស្រី ឡឹង-គីមស្រាន	២០០ដុ
អាចារ្យប្រាក់-ភាច ឧបាសិកា សុខ-ភឿន	២០០ដុ
ឧត្តមធម្មឃោសាចារ្យ កុត-កុសល កែវ-សុធម្មា ឡៃ-យ៉ុន	២០០ដុ
លោក តាំង-ចឺ អ្នកស្រី ឡេា-គីមឡេង	២០០ដុ
លោក ឡាំ-រឿង ព្រមទាំងក្រុមគ្រួសារ	២០០ដុ
Mrs NAMTYHUY, Mr, & Mrs. KEIW LEE, TINATH LEE	២០០ដុ
ឧបាសិកា អ៊ឹង-សាយទាវ នាង អ៊ឹង-គិមអេង	២០០ដុ

ព្រះតេជះគុណ ថុន-សុផុន	២០០ដុ
លោកវោហា-ជួន អ្នកស្រីណាត្រី-ជួន	២០០ដុ
ពុទ្ធិកសមាគម វត្តធម្មរង្សី	២០០ដុ
លោក ឯក-ឆាលី អ្នកស្រី អោម-ខុន	២០០ដុ
ឧបាសិកា ឡូ-មេងឃន ព្រមទាំងកូន	២០០ដុ
លោក ឡូ-មេងហ៊	២០០ដុ
ប៊ុន-ឡេង និង តែ-គិម	២០០ដុ
ស៊ិម-គិម យ៉ុន	២០០ដុ
លោក សុខ-មុត អ្នកស្រី មាស-សន្ដាវរុណ និង បងប្អូន	២០០ដុ
ឧបាសិកា សុខ-មឿន ឧបាសិកា តាន់-សម្បត្តិ	២០០ដុ
អ្នកស្រី មិញ-សូហាច ព្រមទាំង កូនចៅ	២០០ដុ
ឧបាសិកា ចៅ-សារួន ព្រមទាំងកូនចៅ	២០០ដុ
ពុទ្ធបរិស័ទវត្តវិបស្សនារាម	២០០ដុ
ឧបាសក ជូ-មី ឧបាសិកា ឯក-បូលីន និង កូនចៅ	១៨៥ដុ
អ្នកស្រី កុត-កណ្ណិកា សោម៉ា(សុជាតា) ស្វាមី និង បុត្រ	១៧៥ដុ
លោកតាអ៊ឹម-ពន្លក និង ឧបាសិកាដួង-សុខុម	១៧៥ដុ
ភិក្ខុ ប្រាជ្ញ-សារ៉ាន់	១៦៦ដុ
DARA HENG	១៥០ដុ
ឧបាសិកា អ៊ុន-ហេង និង កូនចៅ	១៥០ដុ
ឧបាសិកា វេន	១៥០ដុ
ភិក្ខុ ម៉ែន-សុខ	១៤០ដុ
ភិក្ខុ និង សាមណេរ វត្តអែរ៉ាប់	១៣០ដុ
ឧបាសក ជ្រូក-វួន ឧបាសិកា ម៉ែន-ផាត កូនចៅ	១២០ដុ
ឧបាសិកា យឹម-លឹម ព្រមទាំងកូនចៅ	១២០ដុ
ឧបាសិកា អ៊ុក-ស៊ីណា	១៥០ដុ
ឧបាសិកា ផាវ-សារៀប, សក់-សាលឿន លោកអេង-កាំង	១៥០ដុ
ឧបាសិកា ទួន-មុំ	១៥០ដុ
ឧបាសិកា ប្រីយ៍-យ៉ុម	១៤០ដុ
ឧបាសិកា ចែត-ទទឹម	១៤០ដុ
លោក ឈុន-គីម អៀត និង គ្រួសារ	១៤០ដុ
លោកអាចារ្យ ប៉េ-រី ឧបាសិកា ថូ-ញ៉ឹង និង កូនចៅ	១២៥ដុ
ឧបាសក ជូ-មី ឧបាសិកា ឯក-បូលីន	១២០ដុ
ឧបាសិកា លី-ឡាំងជាង និង កូនចៅ	១២០ដុ

លោក ពា-ប៉ាវស្រី ព្រមទាំងគ្រួសារ	១២០ដុ
អ្នកស្រី ញ៉ឹក-ស៊ីថា និង កូនចៅ	១២០ដុ
ពុទ្ធបរិស័ទ វត្ត រតនារាម	១១៨ដុ
ព្រះធម៌ទេសនា	១១៥ដុ
ភិក្ខុ ប៉ាន-សំម៉ាយ និង ពុទ្ធបរិស័ទ វត្តច័ន្ទស៊ីសាមគ្គីធម៌	១១០ដុ
ឧបាសិកា ញ៉ែម-នីម និងកូនចៅ	១១០ដុ
ភិក្ខុ មហាប៊ុន-ឈឺន	១១០ដុ
ឧបាសិកា លី-គឹមស៊ា និង បុត្រធីតា	១១០ដុ
ភិក្ខុ សោម-សុភា (ធម្មធរោ)	១០៧ដុ
ភិក្ខុ ឫទ្ធិពល នាថបណ្ឌិតោ	១០៥ដុ
CHHAY SEREI CHAN	១០៥ដុ
អ្នកស្រី ជា-តោ	១០៥ដុ
ភិក្ខុ ឃុន-ទុយ	១០៥ដុ
លោក ញិន-ផុន អ្នកស្រី សុខ-សារ៉េត កញ្ញា ញិន-រ័ត្ន	១០១ដុ
លោក អឿ-សៅ, ឧបាសកប៊ូ-ហោនាង,	
ឧបាសិកា អ៊ឹង-រិទ្ធានី, ឧបាសិកាលី-ប៉ូលីន ស៊ីម-ប៉ូ	១០០ដុ
លោក តាំង-ហាំងសាយ អ្នកស្រីជីវ-សុខមួយ និង កូនចៅ	១០០ដុ
លោកអាចារ្យ ឡុង ឧបាសិកា ឈាង-សាមិន	១០០ដុ
លោក សារិន អ្នកស្រី គីម-លាង	១០០ដុ
ឧបាសិកា សុខ-សាមឿន តាន់-សម្បត្តិ	១០០ដុ
ឧបាសិកា អ៊ឹម-ណូយ	១០០ដុ
MOLANIE, ALLAN, LONIS & MADELYN LIM	១០០ដុ
អាចារ្យ វិសុទ្ធិ-ឱម ឧបាសិកា សូត-សាខន	១០០ដុ
អ្នកស្រី កែវ-បុប្ផាទិព្វ	១០០ដុ
ឧបាសិកា កង-សាលី និង កូនចៅ	១០០ដុ
TAING KIM LEAANG	១០០ដុ
ឧបាសិកា ថោង-មុំ	១០០ដុ
ឧបាសិកា ហ៊ីង-ប៊ូ	១០០ដុ
អ្នកស្រី គួយ-វ៉ាន់	១០០ដុ
ឧបាសិកា ភន-ស៊ាងហៃ និង បុត្រធីតា	១០០ដុ
ឧបាសិកា យិន-ហ៊ុន ឧបាសក យិន-សឿន	១០០ដុ
ឧបាសិកា យូ-ស្រ៊ន	១០០ដុ
លោកអាចារ្យ ហេង អ្នកស្រី ហ៊ុន-គឹមសាយ	១០០ដុ
ឧបាសិកា ញ៉ក-ហ៊ួ ព្រមទាំងកូនចៅ	១០០ដុ

ឧបាសក ឈុំ-កុសល ឧបាសិកា ហេង-យិន និង បុត្រធីតា	១០០ដុ
លោក ស៊ីសុវណ្ណ-ណាយ និង ភរិយា	១០០ដុ
លោក ផង់-វ៉ើម អ្នកស្រី វ៉ែន-អឿន	១០០ដុ
ឧបាសិកា សាន-អឿន ព្រមទាំងកូនចៅ	១០០ដុ
ឧបាសិកា សួស-ណៃទៀង ព្រមទាំងកូនចៅ	១០០ដុ
ឧបាសិកា ជិង-សាយ ថ ព្រមទាំងកូនចៅ	១០០ដុ
ឧបាសិកា ណាវ៉េត-អ៊ូ	១០០ដុ
ឧបាសក ថ្លាង-សាវន ឧបាសិកា យិន-សំណាង	១០០ដុ
ឧបាសិកា កាក់-កួយ	១០០ដុ
ឧបាសក ស៊ិន-ផូ លោកយាយពុំ	១០០ដុ
ឧបាសិកា ឌុច-សាមីន	១០០ដុ
បណ្ឌិត តូច-ផលមាន និង គ្រួសារ	១០០ដុ
កម្លោះ ពៅ វីឌៀល សម្បូរ	១០០ដុ
ផ្លូក-សុទ្ធី	១១០ដុ
ឧបាសិកា កុល-យន់ យាយសម្មា	១០០ដុ
ឧបាសិកា ឈា លោកតា ហេន	១០០ដុ
ឧបាសិកា ញ៉ៀម-ឡាង និង បុត្រ	១០០ដុ
ឧបាសិកា កាក់-គីគង់ និង បុត្រធីតា	១០០ដុ
LAKHANA SAR (BONG LEAK) កូនយាយរេន	១០០ដុ
លោក ប៉ុក-ប៊ុនរិទ្ធ ព្រមទាំងគ្រួសារ និង កូនចៅ	១០០ដុ
ឧបាសិកា ទិត-សាត ព្រមទាំងកូនចៅ	១០០ដុ
ឧបាសិកា អ៊ុក-ទូរ៉េត	១០០ដុ
ម៉ន-ស៊ិងហេង ភរិយា ឡាយ-សុខគា	១០០ដុ
ស៊ុម-រ៉ាត់ ភរិយា យិន-ឃីម និង បុត្រធីតា	១០០ដុ
ឧបាសិកា ឱម-សង្វ៉ាន លោកនេត្រ-ហេង និងកូនចៅ	១០០ដុ
ឧបាសិកា គីម-ស៊ី លោក ប្រៀន-គាង និង ភរិយា	១០០ដុ
ឧបាសិកា ជា-លីមអេង	១០០ដុ
ឧបាសិកាផាវ-សារៀប អ្នកស្រីសក់-សាលឿន គ្រួសារ	១០០ដុ
ឧបាសិកា ផាន់-ឡាន និង បុត្រធីតា	១០០ដុ
លោកគ្រូ ឆាយ-យស ឧបាសិកា ចាប-សំអៀន	១០០ដុ
ឧបាសិកា កុត-សាខន និង បុត្រធិតា	១០០ដុ
ភិក្ខុ អ៊ុន-វ៉ិន	១០០ដុ
លោក ជា-ព្រហម៉ន នាង ផ្លាសារ៉េត	១០០ដុ
នាង ព្រហ្ម-ច័ន្ទ សូវ៉ន និង កូនលក្ខណា	១០០ដុ

លោកអាចារ្យ កែវ-ប៉ុន ឧបាសិកា ហាច-សួង	១០០ដុ
ឧបាសិកា ប៉ាន-សារិទ្ធ ព្រមទាំងកូនចៅ	១០០ដុ
អ្នកស្រី ប៊ុត-សុផានី	១០០ដុ
ឧបាសិកា គាន-សរ	១០០ដុ
លោក តាន់-កៅ អ្នកស្រី តាន់-សារឿន	១០០ដុ
ឧបាសិកា ង៉ោ-ស៊ូអេង	១០០ដុ
ព្រះវិភទ្ទញ្ញាណ (ព្រហ្ម-ខៀន) វត្តសុវណ្ណគិរី	១០០ដុ
ភិក្ខុ ប៊ុន-ស្លៀន ធម្មវរោ	១០០ដុ
ភិក្ខុ សឹម-សៀម ធម្មរក្ខិតោ	១០០ដុ
ភិក្ខុ អឿ-សៅ	១០០ដុ
ព្រះតេជះគុណមាស-គីមអេង	១០០ដុ
ភិក្ខុ យិន-សាគុណ	១០០ដុ
ព្រះតេជះគុណ ម៉ី-រស	១០០ដុ
ភិក្ខុ ឡាយ-រិន	១០០ដុ
ភិក្ខុ មហាមុនី-រត្ន	១០០ដុ
ភិក្ខុ គង់-សុទ្ធី	១០០ដុ
សាមណេរ ជិម-មាល័យ	១០០ដុ
លោកអាចារ្យ ថាច់-សុង ហុង-គិមហ៊ាន់	១០០ដុ
អ្នកស្រី ឆាន់-ហ្វាង	១០០ដុ
លោកអាចារ្យស៊ីន-ដុង ឧបាសិកា ឡុង-ប៉ែន	១០០ដុ
ឧបាសក លន់-ធន់	១០០ដុ
ឧបាសក ជិក-វិញ និង ឧបាសិកា គិម-ថាញ់	១០០ដុ
ឧបាសិកា ផាវ-សារៀប និង កូនចៅ	១០០ដុ
អ្នកស្រី ឈុន-យ៉េន	១០០ដុ
ឧបាសក ហ៊ឹម-ម៉ៅ ភរិយា និង បុត្រធីតា	១០០ដុ
អ្នកស្រី លឹម-ចាន់ណា	១០០ដុ
បុណ្យឧបាសក សឹន-អឿង ឧបាសិកា គិម-ថីសី	១០០ដុ
ភិក្ខុ តាន់-ភោគ កិត្តិសារោ (វត្តធម្មរង្សី)	១០០ដុ
ព្រះតេជគុណ ឡុង-សុខឡាំ (វត្តសាគរបុរី)	១០០ដុ
ឱឧបាសិកា តាន់-ឈីវគិន និង កូនចៅ	
លី-ឆេងស៊ុន និង ទឹង-រួចហ៊ុន ព្រមទាំង កូនចៅ	១០០ដុ
ភិក្ខុ សំ-រ័ត្ន	១០០ដុ
ឧបាសិកា អ៊ូ-ហាំងចេង និង កូនចៅ	១០០ដុ
ភិក្ខុ ប៊ូ-សាំងយ៉ុន កិត្តិកធម្មោ	១០០ដុ

លោកអាចារ្យ អោក-យៀម និង កូនចៅ	១០០ដុ
ឧបាសិកា ធិ-ប៊ុតស៊ាន	១០០ដុ
លោក និង លោកស្រី សំបាន-នូ	១០០ដុ
លោកខៀវ-ស៊ីណារ៉េត	១០០ដុ
លោក សារិន អ្នកស្រី គីម-លាង	១០០ដុ
លឹម-យ៉េត	១០០ដុ
វង្ស-កុរុណា និង គ្រួសារ	១០០ដុ
វង្ស-វីណា ស្វាមី និង បុត្រ	១០០ដុ
ឧបាសិកា លឹម-ណៃស្រីម	១០០ដុ
ឧបាសិកា សេង-យ៉ាន	១០០ដុ
ឧបាសិកា ព្រះឈាង ហៅ ញាណ-សុធា	១០០ដុ
កុល-ស៊ុម	១០០ដុ
ឧបាសក អឿ-សៅ	១០០ដុ
ប៉ក់-បុប្ផា	១០០ដុ
លោក និង លោកស្រី សុផាន	១០០ដុ
ឧបាសិកា ភន-ស៊ាងហៃ	១០០ដុ
ឧបាសិកា ភន-ស៊ាងហៃ និង បុត្រ, ឧបាសិកា យ៉ក-ស្រ៊ន, ឧបាសិកា ជា-លាងហ៊ី, ឧបាសិកា ឈុន-គីមស្រី	១០០ដុ
ឧបាសិកា អ៊ុន-អ៊ន	១០០ដុ
លោក ង៉ូវ-មួយឡាយ និង បុត្រ	១០០ដុ
ឧបាសិកា អៀប-ឆៃហុង	១០០ដុ
ឧបាសិកា ហុយ-ណាំទី	១០០ដុ
ឧបាសិកា ឡុង-ប៉ែន ឧបាសក សន-ជុំ	១០០ដុ
ឧបាសិកា ស៊ន-ឡេង	១០០ដុ
បុណ្យ ១០០ ថ្ងៃ លោកអ៊ុង-ធារី	១០០ដុ
ឧបាសិកា សរ-យុត	១០០ដុ
ឧបាសក អៀង-ឆាយ ឧបាសិកា អៀ-កេសរ	១០០ដុ
ឧបាសក អ៊ុន-ឆាយត្រី	១០០ដុ
ឧបាសក ហោ-លាន ឧបាសិកា ឆឹង-អុន	១០០ដុ
លោកអាចារ្យ ម៉ន-ផាន ផង់-គាំ	១០០ដុ
ភិក្ខុ វិជ្ជាសម្បន្នោ វត្តពន្លឺពុទ្ធចក្រ	១០០ដុ
ឧបាសិកា ថេត-រ៉ុន ឧបាសក វ៉ៃ-សារុន	១០០ដុ
ឧបាសិកា សុផន-សួរ	១០០ដុ
ឧបាសិកា តាន់-ណៃស៊ីន និង កូនចៅ	១០០ដុ

ឧបាសិកា ឈុន-យ៉េន	១០០ដុ
លោកអាចារ្យ ដោក-សុន ឧបាសិកា អ៊ូ-អ៊ូច និង កូនចៅ	១០០ដុ
ឧបាសក យ៉ម-ដេង ឧបាសិកា ហេង-វណ្ណឌី កូនចៅ	១០០ដុ
ឧបាសិកា ធូ-ម៉ុំ ឧបាសក កុយ-ធួន	១០០ដុ
ឧបាសក លី-ថុង អ្នកស្រី គីម-សាន ព្រមទាំងកូនចៅ	១០០ដុ
លោក ហៀប-បេ អ្នកស្រី ឡៅ-កែវម្លិះ	១០០ដុ
អ្នកស្រី ញ៉ិក-សីថា ព្រមទាំងកូនចៅ	១០០ដុ
ភិក្ខុ សុខ-ភាគរ:	១០០ដុ
អ្នកស្រី សំបូ-រ័ត្ន (ហៅហ៊ីង-ស៊ុនថា)	១០០ដុ
ភិក្ខុ គីម-បាន	១០០ដុ
ភិក្ខុ ទិម-ញូល (តិណកាមោ)	១០០ដុ
ឧបាសក ម៉េង-ប៉ុង ឧបាសិកា ចាន់-ញឹម	១០០ដុ
ឧបាសក ផេន-អាន ឧបាសិកា លន់-សេងហ៊ាង	១០០ដុ
អ្នកស្រី ទេព-សូនី	១០០ដុ
ឧបាសិកា ពៅ-តុន ព្រមទាំងកូនប្រុសស្រី	១០០ដុ
លោក កែវ-សំអឿន អ្នកស្រី ហ៊ុន-វណ្ណា និង បុត្រ	១០០ដុ
PHNOM PENP EXPRESS	៩០ដុ
LOEUNG NINA	៩០ដុ
អ្នកស្រី សន-លីណា ហៅ អាភាព កូនខ្ញុំ	៩០ដុ
លោក តាំង-ហាំងឆាយ អ្នកស្រីជីវ-សុខម៉ួយ	៩០ដុ
ឧបាសិកា លឹម-មួយជូ	៩០ដុ
ភិក្ខុ ជា-ហឿង ឧបាសិកា អ៊ូច-សូត្រ	៩០ដុ
បូជាព្រះធម៌ទេសនា វត្តសាន់តាអាណា	៨៨ដុ
ឧបាសក ជូ-មី ឧបាសិកា បូលីន កូនចៅ	៨៥ដុ
ឧបាសិកា ទិត្យ-យ៉ាន ប៉ុក-សំអាន	៨០ដុ
អ្នកស្រី សឿន-សុឃួន ព្រមទាំងគ្រួសារ	៨០ដុ
ឧបាសិកា ព្រះ-ឈាង (ញាណសុភា)	៨០ដុ
ឧបាសក សន-ជុង ឧបាសិកា ឡុង-ប៉ែន	៨០ដុ
ឧបាសិកា យី-គីមលន	៨០ដុ
ឧបាសិកា ទិត-សាធ	៧០ដុ
ឧបាសក ទៀង ឧបាសិកា រួម និងកូនចៅ	៧០ដុ
លោក ចាន់-យឿន អ្នកស្រី ងួន-ខន, អ្នកស្រី ងួន-ដកច័ន្ទ, ព្រមទាំងបុត្រធីតា	៧០ដុ
អ្នកស្រី គីម-សារុន និង លោក គីរី	៧០ដុ

បច្ច័យធម្មទេសនា ភិក្ខុយិន-នឿន	៦៥ដុ
ភិក្ខុ សន-សែន (វត្តព្រះពុទ្ធ)	៦០ដុ
ឧបាសក តេង-ខាំសន ឧបាសិកា ធុយ-ប៊ុនម៉ា	៦០ដុ
ឧបាសិកា យឹម-លឹម ព្រមទាំងកូនចៅ	៦០ដុ
នាង គ្រួ	៦០ដុ
ឧបាសិកា លឹម-អាង	៦០ដុ
ឧបាសិកា ចេង-ប៉ោយ	៦០ដុ
ឧបាសិកា ងី-ឆេ កូនចៅ	៦០ដុ
លោក ឡេង-ឆាយ និង សុខ-ម៉ួយជាវ	៦០ដុ
យាយ អ៊ុំង-ហ្គិច គ្រី-ម៉េងលាង គ្រី-ជិនណាំ	៦០ដុ
ឧបាសក ឡឹម-ម៉ាតធីតា ឧបាសិកា តាំង-ធីយន	៦០ដុ
ទៀវ-ឈីវហ៊ុន	៦០ដុ
ឧបាសិកា ទូន-សារ៉េន (ហៅវ៉ុយ)	៦០ដុ
អ្នកស្រី ស៊ី-អ៊ីង	៦០ដុ
អ្នកស្រី សំបួ-រ័ត្ន	៦០ដុ
ឧបាសក ខោល-ឈិន ឧបាសិកា ឡូ-គីមហ៊ាង	៦០ដុ
អ្នកស្រី ជូ-ជាតិ	៦០ដុ
ថាច-សៀន	៦០ដុ
លោក ទូច-សោភ័ណ អ្នកស្រី ស៊ីនួន	៦០ដុ
អ្នកស្រី គីម-រួច	៦០ដុ
អ្នកស្រី លីណា-តាន់	៦០ដុ
ឧបាសិកា ហេង-ស៊ន	៦០ដុ
ក្រុមវេន គ្រួសារតាម៉ាន និង ញាតិមិត្រ នៅសៅមុនី	៥៦ដុ
បច្ច័យបិណ្ឌបាត្រ ភិក្ខុ សឿ-សុជិន វត្តសាន់ហូសេ	៥៥ដុ
អ្នកស្រី ឡាច-រ៉ាន់ និង គ្រួសារ	៥៥ដុ
ROSS CHANTY	៥៥ដុ
តៅ-ច្រិក និង កូនចៅ	៥៣ដុ
អ្នកស្រី ចាន់-កូឡាប, សេក-គ្រិច, សេក-ទី	៥៣ដុ
ឧបាសក សុភោគ-ឧស្សរេន	៥០ដុ
ឧបាសក អ៊ិន-លួង ឧបាសិកា ហ៊ាម-តេង	៥០ដុ
ឧបាសិកា សេង-ម៉ាឡៃ, សាំង-ធារ៉ា, សាំង-ធារី	៥០ដុ
លោក សាផូ-យន អ្នកស្រី ច័ន្ទ និង បុត្រ	៥០ដុ
លោក យន-ឡាំង អ្នកស្រី អ៊ិត-លី និង បុត្រ	៥០ដុ
លោក រឿន-ថន អ្នកស្រី លីង	៥០ដុ

ឧបាសិកា ឡុង-អ៊ីម	៥០ដុ
ឧបាសក សឿន ឧបាសិកា គីម-ឈុន	៥០ដុ
ឧបាសិកា ទឹម-ហ៊ាន	៥០ដុ
លោក ទូច-ស៊ីមន ប៊ិន	៥០ដុ
យិម-ផល្លា រី-ផៃ	៥០ដុ
អ្នកស្រី ហេង-ឈាប	៥០ដុ
ឧបាសក ឡូ-ប៊ុនឡេង ឧបាសិកា អៀប-ឆៃគិម	៥០ដុ
ឧបាសក គង់-វុត ឧបាសិកា អ៊ុក-ស៊ិនហួរ	៥០ដុ
ឧបាសិកា លឹម-គាមទី ព្រមទាំងបុត្រ	៥០ដុ
ឧបាសិកា លី-ប៉ូលីន ស៊ឹម-ប៉ូ	៥០ដុ
ឧបាសិកា សុខ-លន់	៥០ដុ
SIDARY SAM	៥០ដុ
លោក ភួង-ប៊ុនហ៊ីម អ្នកស្រី ងួន-យានា	៥០ដុ
អ្នកស្រី អ៊ុល-ស៊ីណា	៥០ដុ
វត្តត្រៃកូដិ	៥០ដុ
ឆាន់-ហ្គួង និង គ្រួសារ	៥០ដុ
ភាច-សារី	៥០ដុ
សុភាក់ និង គ្រួសារ	៥០ដុ
ពូធី ថង	៥០ដុ
អ្នកស្រី លី-មឿន	៥០ដុ
អ្នកស្រី គីមលី-ផ្លុង	៥០ដុ
ឧបាសិកា ឌុច-សាខន	៥០ដុ
ឧបាសិកា ថាប់-ថូ	៥០ដុ
លោក ឈុន-គីមអៀត និង ភរិយា	៥០ដុ
ឧបាសិកា តាំង-គីមលាង	៥០ដុ
អ្នកស្រី សុខ-គាង	៥០ដុ
មុនី-ឡាំ និង គ្រួសារ	៥០ដុ
ម្ដាយសាមណេរចេក	៥០ដុ
លោក គង់-វុត អ្នកស្រី អ៊ុក-ស៊ិនហ៊ា	៥០ដុ
ភិក្ខុ ធឹង យីម (វត្តធម្មនិការាម)	៥០ដុ
លោកយាយ ជិ ប៉ុនឡុង និង ប៊ូ រ៉ាស៊ី	៥០ដុ
លោក វេង ណាំ និង សក់ សាន់នី	៥០ដុ
ព្រះគ្រូចៅអធិការ ទេព-សៀង វត្តត្រៃរតនារាម ប្រទេសបារាំង	៥០E
យុវជន ដារ៉ា-ហេង	៥០ដុ

ឧបាសិកា ម៉ែន-ណៃស្រីម	៥០ដុ
Mr. ANG CHUN	៥០ដុ
ឧបាសិកា លី-ណារី និង កូនចៅ	៥០ដុ
ឧបាសិកា សរ-យុត	៥០ដុ
ឧបាសិកា ពា-តុប	៥០ដុ
ឧបាសិកា គី-គង់	៥០ដុ
អ្នកស្រី សូរិយា អូស្តិន	៥០ដុ
បងតាំង	៥០ដុ
អ្នកស្រី ឈុន-យេន	៥០ដុ
អ្នកស្រី អ៊ុង-ស៊ីផាន់ណា	៥០ដុ
លោក អ៊ែង-លី អ្នកស្រី ទួត-រ៉ុម	៥០ដុ
អ្នកស្រី លីសា (LISA)	៥០ដុ
គិម-ឡឹម ថាញ់	៥០ដុ
លោក សោម-ងន អ្នកស្រីឡៅ-ម៉ាឡៃ	៥០ដុ
អ្នកស្រី ខៀវ□ស្រីវ៉ែន ព្រមទាំងគ្រួសារ	៥០ដុ
ពេទ្យ សម្បត្តិ និង គ្រួសារ	៥០ដុ
លោកអាចារ្យ អ៊ុយ-យាន	៥០ដុ
លោក លី-ហួ និង អ្នកស្រី វ៉ាស៊ី-ងួន	៥០ដុ
ឧបាសិកា សួយ-សេន	៥០ដុ
ភិក្ខុ នង-សុជាតិ	៥០ដុ
លោក មុខ-សាម៉ន និង គ្រួសារ	៥០ដុ
អ៊ាម-គាក់ និង ប៊ី-ស៊ីម	៥០ដុ
ឧបាសិកា ហេង-ថូ ឧបាសក ស៊ា-ថូ កូនចៅ	៥០ដុ
ឧបាសិកា ថ្លាង-ធៀម	៥០ដុ
អ្នកស្រី ឡៃ-សៀង គ្រួសារ	៥០ដុ
ឧបាសក ប៉ែន-ញឹម ឧបាសិកា តូ-សារិ	៥០ដុ
ឧបាសិកា ប៉ោ-សៃគ្លិច	៥០ដុ
ភិក្ខុ ច័ន្ទ-សុខា វត្តពោធិសុវណ្ណារាម	៥០ដុ
អាចារ្យ ប៉េ-រី ឧបាសិកា ញឹង	៥០ដុ
ឧបាសិកា ស៊ិន-ង៉ែត	៥០ដុ
កញ្ញា យុត	៥០ដុ
ឧបាសិកា ឆាយ-ទន	៥០ដុ
ភិក្ខុ អ៊ុយ-ហេង	៥០ដុ
ឧបាសិកា ផលី	៥០ដុ

លោក អាចារ្យ ទិក-យី	៥០ដុ
ឧបាសិកា ង៉ូវ-ស៊ីលាន ព្រមទាំងកូនចៅ	៥០ដុ
លោក អ៊ឹង-ង៉ួនហាវ អ្នកស្រី អ៊ឹង-សាយឃីម	៥០ដុ
HOUT SOU PHALLY KHUTH	៥០ដុ
អ្នកស្រី បាន-ជាហួ និង បុត្រធីតា	៥០ដុ
ឧបាសិកា ដួង-យ៉ាន	៥០ដុ
លោក ដុះ-នីយ	៥០ដុ
អ្នកស្រី ម៉ីង-ឡៃ	៥០ដុ
អ្នកស្រី បាន-ជានិចជូ គ្រួសារ និង បុត្រ	៥០ដុ
ឧបាសិកា អៀង-គីមហួយ	៥០ដុ
ម៉ិល-យ៉ែម	៥០ដុ
កញ្ញា ឆាយ-យុផល	៥០ដុ
ឧបាសក ស៊ុន-ជាង ឧបាសិកា លី-ឡាំងជាង	៥០ដុ
ភិក្ខុ ស៊ិន-ថោង ធម្មសុវណ្ណោ	៥០ដុ
ភិក្ខុ បណ្ឌិតោ ជីក-ព្រហ្ម	៥០ដុ
ឧបាសិកា ឈា-ហ៊ន	៥០ដុ
ឧបាសិកា ចេង-ឆៃមាន	៥០ដុ
ឧបាសិកា គ្រី-សេងលី	៥០ដុ
ភិក្ខុ ស៊ិន-សុវត្ថា	៥០ដុ
លោក ឌួង-ប៊ុន អ្នកស្រី ភី-រិន	៥០ដុ
ឧបាសិកា យូ-ឡោ	៥០ដុ
ភិក្ខុ ប្រាក់-ឈន	៥០ដុ
ភិក្ខុ សុបណ្ណោ ហៀប-ឈាន	៥០ដុ
អ្នកស្រី ប៉ុក-សុគន្ធមាលី លោកខៀវ-សំអាត បុត្រ	៥០ដុ
ភិក្ខុ ខឿ-ឧត្តម	៥០ដុ
ឧបាសិកា ពីដ	៥០ដុ
លោក នូ-ច័ន្ទប៊ុននី និង ភរិយា	៥០ដុ
ឧបាសិកា គង់-សូភន	៥០ដុ
ឧបាសិកាអៀង-គីមហួយ កូនចៅ, ឧបាសកភោគ-ឈុំ អ៊ឹង-ស៊ីណា	៥០ដុ
គីម-សេង	៥០ដុ
រាជ-រតនៈ, ចេង ហ៊ុយ ផេង ភរិយា និង បុត្រ,	
ឡាយ-នាង ជា-សុគុំ ភរិយា និង បុត្រ	៥០ដុ
ឧបាសិកា នេត-ដានី (អ៊ើម)	៥០ដុ
ភិក្ខុ សុវណ្ណបញ្ញោ សោ-អ៊ួន	៥០ដុ

អ្នកស្រី ស៊ូ-នឿន	៥០ដុ
ឧបាសិកា ម៉ារ-ប៊ូរី (ផល)	៥០ដុ
ឧបាសិកា សីល-ចាន់លន់	៥០ដុ
អ្នកស្រី អៀ-ប៊ិវ និង កូនចៅ	៥០ដុ
DARIN & SAROM SOK	៥០ដុ
អ្នកស្រី ហេង-ឈាប	៥០ដុ
ឧបាសិកា ស៊ុម-រដ្ឋ ព្រមទាំងកូនចៅ	៥០ដុ
អ្នកស៊ន-យ៉ាន គ្រួសារ និង កូនចៅ	៥០ដុ
លោកម៉ៅ គ្រួសារតាចិន	៥០ដុ
ឧបាសិកា មាស-ឌឹម	៥០ដុ
អ្នកនាង ស៊ូសានណា-ច័ន្ទកៅ	៥០ដុ
អ្នកស្រី **CHAN SOKHA LIKE**	៥០ដុ
ព្រះតេជះព្រះគុណ **KHUN BUNSON**	៥០ដុ
AMY CHEA	៥០ដុ
លោក ទ្រី-គិមម៉េង អ្នកស្រី សៀក-អ៊ាមគុយ	៥០ដុ
ឧបាសិកា ទូច-ឈុន ឧបាសក ឡាច	៤៥ដុ
ឧបាសិកា ឡូ-ប៊ុនហ៊ាង ឧបាសក អោ-ឈីន	៤៥ដុ
អ្នកស្រី សុខ-មួយលាង	៤៥ដុ
ភិក្ខុ បញ្ញាទីបោ ភួង-ប៊ុនហ៊ុម	៤៥ដុ
ឧបាសិកា គិម-ចេងស្រ៊ុន	៤៥ដុ
ឧបាសក ហួន-ជូលាង	៤៥ដុ
ឧបាសិកា ស៊ីវ-យក់លុយ	៤៥ដុ
ណាតាលី និង ឌីណា	៤៥ដុ
ឧបាសិកា រឿម	៤៥ដុ
លោក ណិប-វង វង្សជ័យវិរៈ អ្នកស្រី ហុក-ច័ន្ទដាលីស	៤៥ដុ
អ្នកស្រី ទិត្យ-សារិន គ្រួសារ និង បុត្រ	៤៥ដុ
ឧបាសិកា នុប-រស់	៤៥ដុ
ឧបាសិកា ម៉ម-អុន	៤៥ដុ
ឧបាសិកា ទេស-ស៊ីថា	៤៥ដុ
ឧបាសក ជា-ហេង ឧបាសិកា អែម-មុំ	៤៥ដុ
ឧបាសិកា ឈុន-គីមស្រ៊ី និង បុត្រធីតា	៤៥ដុ
ឧបាសិកា ជា-លាងហ៊ី និង បុត្រធីតា	៤៥ដុ
អ្នកស្រី ថាច, លោកមុត-ឆុត ភរិយា និង បុត្រធីតា	៤៥ដុ
ធម្មាចារ្យ ថាច់-សៅ អាចារ្យវិបស្សនា	៤៥ដុ

ឧបាសិកា យឹម-សារ៉ន	៤៥ដុ
អ៊ឹង-លាងគង់, ទាឡាង មួយ	៤៥ដុ
ជា-វួចលាង	៤៥ដុ
មហាឧបាសិកា កែវ-ពេជ្រ ច័ន្ទ-ស៊ីថុល	៤៤ដុ
ឧបាសក លាក់-ផន ឧបាសិកា ចុន-អេត	៤៤ដុ
ឧបាសក គ្រូ តោ-ស្វាង	៤៤ដុ
ឧបាសិកា ឈួន-ង៉ន	៤៤ដុ
អ្នកស្រីសេក-ណារី សេក-មាធិន សេក-មុនីរតនា គីម-បុប្ផជនណា	៤៤ដុ
លោក អាំង-សូវ៉ាន់ និង ហែម-ច័ន្ទសុផល	៤២ដុ
អ្នកស្រី វាំង-សុហ្វីនី, អ្នកស្រី វាំង-សុណន្តា	៤២ដុ
លោក សុនន-សុខ និហ ហែម-ចន្ធី	៤២ដុ
ទ្រី-គីងឡេង ម៉ៅ-ឆៃអ៊ីវ ទ្រី-សុគា	៤១ដុ
ឧបាសិកា លឿម-ឡុម	៤០ដុ
ឧបាសិកា តាំង-កួយ	៤០ដុ
លោក ឆាយ-ទ្រី និង អ្នកស្រី លី-អៀវឆេង	៤០ដុ
ឧបាសិកា ឃុត-សុត, អ្នកស្រីវាំង-ផុន, ទុំ-ណារិទ្ធ សេង-ដានេត្រ និង បុត្រធីត	៤០ដុ
ឧបាសិកា ឈូ-ច្រែង	៤០ដុ
ភិក្ខុ ទឹម-ញ៉ុល	៤០ដុ
លោក **FRANK LY**	៤០ដុ
អោម-ជឿន	៤០ដុ
ឧបាសិកា ផេង-នាង	៤០ដុ
ឧបាសិកា ឡេង-ញ៉ូ	៤០ដុ
ឧបាសក ផេង-ហ៊ុម ឧបាសិកា ស្រ៊ាង-អ៊ា និង កូនចៅ	៤០ដុ
ឧបាសកថេត-រិន,ឧបាសិកាម៉ៅ-ខាត់, ថេត-កូ, អ៊ុំម-កឿត, រិន-កុសល, រិន-ចំរើន, ស៊ីវ-វិរៈ, ឫទ្ធិ-រតនៈ	៤០ដុ
ឧបាសិកា ចាន់-ញ៉ឹម	៤០ដុ
រឿន	៤០ដុ
ឧបាសិកា កែវ-ប៊ូ	៤០ដុ
លោក គាត-ជ្រឹម ហៅសារី អ្នកស្រី លឹម-យ៉ុម កូនចៅ	៤០ដុ
អ្នកស្រី **SU MARIE**	៤០ដុ
លោក អៀម-សៀកគិម អ្នកស្រីអៀម-គិមហ៊ន	៤០ដុ
ឧបាសិកា ង៉ួម-យ៉ម	៤០ដុ
យុវជន លី-សុវិចិត្រ (បូរ៉ា)	៤០ដុ

ពុត-សុគន្ធវារី	៤០ដុ
អ្នកមីង សន-ឡេន	៤០ដុ
NARY	៤០ដុ
អកស្រី ឌី-វណ្ណៈ និង គ្រួសារ	៤០ដុ
ឧបាសិកា ជុំ-ឃន ឧបាសក ព្រុំ-រិត និង បុត្រ	៤០ដុ
អ្នកស្រី វណ្ណារី និង គ្រួសារ	៤០ដុ
គ្រួសារ សេង-គីម និង ភរិយា	៤០ដុ
MARY DY	៤០ដុ
ប៉ាន់-សុខហេង ភរិយា ប៉ាន់-សុខុន	៤០ដុ
ឧបាសកគួយ-ធុន ឧបាសិកា ធូរ-មុំ	៤០ដុ
អ្នកស្រី តូច-សារី	៤០ដុ
ភិក្ខុ ចាប-ញ៉ម	៤០ដុ
DIANE TAN & SOKLY TAN BRIAN	៤០ដុ
ឧបាសិកា នួន-ផន	៤០ដុ
អ្នកស្រី សឹម-គិមឃុន ព្រមទាំងបុត្រ	៤០ដុ
លោក ធម្មណាត ជនប្រសិទ្ធិ៍	៤០ដុ
ឧបាសិកា ញ៉ក-ហួ	៤០ដុ
នាង ញ៉	៤០ដុ
ឧបាសិកា ប្រី-យ៉ុម	៤០ដុ
ឧបាសិកា ស្តើង-មុយ	៤០ដុ
ឧបាសិកា ម៉ី-រ៉ាវី	៤០ដុ
ឧបាសិកា ម៉ូរ៉ា	៤០ដុ
បណ្ឌិត ទូន-សុភ័ក្រ្ត	៤០ដុ
តាំង-ង៉ុយឡាង	៤០ដុ
អ្នកស្រី សីម-ឡេន	៤០ដុ
ឧបាសិកា ងី-ឆេ	៤០ដុ
ឧបាសិកា ចាន់ថា ឡុន	៤០ដុ
លោកអាចារ្យ គង់-យុត	៤០ដុ
អៀវ-ថាញ៉ និង កូនចៅ	៣៥ដុ
យ៉ង់-មាលី	៣៥ដុ
ទាន់-សាយ ទីវ-រ៉េម និង កូនចៅ	៣៥ដុ
ត្រាំង-ដែន និង កូនចៅ	៣៥ដុ
យូ-គុណវុត ភរិយា និង កញ្ញា យូ-មុនីរ័ត្ន	៣៥ដុ
យក់-ព្រីដា កញ្ចនា និង កូន	៣៥ដុ

លឹម-ប៊ុនធឿន មិន-សាវ៉ាន់ និង កុន	៣៥ដុ
លោក ពៅ-កុច អ្នកស្រី ទេស-ហ៊ន	៣៥ដុ
ឧបាសិកា ថៃ-តាំង	៣៥ដុ
លោក ព្រុំ-ឡាយ និង ភរិយា	៣៥ដុ
លោក ជីន-សុគន្ធ អ្នកស្រី ហេង-ស៊ីហ៊ាង	៣៥ដុ
ឧបាសិកា ហ៊ុន-ពត ព្រមទាំងបុត្រធីតា	៣៥ដុ
ឧបាសិកា អ៊ិត-ឡម	៣៥ដុ
ឧបាសិកា កាន់-ឆន	៣៥ដុ
ភិក្ខុ ពេជ្រ-សុធីរ	៣៥ដុ
ភិក្ខុ សឹម-យីម	៣៥ដុ
លោក រូឡង់-ឌី ពែក-សុផាន	៣៥ដុ
លោក រូ-សាមលី ព្រមទាំងបុត្រ	៣៥ដុ
លោក ញឹម-ពែក មុំ-សារឿន	៣៥ដុ
លោក គួយ-សុថុន អ្នកស្រី លន់-ស៊ីនួន	៣៥ដុ
លោក គួយ-សុវណ្ណារិទ្ធិ អ្នកស្រី ប៊ុត-រ័ត្ន	៣៥ដុ
ឧបាសក យ៉ម-ដែង ឧ:សិកា ហេង-វ៉ាន់ឌី	៣៥ដុ
កញ្ញា យ៉ម-ចិន្តា, កញ្ញា យ៉ម-ផលា, កញ្ញា យ៉ម-ច័ន្ទរ៉ុង	៣៥ដុ
លោកស្រី ស៊ុយ-ផល្លី កុមារា អាឡិចសិនដា កុមារី អញ្ជលី	៣៥ដុ
លោក យ៉ម-គីរីវ៉ាន់ អ្នកស្រី គីម-សុភាព	
កុមារា យ៉ម-រ៉េនឌី កុមារី យ៉ម-ឃាលី ឧបាសិកា ចេង-ស្រ៊ុន	៣៥ដុ
ឧបាសក ម៉ី-សារ៉ន ឧបាសិកា ឡាំង-ជាង	៣៥ដុ
ឧបាសិកា ហៀន-សូឯម	៣៥ដុ
អ្នកស្រី ថង-ចួប	៣៥ដុ
លោក អ៊ួង-គាងហេង អ្នកស្រី ហៅ-ម៉េង និង បុត្រធីតា	៣៥ដុ
ឧបាសក ឌួង-ឆែម ឧបាសិកា អ៊ុយ-អ៊ាត	៣៥ដុ
លោក បេង-ជុត អ្នកស្រី ស៊ីវ-ហេង និង បុត្រធីតា	៣៥ដុ
ឧបាសិកា រឿន-រាជ ឧបាសក ឆ-ភោគ និង បុត្រធីតា	៣៥ដុ
ឧបាសិកា អ៊ុន-ផូវ និង បុត្រធីតា	៣៥ដុ
ឧបាសិកា ប៊ិល-សាគុណ និង បុត្រធីតា	៣៥ដុ
អ្នកស្រី តាន់-ឆេងស៊ីម និង បុត្រធីតា	៣៥ដុ
លោក ប៉ែន-សុខន អ្នកស្រី យិវ-សេដ្ឋា	៣៥ដុ
លោក គូ-ប៊ុនកាន អ្នកស្រី សេង-ថង	៣៥ដុ
លោក ផន-វី អ្នកស្រី លន-ឡេង	៣៥ដុ
ឧបាសក អុន-លន ឧបាសិកា ហេង-លន់	៣៥ដុ

លោក អៀម-ឃុនណាវុធ អ្នកស្រី ណៃ-យុំ	៣៥ដុ
លោក កាំង-ហេង អ្នកស្រីតាន់-អាយគួន	៣៥ដុ
អ្នកស្រី ង៉ួន-គីមសេង	៣៥ដុ
គួ-ហ៊ីង និង កូនចៅ	៣៥ដុ
គង់-សូ និង កូនចៅ	៣៥ដុ
អែម-ដើង និង កូនចៅ	៣៥ដុ
ឧបាសក សេង-សួត ឧបាសិកា សុន្ទរ៍-ធឹង	៣២ដុ
ឧបាសក ឆុង-ញិប ឧបាសិកា សរិត-សួម	៣២ដុ
ថាន សូផុន និង ធឿនយ៉ាវ	៣២ដុ
អ្នកស្រី មាស-ដម	៣០ដុ
ជា-សាយ	៣០ដុ
ឡាយ-មុំ	៣០ដុ
ឧបាសិកា ប៊ុត-សាខន ព្រមទាំងគ្រួសារ	៣០ដុ
ឧបាសិកា កែម-ថុល និង បុត្រ	៣០ដុ
ឧបាសិកា អុន-ញ៉ូ	៣០ដុ
ឧបាសិកា រស់-សុផល	៣០ដុ
ឧបាសក ជូ-មី គ្រួសារ	៣០ដុ
លោក ស៊ីផាន បុប្ផ	៣០ដុ
ឧបាសិកា អៀង-គីមហ៊ួយ	៣០ដុ
ឧបាសិកា នឹម	៣០ដុ
លោកអាចារ្យ ឱត្តប្បៈ អ្នកស្រី ស៊ុំ-ស៊ុក បុត្រធីតា	៣០ដុ
អ្នកស្រី គ្រួច-អុល អ្នកស្រី សេង-បូ	៣០ដុ
SAREN TOUN	៣០ដុ
លោក ឌិក-គិមអាន អ្នកស្រី ផល្លា	៣០ដុ
ឧបាសិកា អ៊ី-ស្រ៊ុន	៣០ដុ
អ្នកគ្រូ សេដា-លីថុន	៣០ដុ
ពៅ-ណារីន	៣០ដុ
ប៊ុនណារុំ-ជ័យ សុខា-សេង	៣០ដុ
លោក MAK NIMUL	៣០ដុ
គ្រី-សុផារី និង វណ្ណធី	៣០ដុ
លោក ឈួម-ឈីត និង គ្រួសារ	៣០ដុ
ឧបាសិកា ម៉ី-អ៊ួក	៣០ដុ
ឧបាសិកា អ៊ុក-លឿប	៣០ដុ
ឧបាសិកា សូ-សៀន ហៅ សូផន-សូ	៣០ដុ

ក្រុមគ្រួសារ កូនចៅ ញោម អ៊ិន-សរ	៣០ដុ
YAN SIM	៣០ដុ
ឧបាសិកា អ៊ាត-អេង	៣០ដុ
នាង ឆាត-ឆោម និង បុត្រធីតា	៣០ដុ
ឧបាសិកា ប៊ិត-ផងខាំ	៣០ដុ
លី-វ៉ានី វិត្ថារា-តាន់	៣០ដុ
ឧបាសិកា ប៉ោ-យេង និង បុត្រធីតា	៣០ដុ
ឧបាសិកា ទន-យិន	៣០ដុ
ឧបាសិកា ចាន់-គីមហ៊ួយ	៣០ដុ
លោក ឌី-សូផល អ្នកស្រី ហួយ-សាត	៣០ដុ
លោក គ្រី-ជិនលាង និង សុខា	៣០ដុ
ឧបាសិកា សឿង-លឿង ឧបាសិកា យាន	៣០ដុ
អ្នកស្រី ប៉ុក-សុគន្ធារុធ	៣០ដុ
អ្នកស្រី ឡាយ-គុយអេង ព្រមទាំងបុត្រ	៣០ដុ
លោក សំបូ-ចាន់ អ្នកស្រី អ៊ីន-ញ៉ី	៣០ដុ
ឧបាសិកា មុំ-គីមឆេង	៣០ដុ
ឧបាសក ជុំ-ហេង	៣០ដុ
ឧបាសិកា គីម-ហូ	៣០ដុ
LIHOUR PROM	៣០ដុ
អ្នកស្រី រស់-សៅវ៉ាន	៣០ដុ
លោក មាស-គង់ អ្នកស្រី មាស-ទូច	៣០ដុ
ឧបាសក ព្រម-ផន ឧបាសិកា ពោធិ-ពាជ	៣០ដុ
ឧបាសិកា ម្លួង-ច័ន្ទ និង បុត្រធីតា	៣០ដុ
ឧបាសិកា អ៊ូ-យុត្ថានី ឡេង ចាន់ រស្មី	៣០ដុ
ឧបាសិកា SENG SEANG LIM	៣០ដុ
ឧបាសិកា ខែត-ឃី	៣០ដុ
ឧបាសិកា អ៊ឹម-សាវ	៣០ដុ
ឧបាសកសៀក-ស្រ៊ុន ឧបាសិកា គិត-ស្រ៊ុន	៣០ដុ
លោក ឃួន ណុន និង សក់ ស៊ីនួន	៣០ដុ
លោក ចាន់-សាម៉ន់ អ្នកស្រី ផល្លី	៣០ដុ
លោក ហឿត-មឿន អ្នកស្រី ជីវ៉ា	៣០ដុ
ឧបាសក គាត-ជ្រឹម ហៅ សារី	៣០ដុ
នាង ផាន់-ណា	៣០ដុ
លោកអាចារ្យ ប៉ុក-ធឿន ឧបាសិកា ញាណ-ឈឿម	៣០ដុ

ឧបាសិកា លឹម-ឈួន	៣០ដុ
លោក គីម-កន អ្នកស្រី គីម-ណារិន និង បុត្រ	៣០ដុ
ឧបាសិកា ប្រាក់-ហាន	៣០ដុ
ឧបាសក កែម-សាន	៣០ដុ
ឧបាសិកា សេង-គីមហ៊ន	៣០ដុ
ឧបាសិកា អ៊ាក-គីម	៣០ដុ
ឧបាសិកា ប៊ិត-ថងខាំ	៣០ដុ
លោកអាចារ្យ នេត្រ-គឿន	៣០ដុ
ឧបាសក សួគ៌-ស្រ៊ុន	៣០ដុ
អ្នកស្រី សុផន-ខេន	៣០ដុ
ឧបាសិកា ជិន-ស៊ីវអេង	៣០ដុ
ឧបាសិកា អ៊ុន-យុន	៣០ដុ
ភិក្ខុ សន្តិបាលត្ថេរ ឈេន-អូន	៣០ដុ
ភិក្ខុ ធម្មវិនយោ ទូច-ផន	៣០ដុ
ភិក្ខុ យឹម-វិចិត្រ	៣០ដុ
ភិក្ខុ ខេមិយោ អឿន-ហ៊ាង	៣០ដុ
ភិក្ខុ ស៊ិមហក-ហេង	៣០ដុ
ឧបាសិកា សរ-យុត	៣០ដុ
លោក ភោ-សុផាត អ្នកស្រីសុខ-យី	៣០ដុ
TOUCH & SIMONE	៣០ដុ
ឧបាសិកា វ៉ាន់-ដា	៣០ដុ
លោក ងិក-លី លក្ខិណា-លី និង ក្រុមគ្រួសារ	៣០ដុ
លី-មឿន	៣០ដុ
ឧបាសក ប្រាក់-ភាច ឧបាសិកា សុខ-ភឿន	៣០ដុ
ម៉ាន-ចយ ផន-អេង	៣០ដុ
ឧបាសិកា រ័ត្ន-ស៊ុំ	៣០ដុ
ជន-វណ្ណី ស្វាយអាត	៣០ដុ
សៅ-ប៊ីលី កែវ-ម៉ាលី	៣០ដុ
ឧបាសិកា ប៉ោ-យ៉េង	៣០ដុ
វី-ង៉ែត គូវ-គេច លន	៣០ដុ
លោកប្រាក់-ពុទ្ធី អ្នកស្រី នុប-សុភា	៣០ដុ
ឧបាសិកា ខាត់ ឧបាសិកា នឿយ-ខឿម	៣០ដុ
លោក ពេជ្រ-ឈីង និង គ្រួសារ	៣០ដុ
ឧបាសិកា គឹម-អ៊ិន	៣០ដុ

លោក គិន-ប៊ុនរ៉ាណា អ្នកស្រី ប៊ុន-ណារី-ជ័យ	៣០ដុ
ឧបាសិកា ប៊ុនណា-មឿន	៣០ដុ
ឧបាសិកា ម្លង-សារុម និង បុត្រ	៣០ដុ
ញោមស្រី ម៉ី-ផូ	៣០ដុ
ឧបាសិកា ទូច-យ៉ុន	៣០ដុ
អ្នកស្រី អំ-សុខឃឿន លោកកែ-ភារុណ និង បុត្រ	៣០ដុ
អ្នកស្រី យុននី-អ៊ីង និង កូនចៅ	៣០ដុ
ឧបាសក ម៉ម-លាង ឧបាសិកា រស់-ហ៊ុត	៣០ដុ
ឧបាសក ហ៊ុល-សារុំ ឧបាសិកា ហ៊ុល-តន	៣០ដុ
ឧបាសិកា ជី ឧបាសក ប៉ូន	៣០ដុ
ភិក្ខុ ពិសិដ្ឋ-កំសាន្ត	៣០ដុ
ភិក្ខុ គល-ស៊ីនួន	៣០ដុ
ឧបាសិកា មឿង-យាន	៣០ដុ
លី-ពន្លក ហ៊ូ-ប៉ូលីណេ លី-ធីមប៊ី	៣០ដុ
ឌី-សៀង ប៉ូលី-ណែត-ហ៊ូ JONATHAN JULIE	៣០ដុ
ឧបាសក ប្រាក់-វិឆ័យ ឧបាសិកា ដែង-ផុនចំរើន	៣០ដុ
ឧបាសិកា ថោង-សុធី ស្វាមី និង បុត្រ	៣០ដុ
អ្នកស្រី ផេង-គីមញ៉ាន	៣០ដុ
កញ្ញា ផេង-ចិន្តា	៣០ដុ
ឧបាសិកា រុន-ចរណៃ	៣០ដុ
ឧបាសិកា ឧច-សាខន និង បុត្រធីតា	៣០ដុ
ឧបាសិកា អុំ-មន់	៣០ដុ
ឧបាសិកា យ៉ុន□ និង កូនចៅ	៣០ដុ
CHAND YOUST & VI B. NGUYEN	៣០ដុ
ឧបាសិកា វ៉ាយ-រុន	២៧ដុ
លោកអាចារ្យ ធូរ-ម៉ៅ ឧបាសិកា យ៉ឹយ-យ៉ាង	២៧ដុ
ឧបាសក យិម-ហ៊ិរ និង ភរិយា ស៊ុម-ពេត	២៧ដុ
ឧបាសិកា ចេង-លឹម	២៥ដុ
លោក តេង-ភេ និង គ្រួសារ	២៥ដុ
លោកអាចារ្យ ហ៊ិរ អ្នកស្រី ស៊ុំ-ទេព និង បុត្រធីតា	២៥ដុ
ឧបាសក សេ ឧបាសិកា សុង	២៥ដុ
NCHIN & CHAI EATON	២៥ដុ
ឧបាសិកា ទួន-មុំ	២៥ដុ
ឧបាសិកា គិម-កន	២៥ដុ

លោក ទីត-សាត	២៥ដុ
ឧបាសិកា សារ៉ាយ-ប្រាក់	២៥ដុ
លួត-ឈឿន	២៥ដុ
អ្នកស្រី ឯម-ពៅ	២៥ដុ
អ្នកស្រី និន-ឌិន	២៥ដុ
អ៊ឹម-ចាន់	២៥ដុ
ប្រាក់-អាត់	២៥ដុ
អ្នកស្រី ស៊ុំ-សាគន់ និង គ្រួសារ	២៥ដុ
IM KIMCHHORN	២៥ដុ
ឧបាសិកា តាត-មុនី	២៥ដុ
លោក បិន-កាន់ អ្នកស្រី រ័ត្ន-ថន កាន់-ធឿន កាន់-សុខា	
គាន់-ដា កាន់-សុធា	២៤ដុ
អ្នកស្រី **TONG TIBET**	២៤ដុ
ឧបាសិកា សរ-យុត និង បុត្រធីតា	២២ដុ
បច្ច័បំសុកូល នៅវត្តសាន់តាអាណា	២២ដុ
អ្នកស្រី សារុំ និង កូនចៅ	២២ដុ
ឧបាសិកា ខេម-ច្រែស	២២ដុ
បងស្រី សារុម-ប៉ិច	២២ដុ
លោក សាមួន-ប៉ុក	២២ដុ
ឧបាសិកា បេស្កាលីន	២១ដុ
អ្នកស្រី ប៉ិច	២១ដុ
លោក សំរ៉ាន-វណ្ណដា អ្នកស្រី យិន-យ៉ាន កញ្ញា យិន-វន់	២១ដុ
ឧបាសក យ៉ាំង-ស៊ីង ឧបាសិកា ថង-ស៊យ	២១ដុ
សេង-នី និង កូនចៅ	២១ដុ
ប៉ុក-គួន និង កូនចៅ	២១ដុ
លោក ហុង-ឯក អ្នកស្រី ផាត-ញ៉ិប	២១ដុ
ឧបាសិកា សុខ-ហួង	២១ដុ
លោក ថាច់-ប៊ុនធី អ្នកស្រី ឌឿង-សារ៉ាត	២១ដុ
អ្នកស្រី កែវ-ច័ន្ទី និង បុត្រ	២១ដុ
ឧបាសិកា ប៉ិច-សុខុម និង បុត្រ	២១ដុ
លោក ឈិម-អឿង អ្នកស្រី ឈឹម-វណ្ណា	២១ដុ
លោក ឈឹម-សាខន អ្នកស្រី ឡាច-សាវឿន	២១ដុ
លោក កៅ-ជិន អ្នកស្រី កែវ-លួន	២១ដុ

អ្នកស្រី ម៉ុន-រ៉ាម៉ី	២១ដុ
អ្នកស្រី ម៉ុន-សូផន	២១ដុ
ឧបាសិកា ហែម-សារី	២០ដុ
ឧបាសិកា ស៊ុង-សឿម	២០ដុ
ឧបាសិកា សុខុម-ស្រែ ឡេន-រឿង	២០ដុ
ឧបាសិកា ហែម-យឹម	២០ដុ
សាមណេរ ថែម-សារ៉ាត ឧបាសិកា ស៊ុម-ស៊ុក	២០ដុ
យុវជន ថាច់-ចននី	២០ដុ
អ្នកស្រី សុភក្រ្ត-ឌឿង	២០ដុ
អ៊ឹម-សាលី	២០ដុ
លោក ថាំង-ចេវ ព្រមទាំងគ្រួសារ	២០ដុ
ឧបាសិកា មិល-ម៉ាលី	២០ដុ
លោក ថាច់-ថេង អ្នកស្រី ប្រាក់-សាម	២០ដុ
កញ្ញា លី-ថុងសូលីដា	២០ដុ
កញ្ញា លី-សូលីណា	២០ដុ
ឧបាសក លី-ថុង ឧបាសិកា មាឃ-គឹមសាន	២០ដុ
YONG SITHON	២០ដុ
ឧបាសិកា អ៊ូ-ឆេង និង កូនស្រី លីដា	២០ដុ
លោក សារឿត-រិត និង គ្រួសារ	២០ដុ
ឧបាសក សួន-សារិ ឧបាសិកា ទឹម-ញ៉ូ	២០ដុ
ឧបាសិកា ញាណ-សុំ	២០ដុ
ឧបាសិកា ណយ-ប៊ុនម៉ា	២០ដុ
លោក ហួយ-យ៉ុង អ្នកស្រី ហ៊ុន-សារ៉ុម និង បុត្រ	២០ដុ
ភិក្ខុ សុធម្មប្បញ្ញោ ច័ន្ទ-ស៊ី, ឧបាសិកា ស៊ុយ-សាង	២០ដុ
លោកគ្រូសូត្រ ផល	២០ដុ
លឹម-ញ៉ូល ពិន-អ៊ិត និង កូនចៅ	២០ដុ
ស៊ូ-ឡុង ណៃ-យឹម	២០ដុ
ឧបាសិកា គង់-សុគន្ធា និង បុត្រធីតា	២០ដុ
ឧបាសិកា ឡុង-ស៊ីនួន	២០ដុ
លោក សន-ណាត និង គ្រួសារ	២០ដុ
លោក ខៀវ-ដារារ័ត្ន អ្នកស្រី ងួន-ច័ន្ទថា	២០ដុ
លោក សំ-សាវឿន អ្នកស្រី មឿន-យ៉ឹង	២០ដុ
Mr. CHM KHOUN	២០ដុ
លឹម-ស៊ីវប៊ី និង បុត្រក្មួយ អ៊ឹង-ប៊ុន-ម៉ៅ ពិសី-ជៀវ បុត្រធីតា	២០ដុ

PHATH RTH	២០ដុ
ឈិត-ដាវ សុជាតា លោក លី-សុខឌែន ឆី-ម៉ាលីណា	២០ដុ
អ្នកនាង DIANNA KAO និង បុត្រ	២០ដុ
RAKSMEY MEAS & MOEUN YIM	២០ដុ
កុមារា DAVIS BOURAMAI CHHLAT	២០ដុ
អ្នកស្រី SOPHY LONG	២០ដុ
រដ្ឋានី	២០ដុ
ឧបាសក ផាត-សាវឿយ	២០ដុ
NICOLE HOUR	២០ដុ
ឧបាសិកា គង-សុគន្ធា	២០ដុ
ឧបាសិកា ថុល	២០ដុ
យាយ សឿម	២០ដុ
សុភា-ថាវ	២០ដុ
លាភ និង កូនចៅ	២០ដុ
លោក ប៉ាន-រ៉ប អ្នកស្រី ណារី	២០ដុ
លោក នូ-សំបាន និង គ្រួសារ	២០ដុ
អ៊ុំ-ថុង	២០ដុ
ប៉ក-ផុន	២០ដុ
គង-អ៊ិន និង គ្រួសារ	២០ដុ
ឧបាសិកា គឹម-កន	២០ដុ
ឧបាសិកា យ៉ែម-ទុម ឧបាសិកា យ៉ែម-តង	២០ដុ
ឧបាសិកា មាស-ផា	២០ដុ
ចំរើន និង ភរិយា	២០ដុ
ឧបាសក ប៉ែន-ប៉ន	២០ដុ
លោកឈាន-លីមហ៊ាង អ្នកស្រី តាំង-គីមឡេង	២០ដុ
លោក ហុក-សុមនបុត្រ អ្នកស្រី ហុក-និមល	២០ដុ
លោក រតនា	២០ដុ
ឧបាសក ថេត-រិន ឧបាសិកា ម៉ៅ-ខាត់ កូនចៅ	២០ដុ
អ្នកស្រី សិ-ចន	២០ដុ
ឧបាសក ឡុង-រឿន	២០ដុ
ព្រុំ-សឿម	២០ដុ
គឹម-ពន	២០ដុ
ធារ៉ា	២០ដុ
ថង-សៃ-គុំ ព្រមទាំងបុត្រ	២០ដុ

លោក វុឌ្ឍី អ្នកស្រី ម៉ៅ	២០ដុ
ឧបាសក ថាញ់-ផេង	២០ដុ
ឧបាសិកា យុន-កៀន	២០ដុ
កែ-ធី និង ឡេង-សុនី	២០ដុ
LANG HIELL	២០ដុ
SAM-YORK	២០ដុ
លីម-ជូ	២០ដុ
លោកចៅ-ង៉ៅ អ្នកស្រីឡេា-នាង	២០ដុ
អៀង-សុខ និង កូនចៅ	២០ដុ
នាង-ហ៊ុន និង កូនចៅ	២០ដុ
ឧបាសក លី-សន ឧបាសិកា សើន-ទ្រី	២០ដុ
TAING MUY LANG	២០ដុ
ឧបាសិកា កែវ-ពេជ្រចាំ ស៊ី-ថុល	២០ដុ
យុវជន សោម-សុភក្តី	២០ដុ
កញ្ញា សោម-សុជា	២០ដុ
ឧបាសក ថាច់-សួផាត ឧបាសិកា យ៉ង-វន្នី	២០ដុ
ភិក្ខុ រស់-យ៉ាន	២០ដុ
ឧបាសិកា ថង-ខាំ	២០ដុ
ឧបាសក ស៊ិន-មេន ឧបាសិកា ប៉ុន-រិ	២០ដុ
កញ្ញា សោម-ច័ន្ទ សុពីន	២០ដុ
ឧបាសិកា យ៉ាន-រុន	២០ដុ
ឧបាសិកា ឃឿម និង គ្រួសារ	២០ដុ
ភិក្ខុ យឹម-វិចិត្រ	២០ដុ
អ្នកស្រី សុភោគ-គន្ធា	២០ដុ
ឧបាសិកា ហ៊ួយ-គីមឡេង និង កូនចៅ	២០ដុ
យុវជន សោម-សុភ័ណ	២០ដុ
ម៉ែន-សុឃឿន	២០ដុ
អ្នកស្រី អ៊ុង-សីផាន់ណា	២០ដុ
KEN SOPHON	២០ដុ
អាចារ្យ កាំង-ហេង និង គ្រួសារ	២០ដុ
អ៊ីន-តង៉	២០ដុ
លោក រឿន	២០ដុ
លោក វៃ-មែម អ្នកស្រី ម៉ៅ-ស៊ីណាង	២០ដុ
លោក ហា-ញ៉ូត ថន-ឌី	២០ដុ

មីង-ឡឹង	២០ដុ
អ្នកនាង DIEM KAO និង បុត្រ	២០ដុ
ហំ-ទី	២០ដុ
យឹម-ផល្លា ព្រមទាំងគ្រួសារ	២០ដុ
ឧបាសិកា ផា-រើន	២០ដុ
ប៉ាន-ហួរ	២០ដុ
ឧបាសិកា ណាំ-ស៊ី	២០ដុ
ឧបាសិកា គីម-សៀន	២០ដុ
លិម-ជូ	២០ដុ
សេន-យ៉ាត	២០ដុ
ឧបាសក សម្បត្តិ-ហ៊ួត ឧបាសិកា សម្បូរ-បាន	២០ដុ
ឧបាសិកា អ៊ុក-ផៃ ឧបាសក ឈុន-អ៊ី	២០ដុ
ឧបាសិកា សាន់-សុផាត	២០ដុ
អ្នកស្រី ធិន-ណារិទ្ធ និង បុត្រ	២០ដុ
ឧបាសិកា កែ-យឿន	២០ដុ
ញោម ហ៊ិន-ផាន	២០ដុ
ឧបាសិកា ថោង-ឃាន	២០ដុ
ឧបាសក ប៉ែន-ញឹម ឧបាសិកា តូ-សារី	២០ដុ
ឧបាសិកា ម៉ឹង-លន់	២០ដុ
ឧបាសិកា លេង-អឿង	២០ដុ
ឧបាសក តុល-យៀ	២០ដុ
ឧបាសិកា ងីន-សាត	២០ដុ
លោក តាន់-ស្រុន និង គ្រួសារ	២០ដុ
តាំង-វី និង SAMPHEARY	២០ដុ
លោកស្រី ផា-វណ្ណារី	២០ដុ
លោក ប៉ែន-សុខ និង គ្រួសារ	២០ដុ
លោក ទិត្យ-ណូវ៉ា	២០ដុ
លោកប្រុស HAM SOEUNG	២០ដុ
ចន្ទូ	២០ដុ
ភិក្ខុ KEM SOPHORN	២០ដុ
អ្នកស្រី សុផល-មុំ	២០ដុ
ឧបាសក ឈុន-ប៊ុនទី	២០ដុ
ឧបាសក យិន-គុណ	២០ដុ
ភិក្ខុ សោម-វន្ដា វត្តអ៊ុកឡែន	២០ដុ

គា-ឆេង លី-ភួង ស៊ីវ-អេង គីម-យិន	២០ដុ
អ្នកស្រី ជុំ-សុជាត	២០ដុ
លោកអាចារ្យ ថាច់-ង៉ុក ជា-គិមតាក	២០ដុ
ឧបាសិកា ហង្ស-សំអុល	២០ដុ
លោក សុយុទ្ធ-ចេឡា អ្នកស្រី ជ្រូក-ហាច	២០ដុ
អាចារ្យនាង-ណាត	២០ដុ
សួម-វុទ្ធី វន្នី	២០ដុ
វ៉ានី និង គ្រួសារ	២០ដុ
អ្នកមីង ម៉ៅ-សារុន	២០ដុ
អ្នកស្រី ឆុន-រិត និង គ្រួសារ	២០ដុ
លោក ប្រាក់-ភន អ្នកស្រី ភិន-វ៉ាន់ណាន	២០ដុ
លោក ប៉ុក-សុគន្ធាណា	២០ដុ
អ្នកស្រី ស៊ឹម-សាវ៉េន លោក ផេង-ហួត និង បុត្រ	២០ដុ
ឧបាសិកា ឈឺ-ស៊ីវហ៊ាង	២០ដុ
ទូច-លឹមសេង មែន-សុខឿន	២០ដុ
ឧបាសិកា មាស-ដា	២០ដុ
ឧបាសិកា ចាន់-សូផាត	២០ដុ
ទាយិកា ពិសី	២០ដុ
ឧបាសិកា ខាន់-ហួយ	២០ដុ
ឈិត-ដាវ ច័ន្ទសិតា កែវ-សុវណ្ណ	២០ដុ
ឧបាសក ឃុន-ម៉េហាវ ឧបាសិកា សៀវ-ឆេង	២០ដុ
ឧបាសិកា គង់-យ៉េន	២០ដុ
SOPHAN TAN	២០ដុ
លោក សុខ-មឿត អ្នកស្រី ហេង-វ៉ាន់	២០ដុ
លោក ស៊ូ-ស៊ឹម អ្នកស្រី គិន-សំបូរ	២០ដុ
ព្រហ្ម-មាស សុវណ្ណ	២០ដុ
ឧបាសិកា យស-ម៉ន	២០ដុ
លោក ឡាំង-គិមឆេង	២០ដុ
ទាយក សុផល	២០ដុ
អ្នកស្រីសក់-សំនៀង និង គ្រួសារ	២០ដុ
អ្នកស្រី ហ៊ីម-ឡុង	២០ដុ
អ្នកស្រី នី-ផា និង ភ្វាមី	២០ដុ
អ្នកស្រី សួន-វី និង ស្វាមី	២០ដុ
អ្នកស្រី វ៉ាន់-គៀ	២០ដុ

ឧបាសិកា ញ៉ក-ហួ ព្រមទាំងបុត្រ	២០ដុ
ឧបាសិកា ហ-ស៊ុន	២០ដុ
ឧបាសិកា សយ-ប៊ុន	២០ដុ
ឧបាសិកា សៀក-សៀន	២០ដុ
ឧបាសិកា លឹម-យ៉ុម ហៅ សាលី	២០ដុ
កញ្ញា យិន-ចាន់ណារា	២០ដុ
ឧបាសិកា ថាច់-វ៉េង	២០ដុ
លោក ខៀវ-សារឿន និង គ្រួសារ	២០ដុ
លោក ឌុក-ប៊ុនភិត និង ណម-រិត	២០ដុ
សុខ-នីន នាង ជីម-កញ្ញា	២០ដុ
សុផាន់ណ្ណារី ADAM, CHRISTOPHER, SOUR	
LENG KAO LEE ABEL	២០ដុ
SOPHEA KEN, MORN KEN, PHALLY SHMITH,	
CHENDA KEN, GASSENDRA KEN, ALVIN KEN,	
SOPHEAP SAMITH	២០ដុ
អ្នកស្រី ណុប-ណុំ	២០ដុ
ឧបាសិកា ជុក-សឿន	២០ដុ
អ្នកស្រី ប៉ូ-ណាន	២០ដុ
ឧបាសក ឈឺន-ប៊ុនលឹត និង ភរិយា	២០ដុ
ឧបាសិកា សយ-ប៊ុន	២០ដុ
ឧបាសិកា សៀក-សៀន	២០ដុ
ឧបាសិកា លឹម-យ៉ុម ហៅ សាលី	២០ដុ
កញ្ញា យិន-ចាន់ណារា	២០ដុ
ឧបាសិក ថាច់-វ៉េង	២០ដុ
ជា-កែវបូរុន សាន-សុខា	២០ដុ
លោក តូច-ឧប្បាលា (ឆឺត)	២០ដុ
SAORAN LATOUR	២០ដុ
BIN VETH	២០ដុ
BIN TOUCH	២០ដុ
BIN ARTH	២០ដុ
BIN RITH	២០ដុ
BIN BO	២០ដុ
អ្នកស្រី ស៊ីម-បុប្ផា និង បុត្រ	២០ដុ

អ្នកស្រី ហំ-សំអាត និង បុត្រ	២០ដុ
មុត-សុផល ភោ-សូវឿន	២០ដុ
កម្លោះ ថេត-កូ និង ដារ:	២០ដុ
លោកតា រេត	២០ដុ
ឧបាសិកា កាន់-សារ៉ាន់	២០ដុ
នាង បុប្ផា	២០ដុ
ខៀវ-ណាត	២០ដុ
ឧបាសិកា អោម-ចៀន	២០ដុ
អ្នកស្រី សំ-សាម៉ន ឧបាសក សេក-សៀន កូនចៅ	២០ដុ
ឧបាសិកា សេន-ជឹម	២០ដុ
វ៉ាន-ចាន់	២០ដុ
ឌី-ណែត គឿន	២០ដុ
ប៉ុន-ម៉ៅ	២០ដុ
សារ៉ាន	២០ដុ
សារ៉ាត	២០ដុ
ឧបាសិកា យិន-ឌីនុត	២០ដុ
អ្នកស្រី អ៊ុង-ធារី	២០ដុ
ពៅ-ទិត្យា	២០ដុ
សុជាត នាង ភឿង	២០ដុ
លោក មុនីសូតា-ទេព	២០ដុ
អ្នកស្រី សោភ័ណ	២០ដុ
ឧបាសិកា ឡុងប៉ែន	២០ដុ
អ្នកស្រី យី	២០ដុ
អ្នកស្រី យ៉ាន	២០ដុ
លោក លឹម-សៀង	២០ដុ
ឧបាសក ចេក-ឃាន	២០ដុ
ឧបាសិកា ប៉ែន-សួន	២០ដុ
ម៉ាក់-អ៊ុយ និង យឹម-ហ៊ុន	២០ដុ
រុន-ចណៃ	២០ដុ
អ្នកស្រី ណៃ លោកតា ភី	២០ដុ
ខ្លឹត និង គ្រួសារ	២០ដុ
លោក សារ៉ាត់ អ្នកស្រី អៀន	២០ដុ
ម៉ាច-ជន និង គ្រួសារ	២០ដុ
ប្រាក់-សម្បត្តិ ចាន់-ឡៃ និង គ្រួសារ	២០ដុ

លោក និង លោកស្រី ធាម-អុន	២០ដុ
SIA REN QA	២០ដុ
អ្នកស្រី ម៉ៅ-ហៀង	២០ដុ
លោក ផូ-ចយ អ្នកស្រី យី	២០ដុ
ឧបាសិកា អ៊ុន-អ៊ន	២០ដុ
លោក មេ-ប៉ុង	២០ដុ
ហ៊ុន-គីមហេង	២០ដុ
លោក ជា-ស៊ុវត្ថនា អ្នកស្រីឃុន-សូនីម៉ា និង បុត្រ	២០ដុ
ហុង **(HONG)**	២០ដុ
អ្នកស្រី លី-គីមស៊ី	២០ដុ
វ៉ែន-សារឿន	២០ដុ
ឧបាសក ចេក-ឃាន	២០ដុ
ឧបាសក ឈុន-ម៉ៅ	២០ដុ
លោក ជា-ហ៊្វុង អ្នកស្រី តូ-សុផាន់ណា	២០ដុ
អ្នកស្រី ផា-ឆាយ៉ាស៊ី	២០ដុ
អ្នកស្រី គីម-ហាន	២០ដុ
អ្នកស្រី គីម-ហេង	២០ដុ
អ្នកស្រី ម៉ី-សុធារ	២០ដុ
SEAK CHEA	២០ដុ
ឈិន-លី **(CHIN LEE)**	២០ដុ
ឧបាសិកា តួច-ឃុនណាង	២០ដុ
BOU SAMY	២០ដុ
ឧបាសិកា ងី-ឆេ	២០ដុ
លោក ហ៊ិន-សុវណ្ណ នាង អ៊ឹង-មួយហ៊ាង	២០ដុ
អ្នកស្រី លីម-បុប្ផ	២០ដុ
អ្នកស្រី លី-ង៉ែត លោកកូវ-គិហ្វលង់	២០ដុ
អ្នកស្រី ចាន់-លី	២០ដុ
អ្នកស្រី ស៊ីម-សារ៉ន និងគ្រួសារ បុប្ផ-ស៊ីម	២០ដុ
ឧបាសិកា ស៊ី-លេន	២០ដុ
ជា-កែវបូរ៉ុន សាន-សុខា	២០ដុ
តួច-ឧប្បាលា (ឆឹត)	២០ដុ
វ៉ាតធិរៈ	២០ដុ
ឧបាសិកា មួង-សឿន និង បុត្រ	២០ដុ
សុខុម, លោករ័ត្ន-វ៉ុន, ឌី-យ៉ានី, រូសាលីន, រូសានីណារា	២០ដុ

ឧបាសក គីម-សាំង ឧបាសិកា សួស	២០ដុ
ឧបាសិកា លេង	២០ដុ
លោក អ៊ាប-ហាំងឃុន អ្នកស្រី អ៊ឹង-លីគាង	២០ដុ
ឧបាសិកា ស្តើង-មុយ	២០ដុ
អ្នកស្រី ធឿន លោកម៉ៅ បុត្រធីតា	២០ដុ
លោក ស៊ុម-វណ្ណៈ អ្នកស្រី វណ្ណី បុត្រធីតា	២០ដុ
ឧបាសិកា ពេជ្រ-សួន	២០ដុ
លោក កង-ជួន អ្នកស្រីទូច-រ៉េន	២០ដុ
ឧបាសក ព្រុំ-យឿន	១៩ដុ
ឧបាសក កែវ-ឆាត ឧបាសិកា នង-រុន	១៨ដុ
ឧបាសក កៅ-លីសេង ឧបាសិកា ចាប់-ម៉ានី	១៨ដុ
ស្រី-ហឿន និង កូន	១៨ដុ
ស៊ីម-វេងគាវ និង កូន	១៨ដុ
លោក ស៊ីម-សារិត អ្នកស្រី ហ៊ុយ-សែន និង បុត្រធីតា	១៨ដុ
លោក សូត-តេង អ្នកស្រី ហ៊ុយ-សៀន និង បុត្រធីតា	១៨ដុ
លោក លីម-ទិត អ្នកស្រី សែម-សុខុន	១៨ដុ
ឧបាសិកា អ៊ុន-ផៃ ហៅស៊ីថា	១៨ដុ
លោក ហ៊ុយ-សុថាន អ្នកស្រី ស៊ុម-ម៉ាច និង បុត្រ	១៨ដុ
អ្នកឥតមានឈ្មោះ	១៧ដុ
ឧបាសិកា អ៊ាវ-ប៊ួយ និង បុត្រធីតា	១៧ដុ
លោក សារួន និង គ្រួសារ	១៥ដុ
អ្នកស្រី តាំង-ជាវណ្ណៈ	១៥ដុ
អ៊ុង-សំខាន់ ជា-គុយហ៊ាង	១៥ដុ
ឧបាសិកា ឡេ-សាម៉ុត	១៥ដុ
ឧបាសិកា ឡុង-នាង	១៥ដុ
លោក ចេង-គា អ្នកស្រី ឈឹម-ចន្ធី	១៥ដុ
ប៉េ-សារ៉ង	១៥ដុ
លោកប្រុស **CHARO BAN**	១៥ដុ
មីន-សាង	១៥ដុ
លោក ម៉ុក-គៀង និង គ្រួសារ	១៥ដុ
លោក បួង-តាំង និង គ្រួសារ	១៥ដុ
អាចារ្យ អ៊ុក-សែម ឧបាសិកា ហង់-ជីម	១៥ដុ
ឧបាសិកា សាត់-ចាន់	១៥ដុ
លោក ប្រាក់-ផន អ្នកស្រី ភិន-បាណាន	១៥ដុ

លោក គីម-សារុន អ្នកស្រី រូ-គីរី	១៥ដុ
ឧបាសិកា ឆែម-ឡាប និង បុត្រធីតា	១៥ដុ
SOUPHAPHONE KEOVONGKOT	១៥ដុ
អ្នកស្រី វ៉ានី លោក ពុទ្ធជន និង បុត្រធីតា	១៥ដុ
លោកសៀវ-គីមរួច និង ភរិយា	១៥ដុ
លោក ទូច-ទិព អ្នកស្រី ខេម-ភាព	១៥ដុ
លោក សៀន អ្នកស្រី ចរិយា	១៥ដុ
លោក ពើង-យឿម	១៥ដុ
អ្នកស្រី ពើង-សុខុម	១៥ដុ
ពើង-ចិរតេជ	១៥ដុ
ពើង-ចិរវណ្ណ	១៥ដុ
យ៉ាំង-វិន្ទា	១៥ដុ
អ៊ុង-សំអាត និង គ្រួសារ	១៥ដុ
ជឿ-ធី	១៥ដុ
ជា-គីមឡេង	១៥ដុ
ញ៉ែម-ឡាង	១៥ដុ
ឧបាសិកា ទួន-សារិន និង គ្រួសារ	១៥ដុ
ឧបាសិកា ឡេា-ស៊ីរុន	១៥ដុ
នាង លក្ខិណា	១៤ដុ
លោក សួង-សុភាព អ្នកស្រី សួង-មាលី	១៤ដុ
ឧបាសិកា ទេស-សុន និង កូនចៅ	១៤ដុ
លោក សុខ-ហេង ឧបាសិកា សឿង-អេង	១៤ដុ
លោក ថាច់-ឈួង អ្នកស្រី យ៉ែម-ចន្ធូ និង បុត្រធីតា	១៤ដុ
អ្នកស្រី មឿន-រស្មី និង បុត្រធីតា	១៣ដុ
យ៉ាំង-ដាំ	១២ដុ
ឧបាសិកា ប្រាក់-ឃិន	១២ដុ
លោក កែវ-កែន ពែក-សុភា	១១ដុ
លោក ពែក-សំណាង ស្រី អែម	១១ដុ
ភឹង-សារិត	១២ដុ
ឧបាសិកា ចាប-ឃិន	១១ដុ
ឧបាសិកា ម៉ៃ-សារ៉េត	១១ដុ
ឧបាសិកា ផាន់-សួង	១១ដុ
កញ្ញា ហុង-ភានី	១១ដុ
លោក សេង-សុត អ្នកស្រី ហ៊ុយ-ពៅ	១១ដុ

លោក សេង-ស៊ិន និង កូន សេង-សាលីណា	១១ដុ
លោក សេង-ស៊ីម អ្នកស្រី ញ៉ែម-គឿន	១១ដុ
កញ្ញា សេង-រតនា	១១ដុ
អ្នកស្រី ឡាច-សុផល	១១ដុ
ឧបាសិកា ង៉ែត-ហួយ	១១ដុ
អ្នកស្រី ស៊ីសុវត្ថិ ច័ន្ទ វល្លក្ខិណា	១១ដុ
លោក សេក-អាង	១១ដុ
លោក ហ៊ុយ-សុខា អ្នកស្រី ចន្ធី និង បុត្រធីតា	១១ដុ
នាង ឡាច-សុផាន	១១ដុ
លោក ពែក-សម្ភស្ស	១១ដុ
លោក ពែក-សំអៀត កុត-វ៉ៃ	១១ដុ
ប៉េ-សារឿន	១០ដុ
នាង បាឡៃ	១០ដុ
នាង សុន្ធូន	១០ដុ
អ្នកស្រី ញឹប	១០ដុ
អ្នកស្រី យ៉ង់-ម៉ៅ	១០ដុ
លោក ភូ-តេង អ្នកស្រី ធី	១០ដុ
លោកស្រី ម៉ា-សុទ្ធ	១០ដុ
អ្នកស្រី អ៊ាង-ដាវ	១០ដុ
សាន-ស៊ីយន	១០ដុ
ផល្លី-ឃុត	១០ដុ
អ្នកស្រី សៅ-សារៀប លោក តាន់-សុខា	១០ដុ
អ្នកស្រី ឡៅ-គីមហ៊ាង លោក សៅ-សារួន	១០ដុ
ប៉េ-សុខុម	១០ដុ
គីមសាន-ជា	១០ដុ
ផូ-ភីរើក	១០ដុ
ឧបាសិកា ស៊ើង-ធីហ៊ាន	១០ដុ
ឧបាសិកិា ជុំ-ថន	១០ដុ
លោក ស៊ិន-គៀម	១០ដុ
លោក ម៉ែន-ម៉េត និង គ្រួសារ	១០ដុ
ឧបាសក អ៊ិន-សន	១០ដុ
លោក ញិល-មឿន ព្រមទាំងគ្រួសារ	១០ដុ
អ្នកស្រី **CHAN DOUNG CHAN**	១០ដុ
ឧបាសិកា សែ	១០ដុ

ច័ន្ទតានីកែវ	១០ដុ
ហួត និង គ្រួសារ	១០ដុ
លោកអាចារ្យ ពេជ្រ-វិសុទ្ធិឌិម ឧបាសិកា សូត-សាថន	១០ដុ
អ្នកស្រី ស៊ីយ៉ាន-ណោត	១០ដុ
Khmning Annie (Pann) Family	១០ដុ
កុំ ព្រមទាំងគ្រួសារ, វុណា-ព្រមទាំងគ្រួសារ	១០ដុ
អ្នកស្រី ស-សុខា	១០ដុ
អ្នកស្រី ញ៉ឹក-លី	១០ដុ
កញ្ញា មៀច-មករា	១០ដុ
លោក កែវ-កុសល	១០ដុ
KAO CHANDANY	១០ដុ
អ្នកស្រី ជាម-ហ្វីង	១០ដុ
លោក អ៊ុក-ស៊ុម អ្នកស្រី អ៊ុក-ផេងឡេង	១០ដុ
លោក អ៊ិញ-សិញ អ្នកស្រី ជុយ-ណៃអ៊ិញ	១០ដុ
អរាភា	១០ដុ
លោក មូត្រ-វិចិត្រ អ្នកស្រីកែ-សឿន	១០ដុ
ឆាន់-ជន	១០ដុ
លីម-សុខជូ	១០ដុ
អ្នកស្រី តែ-ស៊ីវលាង	១០ដុ
អ្នកស្រី អ៊ុំ-យ៉ឹក អែម-មី-យាំ	១០ដុ
លោកជួង-ប៉ាន នាង ញ៉ិល-មាលិះ និង ញ៉ិល-ឥន្ទ្រីយ៍	១០ដុ
នាង **KIM ROS**	១០ដុ
CHAYA DARY និង កូនទាំង ២	១០ដុ
ឧបាសិកា ឡុង-អ៊ី	១០ដុ
ឧបាសិកា ទូច-យ៉ុន	១០ដុ
ឧបាសិកា ប៊ន-រ៉ា	១០ដុ
ឧបាសិកា ព្រះ-ឈាង	១០ដុ
នាង លី-ឆៃ	១០ដុ
អ្នកស្រី ផាន់-សារីម	១០ដុ
ឧបាសក ថាច់-សុផាត អ្នកស្រី យង-វន្នី	១០ដុ
លោកយាយ តាន់-ប៉ាវ	១០ដុ
ដារី-រិត	១០ដុ
ឧបាសិកា ប្រីយ-យ៉ុម	១០ដុ
ឧបាសិកា អ៊ួ-នង	១០ដុ

លោក ធឿម អ្នកស្រី ណែប	១០ដុ
ឧបាសិកា ង៉ូវ-មួយឡាយ	១០ដុ
ឧបាសិកា ហេង-ស៊ីវទៀង និង បុត្រធីតា	១០ដុ
ឧបាសិកា លី-សារី	១០ដុ
ឧបាសិកា ពៅ-ឃីន ឧបាសក អ៊ឹម-ឃន	១០ដុ
នាង បាយ-អូន និង ក្រុមគ្រួសារ	១០ដុ
ភិក្ខុ ព្រំ-សៀន	១០ដុ
អ្នកស្រី ហេង-ឈាប	១០ដុ
លោក សារ៉ាត-រិត និង គ្រួសារ	១០ដុ
ឧបាសិកា ចឹក-ងឿន	១០ដុ
SOPOHY ROEUNG ឥណា-តេ **SON**	១០ដុ
សន-សួន	១០ដុ
អ្នកស្រី ផៃ-លី	១០ដុ
ឧបាសិកា ឡុង-អ៊ុម	១០ដុ
ឧបាសិកា ជឹម-អុល	១០ដុ
ឧបាសិកា សេង-គីមហ៊ន និង បុត្រ	១០ដុ
ឧបាសិកា វ័ត្ត	១០ដុ
អ៊ុំ ឡាច	១០ដុ
ឧបាសិកា ជា-ស៊ុនស៊ីម	១០ដុ
គីម-ហៀង	១០ដុ
គុយ-វ៉ាន់ណា	១០ដុ
កែវ-សឿន	១០ដុ
MUY VOUN	១០ដុ
ឧបាសក អ៊ុន-សារុម	១០ដុ
ចៅ-ឡៅហ្វុង ជុង-សុងម៉េង ចៅ-យោវលួង	១០ដុ
ឧបាសិកា ណម	១០ដុ
អ្នកស្រី ទូច-គីមអេង ព្រមទាំងបុត្រ	១០ដុ
KIM BERLY HUN SOK DIM IM	១០ដុ
ហួត-លឿត នាក-រីម	១០ដុ
ហ៊ីង-ហ៊ន ហៅ កុក-សារ៉ាន់ ខឹម-សាន់	១០ដុ
ឧបាសិកា មៀង-ម៉ៅ ឃឹម វណ្ណា	១០ដុ
ឧបាសក លី-គីវ ឧបាសិកា តោ-អេង	១០ដុ
វ៉ាន់-អ៊ុម	១០ដុ
ឧបាសិកា យី-ជ្រិន	១០ដុ

អឿន-តុង ណារី	១០ដុ
ផាន់-សាវ៉ាត	១០ដុ
លោក មាស-សាំង	១០ដុ
ឧបាសិកា ចាន់-ឡុង និង កូនចាន់-លី	១០ដុ
អ្នកស្រី ខុង-បភាវត្តី ស្វាមី និង បុត្រ	១០ដុ
អ្នកស្រី ព្រឹន-វ៉ាន់	១០ដុ
អ្នកស្រី នួន-សុភី	១០ដុ
អ្នកស្រី សួន-សុខុម	១០ដុ
ទាយក ថន	១០ដុ
ញោម សៀង-លិម	១០ដុ
លោកសិរី-សំបាន និង គ្រួសារ	១០ដុ
ឧបាសិកា សុខ-យ៉ាន	១០ដុ
លោក យ៉ាវ-នាង នាងសុខា	១០ដុ
ឧបាសិកា អ៊ឹម-អឿន	១០ដុ
ញោម លីណា	១០ដុ
ឧបាសិកា ម៉ិល-ប៉ិច	១០ដុ
ឧបាសិកា តឹក-អុន	១០ដុ
ឧបាសិកា អែម-ទេត	១០ដុ
ឧបាសក សេក-ម៉ុន ឧបាសិកា កែវ-អ៊ន	១០ដុ
ឧបាសិកា អ៊ាប-ច័ន្ទលី	១០ដុ
ឧបាសិកា យិន-កែម	១០ដុ
ឧបាសិកា ម៉ឹង-លន់	១០ដុ
អ្នកស្រី អឿន-សារី	១០ដុ
មែឡូ-ថានោកា	១០ដុ
ឈិត-ដាវគុណទ្រី	១០ដុ
ឈិត-ដាវចិត្រា	១០ដុ
ឈិត-ដាវសៅ-វ៉ាន្នី	១០ដុ
លោក ទេស-សាមិត	១០ដុ
លោក ប៊ូ-យើន និង សុមាលី	១០ដុ
ឧបាសិកា អឿង	១០ដុ
ទាយិកា ចន្ធូ	១០ដុ
នុត-ស៊ីម	១០ដុ
អ៊ុ-ស៊ីន	១០ដុ
អ្នកស្រី ពុំ-សូភី លោក មួង-សំអាត	១០ដុ

ឧបាសិកា ម៉ុម-រី	១០ដុ
លោក ប៊ុន-លឿង និង ភរិយា	១០ដុ
លោក យឹម-សេង អ្នកស្រីសឿន	១០ដុ
អ្នកស្រី ប៊ុន-ហេង	១០ដុ
កញ្ញា យ៉ែម-ស្រីមុំ	១០ដុ
កញ្ញា យ៉ែម-ស្រីអូន	១០ដុ
លោក ប៊ឹក-ឈាង អ្នកស្រី ហែម-ឆេងប៉ៅ	១០ដុ
ឧបាសកា នួន-សេង ឧបាសិកា គង់-ណាវ៉ាន់	១០ដុ
ឧបាសិកា លី-សាយជូ	១០ដុ
ឧបាសិកា បេ-យ៉េន	១០ដុ
ដន្លួងឧបាសិកាឆាន់-កាន់ដួង	១០ដុ
ផេង-នាង	១០ដុ
ប៊ិត-សុខា	១០ដុ
ឧបាសក សារឿន ឧបាសិកា ប៉ុក-មិន	១០ដុ
លោក អ៊ុំ-សុផល អ្នកស្រី ឡុង-ភា	១០ដុ
លោក សានី អ្នកស្រី ភិរុន និងបុត្រធីតា	១០ដុ
ឧបាសិកា ង៉ែត-ខុន	១០ដុ
លោកអាចារ្យ សាម-គុណ ឧបាសិកា រ័ត្ន-រី	១០ដុ
ឧបាសិកា វិន លោកតា ជឿម កូនចៅ	១០ដុ
អ្នកស្រី វ៉ានី និង គ្រួសារ	១០ដុ
អ្នកស្រី វ៉ាស៊ី និង គ្រួសារ	១០ដុ
យុវជន មេ-ផាន់ណា	១០ដុ
ឧបាសក ឌី□សុផល និង គ្រួសារ	១០ដុ
ឧបាសិកា លី-សារី	១០ដុ
ភិក្ខុ ថោង-អ៊ាត	១០ដុ
ភិក្ខុ មុត-សុង	១០ដុ
ឧបាសក ឈុន-សាវ៉ាន និង គ្រួសារ	១០ដុ
អ្នកស្រី ស៊ីម	១០ដុ
ឧបាសិកា អ៊ឹម-ផុល	១០ដុ
ភិក្ខុ មុនិន្ទត្ថេរោ មហាញ៉ូ-ទេពមុនី	១០ដុ
អ្នកស្រី ឈឹម-សាង៉ាត់	១០ដុ
លោក សុវណ្ណ អ្នកស្រី លឿម	១០ដុ
អ្នកស្រី បាយ-អួន និង គ្រួសារ	១០ដុ
លោក នួន-នឿន និង ភរិយា	១០ដុ

ឧបាសិកា ឆេង-យាន	១០ដុ
ឧបាសិកា អ៊ាត-អេង	១០ដុ
មីន-មាលី	១០ដុ
អ៊ឹង-សង	១០ដុ
សាន-សុំផិត សុខ-ជា	១០ដុ
សាន-សុខឃន យស់-សុវណ្ណ	១០ដុ
ភិក្ខុ យ៉ែម-ណាក បស្សន្នោ	១០ដុ
TI CHHOR	១០ដុ
អ៊ាក-តាំង	១០ដុ
អ្នកស្រី សុខ-សំ	១០ដុ
អ្នកស្រី គួច-ឃីម	១០ដុ
ឧបាសិកា អ៊ុម-ថុល	១០ដុ
ឧបាសិកា ហ៊ុយ-ភន	១០ដុ
លោក សុវណ្ណ-ឈុន ឧបាសិកា ប៉ែន	១០ដុ
អ្នកស្រី សីម-គាវ	១០ដុ
ប៉ោ-ណៃ មីន-សារី	១០ដុ
ចាន់ថា និង វណ្ណារី	១០ដុ
ឧបាសិកា ផាន-ឡុង	៩ដុ
យ៉ាំង-សគុណ	៩ដុ
ហ៊ុយ-សវេត	៩ដុ
យ៉ាំង-ស៊ីវុត	៩ដុ
យ៉ាំង-សវេត	៩ដុ
ឧបាសិកា ឈឿម-វ៉ាន់	៧ដុ
អ្នកស្រី ហង់-គីមយ៉ាន	៧ដុ
ឧបាសិកា ឡាង	៧ដុ
ឧបាសិកា សំ-ឃិន	៧ដុ
ឧបាសិកា ឌួង-ច័ន្ទបុប្ផ និង បុត្រ	៧ដុ
លោក វ៉េម-អួន	៧ដុ
ឧបាសិកា ម៉ែន-ស៊ិម	៧ដុ
ឧបាសិកា ឡាង	៧ដុ
អ៊ូច-រឿន	៧ដុ
ឧបាសិកា ស៊ុន-ឡាយ	៧ដុ
អ្នកស្រី ជីច-ណាង និង អ៊ី-ខ្វាន់នី	៧ដុ
លោកតា អឿ-សឿន លោកយាយ គិម-ឈុន	៧ដុ

ឧបាសិកា វង-ហ៊្វឹង និង កូន ថូ-សាឡៅ	៧ដុ
លោក ថូ-ច័ន្ទតារា និង គ្រួសារ	៧ដុ
អ្នកស្រី ថូ-វ៉ាន់ឌី និង គ្រួសារ	៧ដុ
អ្នកស្រី ថូ-និកា និង គ្រួសារ	៧ដុ
លោក ប៉េង-លី និង សុរតន៍	៧ដុ
លោក ប៊ុល-អៀត អ្នកស្រី ស៊ីណា	៧ដុ
អ្នកស្រី កែវ-វ៉េត	៧ដុ
អ្នកស្រី ជិន-វីរ៉ា និង ស្វាមី	៧ដុ
លោក ជិន-បៀល្លី និង ស្រី នុត	៧ដុ
លោក សួន-ច័ន្ទី អ្នកស្រី គីម-លី	៧ដុ
អ្នកស្រី ឈាន-ធឿន	៧ដុ
អ្នកស្រី ដួង-ណារី	៧ដុ
សូង-សុភា	៧ដុ
ឧបាសិកា ជា-គួរ	៧ដុ
លោក ថូ-សុខវ៉ាន់ និង គ្រួសារ	៧ដុ
លោក ស៊ីម-សាម៉ុន អ្នកស្រី សំសុខន	៧ដុ
ណោន-សុខជា	៧ដុ
សូង-សុភ័ណ	៧ដុ
សូង-ផែមម៉ាឡា	៧ដុ
លោក លីម-តៅខេង អ្នកស្រី ហេង-ស៊ីហាន	៧ដុ
អូឡា-ថៃ ចំប៉ាស៊ី	៦ដុ
ឧបាសិកា ខាំ-ភូ	៦ដុ
ហ៊ុយ-ប្រេសសិណា	៦ដុ
ហ៊ុយ-ប្រេសតូន	៦ដុ
ឧបាសិកា សុត-ទេព	៦ដុ
ឧបាសិកា សេង-ណៃ	៦ដុ
ស្រួយ-សេង	៥ដុ
BOUY T. TECH & WANNA W. SAO	៥ដុ
ប្រាក់-ភាជ សុខ-ភឿន	៥ដុ
យុវជន លី-ធារី	៥ដុ
ឧបាសក អែម-រិន ភួន-លឿម	៥ដុ
យែម-សាវ៉ាន ឈាន-ហឺន	៥ដុ
លោក គី-តុងជាង និង គ្រួសារ	៥ដុ
ឧបាសិកា ផាន់-សារឹម និង បុត្រ	៥ដុ

អ្នកស្រី តឹក-ម៉ាលី និង គ្រួសារ	៥ដុ
លោកអាចារ្យ ឈឹន-ប៊ុនលើត	៥ដុ
ឧបាសិកា ញ៉ឹក-លេង	៥ដុ
សិប-យេន	៥ដុ
យឹម-យ៉ាន់ណា ព្រមទាំងបុត្រ	៥ដុ
ឧបាសិកា សុខា-សរ	៥ដុ
ឆែ-ឆេងហាក់ និង គ្រួសារ	៥ដុ
អ្នកស្រី យម និង លោក សារឿន	៥ដុ
លោក ប៊ុនលឿ-អាំខា	៥ដុ
គុច-យូតាំ និបុត្រាបុត្រី	៥ដុ
ឧបាសិកា អូន និងកូនចៅ	៥ដុ
ឧបាសក លោ-សុខផន វ៉ែន-ឡាប	៥ដុ
ស្វាយ-សារី	៥ដុ
ច្រិច	៥ដុ
ឧបាសិកា ប៊ូ-ឡាយ	៥ដុ
ឧបាសិកា ប៊ុន-សុខឡាង	៥ដុ
ភិក្ខុ សុខ-សឿន	៥ដុ
ភែន-សុង	៥ដុ
លោក វ៉ាម៉ូ នាង លី-សុភាព ព្រមទាំងបុត្រ	៥ដុ
ឧបាសិកា រស់-សុំ	៥ដុ
លោកយាយ ល នាង-ប៉ុក	៥ដុ
ញ៉ែម-សារ៉េត	៥ដុ
SADA EUM	៥ដុ
HEANG VOUN	៥ដុ
ឧបាសិកា ប៉ែន-ប៉ុន និង លី-ឈួន	៥ដុ
សុធា-ជួង និង វេត	៥ដុ
ចេក-វ៉ាត	៥ដុ
ចក់-ជួន សត្យា	៥ដុ
ឧបាសិកា ស៊ិន-យ៉ាំ និង បុត្រ	៥ដុ
គាម-ឃឿន	៥ដុ
យិន-ឌី	៥ដុ
យង-កាំ	៥ដុ
ឧបាសក ឈូក-សាន	៥ដុ
សូភាព-មុតជា	៥ដុ

ឈិត-ដាវសុខានី	៥ដុ
លោក មាន-អានី	៥ដុ
ឧបាសិកា ឌី	៥ដុ
អ្នកស្រី ចាន់	៥ដុ
លោក ម៉ាល-ធាន អ្នកស្រី ចំរើន	៥ដុ
បូរេត និង ធារា-ស៊ឹម	៥ដុ
លោក យ៉ុង-ជៀង អ្នកស្រី ថោម-ធាង	៥ដុ
ឧបាសក ព្រិត-ឈុត	៥ដុ
ឧបាសិកា ថាយ	៥ដុ
Chea & Dee ព្រមទាំងកូនចៅ	៥ដុ
Srey Na Vuthy Try	៥ដុ
Savan Chim, Roy Sarou	៥ដុ
មឿត	៥ដុ
ឡាំ ព្រមទាំងកូនចៅ	៥ដុ
សិន-ឌី	៥ដុ
អចារ្យ ជូ-មី ឧបាសិកា បូលីន កូន	៥ដុ
លោក ភួង-នេនៅ និង ភរិយា	៥ដុ
ឧបាសិកា អ៊ុំម-ម៉ុន	៥ដុ
ឧបាសិកា ឃួន-ខាំ	៥ដុ
លោក ប្រម-គ្រួច និង ភរិយា	៥ដុ
លោក អាត់ អ្នកស្រី យិន-យិ	៥ដុ
លោក ម៉ែក-សាខន អ្នកស្រី លី-ឡុង	៥ដុ
លោកតា ជុំ-សុន	៥ដុ
ឧបាសិកា ទិត្យ-លេន	៥ដុ
លោក ទេស-ហ៊ាន	៥ដុ
ឧបាសិកា ឌី-ប៊ុនឆាន	៥ដុ
អ្នកស្រី សេង-ផល្លិ	៥ដុ
CHOUK PHEUN	៥ដុ
BUNHANG KON	៥ដុ
ឧបាសកា ឈាន	៥ដុ
ឧបាសិកា ឆេង-យាន	៥ដុ
ឧបាសិកា អ៊ុំ-ម៉ច	៥ដុ
ឧបាសិកា ទូច-សំបូរ	៥ដុ
SAMNANG TOUCH & SOKHEUN	៥ដុ

អ្នកស្រី ភិន-នី	៥ដុ
ឧបាសិកា ហេង-ហេង	៥ដុ
ឧបាសិកា អ៊ីម-ណម	៥ដុ
ឧបាសិកា ខុំ	៥ដុ
ហេង-ផាន	៥ដុ
ឧបាសិកា ជៀម-ថុន ហៅព្រះអង្គតូ-ញ៉ឹប	៥ដុ
ឧបាសិកា យឿម	៥ដុ
លោកលី លីសុដល់ នាងឃា-រ៉ូឡាយ, លី-ចាន់ថា	៥ដុ
លោក លី-ប៊ូន លី-សុផា ព្រមទាំងបុត្រ	៥ដុ
ឧបាសិកា សម-សំផាន់	៥ដុ
លី-សុភ័ណ នាង វ៉ាន់ឌី ព្រមទាំងបុត្រ	៥ដុ
លោក ហែម-ហុង អ្នកស្រីនុត-និននារី ព្រមទាំងកូនចៅ	៥ដុ
ប៉េ-សារូ	៥ដុ
លោកស្រី LISA NAJARIAN	៥ដុ
លោក កៅ-ច័ន្ទដារ៉ា	៥ដុ
អ្នកស្រី ALYSSA HAN HENG	៥ដុ
កែម-ហេង	៥ដុ
រុម-អ៊ុង	៥ដុ
លោក កែវ-ចាន់ អ្នកស្រី ឃឹម-អេង	៥ដុ
CHOY PHANIXAY	៥ដុ
ឧបាសិកា អាង-ណាយ	៥ដុ
ឧបាសិកា ជុំ-ហ៊ីង	៥ដុ
ឧបាសិកា នួន-ភិន	៥ដុ
ឧបាសិកា ជុក-សឿន	៥ដុ
អ្នកស្រី ឆាត់-ឆោម និង គ្រួសារ	៥ដុ
លោក ស៊ិន-នី និង គ្រួសារ	៥ដុ
លោក សូផាត សំអុន ម៉ែន និង គ្រួសារ	៥ដុ
ទេព-សារិទ្ធ	៥ដុ
សូរិន-ហាក់	៥ដុ
ឧបាសិកា កៅ-សេងវ៉ាន	៥ដុ
លោក សុឃុធា អ្នកស្រី ឈុន-ណាង	៥ដុ
អ្នកស្រី លា	៥ដុ
ឧបាសិកា កែវ-ហេ	៥ដុ

ឧបាសិកា ផាន់-សារីម	៥ដុ
អ្នកស្រី តឹក-ចាន់ធឿន និង គ្រួសារ	៥ដុ
លោក ថង-ឡាក់ អ្នកស្រី លុន	៥ដុ
ឧបាសក ស៊ាន ឧបាសិកា សុភី	៥ដុ
អ្នកស្រី ស៊ី-នឿត	៥ដុ
ឧបាសិកា ខៀវ-ណាត	៥ដុ
អ្នកស្រី ស៊ុំ-សាគឿន និង គ្រួសារ	៥ដុ
អ្នកស្រី ញ៉ង់-សុខន	៥ដុ
ឧបាសិកា សាធ-ភឹម	៥ដុ
លោក គ្រៀល-ឆោម អ្នកស្រី ឧស្សរា	៥ដុ
ឧបាសិកា គឹម-អេង	៥ដុ
ភោ-គឹមហួយ	៥ដុ
អ្នកស្រី ចន្ធី លោក ជុំ-សាឯម	៥ដុ
ឧបាសិកា ក្រិញ-ហុង	៥ដុ
លោក ម៉ី-សាមឿន អ្នកស្រី ឈុន-សារុន	៥ដុ
ឧបាសិកា ដោ-ស៊ីផាត	៥ដុ
ឧបាសិកា នុត-ប៊ិច	៥ដុ
ឧបាសិកា ហែម-ហេង	៥ដុ
លោក ទឹម-យ៉ុន និង គ្រួសារ	៥ដុ
ឧបាសក ហាវ ឧបាសិកា សាយ	៥ដុ
ឧបាសិកា កង-ស៊ី	៥ដុ
ឧបាសិកា ថ្លាង-ខន	៥ដុ
ណោន-សាម៉េត	៨ដុ
ណោន-សាមុត	៨ដុ
ណោន-សុអេង	៨ដុ
ណោន-ផាន់ណាត	៨ដុ
លោក ញ៉ែម-សារឹម	៨ដុ
លោក ប៊ុន-ញាង	៨ដុ
សេម និង សុភ:	៨ដុ
រ៉ននី-រិ លីយ៉ា	៨ដុ
អ្នកស្រី សុខ-វណ្ណា	៨ដុ
អ្នកស្រី រី-លីនអ៊ុប	៨ដុ
អ្នកស្រី សុជាតិ និង គ្រួសារ	៨ដុ
ឧបាសិកា ណែម	៨ដុ

លោក ថង-ឈុត	៨ដុ
ឧបាសិកា នី-វ៉ាន់	៨ដុ
លោក ហូ អ្នកស្រី ប៊ុង	៨ដុ
ឧបាសិកា ខឹម-រុន	៨ដុ
ហ៊ុយ-គ្រីស្ទហ្វី	៨ដុ
ហ៊ុយ-គ្រីស្ទីណា	៨ដុ
ឧបាសិកា ហេង-ស៊ុន	៣ដុ
ហ៊ុន-សោភ័ណ	៣ដុ
ឧបាសិកា ឆោម	៣ដុ
ឧបាសិកា ពក	២ដុ
ឧបាសិកា ជុក-សៀវ	២ដុ
ពិន-ឈុនហ៊ាង	២ដុ
ឧបាសិកា ម៉ម-អឿន	២ដុ
ម៉ៅ-រតនា	២ដុ
សុវ៉ាត-ថាណាស និង ROBERT	២ដុ

កំហុសតែងមានជាធម្មតា

ខ្ញុំសូមខន្តីអភ័យទោសអំពីសំណាក់ព្រះតេជះព្រះ
គុណព្រះថេរានុថេរៈ និង ពុទ្ធបរិស័ទទាំងអស់
កាលបើមានការបាត់ឈ្មោះ ឬ ខុសឈ្មោះ
និង
កាលបើមានការខុសឆ្គងដោយប្រការផ្សេងៗ
ទៀតនោះ សូមព្រះតេជះព្រះគុណ និង
ពុទ្ធបរិស័ទទាំងអស់ អនុគ្រោះផងចុះ ។
សូមអរព្រះគុណ និង អរគុណទុកជាមុន !
សូមប្រគេនពរ និង ជូនពរ

សូមពុទ្ធបរិស័ទរង់ចាំសិក្សាសៀវភៅ
វិសុទ្ធិមគ្គប្រែ ភាគទី៣
ដែលនឹងបោះពុម្ពផ្សាយជាធម្មទាន
នៅពេលខាងមុខនេះជាបន្តទៀត ។

សូមពុទ្ធបរិស័ទជួយឧបត្ថម្ភ ក្នុងកិច្ចការធម្មទាននេះ
តាមកម្លាំងសទ្ធាជ្រះថ្លារៀងៗ ខ្លួន

សូមទាក់ទង : **ភិក្ខុវិនយធរោ មហាយិន-នឿន**
វត្តខ្មែរសាន់តាអាណា
2630 N. Grand Ave. Santa Ana, CA 92705
(714) 744-2844
U.S.A

ទាក់ទង: **ភិក្ខុ យ៉ាន-សារុន**
វត្តនួនមុនីរាម (ហៅវត្តថាន់) ភ្នំពេញ
០១២-៨៧-៣០-០៩
និង
ទាក់ទង: **ភិក្ខុប្រាក់-ផល្លី**
វត្តបទុមវតី ភ្នំពេញ
០៩២-៩៤-៦៧-៨៧